# អដ្ឋកថា បដិសម្ភិទាមគ្គ

## ឈ្មោះ សទ្ធម្មប្បជោតិកា

## នៃព្រះសុត្តន្តបិដក ខុទ្ទកនិកាយ

## បឋមភាគ

# ៦៩

“ ភាគ ២”

ពុទ្ធសករាជ ២៥៥១

# ពាក្យផ្ដើម

ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖

**សុត្ត** បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។

**គេយ្យ** បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។

**វេយ្យាករណ** គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។

**គាថា** គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។

**ឧទាន** គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។

**ឥតិវុត្តក** គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។

**ជាតក** គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មាន



អបណ្ណជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។

**អព្ភូតធម៌** គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។

**វេទល្ល** គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស់ ព្រមទាំងរីករាយ ព្រមទាំងសួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្ដែងថា ៖

> ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
> ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
> មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
> បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្ដីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្ដែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគមាន ៣

ប្រការ គឺ ៖

១ **ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង** ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ **ទ្រង់សម្ដែងធម៌មានហេតុផល** ដែលអ្នកស្ដាប់អាចពិចារណាឃើញតាមសេចក្ដីពិតបាន ។

៣ **ទ្រង់សម្ដែងធម៌ដ៏អស្ចារ្យ** គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍ សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្ដែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះដោយព្រះញាណ ទ្រង់ជ្រាបថាការបានស្ដាប់នូវពុទ្ធោវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្ដែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌វិន័យទុកជាសាស្ដាជំនួសព្រះអង្គ ។ តែការមិនមានសតិ បញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្ដីនៃព្រះធម៌វិន័យតាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិ ផ្សេង ៗ គ្នា រហូតមាននិកាយ ដល់ទៅ ១៨ ។



ព្រះអដ្ឋកថាចារ្យជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធវចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដកនូវសេចក្ដីដែលលំបាកយល់ ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្ដីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមកមាន ៖

១ **ព្រះសូត្រ** គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយបិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ **សុត្តានុលោម** គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយសេចក្ដីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និង បុព្វាចារ្យជំនាន់ក្រោយ ៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្ដែងធម៌ក្នុងព្រះពុទ្ធសាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយច្រើនទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមាន

គោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថា មិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានធនុះក្នុងភាសាបាលីតិច តួចសំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរសដែលមានការចេះដឹងក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដក ប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ
របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្តីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

**ក្រុមរៀបរៀងព្រះអដ្ឋកថា**



## និទានកថា

សេចក្តីសង្ខេបថា ក្នុងទីបំផុតនៃការសម្តែងយមកប្បាដិហារ្យ ព្រះមានព្រះភាគជាម្ចាស់ស្តេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិច្ឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្មកថាដល់ទេវបរិស័ទ លុះទ្រង់សម្តែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្តែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌-វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។
២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។
៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។
៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។
៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។
៦ ខ បដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុស-ត្រូវយ៉ាងណា ប្រព្រឹត្តតាម គួរ ។
៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ

គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បី

ខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ឈ្មោះថា កាកណ្ឌកៈបានស្តាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្ភាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គ ក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌-វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មីឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញ



មកពីនិកាយ គោកុលិកៈ ។ អាចរិយវាទដទៃទៀតឈ្មោះថា ចេតិយវាទកើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជាប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិសាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្តាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តចរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និងធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូលអាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និកាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទយ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយវាទ ១១ និកាយនេះរួមនឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី ជាឈ្មោះរបស់និកាយដែលពោលមកហើយទាំងនោះឯង ។ ម្យ៉ាងទៀត បណ្តានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។



## តារាងសម្តែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈដែលជាធម្មវាទីទាំងឡាយបានបណ្តេញចេញហើយ បានពួកដទៃទៀត ទើបផ្តើមតាំងជាគណាចារ្យថ្មី ។

( ស្រង់ចេញពីព្រះអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បានប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនី ថា ព្រះភិក្ខុមាននាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរអដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យនោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះពុទ្ធឃោសៈតែងព្រះគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការកសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធាឃោសាចារ្យ ជាអ្នកស្រុកជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ពុទ្ធគយាដែនមគធៈ ជិតស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធ-សាសនា បានសិក្សាសិល្បសាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅកាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បានឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នមានសតិបញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហាព្រាហ្មណ៍កំលោះនេះបាន ។



តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែលសមណព្រាហ្មណ៍ និងបណ្ឌិត សួរបាន ដូច្នោះ ព្រាហ្មណ៍ កំលោះទើបមានឈ្មោះបោះសំឡេងខ្ទរខ្ទារគ្របសង្កត់រហូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធគយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិសម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះបានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេងៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិ-ធម្មខ្វះ ៗ ព្រាហ្មណ៍កំលោះ ឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថាពុទ្ធមន្ត ទើបសុំរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ ញាណោទ័យទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា

ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈបានឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃ-បិដកនៅឡើយ តែក្នុងលង្កាទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយមានព្រះសារីបុត្ត ( ឈ្មោះដូចអគ្គសាវក ) ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡ: សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីបត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តី ចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះហើយ ព្រះពុទ្ធឃោសៈក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធ: ហើយធ្វើដំណើរតទៅរហូតដល់កំពង់ផែក្រុងលង្កាសម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា មហានាម មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្វះ ( សិរិកុឋ: ) ខ្វះ ( សិរិកូដ្ឋ: ) ខ្វះពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃ



ក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃ-បាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈនៃសម្នាក់មហាបធានបានស្តាប់អដ្ឋកថាជាភាសាសីហឡ: និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថា ជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃ ដើម្បីបានឱកាសរចនាអដ្ឋកថាព្រះត្រៃបិដកជាភាសាមគធ: ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កាដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនាសិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបានរចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្តីយ៉ាងល្អប្រសើរ រហូតដល់ព្រះសង្ឃលង្កាទទួលស្តាប់នូវសេចក្តីជំនាញរបស់លោកតាមប្រវត្តិបាននិយាយថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធ-ឃោសៈនោះឲ្យប្រាកដ ទេវតាបានបណ្តាលឲ្យគម្ពីរដែលរចនាស្រេចហើយបាត់ទៅ ព្រះពុទ្ធឃោសៈក៏បានរចនាជាថ្មីម្តងទៀត ទេវតាក៏បណ្តាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្តងទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះទើបបានគម្ពីរវិសុទ្ធិមគ្គជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរប្រៀបធៀបគ្នាហើយ មិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬ

ដោយអត្ថ ឬដោយបទដើម បទចុងឬ ដោយថេរវាទ ឬដោយព្រះបាលីទាំងឡាយក្នុងកន្លែងណាទីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បីសម្តែងសេចក្តីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្តីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គនេះជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡ:មកជាភាសាមគធ: ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្តាប់កិត្តិគុណរបស់លោក ស្តេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ ហើយនមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយឈ្មោះ **បធានឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡ: ជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធ: ។

អដ្ឋកថាក្នុងភាសាសីហឡ:ពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរីយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនាព្រះមហិន្ទត្ថេរ:នាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡ: ឈ្មោះ **មហាអដ្ឋកថា** ។



អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡ:ហៅថា បច្ចរីយ: ឈ្មោះថា **បច្ចរីយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុ-វិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទ:ដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរ:ជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡ: ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋកថាព្រះត្រៃបិដកជាភាសាមគធ: មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តបាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋ: និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា

១៤ ញាណោទ័យ តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែងចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្តីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់-ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។

---



# ប្រវត្តិព្រះធម្មសេនាបតី

ព្រះសារីបុត្តត្ថេរ មុននឹងចូលមកបួសក្នុងព្រះពុទ្ធសាសនា មានឈ្មោះថា ឧបតិស្សៈ ជាបុត្តរបស់ព្រាហ្មណ៍ឈ្មោះ វង្គន្តៈ ដែលជាមេ-ស្រុកក្នុងស្រុកមួយឈ្មោះ ឧបតិស្សគ្រាម ជួនកាលហៅថា “ នាលកៈ ” ឬ “ នាលន្ទា ” តាំងនៅមិនឆ្ងាយពីក្រុងរាជគ្រឹះ , មានមាតាឈ្មោះ សារី ហើយត្រកូលរបស់លោក មានទ្រព្យប្រមាណ ៥៦០ កោដិកហាបណៈ , ព្រះសារីបុត្ត ដែលមានឈ្មោះថា សារីបុត្ត ព្រោះហៅតាមឈ្មោះរបស់មាតា ឬន័យម្យ៉ាងទៀត ពាក្យថា សារីបុត្ត ប្រែថា បុត្ររបស់អ្នកលេងបាស្កា តែកាលលោកឧបសម្បទាហើយ មិត្តសព្រហ្មចារីនិយមហៅលោកថា “ សារីបុត្ត ” ឯឈ្មោះដើម ឧបតិស្សៈ ក៏បាត់ទៅ ។

ព្រះសារីបុត្តមានប្អូនប្រុស ៣ នាក់ គឺ ១. ចុន្ទៈ ២. ឧបសេន ៣ . រេវតៈ និងមានប្អូនស្រី ៣ នាក់ គឺ ១ . ចាលា ២ . ឧបចាលា ៣ . សីសុបចាលា រួមទាំងខ្លួនលោកជា ៧ នាក់ និងសុទ្ធតែជាព្រះអរហន្តបានបរិនិព្វានហើយ ក្នុងសម័យព្រះពុទ្ធបរមគ្រូនៃយើងនេះ ។

កាលលោកនៅជាបរិព្វាជក ជាអ្នកបួសក្រៅព្រះពុទ្ធសាសនា ដើរស្វែងរកមោក្ខធម៌ជាមួយសម្លាញ់ កោលិតៈ “ ព្រះមហាមោគ្គល្លាន ” ក៏

បានជួបនឹងព្រះអស្សជិត្ថេរ និមន្តបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ កាលបានចង្ហាន់ហើយ ក៏ត្រឡប់ដើម្បីរកកន្លែងឆាន់ លុះជ្រាបថា លោកប្រាថ្នានឹងគង់ឆាន់ ក៏ក្រាលអាសនៈរបស់ខ្លួនប្រគេន ក្រោយវេលាដែលព្រះថេរៈឆាន់ហើយ ក៏ប្រគេនទឹកកំសៀវរបស់ខ្លួនទៀត កាលធ្វើអាចរិយវត្តដូច្នេះហើយ ទើបប្រាស្រ័យដោយពាក្យពេចន៍យ៉ាងពីរោះនឹងព្រះអស្សជិត្ថេរ បានសួរថា លោកម្ចាស់ ឥន្ទ្រីយ៍របស់លោកផូរផង់ក្រៃលែង ពណ៌សម្បុរក៏បរិសុទ្ធ លោកតាំងចិត្តបួសចំពោះអ្នកណា អ្នកណាជាសាស្តារបស់លោក លោកពេញចិត្តក្នុងធម៌របស់អ្នកណា ? ព្រះអស្សជិត្ថេរឆ្លើយថា មានព្រះសមណៈជាបុត្រសក្យរាជ ចេញបួសពីសក្យៈត្រកូល យើងតាំងចិត្តបួសចំពោះព្រះមានព្រះភាគនោះ ព្រះមានព្រះភាគអង្គនោះ ជាសាស្តារបស់យើង យើងពេញចិត្តក្នុងធម៌របស់ព្រះមានព្រះភាគអង្គនោះ ។

ឧបតិស្សបរិព្វាជក សួរដោយមានការចាប់អារម្មណ៍យ៉ាងខ្លាំងថា សាស្តារបស់លោកប្រៀនប្រដៅយ៉ាងណា ? , អស្សជិត្ថេរ ពិចារណាថា ជាប្រក្រតី ពួកបរិព្វាជករមែងជាបដិបក្ខចំពោះព្រះពុទ្ធសាសនា យើងនឹងសម្តែងជម្រៅព្រះពុទ្ធសាសនាដល់បរិព្វាជកនេះ គិតដូច្នេះហើយ ក៏បានប្រកាសខ្លួនថា យើងជាអ្នកបួសថ្មី ទើបនឹងមកកាន់ធម្មវិន័យនេះ យើងមិនអាចសម្តែងធម៌ឲ្យពិស្តារបានទេ តែយើងនឹងសម្តែងបានចំពោះតែខ្លឹមសារ



ប៉ុណ្ណោះ ។ ឧបតិស្សៈគិតថា យើងឈ្មោះថា ឧបតិស្សៈ ជាអ្នកអាចដឹងច្បាស់នូវធម៌តិច ឬច្រើនបានដោយន័យទាំងរយ ទាំងពាន់ គិតដូច្នេះហើយទើបពោលថា លោកម្ចាស់សម្តែងច្រើន ឬតិចក៏ដោយចុះ សូមសម្តែងតែវត្ថុដែលមានប្រយោជន៍ប៉ុណ្ណោះ ខ្ញុំត្រូវការខ្លឹមសារជាសំខាន់ ការសម្តែងព្យញ្ជនៈច្រើន ឬពាក្យនិយាយច្រើន មានប្រយោជន៍អ្វីទៅ ។

កាលឧបតិស្សបរិព្វាជកពោលយ៉ាងនេះ ព្រះអស្សជិត្ថេរទើបបានពោលគាថាថា ៖

**យេ ធម្មា ហេតុប្បភវា តេសំ ហេតុំ តថាគតោ**
**តេសញ្ច យោ និរោធោ ច ឯវំ វាទីមហាសមណោតិ**

ធម៌ទាំងឡាយកើតអំពីហេតុ ព្រះតថាគតទ្រង់សម្តែងនូវហេតុនៃធម៌នោះ និងការរលត់នៃធម៌នោះ ព្រះមហាសមណៈទ្រង់ទូន្មានយ៉ាងនេះ ។

ឧបតិស្សៈបានស្តាប់ធម្មកថានេះ ត្រឹមតែ ២ បាទដំបូង ក៏តាំងនៅក្នុងសោតាបត្តិមគ្គប្រកបដោយពាន់ន័យ លុះបានស្តាប់ពីរបាទចុងក្រោយ ក៏បានតាំងនៅក្នុងសោតាបត្តិផល ។ល។

ក្នុងតំណែងជាអគ្គសាវកទី ១ និងជាកំពូលលើសភិក្ខុទាំងឡាយផ្នែកខាងបញ្ញា ព្រះសារីបុត្តបានតាំងសេចក្តីប្រាថ្នាអស់កាលដ៏យូរប្រមាណ ១ អសង្ខេយ្យនិង ១ សែនកប្ប ក្នុងសម័យព្រះអនោមទស្សីសម្មាសម្ពុទ្ធ

ជាម្ចាស់ បានប្រារព្ធនូវបុណ្យធំមួយកាលដែលលោកនៅជាតាបស ឈ្មោះថា សរទតាបស ដោយឈរបាំងស្វេតច័ត្រផ្កាឈើធំថ្វាយចំពោះ ព្រះអនោមទស្សីសម្មាសម្ពុទ្ធ ក្នុងពេលព្រះអង្គចូលនិរោធសមាបត្តិរហូត ៧ ថ្ងៃ មិនបរិភោគអាហារអ្វីឡើយ ។

ព្រះសារីបុត្តត្ថេរ ជាអ្នកមានបដិភាណ គឺ បញ្ញា ដោះស្រាយរាល់បញ្ហាចំពោះមុខបានយ៉ាងល្អ និងឆាប់រហ័ស ដែលមានចារឹកទុកក្នុងបាលីគម្ពីរសំយុត្តនិកាយ ខន្ធវគ្គ ក្នុងរឿងសូចិបរិព្វាជិកាសួរអំពីការបរិភោគ ឱនងើយ ងាកឆ្វេង.ស្តាំមើលទៅទិសតូច ទិសធំ ។ល។

ចំណែករឿងទាក់ទងនឹងកតញ្ញូកតវេទី គឺ អ្នកដឹងឧបការគុណដល់អ្នកដទៃធ្វើហើយ មានចារឹកទុកថា ព្រះសារីបុត្តប្រាកដកិត្តិគុណថា ជាអ្នកមានកតញ្ញូកតវេទី រកអ្នកស្មើគ្មាន ដូចមានដំណាលទុកក្នុងអដ្ឋកថាគម្ពីរធម្មបទ នៃព្រាហ្មណវគ្គ បញ្ជាក់ថា ចាប់តាំងពីលោកបានស្តាប់ធម៌អំពីព្រះអស្សជិត្ថេរ បាននូវធម្មចក្ខុ និងបានបួសជាភិក្ខុហើយ លុះបានជ្រាបដំណឹងថា ព្រះអស្សជិត្ថេរជាអាចារ្យនៅក្នុងទិសណា មុននឹងសឹង លោកថ្វាយបង្គំទៅទិសនោះ ហើយសឹងងាកសិរសាទៅទិសនោះ ។ល។

ការរំលត់ខន្ធបរិនិព្វានរបស់ព្រះសារីបុត្ត ការចាត់ចែងពិធីបុណ្យមានទេវតា និងមនុស្សទាំងឡាយរៀបចំឡើងដ៏ធំ មានរឿងដំណាលក្នុង



អដ្ឋកថាសារត្ថប្បកាសិនី ដែលជាគម្ពីរអធិប្បាយបាលីគម្ពីរសំយុត្តនិកាយ មហាវារវគ្គ បញ្ជាក់ថា លុះព្រះសារីបុត្តពោលសុំខមាទោសចំពោះសង្ឃ និងសង្ឃសូមខមាទោសចំពោះលោកហើយ លោកក៏យកចីវរផ្ទាំងធំមកដណ្តប់និងគ្របមុខ ហើយសឹងផ្អៀងទៅខាងស្តាំ និងចូលអនុបុព្វសមាបត្តិ ការចូលសមាបត្តិក្នុងធម៌ជាគ្រឿងនៅដោយលំដាប់ ៤ យ៉ាង គឺ រូបឈាន ៤ អរូបឈាន ៤ និងសញ្ញាវេទយិតនិរោធ ដូចព្រះមានព្រះភាគ ដោយលោកចូលជាអនុលោម និងបដិលោម ហើយក៏បរិនិព្វាន ដោយអនុបាទិសេសនិព្វាន ។

ពន្លឺនៃអារុណោទ័យប្រាកដឡើងនៅលើផ្ទៃមេឃ នាថ្ងៃ ១៥ កើត ខែ កត្តិក , ព្រះសារីបុត្តដែលជាធម្មសេនាបតី ក៏បានរំលត់ខន្ធបរិនិព្វាន ដំណាលគ្នា ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ តថាគតបានប្រាប់អ្នកទាំងឡាយជាមុនហើយមិនមែនឬ ថាការព្រាត់ប្រាសចាកសត្វ និងសង្ខារជាទីស្រឡាញ់ ជាទីពេញចិត្តទាំងអស់ រមែងមានជាធម្មតា តើអ្នកណានឹងបានជាទីពឹងក្នុងរបស់ដែលជាទីស្រឡាញ់ពេញចិត្ត ព្រោះវត្ថុណាកើតឡើងហើយ មានបច្ច័យតាក់តែងហើយ មានការបែកធ្លាយជាធម្មតា ការប្រាថ្នាថា សូមវត្ថុទាំងនោះកុំបែកធ្លាយទៅឡើយ មិនជាឋានៈដែលអាចប្រព្រឹត្តទៅបានឡើយ យ៉ាងណាមិញ សារីបុត្តដែលដូចជាដើមឈើធំ ជា

ទីពឹងពំនាក់របស់ភិក្ខុសង្ឃជាច្រើន ក៏ត្រូវបរិនិព្វាន ។ ព្រោះដូច្នោះឯង អានន្ទ អ្នកទាំងឡាយចូរមានខ្លួនជាកោះ មានខ្លួនជាទីពឹង មិនគប្បីមានវត្ថុដទៃជាទីពឹងឡើយ គឺ ចូរមានធម៌ជាកោះ មានធម៌ជាទីពឹង មិនគប្បីមានវត្ថុដទៃជាទីពឹងឡើយ ម្នាលអានន្ទ យ៉ាងណាហៅថា ភិក្ខុមានខ្លួនជាកោះ មានខ្លួនជាទីពឹង ? យ៉ាងនេះគឺ ភិក្ខុក្នុងធម្មវិន័យនេះ រមែងជាអ្នកឃើញកាយក្នុងកាយ ឃើញវេទនាក្នុងវេទនា ឃើញចិត្តក្នុងចិត្ត ឃើញធម៌ក្នុងធម៌ទាំងឡាយ ជាអ្នកប្រារព្ធសេចក្តីព្យាយាម មានសតិ មានសម្បជញ្ញៈ កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញបាន ម្នាលអានន្ទ នេះឯងហៅថា ភិក្ខុមានខ្លួនជាកោះ មានខ្លួនជាទីពឹង មិនមែនមានវត្ថុដទៃជា កោះ មិនមែនមានវត្ថុដទៃជាទីពឹងឡើយ ។ល។

ម្នាលភិក្ខុទាំងឡាយ សារីបុត្តនោះ បានបំពេញបារមីអស់មួយ-អសង្ខេយ្យ និងមួយសែនកប្ប បានប្រកាសធម្មចក្រឲ្យប្រព្រឹត្តទៅដូចជាតថាគត សារីបុត្តនោះ បានជាអ្នកប្រៀនប្រដៅសាសនាចាត់ជាទី ២ បន្ទាប់ពីតថាគត សារីបុត្តនោះ ក្នុងបណ្តាសាវកសន្និបាត វៀរតែតថាគតចេញហើយ គ្មាននរណាផ្ទឹមឡើយដោយបញ្ញាក្នុងម៉ឺនចក្រវាឡ សារីបុត្តជាអ្នកមានបញ្ញាច្រើន មានបញ្ញាក្រាស់ មានបញ្ញាទូលំទូលាយ មានបញ្ញារហ័ស មានបញ្ញាមុតស្រួច មានបញ្ញាជាគ្រឿងកម្ចាត់កិលេស ។



សារីបុត្តជាអ្នកមានសេចក្តីប្រាថ្នាតិច មានសេចក្តីសន្តោស ពេញចិត្តនឹងទីស្ងប់ស្ងាត់ មិនប្រឡូកប្រឡំដោយពួកគណៈ ប្រារព្ធសេចក្តីព្យា-យាម ជាអ្នកចូលចិត្តដាស់តឿនអ្នកដទៃ ជាអ្នកតិះដៀលអំពើអាក្រក់ ភិក្ខុរូបនោះជាអ្នកមានខន្តីធម៌ជានិច្ច ដូចជាផែនដី សារីបុត្តប្រព្រឹត្តខ្លួនដូចជាគោឧសភរាជបាក់ស្នែង ប្រព្រឹត្តខ្លួនមានចិត្តទាបដូចកូនរបស់មនុស្សអ្នកស្រុកចណ្ឌាល អ្នកទាំងឡាយចូរមើលអដ្ឋិធាតុទាំងឡាយរបស់ភិក្ខុដែលមានបញ្ញាច្រើន ។ល។ មានបញ្ញាជាគ្រឿងកម្ចាត់កិលេសបាន ។ ព្រះ-មានព្រះភាគ ទ្រង់ត្រាស់សរសើរគុណរបស់ព្រះសារីបុត្ត ដោយព្រះគាថា ៥០០ គាថា ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ទទួលអដ្ឋិធាតុរបស់ព្រះសារីបុត្តត្ថេរទុកហើយ ទើបប្រោសឲ្យសាងស្តូបបញ្ចុះអដ្ឋិធាតុរបស់លោកទុកក្នុងទីជិតទ្វារវត្តជេតពនមហាវិហារ ក្រុងសាវត្ថី ដើម្បីបានជា “ **អគ្គសាវកានុស្ស-រណដ្ឋាន** ” ជាការលើកឡើងនូវកិត្តិគុណរបស់ព្រះធម្មសេនាបតីសារីបុត្ត និងដើម្បីជាទីសក្ការបូជារបស់ពុទ្ធបរិស័ទតទៅក្នុងអនាគតកាល ។

# រាយនាមលោកអ្នកមានឧបការ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុផាត

| | |
|---|---|
| ឧបាសក ក្អាត ហ៊ន | ឧបាសក នាក់ ម៉ៅ |
| ឧបាសក ទុំ ទួន | ឧបាសក ហុក សឹងហួត |
| ឧបាសក ជឹម ជំនិត | ឧបាសក កើត ទិត្យ |
| ឧបាសក សន ម៉ារឌី | ឧបាសក ហាយ ចំរើន |
| ឧបាសក អ៊ឹម វ៉ៃយ៉ា | ឧបាសក សុក្រ ហ៊ត |
| ឧបាសក សំ ឆាយ | ឧបាសិកា ថាប់ ឈឿម |
| ឧបាសិកា ហាយ សារ៉ាត់ | ឧបាសិកា ប៊ុត សុម៉ាលី |
| ឧបាសិកា យស សម្បត្តិ | ឧបាសិកា ពូ ហ៊ាង |

**ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស**



# រាយនាមអ្នកប្រែសម្រួល

**ព្រះសង្ឃអាស្រមព្រះគន្ធកុដិ**

| | |
|---|---|
| ព្រះភិក្ខុអគ្គទិន្នោ នូវ បូរ៉ា | ចៅអាវាស |
| ព្រះភិក្ខុឌាហមុត្តោ ប៉ូច សុផល | ធម្មាចារ្យ |
| ព្រះភិក្ខុធម្មប្បញ្ញោ ឆុំ សារឿន | ធម្មាចារ្យ |
| ព្រះភិក្ខុចន្ទរក្ខិតោ ម៉ឺន សុច័ន្ទ | ធម្មាចារ្យ |
| ព្រះភិក្ខុវរធម្មោ ផុត តៅ | ធម្មាចារ្យ |
| ព្រះភិក្ខុសរញ្ញាណោ ស សត្ថា | ធម្មាចារ្យ |

ព្រះភិក្ខុកល្យាណធម្មោ យ៉ាត កល្យាណ ធម្មាចារ្យ

សាមណេរ អ៊ឹម សុជាន សាមណេរ ម៉ៅ អៀប

សាមណេរ រិន សុវ៉ាន

**ផ្នែកឧបាសក**

| | |
|---|---|
| ឧបាសក ក្អាត ហ៊ន | ឧបាសក ហាយ ចំរើន |
| ឧបាសក សន ម៉ារឌី | ឧបាសក អ៊ឹម វ៉ៃយ៉ា |
| ឧបាសក ទុំ ទួន | ឧបាសក ហុក សឹងហួត |

# មាតិកាធម៌


| ឈ្មោះធម៌ | ទំព័រ |
|---|---|
| អដ្ឋកថា សមាធិភាវនាមយញ្ញាណនិទ្ទេស | ១ |
| អធិប្បាយ អនុស្សតិ | ២ |
| ព្រហ្ម ១៦ ជាន់ | ១៤ |
| អដ្ឋកថា ធម្មដ្ឋិតិញ្ញាណនិទ្ទេស | ២៩ |
| អធិប្បាយ បដិច្ចសមុប្បាទ | ៣២ |
| អដ្ឋកថា សម្មសនញ្ញាណនិទ្ទេស | ៤៨ |
| អធិប្បាយ ខន្ធ ៥ មានក្នុងទីជិត-ឆ្ងាយ | ៥២ |
| អដ្ឋកថា ឧទយព្វយញ្ញាណនិទ្ទេស | ៧០ |
| សច្ចបួន រមែងប្រាកដ | ៧៧ |
| ន័យ ៤ យ៉ាង មានឯកត្តន័យជាដើម | ៨០ |
| សាមញ្ញលក្ខណៈ | ៨១ |
| វិបស្សនូបកិលេស | ៨២ |
| អដ្ឋកថា ភង្គានុបស្សនាញាណនិទ្ទេស | ៨៥ |
| អដ្ឋកថា អាទីនវញ្ញាណនិទ្ទេស | ៩៨ |
| អដ្ឋកថា សង្ខារុបេក្ខាញាណនិទ្ទេស | ១០៦ |
| អដ្ឋកថា គោត្រភូញាណនិទ្ទេស | ១៣៥ |
| អដ្ឋកថា មគ្គញ្ញាណនិទ្ទេស | ១៤២ |
| អដ្ឋកថា ផលញ្ញាណនិទ្ទេស | ១៥៧ |
| អដ្ឋកថា វិមុត្តិញ្ញាណនិទ្ទេស | ១៥៨ |




# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.០០០ ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ ៖-

**ឧទ្ទិសថ្វាយ និងគោរពជូន :**

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុផាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជារដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រៃភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះបានស្មើ ៗ គ្នា

សូមអនុមោទនា !.....

**ក្រុមរៀបរៀង និងប្រែសម្រួល**

| | |
|---|---|
| អដ្ឋកថា បច្ចវេក្ខណញាណនិទ្ទេស | ១៦១ |
| អដ្ឋកថា វត្ថុនានត្តញាណនិទ្ទេស | ១៦៩ |
| អដ្ឋកថា គោចរនានត្តញាណនិទ្ទេស | ១៧២ |
| អដ្ឋកថា ចរិយានានត្តញាណនិទ្ទេស | ១៧៥ |
| អដ្ឋកថា ភូមិនានត្តញាណនិទ្ទេស | ១៨៩ |
| អដ្ឋកថា ធម្មនានត្តញាណនិទ្ទេស | ២០៥ |
| អដ្ឋកថា ញាណបច្ចកនិទ្ទេស | ២១៥ |
| អដ្ឋកថា បដិសម្ភិទាញាណនិទ្ទេស | ២១៨ |
| អដ្ឋកថា ញាណត្តយានិទ្ទេស | ២២៣ |
| អដ្ឋកថា អនន្តរិកសមាធិញ្ញាណនិទ្ទេស | ២២៧ |
| អដ្ឋកថា អរណវិហារញ្ញាណនិទ្ទេស | ២៣៧ |
| អដ្ឋកថា និរោធសមាបត្តិញ្ញាណនិទ្ទេស | ២៤១ |
| អដ្ឋកថា បរិនិព្វានញ្ញាណនិទ្ទេស | ២៦៤ |
| អដ្ឋកថា សមសីសដ្ឋញ្ញាណនិទ្ទេស | ២៦៨ |
| អដ្ឋកថា សល្លេខដ្ឋញ្ញាណនិទ្ទេស | ២៧៣ |
| អដ្ឋកថា វិរិយារម្ភញ្ញាណនិទ្ទេស | ២៨១ |
| អដ្ឋកថា អត្ថសន្ទស្សនញ្ញាណនិទ្ទេស | ២៨៤ |
| អដ្ឋកថា ទស្សនវិសុទ្ធិញ្ញាណនិទ្ទេស | ២៨៦ |
| អដ្ឋកថា ខន្តិញ្ញាណបរិយោគាហណញ្ញាណ | ២៩៣ |
| អដ្ឋកថា បទេសវិហារញ្ញាណនិទ្ទេស | ២៩៥ |
| អដ្ឋកថា វិវដ្តញ្ញាណឆក្កៈនិទ្ទេស | ៣០៥ |
| អដ្ឋកថា ឥទ្ធិវិធិញ្ញាណនិទ្ទេស | ៣១៦ |
| អដ្ឋកថា សោតធាតុវិសុទ្ធិញ្ញាណនិទ្ទេស | ៣៤១ |





| | |
|---|---|
| អដ្ឋកថា ចេតោបរិយញ្ញាណនិទ្ទេស | ៣៤៧ |
| អដ្ឋកថា បុព្វេនិវាសានុស្សតិញ្ញាណនិទ្ទេស | ៣៥៣ |
| ពោលអំពី ការព្រេកបេស់បុគ្គល ៦ ពួក | ៣៧៦ |
| ពោលអំពី ពុទ្ធខេត្ត និងការវិនាសកប្ប | ៣៨៥ |
| អដ្ឋកថា ទិព្វចក្ខុញ្ញាណនិទ្ទេស | ៤០៩ |
| ពោលអំពី ការតិះដៀលព្រះអរិយៈ | ៤១៨ |
| ពោលអំពី ញាណ ៥ យ៉ាង | ៤២៦ |
| អដ្ឋកថា អាសវក្ខយញ្ញាណនិទ្ទេស | ៤២៨ |
| អដ្ឋកថា សច្ចញាណចតុក្កទ្វយនិទ្ទេស | ៤៣៥ |
| អដ្ឋកថា សុទ្ធិកបដិសម្ភិទាញាណនិទ្ទេស | ៤៤៣ |
| អដ្ឋកថា ឥន្ទ្រិយោបរិយត្តញ្ញាណនិទ្ទេស | ៤៤៦ |
| អដ្ឋកថា យមកប្បាដិហារិយញ្ញាណនិទ្ទេស | ៤៥៨ |
| អដ្ឋកថា អាសយានុសយញ្ញាណនិទ្ទេស | ៤៦៨ |
| អដ្ឋកថា មហាករុណាសមាបត្តិញ្ញាណនិទ្ទេស | ៤៩៣ |
| ពោលអំពី មានះ ៧ យ៉ាង | ៥៣៨ |
| ពោលអំពី អាឃាតវត្ថុ ១០ យ៉ាង | ៥៤៩ |
| អដ្ឋកថា សព្វញ្ញុតញ្ញាណនិទ្ទេស | ៥៦៤ |
| ប្រជុំកងធម៌ | ៥៨៣ |

# បដិសម្ភិទាមគ្គ
# នៃព្រះសុត្តន្តបិដក ខុទ្ទកនិកាយ
# បឋមភាគ ( ភាគ ២ )

សូមនមស្ការ

ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ អង្គនោះ

## *អដ្ឋកថា សមាធិភាវនាមយញ្ញាណនិទ្ទេស*

គប្បីជ្រាបវិនិច្ឆ័យ ក្នុងសមាធិភាវនាមយញ្ញាណនិទ្ទេស ដូចតទៅនេះ ព្រះសារីបុត្តកាលនឹងសម្ដែងប្រភេទសមាធិតាំងពីពួក ១ រហូតដល់ពួក ១០ ទើបពោលបទមានជាអាទិ៍ថា **ឯកោ សមាធិ** សមាធិ ១ ។

ក្នុងបទទាំងនោះ បទថា **ចិត្តស្ស ឯកគ្គតា** សេចក្ដីថា ឈ្មោះថា **ឯកគ្គោ** ព្រោះអត្ថថា មានអារម្មណ៍ដ៏ប្រសើរ គឺយ៉ាងខ្ពង់ខ្ពស់ ព្រោះមិនមានសេចក្ដីរាយមាយទៅក្នុងអារម្មណ៍ផ្សេង ៗ , ភាពនៃ **ឯកគ្គោ** នោះ ឈ្មោះថា **ឯកគ្គតា** ដើម្បីសម្ដែងសភាពនៃចិត្តដែលមានអារម្មណ៍តែមួយនោះ មិនមែនសត្វ លោកទើបពោលថា **ចិត្តស្ស** ។

ក្នុងពួកទី ២ បទថា **លោកិយោ វដ្ដៈ** លោកពោលថា



**លោកោ** ព្រោះអត្ថថា បែកធ្លាយ , សមាធិប្រកបហើយក្នុងលោក ដោយភាពជាសមាធិជាប់នៅក្នុងវដ្ដៈនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **លោកិយ** ។

បទថា **លោកុត្តរោ** ឈ្មោះថា **ឧត្តរ** ព្រោះឆ្លងហើយ , ឈ្មោះថា **លោកុត្តរ** ព្រោះឆ្លងចាកលោក ដោយភាពជាសមាធិមិនជាប់នៅក្នុងលោក ។

ក្នុងពួកទី ៣ ឈ្មោះថា **សវិតក្កសវិចារោ** ព្រោះសមាធិមានវិតក្កៈ និងវិចារៈ ។ សមាធិមិនមានវិតក្កៈ មិនមានវិចារៈ ក៏មានទំនងដូចគ្នា ។ ក្នុងសមាធិដែលមានវិតក្កៈ និងវិចារៈ ឈ្មោះថា **វិចារមត្តោ** ព្រោះអត្ថថា មានតែវិចារៈប៉ុណ្ណោះ ជាប្រមាណ អធិប្បាយថា សមាធិមិនមានការប្រកបរួមគ្នា ជាមួយវិតក្កៈ ក្រៃលែងជាងវិចារៈ ។ ឈ្មោះថា អវិតក្កវិចារមត្តោ ព្រោះសមាធិនោះ មិនមានវិតក្កៈ មានតែវិចារ ។ សូម្បីក្នុង ៣ យ៉ាង អាចារ្យពួកខ្លះក៏កាត់ចេញ ។

ពួក ៤ មានអធិប្បាយទុកហើយ ។

ក្នុងពួក ៦ សតិនោះឯង ព្រោះកើតឡើងរឿយ ៗ ទើបឈ្មោះថា **អនុស្សតិ** ម្យ៉ាងទៀត ឈ្មោះថា **អនុស្សតិ** ព្រោះសមគួរដល់កុលបុត្តអ្នកបួសដោយសទ្ធា ព្រោះប្រព្រឹត្តទៅក្នុងឋានៈដែលគួរប្រព្រឹត្តទៅខ្លះ , **អនុស្សតិ** កើតឡើងប្រារព្ធដល់

ព្រះពុទ្ធជាម្ចាស់ ឈ្មោះថា **ពុទ្ធានុស្សតិ** បទនេះ ជាឈ្មោះនៃសតិ ដែលមានគុណព្រះពុទ្ធ មានព្រះអរហន្តជាដើម ជាអារម្មណ៍ ។ ដែលឈ្មោះថា **អវិក្ខេបោ** ព្រោះសភាពនៃចិត្តមានអារម្មណ៍តែមួយ ដោយអំណាចនៃពុទ្ធានុស្សតិនោះឯង មិនរាយមាយ ព្រោះជាបដិបក្ខនៃសេចក្ដីរាយមាយ បានដល់ **ឧទ្ធច្ច** ។

អនុស្សតិកើតឡើង ព្រោះប្រារព្ធព្រះធម៌ ឈ្មោះថា **ធម្មានុស្សតិ** , បទនេះ ជាឈ្មោះនៃសតិ ដែលមានគុណព្រះធម៌ ដែលមានអត្ថនៃព្រះធម៌ ដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកល្អហើយជាដើម ជាអារម្មណ៍ ។

**អនុស្សតិ** កើតឡើងប្រារព្ធព្រះសង្ឃ ឈ្មោះថា **សង្ឃានុស្សតិ** បទនេះ ជាឈ្មោះរបស់សតិដែលមានគុណព្រះសង្ឃ ដែលមានព្រះសង្ឃជាអ្នកប្រតិបត្តិល្អហើយជាដើម ជាអារម្មណ៍ ។

**អនុស្សតិ** កើតឡើងប្រារព្ធនូវសីល ឈ្មោះថា **សីលានុស្សតិ** , បទនេះ ជាឈ្មោះរបស់សតិដែលមានគុណរបស់សីល គឺ សីលរបស់ខ្លួនមិនដាច់ជាដើម ។

**អនុស្សតិ** កើតឡើងប្រារព្ធនូវចាគ **ចាគានុស្សតិ** , បទនេះ



ជាឈ្មោះរបស់សតិ ដែលមានគុណនៃចាគៈ ដែលខ្លួនបានលះបង់ទៅហើយ ។

**អនុស្សតិ** កើតឡើងប្រារព្ធនូវទេវតាទាំងឡាយ ឈ្មោះថា ទេវតានុស្សតិ , បទនេះ ជាឈ្មោះរបស់សតិដែលមានគុណនៃសទ្ធាជាដើមរបស់ខ្លួន ជាអារម្មណ៍ តាំងទេវតាទុកក្នុងឋានៈជាសាក្សី ។

ក្នុងពួក ៧ បទថា **សមាធិកុសលតា** សភាពជាអ្នកឈ្លាសក្នុងសមាធិច្រើនប្រភេទ ដោយប្រភេទមានសមាធិ ១ យ៉ាងជាដើមថា នេះជាសមាធិយ៉ាងនេះ , នេះជាសមាធិយ៉ាងនេះ ។ បទនេះ ជាឈ្មោះរបស់បញ្ញាកំណត់សមាធិ ។ ភាពជាអ្នកឆ្លាតដោយវិធីធ្វើឲ្យសមាធិកើត ព្រោះជាអ្នកឆ្លាតក្នុងសមាធិ ។

បទថា **សមាធិស្ស សមាបត្តិកុសលតា** ភាពជាអ្នកឈ្លាសក្នុងការចូលសមាធិ បានដល់ ភាពជាអ្នកឆ្លាតក្នុងការចូលសមាធិដែលធ្វើឲ្យកើតហើយ ។ ដោយបទដែលលោកពោលដល់ភាពជាអ្នកជំនាញក្នុងការចូលសមាធិ ។

បទថា **សមាធិស្ស ឋិតិកុសលតា** ភាពជាអ្នកឈ្លាសក្នុង

ការតាំងនៅនៃសមាធិ បានដល់ ភាពជាអ្នកឆ្លាតក្នុងការតាំងនៅនៃសមាធិ ដែលសម្រេចហើយដោយប្រពៃ ដោយអំណាចការជាប់តគ្នាទៅនៃចិត្ត ។ ដោយបទដែលលោកពោលដល់ភាពជាអ្នកជំនាញនៃការតាំងនៅ ។

ម្យ៉ាងវិញទៀត កាលព្រះយោគាវចរនោះ ញុំាងអាការទាំងនោះឲ្យដល់ព្រម ដោយការកាន់យកនិមិត្ត រមែងសម្រេចត្រឹមតែអប្បនាប៉ុណ្ណោះ , មិនយឺតយូរ ។ ចំណែកឋានៈដែលយឺតយូររមែងមាន ព្រោះជម្រះធម៌ដែលជាអន្តរាយដល់សមាធិទុកដោយល្អ ។ ពិតណាស់ ភិក្ខុណាគ្របសង្កត់កាមច្ឆន្ទៈដោយការពិចារណាទោសរបស់កាមជាដើម ទុកមិនបានល្អ , ការធ្វើសេចក្ដីក្រោតក្រោតតាមផ្លូវកាយ ដោយកាយបស្សទ្ធិឲ្យស្ងប់ មិនបានល្អ , ការដកចេញនូវថីនមិទ្ធៈ ដោយការយកចិត្តទុកដាក់ដល់អារម្ភធាតុប្រារព្ធនូវសេចក្ដីព្យាយាមមិនបានល្អ , ការដកចេញនូវឧទ្ធច្ចកុក្កុច្ចៈ ដោយការយកចិត្តទុកដាក់ដល់សមថនិមិត្ត មិនបានល្អ , ការជម្រះធម៌ដែលអន្តរាយដល់សមាធិមិនបានល្អ ហើយក៏ចូលឈាន , ភិក្ខុនោះ រមែងចេញចាកឈានដោយលឿនរហ័ស ដូច



ភមរជាតិចូលទៅកាន់កន្លែងដែលមិនស្អាត និងដូចព្រះរាជាចូលទៅកាន់ឧទ្យានដែលស្មោគគ្រោគ រមែងចេញទៅដោយប្រញាប់មួយរំពេចដូច្នោះ ។

ចំណែកភិក្ខុណាជម្រះធម៌ ដែលអន្តរាយដល់សមាធិបានល្អ ហើយចូលឈាន , ភិក្ខុនោះរមែងចូលឈានសមាបត្តិបានរហូតអស់ថ្ងៃ ដូចភមរជាតិចូលទៅកាន់កន្លែងដែលស្អាត , និងដូចព្រះរាជាចូលទៅកាន់ឧទ្យានដែលល្អស្អាត រមែងនៅបានរហូតអស់ថ្ងៃ ។ ដូចដែលបុរាណាចារ្យពោលទុកថា ៖

**កាមេសុ ឆន្ទំ បដិឃំ វិនោទយេ ឧទ្ធច្ចថីនំ**
**វិចិកិច្ឆបញ្ចមំ , វិវេកបាមុជ្ជករេន ចេតសា**
**រាជាវ សុទ្ធន្តគតោ តហឹ រមេ ។**

ព្រះយោគាវចរ អ្នកមានចិត្តធ្វើសេចក្ដីបាមោជ្ជៈក្នុងវិវេក គប្បីដកចេញនូវសេចក្ដីពេញចិត្តក្នុងកាមទាំងឡាយ សេចក្ដីខឹងក្រោធ សេចក្ដីរាយមាយ សេចក្ដីទាស់ចិត្ត និងសេចក្ដីសង្ស័យទាំង ៥ នេះ , ដូចព្រះរាជាចូលទៅកាន់កន្លែងដែលមានរបៀបរៀបរយ ទ្រង់ក៏សព្វព្រះទ័យក្នុងទីនោះ ។

ព្រោះដូច្នោះលោកទើបពោលទុកថា ដែលព្រះយោគាវចរអ្នកមានបំណងនឹងតាំងនៅរហូតអស់កាលយូរ គប្បីជម្រះធម៌ដែលជាសត្រូវហើយ ទើបចូលឈាន ដែលលោកពោលដល់ភាពជាអ្នកឈ្លាសក្នុងការញ៉ាំងវិធីនោះ ឲ្យដល់ព្រមហើយ ទើបញ៉ាំងសមាធិឲ្យតាំងនៅបានយូរ ។

បទថា **សមាធិស្ស វុដ្ឋានកុសលតា** ភាពជាអ្នកឈ្លាសក្នុងការចេញចាកសមាធិ បានដល់ ភាពជាអ្នកឈ្លាសក្នុងការចេញចាកសមាធិ ដោយការចេញតាមវេលា ដែលកំណត់ទុកនៃសមាធិ ដែលបានប្រព្រឹត្តទៅហើយតាមសេចក្តីពេញចិត្ត ដោយការជាប់បន្តគ្នា ។ គប្បីជ្រាបថា លោកធ្វើជាឆដ្ឋីវិភត្តិដែលចុះក្នុងអត្ថនៃបញ្ចមីវិភត្តិ ដូចក្នុងប្រយោគមានជាអាទិ៍ថា **យស្មាបិ ធម្មំ បុរិសោ វិជញ្ញា** បុរសគប្បីដឹងច្បាស់នូវធម៌សូម្បីអំពីបុគ្គលណា ។ ដោយបទដែលលោកពោលដល់ភាពជាអ្នកជំនាញក្នុងការចេញចាកសមាធិ។

បទថា **សមាធិស្ស កល្លតាកុសលតា** ភាពជាអ្នកឈ្លាសក្នុងភាពងាយស្រួលក្នុងសមាធិ សេចក្តីថា ភាពជាអ្នកមិនមាន



ជម្ងឺ ភាពអ្នកមិនមានរោគ ឈ្មោះថា **កល្លតា** ។ ការឈឺ លោកពោលថា **អកល្លកោ** សូម្បីក្នុងវិន័យលោកក៏ពោលទុកថា **នាហំ ភន្តេ អកល្លកោ** ខ្ញុំមិនទទួលការឈឺចាប់ ។ ភាពជាអ្នកឈ្លាសក្នុងការញ៉ាំងការមិនមានអាពាធនៃសមាធិ ដោយការមិនមានសេចក្តីប្រាថ្នាដ៏លាមក ដែលជាសត្រូវនៃការបានឈាន ដូចដែលលោកពោលទុកក្នុងអនង្គណសូត្រ និងវត្ថសូត្រ ដោយការប្រាសចាកឧបក្កិលេសនៃចិត្តមានអភិជ្ឈាជាដើម , លោកពោលថា ភាពជាអ្នកឈ្លាសវៃក្នុងភាពងាយស្រួលក្នុងសមាធិ គឺ ភាពជាអ្នកឈ្លាសក្នុងភាពជាអ្នកមិនមានជម្ងឺ គឺ កិលេស ។

ម្យ៉ាងទៀត បទថា **កល្លតា** បានដល់ ភាពជាអ្នកគួរដល់ការងារ ព្រោះពាក្យថា **កល្ល** ជាវេវចនៈរបស់ **កម្មញ្ញតា** ភាពជាអ្នកគួរដល់ការងារ ។ ដូចដែលលោកពោលថា **យា ចិត្តស្ស អកល្យតា អកម្មញ្ញតា** ការដែលចិត្តមិនសមប្រកប ការដែលចិត្តមិនគួរដល់ការងារ , និងថា **កល្លចិត្តំ មុទុចិត្តំ វិនីវរណចិត្តំ** ចិត្តគួរដល់ការងារ ចិត្តគួរដល់ភាពទន់ភ្លន់ ចិត្តប្រាសចាកនីវ-រណៈ ។

កល្ល ស័ត្តុ ក្នុងបទនេះមានសេចក្តីថា គួរដល់ការងារ ។ ព្រោះដូច្នោះ លោកទើបពោលទុកថា ភាពជាអ្នកឈ្លាសក្នុងការញុំាងភាពជំនាញនៃសមាធិដោយការហ្វឹកហាត់ចិត្ត ដោយអាការ ១៤ យ៉ាងទាំងនេះ គឺ ៈ-

ដោយអនុលោមនៃកសិណ ១

ដោយបដិលោមនៃកសិណ ១

ដោយអនុលោមបដិលោមនៃកសិណ ១

ដោយអនុលោមនៃឈាន ១

ដោយបដិលោមនៃឈាន ១

ដោយអនុលោមបដិលោមនៃឈាន ១

ដោយការឈានចូលទៅកាន់ឈាន ១

ដោយឈានចូលទៅកាន់កសិណ ១

ដោយការឈានចូលទៅកាន់ឈាន និងកសិណ ១

ដោយការឈានទៅកាន់អង្គ ១

ដោយការឈានទៅកាន់អារម្មណ៍ ១

ដោយការឈានទៅកាន់អង្គ និងអារម្មណ៍ ១



ដោយការកំណត់អង្គ ១

ដោយការកំណត់អារម្មណ៍ ១

ឬដោយអាការ ១៥ ផ្តើមបទថា ដោយការកំណត់អង្គ និងអារម្មណ៍ ១ ។

បទថា **សមាធិស្ស គោចរកុសលតា** ភាពជាអ្នកឈ្លាសក្នុងគោចរនៃសមាធិ សេចក្តីថា ភាពជាអ្នកឈ្លាសក្នុងអារម្មណ៍មានកសិណជាដើម ដែលជាទីគោចរនៃសមាធិក្នុងអារម្មណ៍ទាំងនោះ ដោយការញុំាងសេចក្តីនឹកគិតតាមសេចក្តីពេញចិត្ត ព្រោះបំណងនឹងចូលឈាននោះ ៗ ។ ដោយបទដែលលោកពោលដល់ភាពជាអ្នកជំនាញ ក្នុងការនឹកគិត ដោយការនឹកគិតដល់កសិណ ។

ម្យ៉ាងវិញទៀត ភាពជាអ្នកឈ្លាសក្នុងគោចរនៃសមាធិដោយអំណាចការពង្រីកទៅក្នុងទិសាភាគនោះ ៗ និងដោយអំណាចការតាំងទុកនៃកសិណ ដែលត្រឹមត្រូវហើយយ៉ាងនេះ ។

បទថា **សមាធិស្ស អភិនីហារកុសលតា** ភាពជាអ្នកឈ្លាសក្នុងការប្រមូលមកនូវសមាធិ សេចក្តីថា ភាពជាអ្នកឈ្លាសក្នុងការបង្អោនទៅក្នុងការញុំាងសមាធិផ្សេង ៗ ដោយន័យមានសភាព

ដូចគ្នា ដោយការបង្អោនចូលទៅកាន់សមាធិខ្ពស់ ៗ ។ ពិតណាស់ ឧបចារៈឈានដល់ភាពជំនាញ រមែងបង្អោនចូលទៅដើម្បីប្រយោជន៍ដល់បឋមជ្ឈាន ឬដើម្បីប្រយោជន៍ដល់វិបស្សនា ។ បឋមជ្ឈានជាដើម ក៏យ៉ាងនោះ រមែងបង្អោនចូលទៅដើម្បីប្រយោជន៍ដល់ទុតិយជ្ឈានជាដើម ឬដើម្បីប្រយោជន៍ដល់វិបស្សនា , ចតុត្ថជ្ឈាន រមែងបង្អោនចូលទៅដើម្បីប្រយោជន៍ដល់អរូបសមាបត្តិ ឬដើម្បីប្រយោជន៍ដល់អភិញ្ញា ដើម្បីប្រយោជន៍ដល់វិបស្សនា , អាកាសានញ្ចាយតនៈ រមែងបង្អោនចូលទៅដើម្បីប្រយោជន៍ដល់វិញ្ញាណញ្ចាយតនៈជាដើម ឬដើម្បីប្រយោជន៍ដល់វិបស្សនា ភាពជាអ្នកឈ្លាសក្នុងការបង្អោនចូលទៅនៃសមាធិក្នុងញាណនោះ ៗ ដោយប្រការយ៉ាងនេះ ។ ក៏ព្រោះបញ្ញា ឈ្មោះថា ភាពនៃសេចក្តីឈ្លាស , បញ្ញានោះ មិនមែនសមាធិ , ដូច្នោះគប្បីជ្រាបថា សមាធិ ៧ យ៉ាង លោកពោលដោយអំណាចបញ្ញា ដែលប្រព្រឹត្តទៅក្នុងសមាធិ ។

ចំណែកអាចារ្យពួកខ្លះពោលថា បទថា **សមាធិ កុសលតា** ភាពជាអ្នកឈ្លាសក្នុងសមាធិ បានដល់ ភាពជាអ្នកឈ្លាសក្នុងការ



យកចិត្តទុកដាក់ ដែលធ្វើឲ្យចិត្តមិនរាយមាយ ។

បទថា **សមាបត្តិកុសលតា** ភាពជាអ្នកឈ្លាសក្នុងសមាបត្តិ បានដល់ ភាពជាអ្នកឈ្លាសក្នុងការយកចិត្តទុកដាក់ញ៉ាំងអង្គឈានឲ្យប្រាកដដល់អ្នកចូលឈាន ។

បទថា **ឋិតិកុសលតា** ភាពជាអ្នកឈ្លាសក្នុងការតាំងនៅ បានដល់ ភាពជាអ្នកឈ្លាសក្នុងការយកចិត្តទុកដាក់ ដែលសមាធិប្រាកដមិនរាយមាយ ។

បទថា **វុដ្ឋានកុសលតា** ភាពជាអ្នកឈ្លាសក្នុងការចេញ បានដល់ ការដឹងក្នុងការចេញចាកនីវរណៈក្នុងបឋមជ្ឈាន , ការដឹងក្នុងការចេញចាកអង្គឈានទាំង ៣ , ការដឹងក្នុងការចេញចាកអារម្មណ៍នៃអរូបសមាបត្តិ , ការដឹងក្នុងការចេញចាកសេចក្តីរាយមាយនៃលក្ខណៈដែលមានប្រមាណក្រៃលែង , ការដឹងក្នុងការចេញចាកសេចក្តីពេញចិត្តរបស់ខ្លួនក្នុងកាលមានទីបំផុត និងកាលមានកិច្ចដែលគួរធ្វើក្នុងគ្រាចុងក្រោយ ។

បទថា **កល្លតាកុសលតា** ភាពជាអ្នកឈ្លាសក្នុងភាពងាយស្រួល បានដល់ ភាពជាអ្នកឈ្លាសក្នុងភាពងាយស្រួលនៃសមាធិ

ព្រោះចិត្តសប្បាយ រាងកាយសប្បាយ អាហារសប្បាយ សេនាសនៈសប្បាយ និងបុគ្គលសប្បាយ ។

បទថា **គោចរកុសលតា** ភាពជាអ្នកឈ្លាសក្នុងគោចរ បានដល់ សេចក្ដីដឹងដើម្បីការកំណត់អារម្មណ៍ , សេចក្ដីដឹងដើម្បីពង្រីកទៅកាន់ទិស សេចក្ដីដឹងដើម្បីការចម្រើន ។

បទថា **អភិនីហារកុសលតា** ភាពជាអ្នកឈ្លាសក្នុងការបង្អោនចូលទៅ បានដល់ ការបង្អោនចិត្តចូលទៅ ដោយការយកចិត្តទុកដាក់ដោយប្រពៃក្នុងសមាធិនោះ ៗ , កាលឧបចារៈដល់សេចក្ដីជំនាញហើយ រមែងនាំចិត្តចូលទៅក្នុងបឋមជ្ឈាន , រមែងនាំចិត្តចូលទៅក្នុងឈានខ្ពស់ ៗ មានក្នុងអភិញ្ញា ក្នុងអរូបសមាបត្តិ និងក្នុងវិបស្សនា ។

អាចារ្យទាំងឡាយ រមែងពណ៌នាសេចក្ដីនៃបទទាំងឡាយនេះ យ៉ាងនេះថា ភាពនៃសេចក្ដីឈ្លាសក្នុងការបង្អោនចូលទៅក្នុងសមាធិនោះ ៗ ដោយប្រការដូច្នេះ ។

ក្នុងពួកទី ៨ មានអត្ថដូចពោលហើយ ។

ក្នុងពួកទី ៩ បទថា **រូបាវចរោ** ធម៌ជារូបាវចរៈ តើដូច



ម្ដេច ? រូបាវចរៈជាប់ទាក់ទង និងរូបាវចរធម៌ ដូចដែលលោកពោលទុកដោយន័យមានជាអាទិ៍ថា **ហេដ្ឋតោ ព្រហ្មលោកំ បរិយន្តំ ករិត្វា ឧបរិតោ អកនិដ្ឋេ ទេវេ អន្តោករិត្វា** ខាងក្រោមញុំាងព្រហ្មលោកឲ្យមានទីបំផុត ខាងលើញុំាងជាន់អកនិដ្ឋជាទីបំផុត ។ ក្នុងសេចក្ដីនេះមានវចនត្ថៈដូចតទៅនេះ ឈ្មោះថា **រូបាវចរ** ព្រោះអត្ថថា **រូប** បានដល់ រូបក្ខន្ធរមែងត្រាច់ទៅក្នុងរូបភពនេះ , មិនមែនកាមភព ។ ព្រោះថា សូម្បីរូបក្ខន្ធ លោកក៏ពោលថា រូប ដូចក្នុងពាក្យថា **រូបក្ខន្ធោ រូបំ** រូបក្ខន្ធ ជារូប ។

**ម្យ៉ាងទៀត រូបព្រហ្មនោះ មាន ១៦ ជាន់ គឺ ៖**

ព្រហ្មបារិសជ្ជៈ ១

ព្រហ្មបុរោហិត ១

មហាព្រហ្ម ១

បរិត្តាភា ១

អប្បមាណាភា ១

អាភស្សរា ១

បរិត្តសុភា ១

អប្បមាណសុភា ១

សុភកិណ្ហា ១

អសញ្ញីសត្ត ១

វេហប្ផលា ១

អវិហា ១

អតប្បា ១

សុទស្សា ១

សុទស្សី ១

អកនិដ្ឋា ១

ដែលពិត លោកពោលថា គឺ រូបាវចរៈនោះ ថាជារូប ព្រោះលុបបទខាងក្រោយ , ឈ្មោះថា **រូបាវចរ** ព្រោះត្រាច់ទៅក្នុងរូបនោះ ។ ម្យ៉ាងវិញទៀត **រូប** គឺ រូបភព , ឈ្មោះថា **រូបាវចរ** ព្រោះត្រាច់ទៅក្នុងរូបភពនោះ ។ ពិតណាស់ សមាធិនេះត្រាច់ទៅសូម្បីក្នុងកាមភព កាលដែលត្រាច់ទៅក្នុងទីដទៃ លោកក៏ពោលថា រូបាវចរភព ដូចសត្វដំរីបានឈ្មោះថា **សង្គាមាវចរ** ព្រោះត្រាច់ទៅក្នុងសង្គ្រាម សូម្បីត្រាច់ទៅក្នុងក្រុង ក៏ហៅថា **សង្គាមាវចរ** ,



ដូចសត្វទាំងឡាយ ដែលត្រាច់ទៅលើគោក និងត្រាច់ទៅក្នុងទឹក សូម្បីសត្វទាំងនោះនឹងមិននៅក្នុងទីមិនមែនលើគោក មិនមែននៅក្នុងទឹក ក៏ហៅថា ត្រាច់ទៅលើគោក ឬត្រាច់ទៅក្នុងទឹកដូច្នោះ ។ ម្យ៉ាងវិញទៀត ឈ្មោះថា **រូបាវចរ** ព្រោះញុំាងបដិសន្ធិឲ្យត្រាច់ទៅក្នុងរូប គឺ រូបភព ។

បទថា **ហីនោ** ថោកទាប បានដល់ លាមក ។ ភពក្នុងចំណោមនៃសមាធិថោកទាប និងសមាធិប្រណីត , ឈ្មោះថា **មជ្ឈោ** កណ្ដាល បាឋៈថា **មជ្ឈិមោ** មជ្ឈិមខ្ចៈ ។ មានសេចក្ដីដូចគ្នា , សមាធិដល់ភាពជាប្រធាន ឈ្មោះថា **បណីតោ** ប្រណីត សេចក្ដីថា ប្រសើរខ្ពង់ខ្ពស់ ។ គប្បីជ្រាប សមាធិទាំងនោះដោយការប្រកបទុក ។ ក្នុងខណៈប្រកបឆន្ទៈ វីរិយៈ ចិត្ត ឬវីមំសា នៃសមាធិណាដែលថោកទាប , សមាធិនោះ ឈ្មោះថា **ហីន** ។ ធម៌ទាំងនោះនៃសមាធិណា ដែលជាកណ្ដាល , សមាធិនោះ ឈ្មោះថា **មជ្ឈិម** ។ ភាពនៃសមាធិណាដែលប្រណីត , សមាធិនោះឈ្មោះថា **បណីត** , ឬសមាធិត្រឹមតែឲ្យកើតឡើងឈ្មោះថា ហីន , ការចម្រើនមិនសូវធ្ងន់ល្អ ឈ្មោះថា **មជ្ឈិម** , ការចម្រើនយ៉ាងល្អ

ក្រៃលែងដល់ភាពជំនាញ ឈ្មោះថា **បណីត** មានទំនងដូចគ្នា ដោយន័យដូចពោលហើយក្នុងរូបាវចរសមាធិ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទមានជាអាទិ៍ថា **សុញ្ញតោ សមាធិ** ដូចតទៅនេះ កាលចេញចាកមគ្គដែលកើតហើយ ដោយអនត្តា-នុបស្សនានៃព្រះយោគាវចរ អ្នកឃើញតាមលំដាប់នៃវិបស្សនាថា **សព្វេ សង្ខារា អនិច្ចា ទុក្ខា អនត្តា** សង្ខារទាំងឡាយទាំងពួងមិនទៀង ជាទុក្ខ ជាអនត្តា ព្រោះវិបស្សនានោះ ប្រព្រឹត្តទៅហើយ ដោយភាពជារបស់សូន្យក្នុងសង្ខារទាំងឡាយ ដែលមិនមានតួខ្លួន , ដូច្នោះទើបឈ្មោះថា **សុញ្ញតា** ។ អរិយមគ្គសមាធិសម្រេចដោយសុញ្ញតានោះ ឈ្មោះថា **សុញ្ញតសមាធិ** , អធិប្បាយថា សមាធិដែលប្រព្រឹត្តទៅហើយដោយអំណាចនៃ **សុញ្ញត** ។ ពិតណាស់ សមាធិនោះ រមែងប្រព្រឹត្តទៅដោយអាការដែលវិប-ស្សនាប្រព្រឹត្តទៅហើយ ។

កាលចេញចាកមគ្គដែលកើតហើយដោយ **អនិច្ចានុបស្សនា** ព្រោះវិបស្សនានោះប្រព្រឹត្តទៅហើយ ដោយបដិបក្ខចំពោះនិមិត្តថាទៀង ។ ដូច្នោះទើបឈ្មោះថា **អនិមិត្តវិបស្សនា** ។ អរិយមគ្គ-



សមាធិ សម្រេចដោយវិបស្សនានោះ ទើបឈ្មោះថា **អនិមិត្ត-សមាធិ** ។ អធិប្បាយថា សមាធិដែលវៀរចាកនិមិត្តដែលទៀង ។ ពិតណាស់ សមាធិនោះ រមែងប្រព្រឹត្តទៅដោយអាការ ដែលប្រព្រឹត្តទៅហើយនៃវិបស្សនា ។ កាលចេញចាកមគ្គដែលកើតហើយដោយ **ទុក្ខានុបស្សនា** ព្រោះវិបស្សនានោះប្រព្រឹត្តទៅហើយដោយបដិបក្ខចំពោះសេចក្តីប្រាថ្នា , ដូច្នោះទើបឈ្មោះថា **អប្ប-ណិហិតសមាធិ** សមាធិដែលវៀរចាកនូវសេចក្តីប្រាថ្នា ។ ព្រោះសមាធិនោះ រមែងប្រព្រឹត្តទៅដោយអាការប្រព្រឹត្តទៅហើយ ដោយវិបស្សនា ។ គប្បីជ្រាបថា សូម្បីផលសមាធិក៏ដូច្នោះ ដែលលោកកាន់យកដោយសមាធិ ៣ ទាំងនោះ ។ តែលោកមិនលើកយកប្រភេទនៃសមាធិ មានសមាធិថោកទាបជាដើម ព្រោះលោ-កុត្តរសមាធិ ជាសមាធិដែលប្រណីត ។

ក្នុងពួក ១០ គប្បីជ្រាបវិនិច្ឆ័យក្នុងបទមានជាអាទិ៍ថា ៖ **ឧទ្ធុមាតកសញ្ញាវសេន** ដោយអំណាចការសំគាល់សាកសពដែលហើមប៉ោង ឈ្មោះថា **ឧទ្ធុមាតកំ** ព្រោះឡើងប៉ោង ដោយការប៉ោងឡើង ៗ តាមលំដាប់ខាងលើ ដោយខ្យល់ ដូចគ្រឿងបូម

ខ្យល់ ព្រោះអស់ជីវិត ។ ការប៉ោងឡើងនោះឯង ឈ្មោះថា **ឧទ្ធុមាតកំ** ។ មយ៉ាងទៀត ឈ្មោះថា **ឧទ្ធុមាតកំ** ព្រោះហើមប៉ោងគួរឲ្យខ្ពើម ព្រោះជាវត្ថុបដិកូល , បទនេះជាឈ្មោះនៃសាកសពដែលឃើញនោះ ។

ពណ៌ដែលបែកចេញហៅថា **វិនីលំ** ពណ៌ខៀវគួរឲ្យខ្ពើម , ពណ៌ខៀវគួរឲ្យខ្ពើមនោះឯង ឈ្មោះថា **វិនីលកំ** ។ ឈ្មោះថា **វិនីលកំ** ព្រោះពណ៌ខៀវគួរឲ្យខ្ពើម ព្រោះជាវត្ថុបដិកូល ។ បទនេះជាឈ្មោះនៃសាកសព មានពណ៌ក្រហម ក្នុងកន្លែងដែលមានសាច់ច្រើន , មានពណ៌ខៀវក្នុងកន្លែងដែលបៀមខ្ទុះ ដោយច្រើនមានពណ៌ខៀវ ក្នុងកន្លែងមានពណ៌ខៀវ ស្រដៀងសំពត់ដណ្ដប់ពណ៌ខៀវ ។

ខ្ទុះហូរចេញក្នុងកន្លែងដែលស្បែកប្រេះបែក ឈ្មោះថា **វិបុព្វំ** , ខ្ទុះហូរនោះឯង ឈ្មោះថា **វិបុព្វកំ** ។ ឈ្មោះថា **វិបុព្វកំ** ព្រោះខ្ទុះហូរចេញគួរឲ្យខ្ពើម ព្រោះជាវត្ថុបដិកូល ។ បទនេះជាឈ្មោះនៃសាកសពដែលឃើញនោះ ។

សាកសពដែលដោយដាច់ចេញជា ២ កំណាត់ ហៅថា



**វិច្ឆិទ្ទំ** , សាកសពដែលដាច់ជាកំណាត់នោះឯង ឈ្មោះថា **វិច្ឆិទ្ទកំ** ។ មយ៉ាងទៀត ឈ្មោះថា **វិច្ឆិទ្ទកំ** ព្រោះសាកសព ដែលដាច់ជាកំណាត់គួរឲ្យខ្ពើម ព្រោះជាវត្ថុបដិកូល ។ បទនេះ ជាឈ្មោះនៃសាកសពដែលដាច់ពាក់កណ្ដាល ។

សាកសពឈ្មោះថា **វិក្ខាយិតំ** ព្រោះត្រូវឆ្កែស្រុក និងឆ្កែចចកជាដើម ខាំស៊ីខាងនេះ និងខាងនោះ ដោយអាការផ្សេង ៗ , គួរពោលថា **វិក្ខាយិតំ** លោកពោលថា **វិក្ខាយិតកំ** លោកឈ្មោះថា **វិក្ខាយិតកំ** សាកសពដែលត្រូវសត្វខាំស៊ី , មយ៉ាងវិញទៀត ឈ្មោះថា **វិក្ខាយិតកំ** ព្រោះសាកសពដែលត្រូវសត្វខាំស៊ីគួរខ្ពើម ព្រោះជារបស់បដិកូល ។ បទនេះ ជាឈ្មោះនៃសាកសពដែលឃើញហើយនោះ ។

សាកសពដែលខ្ចាត់ខ្ចាយទៅក្នុងកន្លែងផ្សេង ៗ ឈ្មោះថា **វិក្ខិត្តំ** សាកសពដែលខ្ចាត់ខ្ចាយនោះឯង ឈ្មោះថា **វិក្ខិត្តកំ** , ឈ្មោះថា **វិក្ខិត្តកំ** ព្រោះសាកសពខ្ចាត់ខ្ចាយគួរខ្ពើម ព្រោះជាវត្ថុបដិកូល ។ បទនេះជាឈ្មោះ នៃសាកសពដែលខ្ចាត់ខ្ចាយទៅពីទីនោះ ៗ យ៉ាងនេះ គឺ ដៃទៅម្ខាង ជើងទៅម្ខាង សីសៈទៅម្ខាង ។

សាកសពឈ្មោះថា **ហតវិក្ខិត្តកំ** ព្រោះសាកសពនោះត្រូវកាប់ និងខ្ចាត់ខ្ចាយទៅដោយន័យមុននោះឯង ។ បទនេះជាឈ្មោះនៃសាកសពដែលត្រូវកាប់ដោយសស្ត្រា ត្រង់អវយវៈតូច-ធំ ដោយអាការដូចសញ្ញាលេខបូក ហើយខ្ចាត់ខ្ចាយទៅ ដោយន័យដូចពោលហើយ ។

សាកសពឈ្មោះថា **លោហិតកំ** ព្រោះលោហិតហូរចេញខ្ចាតទៅខាងនោះ ទៅខាងនេះ ។ បទនេះ ជាឈ្មោះនៃសាកសពដែលប្រឡាក់ពាសពេញដោយលោហិត ដែលហូរខ្ចាតទៅ ។

សាកសពឈ្មោះថា **បុឡុវកំ** ព្រោះដង្កូវ លោកហៅថា **បុឡុវា** , លោហិតខ្ចាយទៅលើដង្កូវ ។ បទនេះ ជាឈ្មោះនៃសាកសពដែលពេញទៅដោយដង្កូវ ។

ឆ្អឹងនោះឯង ឈ្មោះថា **អដ្ឋិកំ** , ម្យ៉ាងទៀត ឈ្មោះថា **អដ្ឋិកំ** ព្រោះអត្ថថា ជាឆ្អឹងដែលគួរឲ្យខ្ពើម ព្រោះជាវត្ថុបដិកូល ។ បទនេះ ជាឈ្មោះនៃគ្រោងឆ្អឹងខ្លះ នៃឆ្អឹងមួយប្រភេទខ្លះ ។ ទាំងនេះ ជាឈ្មោះនៃនិមិត្តដែលកើតព្រោះអាស្រ័យសាកសពដែលជា **ឧទ្ធុមាតក** ជាដើមខ្លះ នៃឈានដែលបានហើយក្នុងនិមិត្តទាំងឡាយ



ខ្លះ ។ តែក្នុងឧទ្ធុមាតកនិមិត្តនេះ សញ្ញាដែលកើតដោយអំណាចអប្បនាកំណត់យកអាការដែលគួរខ្ពើម ឈ្មោះថា **ឧទ្ធុមាតកសញ្ញា** , ដោយអំណាចនៃឧទ្ធុមាតកសញ្ញានោះ ឈ្មោះថា ឧទ្ធុមាតកសញ្ញាវស , សូម្បីក្នុងបទនេះ ដ៏សេសក៏មានន័យនេះដូចគ្នា ។ បទថា **បញ្ចបញ្ញាស សមាធិ** សមាធិ ៥៥ លោកពោលដោយអំណាចនៃធម៌ពួកមួយ ជាដើម ។

ព្រះសារីបុត្តគ្រាសម្តែងដល់ប្រភេទនៃសមាធិដោយអំណាចពួកមួយជាដើមយ៉ាងនេះហើយ ឥឡូវនេះលោកបំណងនឹងសម្តែងសមាធិដោយបរិយាយសូម្បីដទៃ ទើបសម្តែងប្រារព្ធបរិយាយដទៃថា **អបិច** ដូច្នេះហើយ ពោលបទមានជាអាទិ៍ថា **បញ្ចវីសតិ ២៥** ក្នុងបទទាំងនោះ បទថា **សមាធិស្ស សមាធិដ្ឋា** គឺ សភាពនៃសមាធិក្នុងសមាធិ , សមាធិនោះ រមែងមានបានដោយសភាពណា , សភាពទាំងនោះ ឈ្មោះថា ជាប្រយោជន៍ក្នុងសមាធិនោះ ។

បទថា **បរិគ្គហដ្ឋេន សមាធិ** ដែលឥន្ទ្រិយ មានសទ្ធិន្ទ្រិយជាដើម កំណត់កាន់យក ។ ម្យ៉ាងទៀត ឥន្ទ្រិយទាំងនោះឯង រមែងជាបរិវារដល់គ្នានឹងគ្នា ហើយរមែងជាឥន្ទ្រិយបរិបូណ៌ដោយ

ការបំពេញភាវនា ។ ព្រោះដូច្នោះ ឈ្មោះថា **សមាធិ** ព្រោះអត្ថថា ឥន្ទ្រិយជាបរិវារដល់គ្នានឹងគ្នា ព្រោះអត្ថថា **សទ្ធិន្ទ្រិយ** ជាដើម បរិបូរណ៍ ។ ព្រោះថា មានអារម្មណ៍តែមួយ ព្រោះសម្រឹងអារម្មណ៍តែមួយ ដោយអំណាចសមាធិនៃឥន្ទ្រិយទាំងនោះ , ព្រោះអត្ថថា មិនរាយមាយ ព្រោះសម្រឹងការមិនមានសេចក្ដីរាយ-មាយក្នុងអារម្មណ៍ផ្សេង ៗ , គប្បីជ្រាប លោកមិនកាន់យកអត្ថថា កំណត់កាន់យកសេចក្ដីទៀង និងអត្ថថា មិនបន្តទៅក្នុងទីនេះនិងពេលក្រោយ ព្រោះគួរចាក់ធ្លុះដោយការកំណត់កាន់យកវីរិ-យពលៈជាធំក្នុងលោកុត្តរនោះឯង ព្រោះមិនមានការទៅ ដោយការវិនាសនៃលោកុត្តរមគ្គ ។ ឈ្មោះថា **សមាធិ** អត្ថថា ដោយមិនមានកិលេសកើតឡើង ។ ឈ្មោះថា **សមាធិ** ព្រោះអត្ថថា មិនញាប់ញ័រ ព្រោះការមិនញាប់ញ័រ , ឈ្មោះថា **សមាធិ** ព្រោះអត្ថថា ផុតចាកកិលេស ព្រោះផុតចាកកិលេសដោយការគ្រប សង្កត់ ឬដោយការកាត់ផ្ដាច់ និងព្រោះបង្អោនទៅក្នុងអារម្មណ៍ ។

បទថា **ឯកត្តុបដ្ឋានវសេន ចិត្តស្ស ឋិត្តតា** ព្រោះភាពនៃចិត្តតាំងនៅ ដោយអំណាចការតាំងមាំ ក្នុងការដែលចិត្តមាន



អារម្មណ៍តែមួយ សេចក្ដីថា ព្រោះការដែលចិត្តតាំងមាំដោយការមិនញាប់ញ័រក្នុងអារម្មណ៍នៃចិត្ត ដោយអំណាចការតាំងមាំយ៉ាងធ្ងន់ក្នុងអារម្មណ៍តែមួយ ដោយការប្រកបសមាធិនោះឯង ។ គប្បីជ្រាបថា ក្នុងគូទី ៨ លោកពោលដល់ ៣ គូទាំងនេះ គឺ រមែងស្វែងរក រមែងមិនស្វែងរក ជាគូទី ១ , រមែងកាន់យក រមែងមិនកាន់យក ជាគូទី ២ , រមែងបដិបត្តិ រមែងមិនបដិបត្តិ ជាគូទី ៣ ដោយការមិនមានសល់នៃចិត្ត ដែលបង្អោនទៅក្នុងកណ្ដាល ការបង្អោននៃឧបចារៈ ក្នុងចំណែកខាងដើមអំពីវិថីនៃអប្បនា , គប្បីជ្រាបបទនេះថា **ឈាយតិ ឈាបេតិ** ក្នុងវិថីនៃអប្បនា ។ គប្បីជ្រាបថា លោកពោលដល់ ៤ គូទាំងនេះ គឺ ព្រោះការស្វែងរក ព្រោះការមិនស្វែងរក ជាគូទី ១ , ព្រោះការប្រកាន់មាំ ព្រោះការមិនប្រកាន់មាំ ជាគូទី ២ , ព្រោះបដិ-បត្តិហើយ ព្រោះមិនបដិបត្តិហើយ ជាគូទី ៣ , ព្រោះដុតហើយ ព្រោះមិនដុតហើយ ជាគូទី ៤ ដោយអំណាចអប្បនា ។

ក្នុងបទទាំងនោះ បទថា **សមំ** ក្នុងបទមានជាអាទិ៍ថា **សមំ ឯសតីតិ សមាធិ** បានដល់ អប្បនា ។ ពិតណាស់ អប្បនា

នោះ ឈ្មោះថា **សមា** ព្រោះស្ងប់ គឺ ញុាំងធម៌ដែលជាសត្រូវឲ្យវិនាសទៅ , ម្យ៉ាងទៀត ឈ្មោះថា **សមា** ព្រោះកើតពីការមិនមានសេចក្ដីមិនស្ងប់ ដែលជាសត្រូវ ។ **សមាធិ** រមែងស្វែងរកសេចក្ដីស្ងប់នោះ គឺ រមែងស្វែងរកដោយអធ្យាស្រ័យ ។ **ឥតិ** ស័ព្ទ ជាការណត្ថៈ ប្រែថា ព្រោះហេតុនោះ , អធិប្បាយថា ព្រោះស្វែងរកសេចក្ដីស្ងប់ ព្រោះដូច្នោះ ទើបឈ្មោះថា **សមាធិ** ។

បទថា **វិសមំ នេសតិ** សេចក្ដីថា មិនស្វែងរកសេចក្ដីមិនស្ងប់ ដែលជាសឹកសត្រូវដល់ឈាននោះ ៗ ។

ពិតណាស់ សមាធិដែលជាចំណែកខាងដើម ជាសមាធិទន់ខ្សោយ ឈ្មោះថា រមែងស្វែងរកសេចក្ដីស្ងប់ , មិនស្វែងរកសេចក្ដីមិនស្ងប់ ព្រោះជាសមាធិខាងដើម ។ សមាធិជាកណ្ដាល ឈ្មោះថា រមែងកាន់យកសេចក្ដីស្ងប់ , មិនកាន់យកសេចក្ដីមិនស្ងប់ ព្រោះជាសមាធិមាំទាំ ។

សមាធិមានប្រមាណក្រៃលែង ឈ្មោះថា រមែងបដិបត្តិសេចក្ដីស្ងប់ , មិនបដិបត្តិសេចក្ដីមិនស្ងប់ ព្រោះជាសមាធិជិតវិថីនៃអប្បនា ។



បទថា **សមំ ឈាយតិ** ជាការនបុំសកៈ សេចក្ដីថា ជាសេចក្ដីស្ងប់ទើបសម្ងឹង ឬសម្ងឹងដោយអាការស្ងប់ , ពិតណាស់ សមាធិក្នុងវិថីនៃអប្បនា រមែងប្រព្រឹត្តទៅដោយអាការស្ងប់ ព្រោះស្ងប់ ដោយប្រាសចាកធម៌ដែលជាសត្រូវ និងព្រោះតាំងនៅដោយភាពជាសមាធិឧបការៈដល់អប្បនា ដែលស្ងប់ហើយ ។

បទថា **ឈាយតិ** មានសេចក្ដីរុងរឿង ដូចក្នុងប្រយោគមានជាអាទិ៍ថា ប្រទីបក្នុងពន្លាទាំងនេះ រមែងរុងរឿងរហូតយប់ , និងដូចប្រទីបប្រេង រមែងរុងរឿងរហូតយប់ , ប្រទីបប្រេងគប្បីរុងរឿងក្នុងពន្លានេះ ។ បាឋៈថា **សមំ ជាយតិ** រមែងកើតដោយអាការស្ងប់ , បាឋៈមុនល្អជាង ព្រោះភាពជាគូថា **ឈាយតិ ឈាបេតិ** សម្ងឹងសេចក្ដីស្ងប់ ដុតសេចក្ដីមិនស្ងប់ ។

ម្យ៉ាងទៀត បទថា **ឈាបេតិ** យកសេចក្ដីថា ដុត ។ ព្រោះថា សមាធិនោះឈ្មោះថា រមែងដុតធម៌ដែលជាសត្រូវធ្វើឲ្យឃ្លាតឆ្ងាយ ។ លោកពោលដល់អប្បនាសមាធិ ដោយបទមានជាអាទិ៍ថា **ឯសិតត្តា នេសិតត្តា** ព្រោះស្វែងរក ព្រោះមិនស្វែងរក ព្រោះការស្វែងរក និងការមិនស្វែងរកជាដើម សម្រេចដោយអប្បនា ។

បទថា **សមំ ឈាតត្តា** ព្រោះសម្លឹងសេចក្តីស្ងប់ , គឺព្រោះរុងរឿងជានិច្ច ។ បាឋៈថា **សមំ ជាតត្តា** ព្រោះកើតជានិច្ចខ្លះ ។ ភាពជាសមាធិ នៃសមាធិ ២៥ ទាំងនេះ គឺ សមាធិ ១៦ ដោយអំណាចនៃគូ មាន ៨ ទាំងនេះ , និងសមាធិមាន ៩ ខាងដើម ។

ក្នុងបទនេះថា **សមោ ច ហិតោ ច សុខោ ចា សមាធិ** ឈ្មោះថា **សមាធិ** ព្រោះជាធម៌ស្ងប់ មានសភាពឧបការៈ និងជាសេចក្តីសុខ លោកពោលដើម្បីឲ្យសម្រេចប្រយោជន៍នៃសមាធិដែលសម្រេចហើយដោយអាការ ២៥ ។

ក្នុងបទទាំងនោះ បទថា **សមោ** មានសេចក្តីនៃ **សម** ស័ព្ទ ឬ **សំ** ស័ព្ទ ។

ពិតណាស់ សមាធិនោះឈ្មោះថា **សមោ** វៀរចាកសេចក្តីមិនស្ងប់ ដែលកម្រើកជាសត្រូវ ។

បទថា **ហិតោ** មានសេចក្តីន័យ **អធិ** ស័ព្ទ , អធិប្បាយថាតាំងនៅក្នុងអារម្មណ៍ គឺ ឲ្យតាំងនៅដោយភាពមិនញាប់ញ័រ ។ លោកអធិប្បាយថា ដោយបទទាំង ២ ឈ្មោះថា **សមាធិ** ព្រោះស្ងប់



និងតាំងមាំ ។

បទថា **សុខោ** , ឈ្មោះថា **សុខោ** ព្រោះអត្ថថា **ស្ងប់** ។ សូម្បីសមាធិដែលសហគតដោយឧបេក្ខា លោកក៏កាន់យកដោយសុខស័ព្ទ មានអត្ថថា **ស្ងប់** ព្រោះលោកពោលទុកថា បពិត្រលោកដ៏ចម្រើន **អទុក្ខមសុខវេទនា** ព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកក្នុងសេចក្តីស្ងប់ គឺ ក្នុងសេចក្តីសុខដ៏ប្រណីត និងឧបេក្ខា លោកពោលថា ជាសេចក្តីសុខ ព្រោះស្ងប់ ។ លោកពោលសមាធិទាំងអស់ទុកក្នុងទីនេះដោយមិនមានកំណត់ ។ ទើបជាចំណែកដែលលោកពោលហេតុនៃការតាំងមាំដោយ **សុខ** ស័ព្ទនោះ ។ គប្បីជ្រាបពាក្យអធិប្បាយថា ព្រោះសមាធិជាសេចក្តីស្ងប់ , ដូច្នោះសមាធិទើបតាំងមាំក្នុងអារម្មណ៍តែមួយ ដោយប្រការដូច្នេះ ។

( ចប់អដ្ឋកថា សមាធិភាវនាមយញ្ញាណនិទ្ទេស )

# អដ្ឋកថា ធម្មដ្ឋិតិញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងធម្មដ្ឋិតិញ្ញាណនិទ្ទេស ដូចតទៅនេះ ក្នុងបទមានជាអាទិ៍ថា **អវិជ្ជា សង្ខារានំ ឧប្បាទដ្ឋិតិ** អធិប្បាយដូច្នេះ ឈ្មោះថា **ឋិតិ** ព្រោះអត្ថថា អវិជ្ជាជាហេតុតាំងឡើងនៃសង្ខារ ។ ឋិតិនោះ គឺអ្វី ? គឺ អវិជ្ជា ។ ព្រោះថា អវិជ្ជានោះជាទីតាំង គឺ ជាហេតុនៃការកើតឡើងនៃសង្ខារទាំងឡាយ ព្រោះហេតុនោះទើបឈ្មោះថា **ឧប្បាទដ្ឋិតិ** ជាហេតុកើតឡើង ។

ឈ្មោះថា **បវត្តដ្ឋិតិ** អត្ថថា ជាហេតុនៃការប្រព្រឹត្តទៅនៃសង្ខារទាំងឡាយដែលកើតឡើងហើយ ។ អធិប្បាយថា សេចក្តីពិត អានុភាពនៃកិច្ច រមែងមានក្នុងខណៈជនកប្បច្ច័យកើតឡើងនោះឯងដោយពិត , ប៉ុន្តែព្រោះការប្រព្រឹត្តទៅនៃសង្ខារទាំងឡាយដែលជនកប្បច្ច័យនោះឲ្យកើតឡើង ទើបឈ្មោះថា ជាហេតុ សូម្បីការប្រព្រឹត្តទៅក្នុងខណៈរបស់ខ្លួន , មួយវិញទៀត ជាហេតុនៃការប្រព្រឹត្តទៅដោយអំណាចសន្តតិ ។

មួយទៀត បទថា **បវត្តំ** នេះ ជាភាវវចនៈចុះក្នុងនបុំ-



សកលិង្គ , ព្រោះដូច្នោះ **បវត្តំ** ទើបជាចំណែកតែមួយដោយអត្ថថា **បវត្តិ** ការប្រព្រឹត្តទៅ ។ ប៉ុន្តែព្រោះ **បវត្តិ** ស័ព្ទប្រាកដហើយ លោកទើបអធិប្បាយប្រកបដោយបទថា **បវត្តំ** នោះ **ឋិតិ** ស័ព្ទ ក្នុងការមិនមានក្នុងទីនេះ ព្រោះ **ឋិតិ** ស័ព្ទ សូម្បីក្នុងការៈក៏សម្រេចបាន ។ ដើម្បីសម្តែងថា **ឋិតិ** ស័ព្ទ ប្រព្រឹត្តទៅក្នុងសេចក្តីថា **ហេតុ** លោកទើបពោលថា **និមិត្តដ្ឋិត** អធិប្បាយថា **ឋិតិ** ។ មិនមែនត្រឹមតែជាគ្រឿងកំណត់តែម្យ៉ាង ដែលពិតព្រះសារីបុត្តកាលនឹងសម្តែងភាពជាអ្នកអាចក្នុងបច្ច័យថា រមែងប្រមូលមក រមែងព្យាយាម ដូចជាមានសេចក្តីខ្វល់ខ្វាយក្នុងការឲ្យកើតសង្ខារ ទើបពោលថា **អាយូហនដ្ឋិតិ** អធិប្បាយថា **ឋិតិ** ជាហេតុប្រមូលមក ។ ព្រោះអវិជ្ជាឲ្យសង្ខារកើតឡើង ឈ្មោះថាប្រកបក្នុងការកើត អធិប្បាយថា **ព្យាយាម** , អវិជ្ជាឲ្យសង្ខារប្រព្រឹត្តទៅ ឈ្មោះថា ពាក់ព័ន្ធក្នុងការប្រព្រឹត្តទៅ , អធិប្បាយថា ចងព័ន្ធ ដូច្នោះលោកទើបពោលថា សញ្ញោគដ្ឋិតិ ជាហេតុប្រកបទុក **បលិពោធដ្ឋិតិ** ជាហេតុពាក់ព័ន្ធ អធិប្បាយថា ជាហេតុប្រកប ជាហេតុកង្វល់ ។

ព្រោះអវិជ្ជាឲ្យសង្ខារកើតឡើង ឈ្មោះថា **សមុទ័យ** ព្រោះអត្ថថា ជាមូលហេតុនៃការកើត និងការប្រព្រឹត្តទៅ , ឈ្មោះថា **សមុទយឋិតិ** ព្រោះជាហេតុឲ្យកើត អធិប្បាយថា ជាមូលហេតុ ។ អវិជ្ជានោះឯង លោកពោលថា **ហេតដ្ឋិតិ** ជាហេតុដើម , **បច្ចយដ្ឋិតិ** ជាហេតុក្នុងការប្រព្រឹត្តទៅ ព្រោះជាហេតុក្នុងការឲ្យកើតនៃសង្ខារ , ព្រោះជាបច្ច័យ ឧបត្ថម្ភក្នុងការប្រព្រឹត្តទៅ អធិប្បាយថា **ឋិតិ** ជាដើមហេតុ , **ឋិតិ** លោកពោល ជនកប្បច្ច័យ ជាហេតុ , ឧបត្ថម្ភកប្បច្ច័យ ជាគ្រឿងអាស្រ័យ ។ សូម្បីក្នុងបទដ៏សេស ក៏គប្បីប្រកបយ៉ាងនេះ ។

ក្នុងបទនេះថា **ភវោ ជាតិយា ជាតិ ជរាមរណស្ស** ភព ជាបច្ច័យដល់ជាតិ , ជាតិជាបច្ច័យដល់ជរាមរណៈ លោកពោលដល់បទដែលប្រកបដោយអំណាចការកើតថា **ឧប្បាទដ្ឋិតិ សញ្ញោគដ្ឋិតិ ហេតដ្ឋិតិ** ដោយបរិយាយ ដោយអំណាចនៃខន្ធទាំងឡាយ មានជាតិ ជរា និងមរណៈ , តែអាចារ្យពួកខ្លះ ពណ៌នាសេចក្ដីក្នុងបទនេះ ដោយន័យមានជាអាទិ៍ថា **ឧប្បាទាយ ឋិតិ ឧប្បាទដ្ឋិតិ** ហេតុនៃការកើត ឈ្មោះថា **ឧប្បាទដ្ឋិតិ** ជាហេតុកើត ។ បទថា



**អវិជ្ជា បច្ចយោ** អវិជ្ជាជាបច្ច័យ លោកពោលដល់អវិជ្ជាជាបច្ច័យនៃសង្ខារទាំងឡាយ ។

ម្យ៉ាងទៀត ដើម្បីសម្ដែងការកំណត់អវិជ្ជានោះ ជាបច្ច័យ ព្រោះសូម្បីអវិជ្ជា ក៏កើតព្រោះបច្ច័យ លោកទើបពោលថា **ឧភោបេតេ ធម្មា បច្ចយសមុប្បន្នាតិ បច្ចយបរិគ្គហេ បញ្ញា** បញ្ញាក្នុងការកំណត់បច្ច័យថា សូម្បីធម៌ទាំង ២ យ៉ាងនេះ ក៏កើតឡើងពីបច្ច័យ ។ សូម្បីក្នុងបទដ៏សេសក៏គប្បីប្រកបយ៉ាងនេះ ។ ចំណែកបទថា **ជាតិ បច្ចយោ , ជរាមរណំ បច្ចយសមុប្បន្នំ** ជាតិជាបច្ច័យ , ជរា និងមរណៈ ក៏កើតឡើងពីបច្ច័យ លោកពោលទុកដោយបរិយាយ បទថា **អតីតម្បិ អទ្ធានំ** កាលដែលកន្លងទៅហើយ ។ បទថា **អនាគតម្បិ អទ្ធានំ** បានដល់ កាលដែលនៅមិនទាន់មកដល់ ។ សូម្បីក្នុងបទទាំង ២ ក៏ជាទុតិយាវិភត្តិចុះក្នុងអត្ថនៃអច្ចន្តសំយោគ គឺ ប្រើអាយតនិបាតថា **អស់** ។

ឥឡូវនេះ ព្រះសារីបុត្តលះអាការ ៩ ទាំងនោះ ក្នុងលំដាប់វារៈនៃអាការ ៩ ហើយប្រកបដោយបទនៃបច្ច័យ អាស្រ័យហេតុហើយបង្ហាញវារៈ ៣ មានជាអាទិ៍ថា **អវិជ្ជាហេតុ , សង្ខារា**

**ហេតុសមុប្បន្ន** អវិជ្ជាជាហេតុ សង្ខារទាំងឡាយអាស្រ័យហេតុកើតឡើង ក្នុងវារៈនៃអាការ ៩ លោកពោលបច្ច័យ ដោយអំណាចជាជនកឧបត្ថម្ភកប្បច្ច័យ បច្ច័យដែលឧបការៈឲ្យកើត , ក្នុងទីនេះបទថា **ហេតុ** បានដល់ ភាពជាជនកប្បច្ច័យ ព្រោះហេតុវារៈ និងបច្ចយវារៈ មានសេចក្ដីផ្សេងគ្នា ។ បទថា **បច្ចយោ** គប្បីជ្រាបថាភាពជាឧបត្ថម្ភកប្បច្ច័យ ព្រោះបច្ច័យ មានអវិជ្ជាជាដើម សូម្បីមួយ ៗ ក៏កើតដោយប្រការទាំង ២ ។

គប្បីជ្រាបការវិនិច្ឆ័យក្នុងបដិច្ចវារៈ ដូចតទៅនេះ បទថា **អវិជ្ជា បដិច្ច** អវិជ្ជាអាស្រ័យបច្ច័យប្រព្រឹត្តទៅ សេចក្ដីថា អវិជ្ជាឈ្មោះថា **បដិច្ច** ព្រោះត្រូវទៅដោយចំពោះមុខនៃសង្ខារទាំងឡាយព្រោះសម្លឹងឃើញអវិជ្ជា ជាហេតុនៃសង្ខារទាំងឡាយក្នុងការកើតរបស់ខ្លួន ។ ចំណែកបទនេះ លោកពោលដល់សភាពនៃអវិជ្ជាដែលអាចឲ្យសង្ខារកើតឡើង ។

បទថា **សង្ខារា បដិច្ចសមុប្បន្នា** អាស្រ័យអវិជ្ជាកើតឡើងសេចក្ដីថា សង្ខារទាំងឡាយមិនបានកើតឡើងដោយមិនបានអាស្រ័យអ្វីនោះទេ ព្រោះត្រូវអាស្រ័យអវិជ្ជា ទើបកើតឡើងប្រព្រឹត្តទៅ ។



សូម្បីបទដ៏សេស ក៏គប្បីប្រកបតាមសមគួរដល់លិង្គយ៉ាងនេះ ។ម្យ៉ាងទៀត បាឋៈថា **អវិជ្ជា បដិច្ច** អវិជ្ជាអាស្រ័យបច្ច័យប្រព្រឹត្តទៅដោយអំណាចការខ្វល់ខ្វាយ តែសេចក្ដីក្នុងបទនេះ គប្បីប្រកបដោយបាឋៈដ៏សេសថា អវិជ្ជាអាស្រ័យបច្ច័យរបស់ខ្លួនប្រព្រឹត្តទៅ ។សូម្បីក្នុងបទដ៏សេសក៏យ៉ាងនោះ ។ ក្នុងវារៈសូម្បី ៤ យ៉ាងទាំងនេះ លោកបង្ហាញនូវធម្មដ្ឋិតិញ្ញាណដោយអំណាចនៃអង្គ ១១មានអវិជ្ជាជាដើម ព្រោះធម្មដ្ឋិតិញ្ញាណបានបង្ហាញច្បាស់ដោយអំណាចបច្ច័យនៃអង្គបដិច្ចសមុប្បាទ ១២ ។ តែលោកមិនបានបង្ហាញដោយអំណាចជរាមរណៈនោះ ព្រោះជរាមរណៈតាំងនៅក្នុងទីបំផុត ។ ធម្មដ្ឋិតិញ្ញាណ ដោយអំណាចជរាមរណៈនោះធ្វើជរាមរណៈឲ្យជាបច្ច័យនៃអង្គបដិច្ចសមុប្បាទទាំងនោះ ហើយពិចារណាទៅគួរ ព្រោះសូម្បីជរា និងមរណៈ ក៏ជាបច្ច័យនៃសោកៈបរិទេវៈ ទុក្ខៈ ទោមនស្សៈ និងឧបាយាសៈ ។

ឥឡូវនេះ ព្រះសារីបុត្តបំណងនិងចែកអង្គបដិច្ចសមុប្បាទ ១២ ទាំងនោះ ទើបសម្ដែងសង្ខេប ៤ , កាល ៣ , សន្ធិ ៣ , ដោយអាការ ២០ ហើយទើបបង្ហាញធម្មដ្ឋិតិញ្ញាណ លោកពោល

បទមានអាទិ៍ថា **បុរិមកម្មភវស្មឹ** ក្នុងកម្មភពមុន ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **បុរិមកម្មភវស្មឹ** បានដល់ ក្នុងកម្មភពមុន , អធិប្បាយថា កាលធ្វើកម្មភពក្នុងអតីតជាតិ ។

បទថា **មោហោ អវិជ្ជា** មោហៈ គឺ អវិជ្ជា សេចក្តីថា វង្វេងដោយមោហៈក្នុងទុក្ខជាដើម ហើយធ្វើកម្ម , នុ៎ះ គឺ អវិជ្ជា ។

បទថា **អាយូហនា សង្ខារា** កម្មដែលប្រមូលមក គឺ **សង្ខារ** សេចក្តីថា ចេតនាមុនរបស់អ្នកធ្វើកម្មនោះ , ចេតនាមុនកើតឡើងដល់អ្នកគិតថា យើងនឹងឲ្យទាន ដូច្នេះ ហើយលះបង់ឧបករណ៍ឲ្យមួយខែខ្លះ មួយឆ្នាំខ្លះ ។

**ចេតនា** លោកពោលថា **ភព** ។ ព្រោះដាក់ទក្ខិណាទុកលើដៃនៃបដិគ្គាហកៈ ។ ចេតនាក្នុងអាវជ្ជនៈ ១ ឬក្នុងជវន ៦ ឈ្មោះថា កម្មដែលប្រមូលមក គឺ សង្ខារ ។ ចេតនាក្នុងជវនៈទី ៧ ជាភព ។ ម្យ៉ាងទៀត ចេតនាណាមួយក៏គឺ ភព , ឈ្មោះថា ការប្រមូលមក ជាសង្ខារ ព្រោះសម្បយុត្តដោយចេតនានោះ ។

បទថា **និកន្តិ តណ្ហា** សេចក្តីប្រាថ្នា គឺ តណ្ហា សេចក្តីថា



សេចក្តីប្រាថ្នា សេចក្តីត្រូវការក្នុងឧប្បត្តិភព ដែលជាផលនៃអ្នកធ្វើកម្ម ឈ្មោះថា **តណ្ហា** ។

បទថា **ឧបគមនំ ឧបាទានំ** ការចូលដល់ គឺ ឧបាទាន សេចក្តីថា ការចូលដល់ គឺ ការប្រកាន់មាំ ដែលជាបច្ច័យនៃកម្មភពប្រព្រឹត្តទៅហើយថា កាលធ្វើកម្មនេះ នឹងសម្រេចតាមបំណង ដូច្នេះក្តី យើងធ្វើកម្មនេះហើយ និងបានសោយផលកម្មក្នុងឋានៈឯណោះ ដូច្នេះក្តី **អត្ត** គឺ តួខ្លួនដាច់សូន្យ ដាច់សូន្យដោយល្អហើយក្តី មានសេចក្តីសុខប្រាសចាកសេចក្តីក្តៅក្រហាយក្តី បំពេញសីលវត្តបានដោយងាយស្រួលក្តី នេះឈ្មោះថា **ឧបា-ទាន** ។

បទថា **ចេតនា ភវោ** គឺ ភព បានដល់ ចេតនាដូចពោលហើយ ក្នុងទីបំផុតនៃការប្រមូលមក ឈ្មោះថា **ភព** ។

បទថា **បុរិមកម្មភវស្មឹ** ក្នុងកម្មភពមុន បានដល់ កាលធ្វើកម្មភពទុកក្នុងអតីតជាតិ ធម៌ទាំងនេះប្រព្រឹត្តទៅហើយ ។ បទថា **ឥធ បដិសន្ធិយា បច្ចយា** នេះជាបច្ច័យនៃបដិសន្ធិក្នុងភពនេះ បានដល់ ជាបច្ច័យនៃបដិសន្ធិក្នុងបច្ចុប្បន្ន ។

បទថា **ឥធ បដិសន្ធិ វិញ្ញាណំ បដិសន្ធិ** បដិសន្ធិ គឺ វិញ្ញាណក្នុងភពនេះ បានដល់ វិញ្ញាណដែលលោកពោលថា ជា **បដិសន្ធិ** ព្រោះភពបច្ចុប្បន្នកើតឡើងដោយអំណាចនៃការជាប់បន្តគ្នាក្នុងរវាងភពនោះ ឈ្មោះថា **វិញ្ញាណ** ។

បទថា **ឱក្កន្តិ នាមរូបំ** បានដល់ ការឈានចុះ គឺ នាមរូប បានដល់ ការឈានចុះក្នុងគភ៌នៃរូបធម៌ និងអរូបធម៌ ដូចពោលមកហើយ នេះឈ្មោះថា **នាមរូប** ។

បទថា **បសាទោ អាយតនំ** បសាទ គឺ ភាពថ្លាជា អាយតនៈ បានដល់ រូបដែលថ្លា នេះជាអាយតនៈ ។ លោកធ្វើជាឯកវចនៈដោយកាន់យកជាតិ ។ ក្នុងបទនេះ លោកពោលដល់អាយតនៈ ៥ មានចក្ខុជាដើម ។ គប្បីជ្រាបថា សូម្បីមនាយតនៈលោកក៏ពោលដោយពាក្យថា **បសាទ** ព្រោះមនាយតនៈជាវិបាកក្នុងទីនេះ ដោយព្រះបាលីថា **បភស្សរមិទំ ភិក្ខវេ ចិត្តំ , តញ្ច ខោ អាគន្តុកេហិ ឧបក្កិលេសេហិ** ម្នាលភិក្ខុទាំងឡាយ ចិត្តនេះបរិសុទ្ធ , ក៏ចិត្តនោះឯងសៅហ្មងដោយឧបក្កិលេសដែលចរមកដូច្នេះ ក្នុងព្រះបាលីនេះ លោកបំណងយកភវង្គចិត្ត , នឹងព្រោះ



ចិត្តនោះថ្លា ព្រោះការមិនមានវត្ថុបដិកូលដោយកិលេស ។

បទថា **ផុដ្ឋោ ផស្សោ** ការពាល់ត្រូវ គឺ ផស្សៈ បានដល់ ការប៉ះខ្ទប់ នេះឈ្មោះថា **ផស្ស** ។

បទថា **វេទយិតំ វេទនា** ការសោយអារម្មណ៍ គឺ វេទនា បានដល់ ការសោយវិបាកកើតរួមជាមួយផស្សៈ ដោយបដិសន្ធិវិញ្ញាណក្តី ដោយសឡាយតនៈជាបច្ច័យក្តី នេះឈ្មោះថា **វេទនា** ។

បទថា **ឥធុប្បត្តិភវស្មឹ បុរេកតស្ស កម្មស្ស បច្ចយា** ធម៌ ៥ ប្រការក្នុងកម្មភពមុន ជាបច្ច័យដល់បដិសន្ធិក្នុងឧប្បត្តិភពនេះ សេចក្តីថា ធម៌ទាំងឡាយរមែងប្រព្រឹត្តទៅដោយបច្ច័យរបស់កម្មដែលធ្វើទុកក្នុងអតីតជាតិ ដែលជាវិបាកភពក្នុងបច្ចុប្បន្ន ។

បទថា **ឥធ បរិបក្កត្តា អាយតនានំ** ព្រោះអាយតនៈទាំងឡាយក្នុងភពនេះដល់ការចាស់ក្លា កាលលោកសម្តែងមោហៈជាដើម ក្នុងការធ្វើកម្មរបស់អ្នកមានអាយតនៈដល់ការចាស់ក្លា ។

បទថា **អាយតឹ បដិសន្ធិយា** គឺ ជាបច្ច័យដល់បដិសន្ធិក្នុងអនាគត ។ បទមានជាអាទិ៍ថា **អាយតឹ បដិសន្ធិ វិញ្ញាណំ** បដិសន្ធិក្នុងអនាគត គឺ វិញ្ញាណ មានអត្ថដូចពោលហើយ ។

លោកកាន់យកអាការ ២០ ទាំងនេះ ដោយអង្គនៃបដិច្ចសមុប្បាទ ១២ តើដូចម្ដេច ? លោកពោលធម៌ទាំង ២ នេះ ដោយសរុបថា **អវិជ្ជា សង្ខារា** ដូច្នេះថា ជាហេតុក្នុងអតីត ។ ក៏ព្រោះមិនដឹងច្បាស់ ទើបតក់ស្លុត , តក់ស្លុតហើយ រមែងប្រកាន់មាំ , ព្រោះការប្រកាន់មាំរបស់បុគ្គលនោះជាបច្ច័យ ទើបមានភព , ដូច្នោះទើបជាចំណែកដែលលោកកាន់យក សូម្បីតណ្ហា ឧបាទាន និងភព ដោយការកាន់យកធម៌ទាំង ២ គឺ អវិជ្ជា និងសង្ខារ ទាំងនោះផង ។ លោកពោលដល់វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ និងវេទនា ក្នុងបច្ចុប្បន្នដោយសរុប ។ លោកពោល តណ្ហា ឧបាទាន និងភព ថាជាហេតុ ក្នុងបច្ចុប្បន្នដោយសរុប , កាលកាន់យកភពហើយ ក៏ជាចំណែកកាន់យកសង្ខារទាំងឡាយ ជាចំណែកខាងដើម នៃភពនោះ ឬសម្បយុត្តដោយភពនោះ ។ ម្យ៉ាងវិញទៀត សង្ខារទាំងឡាយសម្បយុត្តដោយភពនោះ ដោយការកាន់យកតណ្ហា និងឧបាទាន ។ ម្យ៉ាងវិញទៀត លោកកាន់យកតណ្ហា ដែលបុគ្គលឈ្លក់វង្វេងធ្វើកម្មថា ជាអវិជ្ជា ។ លោកពោលធម៌ទាំង ២ គឺ ជាតិ ជរា មរណ



ក្នុងអនាគតដោយសរុប , ដោយការកាន់យកជាតិ ជរា មរណៈនោះឯង ទើបជាចំណែកដែលលោកកាន់យកផល ក្នុងអនាគត ៥ មានវិញ្ញាណជាដើមនោះឯង ។ ជាចំណែកលោកកាន់យកអាការ ២០ ដោយអង្គ ១២ នៃបដិច្ចសមុប្បាទទាំងនោះ ។ ដោយបទថា **ជាតិជរាមរណាទិ** ដោយប្រការដូច្នេះ ។

**អតីតេ ហេតុយោ បញ្ច ឥទានិ ផលបញ្ចកំ**
**ឥទានិ ហេតុយោ បញ្ច អាយតឹផលបញ្ចកំ ។**

អាការ ២០ នៃបច្ចយាការ គឺ ធម៌ជាអតីតហេតុ ៥ យ៉ាង ធម៌ជាបច្ចុប្បន្នផល ៥ យ៉ាង ធម៌ជាបច្ចុប្បន្នហេតុ ៥ យ៉ាង ធម៌ជាអនាគតផល ៥ យ៉ាង ។

លោកពោលសេចក្ដីនៃគាថានោះទុកហើយ , បទថា **ឥតិមេ** ចែកជាបទ **ឥតិ មេ** ។ បាឋៈថា **ឥតិ ឥមេ** ។

បទថា **ចតុសង្ខេប** មានសង្ខេប ៤ បានដល់ មានកង ៤ ។

ធម៌ជាហេតុ ៥ យ៉ាង ក្នុងអតីត ហៅថា ហេតុសង្ខេប ១ ។ ធម៌ជាផល ៥ យ៉ាង ក្នុងបច្ចុប្បន្ន ហៅថា ផលសង្ខេប ១ ។ ធម៌ជាហេតុ ៥ យ៉ាង ក្នុងបច្ចុប្បន្ន ហៅថា ហេតុសង្ខេប ១ ។

ធម៌ជាផល ៥ យ៉ាង ក្នុងអនាគត ហៅថា ផលសង្ខេប ១ ។

បទថា **តយោ អទ្ធេ** បានដល់ ក្នុងកាល ៣ ។ អតីតកាល គប្បីជ្រាបថា ដោយអំណាចបពា្វកៈ គឺ ធម៌ពួក ៥ ទី ១ , បច្ចុប្បន្នកាល គប្បីជ្រាបថា ដោយអំណាចបពា្វកៈទី ២ ទី ៣ , អនាគតកាល គប្បីជ្រាបថា ដោយអំណាចបពា្វកៈទី ៤ ។

បទថា **តិសន្ធិ** សន្ធិ ៣ ឈ្មោះថា **តិសន្ធិ** អត្ថថា មានសន្ធិ ៣ , ដែលបសន្ធិ ៣ នោះ អធិប្បាយថា ហេតុផលសន្ធិ ១ មានក្នុងរវាងនៃហេតុអតីត និងផលបច្ចុប្បន្ន , ផលហេតុសន្ធិ ១ ក្នុងរវាងនៃផលបច្ចុប្បន្ន និងហេតុអនាគត , ហេតុផលសន្ធិ ១ ក្នុងរវាងនៃហេតុបច្ចុប្បន្ន និងផលអនាគត ។

ប៉ុន្តែដោយអំណាចពោលមកហើយ ដោយសរុបក្នុងបដិ-ច្ចសមុប្បាទបាលីមានដូច្នេះ **អវិជ្ជា សង្ខារា** ជាសង្ខេបទី ១ ។ **វិញ្ញាណ នាមរូប សឡាយតន ផស្ស** និង **វេទនា** ជាសង្ខេបទី ២ ។ **តណ្ហា ឧបាទាន ភព** ជាសង្ខេបទី ៣ ។ **ជាតិ ជរា មរណ** ជាសង្ខេបទី ៤ ។

អង្គ ២ គឺ អវិជ្ជា និងសង្ខារ ជាអតីតកាល , ធម៌ ៨ មាន



វិញ្ញាណជាដើម មានភពជាទីបំផុត ជាបច្ចុប្បន្នកាល , អង្គ ២ គឺ ជាតិ និងជរាមរណៈ ជាអនាគតកាល , ហេតុផលសន្ធិ ១ មានក្នុងរវាងនៃសង្ខារ និងវិញ្ញាណ , ផលហេតុសន្ធិ ១ មានក្នុងរវាងនៃវេទនា និងតណ្ហា , ហេតុផលសន្ធិ ១ មានក្នុងរវាងនៃភព និងជាតិ ។

បទថា វីសតិយា អាការេហិ ដោយចំណែក ២០ ។ គប្បីភ្ជាប់សេចក្តីថា ព្រះយោគាវចរ រមែងដឹងបដិច្ចសមុប្បាទ មានសង្ខេប ៤ កាល ៣ សន្ធិ ៣ ដោយអាការ ២០ ដូច្នេះ ។

បទថា **ជានាតិ** រមែងដឹងដោយញាណ គឺ ការផ្តើមវេទនាដោយទំនងដូចគ្នា និងសុត្តៈ គឺ ការស្តាប់ ។

បទថា **បស្សតិ** បានដល់ រមែងឃើញវត្ថុ ដែលដឹងហើយដោយញាណ ដូចឃើញដោយភ្នែក និងធ្វើឲ្យត្រឹមត្រូវហើយ ដូចផ្លែកន្ទួតព្រៃនៅលើបាតដៃ ។

បទថា **អញ្ញាតិ** រមែងដឹងទូទៅ បានដល់ ធ្វើអាសេវនៈដោយអាការដែលឃើញហើយ ឈ្មោះថា រមែងដឹងដោយញាណ ។ សេចក្តីនៃសព្ទថា **មរិយាទ** ក្នុងទីនេះ គឺ **អាការ** ។

បទថា **បដិវិជ្ឈតិ** រមែងចាក់ធ្លុះ បានដល់ ឲ្យដល់ការសម្រេច ដោយការបំពេញភាវនា ឈ្មោះថា ធ្វើការចាក់ធ្លុះដោយញាណ ។ ម្យ៉ាងទៀត រមែងដឹងដោយអំណាចនៃលក្ខណៈ , រមែងឃើញដោយអំណាចការប្រព្រឹត្តទៅដោយកិច្ច , រមែងដឹងទូទៅដោយអំណាចនៃអាការប្រាកដ , រមែងចាក់ធ្លុះដោយអំណាចនៃបទ-ដ្ឋាន ។

ក្នុងបទទាំងនោះ បទថា **បដិច្ចសមុប្បាទោ** គប្បីជ្រាបថា បានដល់ ធម៌ជាបច្ច័យ ។

បទថា **បដិច្ចសមុប្បន្នា ធម្មា** បានដល់ ធម៌ដែលកើតឡើងដោយបច្ច័យនោះ ៗ ។ បើសួរថា ដឹងបានដូចម្ដេច ? ឆ្លើយថា ដោយព្រះពុទ្ធវចនៈ ។ ព្រោះព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកក្នុងទេសនាសូត្រ ដែលបណ្ឌិតកំណត់ដោយបដិច្ចសមុប្បាទ និងបដិច្ចសមុប្បន្នធម៌ថា ៖

**កតមោ ច ភិក្ខវេ បដិច្ចសមុប្បាទោ , ។បេ។**

**អយំ វុច្ចតិ ភិក្ខវេ បដិច្ចសមុប្បាទោ ។**

ម្នាលភិក្ខុទាំងឡាយ បដិច្ចសមុប្បាទតើដូចម្ដេច ?



ព្រោះជាតិជាបច្ច័យ ទើបមានជរាមរណៈ , ព្រះតថាគតទ្រង់ឧប្បត្តិឡើងក៏ដោយ ទ្រង់មិនទាន់ឧប្បត្តិក៏ដោយ ធាតុនោះជាធម្មដ្ឋិតិ តាំងនៅជាធម្មតា ជាធម្មនិយាម ការពិតប្រាកដនៅដោយធម្មតា ជាឥទប្បច្ចយតា ការអាស្រ័យគ្នាកើតឡើង តាំងនៅ , ព្រះតថាគតទ្រង់ត្រាស់ដឹង និងចាក់ធ្លុះធម៌ទាំងនោះ , គ្រាត្រាស់ដឹងហើយ ចាក់ធ្លុះហើយ ទ្រង់ប្រាប់ ទ្រង់សម្ដែង ទ្រង់បញ្ញត្តិ ទ្រង់តាំងទុក ទ្រង់បើកបង្ហាញ ទ្រង់ចំណែក ទ្រង់ធ្វើឲ្យងាយ ត្រាស់ថា ពួកអ្នកចូរឃើញ ដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះជាតិជាបច្ច័យ ទើបមានជរា និងមរណៈ , ព្រោះភពជាបច្ច័យ ទើបមានជាតិ ។បេ។ ព្រោះអវិជ្ជាជាបច្ច័យ ទើបមានសង្ខារ ។ ព្រះតថាគតទ្រង់ឧប្បត្តិក៏ដោយ ទ្រង់មិនទាន់ឧប្បត្តិក៏ដោយ ។បេ។ រមែងធ្វើឲ្យងាយ ត្រាស់ថា ពួកអ្នកចូរឃើញដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះអវិជ្ជាជាបច្ច័យ ទើបមានសង្ខារ ។ ម្នាលភិក្ខុទាំងឡាយ ដោយប្រការដូច្នេះឯង នេះសេចក្ដីពិត មិនជាយ៉ាងដទៃ ឈ្មោះថា គឺវត្ថុនេះជាបច្ច័យនៃវត្ថុនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះឈ្មោះថា **បដិច្ចសមុប្បាទ** ។

ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងបដិច្ចសមុប្បាទ យ៉ាងនេះ ទើបត្រាស់ថា ធម៌ជាបច្ច័យនោះឯង ឈ្មោះថា **បដិច្ចសមុប្បាទ** ដោយវេចនៈមានពាក្យថា **តថតា** សភាពជាការពិតជាដើម ។ ព្រោះដូច្នោះ បដិច្ចសមុប្បាទ ទើបមានភាពជាបច្ច័យដល់ធម៌ទាំងឡាយ មានជរា និងមរណៈជាដើម ជាលក្ខណៈ , មានការពាក់ព័ន្ធជាមួយទុក្ខ ជាកិច្ច , មានការដើរខុសផ្លូវ ជាផល , មានបច្ច័យពិសេសនៃខ្លួន ជាហេតុជិត ព្រោះសូម្បីខ្លួនឯង ក៏មានបច្ច័យ ។

បទថា **ឧប្បាទា វា អនុប្បាទា វា** បានដល់ កាលឧប្បត្តិក៏ដោយ មិនទាន់ឧប្បត្តិក៏ដោយ អធិប្បាយថា កាលព្រះតថាគតសូម្បីឧប្បត្តិហើយ សូម្បីនៅមិនទាន់ឧប្បត្តិ ដូច្នេះ ។

បទថា **ឋិតា វ សា ធាតុ** សភាពនៃបច្ច័យនោះ តាំងនៅ អធិប្បាយថា ក្នុងកាលណា ៗ នឹងមិនមានបច្ច័យនៃជាតិ ជរា និងមរណៈ មិនមានឡើយ ។

បទថា **ធម្មដ្ឋិតតា ធម្មនិយាមតា ឥទប្បច្ចយតា** មានជាតិជាបច្ច័យនោះឯង ។ ធម៌កើតឡើងព្រោះបច្ច័យ ពោលគឺ ជរា



និងមរណៈ រមែងតាំងនៅបាន ព្រោះអាស្រ័យធម៌នោះ ព្រោះជាតិជាបច្ច័យ , ជាតិជាបច្ច័យ រមែងកំណត់ធម៌ គឺ ជរា និងមរណៈ , ព្រោះដូច្នោះ ជាតិ លោកពោលថា **ធម្មដ្ឋិតតា ធម្មនិយាមតា** ដូច្នេះ ។ ជាតិនោះឯង ជាបច្ច័យនៃជរា និងមរណៈនេះ ព្រោះដូច្នោះ ទើបឈ្មោះថា **ឥទប្បច្ចយោ** , **ឥទប្បច្ចយោ** នោះឯង ឈ្មោះថា ឥទប្បច្ចយតា ។

បទថា **តំ** គឺ បច្ច័យនោះ ។ បទថា **អភិសម្ពុជ្ឈតិ** គឺ រមែងត្រាស់ដឹងដោយញាណ ។ បទថា **អភិសមេតិ** គឺ រមែងចាក់ធ្លុះដោយញាណ ។ បទថា **អាចិក្ខតិ** រមែងពោល ។ បទថា **ទេសតិ** គឺ រមែងសម្តែង ។ បទថា **បញ្ញាបេតិ** គឺ រមែងឲ្យដឹង ។ បទថា **បដ្ឋបេតិ** រមែងតាំងនៅក្នុងមាតិកា គឺ ញាណ ។ បទថា **វិវរតិ** គឺ រមែងទ្រង់បើកសម្តែង ។ បទថា **វិភជតិ** គឺ រមែងទ្រង់ចំណែក ។ បទថា **ឧត្តានីករោតិ** គឺ រមែងធ្វើឲ្យប្រាកដ ។ បទថា **ឥតិ ខោតិ** គឺ ដោយប្រការដូច្នេះឯង ។ បទថា **យា តត្រ** បានដល់ ភាពជារបស់ពិតប្រាកដ មិនប្រែប្រួល ដូចក្នុងបទមានជាអាទិ៍ថា **ជាតិប្បច្ចយា ជរាមរណំ** ព្រោះជាតិជាបច្ច័យ ទើបមាន

ជរា និងមរណៈ ។

ក្នុងបដិច្ចសមុប្បាទនេះ លោកពោលថា **តថតា** សភាពពិត ព្រោះធម៌នោះ ៗ កើតដោយមិនខ្វះមិនលើស ដោយបច្ច័យនោះ ៗ , លោកពោល **អវិតថតា** ភាពពិតប្រាកដ ព្រោះមិនមានការមិនកើតនៃធម៌ ដែលកើតពីធម៌នោះ សូម្បីមួយរំពេចក្នុងបច្ច័យ ដែលចូលដល់សេចក្ដីព្រមព្រៀង , លោកពោលថា **អនញ្ញថតា** ភាពមិនជាយ៉ាងដទៃ ព្រោះមិនមានធម៌ដទៃកើតឡើងដោយបច្ច័យនៃធម៌ដទៃ , លោកពោលថា **ឥទប្បច្ចយតា** ភាពជាបច្ច័យនៃធម៌នេះ ព្រោះជាបច្ច័យដល់ជរា និងមរណៈជាដើមទាំងនេះ ឬព្រោះជាទីរួមបច្ច័យ ។

ក្នុងបទនោះមានអធិប្បាយ ពាក្យដូចតទៅនេះ បច្ច័យនៃធម៌ទាំងនោះ ឈ្មោះថា **ឥទប្បច្ចយា** , **ឥទប្បច្ចយា** នោះឯងឈ្មោះថា **ឥទប្បច្ចយតា** , ម្យ៉ាងទៀត ការរួម **ឥទប្បច្ចយា** ទាំងឡាយ ឈ្មោះថា **ឥទប្បច្ចយតា** ។ តែក្នុងទីនេះ គប្បីជ្រាបលក្ខណៈ ដោយអត្ថនៃស័ព្ទ ។

( ចប់អដ្ឋកថា ធម្មដ្ឋិតិញ្ញាណនិទ្ទេស )



# អដ្ឋកថា សម្មសនញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ ក្នុងសម្មសនញ្ញាណនិទ្ទេស ដូចតទៅនេះ បទថា **យំកិញ្ចិ** គឺ ការកំណត់កាន់យកមានសល់ ។ បទថា **រូបំ** បានដល់ កំណត់ដោយសេចក្ដីបំណងដ៏ក្រៃលែង ។ លោកធ្វើការកំណត់ដោយមិនមានសល់នូវរូប សូម្បីដោយបទទាំងពីរយ៉ាងនេះ ។ បើដូច្នោះ ព្រះយោគាវចរ រមែងប្រារព្ធការចែកដោយបទមានជាអាទិ៍ថា **អតីត** នៃរូបនោះ ។ រូបនោះ រូបខ្លះជាអតីត រូបខ្លះមានប្រភេទជាអនាគតជាដើម ។ សូម្បីក្នុងវេទនាជាដើម ក៏មានន័យនេះ ។ **រូប** ក្នុងបទនោះឈ្មោះថា ជាអតីត ៤ យ៉ាង ដោយអំណាចនៃកាល ការបន្ត សម័យ និងខណៈ , រូបអនាគត និងបច្ចុប្បន្ន ក៏ដូច្នោះ ។

ក្នុងរូបទាំងនោះ គប្បីជ្រាបដោយអំណាចកាល ជាមុនបានដល់ រូបក្នុងអតីត មុនអំពីបដិសន្ធិក្នុងភពមួយរបស់រូប , រូបអនាគត បន្ទាប់អំពីចុតិ , រូបបច្ចុប្បន្ន ក្នុងចន្លោះរូបអតីត និងអនាគតទាំងពីរ ។

គប្បីជ្រាប រូបដោយអំណាចសន្តតិ បានដល់ រូបបច្ចុប្បន្ន សូម្បីប្រព្រឹត្តទៅហើយ ដោយការបន្តគ្នាមកអំពីមុន មានសមុដ្ឋានពីឧតុតែម្យ៉ាង ជាសភាគៈគ្នា និងមានសមុដ្ឋានពីអាហារតែម្យ៉ាង ។ រូបអតីត មានសមុដ្ឋានពីឧតុ និងអាហារ មិនជាសភាគៈគ្នាមុនអំពីនោះ , រូបអនាគត មានក្នុងខាងក្រោយ ។ រូបបច្ចុប្បន្ន មានសមុដ្ឋានពីវិថីចិត្តជួងតែមួយ ជវនចិត្តជួងតែមួយ និងសមាបត្តិតែមួយដែលកើតអំពីចិត្ត , រូបអតីតមុនពីនោះ , រូបអនាគតមានក្នុងចំណែកខាងក្រោយ ។ ប្រភេទនៃរូប មានរូបអតីតជាដើម រមែងមិនមានដោយអំណាចសន្តតិ ចំពោះកម្មជាសមុដ្ឋានតែម្យ៉ាង ។ គប្បីជ្រាប សភាពនៃរូបនោះ មានរូបអតីតជាដើម ដោយអំណាចការឧបត្ថម្ភនៃសមុដ្ឋានចាកពីឧតុ អាហារ និងចិត្តទាំងនោះ ។

គប្បីជ្រាបដោយអំណាចសម័យ បានដល់ រូបដែលមានសម័យនោះ ៗ ប្រព្រឹត្តទៅដោយអំណាចបន្តគ្នា ក្នុងសម័យទាំងឡាយ មានមួយស្របក់ វេលាព្រឹក វេលារសៀល កន្លះថ្ងៃ កន្លះយប់ជាដើម ឈ្មោះថា រូបបច្ចុប្បន្ន ។ មុនអំពីនោះ ជាអតីត ,



ក្រោយអំពីនោះ ជាអនាគត ។ គប្បីជ្រាបដោយអំណាចខណៈ រូបបច្ចុប្បន្នទាក់ទង ដោយ ៣ ខណៈ មានឧប្បាទខណៈជាដើម , តអំពីនោះ ជាអនាគត , មុនអំពីនោះជាអតីត ។ ម្យ៉ាងទៀត រូបអតីត មានកិច្ចដែលជាហេតុបច្ច័យកន្លងទៅហើយ , រូបបច្ចុ-ប្បន្ន មានកិច្ចដែលមានហេតុចប់ហើយ និងមានកិច្ចដែលមានបច្ច័យចប់ហើយ , រូបអនាគត ដល់ព្រមដោយកិច្ចទាំងពីរ ។ ឬថា រូបបច្ចុប្បន្ន កើតក្នុងខណៈកិច្ចរបស់ខ្លួន , រូបអនាគតតអំពីនោះ , រូបអតីត ក្រោយអំពីនោះ ។ ក្នុងបទនេះ កថាមានខណៈជាដើម ជាកថាដោយត្រង់ ដ៏សេសជាកថាដោយអម ។

បទថា **អជ្ឈត្តំ** ក្នុងទីនេះ លោកបំណងយករូបខាងក្នុងរបស់ខ្លួនឯង , ព្រោះដូច្នោះគប្បីជ្រាបថា រូបចំពោះបុគ្គលប្រព្រឹត្តទៅក្នុងសន្តានរបស់ខ្លួន ឈ្មោះថា **អជ្ឈត្តំ** ។ រូបខាងក្រៅអំពីនោះ ដែលទាក់ទងជាមួយឥន្ទ្រីយ៍ក៏ដោយ មិនទាក់ទងជាមួយឥន្ទ្រីយ៍ក៏ដោយ ឈ្មោះថា **ពហិទ្ធា** ។

បទថា **ឱឡារិកំ** បានដល់ រូប ១២ យ៉ាង គឺ ចក្ខុ សោតៈ ឃានៈ ជិវ្ហា កាយ រូប សំឡេង ក្លិន រស និងផោដ្ឋព្វៈ ដែល

បានដល់ បឋវី តេជោ វាយោ ឈ្មោះថា **ឱឡារិក** ព្រោះគួរកាន់យកដោយអំណាចការបន្តគ្នា ។

ចំណែករូបដែលសល់ ១៦ យ៉ាង គឺ អាបោ ឥត្ថិន្ទ្រីយ៍ បុរិសិន្ទ្រីយ៍ ជីវិតិន្ទ្រីយ៍ ហទយវត្ថុ ឱជា អាកាសធាតុ កាយ-វិញ្ញត្តិ វចីវិញ្ញត្តិ រូបស្សលហុតា មុទុតាកម្មញ្ញតា ឧបចយៈ សន្តតិ ជរតា អនិច្ចតា ឈ្មោះថា **សុខុម** ព្រោះមិនគួរកាន់យកដោយអំណាចការបន្ត ។

គប្បីជ្រាប ភាពថោកទាប និងប្រណីត ក្នុងបទនេះថា **ហីនំ វា បណីតំ វា** ដោយអម ឬដោយត្រង់ ។ ក្នុងបទនោះ រូបរបស់ព្រហ្មជាន់សុទស្សី ជារូបថោកទាបជាងរូបរបស់ព្រហ្មជាន់អកនិដ្ឋ រូបជាន់ព្រហ្មសុទស្សីនោះ ៗ ឯង ប្រណីតជាងរូបរបស់ព្រហ្មជាន់សុទស្សា គប្បីជ្រាបសភាពថោកទាប និងប្រណីតដោយបរិយាយ រហូតដល់រូបរបស់សត្វនរក ។ រូបដែលជាអកុសលវិបាកកើតឡើង ជារូបថោកទាប , រូបដែលជាកុសល-វិបាកកើតឡើង ជារូបប្រណីត ។

គប្បីជ្រាបសេចក្តីក្នុងបទថា **យំ ទូរេ សន្តិកេ វា** នេះ



រូបណា **សុខុម** រូបនោះឯងឈ្មោះថា **ទូរេ** ព្រោះមានសភាពដឹងបានដោយលំបាក ។ រូបណា គ្រោតគ្រាត រូបនោះ ឈ្មោះថា **សន្តិកេ** ព្រោះមានសភាពដឹងបានងាយ ។

គប្បីជ្រាបសេចក្តីក្នុងបទនេះថា **សព្វំ រូបំ អនិច្ចតោ ववត្ថេតិ ឯកំ សម្មសនំ , ទុក្ខតោ ववត្ថេតិ ឯកំ សម្មសនំ , អនត្តតោ ववត្ថេតិ ឯកំ សម្មសនំ** ភិក្ខុកំណត់ដឹងរូបទាំងពួងថាជារបស់មិនទៀង ការកំណត់នេះ ជាសម្មសនញ្ញាណម្យ៉ាង , កំណត់ថាជាទុក្ខ ជាសម្មសនញ្ញាណម្យ៉ាង , កំណត់ថាជាអនត្តា ជាសម្មសនញ្ញាណម្យ៉ាង សេចក្តីថា ភិក្ខុនេះកំណត់រូបសូម្បីទាំងអស់ ដែលលោកចង្អុលទុក ដោយមិនបានកំណត់ពិតប្រាកដយ៉ាងនេះថា **យំកិញ្ចិ រូបំ** រូបណានីមួយ ដោយការប្រាកដ ១១ យ៉ាង គឺ ដោយរូបអតីតតិកៈ តិកៈក្នុងអតីត និងដោយទុកៈមានអជ្ឈត្តៈជាដើម ៤ ហើយកំណត់រូបទាំងពួងថា ជារបស់មិនទៀង រមែងពិចារណាថា **អនិច្ចំ** ដូច្នេះ ។ ពិចារណាយ៉ាងណា ? ពិចារណាដោយន័យដូចពោលហើយខាងមុខ ។

ដូចដែលព្រះសារីបុត្របានពោលទុកថា **រូបំ អតីតានាគត-**

**បច្ចុប្បន្នំ អនិច្ចំ ខយដ្ឋេន** រូបដែលជាអតីត អនាគត បច្ចុប្បន្ន ឈ្មោះថា មិនទៀង ព្រោះអត្ថថា អស់ទៅ ។ ព្រោះដូច្នោះ ភិក្ខុនោះរមែងពិចារណាថា រូបជាអតីតអស់ទៅក្នុងអតីតនោះឯង , រូបនោះមិនអាចមកដល់ភពនេះ ព្រោះហេតុនោះ ទើបឈ្មោះថា **អនិច្ចំ** ព្រោះអត្ថថា អស់ទៅ , រូបដែលជាអនាគត នឹងកើតក្នុងភពជាលំដាប់តទៅ , សូម្បីរូបនោះ ក៏អស់ទៅក្នុងភពនោះ នឹងមិនទៅកាន់ភពដទៃអំពីភពនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **អនិច្ចំ** ព្រោះអត្ថថា អស់ទៅ , រូបដែលជាបច្ចុប្បន្ន រមែងអស់ទៅក្នុងបច្ចុប្បន្ននោះឯង , រមែងមិនអស់ទៅអំពីនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **អនិច្ចំ** ព្រោះអត្ថថា អស់ទៅ , រូបដែលជាខាងក្នុង ក៏អស់ទៅក្នុងខាងក្នុងនោះឯង , មិនអស់ទៅកាន់ចំណែកខាងក្រៅ ព្រោះហេតុនោះ ទើបឈ្មោះថា **អនិច្ចំ** ព្រោះអត្ថថា អស់ទៅ ។ សូម្បីរូបខាងក្រៅគ្រោតគ្រាត និងល្អិតថោកទាប ប្រណីត មាននៅក្នុងទីឆ្ងាយ មាននៅក្នុងទីជិត ក៏អស់ទៅក្នុងទីនោះ ៗ ឯង ព្រោះហេតុនោះ ទើបឈ្មោះថា **អនិច្ចំ** ព្រោះអត្ថថា អស់ទៅ ។ សូម្បីការពិចារណាទាំងអស់នេះ



ក៏ជាសម្មសនញ្ញាណម្យ៉ាង ដោយអំណាចនៃបទនេះថា **អនិច្ចំ ខយដ្ឋេន** តែដោយប្រភេទមាន ១១ យ៉ាង ។

ម្យ៉ាងទៀត ភិក្ខុរមែងពិចារណារូបនោះទាំងអស់ថា **ទុក្ខំ ភយដ្ឋេន** ឈ្មោះថា ជាទុក្ខ ព្រោះងត្ថថា គួរខ្លាច ។ វត្ថុដែលមិនទៀង រមែងនាំមកនូវភ័យ ដូចភ័យរបស់ពួកទេព ក្នុងសីហូបមសូត្រ ។ សូម្បីការពិចារណានេះ ក៏ជាសម្មសនញ្ញាណមួយយ៉ាង ដោយអំណាចនៃរូបនេះថា **ទុក្ខំ ភយដ្ឋេន** តែដោយប្រភេទមាន ១១ យ៉ាង ។

ម្យ៉ាងទៀត ភិក្ខុរមែងពិចារណាថា រូបសូម្បីទាំងអស់នោះជាអនត្តា ព្រោះអត្ថថា រកខ្លឹមសារមិនបាន ដូចទុក្ខ ។ បទថា **អសារកដ្ឋេន** ព្រោះមិនមានសារៈក្នុងខ្លួន ដែលកំណត់ទុកយ៉ាងនេះថា **អត្តា** តួខ្លួន , និវាសី អ្នកអាស្រ័យ , **ការកោ** អ្នកធ្វើ , **វេទកោ** អ្នកសោយ , **សយំវសី** អ្នកមានអំណាចដោយខ្លួនឯង ។ វត្ថុណាមិនទៀង វត្ថុនោះក៏ជាទុក្ខ មិនអាចនឹងហាមសេចក្ដីមិនទៀង ឬការកើត ការវិនាស និងការបៀតបៀនរបស់ខ្លួនបាន , ជាអ្នកធ្វើជាដើមរបស់អ្នកនោះ នឹងមានអំពីណា ។ ដូចព្រះមាន-

ព្រះភាគត្រាស់ថា **រូបញ្ច ហិទំ ភិក្ខវេ អត្តា អភវិស្ស , នយិទំ រូបំ អាពាធាយ សំវត្តេយ្យ** ជាអាទិ៍ សេចក្ដីថា ម្នាលភិក្ខុទាំង-ឡាយ ប្រសិនបើរូបនេះ គប្បីជាតួខ្លួនដែរនោះ , រូបនេះមិនគប្បីប្រព្រឹត្តទៅដើម្បីសេចក្ដីឈឺចាប់ឡើយ ។ ព្រោះហេតុនោះការពិចារណានេះ ទើបជាសម្មសនញ្ញាណមួយយ៉ាង ដោយអំណាចនៃបទនេះថា **អនត្តា អសារកដ្ឋេន** រូបជាអនត្តា ព្រោះរក ខ្លឹមសារមិនបាន , តែដោយប្រភេទមាន ១១ យ៉ាង ។

ក្នុងវេទនាជាដើម ក៏មានន័យនោះដូចគ្នា ។ ដោយប្រការដូច្នេះ ក្នុងខន្ធមួយ ៗ ធ្វើឲ្យទៅជា ១១ យ៉ាង ទើបមានសម្មស-នញ្ញាណ ៥៥ ក្នុងខន្ធ ៥ គឺ ដោយភាពមិនទៀង ៥៥ ដោយភាពជាទុក្ខ ៥៥ ដោយភាពជាអនត្តា ៥៥ ព្រោះហេតុនោះទាំងអស់រួមសម្មសនញ្ញាណបាន ១៦៥ យ៉ាង ។

តែអាចារ្យពួកខ្លះពោលថា បន្ថែមសូម្បីបទថា **សព្វំ រូបំ សព្វំ វេទនំ សព្វំ សញ្ញំ សព្វេ សង្ខារេ សព្វំ វិញ្ញាណំ** ចុះក្នុងខន្ធមួយ ៗ ហើយធ្វើឲ្យបាន ១២ រួមជា ៦០ ក្នុងខន្ធ ៥ , ដោយអនុបស្សនា ត្រូវជាសម្មសនញ្ញាណ ១៨០ យ៉ាង ។



មយ៉ាងទៀត ក្នុងការចែកជាអតីតជាដើម គប្បីជ្រាបដល់វេទនាជាអតីត អនាគត និងបច្ចុប្បន្ន ដោយអំណាចនៃសន្តតិ និងដោយអំណាចនៃខណៈជាដើម ។ ក្នុងបទនោះ គប្បីជ្រាបវេទនា ដោយអំណាចសន្តតិដូចតទៅនេះ វេទនាដែលរាប់ចូលក្នុងវីថិចិត្ត ១ ជវនចិត្ត ១ សមាបត្តិ ១ និងប្រព្រឹត្តទៅដោយការប្រកបរឿយ ៗ ក្នុងអារម្មណ៍ណាមួយ ជាបច្ចុប្បន្ន , មុនអំពីនោះជាអតីត , ក្រោយអំពីនោះជាអនាគត ។ វេទនាដោយអំណាចខណៈ គឺ វេទនាធ្វើកិច្ចរបស់ខ្លួន ដែលរាប់បញ្ចូលក្នុងខណៈ ៣ គឺ ដែលដល់ទីបំផុតខាងដើម ទីបំផុតខាងចុង និងកណ្ដាល ជាបច្ចុប្បន្ន , មុនអំពីនោះ ជាអតីត , ក្រោយអំពីនោះ ជាអនាគត ។ គប្បីជ្រាបសេចក្ដីផ្សេងគ្នានៃវេទនាខាងក្នុងនិងខាងក្រៅ ដោយអំណាចវេទនាខាងក្នុងរបស់ខ្លួននោះឯង ។

គប្បីជ្រាបសភាពគ្រោតគ្រាត និងសភាពដែលល្អិតរបស់វេទនាដោយអំណាចនៃ ជាតិ សភាវ បុគ្គល លោកិយៈ និងលោកុត្តរៈ ដែលលោកពោលទុកក្នុងវិភង្គ ដោយន័យមានជាអាទិ៍ថា វេទនាជាអកុសលគ្រោតគ្រាត , វេទនាជាកុសល និង

អព្យាក្រិត ល្អិត ។ គប្បីជ្រាបវេទនា ដោយអំណាចនៃជាតិមុន ដូចតទៅនេះ វេទនាជាអកុសល ប្រព្រឹត្តទៅដើម្បីសេចក្តីមិនស្ងប់ ព្រោះជាកិរិយហេតុដែលមានទោស និងព្រោះកិលេសធ្វើឲ្យក្តៅក្រហាយ ព្រោះហេតុនោះ ទើបជាវេទនាគ្រោតគ្រាតជាងវេទនាដែលជាកុសល , ជាវេទនាគ្រោតគ្រាតជាងវិបាកអព្យាក្រិត ព្រោះមានសេចក្តីខ្វល់ខ្វាយ មានឧស្សាហ៍ មានវិបាក ដោយកិលេសធ្វើឲ្យក្តៅក្រហាយ និងមានទោស , ជាវេទនាគ្រោត-គ្រាតជាងកិរិយាអព្យាក្រិត ព្រោះមានវិបាក ដោយកិលេសធ្វើឲ្យក្តៅក្រហាយ ដោយមានព្យាបាទ និងមានទោស ។ ក៏វេទនាជាកុសល និងអព្យាក្រិត ល្អិតជាងវេទនាជាអកុសល ដោយបរិយាយដូចពោលមកហើយ ។ កុសលវេទនា និងអកុសល-វេទនា សូម្បីទាំងពីរយ៉ាង ក៏ជាវេទនាគ្រោតគ្រាតជាងវេទនាដែលជាអព្យក្រិត សូម្បីពីរយ៉ាងតាមសមគួរ ដោយមានសេចក្តីខ្វល់ខ្វាយ មានឧស្សាហ៍ និងមានវិបាក ។ សូម្បីវេទនាជាអព្យា-ក្រិត ២ យ៉ាង ក៏ល្អិតជាងវេទនាទាំងនោះ ដោយបរិយាយដូចបានពោលហើយ ។គប្បីជ្រាប វេទនាគ្រោតគ្រាត និងល្អិតដោយ



អំណាចនៃជាតិ ដោយប្រការដូច្នេះ ។

គប្បីជ្រាបវេទនា ដោយអំណាចសភាវៈ ដូចតទៅនេះ ទុក្ខវេទនា គ្រោតគ្រាតជាងវេទនា ២ យ៉ាង ក្រៅពីនេះ ព្រោះមិនមានសេចក្តីពេញចិត្ត ដោយមានការផ្សាយទៅ ដោយធ្វើការកម្រើក ដោយគួរដល់សេចក្តីក្តៅក្រហាយ និងដោយការគ្របសង្កត់ , តែវេទនា ២ យ៉ាងក្រៅពីនេះ ជាវេទនាល្អិតជាងទុក្ខវេទនាតាមសមគួរ ព្រោះសេចក្តីសុខ សេចក្តីស្ងប់ ប្រណីតសេចក្តីពេញចិត្ត និងដោយភាពជាកណ្តាល ។ សុខ-ទុក្ខ ២ យ៉ាង ជាវេទនាគ្រោតគ្រាតជាង អទុក្ខមសុខដោយការផ្សាយទៅ ដោយភាពគួរដល់សេចក្តីក្តៅប្រហាយ ដោយធ្វើសេចក្តីកម្រើក និងដោយប្រាកដ ។ វេទនានោះ ល្អិតជាងទាំងពីរយ៉ាងនោះ ដោយបរិយាយដូចពោលហើយ ។ គប្បីជ្រាប សភាពវេទនាដែលគ្រោតគ្រាត និងល្អិត ដោយសភាវៈ ដោយប្រការដូច្នេះ ។

គប្បីជ្រាប វេទនាដោយអំណាចបុគ្គល ដូចតទៅនេះ :-

វេទនារបស់អ្នកមិនចូលសមាបត្តិ ជាវេទនាគ្រោតគ្រាត ជាងវេទនារបស់អ្នកចូលសមាបត្តិ ព្រោះសភាពដែលចិត្តរាយមាយ

ទៅក្នុងអារម្មណ៍ផ្សេង ៗ , វេទនាក្រៅអំពីនេះ ជាវេទនាល្អិត ដោយបរិយាយផ្សេង ៗ ។ គប្បីជ្រាបវេទនាគ្រោតគ្រាត និង ល្អិត ដោយអំណាចបុគ្គល ដោយប្រការដូច្នេះ ។

គប្បីជ្រាបវេទនា ដោយអំណាចលោកិយៈ លោកុត្តរៈ ដូចតទៅនេះ វេទនាមានអាសវៈ ជាលោកិយៈ , លោកិយវេទនាទាំងនោះ ជាវេទនាគ្រោតគ្រាតជាង វេទនាដែលមិនមានអាសវៈ ព្រោះជាហេតុកើតអាសវៈ ជាទីតាំងនៃឱឃៈ ជាទីតាំងនៃយោគៈ ជាទីតាំងនៃគន្ថៈ កិលេសជាគ្រឿងជោតក្រង , ជាទីតាំងនៃនិវរណៈ ជាទីតាំងនៃឧបាទាន មានសេចក្ដីសៅហ្មង និងជារបស់ទូទៅដល់បុថុជ្ជន , មយ៉ាងទៀត វេទនាមិនមានអាសវៈ ជាវេទនាល្អិតជាងវេទនាមានអាសវៈ ដោយបរិយាយផ្សេង ៗ ។ គប្បីជ្រាបវេទនាដែលគ្រោតគ្រាត និងល្អិត ដោយលោកិយៈ និងលោកុត្តរៈ ដោយប្រការដូច្នេះ ។

ក្នុងបទទាំងនោះ គប្បីជ្រាបសេចក្ដីផ្សេងគ្នា ដោយជាតិជាដើម ។ ព្រោះថា វេទនាដែលសម្បយុត្តដោយកាយវិញ្ញាណអកុសលវិបាក សូម្បីល្អិត ព្រោះជាអព្យាក្រិត ដោយអំណាចនៃ



ជាតិ ក៏ជាវេទនាគ្រោតគ្រាត ដោយភាវៈរបស់ខ្លួនជាដើម ។ ដូចដែលលោកពោលទុកថា ៖

> អព្យាកតា វេទនា សុខុមា , ទុក្ខា វេទនា
> ឱឡារិកាសមាបន្នស្ស វេទនា សុខុមា ,
> អសមាបន្នស្ស វេទនាឱឡារិកា ។ អសា
> សវា វេទនា សុខុមា , សាសវា វេទនា
> ឱឡារិកា ។

> វេទនាជាអព្យាក្រិត ល្អិត , ទុក្ខវេទនា គ្រោត
> គ្រាត , វេទនារបស់អ្នកចូលសមាបត្តិ ល្អិត ,
> វេទនារបស់អ្នកមិនចូលសមាបត្តិ គ្រោតគ្រាត
> វេទនាមិនមានអាសវៈល្អិត , វេទនាមានអាសវៈ
> គ្រោតគ្រាត ។

សូម្បីសុខវេទនាជាដើម ក៏ដូចទុក្ខវេទនា ។ ព្រោះថា សូម្បីវេទនាទាំងនោះ គ្រោតគ្រាត ក៏ដោយជាតិ , ល្អិត ក៏ដោយភាវៈរបស់ខ្លួនជាដើម ។ ព្រោះដូច្នោះ គប្បីជ្រាបចំពោះវេទនាគ្រោតគ្រាត និងល្អិត ដែលមិនមានការផ្សេងគ្នាដោយជាតិ

ជាដើម ។ មិនផ្សេងគ្នា ដូចម្ដេច ? ដូចជាវេទនាដែលជាអព្យាក្រិត ល្អិតជាងវេទនាជាកុសល អកុសល ដោយជាតិ ។ ក្នុងវេទនាទាំងនោះ អព្យាក្រិតវេទនា យ៉ាងណា ? អ្វីជាទុក្ខវេទនា ? អ្វីជាសុខវេទនា ? អ្វីជាវេទនារបស់អ្នកចូលសមាបត្តិ ? អ្វីជាវេទនារបស់អ្នកមិនចូលសមាបត្តិ ? អ្វីជាសាសវវេទនា ? អ្វីជាអនាសវវេទនា ? មិនគប្បីប្រកាន់ខុសសេចក្ដីផ្សេងគ្នានៃសភាវៈដោយប្រការដូច្នេះ ។ ក្នុងបទទាំងពួង ក៏មានន័យនេះ ។

ម្យ៉ាងវិញទៀត ព្រោះបាលីថា គប្បីឃើញវេទនាគ្រោតគ្រាត និងល្អិត ព្រោះអាស្រ័យវេទនានោះ កើតឡើងរឿយ ៗ ។ វេទនាសហគតដោយទោសៈ គ្រោតគ្រាតជាងវេទនាដែលសហគតដោយលោភៈក្នុងអកុសលជាដើម ព្រោះដុតនិស្ស័យ ដូចភ្លើង , វេទនាសហគតដោយលោភៈល្អិត ។ វេទនាសូម្បីសហគតដោយទោសៈ ជានិយតៈ គ្រោតគ្រាតពិតប្រាកដ , មិនពិតប្រាកដល្អិត ។ វេទនាតាំងនៅមួយកប្ប សូម្បីពិតប្រាកដ ក៏គ្រោតគ្រាត , ក្រៅអំពីនោះ ល្អិត ។ សូម្បីការតាំងនៅមួយកប្ប ជាវេទនាគ្រោតគ្រាត , ក្រៅអំពីនោះ ល្អិត ។ សូម្បីវេទនានោះពិតប្រាកដ



តាំងនៅមួយកប្ប ជាអសង្ខារិកៈ អសង្ខារិកៈគ្រោតគ្រាត ក្រៅពីនោះល្អិត ។ ម្យ៉ាងទៀត ដោយមិនប្លែកគ្នា វេទនាជាអកុសលមានវិបាកច្រើន និងគ្រោតគ្រាត , មានវិបាកតិច ល្អិត ។ ចំណែកវេទនាជាកុសល មានវិបាកតិច គ្រោតគ្រាតមានវិបាកច្រើន តែល្អិត ។

ម្យ៉ាងវិញទៀត វេទនាជាកាមាវចរកុសល គ្រោតគ្រាត , ជារូបាវចរកុសល ល្អិត ។ វេទនាជាអរូបាវចរកុសល ល្អិតជាងនោះ ។ វេទនាជាលោកុត្តរកុសល ក៏ល្អិតជាងនោះ ។ ម្យ៉ាងទៀត វេទនាជាកាមាវចរកុសល សម្រេចដោយទានគ្រោតគ្រាត , សម្រេចដោយសីលល្អិត ។ សូម្បីសម្រេចដោយសីល ក៏គ្រោតគ្រាត , សម្រេចដោយភាវនាល្អិត ។ សូម្បីសម្រេចដោយភាវនាជាទុហេតុកៈ ក៏គ្រោតគ្រាត ។ ជាតិហេតុកៈល្អិត ។ សូម្បីជាតិហេតុកៈ ជាសង្ខារិកៈក៏គ្រោតគ្រាត ។ ជាអសង្ខារិកៈល្អិត ។ ម្យ៉ាងទៀត រូបាវចរប្រព្រឹត្តទៅក្នុងបឋមជ្ឈានគ្រោតគ្រាត ។ល។ ដែលជាបញ្ចមជ្ឈានល្អិត អរូបាវចរដែលសម្បយុត្តដោយអាកាសានញ្ចាយតនៈគ្រោតគ្រាត ។ល។ ដែលសម្បយុត្តដោយនេវ-

សញ្ញានាសញ្ញាយតនៈល្អិត លោកុត្តរវេទនា សម្បយុត្តដោយសោតាបត្តិមគ្គគ្រោតគ្រាត ។ល។ ដែលសម្បយុត្តដោយអរហត្តមគ្គល្អិតដោយពិត ។ ក្នុងវេទនាដែលជាវិបាកកិរិយារបស់ភូមិនោះ ៗ និងវេទនាដែលលោកពោលទុក ដោយអំណាចនៃទុក្ខវេទនាជាដើម វេទនារបស់អ្នកមិនចូលសមាបត្តិជាដើម សាសវវេទនាជាដើម ក៏មានន័យនេះ ។ ឬសូម្បីពោលដោយអំណាចឱកាស ទុក្ខវេទនាក្នុងនរកក៏គ្រោតគ្រាត , ទុក្ខវេទនាក្នុងកំណើតតិរច្ឆានល្អិត ។ល។ ទុក្ខវេទនាក្នុងសួគ៌ជាន់បរនិម្មិតវសវត្តីល្អិត ។ម្យ៉ាងទៀត គប្បីប្រកបសូម្បីសុខវេទនា ក្នុងបទទាំងពួងតាមសមគួរ ដូចពោលក្នុងទុក្ខវេទនា , វេទនាណា ៗ មានវត្ថុថោកទាប ដោយអំណាចវត្ថុ ជាវេទនាគ្រោតគ្រាត , មានវត្ថុប្រណីតជាវេទនាល្អិត , វេទនាណាដែលគ្រោតគ្រាត ក្នុងប្រភេទនៃវត្ថុដែលថោកទាប និងប្រណីត វេទនានោះ ជាវេទនាថោកទាប , វេទនាដែលល្អិត ជាវេទនាប្រណីត គប្បីឃើញដោយប្រការដូច្នេះ ។

ចំណែកបទថា **ទូរេសន្តិកេ** ជិត និងឆ្ងាយ លោកបានចែកទុកក្នុងវិភង្គដោយន័យមានជាអាទិ៍ថា **អកុសលា វេទនា កុសលាព្យាកតាហិ វេទនាហិ ទូរេ , អកុសលា វេទនា អកុសលាយ វេទនាយ សន្តិកេ** វេទនាមានក្នុងទីឆ្ងាយ អំពីវេទនាជាកុសល និងអព្យាកត , អកុសលវេទនា ដែលមានក្នុងទីជិតវេទនាជាអកុសល ។ ព្រោះដូច្នោះ អកុសលវេទនាមានក្នុងទីឆ្ងាយពីកុសល និងអព្យកតៈ ដោយជាសភាគៈគ្នា ដោយមិនទំនាក់ទំនងគ្នា និងដោយមិនដូចគ្នា ។ វេទនាជាកុសល និងអព្យាក្រិតក៏មានក្នុងទីឆ្ងាយពីអកុសលដូចគ្នា ។ ក្នុងវារៈទាំងពួង ក៏មានន័យនេះ ។ បទនេះថា វេទនាជាអកុសល មានក្នុងទីជិតនៃអកុសល ដោយជាសភាគៈគ្នា ដោយទាក់ទងគ្នា និងដូចគ្នា ជាកថាមុខដោយពិស្តារក្នុងការចែក មានវេទនាអតីតជាដើម ។ តែបទនេះ គប្បីជ្រាបសូម្បីសញ្ញាជាដើម ដែលសម្បយុត្តដោយវេទនានោះៗ យ៉ាងនេះដូចគ្នា ។

ម្យ៉ាងទៀត វេទនាជាដើមនេះ លោកុត្តរធម៌ណាមកហើយក្នុងធម៌ទាំងឡាយ ដោយសង្ខេបដោយបេយ្យាលថា **ចក្ខុ ។បេ។ ជរាមរណំ** , ធម៌ទាំងឡាយនោះ មិនគប្បីកាន់យកក្នុងអធិការនេះ

ព្រោះចូលទៅជិតអសម្មសនញ្ញាណ ។ ធម៌ទាំងនោះលោកពោលទុកដោយអំណាចការសម្ដែងធម៌ ដែលលោកសង្គ្រោះដោយបទនោះ ៗ តែម្យ៉ាង និងដោយន័យមានមកហើយក្នុងអភិញ្ញេយ្យ-និទ្ទេស ។ ម្យ៉ាងទៀត ធម៌ទាំងឡាយណាចូលដល់សម្មសន-ញ្ញាណ , ក្នុងធម៌ទាំងនោះ ធម៌ទាំងឡាយណាប្រាកដដល់ញាណណា រមែងដល់ការកំណត់កាន់យកបានដោយងាយ , ក្នុងធម៌ទាំងនោះគប្បីប្រារព្ធសម្មសនញ្ញាណ ដោយញាណនោះ ។ គប្បីជ្រាបថា លោកពោលដល់សម្មសនញ្ញាណ ដោយអំណាចញាណទាំងនោះ ដោយបរិយាយថា កាលបើពិចារណាធម៌ មានជាតិ ជរា និងមរណៈ ក្នុងសេចក្ដីមិនមានសម្មសនញ្ញាណ ដោយអំណាចជាតិ ជរា និងមរណៈ សូម្បីញាណទាំងនោះ ក៏ជាការបានពិចារណាហើយ ។

សូម្បីមិនប៉ះពាល់ដល់សេចក្ដីផ្សេង ៗ មាន **អជ្ឈត្ត** ជាដើម ព្រោះលោកពោលសម្មសនញ្ញាណទុកដោយអំណាចនៃតិកៈដែលជាអតីត ដោយន័យមានជាអាទិថា **អតីតានាគតប្បច្ចុប្បន្នំ អនិច្ចតោ វវត្ថេតិ** ព្រះយោគាវចររមែងកំណត់អតីត អនាគត



បច្ចុប្បន្ន ថាជារបស់មិនទៀង សូម្បីកំណត់ដោយអំណាចនៃអតីតតិកៈហើយ ក៏គប្បីធ្វើសម្មសនញ្ញាណ ដោយសេចក្ដីមិនទៀងជាដើមនោះឯង ។

ក៏ព្រោះដឹងវត្ថុដែលមិនទៀង មានប្រភេទជាសង្ខតៈជាដើម ដោយសភាពពិតប្រាកដ ។ ដូច្នោះ ដើម្បីសម្ដែងបរិយាយនៃរូបនោះ ឬដើម្បីសម្ដែងការប្រព្រឹត្តទៅនៃមនសិការ ដោយអាការផ្សេង ៗ ព្រះសារីបុត្រ ទើបពោលបទមានជាអាទិ៍ថា **រូបំ អតីតានាគតប្បច្ចុប្បន្នំ អនិច្ចំ សង្ខតំ** រូបដែលជាអតីត អនាគត និងបច្ចុប្បន្នមិនទៀង ដែលបច្ច័យតាក់តែង ។ ពិតណាស់ រូបនោះជា **អនិច្ចំ** ព្រោះអត្ថថា មានហើយមិនមានវិញ , ឈ្មោះថា **អនិច្ចំ** ព្រោះមានទីបំផុត គឺ សេចក្ដីមិនទៀង ឬព្រោះមានខាងដើម និងខាងចុង , ឈ្មោះថា **សង្ខត** ព្រោះត្រូវបច្ច័យតាក់តែង ។ ឈ្មោះថា **បដិច្ចសមុប្បន្នំ** ព្រោះអាស្រ័យបច្ច័យកើតឡើង ។ ព្រះសារីបុត្រសម្ដែងដល់សេចក្ដីមិនខ្វល់ខ្វាយដល់បច្ច័យ សូម្បីកាលបើរូបត្រូវបច្ច័យតាក់តែង ។ បទថា **ខយធម្មំ** មានការអស់ទៅជាធម្មតា បានដល់ អស់ទៅជាធម្មតា អស់ទៅជាប្រក្រតី ។

បទថា **វយធម្មំ** វិនាសទៅជាធម្មតា បានដល់ មានការវិនាសទៅជាធម្មតា ។ រូបនេះ មិនអស់ទៅ ដោយអំណាចការអស់ទៅនៃភាពជាអ្នកមានសេចក្ដីខ្ជិលច្រអូស ប្រាសចាកប្រក្រតីតែម្យ៉ាង ។ សូម្បីសេចក្ដីព្យាយាមល្មមនឹងធ្វើឲ្យខ្ជិលច្រអូស លោកក៏ពោលថា ការអស់ទៅក្នុងលោក ។

បទថា **វិរាគធម្មំ** បទនេះ មិនមែនភ្ជាប់ទៅជាមួយដោយការទៅក្នុងទីណា ឈានកន្លងសភាវៈជាប្រក្រតីតែម្យ៉ាង ។ ដូចលោកពោលទុកថា ការខ្ចីមរអើមក្ដី ការឈានកន្លងក្ដី ឈ្មោះ **វិរាគ** ។

បទថា **និរោធធម្មំ** មានការរលត់ទៅជាធម្មតា បទនេះមិនមែនវិលត្រឡប់មកទៀត ដោយឈានកន្លងសភាវៈ , គប្បីជ្រាបថា លោកពោលដល់បទក្រោយ ៗ ដោយអំណាចការបកស្រាយបទមុន ៗ ថា មានការរលត់ទៅ ដោយការរលត់សេចក្ដីមិនវិលត្រឡប់មកទៀតជាធម្មតាតែម្យ៉ាង ។

ម្យ៉ាងវិញទៀត គប្បីប្រកបថា រូបមានការអស់ទៅជាធម្មតាដោយការបែកធ្លាយទៅនៃរូប ដែលទាក់ទងនៅក្នុងភពមួយ ,



មានការវិនាសទៅជាធម្មតា ដោយការវិនាសនៃរូបដែលទាក់ទងដោយសន្តតិ ។ រូបមានការបែកធ្លាយទៅជាធម្មតា ដោយការបែកធ្លាយនៃខណៈរបស់រូប , មានការរលត់ជាធម្មតា ដោយការធ្លងផុតហើយ មិនកើតមកទៀត ។

ក្នុងបទមានជាអាទិ៍ថា **ជរាមរណំ អនិច្ចំ** ជរា និងមរណៈមិនទៀង សេចក្ដីថា ជរា និងមរណៈ មិនមែនមិនទៀង , តែជរា និងមរណៈ ឈ្មោះថា មិនទៀង ព្រោះខន្ធទាំងឡាយមានការមិនទៀងជាសភាវៈ ទើបមានជរា និងមរណៈ ។ សូម្បីក្នុង **សង្ខត** ជាដើមក៏មានន័យនេះដូចគ្នា ។ ក្នុងវាងបេយ្យាល ព្រោះសូម្បីជាតិ ក៏មិនទៀងជាដើម ទើបមានន័យនេះដូចគ្នា ។

បទមានជាអាទិ៍ថា **ជាតិប្បច្ចយា ជរាមរណំ** ជាតិជាបច្ច័យទើបមានជរា និងមរណៈនេះ លោកមិនបានពោលដោយអំណាចវិបស្សនា លោកពោលដោយបរិយាយថា សម្មសនញ្ញាណរមែងមាន បានដល់សេចក្ដីសង្ខេបដោយអំណាចអង្គមួយ ៗ នៃបដិច្ចសមុប្បាទ ហើយកំណត់ទុកតែម្យ៉ាង , តែសេចក្ដីនោះ មិនមែនកលាបសម្មសនញ្ញាណ , នោះជាធម្មដ្ឋិតិញ្ញាណប៉ុណ្ណោះ ។

បទថា អសតិ ជាតិយា កាលបើជាតិមិនមាន នេះលោកធ្វើជាលិង្គវិបល្លាស ។ ទើបលោកពោលថា **អសន្តិយា ជាតិយា** ។ បទថា **អសតិ សង្ខារេសុ** កាលបើសង្ខារមិនមាន លោកធ្វើជាវចនវិបល្លាស លោកពោលថា **អសន្តេសុ សង្ខារេសុ** ។

បទមានជាអាទិ៍ថា **ភវប្បច្ចយា ជាតិ** , **អសតិ** ព្រោះភពជាបច្ច័យ ទើបមានជាតិ ។ កាលបើភពមិនមាន គប្បីប្រកបដោយន័យមានជាអាទិ៍ថា ព្រោះភពជាបច្ច័យ ទើបមានជាតិ , កាលបើភពមិនមាន ជាតិក៏មិនមាន ។

( ចប់ អដ្ឋកថាសម្មសនញ្ញាណនិទ្ទេស )



# អដ្ឋកថា ឧទយព្វយញ្ញាណនិទ្ទេស

ឥឡូវនេះ ដើម្បីកំណត់សង្ខារទាំងឡាយដែលអ្នកទៅដល់ត្រើយតាំងនៅហើយ ដោយធ្វើការនាឲ្យគន់វង្ស ដោយន័យផ្សេងៗនៃសម្មសនញ្ញាណដូចពោលហើយក្នុងលំដាប់ ឃើញហើយដោយភាពជារបស់មិនទៀងជាដើម ដោយឧទយព្វយញ្ញាណ របស់មិនទៀងជាដើម ព្រះសារីបុត្ត ទើបសម្តែងរូបដែលកើតដោយបច្ច័យទាំងឡាយតាមដែលជារបស់ខ្លួន ដោយសន្តតិ ក្នុងបទមានជាអាទិ៍ **ជាតំ រូបំ** រូបដែលកើតហើយ ក្នុងនិទ្ទេសនៃឧទយព្វយានុបស្សនាដូចពោលហើយ ។

បទថា **ឧទយោ** បានដល់ **ជាតិ** គឺ ការកើត ជាអាការថ្មីនៃរូបដែលកើតហើយនោះ មានការកើតជាលក្ខណៈ ។

បទថា **វយោ** បានដល់ ការអស់ទៅ ការរលត់ទៅ មានការប្រែប្រួល ជាលក្ខណៈ , ការពិចារណារឿយ ៗ ឈ្មោះថា **អនុ-បស្សនា** , អធិប្បាយថា បានដល់ **ឧទយព្វយានុបស្សនាញាណ** ។ សូម្បីក្នុងវេទនាជាដើម ក៏មានន័យនេះដូចគ្នា ។ មិនប៉ះពាល់ដល់ជរា

និងមរណៈ ព្រោះការកើត ការវិនាសដែលមានជាតិ ជរា និងមរណៈគួរកំណត់កាន់យក មិនប៉ះពាល់ជាតិ ជរា និងមរណៈ ព្រោះមិនមានការកើត និងការវិនាស ហើយលោកធ្វើបេយ្យាលថា **ជាតំ ចក្ខុំ ។បេ។ ជាតោ ភវោ** ចក្ខុកើតហើយ.... ភពកើតហើយ ដូច្នេះ ។ ព្រះយោគាវចរនោះ កាលឃើញការកើត និងការវិនាសនៃខន្ធ ៥ យ៉ាងនេះ រមែងដឹងយ៉ាងនេះថា ការរួមជាកងក្តី ការសន្សំក្តី រមែងមិនមានដល់ខន្ធដែលនៅមិនទាន់កើតមុនអំពីខន្ធទាំងនេះកើត , ឈ្មោះថា ការមកដោយរួមជាកង ដោយការសន្សំ រមែងមិនមានសូម្បីដល់ខន្ធដែលកើតឡើង , ឈ្មោះថា ការទៅកាន់ទិសតូចធំ រមែងមិនមានសូម្បីដល់ខន្ធដែលរលត់ , ឈ្មោះថា ការតាំងចុះ ដោយការរួមជាកង ដោយការសន្សំ ដោយការរក្សាទុកក្នុងទីកន្លែងមួយ រមែងមិនមានសូម្បីដល់ខន្ធដែលរលត់ហើយ ។ ដូចអ្នកដេញពិណ កាលគេដេញពិណហើយ សំឡេងពិណក៏កើត , មិនមានការសន្សំទុកពីមុនឲ្យកើត , កាលកើត ក៏មិនមានការសន្សំ , ការទៅកាន់ទិសតូចធំរបស់សម្លេងពិណដែលរលត់ទៅក៏មិនមាន , រលត់ហើយ មិនថា



កន្លែងណាក៏មិនសន្សំទុក , ការពិតពិណក្តី អ្នកដេញពិណក្តី អាស្រ័យសេចក្តីព្យាយាម ដែលកើតពីការព្យាយាមនៃកូនឈើដេញពិណមិនមានហើយ ក៏នៅមានបាន , លុះមានហើយ ក៏គង់វិនាសបានយ៉ាងណា , ធម៌មានរូប និងមិនមានរូប សូម្បីទាំងអស់ក៏ដូច្នោះ មិនមាន ក៏គង់មានបាន លុះមានហើយ ក៏នឹងវិនាសវិញ ព្រះយោគាវចររមែងឃើញ ដោយប្រការដូច្នេះឯង ។

ព្រះសារីបុត្តកាលសម្តែងការឃើញការកើត និងការវិនាសដោយសង្ខេបយ៉ាងនេះហើយ ឥឡូវនេះដើម្បីសម្តែងដោយពិស្តារទើបសួរដល់ចំនួន ដោយរួមជាកង ដោយបទមានជាអាទិ៍ថា **បញ្ចន្នំ ខន្ធានំ ឧទយំ បស្សន្តោ កតិ លក្ខណានិ បស្សតិ** ព្រះយោគាវចរកាលពិចារណាឃើញការកើតនៃខន្ធ ៥ រមែងពិចារណាឃើញលក្ខណៈប៉ុន្មាន , កាលពិចារណាឃើញការកើតនៃខន្ធ ៥ ទើបឆ្លើយដល់ចំនួន ដោយរួមជាកង ដោយបទមានជាអាទិ៍ **បញ្ចវីសតិ លក្ខណានិ បស្សតិ** រមែងពិចារណាឃើញលក្ខណៈ ២៥ ហើយសួរដល់ចំនួនដោយការបែកទៀត ដោយបទមានជាអាទិ៍ **រូបក្ខន្ធស្ស ឧទយំ បស្សន្តោកតិ លក្ខណានិ បស្សតិ** ព្រះយោគាវចរ

កាលពិចារណាឃើញការកើតនៃរូបក្ខន្ធ រមែងឃើញលក្ខណៈប៉ុន្មាន ហើយឆ្លើយចំនួន ដោយការចំណែក ដោយបទមានជាអាទិ៍ថា **រូបក្ខន្ធស្ស ឧទយំ បស្សន្តោ បញ្ច លក្ខណានិ បស្សតិ** ព្រះយោគាវចរ កាលពិចារណាឃើញការកើតនៃរូបក្ខន្ធ រមែងពិចារណាឃើញលក្ខណៈ ៥ ហើយសួរដល់ការចែកលក្ខណៈម្យ៉ាងទៀតដោយបទមានជាអាទិ៍ថា **រូបក្ខន្ធស្ស ឧទយំ បស្សន្តោ កតមានិ បញ្ច លក្ខណានិ បស្សតិ** កាលពិចារណាឃើញការកើតនៃរូបក្ខន្ធ រមែងឃើញលក្ខណៈ ៥ តើដូចម្តេច ហើយទើបឆ្លើយតទៅ ។

ក្នុងបទទាំងនោះ បទថា **អវិជ្ជាសមុទយា រូបសមុទ្ទយោ** ព្រោះអវិជ្ជាកើត រូបទើបកើត សេចក្តីថា កាលមានអវិជ្ជាដូចពោលហើយថា មោហៈក្នុងកម្មភពមុនជាអវិជ្ជា រមែងកើតរូបក្នុងភពនេះ ។ បទថា **បច្ចយសមុទយដ្ឋេន** សេចក្តីថា ដោយការកើតឡើងនៃបច្ច័យ ។ ម្យ៉ាងទៀត អវិជ្ជា តណ្ហាកម្ម ជាបច្ច័យក្នុងអតីត ជាហេតុនៃបដិសន្ធិក្នុងភពនេះ ។ ម្យ៉ាងទៀត កាលប្រកាន់មាំ អវិជ្ជា តណ្ហា កម្ម ៣ យ៉ាង ទាំងនេះ ជាការប្រកាន់



មាំសង្ខារុបាទាន ការប្រកាន់មាំក្នុងសង្ខារនោះឯង ។

បទថា **អាហារសមុទយា** ព្រោះអាហារកើត បានដល់ព្រោះកវឡឹង្ការាហារមានកម្លាំងក្នុងបច្ច័យដែលប្រព្រឹត្តទៅ ទើបកាន់យកអាហារនោះឯង ។ ក៏កាលកាន់យកអាហារនោះ ក៏ជាចំណែកកាន់យកសូម្បីឧតុ និងចិត្ត ដែលជាហេតុនៃការប្រព្រឹត្តទៅផងដូចគ្នា ។

បទថា **និព្វត្តិលក្ខណំ** មានការកើត ជាលក្ខណៈ សេចក្តីថា លោកពោលដល់ការកើតនៃរូបដោយអំណាចនៃអទ្ធា គឺ កាលសន្តតិ និងខណៈ , ម្យ៉ាងទៀតការកើតនោះឯង ឈ្មោះថា លក្ខណៈ ព្រោះជាលក្ខណៈនៃសង្ខតៈ ។

បទថា **បញ្ច លក្ខណានិ** លក្ខណៈ ៥ បានដល់ លក្ខណៈ ៥ ទាំងនោះ គឺ អវិជ្ជា តណ្ហា កម្ម អាហារ និងការកើត ។ ពិតណាស់សូម្បីធម៌ ៤ មានអវិជ្ជាជាដើម ក៏ឈ្មោះថា លក្ខណៈ ព្រោះជាគ្រឿងកំណត់ការកើតនៃរូប ។ ចំណែក **និព្វត្តិ** ការកើតជាលក្ខណៈនៃសង្ខតៈ ឈ្មោះថា លក្ខណៈ ព្រោះជាគ្រឿងកំណត់ថាសូម្បីការកើតនោះក៏ជា សង្ខតៈ ។

បទថា **អវិជ្ជានិរោធា រូបនិរោធោ** ព្រោះអវិជ្ជារលត់ រូបទើបរលត់ សេចក្ដីថា កាលរលត់អវិជ្ជាក្នុងភពនេះ ព្រោះជាបច្ច័យនៃភពក្នុងអនាគត ដោយអរហត្តមគ្គញ្ញាណ រូបអនាគតរមែងមិនកើត គឺ រលត់ព្រោះមិនមានបច្ច័យ ។

បទថា **បច្ចយនិរោធដ្ឋេន** ដោយការរលត់នៃបច្ច័យ គឺ ដោយការរលត់នៃបច្ច័យ ។ មប៉្យាងទៀត ក្នុងការរលត់ ក្នុងបទនេះ ជាការរលត់អវិជ្ជា តណ្ហា និងកម្ម ដែលជាបច្ច័យនៃបដិសន្ធិក្នុងអនាគត ។

បទថា **អាហារនិរោធា រូបនិរោធោ** ព្រោះអាហាររលត់ រូបទើបរលត់ បានដល់ ការមិនមានរូបដែលមានអាហារនោះជាសមុដ្ឋាន រមែងមានមិនបាន ព្រោះការមិនមានកវឡីង្ការាហារ ដែលជាបច្ច័យនៃការប្រព្រឹត្តទៅ ។

បទថា **វិបរិណាមលក្ខណំ** មានការប្រែប្រួល ជាលក្ខណៈ បានដល់ ការរលត់នៃរូបដោយអំណាចអទ្ធា កាល សន្តតិ និងខណៈ , ការរលត់នោះឯង លោកពោលថា ជាលក្ខណៈ ព្រោះជាលក្ខណៈនៃសង្ខតៈ ។



បទថា **បញ្ច លក្ខណានិ** លក្ខណៈ ៥ ក្នុងបទនេះ បានដល់ ការរលត់ដោយមិនមានអវិជ្ជា តណ្ហា កម្ម និងអាហារ ៤ , ព្រមទាំងការប្រែប្រួល ១ រួមជា ៥ ។ ក្នុងវេទនាខន្ធជាដើម ក៏មានន័យនេះ ។ ប៉ុន្តែផ្សេងគ្នា គឺ ការឃើញការកើត និងការវិនាស នៃអរូបក្ខន្ធ ដោយអំណាចនៃអទ្ធា កាល និងសន្តតិ មិនមែនដោយខណៈ ។ ផស្សៈ ជាបច្ច័យនៃការប្រព្រឹត្តទៅរបស់វេទនាខន្ធ សញ្ញាខន្ធ និងសង្ខារក្ខន្ធ , និរោធ ជាបច្ច័យនៃការប្រព្រឹត្តទៅរបស់វេទនាខន្ធ សញ្ញាខន្ធ និងសង្ខារក្ខន្ធ ព្រោះរលត់ផស្សៈនោះ ។ នាមរូប ជាបច្ច័យនៃការប្រព្រឹត្តរបស់វិញ្ញាណក្ខន្ធ ។ និរោធ ជាបច្ច័យនៃវិញ្ញាណក្ខន្ធ ព្រោះរលត់នាមរូបនោះ ។

តែអាចារ្យពួកខ្លះពោលថា នាមរូបមិនទាក់ទងដល់ចំណែកអតីតជាដើម ព្រោះឃើញការកើត និងការវិនាស ដោយបច្ច័យ ៤ ដោយកើតឡើងព្រោះអវិជ្ជាជាដើម ដោយអំណាចភាពស្មើគ្នាទាំងអស់ ព្រោះហេតុនោះ ទើបកាន់យកហេតុត្រឹមតែថា ការកើតឡើង ។ ព្រោះអវិជ្ជាជាដើមរលត់ នាមរូបទើបរលត់ ព្រោះហេតុនោះ ទើបកាន់យកហេតុត្រឹមតែការមិនកើត , មិនមែនកាន់

យកការរលត់ ។ នាមរូប បានដល់ ព្រះយោគាវចររមែងកាន់យកការកើត ការរលត់នៃខន្ធទាំងឡាយ ដែលជាបច្ចុប្បន្ន ព្រោះឃើញការកើត និងការរលត់ដោយខណៈ ដូច្នេះ ។

អ្នកចម្រើនវិបស្សនា កាលចម្រើនវិបស្សនាធ្វើទុកក្នុងចិត្តដល់ការកើត និងការរលត់ដោយភាពជាបច្ច័យមុន ហើយលះបង់ធម៌ ៤ មានអវិជ្ជាជាដើម ក្នុងខណៈចម្រើនវិបស្សនា កាន់យកខន្ធទាំងឡាយដែលមានការកើត និងការរលត់នោះឯង ទើបឃើញការកើត និងការរលត់នៃខន្ធទាំងនោះ ។ កាលចម្រើនវិបស្សនាយ៉ាងនេះ ឃើញការកើត និងការរលត់ដោយពិស្តារដោយបច្ច័យ និងដោយលក្ខណៈថា ការកើតនៃរូបជាដើមយ៉ាងនេះ , ការវិនាសយ៉ាងនេះ , រូបជាដើមកើតឡើងយ៉ាងនេះ , វិនាសទៅយ៉ាងនេះ ញាណដឹងថា ន័យថា ធម៌ទាំងនេះមិនមានហើយមាន មានហើយមិនមានដូច្នេះ ជាញាណដ៏បរិសុទ្ធិជាង ។ ប្រភេទនៃសច្ចៈបដិច្ចសមុប្បាទន័យ និងលក្ខណៈ រមែងប្រាកដ ។ ព្រះយោគាវចរនោះ រមែងឃើញការកើតនៃខន្ធទាំងឡាយ ព្រោះអវិជ្ជាជាដើមកើត និងការរលត់នៃខន្ធទាំងឡាយ ព្រោះអវិជ្ជាជា



ដើមរលត់ , នេះជាការឃើញការកើត និងការរលត់ព្រោះបច្ច័យរបស់ព្រះយោគាវចរនោះ ។

ម្យ៉ាងទៀត ព្រះយោគាវចរកាលឃើញការកើតជាលក្ខណៈការប្រែប្រួលជាលក្ខណៈ ឈ្មោះថា រមែងឃើញការកើត និងការវិនាសនៃខន្ធទាំងឡាយ នេះជាការឃើញការកើត និងការវិនាសព្រោះខណៈ នៃព្រះយោគាវចរនោះ ។ ពិតណាស់ ការកើតជាលក្ខណៈក្នុងខណៈកើតនោះឯង និងការប្រែប្រួល ក៏ជាលក្ខណៈក្នុងខណៈរលត់ ។

**សមុទយសច្ច** រមែងប្រាកដដល់ព្រះយោគាវចរ ដោយឃើញការកើតដោយបច្ច័យ ដែលឃើញការកើត និងការវិនាសដោយចំណែកទាំង ២ គឺ ដោយបច្ច័យ និងដោយខណៈ របស់ព្រះយោគាវចរអ្នកបានដឹងដល់តណ្ហាឲ្យកើត ។

**ទុក្ខសច្ច** រមែងប្រាកដ ដោយការឃើញការកើត ដោយខណៈ ដល់ព្រះយោគាវចរអ្នកបានដឹងដល់ទុក្ខដែលកើត ។

**និរោធសច្ច** រមែងប្រាកដដោយការឃើញការរលត់ព្រោះបច្ច័យ ដល់ព្រះយោគាវចរអ្នកបានដឹងដល់ការមិនកើត នៃការ

មានបច្ច័យ ព្រោះបច្ច័យមិនកើត ។ **ទុក្ខសច្ច** នោះឯង រមែងប្រាកដដល់ការឃើញការវិនាស ដោយខណៈដល់ព្រះយោគាវចរអ្នកដឹងក្នុងមរណៈទុក្ខ ។ មយ៉ាងទៀត ការឃើញការកើត និងការវិនាស របស់ព្រះយោគាវចរនោះ **មគ្គសច្ច** រមែងប្រាកដថា មគ្គនេះនៅជាលោកិយៈ ព្រោះកម្ចាត់សេចក្តីវង្វេងក្នុងការឃើញការកើត និងការវិនាសនោះ ។

មយ៉ាងទៀត បដិច្ចសមុប្បាទជាអនុលោម ដោយការឃើញការកើតដោយបច្ច័យ រមែងប្រាកដដល់ព្រះយោគាវចរនោះដែលបានឃើញថា **ឥមស្មឹ សតិ ឥទំ ហោតិ** កាលវត្ថុនេះមាន , វត្ថុនេះរមែងមាន ។ បដិច្ចសមុប្បាទជាបដិលោម ដោយការឃើញការវិនាសដោយបច្ច័យ រមែងប្រាកដដល់ព្រះយោគាវចរអ្នកបានឃើញថា **ឥមស្មឹ និរោធា ឥទំ និរុជ្ឈតិ** ព្រោះវត្ថុនេះរលត់ វត្ថុនេះទើបរលត់ ដូច្នេះ ។ មយ៉ាងវិញទៀត ធម៌ទាំងឡាយដែលអាស្រ័យគ្នាកើតឡើង ដោយការឃើញការកើត និងការសូន្យទៅដោយខណៈ រមែងប្រាកដដល់ដល់ព្រះយោគាវចរអ្នកបានឃើញលក្ខណៈនៃសង្ខតៈ ។ ព្រោះសង្ខតធម៌ទាំងឡាយមាន



ការកើត និងការសូន្យទៅ , សង្ខតធម៌ទាំងនោះអាស្រ័យគ្នាទើបកើតឡើង ។

មយ៉ាងទៀត ន័យ ៤ គឺ **ឯកត្តន័យ** ន័យនៃភាពតែមួយ ដោយការឃើញការកើតដោយបច្ច័យ រមែងប្រាកដដល់ព្រះយោ-គាវចរនោះ អ្នកបានដឹងក្នុងការដាច់ទៅនៃសន្តាន ដោយការសម្ព័ន្ធគ្នាដោយហេតុផល ដែលព្រះយោគាវចរ រមែងលះបង់ឧច្ឆេទទិដ្ឋិបានយ៉ាងល្អ ។ **នានត្តន័យ** នៃភាពផ្សេង ៗ គ្នា ដោយការឃើញការកើតដោយខណៈ រមែងប្រាកដដល់ព្រះយោគាវចរអ្នកឃើញដល់ការកើតនៃធម៌ថ្មី ៗ ព្រះយោគាវចរនោះ រមែងលះបង់សស្សតទិដ្ឋិបានយ៉ាងល្អ ។ មយ៉ាងទៀត **អព្យាបារន័យ** ន័យនៃភាពមិនខ្វល់ខ្វាយ ដោយការឃើញការកើតដោយបច្ច័យ រមែងប្រាកដដល់ព្រះយោគាវចរ អ្នកឃើញដល់សភាពដែលធម៌ទាំង-ឡាយមិនប្រព្រឹត្តទៅក្នុងអំណាច ដែលព្រះយោគាវចរនោះរមែងលះបង់អត្តទិដ្ឋិបានយ៉ាងល្អ ។ មយ៉ាងវិញទៀត **ឯវំធម្មតាន័យ** ន័យជាធម្មតាយ៉ាងនេះ ដោយការឃើញការកើតដោយបច្ច័យ រមែងប្រាកដដល់ព្រះយោគាវចរអ្នកឃើញក្នុងការកើតនៃផល តាមសម

គួរដល់បច្ច័យ ពេលនោះព្រះយោគាវចររមែងលះបង់អកិរិយទិដ្ឋិបានយ៉ាងល្អ ។

ម្យ៉ាងទៀត **អនត្តលក្ខណ** ដោយការឃើញការកើតដោយបច្ច័យ រមែងប្រាកដដល់ព្រះយោគាវចរនោះ អ្នកឃើញដល់ការប្រព្រឹត្តទៅដែលទាក់ទងជាមួយបច្ច័យ គឺ មិនមានសេចក្តីព្យាយាមក្នុងធម៌ទាំងឡាយ ។ **អនិច្ចលក្ខណ** ដោយការឃើញការកើតនិងការរលត់ទៅដោយបច្ច័យ រមែងប្រាកដដល់ព្រះយោគាវចរដែលឃើញដល់ការមានហើយ មិនមានវិញ និងអ្នកឃើញដល់ការស្វាត់ក្នុងទីបំផុតខាងដើម និងខាងចុង ។ សូម្បីទុក្ខលក្ខណៈក៏ប្រាកដដល់ព្រះយោគាវចរដែលឃើញដល់ការបៀតបៀនដោយការកើត និងការរលត់ទៅ ។ **សូម្បីសភាវលក្ខណ** ក៏រមែងប្រាកដដល់ព្រះយោគាវចរដែលឃើញដល់ការកំណត់ការកើត និងការអស់ទៅ សូម្បីការប្រព្រឹត្តទៅមួយគ្រានៃសង្ខតលក្ខណៈ ក្នុងសភាវលក្ខណៈ ដែលឃើញដល់ការមិនមានការវិនាសក្នុងលក្ខណៈនៃការកើត និងការកើត ក្នុងខណៈនៃការវិនាសទៅ ។

សង្ខារទាំងឡាយថ្មីជានិច្ច រមែងប្រាកដដល់ប្រភេទរបស់



សច្ចបដិច្ចសមុប្បាទន័យ និងលក្ខណៈដែលមានការប្រាកដហើយនោះថា ធម៌ទាំងនេះដែលមិនធ្លាប់កើត ក៏កើតឡើង ដែលកើតឡើងហើយក៏រលត់ទៅ ដូច្នេះ ។ សង្ខារទាំងឡាយមិនមែនថ្មីជានិច្ចតែម្យ៉ាង , សង្ខារទាំងឡាយ ប្រាកដដូចដំណក់ទឹកសន្សើមត្រូវស្ងួតក្នុងវេលាព្រះអាទិត្យរះឡើង ដូចដុំពពុះទឹក ដូចស្នាមគំនូសឈើក្នុងទឹក ដូចគ្រាប់ស្ពៃដាក់លើចុងម្ជុល ដូចផ្លេកបន្ទោរដូចកលមាយា ដូចថ្ងៃបណ្តើរកូន , ដូចការយល់សប្តិ ដូចផ្កាភ្លើង , ដុំរថ , គន្ធព្វ , នគរ , ដូចក្រពេញទឹក និងដើមចេកជាដើម រកខ្លឹមសារមិនបាន មិនមានសារៈ ។ ដោយហេតុត្រឹមតែប៉ុណ្ណេះ វិបស្សនាដែលទន់ខ្ចីឈ្មោះថា ឧទយព្វយានុបស្សនា ដែលព្រះយោគាវចរនោះចាក់ធ្លុះលក្ខណៈ ៥០ ដោយអាការនេះថា ការវិនាសជាធម្មតា រមែងកើតឡើង , និងព្រះយោគាវចរ រមែងចូលដល់ភាពវិនាសដែលកើតឡើងហើយ ដូច្នេះតាំងនៅដោយការចាក់ធ្លុះមុន , ព្រោះសម្រេចញាណណា ព្រះយោគាវចររមែងឈ្មោះថា **អារទ្ធវិបស្សកោ** អ្នកប្រារព្ធវិបស្សនា , វិបស្សនូបក្កិលេស ១០ មានឱភាសជាដើម រមែងកើតដល់ព្រះ-

យោគាវចរអ្នកតាំងនៅក្នុងញាណនេះ , ព្រះយោគាវចរដែលមិនឆ្លាត ជាអ្នកមានការសំគាល់ក្នុងឧបក្កិលេសដែលកើតឡើងនោះថាជា **មគ្គញ្ញាណ** រមែងកាន់យកវត្ថុដែលមិនមែនជាមគ្គ ថាជាមគ្គ , និងជាអ្នកត្រូវឧបក្កិលេសចងទុក ។

ចំណែកព្រះយោគាវចរដែលឆ្លាត លើកវិបស្សនាឡើងក្នុងឧបក្កិលេសទាំងនោះ ដោះស្រាយភាពជាប់នៅ គឺ ឧបក្កិលេសចេញ ហើយកំណត់មគ្គ គឺ ផ្លូវ និងមិនមែនផ្លូវថា ធម៌ទាំងនេះមិនមែនមគ្គ ។ ចំណែកវិបស្សនាញាណ ដែលបដិបត្តិទៅតាមវីថិរួចផុតចាកឧបក្កិលេស ជាមគ្គ ។ ញាណ ដែលដឹងថាជាមគ្គ និងមិនមែនមគ្គរបស់ព្រះយោគាវចរនោះ តាំងនៅយ៉ាងនេះ ឈ្មោះថាមគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ សេចក្តីបរិសុទ្ធនៃញាណ ជាគ្រឿងឃើញថា ផ្លូវ ឬមិនមែនផ្លូវ ។

ក៏ដោយហេតុត្រឹមប៉ុណ្ណេះ ជាការកំណត់សច្ចៈ ៤ ដោយញាណនោះ ។ យ៉ាងណា ? កាលបើយល់ដល់នាមរូប ក៏ជាការកំណត់ទុក្ខសច្ចដោយការកំណត់នាមរូប ពោលគឺ ទិដ្ឋិវិសុទ្ធិដូចពោលមកហើយ ដោយពាក្យថា **ធម្មដ្ឋិតិញ្ញាណ** ព្រោះមានការ



យល់ក្នុងបច្ច័យ ។ ការកំណត់សមុទយសច្ច ដោយការយល់ក្នុងបច្ច័យ បានដល់ **កង្ខាវិតរណវិសុទ្ធ** , ជាការកំណត់ទុក្ខសច្ចដោយឃើញការកើត និងការរលត់ដោយខណៈ ដោយឧទយព្វ-យានុបស្សនាញាណ , ការកំណត់សមុទយសច្ច ដោយឃើញការកើតឡើងអាស្រ័យបច្ច័យ , ការកំណត់និរោធសច្ច ដោយឃើញការវិនាសទៅនៃបច្ច័យ , ឃើញការកើត និងការវិនាសទៅរបស់ព្រះយោគាវចរដែលឃើញច្បាស់ក្នុង **មគ្គាមគ្គញ្ញាណទស្សន-វិសុទ្ធិ** គឺ មគ្គជាលោកិយៈ ជាការកំណត់មគ្គសច្ច ដោយការទទួលស្គាល់មគ្គដោយប្រពៃ ដោយប្រការដូច្នេះ ដែលជាការកំណត់សច្ចៈ ៤ ដោយញាណជាលោកិយៈ ។

( ចប់អដ្ឋកថា ឧទយព្វយញ្ញាណនិទ្ទេស )

# អដ្ឋកថា ភង្គានុបស្សនាញាណនិទ្ទេស

ព្រះយោគាវចរនោះ តាំងនៅក្នុងឧទយព្វយានុបស្សនាញាណ លុះដឹងឧទយព្វយានុបស្សនាញាណ ដែលបដិបត្តិទៅតាមវិថិ ផុតចាកឧបកិលេសដោយការកំណត់មគ្គ " ផ្លូវ " និងមិនមែនមគ្គ ថាជាមគ្គ " ផ្លូវដូច្នេះហើយ " ប្រារព្វឧទយព្វយានុបស្សនាញាណទៀត ដើម្បីធ្វើញាណនោះឲ្យបរិសុទ្ធិ៍ដោយល្អ ដោយកំណត់ត្រៃលក្ខណ៍ ហើយឃើញច្បាស់សង្ខារទាំងឡាយដែលកំណត់ដោយការកើត និងការរលត់ ដោយសភាពជារបស់មិនទៀងជាដើម ។ ញាណនោះ របស់ព្រះយោគាវចរនោះ ជាញាណចាស់ក្លា រមែងនាំទៅយ៉ាងនេះ , សង្ខារទាំងឡាយរមែងប្រាកដច្បាស់ , កាលបើញាណចាស់ក្លានាំទៅ កាលបើសង្ខារប្រាកដច្បាស់ ញាណមិនឈានកន្លងការកើត ការរលត់មានហើយ ក៏រមែងតាំងនៅព្រម ។

ម្យ៉ាងវិញទៀត ព្រោះបង្អោនទៅកាន់និរោធ ញាណក៏លះបង់ការកើត សតិតាំងទុកក្នុងការរលត់ , ភង្គានុបស្សនាញាណ



រមែងកើតឡើងក្នុងទីនេះ ។ ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃញាណនោះ បទថា **រូបារម្មណតា ចិត្តំ ឧប្បជ្ជិត្វា ភិជ្ជតិ** បានដល់ ចិត្តដែលមានរូបជាអារម្មណ៍កើតឡើងហើយរលត់ទៅ ។ ម្យ៉ាងវិញទៀត អធិប្បាយថា ចិត្តកើតឡើងព្រោះមានរូបជាអារម្មណ៍ ហើយរលត់ទៅ ។

បទថា **តំ អារម្មណំ បដិសង្ខា** ពិចារណាឃើញអារម្មណ៍នោះ សេចក្តីថា ដឹងអារម្មណ៍នោះ ដោយការពិចារណា ។ ឃើញដោយការអស់ទៅ ដោយសេចក្តីវិនាសទៅ ។

បទថា **តស្ស ចិត្តស្ស ភង្គំ អនុបស្សតិ** រមែងពិចារណាឃើញការរលត់នៃចិត្តនោះ សេចក្តីថា រូបជាអារម្មណ៍នោះ ដែលចិត្តណាឃើញដោយសភាពអស់ទៅ និងដោយសេចក្តីវិនាស , ព្រះយោគាវចររមែងពិចារណាឃើញការរលត់នៃចិត្តនោះ ដោយចិត្តដួងដទៃ ។ ដោយហេតុនោះ ព្រះបុរាណាចារ្យ ទើបពោលទុកថា **ញាតញ្ច ញាណញ្ច ឧភោ វិបស្សតិ** ព្រះយោគាវចររមែងពិចារណាឃើញទាំងពីរយ៉ាង គឺ ចិត្តដែលដឹងហើយ និងញាណ ។

ម្យ៉ាងទៀត ក្នុងបទថា **ចិត្តំ** នេះ លោកបំណងយកសម្ប-

ចិត្ត ។

បទថា **អនុបស្សតិ** រមែងពិចារណាឃើញ សេចក្ដីថា រមែងតាមឃើញរឿយ ៗ ដោយអាការមិនតិច ។ ដោយហេតុនោះ ព្រះសារីបុត្តទើបពោលថា **អនុបស្សតីតិ កថំ អនុបស្សតិ** , **អនិច្ចតោ អនុបស្សតិ** ជាអាទិ៍ រមែងពិចារណាឃើញយ៉ាងណា ឈ្មោះថា ពិចារណាឃើញ រមែងពិចារណាឃើញដោយសភាពមិនទៀង ។

ក្នុងបទនោះ មានអធិប្បាយដូចតទៅនេះ ព្រោះទីបំផុតខាងចុង ជារបស់មិនទៀង ឈ្មោះថា **ភង្គ** , ដូច្នោះ ព្រះយោគាវចរអ្នកចម្រើនភង្គានុបស្សនា រមែងពិចារណាឃើញរូបទាំងអស់ថា ជារបស់មិនទៀង , មិនមែនឃើញថា ជារបស់ទៀងទេ ។ ប៉ុន្តែការពិចារណាឃើញរូបនោះឯង ថាជាទុក្ខ មិនមែនឃើញថាជាសុខ ព្រោះវត្ថុដែលមិនទៀង ជាទុក្ខ និងវត្ថុដែលជាទុក្ខ ជាអនត្តា ។ រមែងពិចារណាឃើញថា ជាអនត្តា , មិនមែនឃើញថាជាអត្តាឡើយ ។

ម្យ៉ាងទៀត ព្រោះវត្ថុណាមិនទៀង ជាទុក្ខ ជាអនត្តា វត្ថុ



នោះមិនគួរត្រេកអរ , វត្ថុណាមិនគួរត្រេកអរ មិនគួរប្រាថ្នាក្នុងវត្ថុនោះ ។ ដូច្នោះ ព្រះយោគាវចររមែងនឿយណាយ ។ មិនមែនពេញចិត្ត , រមែងប្រាសចាកតម្រេក , មិនមែនប្រាថ្នាក្នុងរូបដែលបានឃើញនោះថា **អនិច្ចំ ទុក្ខំ អនត្តា** ដោយទំនងដូចគ្នានឹងភង្គានុបស្សនាញាណ ។

ព្រះយោគាវចរនោះ ប្រាសចាកតម្រេកយ៉ាងនេះ រំលត់រាគៈដោយញាណ ដែលត្រឹមតែជាលោកិយៈ , អធិប្បាយថា មិនកើតឡើង , មិនធ្វើឲ្យកើតឡើង ។ ម្យ៉ាងទៀត ព្រះយោគាវចរនោះ ប្រាសចាកតម្រេកយ៉ាងនេះហើយ រមែងរំលត់សមុទ្ររូបដែលមិនបានឃើញ ដូចរូបដែលបានឃើញដោយអំណាច **អន្វយញ្ញាណ** ញាណដែលបន្តជាប់គ្នា មិនមែនឲ្យកើតឡើង ។

ព្រះយោគាវចរធ្វើទុកក្នុងចិត្តដោយការរលត់ , រមែងឃើញការរលត់របស់រូបនោះ , មិនមែនឃើញការកើត ។ ព្រះយោគាវចរនោះ បដិបត្តិយ៉ាងនេះហើយ រមែងលះបង់ , មិនមែនកាន់យក ។ លោកអធិប្បាយទុកយ៉ាងណា ? ការពិចារណាឃើញភាពមិនទៀងជាដើមនេះ លោកពោលថា ជាការលះបង់

ដោយការបរិច្ចាគ និងលះបង់ដោយការស្ទុះទៅ ព្រោះលះបង់កិលេសជាមួយអភិសង្ខារដោយតទង្គប្បហាន និងព្រោះការស្ទុះទៅ ព្រោះបង្អោនញាណនោះទៅក្នុងព្រះនិព្វាន ដែលផ្ទុយគ្នាជាមួយនឹងកិលេសនោះ ដោយការឃើញទោសរបស់សង្ខតៈ ។

ព្រោះដូច្នោះ ភិក្ខុអ្នកប្រកបដោយអនុបស្សនានោះ រមែងបរិច្ចាគ លះបង់កិលេសទាំងឡាយ ដោយន័យដូចពោលហើយ និងរមែងស្ទុះទៅក្នុងនិព្វាន ។ មិនចាប់ប្រកាន់កិលេស ដោយធ្វើឲ្យកើតឡើង , មិនប្រកាន់សង្ខតៈជាអារម្មណ៍ដោយការសំឡឹងដល់ទោស , ដោយហេតុនោះ លោកទើបពោលថា **បដិនិស្សជ្ជតិ** ,**នោ អាទិយតិ** រមែងលោះបង់ចោល , រមែងមិនកាន់យក ។

ឥឡូវនេះ ដើម្បីសម្តែងការលះបង់ធម៌ដោយញាណទាំងនោះ របស់ព្រះយោគាវចរនោះ ព្រះសារីបុត្តទើបពោលបទមានជាអាទិ៍ថា **អនិច្ចតោ អនុបស្សន្តោ និច្ចសញ្ញំ បជហតិ** ព្រះយោគាវចរ កាលពិចារណាឃើញថា មិនទៀង រមែងលះបង់សញ្ញាថា ទៀង ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **នន្ទឹ** សេចក្តីរីករាយ បានដល់



តណ្ហាប្រកបព្រមជាមួយបីតិ ។

បទថា **រាគំ** តម្រេក បានដល់ តណ្ហាដ៏សេស ។

បទថា **សមុទយំ** ការកើតឡើង បានដល់ ការកើតឡើងនៃរាគៈ ។ ម្យ៉ាងទៀត បានដល់ ការកើតឡើងនៃរូប ។

បទថា **អាទានំ** ការប្រកាន់ បានដល់ ការប្រកាន់ដោយកិលេសដែលធ្វើឲ្យកើតឡើង ។ គប្បីជ្រាបបទមានជាអាទិ៍ថា **វេទនារម្មណតា** ការមានវេទនាជាអារម្មណ៍ ដោយន័យដូចពោលហើយក្នុងទីនេះ និងក្នុងខាងដើម ។

ម្យ៉ាងទៀត គប្បីជ្រាបក្នុងគាថាទាំងឡាយដូចតទៅនេះ បទថា **វត្ថុសង្កមនា** ការឈានទៅកាន់វត្ថុ សេចក្តីថា ការឈានទៅកាន់វត្ថុដទៃពីបុរិមវត្ថុ ដោយឃើញការរលត់របស់ចិត្ត ដែលឃើញការរលត់របស់ខន្ធមួយ ៗ ក្នុងខន្ធទាំងឡាយ មានរូបក្ខន្ធជាដើម ជាការឃើញសភាពរលត់ហើយ ។

បទថា **បញ្ញាយ ច វិវដ្ដនា** ការចៀសចេញដោយបញ្ញា បានដល់ លះបង់ការកើតចេញ ហើយតាំងនៅក្នុងការបែកធ្លាយ ។

បទថា **អាវជ្ជនា ពលញ្ចេវ** ការរំពឹងរកតាមលំដាប់នោះ

ឯង ដើម្បីឃើញការរលត់របស់ខន្ធមួយ ៗ ក្នុងខន្ធទាំងឡាយ មានរូបក្ខន្ធជាដើម ឃើញការរលត់របស់ចិត្តដែលមានការរលត់ជាអារម្មណ៍ ។

បទថា **បដិសង្ខា វិបស្សនា** ការពិចារណារកផ្លូវ និងការឃើញច្បាស់ គឺ ការពិចារណាអារម្មណ៍នេះ ឈ្មោះថា **ភង្គានុបស្សនា** ។

បទថា **អារម្មណអន្វយេន ឧភោ ឯកវវត្ថនា** ធម៌ ២ យ៉ាង បណ្ឌិតកំណត់យកសភាពតែមួយ ដោយការប្រព្រឹត្តទៅតាមអារម្មណ៍ សេចក្ដីថា ការកំណត់ធម៌ ២ ប្រការដោយសភាពតែមួយថា សង្ខារសូម្បីក្នុងអតីតបែកធ្លាយហើយ , សូម្បីក្នុងអនាគតក៏នឹងបែកធ្លាយដូចសង្ខារនេះ ដោយការប្រព្រឹត្តទៅតាមអារម្មណ៍ដែលបានឃើញហើយ ដោយប្រច័ក្ស ។ សូម្បីបុរាណាចារ្យ ក៏ពោលទុកថា ៖

**សំវិជ្ជមានម្ហិ វិសុទ្ធតស្សនោ**
**តទន្វយំ នេតិ អតីតានាគតេ ,**
**សព្វេបិ សង្ខារគតា បលោកិនោ**



**ឧស្សាវពិន្ទូ សុរិយេវ ឧគ្គតេ ។**

ភិក្ខុអ្នកមានការឃើញដ៏បរិសុទ្ធក្នុងសង្ខារ ដែលជាបច្ចុប្បន្ន រមែងបង្អោននាំការឃើញដ៏បរិសុទ្ធនោះទៅ ពិចារណាសង្ខារដែលជាអតីត និងអនាគត សង្ខារទាំងឡាយ សូម្បីទាំងអស់ ក៏មានប្រក្រតីបែកធ្លាយទៅ ដូចទឹកសន្សើមដែលត្រូវស្ងួតទៅ កាលព្រះអាទិត្យរះឡើង ដូច្នោះ ។

បទថា **និរោធ អធិមុត្តតា** ការបង្អោនចិត្តទៅក្នុងការរលត់ សេចក្ដីថា ការបង្អោនទៅក្នុងភាពជាអ្នកចុះចិត្តស៊ប់ ភាពទេរទៅ ការឱនទៅ ការទេរទៅ ក្នុងភាពរលត់ ដែលបានដល់ភង្គៈ ការបែកធ្លាយនោះ ព្រោះធ្វើការកំណត់ធម៌ទាំងពីរយ៉ាងឲ្យមកតែមួយ ដោយអំណាចការរលត់យ៉ាងនេះ ។

បទថា **វយលក្ខណវិបស្សនា** ពិចារណាឃើញនូវលក្ខណៈសូន្យទៅ លោកអធិប្បាយថា វិបស្សនានេះ ឈ្មោះថា **វយលក្ខណវិបស្សនា** ។

បទថា **អារម្មណញ្ច បដិសង្ខា** ពិចារណាអារម្មណ៍ គឺដឹងអារម្មណ៍ មានរូបជាដើម ។

បទថា **ភង្គញ្ច អនុបស្សតិ** ពិចារណាឃើញការបែកធ្លាយ សេចក្ដីថា ឃើញការរលត់របស់អារម្មណ៍នោះហើយ ពិចារណាឃើញការរលត់របស់អារម្មណ៍នោះ និងរបស់ចិត្ត ។

បទថា **សុញ្ញតោ ច ឧបដ្ឋានំ** ប្រាកដដោយភាពជារបស់សូន្យ បានដល់ ការប្រាកដដោយភាពជារបស់សូន្យថា សង្ខារទាំងឡាយរមែងបែកធ្លាយ , ការបែកធ្លាយនៃសង្ខារទាំងនោះ គឺសេចក្ដីស្លាប់ , មិនមានអ្វី ៗ ដទៃ ដូច្នេះរមែងសម្រេច ។ ដោយហេតុនោះ បុរាណាចារ្យទើបពោលថា

**ខន្ធា និរុជ្ឈន្តិ ន ចត្ថិ អញ្ញោ**
**សន្ធាន ភេទោ មរណន្តិ វុច្ចតិ ,**
**តេសំ ខយំ បស្សតិ អប្បមត្តោ**
**មណីវ វិជ្ឈំ វជិរេន យោនិសោ ។**

ខន្ធទាំងឡាយរមែងរលត់ មិនមានអ្វី ៗ ដទៃ គឺ មិនមានសត្វបុគ្គល ការបែកធ្លាយនៃខន្ធ លោកហៅថា មរណៈ អ្នកមិនប្រមាទ ឃើញការអស់ទៅនៃខន្ធទាំងនោះដោយប្រពៃ ដូចជាងកែវមណី ធ្វើទុកក្នុងចិត្តនូវការចោះទម្លុះដោយពេជ្រ ដូច្នោះ ។



បទថា **អធិប្បញ្ញា វិបស្សនា** លោកអធិប្បាយទុកថា ការពិចារណាអារម្មណ៍ ការឃើញច្បាស់នូវការបែកធ្លាយ និងការប្រាកដឡើង ថាសូន្យ ឈ្មោះថា **អធិប្បញ្ញាវិបស្សនា** ការឃើញច្បាស់ដោយអធិប្បញ្ញា ។

បទថា **កុសលោ តីសុ អនុបស្សនាសុ** បានដល់ ភិក្ខុអ្នកឆ្លាតក្នុងអនុបស្សនា ៣ មានអនិច្ចានុបស្សនាជាដើម ។

បទថា **ចតូសុ ច វិបស្សនាសុ** បានដល់ ក្នុងវិបស្សនា ៤ មាននិព្វិទានុបស្សនាជាដើម ។

បទថា **តយោ ឧបដ្ឋានេ កុសលតា** ភាពជាអ្នកឆ្លាតសេចក្ដីប្រាកដ ៣ ប្រការ បានដល់ ព្រោះភាពជាអ្នកឆ្លាតក្នុងសេចក្ដីប្រាកដ ៣ ប្រការនេះ គឺ ដោយការអស់ទៅ , ដោយការវិនាស និងដោយការសូន្យទៅ ។

បទថា **នានាទិដ្ឋីសុ ន កម្បតិ** រមែងមិនញាប់ញ័រក្នុងទិដ្ឋិផ្សេងៗ គឺ មិនញាប់ញ័រក្នុងទិដ្ឋិមានប្រការផ្សេង ៗ មានសស្សតទិដ្ឋិជាដើម ។ ព្រះយោគាវចរនោះ មិនបានញាប់ញ័រយ៉ាងនេះ មានមនសិការប្រព្រឹត្តទៅហើយថា វត្ថុមិនរលត់ រមែងរលត់ ,

វត្ថុមិនបែកធ្លាយ រមែងបែកធ្លាយ ដូច្នេះ ក៏លះបង់និមិត្តដែលប្រព្រឹត្តទៅហើយក្នុងឧប្បាទឋិតិនៃសង្ខារទាំងពួង ដូចភាជនៈចាស់កំពុងបែក , ដូចធូលីល្អិតកំពុងតែហុយឡើង , ដូចគ្រាប់ល្ងលីង រមែងឃើញការបែកធ្លាយនោះឯង ។ ព្រះយោគាវចរនោះ រមែងឃើញថា សង្ខារទាំងឡាយទាំងពួង រមែងបែកទៅបែកធ្លាយ ដូចបុរសអ្នកមានភ្នែកល្អ ឈរលើមាត់ស្រះបោក្ខរណី ឬឈរលើមាត់ជ្រាំងទន្លេ កាលបើគ្រាប់ភ្លៀងធ្លាក់ចុះមក គប្បីឃើញពពកទឹកធំកើតឡើងលើផ្ទៃទឹក ហើយក៏បែកធ្លាយទៅវិញដូច្នោះ ។

ព្រះមានព្រះភាគជាម្ចាស់ ត្រាស់សំដៅដល់ព្រះយោគាវចរអ្នកឃើញយ៉ាងនេះថា

យថា បុព្វុឡកំ បស្សេ យថា បស្សេ មរីចិកំ
ឯវំ លោកំ អវេក្ខន្តំ មច្ចុរាជា ន បស្សតិ ។

មច្ចុរាជ រមែងមិនឃើញអ្នកដែលពិចារណាឃើញលោកដូចព្រះយោគាវចរឃើញពពុះទឹក ឬថ្ងៃបណ្តើរកូន ដូច្នោះ ។

កាលបើព្រះយោគាវចរនោះ ឃើញរឿយ ៗ យ៉ាងនេះថា



សង្ខារទាំងឡាយទាំងពួង រមែងបែកធ្លាយទៅ ៗ ដូច្នេះ ភង្គានុបស្សនាញាណ មានអានិសង្ស ៨ ជាបរិវារ រមែងមានកម្លាំង ។

**អានិសង្ស ៨ ទាំងនេះ គឺ ៖**

ការលះភវទិដ្ឋិ ១

ការលះសេចក្តីប្រាថ្នាក្នុងជីវិត ១

ការប្រកបសេចក្តីខ្វល់ខ្វាយក្នុងបុណ្យកុសលគ្រប់កាល ១

ភាពមានអាជីវៈបរិសុទ្ធ ១

លះសេចក្តីខ្វល់ខ្វាយក្នុងការធ្វើបាប ១

ប្រាសចាកភ័យ ១

ការបានខន្តិ និងសោរច្ចៈ ១

ការអត់ទ្រាំក្នុងសេចក្តីត្រេកអរ និងទាស់ចិត្ត ១

ដោយហេតុនោះ បុរាណាចារ្យទើបពោលថា ៖

ឥមានិ អដ្ឋគុណមុត្តមានិ
ទិស្វា តហិ សម្មសតី បុនប្បុនំ ,
អាទិត្តចេលស្សិរសូបមោ មុនិ
ភង្គានុបស្សី អមតស្ស បត្តិយា ។

ព្រះមុនីអ្នកឃើញសង្ខារទាំងឡាយ បែកធ្លាយទៅរឿយ ៗ លុះឃើញអានិសង្ស ដែលមានការលះភវទិដ្ឋិជាដើមទាំងនេះថា ជាធម៌ដ៏ខ្ពស់បំផុត ដោយគុណ ៨ ប្រការហើយ ដើម្បីសម្រេចអមតៈ គឺ ព្រះនិព្វាន ទើបពិចារណាសង្ខារដោយភង្គានុបស្សនារឿយ ៗ ដូចបុគ្គលមានសំពត់ជួតក្បាលដែលភ្លើងកំពុងឆេះ ដូច្នោះ ។

( ចប់អដ្ឋកថា ភង្គានុបស្សនាញាណនិទ្ទេស )



# អដ្ឋកថា អាទីនវញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងអាទីនវញ្ញាណនិទ្ទេស ដូចតទៅនេះ បទថា **ឧប្បាទោ** ការកើតឡើង គឺ ការកើតឡើងក្នុងលោកនេះ ព្រោះកម្មចាស់ជាបច្ច័យ ។

បទថា **បវត្តំ** ការប្រព្រឹត្តទៅ គឺ ការប្រព្រឹត្តទៅ នៃការកើតឡើងយ៉ាងនោះ ។ បទថា **និមិត្តំ** គឺ សង្ខារនិមិត្តសូម្បីទាំងអស់ ។

បទថា **អាយូហនំ** កម្មប្រមូលមកជាភ័យ គឺ កម្មដែលជាហេតុនៃបដិសន្ធិតទៅ ។ បទថា **បដិសន្ធិ** គឺ ការកើតតទៅ ។

បទថា **គតិ** បានដល់ គតិដែលជាបដិសន្ធិ ។

បទថា **និព្វត្តិ** បានដល់ ការកើតឡើងនៃខន្ធទាំងឡាយ ។

បទថា **ឧបបត្តិ** បានដល់ ការប្រព្រឹត្តទៅនៃវិបាកដែលលោកពោលទុកថា **សមាបន្នស្ស វា ឧប្បន្នស្ស វា** នៃភិក្ខុអ្នកចូលសមាបត្តិហើយក្តី អ្នកចូលដល់ហើតក្តី ។

បទថា **ជាតិ** បានដល់ ជាតិមានភពជាបច្ច័យ ដែលជា

បច្ច័យនៃជរាជាដើម ។ ដោយត្រង់ ជាតិ គឺ ការប្រាកដគ្រាដំបូង នៃខន្ធទាំងឡាយ ដែលប្រាកដដល់សត្វដែលកើតក្នុងភពនោះ ៗ ។

បទថា **ជរា** បានដល់ ការចាស់នៃខន្ធសន្តានដែលទាក់ទងគ្នាក្នុងភពមួយ ក្នុងសន្តតិដែលដឹងថា មានធ្មេញបាក់ជាដើម ។

បទថា **សោកោ** បានដល់ សេចក្តីក្តៅក្រហាយចិត្តរបស់អ្នកដែលត្រូវសេចក្តីវិនាសញាតិជាដើម ពាល់ត្រូវ ។

បទថា **បរិទេវ** បានដល់ សេចក្តីខ្សឹកខ្សួលរបស់អ្នកដែលត្រូវសេចក្តីវិនាសញាតិជាដើម ពាល់ត្រូវ ។

បទថា **ឧបាយាសោ** បានដល់ សេចក្តីចង្អៀតចង្អល់ចិត្តយ៉ាងខ្លាំង គឺ ទោសៈដែលកើតពីទុក្ខតាមផ្លូវចិត្តយ៉ាងខ្លាំងរបស់អ្នកដែលត្រូវសេចក្តីវិនាសញាតិជាដើម ពាល់ត្រូវ ។

ម្យ៉ាងទៀត ក្នុងបទនេះលោកពោលដល់ញាណក្នុងអាទី-នវញ្ញាណ ៥ យ៉ាង មានឧប្បាទៈជាដើម ដោយអំណាចជាទីតាំងនៃអាទីនវញ្ញាណ ។ ដ៏សេស លោកពោលដោយភាពជាវេវចនៈនៃធម៌ទាំងនោះ ។



ពីរបទនេះ គឺ **និព្វត្តិ ជាតិ** ជាវេវចនៈនៃ **ឧប្បាទ** និង **បដិសន្ធិ** ។ ពីរបទនេះ គឺ **គតិ ឧបបត្តិ** ជាវេវចនៈនៃការប្រព្រឹត្តទៅ , **ជរា** ជាដើម ជាវេវចនៈនៃ **និមិត្ត** ។ ដូចដែលលោកពោលទុកថា ៖

**ឧប្បាទញ្ច បវត្តញ្ច និមិត្តំ ទុក្ខន្តិ បស្សតិ**
**អាយូហនំ បដិសន្ធឹ ញាណំ អាទីនវេ**
**ឥទន្តិច ឥទំ អាទីនវេ ញាណំ បញ្ចដ្ឋានេសុ**
**ជាយតីតិច ។**

ព្រះយោគាវចរ រមែងឃើញឧប្បាទៈ គឺ ការកើត បវត្តៈ គឺ ការប្រព្រឹត្តទៅ និមិត្តៈ គឺ គ្រឿងសម្គាល់ អាយូហនៈ គឺ កម្មជាហេតុឲ្យបដិសន្ធិ និងបដិសន្ធិការកើត ថាជាទុក្ខ នេះជាអាទីនវញ្ញាណ និងអាទីនវញ្ញាណនេះ រមែងកើតឡើងក្នុងឋានៈ ៥ ។

ម្យ៉ាងវិញទៀត ពាក្យថា **ភយន្តិ** ក្នុងគ្រប់បទ កាត់បទជា **ភយំ ឥតិ** ។ បទថា **ភយំ** ឈ្មោះថា **ភ័យ** ព្រោះមានភ័យចំពោះមុខ ដោយប្រកបការបៀតបៀន ។ បទថា **ឥតិ** ជាការសម្តែង

ហេតុនៃ **ភយតូបដ្ឋានញ្ញាណ** ។

ចំណែកបទមានជាអាទិ៍ថា **អនុប្បាទោ ខេមន្តិ សន្តិបទេ ញាណំ** គឺ ញាណក្នុងសន្តិបទថា ការមិនកើត ជាការរួចផុតពីភ័យ លោកពោលដើម្បីសម្ដែងញាណដែលជាបដិបក្ខចំពោះអាទីនវញ្ញាណ ។ម្យ៉ាងទៀត បទនេះ លោកពោលទុកដើម្បីឲ្យកើតសេចក្ដីកក់ក្ដៅនៃចិត្តថា សូម្បីហឫទយដែលភ័យខ្លាច ព្រោះឃើញទោសដោយភយតូបដ្ឋានញ្ញាណ មិនមានភ័យ មានការរួចផុតពីភ័យ គឺ មិនមានទោស ។

ម្យ៉ាងវិញទៀត ព្រោះចិត្តរបស់អ្នកដែលមានឧប្បាទៈជាដើម តាំងទុកដោយល្អ ដោយភាពជាភ័យបង្អោនទៅ ក្នុងភាពជាបដិបក្ខចំពោះភ័យនោះ , ដូច្នោះគប្បីជ្រាបថា បទនេះ លោកពោលដើម្បីសម្ដែងដល់អានិសង្សនៃអាទីនវញ្ញាណ ដែលសម្រេចហើយដោយភយតូបដ្ឋាបញ្ញាណ ។

បទមានជាអាទិ៍ថា **អនុប្បាទោ អប្បវត្តំ** ការមិនកើត ការមិនប្រព្រឹត្តទៅ បានដល់ និព្វាននោះឯង ។

បទថា **សន្តិបទេ** ក្នុងសន្តិបទ បានដល់ ក្នុងចំណែកនៃ



សន្តិ គឺ ក្នុងនិព្វាន ។ ពិតណាស់ សូម្បីញាណកើតឡើង ព្រោះកាន់យកសេចក្ដីផ្សេងគ្នាថា **សន្តិបទំ** ដោយការបានស្ដាប់មក ។ លោកក៏ពោលថា **សន្តិបទេ ញាណំ** គឺ ញាណក្នុងសន្តិបទដូច្នេះ ។

បទមានជាអាទិ៍ថា **ឧប្បាទោ ភយំ , អនុប្បាទោ ខេមំ** ការកើតជាភ័យ , ការមិនកើតផុតអំពីភ័យ លោកសង្ខេបបទទាំងពីរដោយអំណាចការផ្ទុយគ្នា ហើយពោលកាន់យកញាណដែលកើតឡេង ។

ម្យ៉ាងទៀត ក្នុងបទនេះ ព្រោះភ័យជាទុក្ខពិតប្រាកដ ។ ហើយវត្ថុណាជាទុក្ខ , វត្ថុនោះឈ្មោះថាជាអាមិស ព្រោះមិនផុតចាកអាមិស គឺ វដ្ដៈ , អាមិស គឺ លោកៈ និងអាមិស គឺ កិលេស ។ ម្យ៉ាងទៀត វត្ថុណាជាអាមិស វត្ថុនោះត្រឹមតែសង្ខារប៉ុណ្ណោះ ។ ព្រោះដូច្នោះ លោកទើបពោលបទមានជាអាទិ៍ថា **ឧប្បាទោ ទុក្ខន្តិ ភយតូបដ្ឋានេ បញ្ញា អាទីនវេ ញាណំ** បញ្ញាក្នុងការប្រាកដថាជារបស់គួរខ្លាចថា ការកើតជាទុក្ខ ជាអាទីនវញ្ញាណ ។

សូម្បីយ៉ាងនោះ គប្បីជ្រាបសេចក្តីផ្សេងគ្នាក្នុងបទនេះ ដោយអំណាចការប្រព្រឹត្តទៅ ដោយសេចក្តីផ្សេងគ្នា ដោយអាការយ៉ាងនេះ គឺ ដោយអាការគួរខ្លាច ដោយអាការជាទុក្ខ ដោយអាការជាអាមិស ដោយអាការជាសង្ខារ ។

លោកមិនបានសំដៅដល់លិង្គ មាន់ប្បាទៈជាដើមថា **ឧប្បាទោ ភយំ , ទុក្ខំ , សាមិសំ , សង្ខារា** ច ការកើតជាភ័យ , ជាទុក្ខ , ជាអាមិសៈ និងសង្ខារ ហើយទើបពោលដល់ការសម្លឹងលិង្គរបស់ខ្លួន ដូចក្នុបទមានជាអាទិ៍ថា **នេតំ ខោ សរណំ ខេមំ , នេតំ សរណមុត្តមំ** នេះឯងមិនមែនជាទីពឹងដ៏ក្សេម , នេះមិនមែនជាទីពឹងដ៏ឧត្តម ។

ម្យ៉ាងទៀត បទថា **សង្ខារា** គឺ លោកមិនបានសម្លឹងសេចក្តីតែម្យ៉ាង ទើបធ្វើជាពហុវចនៈ ដូចក្នុងប្រយោគមានជាអាទិ៍ថា **អប្បច្ចយា ធម្មា , អសង្ខតា ធម្មា** ធម៌ទាំងឡាយដែលមិនមានបច្ច័យ , ធម៌ទាំងឡាយដែលជាអសង្ខតៈ ឬព្រោះថា **ឧប្បាទោ** ជាដើម ជាឯកទេសនៃសង្ខារ គប្បីជ្រាបថា លោកធ្វើជាពហុវចនៈ សូម្បីក្នុងឯកទេសនៃសង្ខារ ជាចំណែកច្រើន ដូចក្នុងបទមានជាអាទិ៍ថា **ឧត្តរេ បញ្ចាលា , ទក្ខិណេ បញ្ចាលា** អ្នកស្រុកបញ្ចាលនគរក្នុងទិសឧត្តរ , អ្នកស្រុកបញ្ចាលនគរ ក្នុងទិសទក្សិណ ។



បទថា **ខេមំ សុខំ និរាមិសំ និព្វានំ** និព្វានជាការរួចផុតពីភ័យ ជាសេចក្តីសុខ មិនមានអាមិស គឺ លោកពោលនិព្វាននោះឯងជា ៤ យ៉ាង ដែលជាបដិបក្ខចំពោះអាការដូចពោលហើយ ។

បទថា **ទស ញាណេ បជានាតិ** គឺ ព្រះយោគាវចរ រមែងដឹងញាណ ១០ បានដល់ ព្រះយោគាវចរកាលដឹងអាទីនវញ្ញាណ រមែងដឹង រមែងចាក់ធ្លុះ រមែងធ្វើឲ្យជាក់ច្បាស់នូវញាណ ១០ គឺ ញាណដែលជាទីតាំងនៃ **ឧប្បាទ** ការកើតជាដើម ៥ , ញាណដែលជាទីតាំងនៃ **អនុប្បាទ** ការមិនកើត ៥ ។

បទថា **ទ្វិន្នំ ញាណានំ កុសលតា** ព្រោះភាពជាឆ្លាតក្នុងញាណទាំង ២ បានដល់ ព្រោះភាពជាអ្នកឆ្លាតក្នុងញាណទាំងពីរយ៉ាង ទាំងនេះ គឺ **អាទីនវញ្ញាណ** និង **សន្តិបទញ្ញាណ** ។

បទថា **នានាទិដ្ឋីសុ ន កម្បតិ** គឺ រមែងមិនញាប់ញ័រក្នុងទិដ្ឋិផ្សេង ៗ គឺ មិនញាប់ញ័រក្នុងទិដ្ឋិទាំងឡាយ ដែលប្រព្រឹត្តទៅ

ហើយដោយអំណាចនិព្វាន ដែលជាទិដ្ឋធម៌ដ៏ប្រសើរ ។

( ចប់អដ្ឋកថា អាទីនវញ្ញាណនិទ្ទេស )



# អដ្ឋកថា សង្ខារុបេក្ខាញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ ក្នុងសង្ខារុបេក្ខាញាណនិទ្ទេសដូចតទៅនេះ បទថា **ឧប្បាទោ** ជាដើម មានអត្ថដូចពោលទុកហើយនោះឯង ។

ច្រើនបទថា **ទុក្ខន្តិ ភយន្តិ សាមិសន្តិ សង្ខារា** ការកើតឡើងជាទុក្ខ ការកើតឡើងជាភ័យ ការកើតឡើងជាអាមិស ការកើតឡើងជាសង្ខារ ជាពាក្យសម្តែងហេតុរបស់ញាណ គឺ ការរួចផុតចាក **ឧប្បាទ** ជាដើម ។

ព្រះសារីបុត្ត លុះសម្តែងដល់សង្ខារុបេក្ខាញាណ ដោយលក្ខណៈយ៉ាងនេះហើយ ពេលនេះដើម្បីសម្តែងដោយអត្ថ ទើបពោលបទមានជាអាទិ៍ថា **ឧប្បាទោ សង្ខារា , តេ សង្ខារេ អជ្ឈុបេក្ខតីតិ សង្ខារុបេក្ខា** ការកើតឡើងជាសង្ខារ , ញាណដែលព្រងើយកន្តើយចំពោះសង្ខារទាំងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **សង្ខារុបេក្ខាញាណ** ។

ក្នុងបទទាំងនោះ បទថា **សង្ខារេ អជ្ឈុបេក្ខតិ** ញាណ

ដែលព្រងើយកន្តើយក្នុងសង្ខារ សេចក្តីថា កាលព្រះយោគាវចរនោះ ផ្តើមចម្រើនវិបស្សនា លះសេចក្តីខ្វល់ខ្វាយក្នុងការស្វែងរកលក្ខណៈ ព្រោះឃើញត្រៃលក្ខណ៍ដោយវិបស្សនាញាណហើយ ឃើញភព ៣ ដូចភ្លើងឆេះដោយទូទៅ មានសភាពជាកណ្តាលក្នុងការកាន់យកសង្ខារ វិបស្សនាញាណនោះ រមែងឃើញសង្ខារទាំងនោះដោយពិសេស និងឃើញ គឺ សម្លឹងមើលញាណដែលវៀរហើយដោយការកាន់យក ព្រោះហេតុនោះ ទើបឈ្មោះថា **សង្ខារុបេក្ខាញាណ** ។ ដូចលោកពោលថា អ្នកឈ្នះដោយពិសេសឈ្មោះថា រមែងឈ្នះដ៏ក្រៃលែងក្នុងលោក , អ្នកវៀរចាកអាហារសូមនៅជាមួយ ឈ្មោះថា ចូលទៅអាស្រ័យ ។ ញាណដែលឃើញសង្ខារថា ជារបស់មិនទៀងជាដើមទៀត ឃើញច្បាស់ សូម្បីសង្ខារុបេក្ខាដែលតាំងនៅក្នុងភាពជាកណ្តាល ដោយភាពជារបស់មិនទៀងជាដើមក្នុងការកាន់យក លោកទើបពោលបទមានជាអាទិ៍ថា **យេ ច សង្ខារា , យា ច ឧបេក្ខា** ទាំងសង្ខារ និងឧបេក្ខា ក៏ជាសង្ខារ ព្រោះកើតព្រមគ្នាជាមួយសង្ខារុបេក្ខា ដែលតាំងនៅដោយអាការជាកណ្តាល ក្នុងការកាន់យកសង្ខារុបេក្ខានោះ ។



ឥឡូវនេះ ព្រះសារីបុត្ត កាលនឹងសម្តែងប្រភេទរបស់ការបង្អោនចិត្តទៅក្នុសង្ខារុបេក្ខា ទើបពោលបទមានជាអាទិ៍ថា **ក-តីហាការេហិ** ដោយអាករប៉ុន្មាន ។ ក្នុងបទទាំងនោះ បទថា **សង្ខារុបេក្ខាយ** ជាសត្តមីវិភត្តិ ប្រែក្នុងសង្ខារុបេក្ខា ។ បទថា **ចិត្តស្ស អភិនីហារោ** ការបង្អោនទៅនៃចិត្ត បានដល់ កាលធ្វើចិត្តដទៃអំពីនោះ ឲ្យឆ្ពោះទៅកាន់សេចក្តីខ្វល់ខ្វាយរបស់សង្ខារ ហើយនាំទៅដ៏យ៉ាងធ្ងន់ ។ **អភិ** សព្ទ ក្នុងបទនេះ មានសេចក្តីថា ចំពោះមុខ ។ **នី** សព្ទ មានសេចក្តីថា ក្រៃលែង ព្រះសារីបុត្តមានបំណងនឹងដោះស្រាយពាក្យសួរ ដែលសួរថា **កតីហាការេហិ** ដោយអាការប៉ុន្មាន ឆ្លើយថា **អដ្ឋហាការេហិ** ដោយអាការ ៨ យ៉ាង ហើយទើបសម្តែងអាការ ៨ ទាំងនោះ ដោយដោះស្រាយពាក្យសួរប្រការទី ២ ទើបមិនសម្តែងអាការទាំងនោះ បានតាំងពាក្យសួរមានជាអាទិ៍ថា **បុថុជ្ជនស្ស កតីហាការេហិ** ការបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខារបស់បុថុជ្ជន ដោយអាការប៉ុន្មាន ។ ក្នុងបទថា **បុថុជ្ជនស្ស** នេះ មានគាថាដូចតទៅនេះ

**ទុវេ បុថុជ្ជនា វុត្តា ពុទ្ធេនាទិច្ចពន្ធុនា**

**អន្ធោ បុថុជ្ជនោ ឯកោ  កល្យាណេកោ បុថុជ្ជនោ ។**

ព្រះសម្ពុទ្ធជាម្ចាស់ អ្នកមានផៅពង្សដូចជាព្រះអាទិត្យ ត្រាស់ដល់បុថុជ្ជនទុក ២ ជំពូក មួយពួកជាអន្ធបុថុជ្ជន មួយពួកជាកល្យាណបុថុជ្ជន ។

ក្នុងបុថុជ្ជន ២ ពួកនោះ បុថុជ្ជនដែលមិនបានរៀន មិនបានសាកសួរ មិនបានស្តាប់ មិនចាំទុក និងមិនពិចារណាជាដើម ក្នុងខន្ធ ធាតុ អាយតនៈជាដើម ជា **អន្ធបុថុជ្ជន** បុថុជ្ជនដែលមានការរៀនជាដើម ជា **កល្យាណបុថុជ្ជន** ។

សូម្បីបុថុជ្ជន ២ ពួកនោះ ក៏មានគាថាថា ៖

**បុថូនំ ជននាទីហិ ការណេហិ បុថុជ្ជនោ**

**បុថុជ្ជនន្តោគធត្តា បុថុវាយំ ជនោ ឥតិ ។**

ឈ្មោះថា បុថុជ្ជន ដោយហេតុញ៉ាំងកិលេសឲ្យកើតឡើង ព្រោះភាវៈជាអ្នកមានកិលេសក្រាស់លិចចុះខាងក្នុង ទើបឈ្មោះថា **បុថុជ្ជន** ។

ឈ្មោះថា **បុថុជ្ជន** ដោយហេតុញ៉ាំងកិលេសជាដើម មានប្រការផ្សេង ៗ ដ៏ក្រាស់ឲ្យកើតឡើង ។ ដូចលោកពោលថា ឈ្មោះ



ថា **បុថុជ្ជន** ព្រោះអត្ថថា ញ៉ាំងកិលេសដ៏ក្រាស់ឲ្យកើត , ព្រោះអត្ថថា មិនកម្ចាត់សក្កាយទិដ្ឋិដ៏ក្រាស់ចេញ , ព្រោះអត្ថថា ជ្រើសរើសសាស្តាច្រើន , ព្រោះអត្ថថា គតិទាំងពួងដោតក្រងទុក , ព្រោះអត្ថថា រមែងចាត់ចែងដោយអភិសង្ខារ ឱឃៈផ្សេងៗ , ព្រោះអត្ថថា រមែងក្តៅក្រហាយ ព្រោះកិលេស ជាហេតុធ្វើឲ្យក្តៅក្រហាយ , ព្រោះអត្ថថា ដុតរោលដោយអន្តរាយផ្សេង ៗ , ព្រោះអត្ថថា ជាអ្នកត្រេកអរ រីករាយ ពេញចិត្ត វង្វេង ជាប់ចិត្ត ទាក់ទង ពាក់ព័ន្ធក្នុងកាមគុណ ៥ , ព្រោះអត្ថថា ត្រូវចងរឹតគ្របទុក បិទបាំង ហ៊ុំព័ទ្ធ លប់បំបាត់ វៀចវេរ ដោយនិវរណៈ ៥ ដូច្នេះ ។

ម្យ៉ាងទៀត ឈ្មោះថា **បុថុជ្ជន** ព្រោះជាអ្នកមានកិលេសក្រាស់រាប់ពុំបាន បែរខ្នងដាក់អរិយធម៌ ប្រព្រឹត្តធម៌ថោកទាប , ម្យ៉ាងទៀត ព្រោះជាអ្នកមានកិលេសក្រាស់ដោយប្រការផ្សេង ៗ មិនសាកសួរជាមួយព្រះអរិយៈ ជាអ្នកប្រកបដោយគុណ ជាអ្នកមានសីល និងសុតៈជាដើម ។ ក្នុងបុថុជ្ជន ២ ពួកនោះ ក្នុងទីនេះ លោកបំណងយកកល្យាណបុថុជ្ជន , ព្រោះជនក្រៅអំពីនេះ

មិនមានការចម្រើនការនោះឡើយ ។

ក្នុងបទថា **សេក្ខស្ស** នេះ បានដល់ ព្រះសេក្ខៈ ៧ ពួក គឺ អ្នកតាំងនៅក្នុងសោតាបត្តិមគ្គ សោតាបត្តិផល សកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផល និងអរហត្តមគ្គ ឈ្មោះថា **សេក្ខ** ព្រោះលោកទាំងនោះនៅសិក្សាសិក្ខា ៣ ។ ក្នុងព្រះសេក្ខៈទាំងនោះ ក្នុងទីនេះ លោកបំណងយកព្រះសេក្ខៈ ៣ ពួក អ្នកតាំងនៅក្នុងសោតាបត្តិផល សកទាគាមិផល និអនាគាមិផល ព្រោះលោកតាំងនៅក្នុងមគ្គ មិនបង្អោនចិត្តទៅក្នុងសង្ខារុបេក្ខា ។

ក្នុងបទថា **វីតរាគស្ស** នេះ ឈ្មោះថា **វីតរាគោ** ព្រោះមានរាគៈប្រាសទៅហើយ ប្រាសទៅដោយសមុច្ឆេទប្បហាន ។ បទនេះ ជាឈ្មោះរបស់ព្រះអរហត្ត ។ សូម្បីក្នុង ៣ បទនោះ លោកក៏ធ្វើឲ្យជាឯកវចនៈ ដោយកាន់យកជាតិ ។

បទថា **សង្ខារុបេក្ខំ អភិនន្ទតិ** ព្រះសេក្ខៈរមែងរីករាយក្នុងសង្ខារុបេក្ខា សេចក្តីថា ព្រះសេក្ខៈ លុះបានសញ្ញាក្នុងធម៌ជាគ្រឿងនៅជាសុខ ក្នុងធម៌ជាគ្រឿងនៅ គឺ ឧបេក្ខានោះហើយ



ជាអ្នកមានមុខឆ្ពោះទៅកាន់សង្ខារុបេក្ខា ដោយការប្រាថ្នាក្នុងសុខវិហារធម៌ រមែងរីករាយ អធិប្បាយថា ញុំាងតណ្ហាដែលប្រកបដោយបីតិឲ្យកើតឡើង ។

បទថា **វិបស្សតិ** រមែងឃើញច្បាស់ គឺ ព្រះសេក្ខៈរមែងឃើញច្រើនយ៉ាង ដោយលក្ខណៈមានការមិនទៀងជាដើម ដើម្បីបានសោតាបត្តិមគ្គ , ព្រះសេក្ខៈរមែងឃើញ ដើម្បីបានមគ្គជាន់ខ្ពស់ , ព្រះសេក្ខៈអ្នកប្រាសចាករាគៈ រមែងឃើញ ដើម្បីនៅជាសុខក្នុងទិដ្ឋធម៌ ។

បទថា **បដិសង្ខាយ** បានដល់ ចូលទៅពិចារណាដោយអំណាចលក្ខណៈ មានការមិនទៀងជាដើម ។ មយ៉ាងទៀត ព្រោះព្រះអរិយទាំងឡាយ មានព្រះសោតាបន្នជាដើម ចូលផលសមាបត្តិរបស់ខ្លួន បើមិនឃើញច្បាស់ដល់វិបស្សនាញាណ ៩ មានឧទយព្វយញ្ញាណជាដើម ក៏មិនអាចចូលសមាបត្តិបាន ដូច្នោះ លោកទើបពោលថា **បដិសង្ខាយ វា ផលសមាបត្តឹ សមាបជ្ជន្តិ** ព្រះអរិយទាំងឡាយ ពិចារណាហើយចូលផលសមាបត្តិ ដូច្នេះ ។

ដើម្បីសម្តែង ការប្រព្រឹត្តទៅនៃផលសមាបត្តិ ទើបមាន

បញ្ហាកម្មរបស់ព្រះសេក្ខៈទាំងនោះ ដូចតទៅនេះ :-

**ផលសមាបត្តិ** គឺអ្វី , នរណាចូលសមាបត្តិនោះ , នរណាមិនចូលសមាបត្តិ , ព្រោះហេតុអ្វី ទើបត្រូវចូលសមាបត្តិ , ការចូលសមាបត្តិនោះយ៉ាងណា ការតាំងនៅយ៉ាងណា , កាចេញយ៉ាងណា , អ្វីជាលំដាប់នៃនផល និងផលជាលំដាប់នៃអ្វី ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបញ្ហាកម្មនោះ ដូចតទៅនេះថា អ្វីជាផលសមាបត្តិ ? ឆ្លើយថា អប្បនាក្នុងនិរោធរបស់អរិយផល[1] នរណាចូលសមាបត្តិនោះ ? នរណាមិនចូលសមាបត្តិ , ឆ្លើយថា បុថុជ្ជនទាំងអស់ ចូលសមាបត្តិមិនបាន ។ ព្រោះហេតុអ្វី ? ព្រោះនៅមិនទាន់សម្រេច ។ ចំណែកព្រះអរិយៈទាំងអស់ ចូលសមាបត្តិបាន ។ ព្រោះហេតុអ្វី ព្រោះសម្រេចហើយ ។ ចំណែកព្រះអរិយៈថ្នាក់ខ្ពស់ មិនចូលសមាបត្តិថ្នាក់ទាប ព្រោះស្ងប់ហើយដោយចូលដល់ភាពជាបុគ្គលដទៃ , និងព្រះអរិយៈថ្នាក់ទាប ក៏មិន

---

១ វិសុទ្ធមគ្គ ។



ចូលសមាបត្តិថ្នាក់ខ្ពស់ ព្រោះនៅមិនទាន់សម្រេច ។ តែលោកទាំងអស់ ក៏ចូលសមាបត្តិដែលជាផលរបស់ខ្លួននោះឯង ព្រោះហេតុនោះ ពាក្យនេះ ទើបជាប្រការសន្និដ្ឋានទុកក្នុងទីនេះ ។

តែអាចារ្យពួកខ្លះពោលថា សូម្បីព្រះសោតាបន្ន ព្រះសកទាគាមី ក៏មិនចូលសមាបត្តិ , ព្រះអរិយៈ ២ ពួកខាងលើរមែងចូលសមាបត្តិ ។ នេះជាហេតុរបស់ព្រះអរិយៈទាំងនោះ , ព្រោះព្រះអរិយៈទាំងនោះ ជាអ្នកធ្វើឲ្យបរិបូរក្នុងសមាធិ ។ នោះមិនមែនជាហេតុរបស់បុថុជ្ជន ព្រោះចូលលោកិយសមាធិ ដែលខ្លួនបានហើយ ។ ក៏ក្នុងទីនេះ ព្រោះគិតដល់ហេតុ និងមិនមែនហេតុ ដូចម្តេច ។ ក្នុងការឆ្លើយបញ្ហាទាំងនេះ សង្ខារុបេក្ខា ១០ រមែងកើតឡើងដោយវិបស្សនា ដូចម្តេច លោកពោលទុកផ្សេងគ្នាក្នុងបាលីនេះមិនមែនឬ ឬថាដើម្បីប្រយោជន៍ការចូលសោតាបត្តិផល ដើម្បីប្រយោជន៍ការចូលសកទាមិផល ។ ព្រោះដូច្នោះ ព្រះអរិយៈ សូម្បីទាំងអស់ ក៏រមែងចូលសមាបត្តិដែលជាផលរបស់ខ្លួន ព្រោះហេតុនោះ ទើបគួរយល់ព្រមបានក្នុងទីនេះ ។

ព្រោះហេតុអ្វី ទើបត្រូវចូលសមាបត្តិ ? ឆ្លើយថា ដើម្បី

នៅជាសុខក្នុងទិដ្ឋធម៌ ។ ដុជជាព្រះរាជាទាំងឡាយ រមែងសោយសុខក្នុងរាជសម្បត្តិ , ពពួកទេពរមែងសោយទិព្វសុខ យ៉ាងណា ព្រះអរិយៈទាំងឡាយក៏ដូច្នោះ ធ្វើការកំណត់ទុកក្នុងកាលវែងថា យើងនឹងសោយលោកុត្តរសុខ ដូច្នេះ ហើយចូលផលសមាបត្តិ ក្នុងខណៈដែលខ្លួនប្រាថ្នា ។

ការចូលសមាបត្តិ ដូចម្តេច ? តាំងនៅយ៉ាងណា ? ចេញយ៉ាងណា ? ឆ្លើយថា ការចូលសមាបត្តិនោះ រមែងបានដោយអាការ ២ យ៉ាង គឺ មិនធ្វើទុកក្នុងចិត្តដល់អារម្មណ៍ដទៃ ក្រៅពីនិព្វាន ១ ធ្វើទុកក្នុងចិត្តដល់និព្វាន ១ ។ ដូចលោកពោលទុកថា

> ម្នាលអាវុសោ បច្ច័យ ២ យ៉ាង គឺ ការធ្វើទុកក្នុងចិត្តដល់និមិត្តទាំងពួង ដោយសមាបត្តិដែលជាចេតោវិមុត្ត រកនិមិត្តមិនបាន ១ ការធ្វើទុកក្នុងចិត្តដោយធាតុ ដែលរកនិមិត្តមិនបាន ១ ។

នេះជាលំដាប់នៃការចូលសមាបត្តិក្នុងទីនេះ , ពិតណាស់ព្រះអរិយសាវកអ្នកត្រូវការដោយផលសមាបត្តិ ទៅកាន់ទីស្ងាត់



គប្បីពិចារណាសង្ខារទាំងឡាយដោយអនុបស្សញាណ មានឧទយព្វយានុបស្សនាញាណជាដើម , ចិត្តរបស់ព្រះអរិយសាវកនោះ ពិចារណាតាមលំដាប់ដែលប្រព្រឹត្តទៅ រមែងរីករាយក្នុងនិរោធ ដោយអំណាចផលសមាបត្តិ ក្នុងលំដាប់នៃគោត្រភូញាណ ដែលមានសង្ខារនោះជាអារម្មណ៍ ។

ម្យ៉ាងទៀត ព្រោះចិត្តបង្អោនទៅក្នុងផលសមាបត្តិ ផលនោះឯងរមែងកើតឡើងដល់ព្រះសេក្ខៈក្នុងផលសមាបត្តិនេះ មិនមែនមគ្គកើត ។

ម្យ៉ាងទៀត អ្នកណាពោលថា ព្រះសោតាបន្នផ្តើមតាំងវិបស្សនា ដោយគិតថា យើងនឹងចូលផលសមាបត្តិ ដូច្នេះ ហើយនឹហជាព្រះសកទាគាមី , និងព្រះសកទាគាមី ក៏នឹងជាព្រះអនាគាមី ដូច្នេះ ។ អ្នកនោះគួរពោលថា កាលបើយ៉ាងនេះ ព្រះអនាគាមី ក៏នឹងជាព្រះអរហន្ត , ព្រះអរហន្ត ក៏នឹងជាព្រះបច្ចេកពុទ្ធ និងព្រះបច្ចេកពុទ្ធ ក៏នឹជាព្រះសម្មាសម្ពុទ្ធ ដូច្នេះ ។ ព្រោះដូច្នោះ ប្រការនោះទើបមិនត្រឹមត្រូវ , និងមិនគួរកាន់យកដោយបាលីថា **បដិក្ខិតំ** ត្រូវហាមឃាត់ ។ តែគួរកាន់យកប្រការនេះទុក ។

ផលប៉ុណ្ណោះ រមែងកើតឡើង សូម្បីដល់ព្រះសេក្ខៈ មិនមែនមគ្គកើតឡើយ ។

ម្យ៉ាងទៀត ប្រសិនបើពោលថា ផលរបស់មគ្គនោះមានហើយ ហើយព្រះសេក្ខៈនោះបានសម្រេចមគ្គដែលមានក្នុងបឋមជ្ឈាន ញាណដែលមានក្នុងបឋមជ្ឈាននោះឯង រមែងកើត , នឹងពោលថា មគ្គមានក្នុងឈានណាមួយក្នុងទុតិយជ្ឈានជាដើម ញាណក៏មានក្នុងទុតិយជ្ឈានជាដើមដូចគ្នា ព្រោះហេតុនោះ ការចូលសមាបត្តិនោះ រមែងមានដោយប្រការដូច្នេះឯង ។

សមាបត្តិនោះ តាំងនៅដោយអាការ ៣ យ៉ាង ព្រោះបាលីថា ៖

> ម្នាលអាវុសោ បច្ច័យ ៣ យ៉ាង គឺ ការ
> មិនធ្វើទុកក្នុងចិត្ត ដល់និមិត្តទាំងពួង
> ដើម្បីការតាំងមាំនៃចេតោវិមុត្តិ ដែល
> រកនិមិត្តមិនបាន ១ , ការធ្វើទុកក្នុងចិត្ត
> ដល់ធាតុដែលរកនិមិត្តមិនបាន ១ , ការ
> តាក់តែងទុកក្នុងកាលមុន ១ ។



ក្នុងបទទាំងនោះ បទថា **បុព្វេ ច អភិសង្ខារោ** ការតាក់តែងក្នុងកាលមុន គឺ កំណត់ក្នុងកាលមុនអំពីចូលសមាបត្តិ ការតាំងនៅរបស់សមាបត្តិនោះ រមែងមានដ៏រាបអស់កាលនោះ ព្រោះកំណត់ទុកថា យើងនឹងចេញក្នុងវេលាឯណោះ ដូច្នេះ ។ ទីតាំងរបស់សមាបត្តិ រមែងមានយ៉ាងនេះ ។

សមាបត្តិនោះ ចេញដោយអាការ ៣ យ៉ាង ព្រោះព្រះបាលីថា

> ម្នាលអាវុសោ បច្ច័យ ២ យ៉ាងនេះឯង គឺ ការ
> ធ្វើទុកក្នុងចិត្តដល់និមិត្តទាំងពួង ដោយការ
> ចេញចាកចេតោវិមុត្តិ ដែលមិនមាននិមិត្ត ១
> ការមិនធ្វើទុកក្នុងចិត្តដល់ធាតុដែលរកនិមិត្ត
> មិនបាន ១ ។

ក្នុងបទទាំងនោះ បទាថា **សព្វនិមិត្តានំ** បានដល់ រូបនិមិត្ត វេទនានិមិត្ត សញ្ញានិមិត្ត សង្ខារនិមិត្ត និងវិញ្ញាណនិមិត្ត ។ ម្យ៉ាងទៀត សូម្បីមិនធ្វើទុកក្នុងចិត្តដល់និមិត្តទាំងអស់ ដោយចំណែកមួយ លោកក៏ពោលបទថា **សព្វនិមិត្តានំ** នេះ ដោយ

អំណាចសង្គ្រោះចូចដូចគ្នាទាំងអស់ ។ កាលបើព្រះយោគាវចរធ្វើទុកក្នុងចិត្តដល់អារម្មណ៍ដែលមានដល់ភវគ្គ ក៏ជាការចេញចាកផលសមាបត្តិ ព្រោះហេតុនោះ គប្បីជ្រាបការចេញនៃផលសមាបត្តិនោះ យ៉ាងនេះ ។

អ្វីជាលំដាប់របស់ផល , និងផលជាលំដាប់របស់អ្វី ? ឆ្លើយថា ផលនោះឯង ឬភវង្គ ជាលំដាប់របស់ផល ។ តែផលមានទៅក្នុងលំដាប់មគ្គ , មគ្គមានទៅក្នុងលំដាប់ផល , ផលមានទៅក្នុងលំដាប់គោត្រភូ គឺ អនុលោមញ្ញាណ ផលមានទៅក្នុងលំដាប់របស់នេវសញ្ញានាសញ្ញាយតនៈ ។ ផលមានទៅក្នុងលំដាប់របស់មគ្គក្នុងវីថិនៃមគ្គនោះ , ផលក្រោយ ៗ មានទៅក្នុងលំដាប់ផលមុន ៗ , ផលមុន ៗ ក្នុងផលសមាបត្តិ មានទៅក្នុងលំដាប់គោត្រភូ គឺ អនុលោមញ្ញាណ ។

មួយ៉ាងទៀត ក្នុងបទថា **គោត្រភូ** នេះ គប្បីជ្រាបថា ជាអនុលោមញ្ញាណ ដូចលោកពោលទុកក្នុងបដ្ឋានថា អនុលោមញ្ញាណរបស់ព្រះអរហន្ត ជាបច្ច័យដល់ផលសមាបត្តិ ដោយអនន្តរប្បច្ច័យ , អនុលោមញ្ញាណរបស់ព្រះសេក្ខៈ ជាបច្ច័យដល់



ផលសមាបត្តិ ដោយអនន្តរប្បច្ច័យ ។ ការចេញចាកនិរោធ រមែងមានដោយផលណា , ផលនោះ រមែងមានលំដាប់របស់នេវសញ្ញានាសញ្ញាយតនៈ ។ ក្នុងបទនោះ ផលទាំងអស់ដ៏សេស វៀរផលដែលកើតឡើងក្នុងមគ្គវីថិ ឈ្មោះថា ប្រព្រឹត្តទៅហើយដោយអំណាចនៃផលសមាបត្តិ ។ ផលនេះ ប្រព្រឹត្តទៅហើយ ដោយការកើតឡើងក្នុងមគ្គវីថិក្តី ក្នុងផលសមាបត្តិក្តី ដោយប្រការដូច្នេះ ។ លោកពោលជាគាថាទុកថា :

**បដិបស្សទ្ធិទរថំ អមតារម្មណំ សុភំ**
**វន្តលោកាមិសំ សន្តំ សាមញ្ញផលមុត្តមំ ។**

សាមញ្ញផលដ៏ឧត្តម រំងាប់សេចក្តីក្រវល់ក្រវាយ មានអមតៈដ៏ស្អាតជាអារម្មណ៍ ខ្ជាក់លោកាមិស ញុំាងសេចក្តីស្ងប់ឲ្យកើត ដូច្នោះ ។

នេះជាផលសមាបត្តិកថា ក្នុងនិទ្ទេសនេះ ។

បទថា **តទជ្ឈុបេក្ខិត្វា** កាពព្រងើយនៃសង្ខារុក្ខានោះ បានដល់ ភាពព្រងើយនៃសង្ខារុបេក្ខានោះ ដោយវិបស្សនាញាណនោះឯង ។ ក្នុងបទមានជាអាទិ៍ថា **សុញ្ញតវិហារេន វា** ដោយ

សុញ្ញតវិហារសមាបត្តិ មានន័យដូចតទៅនេះ ការនៅដោយវិប-
ស្សនា ៣ របស់ព្រះអរហន្តអ្នកបំណន់នឹងនៅដោយវិបស្សនា-
វិហារ វៀរផលសមាបត្តិ ឃើញការប្រកាន់ខ្លួនដោយសភាពគួរ
ខ្លាច ទើបបង្អោនទៅក្នុង **សុញ្ញតវិហារ** ឃើញសេចក្តីវិនាសក្នុង
សង្ខារុបេក្ខា ឈ្មោះថា **សុញ្ញតវិហារ** ។

ការនៅដោយវិបស្សនា ៣ របស់លោកអ្នកឃើញសង្ខារ-
និមិត្ត ដោយសភាពគួរខ្លាច ហើយបង្អោនទៅក្នុង **អនិមិត្តវិហារ**
ឃើញការបែកធ្លាយទៅក្នុងសង្ខារុបេក្ខា ឈ្មោះថា **អនិមិវិហារ** ។
ការនៅដោយវិបស្សនា ៣ របស់លោកអ្នកឃើញសភាពតាំងមាំ
ក្នុងតណ្ហា ដោយសភាពគួរខ្លាច ហើយបង្អោនទៅក្នុង **អប្បណិ-
ហិតវិហារ** ឃើញការបែកធ្លាយក្នុងសង្ខារុបេក្ខា ឈ្មោះថា **អ-
ប្បណិហិតវិហារ** ។ ដូចលោកពោលទុកខាងមុខថា :

ព្រះយោគាវចរ កាលឃើញការប្រកាន់មាំ
**សង្ខារនិមិត្ត** ដោយសភាពគួរខ្លាច ពាល់
ត្រូវហើយ រមែងឃើញការបែកធ្លាយ ព្រោះ
មានចិត្តបង្អោនទៅក្នុងសុញ្ញតនិព្វាន ឈ្មោះ



ថា **សុញ្ញតវិហារ** ។ កាលឃើញនិមិត្តដោយ
សភាពគួរខ្លាចពាល់ត្រូវហើយ រមែងឃើញ
ការបែកធ្លាយ ព្រោះមានចិត្តបង្អោនទៅក្នុង
**អនិមិត្តនិព្វាន** ឈ្មោះថា **អនិមិត្តវិហារ** ។
កាលឃើញបណិធិ ដោយសភាពគួរខ្លាច
រមែងឃើញការបែកធ្លាយ ព្រោះមានចិត្ត
បង្អោនទៅក្នុងអប្បណិហិតនិព្វាន ឈ្មោះថា
**អប្បណិហិតវិហារ** ។

ចិត្តរបស់ព្រះអរហន្តនោះឯង រមែងប្រព្រឹត្តទៅក្នុងអំណាច
ដោយអាការទាំងពួង ដោយមានឆឡង្គុបេក្ខា និងដោយមានវិហារ-
ធម៌ មានការសម្គាល់ក្នុងវត្ថុបដិកូលថា មិនមែនបដិកូលជាដើម ,
បន្ទាប់ពីនោះលោកអធិប្បាយថា វិបស្សនាវិហារ រមែងសម្រេច
ដល់ព្រះអរហន្តប៉ុណ្ណោះ ។ ក្នុងបទនេះថា **វីតរាគោ សង្ខារុបេក្ខំ
វិបស្សតិ** អ្នកប្រាសចាករាគៈ រមែងឃើញច្បាស់សង្ខារុបេក្ខា
មានសេចក្តីថា វិបស្សនានៅមិនទាន់ដល់ភ័យ ៣ យ៉ាង និងអធិ-
មុត្តិ ៣ យ៉ាង គប្បីជ្រាបថា ជាវិបស្សនាដ៏កំពូល ។ កាលបើដូច្នោះ

រមែងមានសេចក្ដីវិសេសទាំងមុន និងក្រោយ ។

ឥឡូវនេះ ព្រះសារីបុត្តបំណងនឹងសម្ដែងប្រភេទនៃភាពតែមួយ និងភាពផ្សេងគ្នានៃសង្ខារុបេក្ខា ដោយអំណាចបុគ្គល ២-៣ ប្រភេទ ទើបពោលបទមានជាអាទិ៍ថា **កថំ បុថុជ្ជនស្ស ច សេក្ខស្ស** ។

ក្នុងបទទាំងនោះ បទថា **ចិត្តស្ស អភិនីហារោ ឯកត្តំ ហោតិ** ការបង្អោនទៅនៃចិត្តតែមួយដូចគ្នា គឺ តែមួយដូចគ្នា ។ គប្បីជ្រាបថា ជា **ភាវវចន** ចុះក្នុង **សកត្ថ** ។ លោកពោលថា **ឥទប្បច្ចយតា** ក៏ដូច **ឥទប្បច្ចយា** ។ **ឯកត្តំ** ក៏គឺ **ឯកោ** នោះឯង ។

បទថា **អភិនីហារោ** ជាបឋមាវិភត្តិ ចុះក្នុងអត្ថនៃឆដ្ឋីវិភត្តិ ។ គឺ **អភិនីហារស្ស** ភាពនៃការបង្អោនទៅ ។ គប្បីជ្រាបថា លោកធ្វើវិភត្តិវិបល្លាស ដូចក្នុងបទថា **សោ ទេសោ សម្មជ្ជិត្វា** បោសសំអាតក្នុងទីកន្លែងនោះ ។

បទថា **ចិត្តំ កិលិស្សតិ** ចិត្តសៅហ្មង បានដល់ ចិត្តសៅហ្មងដោយកិលេស គឺ លោកៈ បានក្នុងបទថា **វិបស្សនានិកំ** ជាសត្រូវនៃវិបស្សនា អធិប្បាយថា ធ្វើឲ្យក្ដៅក្រហាយ ធ្វើឲ្យលំបាក ។



បទថា **ភាវនាយ បរិបន្ថោ ហោតិ** មានអន្តរាយដល់ភាវនា បានដល់ កម្ចាត់វិបស្សនាភាវនាដែលបានហើយ ។

បទថា **បដិវេធស្ស អន្តរាយោ ហោតិ** មានអន្តរាយដល់បដិវេធ បានដល់ ជាការអន្តរាយដល់ការបានសច្ចបដិវេធ ដែលគួរបានដោយវិបស្សនាភាវនា ។

បទថា **អាយតឹ បដិសន្ធិយា បច្ចយោ ហោតិ** មានបច្ច័យនៃបដិសន្ធិតទៅ សេចក្ដីថា កាលកម្មនោះឲ្យសុគតិបដិសន្ធិ ព្រោះកម្មសម្បយុត្តដោយសង្ខារុបេក្ខា មានកម្លាំងកិលេស គឺ លោភៈ ពោលគឺ សេចក្ដីរីករាយជាបច្ច័យនៃសុគតិបដិសន្ធិ ជាកាមាវចរក្នុងអនាគត ព្រោះកម្មមានកិលេសជាសំឡាញ់ រមែងញ៉ាំងវិបាកឲ្យកើតឡើង , ដូច្នោះ កម្មទើបជាជនកបច្ច័យ , កិលេស ជាឧបត្ថម្ភកបច្ច័យ ។

ម្យ៉ាងទៀត បទថា **ឧត្តរិបដិវេធស្ស** នៃបដិវេធក្នុងមគ្គជាន់ខ្ពស់ បានដល់ សច្ចបដិវេធដោយអំណាចសកទាគាមិមគ្គជាដើម របស់ព្រះសេក្ខៈ ។

បទថា **អាយតឹ បដិសន្ធិយា បច្ចយា ហោតិ** គប្បីជ្រាបថា

កិលេស គឺ សេចក្តីពេញចិត្តជាបច្ច័យនៃសុគតិបដិសន្ធិ ជាកាមាវចរដែលកម្ម គឺ សង្ខារុបេក្ខាឲ្យដល់ឈានក្នុងព្រះសេក្ខៈទាំងឡាយ ដែលជាព្រះសោតាបន្ន និងព្រះសកទាគាមីនៅមិនទាន់បានចាក់ធ្លុះ , មិនជាបច្ច័យដល់អ្នកបានឈាន និងដល់ព្រះអនាគាមីតាំងពីបដិសន្ធិក្នុងព្រហ្មលោក , កិលេសនេះឯង ជាបច្ច័យនៃបដិសន្ធិ ដែលគោត្រភូជាអនុលោមឲ្យ ។

បទថា **អនិច្ចតោ** ឈ្មោះថា ភាពមិនទៀង ព្រោះអត្ថថា មានហើយបែរជាមិនមាន ព្រោះមានការមិនទៀងជាទីបំផុត ព្រោះមានខាងដើម និងទីបំផុត ។

បទថា **ទុក្ខតោ** ឈ្មោះថា ជាទុក្ខ ព្រោះអត្ថថា បៀតបៀនរឿយ ៗ ព្រោះបៀតបៀនដោយការកើត និងការវិនាស និងព្រោះជាតាំងនៃទុក្ខ ។

បទថា **អនត្តោ** ឈ្មោះថា ដោភាវៈជាអនត្តា ព្រោះអត្ថថា ប្រព្រឹត្តក្នុងអំណាច ព្រោះអាស្រ័យបច្ច័យប្រព្រឹត្តទៅ និងព្រោះមិនមានសាមី ម្ចាស់របស់ មិនមាននិវាសី អ្នកអាស្រ័យនៅជានិច្ច មិនមានការកៈ អ្នកធ្វើ និងវេទកៈ អ្នកសោយ ។



ឈ្មោះថា **អនុបស្សនត្តេន** ដោយសភាពនៃការពិចារណាបានដល់ ដោយភាពជារបស់មិនទៀងជាដើមតាម ៗ គ្នា ។

បទថា **អធិនីហារោ នានត្តំ ហោតិ** គប្បីជ្រាបថា ការបង្អោនចិត្តទៅផ្សេងគ្នា ឬសភាពផ្សេងគ្នានៃការបង្អោនចិត្ត ។

បទថា **កុសល** ឈ្មោះថា **កុសល** ព្រោះអត្ថថា មិនមានរោគ ព្រោះអត្ថថា មិនមានទោស និងព្រោះអត្ថថា ឆ្លាត ។

បទថា **អព្យាកតា** គឺ អព្យាកតៈ មិនមែនជាកុសល ឬអកុសល ។

បទថា **កិញ្ចិកាលេ សុវិទិតា** ប្រាកដល្អក្នុងកាលបន្តិចបន្តួច បានដល់ ប្រាកដដោយល្អក្នុងកាលនៃវិបស្សនា ។

បទថា **កិញ្ចិកាលេ ន សុវិទិតា** មិនប្រាកដល្អក្នុងកាលបន្តិចបន្តួច គឺ មិនប្រាកដដោយល្អក្នុងកាលនៃការពេញចិត្ត ។

បទថា **អច្ចន្តំ សុវិទិតា** ប្រាកដល្អដោយចំណែកមួយបានដល់ ប្រាកដល្អដោយចំណែកមួយ ព្រោះលះការពេញចិត្តបានហើយ ។

ក្នុងបទនេះថា **វិទិតត្តេន ច អវិទិតត្តេន ច** ដោយសភាព

ដែលប្រាកដ និងដោយសភាពដែលមិនប្រាកដ មានសេចក្តីថា ព្រះសេក្ខៈដែលជាបុថុជ្ជន មានសភាពប្រាកដល្អហើយក្តី ព្រះសេក្ខៈប្រាសចាករាគៈ មានសភាពប្រាកដល្អដោយចំណែកមួយក្តី ឈ្មោះថា ជាអ្នកប្រាកដហើយ , សូម្បីទាំងពីរ មានសភាពប្រាកដមិនល្អ ក៏ឈ្មោះថា មានសភាពប្រាកដមិនល្អនោះឯង ។

បទថា **អតិត្តត្តា** ព្រោះនៅមិនទាន់សម្រេចកិច្ច បានដល់ ព្រោះនៅមិនទាន់សម្រេចកិច្ចដែលគួរធ្វើនៃវិបស្សនា គឺ នៅមិនប្រណីត ។ ឈ្មោះថា **តិត្តត្តា** ព្រោះផ្សុយជាមួយបទថា **អតិត្តត្តា** នោះ ។

បទថា **តិណ្ណំ សញ្ញោជនានំ បហានាយ** ដើម្បីលះបង់សំយោជនៈ ៣ បានដល់ ដើម្បីលះសក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ។ ព្រះពោធិសត្វ សូម្បីមានភពចុងក្រោយ ក៏សង្គ្រោះចូលក្នុងបទនេះដូចគ្នា ។ តែសត្វដែលមិនមានភពចុងក្រោយ ញុំាងវិបស្សនាឲ្យដល់សង្ខារុបេក្ខាហើយតាំងនៅ ។

បទថា **សោតាបត្តិមគ្គំ បដិលាភត្ថាយ** ដើម្បីបានសោតាបត្តិមគ្គ អាចារ្យទាំងឡាយមិនពោលសង្ខេបទុក , ពោលសង្ខេបទុកល្អជាង ។



បទថា **សេក្ខោ តិណ្ណំ សញ្ញោជនានំ បហីនត្តា** លោកពោលដោយភាពស្មើគ្នានៃសោតាបន្នៈ ព្រះសកទាគាមី និងព្រះអនាគាមី ។ ពិតណាស់ សំយោជនៈទាំងនោះ សូម្បីព្រះសកទាគាមី និងព្រះអនាគាមី ក៏លះបានហើយ ។

បទថា **ឧត្តរិបដិលាភត្ថាយ** គឺ ដើម្បីបាននូវមគ្គជាន់ខ្ពស់ៗ ។

បទថា **ទិដ្ឋធម្មសុខវិហារត្ថាយ** ដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន បានដល់ ដើម្បីត្រូវការនៅជាសុខក្នុងបច្ចុប្បន្ន គឺ ក្នុងអត្តភាពដែលប្រចក្ស ។

បទថា **វិហារសមាបត្តដ្ឋេន** ដោយសភាពនៃវិហារសមាបត្តិ បានដល់ ដោយសភាពនៃផលសមាបត្តិរបស់ព្រះសេក្ខៈ , ដោយសភាពនៃផលសមាបត្តិ ដែលជាវិបស្សនារបស់លោកអ្នកប្រាសចាករាគៈ ។

ឥឡូវនេះ ព្រះសារីបុត្តកាលនឹងសម្តែងការកំណត់ដោយចំនួនពាក្យនៃសង្ខារុបេក្ខា ទើបពោលបទមានជាអាទិ៍ថា **កតិ សង្ខារុបេក្ខា** សង្ខារុបេក្ខាប៉ុន្មាន ?

ក្នុងបទទាំងនោះ បទថា **សមថវសេន** គឺ ដោយអំណាចសមាធិ ។ មម្យ៉ាងទៀត បាឋៈនេះដូចគ្នា ។

បទថា **នីវរណេ បដិសង្ខា** បញ្ញាពិចារណានីវរណៈ បានដល់ ការកំណត់ដោយការដែលគួរលះនីវរណៈ ៥ ។

បទថា **សន្តិដ្ឋនា** ការតាំងទុក បានដល់ ការតាំងទុកព្រោះភាពជាកណ្តាល ដោយការចូលដល់ភាពមិនខ្វល់ខ្វាយក្នុងការលះនីវរណៈទាំងនោះ ព្រោះសំដៅការលះបង់នីវរណៈទាំងនោះ ។

បទថា **សង្ខារុបេក្ខាសុ** គឺ ក្នុងការព្រងើយកន្តើយចំពោះសង្ខារ ពោលគឺ នីវរណៈ ដោយការមិនធ្វើភាពខ្វល់ខ្វាយក្នុងការលះនីវរណៈទាំងឡាយ ក្នុងវិតក្កវិចារៈជាដើម និងក្នុងឧប្បាទៈជាដើម ក៏មានន័យនេះ ។ ញាណសម្រេចដោយភាវនា ដែលមានកម្លាំងក្នុងចំណែកខាងដើម ដែលជិតអប្បនាវីថិក្នុងសមថៈ ឈ្មោះថា **សង្ខារុបេក្ខា** ។

ក្នុងបទមានជាអាទិ៍ថា **សោតាបត្តិមគ្គំ បដិលាភត្ថាយ** ដើម្បីបានសោតាបត្តិមគ្គ គឺ ជាការបានមគ្គណាមួយក្នុងសុញ្ញតមគ្គ អនិមិត្តមគ្គ និងអប្បណិហិតមគ្គ ក្នុងមគ្គវារៈ ៤ ។



ក្នុងបទមានជាអាទិ៍ថា **សោតាបត្តិផលសមាបត្តត្ថាយ** ដើម្បីត្រូវការបាន **សោតាបត្តិផលសមាបត្តិ** គប្បីជ្រាបផលសមាបត្តិដែលជាអប្បណិហិតៈក្នុងផលវារៈ ៤ ។ ព្រោះហេតុអ្វី ? ព្រោះលោកពោលដល់ផលសមាបត្តិ ២ ទាំងនេះ គឺ **សុញ្ញតវិហារសមាបត្តត្ថាយ** ដើម្បីត្រូវការសុញ្ញតវិហារសមាបត្តិ ១ **អនិមិត្តវិហារសមាបត្តត្ថាយ** ដើម្បីត្រូវការអនិមិត្តវិហារសមាបត្តិ ១ ទុកផ្សេងគ្នា ។

គប្បីជ្រាបអនិមិត្តមគ្គ ដោយការចេញចាកអនិច្ចានុបស្សនា , គប្បីជ្រាបអនិមិត្តផលសមាបត្តិ ក្នុងកាលនៃផលសមាបត្តិ , គប្បីជ្រាបអប្បណិហិតមគ្គ និងផលសមាបត្តិ ដោយការចេញចាកទុក្ខានុបស្សនា , គប្បីជ្រាបសុញ្ញតមគ្គ និងផលសមាបត្តិ ដោយការចេញចាកអនត្តានុបស្សនា ដោយន័យនៃព្រះសូត្រនោះឯង ។

ម្យ៉ាងទៀត ក្នុងមគ្គវារៈ ៤ ទាំងនេះ លោកពោលដល់បទដែលជាមូលហេតុ ៥ មានជាអាទិ៍ថា **ឧប្បាទំ** កើតឡើង , បទនៃវេវចនៈ ១០ មានជាអាទិ៍ថា **គតិ** រួមជា ១៥ បទ ។ ក្នុងផល-

សមាបត្តិវារៈ ៦ លោកពោលបទដែលជាមូល ៥ ទុក ។

ប្រសិនបើសួរថា ព្រោះហេតុអ្វីទើបលោកពោលទុកយ៉ាងនោះ ។ ឆ្លើយថា កាលសង្ខារុបេក្ខាមានសភាពចាស់ក្លា ដើម្បីសម្តែងដល់សេចក្តីចាស់ក្លានៃសង្ខារុបេក្ខានោះ ព្រោះមានមគ្គក្នុងការលះបង់កិលេស លោកទើបពោលបទជាមូលធ្វើឲ្យមាំ ជាមួយបទដែលជាវេវចនៈ ។ ដើម្បីសម្តែងថា សង្ខារុបេក្ខា សូម្បីទន់ខ្សោយ ក៏ជាបច្ច័យដល់ផល ព្រោះផលមានសភាពស្ងប់ដោយការអស់ភាពឧស្សាហ៍ និងព្រោះជាទីអាស្រ័យនៃមគ្គ គប្បីជ្រាបថា លោកពោលដល់បទដែលជាមូលប៉ុណ្ណោះ ។

ឥឡូវនេះ ព្រះសារីបុត្រកាលសួរដោយជាតិហើយ ដើម្បីនឹងឆ្លើយជាមួយនឹងការបាន ទើបពោលបទមានជាអាទិ៍ថា **កតិ សង្ខារុបេក្ខា កុសលា** សង្ខារុបេក្ខាជាកុសល ប៉ុន្មាន ?

ក្នុងបទទាំងនោះ បទថា **បណ្ណរស សង្ខារុបេក្ខា** សង្ខារុបេក្ខាជាកុសលមាន ១៥ បានដល់ ដោយសមថៈ ៨ និងដោយមគ្គ ៤ ផល ៣ ជា ៧ រួមជា ១៥ ។ សង្ខារុបេក្ខា ៨ ដោយអំណាចសមថៈមិនគួរដល់ធម៌ ឈ្មោះថា សង្ខារុបេក្ខា ព្រោះព្រះ



អរហន្តមិនមានការពិចារណានីវរណៈ និងព្រោះវៀរសេចក្តីខ្វល់ខ្វាយក្នុងការលះបង់វិតក្កវិចារៈជាដើម ជាការលះបង់បានដោយងាយ ព្រោះហេតុនោះ គប្បីជ្រាបថា លោកមិនពោលសង្ខារុបេក្ខាទាំងនោះ ជាអព្យាកតៈ ។ ពិតណាស់ ព្រះអរហន្តអ្នកចូលផល-សមាបត្តិ មិនអាចចូលសមាបត្តិវៀរសង្ខារុបេក្ខាបាន ព្រោះហេតុនោះ លោកទើបពោលសង្ខារុបេក្ខា ៣ ថាជាអព្យាកតៈ ។ ពិតណាស់ ឈ្មោះថា សង្ខារុបេក្ខា ៣ របស់ព្រះអរហន្ត រមែងមានដោយអំណាចអប្បណិហិតៈ សុញ្ញតៈ និងអនិមិត្តៈ ។

ឥឡូវនេះ គប្បីជ្រាបសេចក្តីក្នុងគាថាទាំងឡាយ ៣ ដែលលោកពោលហើយ ដោយការពណ៌នាដល់សង្ខារុបេក្ខា ដូចតទៅនេះ ។

បទថា **បដិសង្ខា សន្តិដ្ឋនា បញ្ញា** បញ្ញាដែលពិចារណារកផ្លូវហើយព្រងើយកន្តើយ បានដល់ សង្ខារុបេក្ខា ។

បទថា **អដ្ឋ ចិត្តស្ស គោចរា** ជាគោចរនៃសមាធិ ៨ សេចក្តីថា លោកពោលដល់សង្ខារុបេក្ខា ៨ ជាវិស័យ គឺ ភូមិរបស់សមាធិ ដោយអំណាចសមថៈ ។ លោកអធិប្បាយដល់

**សមាធិ** ដោយមាតិកាថា **ចិត្ត** ដូចក្នុងប្រយោគមានបទជាអាទិ៍ថា **ចិត្តំ បញ្ញញ្ច ភាវយំ** ចម្រើនសមាធិ និងបញ្ញា , លោកអធិប្បាយ **វិសយ** ដោយ **គោចរ** សព្ទ ដូចក្នុងប្រយោគ មានជាអាទិ៍ថា **គោចរេ ភិក្ខវេ ចរថ សគ្គេ បេត្តិកេ វិសយេ** ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរត្រាច់ទៅក្នុងគោចរ ដែលជាផ្លូវនៃបិតាខ្លួន ។ លោកពោលថា នេះជាគោចររបស់អ្នកអាស្រ័យ ។ បទថា **បុ-ថុជ្ជនស្ស ទ្វេ** គោចរភូមិនៃបុថុជ្ជន ២ គឺ ដោយអំណាចនៃសមថៈ និងវិបស្សនា ។ បទថា **តយោ សេក្ខស្ស** គោចររបស់ព្រះសេក្ខៈ ៣ បានដល់ ដោយអំណាចនៃសមថៈ វិបស្សនា និងសមាបត្តិ ។

បទថា **តយោ ច វីតរាគស្ស** គោចររបស់អ្នកប្រាសចាករាគៈ ៣ បានដល់ ដោយអំណាចនៃផលសមាបត្តិ ដែលជាអប្ប-ណិហិតៈ សុញ្ញតៈ និងអនិមិត្តៈ ។ គួរពោលថា **តិស្សោ** លោកធ្វើជាលិង្គវិបល្លាសថា **តយោ** ។ ឬគប្បីប្រកបថា **តយោ សង្ខារុបេក្ខា ធម្មា** ធម៌ គឺ សង្ខារុបេក្ខា ៣ យ៉ាង ។

បទថា **យេហិ ចិត្តំ វិវដ្ដតិ** ចិត្តប្រាសចាករាគៈ ហើយគេចចេញទៅ សេចក្ដីថា ចិត្តចេញចាកវិតក្កវិចារៈជាដើម ដោយធម៌ គឺ សង្ខារុបេក្ខា , ឬចាកឧប្បាទៈជាដើម លោអធិប្បាយថា ព្រោះសូម្បីអ្នកប្រាសចាករាគៈ ក៏នៅមានសង្ខារុបេក្ខា ចិត្តចេញ



ចាកសង្ខារ ស្ទុះទៅកាន់ព្រះនិព្វាន ។

បទថា **អដ្ឋ សមាធិស្ស បច្ចយា** ជាបច្ច័យនៃសមាធិ ៨ គឺ បច្ច័យ ៨ លោកពោលដោយអំណាចសមថៈ ជាបច្ច័យដល់អប្បនាសមាធិ ព្រោះឲ្យដល់អប្បនា ។

បទថា **ទស ញាណស្ស គោចរា** ជាគោចរនៃញាណ ១០ គឺ ជាភូមិ ១០ នៃមគ្គញ្ញាណ និងផលញ្ញាណ លោកពោលដោយអំណាចនៃវិបស្សនា ។

បទថា **តិណ្ណំ វិមោក្ខាយ បច្ចយា** ជាបច្ច័យនៃវិមោក្ខ ៣ គឺ ជាបច្ច័យនៃសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ និងអប្បណិហិ-វិមោក្ខ ដោយឧបនិស្សយប្បច្ច័យ ។

បទថា **នានាទិដ្ឋីសុ ន កម្បតិ** រមែងមិនញាប់ញ័រ ព្រោះទិដ្ឋិផ្សេង ៗ បានដល់ មិនលះបង់ការរលត់ ហើយពិចារណាឃើញសង្ខារទាំងឡាយ ដោយភាពជារបស់មិនទៀងជាដើម រមែងមិនញាប់ញ័រក្នុងទិដ្ឋិ មានប្រការផ្សេង ៗ មានសស្សតទិដ្ឋិជាដើម ។

( ចប់អដ្ឋកថា សង្ខារុបេក្ខាញាណនិទ្ទេស )

# អដ្ឋកថា គោត្រភូញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ ក្នុងគោត្រភូញាណនិទ្ទេសដូចតទៅ ៖

បទថា **អភិភុយ្យ** គ្របសង្កត់ គឺ រមែងគ្របសង្កត់ រមែងឈានកន្លង ។

បទថា **ពហិទ្ធា សង្ខារនិមិត្តំ** គឺ សង្ខារនិមិត្តខាងក្រៅបានដល់ សង្ខារនិមិត្តដែលជាខាងក្រៅពួកុសលក្ខន្ធ ដែលប្រព្រឹត្តទៅហើយក្នុងសន្តានរបស់ខ្លួន ។ ពិតណាស់ សង្ខារដែលជាលោកិយៈ លោកពោលថា ជានិមិត្ត ព្រោះជាគ្រឿងសម្គាល់របស់កិលេសទាំងឡាយ , ឬព្រោះតាំងឡើងដោយអាការរបស់និមិត្ត ។

បទថា **អភិភុយ្យតីតិ គោត្រភូ** ឈ្មោះថា គោត្រភូ ព្រោះគ្របសង្កត់ លោកពោលដល់ភាពជាគោត្រភូ ព្រោះគ្របសង្កត់គោត្ររបស់បុថុជ្ជន ។

បទថា **បក្ខន្ទតីតិ គោត្រភូ** ឈ្មោះថា គោត្រភូ ព្រោះអត្ថថា ស្ទុះទៅ គឺ លោកពោលដល់ភាពជាគោត្រភូ ព្រោះការកើតឡើងនៃគោត្រព្រះអរិយៈ ។



បទថា **អភិភុយ្យិត្វា បក្ខន្ទតីតិ គោត្រភូ** ឈ្មោះថា គោត្រភូ ព្រោះគ្របសង្កត់ហើយស្ទុះទៅ គឺ លោកពោលសង្ខេបសេចក្តីទាំងពីរ ។

បទថា **វុដ្ឋាតីតិ គោត្រភូតិ ច វិវដ្តតីតិ គោត្រភូតិ ច** ឈ្មោះថា គោត្រភូ ព្រោះអត្ថថា ចេញទៅ និងព្រោះអត្ថថា គេចចេញទៅ គឺ លោកពោលដល់អត្ថ គឺ ការគ្របសង្កត់បុថុជ្ជនគោត្រដោយសមគួរដល់បទថា **វុដ្ឋាន** គឺ កាចេញ **វិវដ្តន** ការគេចចេញទៅនៃមាតិកា ។ គប្បីជ្រាបអត្ថថា ឈ្មោះថា **គោត្រភូ** ព្រោះគ្របសង្កត់គោត្រ មាននីវរណៈជាដើម នៃគោត្រដូចពោលហើយដោយសមថៈ , ឈ្មោះថា គោត្រភូ ព្រោះគ្របសង្កត់គោត្រ មានការកើតជាដើម ក្នុងសមាបត្តិវារៈ ៦ មានជាអាទិ៍ថា **សោតាបត្តិផលសមាបត្តត្ថាយ** ដើម្បីត្រូវការសោតាបត្តិផលសមាបត្តិ , ឈ្មោះថា គោត្រភូ ព្រោះគ្របសង្កត់គោត្រ គោត្រមានសោតាបន្នៈជាដើម ។

ក្នុងមគ្គវារៈ ៣ មានជាអាទិ៍ថា **សកទាគាមិមគ្គបដិលាភត្ថាយ** ដើម្បីត្រូវការបានសកទាគាមិមគ្គ ។

ម្យ៉ាងទៀត ក្នុងបទថា **គោត្រភូ** នេះ មានអត្ថថា គោត្រ និងមានអត្ថថា ពូជ ។ ន័យថា ក្នុងអត្ថនិបករណ៍ លោកពោល **និព្វាន** ថា **គោត្តំ** គោត្រ ព្រោះការពារនូវអន្តរាយទាំងពួង , ឈ្មោះថា គោត្រភូ ព្រោះដំណើរទៅកាន់និព្វាននោះ , សូម្បីសមាបត្តិ ៨ ក៏ឈ្មោះថា **គោត្តំ** គោត្រ ព្រោះការពារនូវអន្តរាយនៃគោត្រភូ , គោត្រភូនោះ លោកពោលថា **គោត្រភូ** ព្រោះដំណើរទៅកាន់គោត្រ ។

អាចារ្យទាំងឡាយពោលថា គោត្រភូនៃមគ្គ ៤ មាននិព្វានជាអារម្មណ៍ , គោត្រភូនៃផលសមាបត្តិ ៤ មាសង្ខារជាអារ-ម្មណ៍ , ព្រោះបង្អោនទៅក្នុងផលសមាបត្តិ ។ ដូចលោកពោលទុកក្នុងវិសុទ្ធិមគ្គថា ចិត្តរបស់ព្រះយោគាវចរ អ្នកបានឃើញច្បាស់តាមលំដាប់ដែលប្រព្រឹត្តទៅហើយនោះ រមែងរីករាយក្នុងនិរោធដោយអំណាចនៃផលសមាបត្តិ ក្នុងរវាងគោត្រភូញាណ មានសង្ខារជាអារម្មណ៍ ដោយហេតុនោះឯង ក្នុងមគ្គវារៈនេះ គប្បីជ្រាបថា លោកធ្វើចិត្តទី ១៦ ហើយកាន់យកចិត្តទី ៦ ក្នុងសមាបត្តិវារៈ នៃសង្ខារនិមិត្តខាងក្រៅ ដែលកាន់យកហើយ ទើប



មិនកាន់យក , ដោយប្រការខាងក្រៅនេះ គប្បីកាន់យកបទដែលជាមូល ។

ក៏អាចារ្យពួកដទៃពោលថា ការចងចិត្តគ្រាដំបូងក្នុងនិព្វានជាការរួបរួមគ្រាដំបូង នេះលោកពោលថា ជាគោត្រភូ ។ គោត្រភូសំដៅដល់ផលនោះ មិនត្រឹមត្រូវ ។

ក្នុងបទនេះថា **បណ្ណរស គោត្រភូធម្មា កុសលា** គោត្រភូ-ធម៌ជាកុសល ១៥ គប្បីជ្រាបអធិប្បាយដូចតទៅនេះ ឈ្មោះថា គោត្រភូ រមែងមិនសមគួរដល់ព្រះអរហន្ត ព្រោះមិនមាននីវរណៈដែលគួរគ្របសង្កត់ ព្រោះវិតក្កវិចារៈជាដើម គប្បីលះបានងាយនិងព្រោះអត្ថថា គ្របសង្កត់ ព្រោះហេតុនោះ គប្បីជ្រាបថា លោកធ្វើទុកហើយនឹងមិនពោល ព្រោះគោត្រភូជាអព្យាកតៈ ។ ម្យ៉ាងទៀត ព្រះអរហន្តអ្នកចូលផលសមាបត្តិ មិនអាចគ្របសង្កត់សង្ខារ ហើយចូលសមាបត្តិបាន ព្រោះហេតុនោះលោកទើបពោលថា គោត្រភូធម៌ជាអព្យាកតៈមាន ៣ ។ តែអាចារ្យពួកខ្លះពោលថា សមាបត្តិ ៨ ប្រព្រឹត្តទៅក្នុងចំណែកនៃការចាក់ធ្លុះ ដោយអំណាចអរិយមគ្គ ដែលលោកចង្អុលទុកហើយក្នុងទីនេះ , ព្រោះ

ដូច្នោះ គោត្រភូនៃសមាបត្តិ ៨ ទើបជាកុសល ។ ម្យ៉ាងទៀត គប្បីជ្រាប សូម្បីក្នុងសង្ខាររុបេក្ខាញាណនោះឯង ។

គប្បីជ្រាបអធិប្បាយសេចក្តីក្នុងគាថា មានជាអាទិ៍ថា **សាមិសញ្ច** ដូចតទៅនេះ ។ បណ្តាវដ្តាមិសៈ លោកាមិសៈ កិលេសាមិសៈទាំងឡាយ គោត្រភូញាណមានអាមិស ដោយលោកាមិសៈ ព្រោះនៅមានសេចក្តីប្រាថ្នា ។ នោះគឺអ្វី ? គឺ សមថគោត្រភូញាណ ៨ យ៉ាង ។ បទថា **វដ្តាមិសំ** ក្នុងទីនេះ បានដល់ វដ្តៈប្រព្រឹត្តទៅក្នុងភូមិ ៣ នោះឯង ។ បទថា **លោកមិសំ** បានដល់ កាមគុណ ៥ ។ បទថា **កិលេសាមិសំ** បានដល់ កិលេសទាំងឡាយនោះឯង ។ បទថា **និរាមិសំ** បានដល់ វិបស្សនាគោត្រភូញាណ ១០ យ៉ាង ព្រោះមិនមានសេចក្តីប្រាថ្នា ។ ពិតណាស់ ព្រះអរិយៈទាំងឡាយ មិនធ្វើសេចក្តីប្រាថ្នាក្នុងគោត្រភូ ។ ក្នុងគម្ពីរអាចារ្យទាំងឡាយសរសេរទុកថា **សាមិសញ្ច** នោះ មិនល្អឡើយ ។

គប្បីជ្រាប **បណិហិត អប្បណិហិត , សញ្ញុត្ត វិសញ្ញុត្ត , វុដ្ឋិត អវុដ្ឋិត** ដូចតទៅនេះ ។ ឈ្មោះថា **បណិហិត** គឺ សេចក្តី



ប្រាថ្នា ព្រោះតាំងនៅក្នុងសេចក្តីប្រាថ្នា ។ ឈ្មោះថា **អប្បណិហិត** ព្រោះមិនមានទីតាំង ។ ឈ្មោះថា **សញ្ញុត្ត** ព្រោះប្រកប ដោយសេចក្តីប្រាថ្នា ។ ឈ្មោះថា **វិសញ្ញុត្ត** ព្រោះមិនប្រកប ដោយសេចក្តីប្រាថ្នា ។

បទថា **វុដ្ឋិតំ** បានដល់ គោត្រភូញាណ ដែលជាវិបស្សនា នោះឯង ។ ពិតណាស់ គោត្រភូញាណនោះ ឈ្មោះថា **វុដ្ឋិត** ព្រោះកាត់សេចក្តីប្រាថ្នា ។ ក្រៅពីនោះជា **អវុដ្ឋិត** ។ ម្យ៉ាងទៀត ឈ្មោះថា **វុដ្ឋិត** ព្រោះចេញទៅខាងក្រៅ ។ គប្បីជ្រាបថា សូម្បីផលគោត្រភូដែលជាសង្ខារនិមិត្តខាងក្រៅ , ក៏ឈ្មោះថា **វុដ្ឋិត** ព្រោះឆ្ពោះមុខទៅកាន់និព្វាន ដោយអធ្យាស្រ័យក្នុងនិព្វាន ។ គប្បីជ្រាបថា សូម្បីក្នុងវារៈនៃការគ្របសង្កត់ ការចេញ ការចៀសចេញទៅ ក្នុងខាងក្រោយ ក៏គប្បីជ្រាបថា ផលគោត្រភូ ឈ្មោះថា រមែងគ្របសង្កត់ រមែងចេញទៅ រមែងចៀសចេញទៅ ព្រោះឆ្ពោះមុខទៅកាន់និព្វាន ដោយអធ្យាស្រ័យ ។

បទថា **តិណ្ណំ វិមោក្ខានបច្ចយា** គឺ មានបច្ច័យនៃវិមោក្ខ ៣ បានដល់ សមថគោត្រភូ ជាបកតូបនិស្សយប្បច្ច័យដល់លោ-

កុត្តវិមោក្ខ ៣ , វិបស្សនាគោត្រភូ ជាអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ និងឧបនិស្សយប្បច្ច័យ ។

បទថា **បញ្ញា យស្ស បរិច្ចិត្វា** ព្រះយោគាវចរអប់រំហើយ ដោយបញ្ញា គឺ បញ្ញាដែលជាចំណែកខាងដើម ដែលព្រះយោគាវចរអប់រំហើយ គឺ សន្សំហើយ ។

បទថា **កុសលោ វិវដ្ដេ វុដ្ឋានេ** ព្រះយោគាវចរជាអ្នកឈ្លាសវៃក្នុងការចេញទៅ ក្នុងការចៀសចេញទៅ គឺ ជាអ្នកឆ្លាតវាងវៃ ជាអ្នកឈ្លាសក្នុងគោត្រភូញាណ ដែលបានដល់ វិវដ្ដៈ ដោយការមិនឈ្លក់វង្វេងនោះឯង ឬជាអ្នកវាងវៃដោយញាណដែលជាចំណែកខាងដើម ។

បទថា **នានាទិដ្ឋីសុ ន កម្បតិ** រមែងមិនញាប់ញ័រ ព្រោះទិដ្ឋិផ្សេង ៗ មិនញាប់ញ័រក្នុងទិដ្ឋិមានប្រការផ្សេង ៗ ដែលលះបង់បានហើយដោយសមុច្ឆេទ ។

( ចប់អដ្ឋកថា គោត្រភូញាណនិទ្ទេស )



# អដ្ឋកថា មគ្គញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងមគ្គញាណនិទ្ទេស ដូចតទៅនេះ បទថា **មិច្ឆាទិដ្ឋិយា វុដ្ឋាតិ** ចេញចាកមិច្ឆាទិដ្ឋិ គឺ ចេញចាកមិច្ឆាទិដ្ឋិ ៦២ ដោយសមុច្ឆេទ ដោយការលះបង់ទិដ្ឋានុស័យ គឺ ទិដ្ឋិដែលដេកត្រាំនៅក្នុងសន្ដាន ។

បទថា **តទនុវត្តកកិលេសេហិ** ចេញចាកកិលេសដែលប្រព្រឹត្តទៅតាមមិច្ឆាទិដ្ឋិនោះ បានដល់ ចេញចាកកិលេសទាំងឡាយ ដែលប្រព្រឹត្តទៅតាមមិច្ឆាទិដ្ឋិ ដែលកើតឡើងដោយអំណាចការប្រកបជាមួយមិច្ឆាទិដ្ឋិ និងដោយឧបនិស្ស័យ គឺ ការដេកត្រាំនៅក្នុងមិច្ឆាទិដ្ឋិ ។ ដោយហេតុនោះ លោកទើបពោលដល់ការលះកិលេស ដែលតាំងនៅក្នុងទី ជាមួយគ្នានឹងមិច្ឆាទិដ្ឋិនោះ ។ ពិតណាស់ ការតាំងនៅ ក្នុងទីជាមួយគ្នា មាន ២ យ៉ាង គឺ តាំងនៅក្នុងទីជាមួយគ្នា ដោយការកើតរួមគ្នា និងតាំងនៅក្នុងទីជាមួយគ្នាដោយ ការលះ , ឈ្មោះថា **តទេកដ្ឋា** ព្រោះអត្ថថា តាំងនៅក្នុងចិត្តមួយដួង ព្រមជាមួយទិដ្ឋិនោះ , ឬបុគ្គលម្នាក់

រហូតលះបាន ។ ព្រោះថា កាលលះទិដ្ឋិបាន កិលេសទាំងនេះ គឺ លោភៈ មោហៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ ដែលកើតរួមគ្នាជាមួយទិដ្ឋិនោះ ក្នុងចិត្តដែលជាអសង្ខារិកៈ ២ ដួង សម្បយុត្តដោយទិដ្ឋិ , កិលេសទាំងនេះ គឺ លោភៈ មោហៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ ដែលកើតរួមគ្នាជាមួយទិដ្ឋិនោះ ក្នុងចិត្តដែលជាសសង្ខារិកៈ ២ ដួង រមែងលះបង់បាន ដោយការតាំងនៅក្នុងទីជាមួយគ្នា ដោយការកើតរួមគ្នា ។

កាលលះកិលេសគឺទិដ្ឋិបាន កាលបុគ្គលម្នាក់តាំងនៅរួមគ្នាជាមួយទិដ្ឋិនោះ កិលេសទាំងនេះ គឺ លោភៈ ទោសៈ មោហៈ មានះ វិចិកិច្ឆា ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ ដែលជាហេតុទៅកាន់អបាយ រមែងលះបានដោយអំណាចការតាំងនៅក្នុងទីជាមួយគ្នា ដោយការកើតរួមគ្នា ។

បទថា **ខន្ធេហិ** បានដល់ ដោយខន្ធទាំងឡាយដែលប្រព្រឹត្តទៅតាមទិដ្ឋិនោះ , ដោយអរូបក្ខន្ធ ៤ ដែលតាំងនៅក្នុងទីជាមួយគ្នាដោយការកើតរួមគ្នា និងដោយការតាំងនៅ ក្នុងទីជាមួយគ្នាដោយការលះ ដែលប្រព្រឹត្តទៅតាមទិដ្ឋិនោះ , ឬដោយខន្ធ ៥



ព្រមជាមួយរូបដែលមានទិដ្ឋិនោះ ជាសមុដ្ឋាន , ដោយវិបាកក្ខន្ធដែលកើតឡើងក្នុងអនាគត ព្រោះកិលេស មានមិច្ឆាទិដ្ឋិជាដើមជាបច្ច័យ ។

បទថា **ពហិទ្ធា ច សព្វនិមិត្តេហិ** ចេញចាកសព្វនិមិត្តខាងក្រៅ បានដល់ ចេញចាកពីសង្ខារនិមិត្តទាំងពួងដែលជាខាងក្រៅពីកងកិលេស តាមដែលពោលហើយ ។

បទថា **មិច្ឆាសង្កប្បា វុដ្ឋាតិ** ចេញចាកមិច្ឆាសង្កប្បៈ គឺ ចេញចាកមិច្ឆាសង្កប្បៈក្នុងចិត្ត ៥ ដួង គឺ ក្នុងចិត្ត ៤ ដួង ដែលសម្បយុត្តដោយទិដ្ឋិ និងក្នុងចិត្តសហគតៈដោយវិចិកិច្ឆា ដែលគប្បីលះដោយសោតាបត្តិមគ្គ នឹងក្នុងអកុសលចិត្តដ៏សេស ដែលជាហេតុទៅកាន់អបាយ ។

បទថា **មិច្ឆាវិចាយ វុដ្ឋាតិ** ចេញចាកមិច្ឆាវាចា បានដល់ ចេញពីមុសាវាទ និងបិសុណាវាចា ផរុសវាចា សម្ផប្បលាបៈ ដែលជាហេតុទៅកាន់អបាយ ។

បទថា **មិច្ឆាកម្មន្តា វុដ្ឋាតិ** ចាកពីមិច្ឆាកម្មន្តៈ បានដល់ ចេញចាកបាណាតិបាត អទិន្នាទាន និងមិច្ឆាចារ ។

បទថា **មិច្ឆាអាជីវា វុដ្ឋាតិ** ចេញចាកមិច្ឆាអាជីវៈ បានដល់ បោកបញ្ឆោត ទាយលក្ខណៈ លេងល្បិច ប្រាថ្នាលាភដោយលាភ , មយ៉ាងទៀត ចេញពីកាយកម្ម វចីកម្ម សុម្បី ៧ យ៉ាង មានអាជីវៈជាហេតុ ។ គប្បីជ្រាប ការចេញចាកមិច្ឆាវាយាមៈ មិច្ឆាសតិ មិច្ឆាសមាធិ ដូចន័យបានពោលហើយក្នុងការចេញចាកមិច្ឆាសង្កប្បៈ ។

មយ៉ាងទៀត បទថា **មិច្ឆាសតិ** បានដល់ ត្រឹមតែអកុសលចិត្តុប្បាទប៉ុណ្ណោះ ដែលកើតដោយអាការផ្ទុយអំពីសតិ ។

គប្បីជ្រាបការវិនិច្ឆ័យក្នុងពួក ៣ នៃមគ្គជាន់លើ ដូចតទៅនេះ ។ អង្គរបស់មគ្គ ៨ មានជាអាទិ៍ថា **ទស្សនដ្ឋេន សម្មាទិដ្ឋិ** ឈ្មោះថា សម្មាទិដ្ឋិ ព្រោះអត្ថថា ឃើញ រមែងឃើញ ដូចក្នុងបឋមមគ្គ ដែលកើតក្នុងបឋមជ្ឈាន ។

ក្នុងបទទាំងនោះមានអធិប្បាយដូច្នេះ សម្មាទិដ្ឋិក្នុងបឋមមគ្គ រមែងលះមិច្ឆាទិដ្ឋិ ព្រោះហេតុនោះទើបឈ្មោះថា **សម្មាទិដ្ឋិ** ។ សូម្បីសម្មាសង្កប្បៈជាដើម ក៏គប្បីជ្រាបដោយអត្ថ គឺ ការលះមិច្ឆាសង្កប្បៈជាដើម ។ បើដូច្នោះ ព្រោះលះទិដ្ឋិ ៦២ បានក្នុង



បឋមមគ្គនោះឯង ទើបមិនមានទិដ្ឋិដែលគួរលះដោយមគ្គ ៣ ខាងលើ ។

ក្នុងទិដ្ឋិទាំងនោះ ឈ្មោះថា **សម្មាទិដ្ឋិ** តើដូចម្តេច ? ដូចថ្នាំពិសមាន ឬក៏មិនមាន ថ្នាំដ៏វិសេសលោកហៅថា **អគទោ** នោះឯងយ៉ាងណា , មិច្ឆាទិដ្ឋិមាន ឬមិនមាន ក៏ឈ្មោះថា សម្មាទិដ្ឋិ ដូច្នោះដែរ ។ នេះត្រឹមតែជាឈ្មោះផ្សេងគ្នាប៉ុណ្ណោះ , តែការមិនមានកិច្ចនៃសម្មាទិដ្ឋិ រមែងមានក្នុងមគ្គ ៣ ខាងលើ , អង្គមគ្គក៏មិនបរិបូណ៌ ។ ព្រោះដូច្នោះ គប្បីធ្វើសម្មាទិដ្ឋិព្រមដោយកិច្ច ។ អង្គមគ្គទើបនឹងបរិបូណ៌ ។ គប្បីសម្តែងសម្មាទិដ្ឋិក្នុងទីនេះ ព្រមដោយកិច្ច ដោយកំណត់តាមមាន តាមបាន ។ មានះណា ដែលសម្លាប់ដោយមគ្គ ៣ ខាងលើនៅមាន , មានះនោះ តាំងនៅក្នុងឋានៈនៃទិដ្ឋិ , ទិដ្ឋិនោះរមែងលះមានះនោះបាន ព្រោះហេតុនោះ ទើបឈ្មោះថា **សម្មាទិដ្ឋិ** ។

ពិតណាស់ សម្មាទិដ្ឋិ រមែងលះមិច្ឆាទិដ្ឋិបានក្នុងសោតាបត្តិមគ្គ ។ តែមានះដែលលះដោយសកទាគាមិមគ្គ មានដល់ព្រះសោតាបន្ន , ទិដ្ឋិនោះ រមែងលះមានះនោះបាន ព្រោះហេតុ

នោះ ទើបឈ្មោះថា **សម្មាទិដ្ឋិ** ។ ការត្រិះរិះ កើតព្រមជាមួយ អកុសលចិត្ត ៧ ដួង មានដល់ចិត្តដួងនោះ ការខ្វល់ខ្វាយតាមផ្លូវវាចា រមែងមានពិតដល់ចិត្តទាំងនោះ ការខ្វល់ខ្វាយតាមផ្លូវកាយ ការបរិភោគបច្ច័យ ការព្យាយាម កើតរួមគ្នា ភាពជាអ្នកមិនមានសតិ ការដែលចិត្តមានអារម្មណ៍តែមួយកើតរួមគ្នា , ទាំងនេះឈ្មោះថា **មិច្ឆាសង្កប្ប** ជាដើម ។

គប្បីជ្រាបថា **សម្មាសង្កប្ប** ជាដើម ក្នុងសកទាគាមិមគ្គ ឈ្មោះថា **សម្មាសង្កប្ប** ព្រោះលះ **មិច្ឆាសង្កប្ប** ទាំងនោះបាន ។ អង្គ ៨ ព្រមដោយកិច្ច រមែងមានក្នុងសកទាគាមិមគ្គ ដោយអាការយ៉ាងនេះ ។ មានះ ដែលលះបង់ដោយអនាគាមិមគ្គ រមែងមានដល់ព្រះសកទាគាមី មានះរមែងតាំងនៅក្នុងឋានៈនៃទិដ្ឋិ ។ សម្មាសង្កប្បៈជាដើម កើតរួមគ្នាជាមួយចិត្ត ៧ ដួង មានដល់ព្រះសកទាគាមីនោះ ។

គប្បីជ្រាបសេចក្តីត្រង់អង្គ ៨ ព្រមដោយកិច្ច ក្នុងអនា-គាមិមគ្គដោយការលះចិត្តទាំងនោះ ។ មានះដែលលះបង់ដោយអរហត្តមគ្គ រមែងមានដល់ព្រះអនាគាមី , មានះនោះ តាំងនៅ



ក្នុងឋានៈនៃទិដ្ឋិ ។ សង្កប្បៈជាដើម កើតរួមគ្នាជាមួយអកុសល-ចិត្ត ៥ ដួងនោះ រមែងមានដល់មានះនោះ ។ គប្បីជ្រាបសេចក្តីត្រង់អង្គ ៨ ព្រមដោយកិច្ចក្នុងអរហត្ត ដោយការលះបង់អកុសលចិត្តទាំងនោះ ។

បទថា **ឱឡារិកា** គឺ ជាចំណែកគ្រោតគ្រាត ព្រោះភាពជាបច្ច័យនៃការឈានកន្លងកាយទ្វារ និងវចីទ្វារ ។

បទថា **កាមរាគសញ្ញោជនា** គឺ សំយោជនៈពោល គឺ ការត្រេកអរក្នុងមេថុន ។ ព្រោះកាមរាគៈនោះរមែងប្រកបសត្វទុកក្នុងកាមភព ព្រោះហេតុនោះទើបលោកពោលថា **សញ្ញោជន**។

បទថា **បដិឃសញ្ញោជនា** បានដល់ សំយោជន៍ គឺ ព្យាបាទៈ , ព្រោះព្យាបាទនោះ រមែងបៀតបៀនអារម្មណ៍ ព្រោះហេតុនោះ លោកទើបពោលថា **បដិឃ** ។ សំយោជន៍ទាំងនោះ រមែងដេកត្រាំនៅក្នុងសន្តាន ដោយអត្ថថា ខ្លាំងក្លា ព្រោះហេតុនោះលោកទើបពោលថា **អនុសយា** ។

បទថា **អណុសហគតា** បានដល់ ចំណែកល្អិត ៗ ។ **សហគត** សព្ទ ក្នុងបទនេះ ចុះក្នុងសេចក្តីយ៉ាងនោះ ។ ពិតណាស់

ណាស់កាមរាគៈ និងព្យាបាទៈរបស់ព្រះសកទាគាមី មានចំណែកតិចដោយហេតុ ២ ប្រការ គឺ ព្រោះកើតតិច និងព្រោះគ្របសង្កត់ទុកក្នុងទីនេះតិច ។ កិលេសទាំងឡាយ រមែងមិនកើតឡើងរឿយ ៗ ដូចកិលេសរបស់ពាលបុថុជ្ជន រមែងកើតគ្រាខ្លះ ។ កាលកើត រមែងមិនកើតញាំញី ជ្រួតជ្រាបទៅបិទបាំងធ្វើឲ្យងងឹតដូចរបស់បុគ្គលពាល ។ តែកើតឡើងតិចតួច មានអាការស្រាលស្តើង ព្រោះលះបានដោយមគ្គ ២ , មិនអាចឲ្យដល់ការឈានកន្លងទៅបាន ។ លះកិលេសស្រាលស្តើងបាន ដោយអនាគាមិមគ្គ ។

បទថា **រូបរាគា** បានដល់ សេចក្តីពេញចិត្តត្រេកអរក្នុងរូបភព , បទថា **អរូបរាគា** សេចក្តីពេញចិត្តត្រេកអរក្នុងអរូបភព ។ បទថា **មានា** បានដល់ មានការលើកតម្កើងខ្លួនជាលក្ខណៈ ។ បទថា **ឧទ្ធច្ចា** មានលក្ខណៈមិនស្ងប់ ។

បទថា **អវិជ្ជាយ** មានការងងឹតជាលក្ខណៈ ។ បទថា **ភវរាគានុសយា** បានដល់ ដេកត្រាំនៅក្នុងភវរាគៈ ដែលប្រព្រឹត្តទៅដោយរូបរាគៈ និងអរូបរាគៈ ។



ឥឡូវនេះ ព្រះសារីបុត្តកាលនឹងពណ៌នាដល់មគ្គញ្ញាណ ទើបពោលបទមានអាទិ៍ថា **អជាតំ ឈាបេតិ** ដូច្នេះ ។

ក្នុងបទនោះ ច្រើនបទថា **អជាតំ ឈាបេតិ ជាតេន , ឈានំ តេន បវុច្ចតិ** រមែងដុតកិលេសដែលមិនទាន់កើត ដោយលោកុត្តរឈានដែលកើតហើយ ព្រោះហេតុនោះលោកទើបពោលថា ជាឈាន សេចក្តីថា សមង្គីបុគ្គលរមែងដុត គឺ ទម្លាយ កម្ចាត់កិលេសទាំងនោះ ដែលនៅមិនទាន់កើត ដោយលោកុត្តរជ្ឈាននោះ ៗ ដែលប្រាកដក្នុងសន្តានរបស់ខ្លួន , ដោយហេតុនោះលោកទើបពោលលោកុត្តរៈនោះថា ជាឈាន ។

បទថា **ឈានវិមោក្ខេ កុសលតា** ព្រោះភាវៈជាអ្នកឆ្លាតក្នុងឈាន និងវិមោក្ខ សេចក្តីថា សមង្គីបុគ្គលរមែង មិនញាប់ញ័រក្នុងទិដ្ឋិផ្សេង ៗ ដែលលះបានហើយដោយបឋមមគ្គ ព្រោះភាវៈជាអ្នកឆ្លាតក្នុងឈានមានវិតក្កៈជាដើម ដែលសម្បយុត្តដោយអរិយមគ្គនោះ និងក្នុងអរិយមគ្គដែល បានដល់ វិមោក្ខដោយភាវៈមិនឈ្វក់វង្វេង ។ ឈ្មោះថា **ឈាន** មាន ២ យ៉ាងគឺ អារម្មណូបនិជ្ឈាន ១ លក្ខណូបនិជ្ឈាន ១ ។ ឈានមានលោកិយបឋម-

ជ្ឈានជាដើម ឈ្មោះថា **ឈាន** ព្រោះអត្ថថា ចូលទៅសម្លឹងអារម្មណ៍ មានកសិណជាដើម ។

វិបស្សនាសង្ខារ ឈ្មោះថា **ឈាន** ព្រោះអត្ថថា ចូលទៅសម្លឹងលក្ខណៈដែលជាសភាវសាមញ្ញ , លោកុត្តរៈ ឈ្មោះថា **ឈាន** ព្រោះអត្ថថា ចូលទៅសម្លឹងលក្ខណៈ នៃព្រះនិព្វាន ។ ប៉ុន្តែក្នុងទីនេះ លោកពោលដល់ឈានទូទៅ សូម្បីដោយគោ-ត្រភូ ថាជាឈាន ព្រោះអត្ថថា មិនពាល់ត្រូវសភាពដែលជាលក្ខណូបនិជ្ឈាន ហើយដុតកិលេសដោយមិនទូទៅ ។ ម្យ៉ាងទៀត ក្នុងទីនេះ សភាវៈនៃវិមោក្ខ ជាសភាវៈដែលបង្អោនទៅដោយល្អក្នុងអារម្មណ៍ គឺ ព្រះនិព្វាន និងសភាពដែលរួចផុតដោយល្អអំពីកិលេសទាំងឡាយ ។

បទថា **សមាហិត្វា យថា ចេ បស្សតិ** ប្រសិនបើព្រះយោគាវចរតាំងចិត្តល្អហើយ រមែងឃើញច្បាស់យ៉ាងណា សេចក្តីថា ព្រះយោគាវចរធ្វើការតាំងចិត្តមុនដោយសមាធិណាមួយ មានអប្បនាសមាធិ ឧបចារសមាធិ និងខណិកសមាធិ ហើយឃើញច្បាស់ក្នុងខាងក្រោយ ។ **ចេ** សព្ទ ជាសមុច្ចយត្ថៈ មានអត្ថថា



រួបរួម រមែងរួបរួមវិបស្សនា ។

បទថា **វិបស្សមានោ តថា ចេ សមាទហេ** កាលបើឃើញច្បាស់ ក៏គប្បីតាំងចិត្តទុកឲ្យមាំដូច្នោះ សេចក្តីថា ឈ្មោះថា វិបស្សនានេះ ជាវិបស្សនាសៅហ្មង មិនមានសេចក្តីពេញចិត្ត , ម្យ៉ាងទៀត ឈ្មោះថា សមថៈ ជាសមថៈ ដែលល្អិត មានការពេញចិត្ត , ព្រោះដូច្នោះ ព្រះយោគាវចរកាលឃើញច្បាស់ គប្បីតាំងចិត្តដែលសៅហ្មងដោយវិបស្សនានោះ ដើម្បីការហួងហែង ។ អធិប្បាយថា ព្រះយោគាវចរកាលឃើញច្បាស់ ក៏ចូលសមាធិទៀត ហើយគប្បីធ្វើការតាំងចិត្ត ដូចការញ៉ាំងវិបស្សនា ។ **ចេ** សព្ទ ក្នុងទីនេះ រមែងរួបរួមការតាំងទុកមាំ ។ **ចេ** អក្សរ លោកធ្វើដោយការប្រព្រឹត្តទៅតាមគាថាពន្ធ , តែសេចក្តី ក៏គឺ ច អក្សរនោះឯង ។

បទថា **វិបស្សនា ច សមថោ តទា អហុ** សមថៈ និងវិបស្សនាមានហើយក្នុងខណៈនោះ សេចក្តីថា ព្រោះកាលសមថៈ និងវិបស្សនាជាធម៌គូគ្នា សេចក្តីប្រាកដនៃអរិយមគ្គរមែងមាន , ដូច្នោះ ការប្រកបធម៌ទាំង ២ នោះ ក្នុងកាលណា រមែងមាន

ព្រោះអាចញុំាងអរិយមគ្គឲ្យកើតឡើង , ក្នុងកាលនោះវិបស្សនា និងសមថៈមានហើយ , សមថៈ និងវិបស្សនា ឈ្មោះថា កើតហើយ ។ មយ៉ាងទៀត សមថៈ និងវិបស្សនានោះរមែងជាគូ ដែលមានចំណែកស្មើគ្នាប្រព្រឹត្តទៅ ឈ្មោះថា **សមានភាគា** ព្រោះអត្ថថា សមថៈ និងវិបស្សនាមានចំណែកស្មើគ្នា ឈ្មោះថា **យុគនទ្ធា** ព្រោះជាគូគ្នា , អធិប្បាយថា មានធុរៈស្មើគ្នា មានកម្លាំងស្មើគ្នា ដោយអត្ថថា មិនឈានកន្លងគ្នានឹងគ្នា ។ ចំណែកសេចក្ដីពិស្ដារនៃបទនោះនឹងមានច្បាស់ក្នុង **យុគនទ្ធកថា** ។

ច្រើនបទថា **ទុក្ខា សង្ខារា , សុខោ និរោធោតិ ទស្សនំ ទុភតោ វុដ្ឋិតា បញ្ញា ផស្សេតិ អមតំ បទំ** ការឃើញថាសង្ខារទាំងឡាយជាទុក្ខ និរោធជាសុខ ឈ្មោះថា បញ្ញាដែលចេញចាកធម៌ទាំងពីរ រមែងពាល់ត្រូវអមតបទ សេចក្ដីថាសង្ខារទាំងឡាយជាទុក្ខ និរោធ គឺ និព្វាន ជាសុខ ព្រោះហេតុនោះ ការឃើញនិព្វានដោយអរិយមគ្គញ្ញាណ នៃអ្នកបដិបត្តិ ឈ្មោះថា បញ្ញាចេញចាកធម៌ទាំង ២ នោះ ។ បញ្ញានោះឯងរមែងពាល់ត្រូវ គឺ រមែងបានអមតបទ គឺ និព្វាន ដោយពាល់



ត្រូវអារម្មណ៍ ។ និព្វាន ឈ្មោះថា **អមតំ** ព្រោះដូចជាអមតៈ ដោយអត្ថថា មិនក្ដៅក្រហាយ ។ ឈ្មោះថា **អមតំ** ព្រោះនិព្វាននោះ មិនមានសេចក្ដីស្លាប់ សេចក្ដីវិនាស , លោកពោលថា **បទំ** ព្រោះអត្ថថា រមែងបដិបត្តិដោយបដិបទាធំ ដោយការឧស្សាហៈធំ តាំងពីចំណែកខាងដើម ។

បទថា **វិមោក្ខចរិយំ ជានាតិ** រមែងដឹងវិមោក្ខចរិយា គឺដឹងការប្រព្រឹត្តទៅនៃវិមោក្ខ ដោយការមិនវង្វេង , រមែងដឹងដោយការពិចារណា ។ គប្បីជ្រាប វិមោក្ខចរិយា ដែលមកហើយក្នុងវិមោក្ខកថាខាងមុខថា ៖

**អរិយមគ្គ ៤ ជាទុភតោវុដ្ឋានវិមោក្ខ ,**

**វិមោក្ខ ៤ ចេញពីទុភតោ គឺ ធម៌ ២**

**វិមោក្ខ ៤ អនុលោម តែទុភតោ-**

**វិមោក្ខ , វិមោក្ខ ៤ ស្ងប់ចាកទុភ-**

**តោវុដ្ឋានវិមោក្ខ ។**

សេចក្ដីពិស្ដារនៃវិមោក្ខទាំងនោះ មានមកហើយក្នុងវិមោក្ខកថានោះឯង ។

បទថា **នានត្តេកត្ត គោចរោ** ព្រះយោគាវចរអ្នកឆ្លាតក្នុងសេចក្ដីផ្សេងគ្នា និងសេចក្ដីដូចគ្នា គឺ ជាអ្នកឆ្លាតក្នុងសេចក្ដីផ្សេង និងសេចក្ដីដូចគ្នានៃវិមោក្ខទាំងនោះ ។ គប្បីជ្រាបសេចក្ដីដូចគ្នានៃវិមោក្ខទាំងនោះ ដោយអំណាចនៃវិមោក្ខ គឺ ការចេញចាកធម៌ទាំង ២ យ៉ាង , សេចក្ដីផ្សេងគ្នាដោយអំណាចអរិយមគ្គ ៤ , ឬសេចក្ដីផ្សេងគ្នា ដោយប្រាថ្នាអនុបស្សនានៃអរិយមគ្គ សូម្បីមួយ ៗ , សេចក្ដីដូចគ្នា ដោយភាពជាអរិយមគ្គ ។

បទថា **ទ្វិន្នំ ញាណានំ កុសលតា** ភាពជាអ្នកឆ្លាតក្នុងញាណទាំង ២ បានដល់ ភាពជាឆ្លាតក្នុងញាណទាំង ២ ទាំងនេះ គឺ ទស្សនៈ និងភាវនា ។

បទថា **ទស្សនំ** បានដល់ សោតាបត្តិមគ្គ ។ ព្រោះថា សោតាបត្តិមគ្គនោះ លោកពោលថា **ទស្សនំ** ទស្សនៈ ព្រោះឃើញនិព្វានមុន ។ ចំណែកគោត្រភូញាណ រមែងឃើញនិព្វានមុនក៏ពិត , តែលោកមិនហៅថាទស្សនៈ ការឃើញ ព្រោះមិនមានការលះកិលេស ដូចជាបុរសអ្នកមក កាន់សម្នាក់របស់ព្រះ-



រាជាដោយកិច្ចណានិមួយ សូម្បីឃើញព្រះរាជាប្រថាប់នៅលើ.កដំរី ស្ដេចមកតាមផ្លូវអំពីទីឆ្ងាយ ត្រូវគេសួរថា លោកគាល់ព្រះ-រាជាហើយឬ សូម្បីឃើញហើយ ក៏ពោលថា ខ្ញុំនៅមិនទាន់បានគាល់ ព្រោះកិច្ចដែលបុគ្គលគប្បីធ្វើ នៅទាន់មិនបានធ្វើ ដូច្នោះ ។ ពិតណាស់ គោត្រភូញាណនោះ តាំងនៅក្នុងត្រង់អាវជ្ជនៈ គឺ ការនឹកដល់មគ្គ ។

បទថា **ភាវនា** បានដល់ មគ្គ ៣ ដ៏សេស ។ ព្រោះមគ្គ ៣ ដ៏សេសនោះ រមែងកើតឡើងដោយអំណាចភាវនា ក្នុងធម៌ដែលឃើញហើយ ដោយបឋមមគ្គនោះឯង , មិនឃើញអ្វី ៗ ដែលមិនធ្លាប់ឃើញ , ដូច្នោះលោកទើបពោលថា **ទស្សនំ** ។ ប៉ុន្តែខាងក្រោយ លោកមិនពោលថា **ទ្វិន្នំ ញាណានំ** នៃញាណ ២ យ៉ាង ព្រោះភាវនាមគ្គនៅមិនទាន់សម្រេច ហើយពោលថា **ឈានវិមោក្ខេ កុសលតា** ភាវៈជាអ្នកឆ្លាតក្នុងឈាន និងវិមោក្ខ សំដៅដល់អ្នកបានសោតាបត្តិមគ្គ សកទាគាមិមគ្គ និងអនាគា-មិមគ្គ , តែគប្បីជ្រាបថា លោកពោលថា **ទ្វិន្នំ ញាណានំ កុសលតា** ភាវៈជាអ្នកឆ្លាតក្នុងញាណ ២ យ៉ាង ព្រោះភាវនាមគ្គ

របស់អ្នក បានអរហត្តមគ្គសម្រេចហើយ ។

( ចប់ អដ្ឋកថាមគ្គញ្ញាណនិទ្ទេស )

## អដ្ឋកថា ផលញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ ក្នុងផលញ្ញាណនិទ្ទេស ដូចតទៅនេះ បទថា **តំបយោគប្បដិប្បស្សទ្ធត្តា** ជាគុណជាតិដែលរម្ងាប់បយោគៈចេញនោះ សេចក្តីថា ព្រោះការរម្ងាប់បយោគៈចេញ ទាំងខាងក្នុង និងខាងក្រៅ ជាគុណជាតិរម្ងាប់ហើយ ។ ពិតណាស់ **មគ្គ** ឈ្មោះថា រមែងធ្វើបយោគៈចេញចាកទាំងពីរ ទាំងខាងក្នុង និងខាងក្រៅ ដោយការលះកិលេសក្នុងខណៈរបស់ខ្លួន ។ ការរម្ងាប់នូវបយោគៈដែលចេញចាកទាំងពីរ ទាំងខាងក្នុង និងខាងក្រៅ នៃមគ្គ ដែលឈ្មោះថា ស្ងប់ហើយ ព្រោះលះកិលេសបានក្នុងខណៈនៃផល ។

បទថា **ឧប្បជ្ជតិ** រមែងកើតឡើង សេចក្តីថា ញាណរមែងកើតឡើងមួយដង ឬពីរដង ក្នុងលំដាប់នៃមគ្គ ។ តែកើត



ឡើងច្រើនដង ក្នុងខណៈនៃផលសមាបត្តិ , រមែងកើតដល់អ្នកចេញពីនិរោធ ២ ដង ញាណសូម្បីទាំងអស់ រមែងកើតឡើង ព្រោះជាគុណជាតិរម្ងាប់បយោគៈចេញនោះ ។

បទថា **មគ្គស្សេតំ ផលំ** ការរម្ងាប់បយោគៈនោះ ជាផលនៃមគ្គ គឺ លោកសម្ដែងដល់ផល ទើបធ្វើឲ្យជានបុំសកលិង្គ សូម្បីក្នុងខណៈនៃសកទាគាមិមគ្គជាដើម ក៏គប្បីជ្រាបការប្រកបការចេញដោយអំណាចអង្គនៃមគ្គនិមួយ ៗ នោះឯង ។

( ចប់ អដ្ឋកថាផលញ្ញាណនិទ្ទេស )

## អដ្ឋកថា វិមុត្តិញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងវិមុត្តិញ្ញាណនិទ្ទេស ដូចតទៅនេះ ។

បទថា **សក្កាយទិដ្ឋិ** ការឃើញថា ជាតួខ្លួន មានវិគ្រោះថា ឈ្មោះថា **សក្កាយទិដ្ឋិ** ព្រោះអត្ថថា ការឃើញក្នុងកាយ

ពោលគឺ ខន្ធបញ្ចកៈដែលមាន ឬក្នុងកាយនោះ ដែលមាននោះឯង ៕

បទថា **វិចិកិច្ឆា** ការមិនជឿជាក់ មានវិគ្រោះថា ឈ្មោះថា **វិចិកិច្ឆា** ព្រោះអត្ថថា ប្រាសចាកការជឿជាក់ ឬកាលស្វែងរកសភាវធម៌ជាហេតុយ៉ាងលំបាក ៕

បទថា **សីលព្វតបរាមាសោ** ការស្ទាបអង្អែលសីល និងវត្ត មានវិគ្រោះថា ជាអ្នកប្រកាន់មាំថា ការបរិសុទ្ធិ មានដោយសីល និងវត្ត ៕ ឈ្មោះថា **សីលព្វតបរាមាសោ** ព្រោះអត្ថថា អ្នកប្រកាន់មាំនោះ លះសភាវធម៌ដែលស្ទាបអង្អែលវត្ថុដទៃ ៕ កាលទិដ្ឋិសូម្បីមានទាំងពីរយ៉ាង លោកក៏នៅពោលថាសក្កាយ-ទិដ្ឋិ ដើម្បីសម្តែងដល់ការលះទិដ្ឋិទាំងអស់ ដោយការលះបង់សក្កាយទិដ្ឋិមានវត្ថុ ២០ យ៉ាង ជាប្រក្រតី ដោយការប្រកាន់សក្កាយទិដ្ឋិតាមប្រក្រតី វៀរកភាពឡេះឡោះ និងការអាងអ្នកដទៃ ៕ ចំណែកសីលព្វតបរាមាស គប្បីជ្រាបថា លោកពោលទុកផ្សេងដទៃទៀត ដើម្បីសម្តែងដល់មិច្ឆាបដិបទា នៃមនុស្សទាំងឡាយអ្នកបដិបត្តិ ដោយគិតថា យើងបដិបត្តិបដិបទាបរិសុទ្ធិ ៕



លោកពោល ដល់ទិដ្ឋានុស័យ ការឃើញខុសដែលដេកនៅក្នុងសន្តាន វិចិកិច្ឆានុស័យ ការសង្ស័យ ដេកត្រាំក្នុងសន្តាន ដើម្បីសម្តែងដល់ការលះដោយលះអនុស័យ សូម្បី ៣ យ៉ាងនោះឯង ៕ មិនមែនព្រោះកិលេសផ្សេងគ្នា ៕ បទថា **ឧបក្កិលេសា** ឧបក្កិលេសទាំងឡាយ មានវិគ្រោះថា ឈ្មោះថា **កិលេសា** ព្រោះអត្ថថា ធ្វើឲ្យសៅហ្មង ធ្វើឲ្យក្តៅក្រហាយ ធ្វើឲ្យលំបាក ៕ ឈ្មោះថា **ឧបក្កិលេសា** ព្រោះអត្ថថា ជាកិលេសដែលមានកម្លាំង ៕

បទថា **សម្មា សមុច្ឆិន្នា ហោន្តិ** ជាកិលេសដែលសោតា-បត្តិមគ្គលះដាច់ល្អហើយ គឺ លះដាច់ដោយល្អ ព្រោះរលត់មិនកើតឡើងទៀត ដោយសមុច្ឆេទប្បហានៈ ៕

បទថា **សបរិយុដ្ឋានេហិ** ព្រមដោយបរិយុដ្ឋានកិលេស បានដល់ កិលេសគ្របសង្កត់ មានវិគ្រោះថា កិលេសទាំងឡាយ ឈ្មោះថា **បរិយុដ្ឋាន** ព្រោះអត្ថថា រួបរឹតចិត្តឲ្យកើតឡើង ៕ បទនេះ ជាឈ្មោះរបស់កិលេសទាំងឡាយ ដែលជាប់ដោយការប្រព្រឹត្ត ៕ ឈ្មោះថា **សបរិយុដ្ឋាន** ព្រោះអត្ថថា ព្រមដោយបរិយុដ្ឋានកិលេស គឺ ឧបក្កិលេសដែលដេកត្រាំក្នុងសន្តាន ៕ បទថា **ចិត្តំ វិមុត្តំ ហោតិ** ចិត្តបានរួចផុតហើយ សេចក្តីថា

ថា ចិត្តប្រព្រឹត្តទៅដោយអំណាចសន្តតិ ព្រោះកិលេសទាំងនោះធ្វើឲ្យកើតក្នុងកន្លែងមិនសមគួរ ឈ្មោះថា ជាការរួចផុតហើយចាកកិលេសនោះ ។ ចិត្តនោះឯង ឈ្មោះថា **សុវិមុត្តំ** ព្រោះរួចផុតហើយដោយល្អ ។

បទថា **តំវិមុត្តិញ្ញាតដ្ឋេន** គឺ ព្រោះអត្ថថា ដឹងវិមុត្តិនោះ ។

( ចប់ អដ្ឋកថាវិមុត្តិញ្ញាណនិទ្ទេស )

## អដ្ឋកថា បច្ចវេក្ខណញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងបច្ចវេក្ខញ្ញាណនិទ្ទេស ដូចតទៅនេះ ព្រះសារីបុត្តត្ថេរ លុះពោលអង្គនៃមគ្គទុកមួយផ្នែក ៗ មុន ព្រោះអត្ថថាជាហេតុក្នុងខណៈនៃមគ្គនោះឯង ហើយទើបសម្តែងដល់ពោជ្ឈង្គៈទុកមួយចំណែក ដោយការៈជាអង្គនៃអរិយៈ ដែលបានឈ្មោះថា **ពោធិ** ព្រោះអត្ថថា ត្រាស់ដឹង ធម៌ដែលជាអង្គនៃមគ្គនឹងមិនមែនអង្គនៃមគ្គទៀត ។ ពិតណាស់ សតិសម្ពោជ្ឈង្គៈ



ធម្មវិចយសម្ពោជ្ឈង្គៈ វីរិយសម្ពោជ្ឈង្គៈ សមាធិសម្ពោជ្ឈង្គៈ ជាអង្គនៃមគ្គតែម្យ៉ាង , បីតិសម្ពោជ្ឈង្គៈ បស្សទ្ធិសម្ពោជ្ឈង្គៈ ឧបេក្ខាសម្ពោជ្ឈង្គៈ មិនមែនអង្គនៃមគ្គ ។

បណ្តាធម៌ទាំងឡាយ ដែលសម្តែងទុកក្នុងទីដទៃទៀត ដោយភាពជាពលៈ និងឥន្ទ្រិយ សទ្ធាប៉ុណ្ណោះមិនមែនជាអង្គនៃមគ្គ ។ ព្រះសារីបុត្តត្ថេរ កាលនឹងសម្តែងធម៌ ដែលកើតក្នុងខណៈនៃមគ្គទៀត ដោយអំណាចជាពួក ទើបពោលពាក្យមានជាអាទិ៍ថា **អាធិបតេយ្យដ្ឋេន** ឈ្មោះថា ឥន្ទ្រិយ ព្រោះអត្ថថាជាធំ ។

ក្នុងបទទាំងនោះ បទថា **ឧបដ្ឋានដ្ឋេន សតិប្បដ្ឋានា** ឈ្មោះថា សតិប្បដ្ឋាន ព្រោះអត្ថថា តាំងមាំ សេចក្តីថា សតិប្រព្រឹត្តទៅក្នុងកាយ វេទនា ចិត្ត ធម៌ មាននិព្វានជាអារម្មណ៍តែម្យ៉ាងប៉ុណ្ណោះ ទាំង ៤ យ៉ាងនោះ ឈ្មោះថា **សតិប្បដ្ឋាន** ដោយអំណាចឲ្យសម្រេចកិច្ចក្នុងការលះ ការសម្គាល់ថា ស្អាត ជាសុខទៀង ជាតួខ្លួន , វីរិយៈតែម្យ៉ាងប៉ុណ្ណោះ មាននិព្វានជាអារម្មណ៍ ឈ្មោះថា សម្មប្បធាន ៤ ដោយឲ្យសម្រេចកិច្ច គឺ លះ

អកុសលដែលកើតហើយ និងអកុសលដែលនៅមិនទាន់កើតមិនឲ្យកើតឡើង ឲ្យសម្រេចកិច្ច គឺ ការកើតឡើងនៃកុសលដែលនៅមិនទាន់ កើត និងការតាំងនៅនៃកុសលដែលកើតឡើងហើយ ។

បទថា **តថដ្ឋេន សច្ចា** ឈ្មោះថាសច្ចៈ ព្រោះអត្ថថា ពិតប្រាកដ សេចក្ដីថា ឈ្មោះថាអរិយសច្ច ៤ ព្រោះអត្ថថា មិនខុស ក្នុងភាវៈជាសច្ចៈ មានទុក្ខសច្ចជាដើម ។ មយ៉ាងទៀត អរិយសច្ច ៤ នោះឯង ឈ្មោះថា ប្រជុំគ្នាក្នុងគ្រានោះ ព្រោះអត្ថថា ជាការដឹងច្បាស់ដោយការចាក់ធ្លុះ ។ ហើយលោកពោលដល់និព្វានទុកផ្សេងដទៃថា **អមតោគធំ និព្វានំ** ឈានចុះកាន់អមតៈ គឺ ព្រះនិព្វាន ។ ចំណែកក្នុងធម៌ដ៏សេសឈ្មោះថា ប្រជុំគ្នាក្នុងគ្រានោះ ព្រោះអត្ថថា បានទទួលចំពោះ ។ ក្នុងបទនេះគួរកាត់សេចក្ដីសង្ស័យថា ព្រះយោគាវចររមែងពិចារណាសច្ចៈ ៤ យ៉ាង ពិតប្រាកដ ក្នុងទីបំផុតនៃមគ្គផល ព្រោះពាក្យថា **តថដ្ឋេន សច្ចា តទា សមុទាគតា** ឈ្មោះថា សច្ចៈប្រជុំគ្នាក្នុងគ្រានោះ ព្រោះអត្ថថា ជាសភាវៈពិតប្រាកដ ។ ហើយព្រោះពាក្យថា **កតំ ករណីយំ នាបរំ ឥតត្ថ តាយាតិ បជានាតិ** រមែងដឹងថា កិច្ច



ដែលគួរធ្វើ បានធ្វើសម្រេចហើយ មិនមានកិច្ចដទៃ ដែលគួរធ្វើយ៉ាងដទៃទៀត ទើបលោកពោលដល់ការពិចារណាថា **ទុក្ខយើងកំណត់ដឹងហើយ សមុទយយើងលះបង់ហើយ និរោធយើងធ្វើឲ្យជាក់ច្បាស់ហើយ មគ្គយើងបានចម្រើនហើយ** ។ ការពិចារណាយ៉ាងនោះសមគួរ ។

មយ៉ាងទៀត ក្នុងបទថា **សមុទយោ** នេះ គប្បីជ្រាបដល់កិលេសដែលទម្លាយដោយមគ្គនោះ ៗ ឯង ។ ដោយពិចារណាសមុទ័យ ដែលលោកពោលទុកក្នុងបទនេះ ក្នុងអដ្ឋកថា លោកទើបពោលថា ការពិចារណាកិលេស ២ យ៉ាង ការពិចារណាមគ្គផល និព្វាន មកហើយដោយសរុបក្នុងទីនេះ ។ លោកមិនបានពោលដល់ការពិចារណាទុក្ខតែមយ៉ាងប៉ុណ្ណោះ ។ ថ្វីបើលោកមិនបានពោលទុកក៏ពិត ការពិត គួរកាន់យកតាមដែលប្រាកដក្នុងបាលី និងតាមសេចក្ដី តាមសមគួរ ។ ពិតណាស់ កាលដឹងច្បាស់ការចាក់ធ្លុះសច្ចៈ សម្រេចដល់អ្នកបដិបត្តិដើម្បីដឹងច្បាស់នូវការចាក់ធ្លុះសច្ចៈ ការពិចារណាដល់កិច្ចដែលសម្រេចហើយដោយខ្លួនឯងជាការសមគួរតែមយ៉ាង ។

បទថាមានជាអាទិ៍ថា **អវិក្ខេបដ្ឋេន សមថោ** ឈ្មោះថា សមថៈ ព្រោះអត្ថថា មិនរាយមាយ សេចក្តីថា ព្រះសារីបុត្តត្ថេរ ពោលធម៌ គឺ សមថៈ និងវិបស្សនា ដែលសម្បយុត្តដោយមគ្គ ដើម្បីសម្តែងដោយអត្ថមានរសតែមួយដូចគ្នា និងដោយអត្ថដែលមិនលាយឡំគ្នា ។

បទថា **សំវរដ្ឋេន សីលវិសុទ្ធិ** ឈ្មោះថា សីលវិសុទ្ធិ ព្រោះអត្ថថា សង្រួម បានដល់ មានវាចាប្រពៃ មានការងារប្រពៃ មានការចិញ្ចឹមប្រពៃ ។

បទថា **អវិក្ខេបដ្ឋេន ចិត្តវិសុទ្ធិ** ឈ្មោះថា ចិត្តវិសុទ្ធិ ព្រោះអត្ថថា មិនរាយមាយ បានដល់ មានការតាំងចិត្តដោយប្រពៃនោះឯង ។

បទថា **ទស្សនដ្ឋេន ទិដ្ឋិវិសុទ្ធិ** ឈ្មោះថា ទិដ្ឋិវិសុទ្ធិ ព្រោះអត្ថថា ឃើញ បានដល់ ឃើញប្រពៃនោះឯង ។

បទថា **វិមុត្តដ្ឋេន** ព្រោះអត្ថថា រួចផុត គឺ រួចផុតចាកកិលេស ព្រោះកម្ចាត់ដោយមគ្គដាច់ជាសមុច្ឆេទ ឬបង្អោនទៅក្នុងអារម្មណ៍ គឺ និព្វាន ។



បទថា **វិមោក្ខោ** ការរួចផុត បានដល់ ការរួចផុតដោយដាច់ជាសមុច្ឆេទ គឺ អរិយមគ្គនោះឯង ។

បទថា **បដិវេធដ្ឋេន វិជ្ជា** ឈ្មោះថា វិជ្ជា ព្រោះអត្ថថា ចាក់ធ្លុះ គឺ ចាក់ធ្លុះសច្ចៈ បានដល់ **សម្មាទិដ្ឋិ** ការឃើញប្រពៃនោះឯង ។

បទថា **បរិច្ចាគដ្ឋេន វិមុត្តិ** ឈ្មោះថា វិមុត្តិ ព្រោះអត្ថថា លះបង់ មានវិគ្រោះថា ឈ្មោះថា **វិមុត្តិ** ព្រោះរួចអំពីកិលេសនោះ ដោយការលះបង់កិលេសដែលមគ្គប្រហារហើយ ។ បានដល់ អរិយមគ្គនោះឯង ។

បទថា **សមុច្ឆេទដ្ឋេន ខយេ ញាណំ** ឈ្មោះថា ខយញ្ញាណ ព្រោះអត្ថថា កាត់ផ្តាច់ សេចក្តីថា ឈ្មោះថា អរិយមគ្គញ្ញាណ ធ្វើឲ្យអស់ទៅនូវកិលេស ដោយការកាត់កិលេសបានដាច់ជាស-មុច្ឆេទ ។ បានដល់ ឃើញប្រពៃនោះឯង ។

គប្បីជ្រាបឆន្ទៈជាដើម ដោយន័យដូចបានពោលហើយក្នុងខាងក្រោយនោះឯង ។ ពិតណាស់ ក្នុងបទនេះព្រះសារីបុត្តត្ថេរសម្តែងដោយអាការជាដើមថា កណ្តាល និងខាងចុងនៃមគ្គ ក្នុង

ខណៈមគ្គនោះឯង ។ មយ៉ាងទៀត ក្នុងបទថា **វិមុត្តិ** នេះ បានដល់មគ្គវិមុត្តិនោះឯង ។

មយ៉ាងទៀត និព្វាន សូម្បីលោកកាន់យកក្នុងបទថា **តថដ្ឋេន សច្ចា** ឈ្មោះថា សច្ចៈ ព្រោះអត្ថថា ពិតប្រាកដ ក៏គប្បីជ្រាបថា លោកពោលទៀតដើម្បីសម្តែងដល់ភាពជាទីបំផុតបទនេះ ។ សូម្បីក្នុងខណៈនៃផល ក៏មានន័យនេះដូចគ្នា ។ តែក្នុងបទនេះថា **ហេតដ្ឋេន មគ្គោ** ឈ្មោះថា មគ្គ ព្រោះអត្ថថា ជាហេតុ គប្បីជ្រាបក្នុងភាពជាហេតុនៃផលនោះឯង ។

បទថា **សម្មប្បធានា** សេចក្តីព្យាយាមត្រូវ គប្បីជ្រាបថា លោកពោល ព្រោះកាលដែលផល ជាកិច្ច នៃសេចក្តីព្យាយាមញុំាងកិច្ច ៤ យ៉ាង ឲ្យសម្រេចហើយក្នុងខណៈកើត ។ ព្រោះសម្មប្បធាន រមែងមិនបានក្នុងខណៈផល ដោយប្រការដទៃ ។ ព្រះថេរៈដែលលើកពោធិបក្ខិយធម៌ ៣៧ ឡើង ក្នុងខណៈនៃមគ្គពោលទុកថា ធម៌ ៣៧ ប្រការ ដ៏សេស វៀរសម្មប្បធាន ៤ រមែងបានក្នុងខណៈនៃផល ។ គប្បីជ្រាប សូម្បីសច្ចៈជាដើមតាមដែលប្រកបដោយអំណាចសម្រេចកិច្ច មានកិច្ច គឺ ការចាក់



ធ្លុះជាដើមយ៉ាងនោះ ដូចគ្នា ។

មយ៉ាងទៀត បទថា **វិមោក្ខោ** បានដល់ ផលវិមោក្ខ ។

បទថា **វិមុត្តិ** បានដល់ ផលវិមុត្តិ ។

ឈ្មោះ **អនុប្បាទញ្ញាណ** ញាណក្នុងការមិនកើត ព្រោះអត្ថថា រម្ងាប់ មានសេចក្តីដូចបានពោលហើយនោះឯង ។

បទថា **វុដ្ឋហិត្វា** ចេញហើយ លោកពោលទុកយ៉ាងនេះ ដោយអំណាចផល ព្រោះមិនមានការចេញក្នុងរវាង ។

បទថា **ឥមេ ធម្មា តទា សមុទាគតា** ធម៌ទាំងនេះ ផ្តើមកើតក្នុងគ្រានោះ គប្បីជ្រាបការជ្រះថ្លា **ឥតិ** ស័ព្ទ ដែលជាបាលីដ៏សេសថា ព្រះយោគាវចររមែងពិចារណាថា ធម៌មានប្រការដូចពោលហើយទាំងនេះ ផ្តើមកើតក្នុងខណៈនៃមគ្គ និងក្នុងខណៈនៃផល ដូច្នេះ ។

( ចប់ អដ្ឋកថាបច្ចវេក្ខណញ្ញាណនិទ្ទេស )

# អដ្ឋកថា វត្ថុនានត្តញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងវត្ថុនានត្តញ្ញាណនិទ្ទេស ដូចតទៅនេះ ។ បទថា **ចក្ខុំ អជ្ឈត្តំ វវត្ថេតិ** ព្រះយោគាវចរ រមែងកំណត់ចក្ខុខាងក្នុង សេចក្ដីថា ព្រះសារីបុត្តត្រេកបំណងនឹងពោលដោយអាការដែលព្រះយោគាវចរនោះ កំណត់ចក្ខុ ទើបសួរថា កំណត់ចក្ខុខាងក្នុង តើដូម្ដេច ? ហើយសម្ដែងអាការកំណត់ដោយពាក្យមានជាអាទិ៍ថា **ចក្ខុ អវិជ្ជាសម្ភូតន្តិ វវត្ថេតិ** រមែងកំណត់ថា **ចក្ខុកើតព្រោះ អវិជ្ជា** ដូច្នេះ ។

គប្បីជ្រាបសេចក្ដីក្នុងបទទាំងនោះដូចតទៅនេះ ៖-

អវិជ្ជា តណ្ហាដែលជាអតីត ជាហេតុឧបត្ថម្ភ
កម្មដែលជាអតីតជាហេតុឲ្យកើត អាហារជា
ហេតុឧបត្ថម្ភក្នុងបច្ចុប្បន្ននេះ ។

ដោយបទនោះលោកកាន់យក ឧតុ និងចិត្ត ឧបត្ថម្ភចក្ខុផង ។ បទថា **ចតុន្នំ មហាភូតានំ ឧបាទាយ** ចក្ខុអាស្រ័យ



មហាភូតរូប ៤ ។ បទនេះជាឆដ្ឋីវិភត្តិចុះក្នុងអត្ថនៃទុតិយាវិភត្តិ អធិប្បាយថា ចក្ខុអស្រ័យមហាភូតរូប ៤ ហើយ ប្រព្រឹត្តទៅ ។ ដោយបទនោះ លោកសម្ដែងដល់ភាវៈបសាទចក្ខុ បដិសេធភាពជាសសម្ភារចក្ខុ គ្រឿងតាក់តែងចក្ខុ ។

បទថា **ឧប្បន្នំ** កើតឡើងហើយ គឺ កើតឡើងចំពោះមុខដោយអំណាចនៃអទ្ធា កាលវែង ឬដោយអំណាចនៃខណៈដែលជាសន្តតិ ការបន្ត ។

បទថា **សមុទាគតំ** ចូលមកប្រជុំហើយ គឺ កើតឡើងហើយពីហេតុ ។ ដោយហេតុត្រឹមប៉ុណ្ណេះ លោកសម្ដែងដល់ការកំណត់ចក្ខុក្នុងចំណែកខាងដើមនៃវិបស្សនា ។

លោកសម្ដែងដល់អនិច្ចានុបស្សនា ដោយបទមានជាអាទិ៍ថា **អហុត្វា សម្ភូតំ** មិនមាន ហើយមាន សេចក្ដីថា ឈ្មោះថា **មិនមាន ហើយមាន** ព្រោះមិនមានការកើតក្នុងកាលមុន ។ ឈ្មោះថា **មានហើយ នឹងមិនមាន** ព្រោះការមិនមានការវិនាសទៅ ។

បទថា **អន្តវន្តតោ** ដោយភាពជារបស់មានទីបំផុត សេចក្ដីថា

ឈ្មោះថា **អន្តវា** ព្រោះមានទីបំផុត ។ មានទីបំផុតនោះឯង ឈ្មោះថា **អន្តវន្តោ** ដូចបទថា **សតិមន្តោ គតិមន្តោ ធិតិមន្តោ ច យោ ឥសិ** អ្នកស្វែងរកគុណជា អ្នកមានសតិ មានគតិ និង មានធិតិ ។ ដោយភាពជារបស់ មានទីបំផុតនោះ ។ អធិប្បាយ ថា ដោយមានការរលត់ទៅ ។

បទថា **អទ្ធុវំ** មិនយឺនយូរ គឺ មិនមាំទាំ ព្រោះធ្លាក់ទៅ ក្នុងការតាំងនៅមិនបាន ដោយប្រការទាំងពួង និងព្រោះមិនមាន ភាពមាំទាំ ។

បទថា **អសស្សតំ** ការមិនទៀង គឺ មិនពិតប្រាកដ ។

បទថា **វិបរិណាមធម្មំ** មានការប្រែប្រួលទៅជាធម្មតា គឺ មានការប្រែប្រួលទៅជាប្រក្រតីដោយអាការ ២ យ៉ាង គឺ ដោយ ជរា និងមរណៈ ។

បទមានជាអាទិ៍ថា **ចក្ខុំ អនិច្ចំ** ចក្ខុមិនទៀង និងបទ មានជាអាទិ៍ថា **ចក្ខុំ អនិច្ចតោ** រមែងកំណត់ចក្ខុ ដោយភាពជា របស់មិនទៀង មានសេចក្តីដូចដែលបានពោលទុកហើយ ។

បទមានជាអាទិ៍ថា **អវិជ្ជាសម្ភូតោ** កើតព្រោះអវិជ្ជា រមែង



សមគួរតែមយ៉ាង ព្រោះក្នុងបទថា **មនោ** នេះ លោកសំដៅយក ចិត្តដែលជាភវង្គ ។

ក្នុងបទនេះថា **អាហារសម្ភូតោ** កើតព្រោះអាហារ គប្បី ជ្រាបដោយអំណាចផស្សាហារ និងមនោសញ្ចេតនាហារ ប្រកប គ្នា ។

បទថា **ឧប្បន្នោ** កើតឡើងហើយ គប្បីជ្រាបដោយអំណាច នៃអទ្ធា កាលវែង និងសន្តតិ ការបន្ត ។

( ចប់ អដ្ឋកថាវត្ថុនានត្តញាណនិទ្ទេស )

# អដ្ឋកថា គោចរនានត្តញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ ក្នុងគោចរនានត្តញាណនិទ្ទេសដូចតទៅ នេះ ។ បទថា **រូបេ ពហិទ្ធា វវត្ថេតិ** ព្រះយោគាវចរ រមែងកំណត់ រូបជាខាងក្រៅ សេចក្តីថា រមែងកំណត់រូបាយតនធម៌ដែលជាខាង

ក្រៅ ។

បទមានជាអាទិ៍ថា **អវិជ្ជាសម្ភូតា** កើតព្រោះអវិជ្ជា លោកពោលទុកហើយ ព្រោះកម្មជ្ជរូបជាប់ដោយអត្តភាព ។ ពិតណាស់ សូម្បីអាហារ ក៏ជាបច្ច័យឧបត្ថម្ភកម្មជ្ជរូប ។ តែព្រោះសម្តែងមានសមុដ្ឋានពីឧតុ និងចិត្ត លោកទើបមិនពោលដល់ធម៌ពួក ៤ មានការកើតព្រោះអវិជ្ជាជាដើម ។ ព្រោះផោដ្ឋព្វៈជាមហាភូតរូបនោះឯង លោកទើបមិនពោលថា អាស្រ័យមហាភូតរូប ៤ ។

ម្យ៉ាងទៀត ក្នុងបទថា **ធម្មា** នេះ បានដល់ ខន្ធមិនមានរូប ៣ ដែលប្រកបដោយចិត្តដែលជាកវគ្គ ។ សុខុមរូប ដែលជាប់ក្នុងធម្មាយតនៈ សូម្បីកម្មជាសមុដ្ឋាន និងរូបជាដើម សូម្បីទាំងអស់ ។ ម្យ៉ាងវិញទៀត រូបណា ៗ រមែងកើតឡើងដោយកម្មណា ៗ ។ គប្បីជ្រាបរូបនោះ ៗ ដោយកម្មនោះ ។

ពិតណាស់ ធម៌ទាំងឡាយមានរូបជាដើម សូម្បីជាប់ក្នុងសន្តានរបស់ខ្លួន ក៏មិនគប្បីសង្រ្គោះចូលទៅទាំងអស់ ។ ព្រោះសូម្បីរូបដែលជាប់ដោយអនិន្ទ្រិយជាដើម ក៏ចូលដល់វិបស្សនាបាន ។ ដូច្នោះគប្បីជ្រាបការសង្រ្គោះធម៌ទាំងនោះ ដោយបទថា



**កម្មសម្ភូតំ** កើតព្រោះកម្ម ។ ព្រោះសូម្បីធម៌ទាំងនោះ ក៏មានឧតុតាំងឡើងព្រោះកម្ម ជាបច្ច័យទូទៅដល់សព្វសត្វ ។ ក៏អាចារ្យពួកដទៃពោលថា រូបជាដើម ដែលជាប់ដោយអនិន្ទ្រិយ មិនចូលដល់វិបស្សនាបាន ។

តែពាក្យនោះខុស ព្រោះក្នុងបាលីមានពាក្យជាអាទិ៍ថា ៖

**សព្វេ សង្ខារា អនិច្ចាតិ យទា បញ្ញាយ បស្សតិ**
**អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។**

កាលណាបុគ្គលរមែងឃើញដោយបញ្ញាថា សង្ខារទាំងឡាយទាំងពួងមិនទៀង , កាលនោះរមែងនឿយណាយក្នុងទុក្ខ នោះជាផ្លូវនៃសេចក្តីបរិសុទ្ធ ។

ម្យ៉ាងទៀត ក្នុងវិសុទ្ធមគ្គលោកពោលថា បុគ្គលពួកខ្លះក្នុងលោកនេះ ពិចារណាឃើញច្បាស់សង្ខារខាងក្នុងខ្លួន ។ តែព្រោះការចេញចាកមគ្គ រមែងមិនមាន ដោយត្រឹមតែឃើញខាងក្នុងបរិសុទ្ធប៉ុណ្ណោះ សូម្បីខាងក្រៅ ក៏គប្បីឃើញផង ។ ព្រោះដូច្នោះ ព្រះយោគាវចររមែងឃើញច្បាស់ សូម្បីខន្ធនៃបុគ្គលដទៃ សូម្បីសង្ខារដែលជាអនុបាទិន្នកៈថា **មិនទៀង ជាទុក្ខ ជា**

**អនត្តា** ។ ដូច្នោះ ទើបគួរប្រាថ្នាសូម្បីការកំណត់ចក្ខុជាដើមរបស់បុគ្គលដទៃ

សូម្បីការកំណត់រូបដែលជាប់ដោយអនិន្ទ្រិយជាដើម ។ ដូច្នោះ សង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា មិនចូលដល់វិបស្សនារមែងមិនមាន ។

( ចប់ អដ្ឋកថាគោចរនានត្តញ្ញាណនិទ្ទេស )

## អដ្ឋកថា ចរិយានានត្តញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ ក្នុងចរិយានានត្តញ្ញាណនិទ្ទេស ដូចតទៅនេះ ។ ក្នុងបទមានជាអាទិ៍បទថា **វិញ្ញាណចរិយា** មានសេចក្តីដូចតទៅនេះ ឈ្មោះថា **ចរិយា** ព្រោះអត្ថថា ប្រព្រឹត្តទៅក្នុងអារម្មណ៍ ។ ចរិយា គឺ វិញ្ញាណ ឈ្មោះថា **វិញ្ញាណចរិយា** ។

ឈ្មោះថា **អញ្ញាណចរិយា** ព្រោះអត្ថថា ប្រព្រឹត្តដោយការមិនដឹង , ឬប្រព្រឹត្តព្រោះការមិនដឹង ។ ឬប្រព្រឹត្តក្នុងអារម្មណ៍ដែលមិនដឹង, ឬប្រព្រឹត្តនូវការមិនដឹង ។



ឈ្មោះថា **ញាណចរិយា** ព្រោះអត្ថថា ចរិយា គឺ ញាណ ឬការប្រព្រឹត្តដោយញាណ , ឬប្រព្រឹត្តព្រោះញាណ , ឬប្រព្រឹត្តក្នុងអារម្មណ៍ដែលដឹងហើយ , ឬប្រព្រឹត្តនូវការដឹង ។

បទថា **ទស្សនត្ថាយ** ដើម្បីត្រូវការឃើញ គឺ ប្រព្រឹត្តទៅដើម្បីត្រូវការឃើញរូប ។ បទថា **អាវជ្ជនកិរិយាព្យាកតា** កិរិយា គឺ ការនឹកជាអព្យាកត គឺ ឈ្មោះថា **អាវជ្ជន** ព្រោះអត្ថថា នាំចាកសន្តានដែលជាភវង្គ ហើយភាវរក គឺ បង្អោនទៅកាន់ចិត្តសន្តានក្នុងរូបារម្មណ៍ ។ ឈ្មោះថា **កិរិយា** ព្រោះអត្ថថា ត្រឹមតែការធ្វើដោយមិនមានវិបាក ។ ឈ្មោះថា **អព្យាកត** ព្រោះអត្ថថា ព្យាករណ៍មិនចាត់ថា ជាកុសល ឬអកុសល ។

បទថា **ទស្សនដ្ឋោ** ត្រឹមតែជាការឃើញ ។ ឈ្មោះថា **ទស្សនំ** ព្រោះអត្ថថា ជាហេតុឃើញ ឬឃើញឯង ឬត្រឹមតែជាការឃើញរូបនោះ ។ អត្ថ គឺ ការឃើញ ឈ្មោះថា **ទស្សនដ្ឋោ** ។

បទថា **ចក្ខុវិញ្ញាណំ** ចក្ខុវិញ្ញាណ បានដល់ កុសលវិបាក ឬអកុសលវិបាក ។

បទថា **ទិដ្ឋត្តា** ព្រោះបានឃើញហើយ គឺ ព្រោះបានឃើញ

រូបារម្មណ៍ដោយចក្ខុវិញ្ញាណ ព្រោះមិនមានការទទួលអារម្មណ៍ដែលមិនឃើញ ។

បទថា **អភិនិរោបនា វិបាកមនោធាតុ** មនោធាតុ ដែលជាវិបាកដែលឡើងកាន់អារម្មណ៍ ។ ឈ្មោះថា **អភិនិរោបនា** ព្រោះអត្ថថា លើកឡើងកាន់អារម្មណ៍ដែលបានឃើញហើយ ។ សម្បដិច្ឆន្នមនោធាតុ ជាវិបាកទាំងពីរ ។

បទថា **អភិនិរោបិតត្តា** ព្រោះលើកឡើងហើយ គឺ ព្រោះលើកឡើងកាន់រូបារម្មណ៍ ។

បទថា **វិបាកមនោវិញ្ញាណធាតុ** មនោវិញ្ញាណធាតុ ដែលជាវិបាក គឺ សន្តីរណមនោវិញ្ញាណធាតុ ពិចារណាអារម្មណ៍ ជាវិបាកទាំងពីរ ។ សូម្បីក្នុងសោតទ្វារជាដើមក៏មានន័យនេះ សូម្បីលោកមិនពោលដល់វោដ្ឋព្វនៈ ការកំណត់អារម្មណ៍ក្នុងលំដាប់សន្តីរណៈ ការពិចារណាអារម្មណ៍ ក៏គប្បីកាន់យកថា រមែងបាន ព្រោះព្រះអដ្ឋកថាចារ្យពោលទុកហើយ ។

បទថា **វិជាននត្ថាយ** ដើម្បីត្រូវការដឹងច្បាស់ គឺ ដើម្បីត្រូវការដឹងច្បាស់ធម្មារម្មណ៍ និងអារម្មណ៍មានរូបជាដើម ។



បទថា **អាវជ្ជនកិរិយាព្យាកតា** កិរិយា គឺ ការនឹក ជាអព្យាកត បានដល់ ចិត្តដែលជាមនោទ្វារាវជ្ជនៈ ។

បទថា **វិជាននដ្ឋោ** ត្រឹមតែជាការដឹងច្បាស់ សេចក្តីថា ការដឹងច្បាស់អារម្មណ៍ ដោយអំណាចចិត្តស្មុះទៅក្នុងលំដាប់អារម្មណ៍នោះជាអត្ថ មិនមែនដទៃ ។ ព្រោះលោកពោលដល់ជវនចិត្តជាអកុសល និងជវនចិត្តដែលជាមគ្គផល នៃវិបស្សនាទុកផ្សេងហើយក្នុងខាងមុខ ក្នុងទីនេះគួរកាន់យកជវនចិត្តដ៏សេស ។ តែគួរកាន់យកជវនចិត្តដែលឲ្យកើតសេចក្តីរីករាយ អំពីពាក្យមានជាអាទិ៍ថា ឈ្មោះថា **វិញ្ញាណចរិយា** ព្រោះអត្ថថា មិនប្រព្រឹត្តដោយកុសលកម្ម ។ ព្រោះលោកពោលអហេតុកចិត្តទុកហើយក្នុងទ្វារ ៦ គប្បីជ្រាបថា **អហេតុកចិត្ត ១៨** គឺ អាវជ្ជនចិត្ត ២ ទ្វិបញ្ចវិញ្ញាណចិត្ត ១០ សម្បដិច្ឆន្នចិត្ត ២ សន្តីរណចិត្ត ៣ ហសិតុប្បាទចិត្ត ចិត្តឲ្យកើតសេចក្តីរីករាយ ១ ថាជា **វិញ្ញាណចរិយា** ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរដើម្បីនឹងសម្តែងថា ដែលឈ្មោះថា **វិញ្ញាណចរិយា** ព្រោះអត្ថថា ត្រឹមតែដឹងច្បាស់អារម្មណ៍

ទើបពោលបទមានជាអាទិ៍ **នីរាគា ចរតិ** ប្រព្រឹត្តមិនមានរាគៈ សេចក្ដីថា វិញ្ញាណ រមែងមានដល់វវាងការតាំងចុះក្នុងការប្រកប ដោយរាគៈជាដើម និងមានការប្រកបដោយសទ្ធាជាដើម ។ កាល មិនមានការប្រកបទាំងនោះ វិញ្ញាណរមែងតាំងនៅក្នុងទីតាំង របស់ខ្លួន ។ ព្រោះដូច្នោះ ព្រះសារីបុត្តត្ថេរ រមែងសម្ដែងត្រឹម តែកិច្ចរបស់វិញ្ញាណ នៃវិញ្ញាណដែលលោកពោលហើយនោះដោយ ពាក្យមាន **នីរាគា** ជាដើម ។ ឈ្មោះថា **នីរាគា** ព្រោះអត្ថថា ប្រព្រឹត្តមិនមានរាគៈ ។ អាចារ្យពួកខ្លះពោលធ្វើជារស្សៈថា **និរាគា** ។

ម្យ៉ាងទៀត បុគ្គលមានរាគៈដោយតម្រេក ។ មានទោសៈ ដោយការប្រទូសរ៉ាយ ។ មានមោហៈដោយការវង្វេង ។ មាន មានះដោយការប្រកាន់ខ្លួន ។ មានទិដ្ឋិដោយការឃើញវិបរិត ។ ភាពជាអ្នករាយមាយ ឬភាពជាអ្នកមិនស្ងប់ ឈ្មោះថា **ឧទ្ធច្ច** ។ **វិចិកិច្ឆា** មានអត្ថដូចបានពោលហើយ ។

ឈ្មោះថា **អនុស័យ** ព្រោះអត្ថថា ដេកត្រាំនៅក្នុងសន្ដាន ។ ពោលថា **និរនុសយា** លោកពោលថា **នានុសយា** មានសេចក្ដី



ដូចគ្នាថា មិនមានអនុស័យ ។ ក្នុងបទនេះគប្បីជ្រាបថា មិនមាន កិលេសយ៉ាងកណ្ដាល ដែលដល់នូវការគ្របសង្កត់ ។

ពិតហើយ **វិញ្ញាណចរិយា** លោកមិនបានពោលដល់អនុ-ស័យដែលលះបានហើយ ។ ព្រះសារីបុត្តត្ថេរដើម្បីសំដែងដល់ ទស្សនៈក្នុងវវាងដោយបរិយាយថា វិញ្ញាណចរិយាណា មាន ឈ្មោះថា **នីរាគា** ជាដើម ។ វិញ្ញាណចរិយានោះ ជាឈ្មោះរួច ផុតហើយពីរាគៈជាដើម ទើបពោលបទមានជាអាទិ៍ថា **រាគវិប្ប-យុត្តា** ផុតហើយពីរាគៈ ។

ម្យ៉ាងទៀត ដើម្បីឃើញចិត្តដែលផុតចាកកិលេសពួកដទៃ ទៀត ទើបពោលថា **កុសលេហិ កម្មេហិ** ជាដើម ។ កុសល នោះឯងជាកម្មមិនមានទោស ព្រោះមិនមានទោស មានរាគៈជា ដើម ។

ឈ្មោះថា **សុក្កានិ** កម្មស ព្រោះប្រកបដោយហិរិឱត្តប្បៈ ដែលធ្វើភាពជាអ្នកបរិសុទ្ធិ ។

ឈ្មោះថា **សុខុទ្រយានិ** ព្រោះអត្ថថា មានសុខកើតឡើង ព្រោះមានសុខប្រព្រឹត្តទៅ ។

ម្យ៉ាងទៀត ឈ្មោះថា **សុខុទ្រយានិ** ព្រោះអត្ថថា មានសុខកើតឡើង ព្រោះមានសុខជាវិបាក ។ គប្បីប្រកបអកុសលដោយផ្ទុយគ្នា ដូចដែលបានពោលហើយ ។

បទថា **វិញ្ញាតេ ចរតិ** ប្រព្រឹត្តទៅក្នុងអារម្មណ៍ដែលដឹងច្បាស់ហើយ សេចក្ដីថា អារម្មណ៍ដែលដឹងច្បាស់ ដោយការជាក់ច្បាស់ ឈ្មោះថា **វិញ្ញាត** ក្នុងអារម្មណ៍ដែលដឹងច្បាស់ហើយនោះ ។ លោកអធិប្បាយទុកយ៉ាងណា ។ លោកអធិប្បាយទុកថា ឈ្មោះថា **វិញ្ញាណចរិយា** ព្រោះប្រព្រឹត្តក្នុងការដឹងច្បាស់ ព្រោះប្រកបដោយការដឹងជាក់ច្បាស់ ដូចសំពត់ពណ៌ខៀវ ព្រោះប្រកបដោយពណ៌ខៀវ ។

បទថា **វិញ្ញាណស្ស ឯវរូបា ចរិយា ហោតិ** វិញ្ញាណមានការប្រព្រឹត្តបែបនេះ សេចក្ដីថា វិញ្ញាណ មានការប្រកបដូចពោលហើយ ជាវិញ្ញាណមានការប្រព្រឹត្តដូចបានពោលហើយ ។ ម្យ៉ាងទៀត លោកពោលទុកដោយវោហារថា ការប្រព្រឹត្តរបស់វិញ្ញាណ ។ តែមិនមានការប្រព្រឹត្តផ្សេងពីវិញ្ញាណ ។

បទថា **បកតិបរិសុទ្ធមិទំ ចិត្តំ និក្កិលេសដ្ឋេន** ចិត្តនេះ



បរិសុទ្ធិដោយប្រក្រតី ព្រោះអត្ថថា មិនមានកិលេស សេចក្ដីថា ចិត្តមានប្រការដូចពោលហើយនេះ បរិសុទ្ធិដោយប្រក្រតី ព្រោះមិនមានកិលេស មានរាគៈជាដើម ។ ព្រោះដូច្នោះ លោកទើបពោលទុកថា ឈ្មោះថា **វិញ្ញាណចរិយា** ព្រោះអត្ថថា ប្រព្រឹត្តទៅត្រឹមតែដឹងប៉ុណ្ណោះ ។ បាឋៈ ថា **និក្លេសដ្ឋេន** ក៏មាន ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **អញ្ញាណចរិយា** ដូចតទៅនេះ ។

បទថា **មនាបិកេសុ** ក្នុងរូបដែលជាទីស្រឡាញ់ សេចក្ដីថា ឈ្មោះថា **មនាបានិ** ព្រោះអត្ថថា ពេញចិត្ត ។ ឬថាញុំាងចិត្តឲ្យពេញចិត្ត ឲ្យចម្រើន ។ ការញុំាងចិត្ត ឲ្យពេញចិត្តនោះឯង ឈ្មោះថា **មនាបិកានិ** ។ ក្នុងរូបដែលជាទីស្រឡាញ់នោះ ។ រូបទាំងនោះ ជារូបដែលគួរប្រាថ្នា ឬមិនគួរប្រាថ្នាក៏ដោយ ។ ដោយអំណាចនៃស័ត្វ គឺ រូបដែលគួរស្រឡាញ់ ។ ព្រោះរាគៈរមែងកើតក្នុងរូបដែលគួរប្រាថ្នាប៉ុណ្ណោះ ទោសៈក៏រមែងកើតក្នុងរូបដែលមិនគួរប្រាថ្នាប៉ុណ្ណោះ ។

បទថា **រាគស្ស ជវនត្ថាយ** ដើម្បីការស្ទុះទៅនៃរាគៈ គឺប្រព្រឹត្តទៅ ដើម្បីការស្ទុះទៅនៃរាគៈដោយអំណាចនៃសន្តតិ ។

បទថា **អាវជ្ជនកិរិយាព្យាកតា** កិរិយា គឺ ការនឹកជាអព្យាកត សេចក្តីថា មនោធាតុជាកិរិយា គឺ ការនឹកជាអព្យាកតជាការធ្វើទុកក្នុងចិត្តដោយមិនប្រពៃ ក្នុងចក្ខុទ្វារ ។

បទថា **រាគស្ស ជវនា** ការស្ទុះទៅនៃរាគៈ គឺ រាគៈប្រព្រឹត្តទៅ ៧ ដង ។ រាគៈនោះឯងប្រព្រឹត្តទៅរឿយ ៗ ។

បទថា **អញ្ញាណចរិយា** ប្រព្រឹត្តក្នុងអារម្មណ៍ដែលមិនដឹង លោកអធិប្បាយថា រាគៈប្រព្រឹត្តដោយមិនដឹង ព្រោះរាគៈកើតដោយការមិនដឹង ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

បទថា **តទុភយេន អសមបេក្ខនស្មឹ វត្ថុស្មឹ** ក្នុងវត្ថុដែលមិនបានសម្លឹងដោយរាគៈ និងទោសៈ ទាំងពីរនោះ បានដល់ក្នុងវត្ថុ ពោលគឺ រូបារម្មណ៍ វៀរចាកការសម្លឹងដោយអំណាចនៃរាគៈ និងទោសៈ ។

បទថា **មោហស្ស ជវនត្ថាយ** ដើម្បីស្ទុះទៅនៃមោហៈ គឺ ដើម្បីស្ទុះទៅនៃមោហៈ ដោយអំណាចនៃវិចិកិច្ឆា និងឧទ្ធច្ចៈ ។

បទថា **អញ្ញាណចរិយា** គឺ ប្រព្រឹត្តដើម្បីសេចក្តីមិនដឹង មិនមែនដើម្បីយ៉ាងដទៃ ។



បទមានជាអាទិ៍ **វិនិពន្ធស្ស** នៃមានះដែលចងជាបទពោលដល់សភាពនៃមានះជាដើម ។

បណ្តាបទទាំងនោះ បទថា **វិនិពន្ធស្ស** បានដល់ មានះដែលរួបរិតហើយ តាំងនៅដោយការក្រអឺតក្រទម ។

បទថា **បរាមដ្ឋាយ** នៃទិដ្ឋិដែលប្រកាន់ បានដល់ ទិដ្ឋិដែលឈានកន្លងរូបដែលជារបស់មិនទៀងជាដើម ហើយប្រកាន់ភាពជារបស់មិនទៀងជាដើម អំពីចំណែកដទៃ ។

បទថា **វិក្ខេបគតស្ស** នៃឧទ្ធច្ចៈដែលមានការរាយមាយ គឺ ឧទ្ធច្ចៈដែលមានការរាយមាយទៅក្នុងរូបារម្មណ៍ ។

បទថា **អនិដ្ឋាគតាយ** នៃវិចិកិច្ឆាដែលមិនដល់ការព្រមព្រៀង គឺ ដល់ភាពមិនមានការសម្រេចចិត្ត ។

បទថា **ថាមគតស្ស** នៃអនុស័យដល់ភាពជាធម៌មានកម្លាំង ។

បទថា **ធម្មេសុ** គឺ ក្នុងធម៌ទាំងឡាយមានរូបជាដើម ឬជាធម្មារម្មណ៍ ។

ព្រោះរាគៈជាដើម រមែងប្រាកដដោយការមិនដឹង ។ ដូច្នោះ ព្រះសារីបុត្តត្ថេរ កាលនឹងញុំាងការមិនដឹងឲ្យប្លែកចេញទៅ ដោយ

ការប្រកបកិលេស មានរាគៈជាដើម ទើបពោលបទមានជាអាទិ៍ថា **សរាគា ចរតិ** ប្រព្រឹត្តជាមួយរាគៈ ។

ក្នុងបទទាំងនោះ បទថា **សរាគា ចរតិ** គប្បីជ្រាបដល់ការប្រព្រឹត្តដោយការស្ទុះទៅនៃមោហៈ មានៈ ទិដ្ឋិ មានានុស័យ ទិដ្ឋានុស័យ អវិជ្ជានុស័យ ។

បទថា **សទោសា ចរតិ** ប្រព្រឹត្តមានទោសៈ បានដល់ប្រព្រឹត្តដោយការស្ទុះទៅនៃអវិជ្ជានុស័យ គឺ មោហៈ ។

បទថា **សមោហា ចរតិ** ប្រព្រឹត្តជាមួយមោហៈ បានដល់ប្រព្រឹត្តដោយការស្ទុះទៅនៃរាគៈ ទោសៈ មានៈ ទិដ្ឋិ ឧទ្ធច្ចៈ និងវិចិកិច្ឆានុស័យ ។

បទថា **សមានា ចរតិ** ប្រព្រឹត្តជាមួយមានៈ បានដល់ប្រព្រឹត្តដោយការស្ទុះទៅនៃរាគៈ មោហៈ កាមរាគៈ ភវរាគៈ និងអវិជ្ជានុស័យ ។

បទថា **សទិដ្ឋិ ចរតិ** ប្រព្រឹត្តជាមួយទិដ្ឋិ បានដល់ ប្រព្រឹត្តដោយការស្ទុះទៅនៃរាគៈ មោហៈ កាមរាគៈ និងអវិជ្ជានុស័យ ។

បទថា **សឧទ្ធច្ចា ចរតិ សវិចិកិច្ឆា ចរតិ** ប្រព្រឹត្តជាមួយ



ឧទ្ធច្ចៈ ប្រព្រឹត្តជាមួយវិចិកិច្ឆា បានដល់ ប្រព្រឹត្តដោយការស្ទុះទៅនៃមោហៈ គឺ អវិជ្ជានុស័យ ។

បទថា **សានុសយា ចរតិ** ប្រព្រឹត្តជាមួយអនុស័យ សូម្បីក្នុងបទនេះ ក៏គួរធ្វើអនុស័យមួយ ៗ ឲ្យជាមូល តាមន័យដែលពោលហើយនោះឯង ហើយប្រកបការប្រព្រឹត្តជាមួយអនុស័យដោយអំណាចអនុស័យដ៏សេសដែលមានក្នុងចិត្តនោះ ។

បទមានជាអាទិ៍ថា **រាគសម្បយុត្តា** ប្រព្រឹត្តប្រកបដោយរាគៈ ជាពាក្យវេចនៈនៃការប្រព្រឹត្តជាមួយរាគៈជាដើមនោះឯង ។

ពិតណាស់ ការប្រព្រឹត្តនោះឯង រមែងប្រព្រឹត្តទៅជាមួយរាគៈជាដើម ដោយអំណាចការប្រកបគ្នា ព្រោះហេតុនោះទើបមានឈ្មោះច្រើនយ៉ាង មានជាអាទិ៍ថា **សរគា** ប្រកបដោយរាគៈ ការប្រព្រឹត្តប្រកបដោយច្រើនប្រការ មានការកើតរួមគ្នា រលត់ជាមួយគ្នា មានវត្ថុរួមគ្នា និងអារម្មណ៍រួមគ្នា ស្មើដោយរាគៈជាដើម ព្រោះហេតុនោះទើបបាន **ឈ្មោះច្រើនយ៉ាង** មានជាអាទិ៍ថា **រាគសម្បយុត្តា** ។

ម្យ៉ាងទៀត ព្រោះការប្រព្រឹត្តនោះ មិនប្រកបដោយកម្ម

ជាកុសលជាដើម ប្រកបដោយកម្មជាអកុសលជាដើម ។ ដូច្នេះ ព្រះសារីបុត្តត្ថេរ កាលសម្តែង **អញ្ញាណចរិយា** ទើបពោលបទមានជាអាទិ៍ថា **កុសលេហិ កម្មេហិ** ដោយកម្មជាកុសល ។

ក្នុងបទទាំងនោះ បទថា **អញ្ញាតេ** ក្នុងអារម្មណ៍ដែលមិនដឹង គឺ ក្នុងអារម្មណ៍ដែលមិនដឹងតាមសភាវៈដែលពិត ព្រោះមោហៈមានការមិនដឹងជាលក្ខណៈ ។ បទដ៏សេសមានសេចក្តីដូចបានពោលទុកហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងញាណចរិយាដូចតទៅនេះ ។ ព្រោះកិរិយា គឺ អាវជ្ជនៈ **ការនឹកជាអព្យាកត** ជាបច្ច័យក្នុងលំដាប់នៃវិវដ្តនានុបស្សនា ការពិចារណាឃើញការបែកធ្លាយជាដើមមិនមាន ។ ដូច្នោះ ដើម្បីប្រយោជន៍ដល់វិវដ្តនានុបស្សនាជាដើមទាំងនោះ លោកទើបមិនពោលដល់កិរិយា គឺ ការនឹកជាអព្យាកតៈពោលវិវដ្តនានុបស្សនាជាដើម ប៉ុណ្ណោះ ។ ពិតណាស់ ការនឹករមែងមានដើម្បីប្រយោជន៍ដល់អនុលោមញ្ញាណប៉ុណ្ណោះ អំពីនោះ លោកពោលដល់វិវដ្តនានុបស្សនាមគ្គ និងផល ។

ម្យ៉ាងទៀត ក្នុងបទថា **ផលសមាបត្តិ** នេះ ញាណចរិយា



នឹងកើតក្នុងលំដាប់មគ្គក្តី កើតក្នុងលំដាប់ផលក្តី ។ លោកបំណងយកសូម្បីទាំងពីរយ៉ាង ។

ក្នុងបទមានជាអាទិ៍ថា **នីរាគា ចរតិ** ប្រព្រឹត្តមិនមានរាគៈ គប្បីជ្រាបការមិនមានរាគៈជាដើម ដោយការកម្ចាត់រាគៈជាដើម ។ ដោយអត្ថត្រឹមតែការមិនមានរាគៈជាដើម ក្នុងវិញ្ញាណចរិយា ។

បទថា **ញាតេ** ក្នុងអារម្មណ៍ដែលដឹង គឺ ក្នុងអារម្មណ៍ដែលដឹងតាមសេចក្តីពិត ។ ព្រះសារីបុត្តត្ថេរ សម្តែងដល់ការរួបរួមគ្នានៃចរិយា ៣ ដោយបទមានជាអាទិ៍ថា **អញ្ញ វិញ្ញាណចរិយា** ។ ព្រោះវិញ្ញាណចរិយា មានអហេតុកចិត្តកើតឡើងដោយអំណាចត្រឹមតែធ្វើនាទីដែលដឹង ។ អញ្ញាណចរិយាដោយអំណាចអកុសលចិត្តកើតឡើង ១២ ដួង មាននាទីមិនដឹង ។ ញាណចរិយាដោយអំណាច **នៃវិបស្សនា មគ្គ ផល ធ្វើនាទីដឹងដោយវិសេស** ។

គប្បីជ្រាបថា ចរិយាទាំងនេះ មានការរួបរួមគ្នា ។ មានសហេតុកកាមាវចរជាកិរិយា កុសល វៀរវិបស្សនា មានសហេតុកកាមាវចរជាវិបាក ហើយរូបាវចរកុសល អរូបាវចរកុសល

ជាអព្យាកតៈ ផុតពីចរិយា ៣ ។

គប្បីជ្រាបថា បច្ចវេក្ខណញ្ញាណ របស់ព្រះសេក្ខៈ អសេក្ខៈ ជាការពិចារណានិព្វាន មគ្គ ផល ព្រោះលោកសម្តែងញាណចរិយា ដែលជាវិវដ្តនានុបស្សនា មាននិព្វានជាអារម្មណ៍ លោកសង្គ្រោះចូលក្នុងញាណចរិយា ។ ព្រោះចរិយា សូម្បីទាំងនោះ ធ្វើនាទីនៃញាណដោយវិសេស ដោយប្រការដូច្នេះ ។

( ចប់ អដ្ឋកថាចរិយានានត្តញ្ញាណនិទ្ទេស )

## អដ្ឋកថា ភូមិនានត្តញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ ក្នុងភូមិនានត្តញ្ញាណនិទ្ទេស ដូចតទៅនេះ ។ បទថា **ភូមិយោ** ភូមិទាំងឡាយ បានដល់ ភាគឬបរិច្ឆេទ ។ ក្នុងបទថា **កាមាវចរា** នេះបានដល់ **កាម ២ យ៉ាង គឺ កិលេសកាម ១ វត្ថុកាម ១** ។ ឆន្ទរាគៈ ជា កិលេសកាម ។ វដ្តៈប្រព្រឹត្តទៅក្នុងភូមិ ៣ ជាវត្ថុកាម ។ កិលេសកាម ឈ្មោះថា



**កាម** ព្រោះអត្ថថា ឲ្យប្រាថ្នា ។ វត្ថុកាម ឈ្មោះថា **កាម** ព្រោះអត្ថថា ដែលបុគ្គលប្រាថ្នា ។ កាម ២ យ៉ាងនោះ ត្រាច់ទៅក្នុងប្រទេសណា ដោយការប្រព្រឹត្តទៅ ។ ប្រទេសនោះឈ្មោះថា **កាមាវចរ** ព្រោះអត្ថថា ជាទីត្រាច់ទៅនៃកាម ។

ម្យ៉ាងទៀត ប្រទេសនោះជាកាមាវចរ ១១ គឺ អបាយ ៤ មនុស្សលោក ១ និងទេវលោក ៦ ។ ដូចជាបុរសព្រមទាំងឈ្មួញរទេះបានត្រាច់ទៅក្នុងប្រទេសណា ប្រទេសនោះសូម្បីមានសត្វជើង ២ ជើង ៤ ដទៃត្រាច់ទៅ លោកក៏ហៅថា **សសត្ថាវចរ** ជាទីត្រាច់ទៅរបស់ពួកឈ្មួញរទេះ ព្រោះកំណត់ឈ្មួញរទេះទាំងនោះទុកយ៉ាងណា សូម្បីកាលមានរូបាវចរជាដើមពួកដទៃ ត្រាច់ទៅក្នុងប្រទេសនោះ ប្រទេសនោះលោកក៏ហៅថា កាមាវចរនោះឯង ព្រោះកំណត់ រូបាវចរជាដើមទាំងនោះទុកដូច្នោះ ។

លោកពោលថា **កាម** ព្រោះលុបបទក្រោយ ដូចរូបភព លោកពោលថា **រូប** ដូច្នោះ ។ ធម៌ឯណានិមួយ ដែលជាប់ដោយកាមនោះ ឈ្មោះថា **កាមាវចរ** ព្រោះត្រាច់ទៅក្នុងកាមដែរ បានដល់ ប្រទេស ១១ យ៉ាងនេះ ។ សូម្បីថា ធម៌ពួកណាក្នុង

កាមាវចរនេះ ប្រព្រឹត្តទៅក្នុងរូបភព និងអរូបភពក៏ដូច្នោះ សូម្បីធម៌ពួកនោះប្រព្រឹត្តទៅក្នុងទីដទៃ ក៏គប្បីជ្រាបថា ជាកាមាវចរដោយពិត ដូចសេចក្តីថា ដំរីបានឈ្មោះថា **សង្គាមាវចរ** ព្រោះត្រាច់ទៅក្នុងសង្គ្រាម សូម្បីត្រាច់ទៅក្នុងនគរ លោកក៏ពោលថា **សង្គាមាវចរ** ត្រាច់ទៅក្នុងសង្គ្រាមដូចគ្នា ។ សត្វទាំងឡាយត្រាច់ទៅលើគោក ក្នុងទឹក សូម្បីនៅក្នុងកន្លែងមិនមែនគោក និងមិនមែនទឹក លោកពោលថា សត្វគោក សត្វទឹកដូចគ្នា ដូច្នោះ ។

ម្យ៉ាងវិញទៀត ឈ្មោះថា **កាមាវចរ** ព្រោះអត្ថថា កាមត្រាច់ទៅក្នុងធម៌ទាំងឡាយមានប្រការដូចពោលហើយ ទាំងនេះដោយការធ្វើឲ្យជាអារម្មណ៍ ។

ម្យ៉ាងទៀត កាមនោះសូម្បីត្រាច់ទៅក្នុងរូបាវចរធម៌ និងអរូបាវចរធម៌ក៏ពិត ដូច្នោះ គប្បីជ្រាបសេចក្តីប្រៀបធៀបដូច្នេះថា កាលពោលថា ឈ្មោះថា កូនគោ ព្រោះស្រែកយំ ឈ្មោះថា ក្របី ព្រោះដេកលើផែនដី ។ សត្វជំពូកមិនស្រែកយំ ឬជំពូកដេកលើផែនដី ឈ្មោះនោះរមែងមានដល់សត្វទាំងពួង ដូច្នោះ ។

ក្នុងបទនេះលោកសម្ងឹងដល់ភូមិស័ព្ទ ពោលធ្វើធម៌ទាំងនោះ



ទាំងអស់ឲ្យជាពួកដូចគ្នា ទើបធ្វើឲ្យជាឥត្ថីលិង្គថា **កាមាវចរា** ។ រូបភព ជារូបក្នុងបទមានជាដើមថា **រូបាវចរា** ។ ឈ្មោះថា រូបាវចរៈ ព្រោះត្រាច់ទៅក្នុងរូបនោះ ។

អរូបភព ជាអរូប ។ ឈ្មោះថា **អរូបាវចរា** ព្រោះត្រាច់ទៅក្នុងអរូបភូមិនោះ ។

ឈ្មោះថា **បរិយាបន្នា** ព្រោះអត្ថថា រាប់ចូល គឺ ឈានចុះខាងក្នុង ក្នុងតេភូមិកវដ្តនោះ ។ ឈ្មោះថា **អបរិយាបន្នា** ព្រោះអត្ថថា មិនរាប់ចូលក្នុងតេភូមិកវដ្តនោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃភូមិ មានកាមាវចរភូមិជាដើម ដូចតទៅនេះ ។

បទថា **ហេដ្ឋតោ** ខាងក្រោម គឺ ដោយចំណែកខាងក្រោម ។

បទថា **អវីចិនិរយំ** អវីចិនរក ឈ្មោះអវីចិ ព្រោះអត្ថថា រលកនៃអណ្តាតភ្លើង នៃសត្វ នៃវេទនា គឺ គ្មានចន្លោះ ក្នុងរណ្តៅអវីចិនេះ ។ ឈ្មោះថា **និរយ** ព្រោះអត្ថថា ការចម្រើន គឺសេចក្តីសុខ មិនមានក្នុងនរកនោះ ។ ម្យ៉ាងទៀត **និរយ** ព្រោះ

អត្ថថា មិនមានសេចក្តីរីករាយ ។

បទថា **បរិយន្តំ ករិត្វា** ការធ្វើទីបំផុត គឺ ធ្វើនរក ពោល គឺ អវីចិនោះឲ្យជាទីបំផុត ។ បទថា **ឧបរិតោ** ខាងលើ គឺ ដោយចំណែកខាងលើ ។ បទថា **បរនិម្មិតវសវត្តី ទេវេ** ទេវតាជាន់បរនិម្មិតវសវត្តី គឺ ទេវតាដែលមានឈ្មោះយ៉ាងនេះ ព្រោះញុំាងអំណាចឲ្យប្រព្រឹត្តទៅក្នុងកាម ដែលអ្នកដទៃនិម្មិតឲ្យ ។ បទថា **អន្តោ ករិត្វា** ការធ្វើក្នុងខាងក្នុង គឺ ដាក់ទុកក្នុងខាងក្នុង ។ បទថា **យំ ឯតស្មឹ អន្តរេ** ក្នុងចន្លោះនេះ គឺ ក្នុងឱកាសនេះ ។ម្យ៉ាងទៀត បទថា **យំ** ជាលិង្គវិបល្លាស ។

បទថា **ឯត្ថាវចរា** ការត្រាច់ទៅក្នុងឱកាសនេះ សេចក្តីថា ដោយបទនេះ ព្រោះសូម្បីខន្ធជាដើម ពួកដទៃត្រាច់ទៅក្នុងឱកាសនេះ គ្រាខ្លះដោយកើតឡើងត្រង់កន្លែងខ្លះ ដូច្នោះលោកទើបពោលថា **អវចរា** ដើម្បីមិនសង្គ្រោះខន្ធជាដើមទាំងនោះ ។ ដោយហេតុនោះ ខន្ធជាដើមពួកណា ឈានចុះក្នុងឱកាសនេះ ត្រាច់ទៅដោយការកើតក្នុងទីគ្រប់ផ្លូវ គ្រប់កន្លែង និងក្នុងកាលគ្រប់កាល ។ ម្យ៉ាងទៀត ត្រាច់ទៅក្នុងចំណែកខាងក្រោម ដោយ



ការប្រព្រឹត្តទៅ សំដៅដល់កើតខាងក្រោមអវីចិនរក ។ រមែងធ្វើការសង្គ្រោះខន្ធជាដើមទាំងនោះ ។ ព្រោះខន្ធជាដើមទាំងនោះឈ្មោះថា **អវចរា** ព្រោះឈានចុះការត្រាច់ទៅ ។ ហើយត្រាច់ទៅក្នុងចំណែកខាងក្រោម ។

បទថា **ឯត្ថ បរិយាបន្នា** ដែលរាប់ចូលក្នុងឱកាសនេះ ដោយបទនេះ ព្រោះខន្ធជាដើមទាំងនេះ ត្រាច់ទៅក្នុងឱកាសនេះ ឈ្មោះថា រមែងត្រាច់ទៅសូម្បីក្នុងឱកាសដទៃ ។ តែមិនរាប់ចូលក្នុងឱកាសនោះ ។ ដូច្នោះកាលខន្ធជាដើមទាំងនោះ ត្រាច់ទៅសូម្បីក្នុងទីដទៃ រមែងជាចំណែកដែលលោកកំណត់យក ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរកាលនឹងសម្តែងធម៌រាប់ចូលក្នុងឱកាសនេះ ដោយភាពជាបច្ច័យនៃការសូន្យចាកក្រុម និងដោយភាពជារបស់ពិត ទើបពោលថា **ខន្ធធាតុអាយតនា** ជាអាទិ៍ ។

បទថា **ព្រហ្មលោកំ** ព្រហ្មលោក គឺ ឋានរបស់ព្រហ្មដែលបានដល់ភូមិនៃបឋមឈាន ។ បទថា **អកនិដ្ឋេ** ទេពជាន់អកនិដ្ឋៈ គឺ មិនមែនកនិដ្ឋៈ ព្រោះអត្ថថា ខ្ពង់ខ្ពស់ ។

បទថា **សមាបន្នស្ស** គឺ ចូលសមាបត្តិ ។ ដោយបទនេះ

លោកពោលដល់កុសលឈាន ។

បទថា **ឧប្បន្នស្ស** គឺ កើតក្នុងព្រហ្មលោកដោយអំណាចវិបាក ។ ដោយបទនេះ លោកពោលដល់វិបាកឈាន ។

បទថា **ទិដ្ឋធម្មសុខវិហារិស្ស** របស់លោកអ្នកមានធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន បានដល់ ធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន គឺ ក្នុងអត្តភាពដែលប្រច័ក្ស ឈ្មោះថា **ទិដ្ឋធម្មសុខវិហារោ** ។ ឈ្មោះថា **ទិដ្ឋធម្មសុខវិហារី** ព្រោះអត្ថថា មានទិដ្ឋធម្មសុខវិហារធម៌នោះ បានដល់ ព្រះអរហន្ត ។ របស់លោកអ្នកមានធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ននោះ ។ ដោយបទនោះ លោកពោលដល់ **កិរិយជ្ឈាន** ។

បទថា **ចេតសិកា** បានដល់ ធម៌ដែលកើតក្នុងចិត្ត ។ អធិប្បាយថា ធម៌សម្បយុត្តដោយចិត្ត ។ បទថា **អាកាសានញ្ចាយតនូបគេ** បានដល់ ទេវតាអ្នកចូលដល់អាកាសានញ្ចាយតនភព ។ សូម្បីក្នុងបទទីពីរ ក៏មានន័យនេះដូចគ្នា ។

បទថា **មគ្គា** បានដល់ អរិយមគ្គ ៤ ។ បទថា **មគ្គផលានិ** បានដល់ ផលនៃអរិយមគ្គ ៤ ។



បទថា **អសង្ខតា ច ធាតុ** អសង្ខតធាតុ គឺ និព្វានធាតុដែលបច្ច័យមិនបានតាក់តែង ។

បទថា **អបរាបិ ចតស្សោ ភូមិយោ** ភូមិ ៤ ប្រការទៀត គប្បីជ្រាបដោយអំណាចចតុក្កៈមួយ ៗ ។

បទថា **ចត្តារោ សតិប្បដ្ឋានា** សតិប្បដ្ឋាន ៤ បានដល់ កាយានុបស្សនាសតិប្បដ្ឋាន វេទនានុបស្សនាសតិប្បដ្ឋាន ចិត្តានុបស្សនាសតិប្បដ្ឋាន ធម្មានុបស្សនាសតិប្បដ្ឋាន ។

មានអធិប្បាយដូច្នេះ ឈ្មោះថា **បដ្ឋានំ** ព្រោះអត្ថថា តាំងទុក សេចក្ដីថា ចូលទៅតាំងទុក គឺ ប្រព្រឹត្តទៅរឿយ ៗ ។ សតិនោះឯងតាំងទុក ឈ្មោះថា **សតិប្បដ្ឋាន** ។ មយ៉ាងទៀត ឈ្មោះថា **សតិ** ព្រោះអត្ថថា ការរលឹក ។ ឈ្មោះថា **បដ្ឋានំ** ព្រោះអត្ថថា ចូលទៅតាំងទុក ។ សតិនោះផង ជាបដ្ឋាន គឺ ការចូលទៅតាំងទុកផង ឈ្មោះថា **សតិប្បដ្ឋាន** ។ ឈ្មោះថា **សតិប្បដ្ឋាន** ទាំងឡាយ ព្រោះសតិទាំងនោះច្រើនដោយអារម្មណ៍ ។

បទថា **ចត្តារោ សម្មប្បធានា** សម្មប្បធាន ៤ គឺ ធ្វើសេចក្ដីព្យាយាមមិនឲ្យអកុសល ដែលនៅមិនទាន់កើតមិនឲ្យកើត

ឡើង ១ ធ្វើសេចក្តីព្យាយាមលះអកុសល ដែលកើតឡើង ១ ធ្វើសេចក្តីព្យាយាមឲ្យកុសលដែលនៅមិនទាន់កើត ឲ្យកើតឡើង ១ ធ្វើសេចក្តីព្យាយាម គឺ ការតាំងនៅកុសលដែលកើតឡើង ១ ។ ឈ្មោះថា **បធាន** ព្រោះអត្ថថា ជាហេតុតាំងទុក គឺ ព្យាយាម ។ បទនេះជាឈ្មោះ នៃសេចក្តីព្យាយាម ។

បទថា **សម្មប្បធានំ** គឺ ព្យាយាមមិនវិបរិត ព្យាយាមតាមហេតុ ព្យាយាមដោយឧបាយ ព្យាយាមដោយប្រពៃ ។ សេចក្តីព្យាយាមតែម្យ៉ាងប៉ុណ្ណោះ លោកធ្វើជា ៤ ចំណែក ដោយអំណាចនៃកិច្ច ទើបពោលថា **សម្មប្បធានា** ។ បទថា **ចត្តារោ ឥទ្ធិបាទា** ឥទ្ធិបាទ ៤ បានដល់ ឆន្ទៈ វីរិយៈ ចិត្តៈ វីមំសា ។ សេចក្តីនៃបទនោះ បានពោលទុកហើយ ។

បទថា **ចត្តារិ ឈានានិ** ឈាន ៤ បានដល់ បឋមជ្ឈានមានអង្គ ៥ គឺ វិតក្ក វិចារ បីតិ សុខ ឯកគ្គតា ។ ទុតិយជ្ឈានមានអង្គ ៣ គឺ បីតិ សុខ ឯកគ្គតា ។ តតិយជ្ឈានមានអង្គ ២ គឺ សុខ ឯកគ្គតា ។ ចតុត្ថជ្ឈានមានអង្គ ២ គឺ ឧបេក្ខា ឯកគ្គតា ។ អង្គទាំងនេះលោកពោលថា ឈាន ព្រោះ



អត្ថថា ចូលទៅសម្លឹងអារម្មណ៍ ។

បទថា **ចតស្សោ អប្បមញ្ញាយោ** អប្បមញ្ញា ៤ បានដល់ មេត្តា ករុណា មុទិតា ឧបេក្ខា ។ ឈ្មោះថា **អប្បមញ្ញា** ដោយការផ្សាយទៅមិនមានប្រមាណ ។ ពិតណាស់ អប្បមញ្ញាទាំងនោះ រមែងផ្សាយទៅកាន់សត្វទាំងឡាយរកប្រមាណមិនបាន ដោយអំណាចនៃអារម្មណ៍ ។ ឬថា ផ្សាយទៅដោយអំណាចការផ្សាយទៅ ដោយមិនមានសល់សូម្បីសត្វមួយ ព្រោះហេតុនោះ លោកទើបពោលថា **អប្បមញ្ញាយោ** ដោយអំណាចការផ្សាយទៅមិនមានប្រមាណ ។

បទថា **ចតស្សោ អរូបសមាបត្តិយោ** អរូបសមាបត្តិ ៤ បានដល់ អាកាសានញ្ចាយតនសមាបត្តិ វិញ្ញាណញ្ចាយតនសមាបត្តិ អាកិញ្ចញ្ញាយតនសមាបត្តិ នេវសញ្ញានាសញ្ញាយតនសមាបត្តិ ។

បទថា **ចតស្សោ បដិសម្ភិទា** បដិសម្ភិទា ៤ មានសេចក្តីដូចបានពោលទុកហើយ ។

បទថា **ចតស្សោ បដិបទា** បដិបទា ៤ បានដល់ បដិបទា

៤ ដែលព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ទុកថា ៖

**ទុក្ខាបដិបទា ទន្ធាភិញ្ញា** បដិបត្តិលំបាក ត្រាស់ដឹងយឺតយូរ ។

**ទុក្ខាបដិបទា ខិប្បាភិញ្ញា** បដិបត្តិលំបាក ត្រាស់ដឹងឆាប់រហ័ស ។

**សុខាបដិបទា ទន្ធាភិញ្ញា** បដិបត្តិងាយស្រួល ត្រាស់ដឹងយឺតយូរ ។

**សុខាបដិបទា ខិប្បាភិញ្ញា** បដិបត្តិងាយស្រួល ត្រាស់ដឹងឆាប់រហ័ស ។

បទថា **ចត្តារិ អារម្មណានិ** អារម្មណ៍ ៤ បានដល់ អារម្មណ៍ ៤ ដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា ៖

**បរិត្តំ បរិត្តារម្មណំ** មានកម្លាំងតិច មានអារម្មណ៍តូច ១ ។

**បរិត្តំ អប្បមាណារម្មណំ** មានកម្លាំងតិច មានអារម្មណ៍ធំ ១ ។

**អប្បមាណំ បរិត្តារម្មណំ** មានកម្លាំងច្រើន មានអារម្មណ៍តូច ១ ។

**អប្បមាណំ អប្បមាណារម្មណំ** មានកម្លាំងច្រើន មានអារម្មណ៍



ធំ ១ ។

គប្បីជ្រាបថា លោកពោលដល់ឈានមានអារម្មណ៍ ដោយអារម្មណ៍ទាំងឡាយ ដោយមិនតាំងចិត្តទៀនទាត់ កំណត់អារម្មណ៍ មានកសិណជាដើម ។

បទថា **ចត្តារោ អរិយវំសា** អរិយវង្ស ៤ សេចក្តីថា ព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធជាម្ចាស់ សាវ័កនៃព្រះពុទ្ធជាម្ចាស់ លោកពោលថា ជាព្រះអរិយៈ ។ វង្ស ខ្សែ បវេណី របស់ព្រះអរិយៈទាំងនោះ ឈ្មោះថា វង្សរបស់ព្រះអរិយៈ ។ វង្សរបស់ព្រះអរិយៈទាំងនោះតើដូចម្តេច ? ធម៌ ៤ ទាំងនេះ គឺ សន្តោសដោយចីវរ ១ , សន្តោសដោយបិណ្ឌបាត ១ , សន្តោសដោយសេនាសនៈ ១ , ត្រេកអរក្នុងភាវនា ១ ។ កាលពោលដល់សន្តោសដោយបិណ្ឌបាត លោកពោលដល់ សន្តោសដោយគិលានបច្ច័យ ព្រោះភិក្ខុណាសន្តោសក្នុងបិណ្ឌបាត ។ ភិក្ខុនោះនឹងមិនសន្តោសដោយគិលានបច្ច័យបាន យ៉ាងណា ។

បទថា **ចត្តារិ សង្គហវត្ថូនិ** សង្គហវត្ថុ ៤ បានដល់ សង្គហវត្ថុ ៤ ទាំងនេះ គឺ ទាន ១ បេយ្យវជ្ជៈ ១ អត្ថចរិយា ១

សមានត្តតា ១ ។ ជាហេតុសង្គ្រោះជន ៤ ទាំងនេះ ។

បទថា **ទានំ** បានដល់ ការឲ្យតាមសមគួរ ។

បទថា **បេយ្យវជ្ជំ** បានដល់ និយាយគួរស្រឡាញ់ តាមសមគួរ ។

បទថា **អត្ថចរិយា** បានដល់ ការធ្វើសេចក្តីចម្រើន ដោយធ្វើកិច្ចដែលគួរធ្វើក្នុងទីនោះ ៗ និងដោយការទូន្មាន ក្នុងវត្ថុដែលគួរធ្វើ និងមិនគួរធ្វើ ។

បទថា **សមានត្តតា** ភាពជាអ្នកមានខ្លួនស្មើ គឺ មានភាពស្មើមិនប្រកាន់ខ្លួន ។ អធិប្បាយថា មានប្រមាណខ្លួន គិតប្រមាណខ្លួន ។ ឈ្មោះថា **សមានត្តោ** ព្រោះអត្ថថា មានខ្លួនស្មើបុគ្គលដទៃ ។ ភាពជាអ្នកមានខ្លួនស្មើ ឈ្មោះថា **សមានត្តតា** ។ អធិប្បាយថា ការគិតប្រមាណខ្លួនថា អ្នកនេះថោកទាបជាងយើង អ្នកនេះស្មើយើង ។ អ្នកនេះល្អជាងយើង ហើយប្រព្រឹត្ត គឺធ្វើតាមសមគួរដល់បុគ្គលនោះ ។ អាចារ្យពួកខ្លះពោលថា ភាពជាអ្នករួមសុខរួមទុក្ខ ឈ្មោះថា **សមានត្តតា** ។

ក្នុងបទថា **ចត្តារិ ចក្កានិ** ចក្ក ៤ នេះ បានដល់ ឈ្មោះថា



ចក្ក មាន ៥ យ៉ាង គឺ ចក្កធ្វើដោយឈើ ១ ចក្កធ្វើដោយកែវ ១ ចក្ក គឺ ធម៌ ១ ចក្ក គឺ ឥរិយាបថ ១ ចក្ក គឺ សម្បត្តិ ១ ។

ចក្កធ្វើដោយឈើ ក្នុងបទថា ខ្ញុំម្ចាស់ទេវៈ ចក្កនោះសម្រេចហើយ ៦ ខែ ខ្វះ ៦ យប់ ។ ចក្កធ្វើដោយកែវក្នុង បទថា **កំណត់យកដោយចក្ករិលទៅ** ។ ចក្ក គឺ ធម៌ក្នុងបទថា **ចក្កដែលតថាគតឲ្យប្រព្រឹត្តទៅហើយ** ។ ចក្ក គឺ ឥរិយាបថ ក្នុងបទថា **សរីរយន្តមានចក្ក ៤ មានទ្វារ ៩** ។

ពាក្យថា ម្នាលភិក្ខុទាំងឡាយចក្ក ៤ យ៉ាងទាំងនេះ , ចក្ក ៤ រមែងប្រព្រឹត្តទៅដល់ទេវតា និងមនុស្សទាំងឡាយ អ្នកមកប្រជុំព្រមគ្នាហើយ , ចក្ក ៤ យ៉ាង គឺអ្វីខ្លះ ? គឺ **បដិរូប-ទេសវាស ១ សប្បុរិសាបស្សយ ១ អត្តសម្មាបណិធិ ១ បុព្វេកតបុញ្ញតា ១** នេះឈ្មោះថា ចក្ក គឺ សម្បត្តិ ។ ក្នុងទីនេះលោកបំណងយកចក្ក គឺ សម្បត្តិនោះឯង ។

ក្នុងបទទាំងនោះបទថា **បដិរូបទេសវាសោ** នៅក្នុងប្រទេសដ៏សមគួរ បានដល់ បរិស័ទ ៤ ប្រាកដក្នុងប្រទេសណា ។ នៅក្នុងប្រទេសដ៏សមគួរបែបនោះ ។

បទថា **សប្បុរិសាបស្សយោ** អាស្រ័យសប្បុរស បានដល់ ពឹងអាស្រ័យ សេពគប់សប្បុរស មានព្រះពុទ្ធជាម្ចាស់ជាដើម ។

បទថា **អត្តសម្មាបណិធិ** ដម្កល់ខ្លួនទុកប្រពៃ ការតាំងខ្លួនទុកប្រពៃ ។ ប្រសិនបើគ្រាមុនជាអ្នកមិនមានសទ្ធា ជាដើម លះបង់ការមិនមានសទ្ធាជាដើមនោះ ហើយតាំងនៅក្នុងសទ្ធាជាដើម ។

បទថា **បុព្វេ ច កតបុញ្ញតា** ភាពជាអ្នកធ្វើបុណ្យទុកក្នុងកាលមុន បានដល់ ភាពជាអ្នកសន្សំកុសលទុកក្នុងកាលមុន ។ នេះជាការកំណត់ក្នុងបទនេះ ។ កុសលកម្ម ដែលធ្វើដោយចិត្តសម្បយុត្តដោយញាណកុសលនោះឯង រមែងនាំបុរសនោះចូលទៅក្នុងប្រទេសដ៏សមគួរ ឲ្យសេពគប់សប្បុរស បុគ្គលនោះឯង រមែងតម្កល់ខ្លួនទុកប្រពៃ ។

បទថា **ចត្តារិ ធម្មបទានិ** ធម្មបទ ៤ បានដល់ ចំណែកនៃធម៌ ៤ ។ ធម្មបទ ៤ គឺអ្វីខ្លះ ? គឺ អនភិជ្ឈា ១ អព្យាបាទ ១ សម្មាសតិ ១ សម្មាសមាធិ ១ ។

ការមិនលោភក្តី ការសម្រេចឈាន វិបស្សនា មគ្គ ផល



និព្វាន ដោយអំណាចនៃអនភិជ្ឈាក្តី ឈ្មោះថា ធម្មបទ គឺ **អនភិជ្ឈា** ។

កាមិនក្រោធក្តី ការសម្រេចឈានជាដើម ដោយអំណាចមេត្តាជាគោលក្តី ឈ្មោះថា ធម្មបទ គឺ **អព្យាបាទ** ។

ការតាំងសតិទុកប្រពៃក្តី ការសម្រេចឈានជាដើមដោយសតិជាប្រធានក្តី ឈ្មោះថា ធម្មបទ គឺ **សម្មាសតិ** ។

សមាបត្តិ ៨ ក្តី ការសម្រេចឈានជាដើម ដោយសមាបត្តិ ៨ ជាប្រធានក្តី ឈ្មោះថា ធម្មបទ គឺ **សម្មាសមាធិ** ។

ម្យ៉ាងទៀត ការសម្រេចឈានជាដើម ដោយអំណាចអសុក ១០ ឈ្មោះថា ធម្មបទ គឺ **អនភិជ្ឈា** ។ សម្រេចឈានដោយអំណាចព្រហ្មវិហារ ៤ ឈ្មោះថា ធម្មបទ គឺ អព្យាបាទ ។ សម្រេចឈាន ដោយអំណាចអនុស្សតិ ១០ និងអាហារេបដិកូលសញ្ញា ឈ្មោះថា ធម្មបទ គឺ **សម្មាសតិ** ។ សម្រេចឈានដោយអំណាចកសិណ ១០ និងអានាបានស្សតិ ឈ្មោះថា ធម្មបទ គឺ **សម្មាសមាធិ** ។ ដោយប្រការដូច្នេះ ។

បទថា **ឥមា ចតស្សោ ភូមិយោ** ភូមិ ៤ ទាំងនេះ គប្បី

ប្រកបបទមួយ ៗ ដោយអំណាចចតុក្កៈនោះឯង ។

( ចប់ អដ្ឋកថាភូមិនានត្តញ្ញាណនិទ្ទេស )

## អដ្ឋកថា ធម្មនានត្តញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ ក្នុងធម្មទានត្តញ្ញាណនិទ្ទេស ដូចតទៅនេះ ។ បទថា **កម្មបថេ** ឈ្មោះថា **កម្មបថ** ព្រោះអត្ថថា កម្មទាំងនោះជាផ្លូវដើម្បីទៅកាន់អបាយ ។ ដែលជាកម្មបថទាំងនោះ ។

កុសលកម្មបថ ១០ បានដល់ **កាយសុចរិត ៣** គឺ វៀរចាកការសម្លាប់សត្វ ១ វៀរចាកការលួចទ្រព្យគេ ១ វៀរចាកការប្រព្រឹត្តខុសក្នុងកាម ១ ។ **វចីសុចរិត ៤** គឺ វៀរចាកការនិយាយកុហក ១ វៀរចាកការនិយាយញុះញង់ ១ វៀរចាកការនិយាយគ្រោតគ្រាត ១ វៀរចាកការនិយាយពាក្យឥតប្រយោជន៍ ១ ។ **មនោសុចរិត ៣** គឺ មិនសម្លឹងរំពៃចង់បានរបស់គេ ១ មិនព្យាបាទ ១ ឃើញត្រូវ ១ ។

អកុសលកម្មបថ ១០ បានដល់ **កាយទុច្ចរិត ៣** គឺ



សម្លាប់សត្វ ១ លួចទ្រព្យគេ ១ ប្រព្រឹត្តខុសក្នុងកាម ១ ។ **វចីទុច្ចរិត ៤** គឺ និយាយកុហក ១ និយាយចាក់ដោត ១ និយាយសម្ដីគ្រោតគ្រាត ១ និយាយពាក្យឥតប្រយោជន៍ ១ ។ **មនោ-ទុច្ចរិត ៣** គឺ សំឡឹងរំពៃចង់បានរបស់គេ ១ ព្យាបាទគេ ១ ឃើញខុស ១ ។

ម្យ៉ាងទៀត សូម្បីទាំងកុសល និងអកុសល លោកក៏ពោលថា **កម្មបថ** ព្រោះឲ្យកើតបដិសន្ធិ ។ សល់អំពីការដែលពោលហើយ លោកមិនពោលថា កម្មបថ ព្រោះមិនមានចំណែកក្នុងការឲ្យបដិសន្ធិ ។ គប្បីជ្រាបថា សូម្បីកុសល និងអកុសលដ៏សេស លោកក៏កាន់យកសំដៅដល់កុសល និងអកុសលដែលគ្រោតគ្រាត ។

បទថា **រូបំ** បានដល់ រូប ២៨ ដោយប្រភេទជាភូតរូប និងឧបាទាយរូប ។

បទថា **វិបាកំ** បានដល់ វិបាក ២៣ ដោយអំណាចនៃកាមាវចរកុសលវិបាក ១៦ ។ អកុសលវិបាក ៧ ។

បទថា **កិរិយំ** បានដល់ កាមាវចរកិរិយា ១១ ដោយអំណាច

នៃបរិត្តកិរិយា ៣ ។ មហាកិរិយា ៨ ។ ឈ្មោះថា កិរិយា ព្រោះមានត្រឹមតែកិរិយាដោយមិនមានវិបាក ។ ដោយហេតុត្រឹមប៉ុណ្ណេះ លោកពោលកាមាវចរដោយអំណាចនៃរូបជាអព្យាក្រិត វិបាកជាអព្យាក្រិត កិរិយាជាអព្យាក្រិត ។

បទថា **ឥធដ្ឋស្ស** បានដល់ របស់បុគ្គលដែលរស់នៅក្នុងលោកនេះ ។ ដោយច្រើន លោកពោលដោយអំណាចនៃមនុស្សលោក ព្រោះមានឈានភាវនាក្នុងមនុស្សលោក ។ ម្យ៉ាងទៀត សូម្បីក្នុងទេវលោកកន្លែងខ្លះ គ្រាខ្លះក៏បានឈាន ។ សូម្បីក្នុងព្រហ្មលោក រូបព្រហ្មទាំងឡាយក៏ធ្វើបាន ដោយអំណាចអ្នកកើតក្នុងព្រហ្មលោកនោះ អ្នកកើតក្នុងចំណែកខាងក្រោម និងអ្នកកើតក្នុងខាងលើ ។ ប៉ុន្តែក្នុងជាន់សុទ្ធាវាស និងអរូបាវចរ មិនមានអ្នកកើតក្នុងខាងក្រោម ។ ក្នុងរូបាវចរ និងអរូបាវចរ អ្នកមិនចម្រើនឈាន កើតក្នុងខាងក្រោម រមែងកើតក្នុងកាមាវចរសុគតិប៉ុណ្ណោះ មិនកើតក្នុងទុគតិ ។

បទថា **តត្រូបបន្នស្ស** នៃបុគ្គលអ្នកកើតក្នុងព្រហ្មលោកនោះ បានដល់ វិបាកឈាន ៤ ប្រព្រឹត្តទៅដោយអំណាចបដិសន្ធិ



ភវង្គ និងចុតិ របស់បុគ្គលអ្នកកើតក្នុងព្រហ្មលោក ដោយអំណាចនៃវិបាក ។ លោកមិនបានពោលដល់កិរិយា ដែលជាអព្យាក្រិតក្នុងឈានសមាបត្តិដែលជារូបាវចរ និងអរូបាវចរ ។ សូម្បីលោកមិនបានពោលទុកក៏ពិត គប្បីជ្រាបថា កាលលោកពោលដល់កុសល ក៏ជាការពោលដល់កិរិយាជាអព្យាកតៈទុកផង ព្រោះប្រព្រឹត្តទៅស្មើគ្នាដោយកុសលមែនពិត ។ គប្បីជ្រាបក្នុងមាតិកានេះក្នុងបដ្ឋាន លោកសង្គ្រោះកិរិយាជវន ដោយស័ព្ទកុសលជវនថា កាលកុសលអកុសលរលត់ វិបាករមែងកើតឡើង ព្រោះកុសលអកុសលនោះជាអារម្មណ៍ ។

បទថា **សាមញ្ញផលានិ** បានដល់សាមញ្ញផល ៤ ។ ដោយបទនេះ លោកពោលដល់លោកុត្តរវិបាកជាអព្យាកត ។ បទថា **និព្វានំ** បានដល់ និព្វាន ជាអព្យាក្រិត ។

បទថា **បាមុជ្ជមូលកា** គឺ មានបាមោជ្ជៈជាខាងដើម ។ ព្រោះប្រកបដោយសេចក្តីរីករាយ ។

ក្នុងបទថា **អនិច្ចតោ មនសិករោតោ បាមុជ្ជំ ជាយតិ** នេះ មានសេចក្តីថា កាលធ្វើទុកក្នុងចិត្តដោយប្រពៃ រមែងកើតបា-

មោជ្ជៈ ។ កាលធ្វើទុកក្នុងចិត្តដោយមិនប្រពៃ រមែងមិនកើតបាមោជ្ជៈ ។ ពិតណាស់ កាលធ្វើទុកក្នុងចិត្តដោយមិនប្រពៃ កុសលនឹងមិនកើត ។ មិនចាំបាច់និយាយដល់វិបស្សនាឡើយ ។ ប្រសិនបើសួរថា ព្រោះហេតុណា លោកទើបពោលទុកដោយសរុប ។ ឆ្លើយថា ដើម្បីសម្តែងសេចក្តីដល់បាមោជ្ជៈមានកម្លាំងខ្លាំង ។ ព្រោះកាលមិនមានបាមោជ្ជៈ ការមិនពេញចិត្ត ការត្រេកអរក៏នឹងកើតឡើង ក្នុងសេនាសនៈដ៏ស្ងប់ និងក្នុងធម៌ដែលជាអធិកុសល ។ កាលមានយ៉ាងនេះ រមែងឈានដល់ភាវនាពិត ។

ម្យ៉ាងទៀត កាលមានសេចក្តីរីករាយ ភាវនារមែងដល់ការពេញប្រៀប ព្រោះមិនមានការត្រេកអរ ។ ដើម្បីសម្តែងដល់ភាវនាដែលមានឧបការៈ ដោយភាពជាខាងដើមនៃការធ្វើទុកក្នុងចិត្តដោយប្រពៃ នឹងពោលដល់ពួក ៩ ខាងមុខ ។

សេចក្តីរីករាយ ព្រោះជាបច្ច័យនៃវិបស្សនា រមែងកើតដល់អ្នកចម្រើនវិបស្សនា ដោយបាលីថា ៖

**យតោ យតោ សម្មសតិ ខន្ធានំ ឧទយព្វយំ**
**លភតី បីតិបាមោជ្ជំ អមតំ តំ វិជានតំ ។**



កាលណាពិចារណាឃើញការកើត
និងការរលត់នៃខន្ធទាំងឡាយ កាល
នោះ រមែងបានបីតិ និងបាមោជ្ជៈ
នោះ ជាអមតៈរបស់អ្នកដឹងច្បាស់
ទាំងឡាយ ។

តែក្នុងទីនេះគប្បីកាន់យកសេចក្តីរីករាយ ព្រោះការពិចារណាកលាបៈជាបច្ច័យ ។ ភាពជាអ្នកដល់នូវសេចក្តីរីករាយឈ្មោះថា **បាមុជ្ជំ** គឺ បីតិមានកម្លាំងខ្សោយ ។ គប្បីឃើញថា ប អក្សរ ចុះក្នុងអត្ថនៃអាទិកម្ម ។

បទថា **បមុទិតស្ស** ដល់ភាវៈបាមោជ្ជៈ បានដល់ សេចក្តីរីករាយ គឺ ត្រេកអរ ដោយសេចក្តីរីករាយនោះ ។ បាឋៈថា **បមោទិតស្ស** ខ្លះ , សេចក្តីដូចគ្នា ។

បទថា **បីតិ** បានដល់ បីតិមានកម្លាំង ។ បទថា **បីតិមនស្ស** ចិត្តមានបីតិ គឺ ចិត្តប្រកបដោយបីតិ ។ គប្បីឃើញថា លុប **យុត្ត** ស័ព្ទចេញ ដូចបទថា **អស្សរថោ** រថទឹមដោយសេះ ។ បទថា **កាយោ** បានដល់ នាមកាយ ឬរូបកាយ ។ បទថា

**បស្សម្ភតិ** រមែងស្ងប់ គឺ ជាអ្នកស្ងប់សេចក្ដីខ្វល់ខ្វាយ ។ បទថា **បស្សទ្ធកាយោ** កាយស្ងប់ គឺ កាយសប្បាយ ព្រោះប្រកបដោយសេចក្ដីស្ងប់ទាំងពីរ ។

បទថា **សុខំ វេទេតិ** រមែងបានសោយសុខ គឺ រមែងបានសោយចេតសិកសុខ ឬកាយិកសុខផង ។ បទថា **សុខិនោ** របស់អ្នកមានសេចក្ដីសុខ គឺ ព្រមព្រៀងដោយសេចក្ដីសុខ ។ បទថា **ចិត្តំ សមាធិយតិ** ចិត្តរមែង តាំងមាំ គឺ ចិត្តរមែងតាំងមាំស្មើ , ចិត្តមានអារម្មណ៍តែមួយ ។

បទថា **សមាហិតេ ចិត្តេ** កាលចិត្តតាំងមាំ ជាសត្តមីវិភត្តចុះក្នុងភាវលក្ខណៈដោយភាវៈ ។ រមែងកំណត់ដឹងតាមសេចក្ដីពិត ដោយការតាំងមាំរបស់ចិត្ត ។

បទថា **យថាភូតំ បជានាតិ** រមែងដឹងតាមកសេចក្ដីពិត គឺ ដឹងសង្ខារតាមសេចក្ដីពិត ដោយអំណាចនៃឧទយព្វយញ្ញាណជាដើម ។

បទថា **បស្សតិ** រមែងឃើញ គឺ ឃើញដោយបញ្ញាចក្ខុធ្វើវត្ថុដែលពាល់ត្រូវនោះ ដូចឃើញដោយភ្នែក ។ បទថា **និព្វិន្ទតិ** រមែងនឿយណាយ គឺ នឿយណាយក្នុងសង្ខារទាំងឡាយ ព្រោះប្រកបដោយវិបស្សនាញាណ ៩ យ៉ាង ។

បទថា **និព្វិន្ទំ វិរជ្ជតិ** កាលនឿយណាយ រមែងលះបង់ការកំណត់ គឺ កាលញ៉ាំងវិបស្សនាឲ្យកើតឡើងដល់ថ្នាក់កំពូលជាការលះបង់ពីសង្ខារដែលប្រកបដោយមគ្គញ្ញាណ ។

បទថា **វិរាគា វិមុច្ចតិ** ព្រោះប្រាសចាកតម្រេក ចិត្តរមែងរួចផុត គឺ ចិត្តរមែងរួចផុត ដោយបង្អោនទៅក្នុងនិព្វាន គឺផលវិមុត្តិ ព្រោះមគ្គជាហេតុ ដែលបានដល់ វិរាគៈ ។ តែក្នុងគម្ពីរខ្លះក្នុងវារៈនេះ លោកសរសេរន័យក្នុងសច្ចៈទុកមានជាដើមថា ដឹងតាមសេចក្ដីពិតថា នេះទុក្ខ ដោយចិត្តតាំងមាំ ។ ម្យ៉ាងទៀត ក្នុងគម្ពីរខ្លះលោកសរសេរទុកន័យក្នុងសច្ចៈនោះ ដោយន័យមានជាដើមថា រមែងធ្វើទុកក្នុងចិត្តដោយប្រពៃថា នេះទុក្ខ ។ សូម្បីក្នុង ២ វារៈនោះ ក៏ផ្សេងគ្នាដោយព្យញ្ជនៈប៉ុណ្ណោះ ដោយអត្ថមិនផ្សេងគ្នា ។ ព្រោះបទថា **និព្វិន្ទំ វិរជ្ជតិ** កាលមគ្គញាណសម្រេច ព្រោះពោលដល់មគ្គញាណ ដែលសម្រេចកិច្ច ព្រោះត្រាស់ដឹងអរិយសច្ចៈ ៤ ផង ។ ព្រោះដូច្នោះ សូម្បីវារៈដែល

លោកពោលដោយន័យរបស់សច្ចៈ ៤ ក៏មិនបានផ្សេងគ្នាដោយអត្ថ ដោយវារៈនេះ ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ កាលនឹងឲ្យអារម្មណ៍ផ្សេងគ្នា ព្រោះពោលដល់អារម្មណ៍មិនផ្សេងគ្នា ដោយបទមានជាដើមថា **អនិច្ចតោ** ទើបពោលបទមានជាអាទិ៍ថា **រូបំ អនិច្ចតោ មនសិក-រោតិ** រមែងមនសិការក្នុងរូប ដោយភាពជារបស់មិនទៀង ។

បទថា **យោនិសោមនសិការមូលកា** គឺ ធម៌មានយោនិ-សោមនសិការជាខាងដើម ជាគោល ។ ព្រោះបាមោជ្ជៈជាដើម លះយោនិសោមនសិការចេញហើយក៏មិនគ្រប់ ៩ ។

បទថា **សមាហិតេន ចិត្តេន** ដោយចិត្តតាំងមាំ គឺ ដោយចិត្តជាហេតុ ។

បទថា **យថាភូតំ បជានាតិ** រមែងដឹងតាមសេចក្តីពិត គឺ ដឹងដោយបញ្ញា ។ លោកសង្គ្រោះការដឹងតាមសច្ចៈ ដែលជាចំណែកខាងដើម ដោយការស្តាប់តាមក្នុងកាល ពោលថា រមែងមនសិការដោយប្រពៃថា នេះទុក្ខ ។

បទថា **យោនិសោមនសិការោ** បានដល់ មនសិការដោយឧបាយ ។



**ធាតុនានត្តំ បដិច្ច ឧប្បជ្ជតិ ផស្សនានត្តំ** សេចក្តីផ្សេងនៃផស្សៈ អាស្រ័យសេចក្តីផ្សេងគ្នានៃធាតុកើតឡើង សេចក្តីថា ការផ្សេងគ្នានៃចក្ខុសម្ផ័ស្សជាដើម អាស្រ័យការផ្សេងនៃចក្ខុធាតុជាដើម កើតឡើង ។

បទថា **ផស្សនានត្តំ បដិច្ច** អាស្រ័យការផ្សេងគ្នានៃផស្សៈ គឺ អាស្រ័យការផ្សេងនៃចក្ខុសម្ផ័ស្សជាដើម ។

បទថា **វេទនានានត្តំ** ការផ្សេងនៃវេទនា គឺ សេចក្តីផ្សេងគ្នានៃចក្ខុសម្ផ័ស្សជាវេទនាជាដើម ។

បទថា **សញ្ញានានត្តំ** ការផ្សេងនៃសញ្ញា គឺ សេចក្តីផ្សេងនៃកាមសញ្ញាជាដើម ។

បទថា **សង្កប្បនានត្តំ** ការផ្សេងនៃការត្រិះរិះ គឺ សេចក្តីផ្សេងនៃការត្រិះរិះដល់កាមជាដើម ។

បទថា **ឆន្ទនានត្តំ** ការផ្សេងនៃឆន្ទៈ គឺសេចក្តីផ្សេងនៃឆន្ទៈ រមែងកើតឡើងយ៉ាងនេះថា ឆន្ទៈក្នុងរូប ឆន្ទៈក្នុងសំឡេង ព្រោះការផ្សេងនៃការត្រិះរិះ ។

បទថា **បរិឡាហនានត្តំ** ការផ្សេងនៃសេចក្តីក្តៅក្រហាយ គឺ សេចក្តីផ្សេងនៃការក្តៅក្រហាយ រមែងកើតឡើងយ៉ាងនេះថា សេចក្តីក្តៅក្រហាយក្នុងរូប សេចក្តីក្តៅក្រហាយក្នុងសំឡេង ព្រោះការផ្សេងនៃធម្មៈ ។

បទថា **បរិយេសនានត្តំ** ការផ្សេងនៃការស្វែងរក គឺ សេចក្តីផ្សេងនៃការស្វែងរករូបជាដើម រមែងកើតឡើង ព្រោះការផ្សេងនៃការក្តៅក្រហាយ ។

បទថា **លាភនានត្តំ** ការផ្សេងនៃការបាន គឺ សេចក្តីផ្សេងនៃការបានរូបជាដើម រមែងកើតឡើង ព្រោះការផ្សេងគ្នានៃការស្វែងរក ។

( ចប់ អដ្ឋកថាធម្មនានត្តញ្ញាណនិទ្ទេស )

## អដ្ឋកថា ញាណបញ្ចកនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ ក្នុងញាណបញ្ចកនិទ្ទេសដូចតទៅនេះ ។ លោកធ្វើបុច្ឆាវិសជ្ជនារួមតែមួយ ព្រោះមានសេចក្តីសម្ព័ន្ធគ្នាជាលំដាប់នៃញាណទាំង ៥ នោះ ។



បទថា **អភិញ្ញាតា ហោន្តិ** ជាអ្នកដឹងធម៌ហើយ គឺ ជាអ្នកដឹងដោយល្អ ដោយអំណាចដឹងលក្ខណៈនៃសភាវធម៌ ។

បទថា **ញាតា ហោន្តិ** ជាការដឹងធម៌ហើយ គឺ ឈ្មោះថា ជាការដឹងហើយ ព្រោះដឹងសភាវដោយអំណាចនៃញាតបរិញ្ញា ។ ជាការដឹងធម៌ទាំងនោះដោយញាណណា ។ ឈ្មោះថា **ញាណ** ព្រោះអត្ថថា ញាណនោះដឹង ។ គប្បីជ្រាបការសម្ព័ន្ធគ្នាថា ឈ្មោះថា **បញ្ញា** ព្រោះអត្ថថា ដឹងច្បាស់ ។ ដោយន័យនេះ គប្បីប្រកបសូម្បីញាណដ៏សេស ។

បទថា **បរិញ្ញាតា ហោន្តិ** ជាការកំណត់ដឹងហើយ គឺ ជាការដឹងដោយជុំវិញ ដោយអំណាចនៃសាមញ្ញលក្ខណៈ ។

បទថា **តីរិតា ហោន្តិ** ជាការពិចារណាហើយ គឺ ចូលទៅកំណត់ឲ្យដល់ព្រម ដោយភាពជារបស់មិនទៀងជាដើម ដោយអំណាចនៃតីរណបរិញ្ញា ។

បទថា **បហីនា ហោន្តិ** ជាការលះបានហើយ គឺ ជាការលះនិច្ចសញ្ញាជាដើម ដោយអនិច្ចានុបស្សនាញាណជាដើម តាំងពីភង្គានុបស្សនាញាណ ។

បទថា **បរិច្ចត្តា ហោន្តិ** ជាការលះបង់ហើយ គឺ ជាការដកចោល ដោយអំណាចនៃការលះនោះឯង ។

បទថា **ភាវិតា ហោន្តិ** ជាការចម្រើនហើយ គឺ ជាការចម្រើន និងអប់រំហើយ ។

បទថា **ឯករសា ហោន្តិ** មានរសតែមួយដូចគ្នា គឺ មានកិច្ចដូចគ្នា ដោយការឲ្យសម្រេចកិច្ចរបស់ខ្លួន និងដោយការលះចំណែកផ្ទុយគ្នា , ឬមានរសតែមួយដូចគ្នា ដោយវិមុត្តិរស ដោយការផុតចាកធម៌ជាចំណែកសត្រូវ ។

បទថា **សច្ឆិកតា ហោន្តិ** ជាការធ្វើឲ្យជាក់ច្បាស់ហើយ គឺ ជាការធ្វើឲ្យប្រចក្សច្បាស់នូវផលធម៌ ដោយអំណាចការបាននិព្វានធម៌ ដោយអំណាចការចាក់ធ្លុះ ។

បទថា **ផស្សិតា ហោន្តិ** ជាការពាល់ត្រូវហើយ គឺ ជាការពាល់ត្រូវ គឺ បានទទួលផល ដោយការពាល់ត្រូវ ដោយការបាន និងដោយការពាល់ត្រូវ ដោយការចាក់ធ្លុះ លោកពោលដល់ញាណ ៥ ទាំងនេះ ដោយអំណាចសុតមញ្ញាណហើយក្នុងខាងក្រោយ ។ ក្នុងទីនេះ លោកពោលដោយអំណាចញុាំងកិច្ច



របស់ខ្លួនឲ្យសម្រេច ។

( ចប់ អដ្ឋកថាញាណបញ្ចកនិទ្ទេស )

# អដ្ឋកថា បដិសម្ភិទាញាណនិទ្ទេស

គប្បីជ្រាប វិនិច្ឆ័យក្នុងបដិសម្ភិទាញាណនិទ្ទេសដូចតទៅនេះ ។ ព្រោះបើលោកមិនពោលធម៌ទុក ក៏មិនអាចនឹងពោលដល់កិច្ចរបស់ធម៌នោះបាន ។ ដូច្នោះ ទើបមិនដាក់ចិត្តដល់ការលើកឡើងចង្អុលបង្ហាញធម៌ទាំងឡាយមុនរបស់លោក ។ អត្ថនៃធម៌ជាដើម លោកបានពោលទុកហើយ ។

ព្រះសារីបុត្តត្ថេរពោលធម៌ដែលទាក់ទងដោយ **ធម្ម** ស័ព្ទ ដោយបទមានជាអាទិ៍ថា **សទ្ធិន្ទ្រិយំ ធម្មោ** សទ្ធិន្ទ្រិយ៍ ជាធម៌ កាលនឹងសម្តែងអត្ថនៃ **នានត្ត** ស័ព្ទ ទើបពោលពាក្យមានជាអាទិ៍ថា

**អញ្ញោ សទ្ធិន្ទ្រិយំ ធម្មោ** សទ្ធិន្ទ្រីយ៍ជាធម៌មួយបែប ។ ពិតហើយ កាលលោកពោលថា **អញ្ញោ ធម្មោ** ជាធម៌មួយបែប គឺលោកសម្ដែងដល់សេចក្ដីផ្សេងគ្នានៃធម៌ទាំងឡាយ ។

បទថា **បដិវិទិតា** ដឹងចំពោះហើយ គឺ ដឹងដោយសភាពជាធម៌ចំពោះមុខ ឈ្មោះថា ប្រាកដហើយ ។ ដោយបទនោះ លោកពោលអត្ថនៃបទបដិសម្ភិទា ។

ព្រះសារីបុត្តត្ថេរសម្ដែងដល់កិច្ច មានការបង្អោនចិត្តជឿជាដើម ជាអត្ថនៃសទ្ធាជាដើមទាំងនោះ ដោយបទមានជាអាទិ៍ថា **អធិមោក្ខដ្ឋោ អត្ថោ** សភាពបង្អោនចិត្តជឿ ជាអត្ថ ។

បទថា **សន្ទស្សេតុំ** គឺ ដើម្បីសម្ដែងសេចក្ដីដទៃ ដល់អ្នកប្រាថ្នានឹងដឹង តែបើអ្នកដទៃស្ដាប់ពាក្យសម្ដី ក៏រមែងបានដូចគ្នា ។

បទថា **ព្យញ្ជននិរុត្តាភិលាបា** ការបញ្ជាក់ព្យញ្ជនៈ និងនិរុត្តិ គឺ នាមព្យញ្ជនៈ នាមនិរុត្តិ នាមាភិលាបៈ ។ ឈ្មោះដែលញ៉ាំងអត្ថឲ្យប្រាកដ ឈ្មោះថា **ព្យញ្ជន** ។ ឈ្មោះថា **និរុត្តិ** ព្រោះចងភ្ជាប់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងឡាយរមែងតាក់តែងវត្ថុដែលជាសង្ខតៈ ព្រោះដូច្នោះទើបហៅថា **សង្ខារ**



ហើយពោលធ្វើឲ្យមានហេតុ ។ លោកពោលថា **អភិលាប** ព្រោះជាហេតុបញ្ជាក់ដល់សេចក្ដី ។

ម្យ៉ាងទៀត ឈ្មោះថា **នាម** នេះ មាន ៤ យ៉ាង គឺ សាមញ្ញនាម ១ , គុណនាម ១ , កិត្តិមនាម ១ , ឱបបាតិក-នាម ១ ។ ក្នុងនាម ៤ យ៉ាងនោះ ក្នុងបឋមកប្ប ព្រះនាមរបស់ព្រះរាជាថា **មហាសម្មតិរាជ** ព្រោះមហាជនសម្មតិតាំងឡើង ឈ្មោះថា **សាមញ្ញនាម** នាមដោយសាមញ្ញ ។

លោកពោលសំដៅដល់ បទថា ម្នាលវាសេដ្ឋៈ និងការ-ទ្វាជៈ ព្រោះហេតុដែលអ្នកជាប្រធាន ដែលមហាជនសម្មតិតាំងឡើងនេះឯង អក្ខរៈថា មហាជនសម្មតិ ទើបកើតឡើងជាគ្រាដំបូង ។

ឈ្មោះដែលបានមកដោយគុណ គឺសេចក្ដីល្អ យ៉ាងនេះថា ព្រះធម្មកថិក បង្សុកូលិកភិក្ខុ វិន័យធរភិក្ខុ តិបិដកធរភិក្ខុអ្នកមានសទ្ធា អ្នកមានសតិ ដូច្នេះ ឈ្មោះថា **គុណនាម** ដោយគុណសេចក្ដីល្អ ។ ឈ្មោះដោយគុណសេចក្ដីល្អរបស់ព្រះតថាគតតាំងច្រើនរយឈ្មោះ មានជាអាទិ៍ថា **ភគវា អរហំ សម្មាសម្ពុទ្ធោ** ។

ដូច្នោះទើបលោកពោលថា

អសង្ខេយ្យានិ នាមានិ សគុណេន មហេសិនោ
គុណេហិ នាមំ ឧទ្ធេយ្យំ អបិនាម សហស្សតោ

ព្រះនាមរបស់ព្រះតថាគត អ្នកស្វែងរកគុណដ៏ធំក្រៃលែង ព្រមដោយគុណ គឺ សេចក្ដីល្អមានប្រមាណមិនបាន ។ បណ្ឌិតគួរលើកព្រះនាម ដោយព្រះគុណឡើងសម្ដែង សូម្បីទាំងពាន់ព្រះនាម ។

ក្នុងថ្ងៃតាំងឈ្មោះក្មេងដែលទើបនឹងកើត ពួកញាតិនាំគ្នាធ្វើសក្ការៈដល់ទក្ខិណេយ្យបុគ្គល ហើយនៅទីជិតៗ កំណត់តាំងឈ្មោះថា ទារកនេះឈ្មោះឯណោះ ដូច្នេះ នេះឈ្មោះថា **កិត្តិមនាម** នាមដោយមានកេរ្តិ៍ឈ្មោះ ។

ម្យ៉ាងទៀត ការបញ្ញត្តិអំពីមុន ក៏នៅបន្តការបញ្ញត្តិតមក ។ វោហារអំពីមុន ក៏នៅបន្តរហូតដល់វោហារខាងក្រោយ ។ ដូចសេចក្ដីថា សូម្បីក្នុងបុរិមកប្បព្រះច័ន្ទ ក៏ឈ្មោះថា ច័ន្ទ ។ សូម្បីមកដល់ពេលនេះ ក៏នៅឈ្មោះថា ព្រះច័ន្ទនោះឯង ។ ក្នុងអតីត



ព្រះអាទិត្យ សមុទ្រ ប្រថពី ក៏មានឈ្មោះដូចដើម ភ្នំ ក៏ឈ្មោះថាភ្នំ ។ សូម្បីក្នុងពេលនេះ ក៏ឈ្មោះថា ភ្នំ នោះឯង ។ នេះឈ្មោះថា **ឱបបាតិកនាម** គឺជានាមដែលកើតឡើង ។ ឈ្មោះសូម្បី ៤ យ៉ាងនេះ ក៏ជាឈ្មោះតែមួយនោះឯង ។ ឈ្មោះនោះប្រើត្រឹមតែជាការសង្កេតរបស់មនុស្សលោក ពោលដោយបរមត្ថមិនមាន ។ ចំណែកអាចារ្យពួកដទៃពោលថា ឈ្មោះថា **នាម** ជាសំឡេង បញ្ជាក់ដល់ខ្លឹមសារ ។

គប្បីជ្រាបអត្ថនៃអង្គមគ្គ គឺ ពលៈ និងពោជ្ឈង្គៈ ដោយទំនងដូចគ្នានឹងន័យដូចពោលហើយនោះឯង ។

( ចប់ អដ្ឋកថាបដិសម្ភិទាញាណនិទ្ទេស )

# អដ្ឋកថា ញាណត្តយានិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងញាណត្តយានិទ្ទេស ដូចតទៅនេះ ។

បទថា **និមិត្តំ** បានដល់ សង្ខារនិមិត្ត ។

បទថា **អនិមិត្តេ** បានដល់ និព្វានដែលបដិបក្ខជាមួយសង្ខារនិមិត្ត ។

បទថា **អធិមុត្តត្តា** ព្រោះមានចិត្តបង្អោនទៅ គឺ ព្រោះបង្អោនចិត្តទៅក្នុងនិព្វាននោះ ។

បទថា **ផុស្ស ផុស្ស វយំ បស្សតិ** ពាល់ត្រូវហើយពាល់ត្រូវហើយ រមែងឃើញការបែកធ្លាយ គឺ ពាល់ត្រូវហើយពាល់ត្រូវហើយ នូវសង្ខារនិមិត្តដោយញាណ រមែងឃើញការបែកធ្លាយទៅនៃសង្ខារនិមិត្តនោះ ដោយវិបស្សនាញាណ ។ ដោយបទនេះ ជាការសម្រេចដល់កង្គានុបស្សនាញាណ ។ កង្គា-នុបស្សនានោះ ញុំាងអនិច្ចានុបស្សនាឲ្យសម្រេច ។ អនិច្ចានុ-បស្សនា ញុំាងទុក្ខានុបស្សនាឲ្យសម្រេច ព្រោះវត្ថុដែលមិនទៀងជាទុក្ខ ។ ទុក្ខានុបស្សនានោះ ញុំាងអនត្តានុបស្សនា ឲ្យសម្រេច ព្រោះវត្ថុដែលជាទុក្ខ ជាអនត្តា ។ ព្រោះហេតុនោះ ទើបលោក



ពោលដល់អនុបស្សនា ៣ ក្នុងបទនេះ ដោយប្រការដូច្នេះ ។

បទថា **អនិមិត្តោ វិហារោ** វិហារធម៌ឈ្មោះថា អនិមិត្ត-វិហារ គឺ វិហារធម៌ដែលជាពួក ៣ នៃវិបស្សនានោះ ឈ្មោះថា **អនិមិត្តវិហារ** ព្រោះហេតុនិមិត្តដោយសភាពជាភ័យ ។

បទថា **បណិធិ** បានដល់ តណ្ហា ។

បទថា **អបណិហិតេ** ក្នុងនិព្វានដែលមិនមានតណ្ហាជាទីតាំង គឺ ក្នុងនិព្វានជាបដិបក្ខដល់តណ្ហា ។

បទថា **អភិនិវេសំ** បានដល់ ការប្រកាន់មាំតួខ្លួន ។

បទថា **សុញ្ញតេ** បានដល់ និព្វានដែលសូន្យចាកតួខ្លួន ។

បទថា **សុញ្ញតោ** គឺ សភាពសូន្យនោះឯង ឈ្មោះថា **សុញ្ញតវិហារ** ។

បទថា **បវត្តំ អជ្ឈុបេក្ខិត្វា** រមែងព្រងើយកន្តើយក្នុងការប្រព្រឹត្តទៅ គឺ ភាពព្រងើយកន្តើយប្រព្រឹត្តទៅដែលជាវិបាក ដោយការព្រងើយកន្តើយក្នុងសង្ខារ ។ ពិតណាស់ សត្វទាំងឡាយជាអ្នកពេញចិត្តក្នុងការប្រព្រឹត្តទៅដែលជាវិបាក ពោលគឺ **សុគតិ** ។ តែព្រះយោគាវចរនេះ បំណងនឹងចូលផលសមាបត្តិ ឃើញសង្ខារ

ទាំងពួងដែលប្រព្រឹត្តទៅនោះឯងថាជា របស់មិនទៀងជាដើម រមែងព្រងើយកន្តើយ ។ ព្រោះថា លុះឃើញយ៉ាងនេះហើយ រមែងចូលផលសមាបត្តិបាន ។ មិនអាចចូលបាន ដោយប្រការដទៃ ។

បទថា **អាវជ្ជិត្វា** ពិចារណាហើយ គឺ ពិចារណាដោយអាវជ្ជនៈ ។

បទថា **សមាបជ្ជតិ** គឺ រមែងចូលដល់ផលសមាបត្តិ ។

បទថា **អនិមិត្តា សមាបត្តិ** សមាបត្តិដែលរកនិមិត្តមិនបាន គឺ ឈ្មោះថា សមាបត្តិដែលមិនមាននិមិត្ត ព្រោះឃើញនិមិត្តថាជាភ័យ ហើយចូលដល់ ។

បទថា **អនិមិត្តវិហារសមាបត្តិ** វិហារសមាបត្តិដែលរកនិមិត្តមិនបាន គឺ មានទាំងពីរយ៉ាងដោយអំណាចនៃវិបស្សនាវិហារ និងដោយអំណាចនៃផលសមាបត្តិ ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ កាលចែកសង្ខារនិមិត្តហើយ ទើបពោលបទមានជាអាទិ៍ថា **រូបនិមិត្តំ** ។ គួរនឹងពោលក្នុងការកាន់យកជរា និងមរណៈ លោកពោលទុកមុនហើយ ។ កាល



ពោលដោយបទមានជាអាទិ៍ថា **អញ្ញោ អនិមិត្តវិហារោ** អនិមិត្ត-វិហារសមាបត្តិឯណាមួយ ព្រះសារីបុត្តត្ថេរបានសម្តែងសរុបទុកហើយ ។ ញាណ ក្នុងសេចក្តីផ្សេងគ្នាពីវិបស្សនាវិហារ របស់អ្នកតាំងនៅក្នុងសង្ខារុបេក្ខាញាណ ដែលជាចំណែកខាងដើមនៃផលសមាបត្តិ ឈ្មោះថា **វិហារដ្ឋញ្ញាណ** ។ ញាណក្នុងភាពផ្សេងគ្នានៃផលសមាបត្តិ ឈ្មោះថា **សមាបត្តដ្ឋញ្ញាណ** ។ ញាណក្នុងភាពផ្សេងគ្នាទាំងពីរយ៉ាងនោះ ឈ្មោះថា វិហារ-សមាបត្តដ្ឋញ្ញាណ ។

ព្រះយោគាវចរ អ្នកបំណងនឹងបង្អោនទៅដោយវិបស្សនា-វិហារ រមែងញុំាងវិបស្សនាវិហារឲ្យប្រព្រឹត្តទៅ ។ បំណងនឹងបង្អោនទៅដោយផលសមាបត្តិវិហារ ខ្វល់ខ្វាយទៅតាមលំដាប់របស់វិបស្សនា រមែងញុំាងផលសមាបត្តិឲ្យប្រព្រឹត្តទៅ ។ បំណងនឹងបង្អោនទៅទាំងពីរយ៉ាងនោះ រមែងញុំាងទាំងពីរយ៉ាងនោះឲ្យប្រព្រឹត្តទៅ ។ មាន ៣ យ៉ាង ដោយបំណងដល់បុគ្គល ដោយប្រការដូច្នេះ ។ បទដ៏សេស គួរពោលទុកក្នុងទីនេះ លោកពោលទុកហើយក្នុងការពណ៌នាដល់សង្ខារុបេក្ខាញាណនោះឯង ។

( ចប់ អដ្ឋកថាញាណត្តយានិទ្ទេស )

# អដ្ឋកថា អានន្តរិកសមាធិញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ ក្នុងអានន្តរិកសមាធិញ្ញាណនិទ្ទេស ដូចតទៅនេះ ។ ក្នុងបទមានជាអាទិ៍ថា **នេក្ខម្មវសេន** ដោយអំណាចនៃនេក្ខម្មៈ មានអធិប្បាយដូចតទៅនេះ ធម៌ទាំងឡាយ គឺ នេក្ខម្មៈ អព្យាបាទៈ អាលោកសញ្ញា ការកំណត់ធម៌ដែលមិនរាយមាយ ញាណ និងបាមោជ្ជៈ ប្រកបដោយឧបចារឈាន របស់ព្រះសុក្ខវិបស្សកៈ ជាបដិបក្ខចំពោះកិលេសនោះ ៗ សម្បយុត្តដោយចិត្តមួយដួងប៉ុណ្ណោះ ។

បទថា **ចិត្តស្ស ឯកគ្គតា អវិក្ខេបោ** ឯកគ្គតាចិត្តដែលមិនរាយមាយ គឺ ជាចិត្តដ៏ប្រសើរមួយដួង ឈ្មោះថា **ឯកគ្គតា** ។ ឈ្មោះថា **អវិក្ខេប** ព្រោះចិត្តមិនរាយមាយទៅក្នុងអារម្មណ៍ផ្សេង ៗ ដោយឯកគ្គតានោះ ។ អធិប្បាយថា ភាពមិនរាយមាយ ពោលគឺ ភាពនៃចិត្តជាឯកគ្គតា ។

បទថា **សមាធិ** សេចក្តីថា ឈ្មោះថាសមាធិ ព្រោះចិត្តតាំងនៅរឿយៗ ក្នុងអារម្មណ៍តែមួយ ។



បទថា **តស្ស សមាធិស្ស វសេន** ដោយអំណាចនៃសមាធិនោះ គឺ ដោយអំណាចនៃសមាធិមានប្រការដូចពោលហើយ ព្រោះដឹងតាមសេចក្តីពិតនៃចិត្តតាំងមាំនោះហើយ ដោយឧបចារសមាធិ ។

បទថា **ឧប្បជ្ជតិ ញាណំ** ញាណរមែងកើតឡើង គឺ មគ្គញ្ញាណរមែងកើតឡើងតាមលំដាប់ ។

បទថា **ខីយន្តិ** រមែងអស់ទៅ ដោយអំណាចការកាត់ផ្តាច់ ។

បទថា **ឥតិ** ជាបទសរុបអត្ថ មានប្រការដូចពោលហើយ ។

បទថា **បឋមំ សមថោ** សមថៈមានមុន គឺ សមាធិ រមែងមានក្នុងចំណែកខាងដើម ។

បទថា **បច្ឆា ញាណំ** ញាណមានជាខាងក្រោយ គឺ ញាណរមែងមានក្នុងខណៈមគ្គ ក្នុងចំណែកខាងក្រោយ ។

បទថា **កាមាសវោ** កាមាសវៈ គឺ រាគៈប្រកបដោយកាមគុណ ៥ ។

បទថា **ភវាសវោ** ភវាសវៈ គឺ ឆន្ទរាគៈក្នុងរូបភព អរូបភព សេចក្តីប្រាថ្នាក្នុងឈាន រាគៈកើតរួមជាមួយសស្ស-

តទិដ្ឋិ សេចក្តីប្រាថ្នាដោយអំណាចនៃកព ។

បទថា **ទិដ្ឋាសវោ** ទិដ្ឋាសវៈ គឺ ទិដ្ឋិ ៦២ ។

បទថា **អវិជ្ជាសវោ** អវិជ្ជាសវៈ គឺ ការមិនដឹងក្នុង ឋានៈ ៨ មានទុក្ខជាដើម ។ លោកធ្វើពាក្យសួរតាមឱកាស ដោយសត្តមីវិភត្តិ ហើយសម្តែងការអស់ទៅនៃអាសវៈដោយមគ្គ ធ្វើសភាពអស់ទៅនៃអាសវៈ ដោយបទមានជាអាទិ៍ថា **សោតបត្តិមគ្គេន** ដោយសោតាបត្តិមគ្គ ហើយទើបឆ្លើយតាមឱកាសដោយបទថា **ឯត្ថ** ។ លោកអធិប្បាយថា ក្នុងខណៈនៃមគ្គ ។

បទថា **អនវសេសោ** មិនមានចំណែកសល់ គឺ អាសវៈមិនមានចំណែកសល់ ឈ្មោះថា **អនវសេស** ។

បទថា **អបាយគមនីយោ** ដែលជាហេតុឲ្យសត្វទៅកាន់អបាយ បានដល់ នរក កំណើតតិរច្ឆាន បេតវិស័យ និងអសុរកាយ ទាំងបួននេះ ឈ្មោះថា **អបាយ** ព្រោះប្រាសចាកសេចក្តីចម្រើន គឺ សេចក្តីសុខ ។

ឈ្មោះថា **អបាយគមនីយោ** ព្រោះអត្ថថា ញុំាងសត្វដែលមានអាសវៈនោះ ឲ្យទៅកាន់អបាយ ។ លោកពោលអាសវក្ខយកថា



ទុកហើយក្នុង ទុកតោវុដ្ឋានកថា ។

បទថា **អវិក្ខេបវសេន** ដោយអំណាចនៃការមិនរាយមាយ គឺ ដោយអំណាចនៃសមាធិជាឧបនិស្ស័យនៃសមាធិ ដែលប្រព្រឹត្តទៅហើយ ។

ក្នុងបទថា **បឋវីកសិណវសេន** ដោយអំណាចនៃបឋវីកសិណ ជាអាទិ៍មានសេចក្តីដូចតទៅនេះ លោកពោលដល់កសិណ ១០ ដោយអំណាចនៃអប្បនាសមាធិដែលមានកសិណជាអារម្មណ៍ ។ លោកពោលពុទ្ធានុស្សតិជាដើម មរណស្សតិនិងឧបសមានុស្សតិ ដោយឧបចារឈាន ។ លោកពោលអានាបានស្សតិ និងកាយគតាសតិ ដោយអំណាចនៃអប្បនាសមាធិ ។ លោកពោលអសុភៈ ១០ ដោយអំណាចនៃបឋមជ្ឈាន ។

ការរឭកដែលប្រារព្ធព្រះពុទ្ធជាម្ចាស់ ឈ្មោះថា **ពុទ្ធានុស្សតិ** ។ ពុទ្ធានុស្សតិនេះ ជាឈ្មោះរបស់សតិមានព្រះពុទ្ធគុណជាអារម្មណ៍ មានជាអាទិ៍ថា **ឥតិបិ សោ ភគវា អរហំ** ។ ដោយអំណាចពុទ្ធានុស្សតិនោះ ។

ម្យ៉ាងទៀត ការរឭកដែលប្រារព្ធព្រះធម៌ ឈ្មោះថា **ធម្មា-**

**នុស្សតិ** ។ ធម្មានុស្សតិនេះ ជាឈ្មោះរបស់សតិមានព្រះធម្មគុណជាអារម្មណ៍ មានជាអាទិ៍ថា **ស្វាក្ខាតោ ភគវតា ធម្មោ**[១] ។

ការរឭកដែលប្រារព្ធព្រះសង្ឃ ឈ្មោះថា **សង្ឃានុស្សតិ** ។ សង្ឃានុស្សតិនេះ ជាឈ្មោះរបស់សតិមានព្រះសង្ឃគុណជាអារម្មណ៍ មានជាអាទិ៍ថា **សុបដិបន្នោ ភគវតោ សាវកសង្ឃោ**[១] ។

ការរឭកដែលប្រារព្ធដល់សីល ឈ្មោះថា **សីលានុស្សតិ** ។ សីលានុស្សតិនេះ ជាឈ្មោះរបស់សតិដែលមានគុណរបស់សីល គឺ សីលរបស់ខ្លួនមិនដាច់ជាដើម ជាអារម្មណ៍ ។

ការរឭកដែលប្រារព្ធដល់ចាគៈ ឈ្មោះថា **ចាគានុស្សតិ** ។ ចាគានុស្សតិនេះ ជាឈ្មោះរបស់សតិដែលមានគុណនៃការបរិច្ចាគ គឺ ភាពជាអ្នកលះបង់ជាដើម ជាអារម្មណ៍ ។

ការរឭកដែលប្រារព្ធទេវតាទាំងឡាយ ឈ្មោះថា **ទេវតានុស្សតិ** ។ ទេវតានុស្សតិនេះ ជាឈ្មោះរបស់សតិដែលមានគុណ

១ មជ្ឈិមនិកាយ មូលបណ្ណាសកៈ



គឺ សទ្ធាជាដើមរបស់ខ្លួនជាអារម្មណ៍ តាំងទេវតាទុកក្នុងទីចំពោះមុខ ៗ

សតិកើតឡើងប្រារព្ធអានាបានៈ ខ្យល់ដង្ហើមចូល-ចេញ ឈ្មោះថា **អានាបានស្សតិ** ។ អានាបានស្សតិនេះ ជាឈ្មោះរបស់សតិមានអានាបាននិមិត្តជាអារម្មណ៍ ។

សតិកើតឡើងប្រារព្ធសេចក្តីស្លាប់ ឈ្មោះថា **មរណស្សតិ** ។ មរណស្សតិនេះ ជាឈ្មោះរបស់សតិដែលមានមរណៈ ពោលគឺ ការដាច់ជីវិតិន្ទ្រិយ៍ដែលជាប់ក្នុងភពមួយ ជាអារម្មណ៍ ។

សតិដែលប្រព្រឹត្តទៅក្នុងសរីរៈ ដែលហៅថា **កាយ** ព្រោះបង្កើតនូវវត្ថុដែលជាបដិកូលទាំងឡាយ មានសក់ជាដើម ដែលគួរខ្ពើម ។ ឬប្រព្រឹត្តទៅកាន់កាយនោះ ឈ្មោះថា **កាយគតាសតិ** ។ បើគួរនឹងពោលថា **កាយគតសតិ** លោកមិនធ្វើជារស្សៈ ពោលថា **កាយគតាសតិ** ។ សូម្បីក្នុងទីនេះ ក៏ដូចគ្នា លោកពោលថា **កាយគតាសតិវសេន** កាយគតាសតិនេះ ជាឈ្មោះរបស់សតិ មានបដិកូលនិមិត្តក្នុងចំណែករបស់កាយ មានសក់ជាដើម ជាអារម្មណ៍ ។

ការរឭកដែលប្រារព្ធឧបសមៈ ( សេចក្តីស្ងប់ ) ឈ្មោះថា **ឧបសមានុស្សតិ** ។ ឧបសមានុស្សតិនេះ ជាឈ្មោះរបស់សតិមានសេចក្តីស្ងប់ទុក្ខទាំងពួងជាអារម្មណ៍ ។

អសុភៈ១០ មានអត្ថបានពោលហើយក្នុងខាងក្រោយ ។

ដើម្បីសម្តែងដល់ប្រភេទអប្បនាសមាធិ និងឧបចារសមាធិ លោកទើបពោលថា **ទីឃំ អស្សាសវសេន** ដោយអំណាចនៃការដកដង្ហើមចូលវែង គឺ ដោយអំណាចនៃការដកដង្ហើមចូលវែង ដែលលោកពោលហើយថា **ទីឃំ** វែង ។ ដូចដែលលោកពោលថា **ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាតិ** កាលដកដង្ហើមចូលវែង រមែងដឹងថា អញដកដង្ហើមចូលវែង ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះ ។

បទថា **សព្វកាយបដិសំវេទី** អ្នកដឹងច្បាស់នូវខ្យល់ដកដង្ហើមចេញចូលទាំងពួង ។

បទថា **បស្សម្ភយំ កាយសង្ខារំ** ការរម្ងាប់កាយសង្ខារ គឺ រម្ងាប់ គឺ ស្ងប់កាយសង្ខារ បានដល់ ការដកដង្ហើមចូល និងការដកដង្ហើមចេញដែលគ្រោតគ្រាត ។ លោកពោលអប្បនា-



សមាធិដោយពួក ៤ នេះ គឺ **ទីឃំ** វែង ១ , **រស្សំ** ខ្លី ១ , **ដឹងច្បាស់កាយទាំងពួង** ១ , **រម្ងាប់កាយសង្ខារ** ១ ។

បទថា **បីតិបដិសំវេទី** ដឹងច្បាស់បីតិ គឺ ធ្វើបីតិឲ្យប្រាកដ ។

បទថា **ចិត្តសង្ខារបដិសំវេទី** ដឹងច្បាស់ចិត្តសង្ខារ គឺ ធ្វើចិត្តសង្ខារ ពោលគឺ សញ្ញា វេទនា ឲ្យប្រាកដ ។

បទថា **អភិប្បមោទយំ ចិត្តំ** ធ្វើចិត្តឲ្យរីករាយ ។

បទថា **សមាទហំ ចិត្តំ** ការតាំងចិត្តទុក គឺ តាំងចិត្តទុករឿយៗ ក្នុងអារម្មណ៍ ។

បទថា **វិមោចយំ ចិត្តំ** ការញុាំងចិត្តឲ្យផុតស្រឡះ គឺ ញុាំងចិត្តចាកនីវរណៈជាដើម ។

លោកពោលពួក ៤ គឺ **បីតិបដិសំវេទី** ដឹងច្បាស់នូវ បីតិ ១ , **សុខបដិសំវេទី** ដឹងច្បាស់នូវសុខ ១ , **ចិត្តសង្ខារបដិ-សំវេទី** ដឹងច្បាស់នូវចិត្តសង្ខារ ១ , **បស្សម្ភយំ ចិត្តសង្ខារំ** រម្ងាប់ចិត្តសង្ខារ ១ ។

និងពួក ៤ គឺ **ចិត្តបដិសំវេទី** ដឹងច្បាស់នូវចិត្ត ១ ,

**អភិប្បមោទយំ ចិត្តំ** ធ្វើចិត្តឲ្យរីករាយ ១ , **សមាទហំ ចិត្តំ** ការតាំងចិត្តទុក ១ , **វិមោចយំ ចិត្តំ** ការញ៉ាំងចិត្តឲ្យរួចផុត ១ ដោយអប្បនាសមាធិ និងដោយអំណាចសមាធិ សម្បយុត្តជាមួយវិបស្សនា ។

បទថា **អនិច្ចានុបស្សី** ការពិចារណាឃើញសភាពមិនទៀង គឺ លោកពោលដោយអំណាចការពិចារណាឃើញថាមិនទៀង ។

បទថា **វិរាគានុបស្សី** ការពិចារណាឃើញការប្រាសចាកតម្រេក គឺ លោកពោលដោយអំណាចការពិចារណាឃើញសេចក្ដីនឿយណាយ ។

បទថា **និរោធានុបស្សី** ការពិចារណាឃើញការរលត់ គឺ លោកពោលដោយអំណាចនៃការបែកធ្លាយ ។

បទថា **បដិនិស្សគ្គានុបស្សី** ការពិចារណាឃើញការលះបង់ លោកពោលដោយអំណាចវុដ្ឋានគាមិនីវិបស្សនា ឃើញច្បាស់ការចេញចាក ។

ពិតហើយ ការពិចារណាឃើញការលះបង់នោះ រមែងលះ



បង់កិលេសជាមួយនឹងខន្ធាភិសង្ខារដោយតទង្គៈ មួ៉ាងទៀត រមែងស្ទុះទៅ ព្រោះបង្អោនចិត្តទៅក្នុងនិព្វាន ដែលផ្ទុយគ្នាជាមួយនឹងកិលេសនោះ ដោយឃើញទោសក្នុងសង្ខតធម៌ ។ លោកពោលពួក ៤ នេះ ដោយអំណាចនៃសមាធិដែលសម្បយុត្តជាមួយនឹងវិបស្សនា ។

មួ៉ាងទៀត ក្នុងបទនេះថា **អស្សាសវសេន បស្សាស-វសេន** ដោយអំណាចនៃការដកដង្ហើមចូល ដោយអំណាចនៃការដកដង្ហើមចេញ លោកពោលកាន់យកត្រឹមតែការប្រព្រឹត្តទៅនៃការដកដង្ហើមចូល និងការដកដង្ហើមចេញ មិនមែនពោលដោយអំណាចការធ្វើខ្យល់ដង្ហើមចេញ.ចូលនោះ ជាអារម្មណ៍ ។ ចំណែកសេចក្ដីពិស្ដារក្នុងបទនេះ នឹងមានច្បាស់ក្នុងអានាបានកថា ។

( ចប់ អដ្ឋកថាអានន្តរិកសមាធិញ្ញាណនិទ្ទេស )

# អដ្ឋកថា អរណវិហារញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងអរណវិហារញ្ញាណនិទ្ទេស ដូចតទៅនេះ ។ អនិច្ចានុបស្សនាជាដើម មានន័យដូចបានពោលទុកហើយ ។

បទថា **សុញ្ញតោ វិហារោ** សុញ្ញតវិហារ បានដល់ អរហត្តផលសមាបត្តិ ដែលប្រព្រឹត្តទៅហើយ ដោយអាការនៃសុញ្ញតៈ គឺភាពសូន្យទទេរបស់អ្នកតាំងនៅក្នុងអនត្តានុបស្សនា ។

បទថា **អនិមិត្តោ វិហារោ** អនិមិត្តវិហារ បានដល់ អរហត្តផលសមាបត្តិ ដែលប្រព្រឹត្តទៅហើយ ដោយអាការនៃអនិមិត្តៈ គឺមិនមាននិមិត្ត របស់អ្នកតាំងនៅក្នុងអនិច្ចានុបស្សនា ។

បទថា **អប្បណិហិតោ វិហារោ** អប្បណិហិតវិហារ បានដល់ អរហត្តផលសមាបត្តិដែលប្រព្រឹត្តទៅ ដោយអាការនៃអប្បណិហិតៈ គឺ មិនតាំងនៅ របស់អ្នកតាំងនៅក្នុងទុក្ខានុបស្សនា ។

បទថា **សុញ្ញតេ អធិមុត្តតា** សភាពនៃចិត្តជាធម្មជាតិបង្អោនទៅក្នុងធម៌ដែលសូន្យទទេ បានដល់ សភាពនៃចិត្តបង្អោន



ទៅក្នុងធម្មជាតិដែលសូន្យទទេ ដោយអំណាចនៃបញ្ញា ដែលជាចំណែកខាងដើមនៃផលសមាបត្តិ ។ សូម្បីក្នុងពីរបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

ដោយបទមានជាអាទិ៍ថា **បឋមំ ឈានំ** បឋមឈាន លោកពោលដល់ឈានសមាបត្តិ ដែលជាអារម្មណ៍នៃវិបស្សនារបស់អ្នកប្រាថ្នាដើម្បីចូលកាន់អរហត្តផលសមាបត្តិ ។ ពិតណាស់ វិបស្សនាផលសមាបត្តិ និងឈានសមាបត្តិ ដែលបង្អោនទៅដើម្បីភាពប្រណីតរបស់ព្រះអរហន្តប៉ុណ្ណោះ រមែងគួរ ដើម្បីពោលថា **អរណវិហារ** គឺ សេចក្តីស្ងប់ ការអស់ទុក្ខ ព្រោះលះបង់កិលេសទាំងពួងបានហើយ ។

បទថា **បឋមេន ឈានេន នីវរណេ ហរតីតិ អរណវិហារោ** ឈ្មោះថា អរណវិហារ ព្រោះនាំចេញនូវនីវរណៈ ដោយបឋមជ្ឈាន ។ បឋមជ្ឈាននោះ ឈ្មោះថា **អរណវិហារ** ព្រោះអង្គប្រកបនៃបឋមជ្ឈាន អធិប្បាយថា រមែងនាំចេញនូវនីវរណៈ ដោយបឋមជ្ឈាន ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ គប្បីជ្រាបថា លោកពោលដល់បឋមជ្ឈាន នាំចេញនូវនីវរណៈ ព្រោះ

បឋមជ្ឈានជាបដិបក្ខចំពោះនីវរណៈ សូម្បីព្រះអរហន្ត ក៏មិនមាននីវរណៈ ។

ប្រសិនបើសួរថា ព្រោះហេតុអ្វី លោកទើបលើកយកអរណវិហារឡើងសម្ដែង ៣ យ៉ាង ដោយអំណាចនៃការបង្អោនទៅដើម្បីភាពប្រណីតនៃវិបស្សនា ផល និងសមាបត្តិ ហើយចង្អុលបង្ហាញថា ឈានសមាបត្តិនោះឯង ជាអរណវិហារ ។ ឆ្លើយថា ៣ យ៉ាងនោះ សម្រេចហើយ ព្រោះអរណវិហារ ដោយអំណាចឧទ្ទេស ។ ឈានសមាបត្តិ ដែលជាភូមិរបស់ផលសមាបត្តិ និងវិបស្សនា កាលលោកមិនពោលទុក ក៏រមែងមិនសម្រេច ។ ព្រោះដូច្នោះ ដើម្បីញុំាងអរណវិហារដែលមិនសម្រេចនោះឯងឲ្យសម្រេច ។ គប្បីជ្រាបថា លោកពោលបទមានជាអាទិ៍ថា បឋមជ្ឈានជាអរណវិហារ ។

ពិតណាស់ ឈានសមាបត្តិទាំងនោះ ជាអរណវិហារ សូម្បីមិនសម្រេចដោយអំណាចនៃឧទ្ទេស ក៏ជាការសម្រេចបាន ព្រោះលោកពោលទុកហើយក្នុងនិទ្ទេស ។ មយ៉ាងទៀត ដោយន័យដែលលោកប្រកបអរណវិហារទុកហើយ គប្បីប្រកបហើយកាន់



យកដូច្នេះ **អនិច្ចានុបស្សនា** ឈ្មោះថា អរណវិហារ ព្រោះនាំចេញនូវនិច្ចសញ្ញា ។ **ទុក្ខានុបស្សនា** ឈ្មោះថា អរណវិហារ ព្រោះនាំចេញនូវសុខសញ្ញា ។ **អនត្តានុបស្សនា** ឈ្មោះថា អរណវិហារ ព្រោះនាំចេញនូវអត្តសញ្ញា ។ **សុញ្ញតវិហារ** ឈ្មោះថា អរណវិហារ ព្រោះនាំចេញនូវភាពមិនសូន្យទទេ ។ **អនិមិត្តវិហារ** ឈ្មោះថា អរណវិហារ ព្រោះនាំចេញនូវនិមិត្ត ។ **អប្បណិហិតវិហារ** ឈ្មោះថា អរណវិហារ ព្រោះនាំចេញនូវការតាំងទុក ។ **សុញ្ញាធិមុត្តតា** សភាពនៃចិត្តជាធម្មជាតិបង្អោនទៅក្នុងធម៌ ដែលសូន្យទទេ ឈ្មោះថា អរណវិហារ ព្រោះនាំចេញនូវការ បង្អោនទៅក្នុងធម៌ដែលមិនសូន្យទទេ ។ **អនិមិត្តាធិមុត្តតា** សភាពនៃចិត្ត ជាធម្មជាតិបង្អោនទៅក្នុងធម៌ ដែលមិនមាននិមិត្ត ឈ្មោះថា អរណវិហារ ព្រោះនាំចេញនូវការបង្អោនទៅក្នុងធម៌ដែលមាននិមិត្ត ។ **អប្បណិហិតាធិមុត្តតា** សភាពនៃចិត្ត ជាធម្មជាតិបង្អោនទៅក្នុងធម៌ ដែលមិនមានទីតាំង ឈ្មោះថា **អរណវិហារ** ព្រោះនាំចេញនូវការបង្អោនទៅក្នុងធម៌ដែលមិនមានទីតាំង ។

( ចប់ អដ្ឋកថាអរណវិហារញ្ញាណនិទ្ទេស )

# អដ្ឋកថា និរោធសមាបត្តិញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងនិរោធសមាបត្តិញ្ញាណនិទ្ទេស ដូចតទៅនេះ ៖-

បទថា **សមថពលំ** សមថពលៈ សេចក្ដីថា **សមថ** ព្រោះអត្ថថា ស្ងប់ធម៌ដែលជាសត្រូវ មានកាមច្ឆន្ទៈជាដើម ។ សមថៈនោះឯងឈ្មោះថា ពលៈ ព្រោះអត្ថថា មិនញាប់ញ័រ ។ ព្រោះព្រះអនាគាមី និងព្រះអរហន្តនោះឯង ជាអ្នកធ្វើឲ្យបរិបូរណ៍ក្នុងសមាធិ ដោយការលះបង់កាមច្ឆន្ទៈ ដែលជាបដិបក្ខដល់សមាធិ លោកទើបធ្វើសមាធិរបស់ព្រះអនាគាមី និងព្រះអរហន្តទាំងនោះថា **ពលប្បត្តោ** អ្នកដល់នូវកម្លាំង ហើយទើបពោលថា **សមថពលំ** មិនមែនរបស់បុគ្គលដទៃ ។ បាឋៈថា **សមាធិពលំ** ខ្លះ ។

បទថា **វិបស្សនាពលំ** វិបស្សនាពលៈ សេចក្ដីថា ឈ្មោះថា **វិបស្សនា** ព្រោះអត្ថថា ឃើញធម៌ ដោយអាការច្រើនយ៉ាងមានមិនទៀងជាដើម ។ វិបស្សនានោះឯង ឈ្មោះថា ពលៈ ព្រោះអត្ថថា មិនញាប់ញ័រ ។ វិបស្សនាញាណជាកម្លាំងរបស់ព្រះ-



អរិយជាម្ចាស់ទាំងពីរពួកនោះ ។

សមថពលៈ ដើម្បីស្ងប់សន្តានចិត្តដោយលំដាប់ និងដើម្បីប្រព្រឹត្តទៅក្នុងនិរោធ ។ ចំណែកវិបស្សនាពលៈ ដើម្បីសម្ដែងទោសក្នុងវដ្ដៈ និងដើម្បីសម្ដែងអានិសង្សក្នុងនិរោធ ។

បទថា **នីវរណោ** ជាសត្តមីវិភត្តិចុះក្នុងអត្ថនៃនិមិត្តសត្តមី ប្រែថា ព្រោះនីវរណៈ ។ អធិប្បាយថា មាននីវរណៈជានិមិត្ត មាននីវរណៈជាបច្ច័យ ។ ឬជាសត្តមីវិភត្តិ ចុះក្នុងអត្ថនៃតតិយាវិភត្តិ ប្រែថា ព្រោះនីវរណៈ ។

បទថា **ន កម្បតិ** មិនញាប់ញ័រ បានដល់ បុគ្គលអ្នកមានការព្រមព្រៀងក្នុងឈាន ។ ម្យ៉ាងវិញទៀត សមាធិសម្បយុត្តដោយឈាននោះ មិនញាប់ញ័រ ព្រោះនីវរណៈ ដោយបឋមឈាន ព្រោះលោកបំណងយកអង្គនៃឈានក្នុងបទថា **ឈានំ** ។ គប្បីកាន់យកការប្រកបនេះឯង ក្នុងនិទ្ទេសនេះ ។

បទថា **ឧទ្ធច្ចេ ច** ព្រោះឧទ្ធច្ចៈ គឺ ចិត្តុប្បាទសហគតៈដោយឧទ្ធច្ចៈ ។ ម្យ៉ាងទៀត បទថា **ឧទ្ធច្ចំ** បានដល់ សេចក្ដីរាយមាយ ។ ឧទ្ធច្ចៈនោះ មានការមិនស្ងប់ជាលក្ខណៈ ។

បទថា **ឧទ្ធច្ចសហគតកិលេសេ ច** ព្រោះកិលេសសហគតៈដោយឧទ្ធច្ចៈ បានដល់ ព្រោះកិលេស គឺ មោហៈ អហិរិកៈ អនោត្តប្បៈ ដែលសម្បយុត្តដោយឧទ្ធច្ចៈ ជាកិលេសកើតឡើងរួមគ្នា សហគតៈដោយឧទ្ធច្ចៈ ។ បទថា **ខន្ធេ ច** ព្រោះខន្ធ គឺ ព្រោះខន្ធ ៤ ដែលសម្បយុត្តដោយឧទ្ធច្ចៈ ។

បទថា **ន កម្បតិ ន ចលតិ ន វេធតិ** មិនកម្រើក មិនយោងយោង មិនញាប់ញ័រ ជាវេវចនៈដល់គ្នានឹងគ្នា ។ គប្បីប្រកបថា មិនកម្រើក ព្រោះឧទ្ធច្ចៈ ។ មិនយោងយោង ព្រោះកិលេសសហគតៈដោយឧទ្ធច្ចៈ ។ មិនញាប់ញ័រ ព្រោះខន្ធសហគតៈដោយឧទ្ធច្ចៈ ។ គប្បីជ្រាប វិបស្សនាពលៈថា ព្រោះលោកពោលអនុបស្សនា ៧ វិបស្សនាពលៈ ទើបបរិបូរណ៍ដោយអំណាចនៃអនុបស្សនានោះឯង ។

បទថា **អវិជ្ជាយ ច** ព្រោះអវិជ្ជា បានដល់ ព្រោះអវិជ្ជាក្នុងចិត្តុប្បាទ ដែលជាអកុសល ១២ យ៉ាង ។ បទថា **អវិជ្ជាសហគតកិលេសេ ច** ព្រោះកិលេសសហគតៈដោយអវិជ្ជា បានដល់ កិលេស គឺ លោភៈ ទោសៈ មានះ ទិដ្ឋិ វិចិកិច្ឆា ថីនៈ



ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ សម្បយុត្តដោយអវិជ្ជា ដែលគួរដល់ការប្រកបទុក ។

បទថា **វចីសង្ខារា** វចីសង្ខារ បានដល់ វិតក្កៈ និងវិចារៈ ។ ឈ្មោះថា **វចីសង្ខារា** ព្រោះអត្ថថា តាក់តែងឲ្យកើតវាចា ព្រោះបាលីថា **ម្នាលអាវុសោវិសាខ បុគ្គល ត្រិះរិះជាមុន ទើបថ្លែងវាចាជាខាងក្រោយ** ។ ព្រោះដូច្នោះ វិតក្កវិចារៈ ទើបជាវចីសង្ខារ ។

បទថា **កាយសង្ខារា** កាយសង្ខារ បានដល់ ខ្យល់អស្សាសបស្សាសៈ ។ ឈ្មោះថា **កាយសង្ខារា**(១) ព្រោះអត្ថថា ការតាក់តែងកាយ ព្រោះបាលីថា ម្នាលអាវុសោ **វិសាខ ធម៌ទាំងនេះ គឺ ខ្យល់អស្សាស ខ្យល់បស្សាស មានហើយក្នុងកាយ ទាក់ទងជាមួយកាយ** ។ ព្រោះដូច្នោះ ខ្យល់អស្សាសបស្សាសៈ ទើបជាកាយសង្ខារ ។

---

១ បាលីថា **កាយេន សំខរិយន្តីតិ កាយសង្ខារា** ( ដោយច្រើនប្រែថា តាក់តែងកាយ ) ។

បទថា **សញ្ញាវេទយិតនិរោធំ** សញ្ញាវេទយិតនិរោធ គឺរលត់សញ្ញា និងវេទនា ។ បទថា **ចិត្តសង្ខារា** ចិត្តសង្ខារបានដល់ សញ្ញា និងវេទនា ។ ឈ្មោះថា **ចិត្តសង្ខារា** [១] ព្រោះអត្ថថា ការតាក់តែងចិត្ត ព្រោះបាលីថា ចេតសិកធម៌ **ទាំងនេះ ទាក់ទងដោយចិត្ត** ។ ព្រោះដូច្នោះ សញ្ញា និង វេទនា ទើបជាចិត្តសង្ខារ ។

ក្នុងញាណចរិយាទាំងឡាយ គប្បីជ្រាបថា ចរិយាកថា ដែលជាខាងដើមនៃអនុបស្សនានោះ លោកពោលថា ញាណចរិយា ដោយអំណាចនៃអនុបស្សនា ឬដោយការកាន់យកនូវវិវដ្តនានុបស្សនា សូម្បីអនុបស្សនាដ៏សេស ក៏កាន់យកទុកហើយដែរ ។ បទថា **សោឡសហិ ញាណចរិយាហិ** ដោយញាណ- ចរិយា ១៦ ជាកំណត់យ៉ាងឧក្រិដ្ឋ ព្រោះព្រះអនាគាមីជាអ្នកមានកម្លាំងបរិបូរណ៍ដោយចរិយា ទាំង ១៤ នឹងបានសម្រេចអរហត្តមគ្គ និងអរហត្តផលតទៅ ។

១ ចិត្តេន សំខរិយន្តីតិ ចិត្តសង្ខារា ( ដោយច្រើនប្រែថា តាក់តែងចិត្ត )



ក្នុងបទថា **នវហិ សមាធិចរិយាហិ** ដោយសមាធិចរិយា ៩ នេះ គប្បីជ្រាបសេចក្តីដូចតទៅនេះ ចរិយា ៨ ដោយបឋមជ្ឈាន ជាដើម ។ ចរិយា ១ ដោយអំណាចនៃឧបចារឈានក្នុងធម៌ទាំងពួង ដើម្បីបានបឋមឈានជាដើម រួមជាសមាធិចរិយា ៩ ។ សួរថា ដោយសេចក្តីផ្សេងគ្នានៃពលចរិយា យ៉ាងណា ? ឆ្លើយថា សូម្បីក្នុងសមថពលៈ លោកក៏ពោលដល់ឧបចារសមាធិទុក ដោយបរិយាយ ៧ មានជា អាទិ៍ថា **នេក្ខម្មវសេន** ដោយអំណាចនៃនេក្ខម្មៈ ដោយសេចក្តី ពិស្តារនៃបេយ្យាល លោកពោលដល់អប្បនាសមាធិ និងឧបចារសមាធិ តាមសមគួរដោយវារៈ ៧០ បរិបូរណ៍ មានជាអាទិ៍ថា **បឋមជ្ឈានវសេន** ដោយអំណាចនៃបឋមឈាន ។ សូម្បីក្នុងសមាធិចរិយា លោកក៏ពោលដល់អប្បនាសមាធិទុក ដោយបរិយាយ ៨ មានជាអាទិ៍ថា **បឋមំ ឈានំ** ។

លោកពោលឧបចារសមាធិទុកដោយបរិយាយ ៨ មានជាអាទិ៍ថា **បឋមំ ឈានំ បដិលាភត្ថាយ** ដើម្បីប្រយោជន៍ដល់ការបានបឋមឈាន ព្រោះហេតុនោះ លោកទើបពោលអប្បនា-

សមាធិ និងឧបចារសមាធិទុកក្នុងទីទាំងពីរ ។ សូម្បីដូច្នោះ ក៏គប្បីជ្រាបថា ឈ្មោះថា ពលៈ ព្រោះអត្ថថា មិនញាប់ញ័រ ឈ្មោះថា **ចរិយា** ព្រោះអត្ថថា មានភាពជំនាញ ។ ម្យ៉ាងទៀត ក្នុងវិបស្សនាពលៈ លោកពោលអនុបស្សនា ៧ ថាវិបស្សនា-ពលៈ ។ និងពោលអនុបស្ស ៧ ទុកក្នុងញាណចរិយា ។ ទាំងលោកពោលអនុបស្សនា ៩ មានវិវដ្ដនានុបស្សនាជាដើម ឲ្យប្លែកអំពីគ្នា ។ នេះជាសេចក្ដីផ្សេងគ្នានៃអនុបស្សនាទាំងនោះ ។ ចំណែកអនុបស្សនា ៧ គប្បីជ្រាបថា ឈ្មោះថា ពលៈ ព្រោះអត្ថថា មិនញាប់ញ័រ ឈ្មោះថា ចរិយា ព្រោះអត្ថថា មានភាពជំនាញ ។ ដើម្បីឆ្លើយ វសីដែលលោកពោលទុកក្នុងបទនេះថា **វសីភាវតា បញ្ញា** បញ្ញារបស់អ្នកមានភាពជំនាញ ទើបលោកពោលជាឥត្ថីលិង្គថា **វសីតិ បញ្ច វសិយោ** ពាក្យថា វសី បានដល់ វសី ៥ ។ លោកអធិប្បាយថា ភាពជំនាញនោះឯងឈ្មោះថា **វសី** ។

ព្រះសារីបុត្តត្ថេរ កាលបើដោះស្រាយវសីទាំងនោះ ដោយសម្ដែងជាបុគ្គលាធិដ្ឋានទៀត ទើបពោលបទមានជាអាទិ៍ថា **អាវ-**



**ជ្ជនាវសី** ជំនាញក្នុងការនឹក ។ ឈ្មោះថា **អាវជ្ជនាវសី** ព្រោះមានភាពជំនាញក្នុងការនឹក ។ ក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

បទថា **បឋមំ ឈានំ យត្ថិច្ឆកំ** នឹកដល់បឋមឈានបានក្នុងពេលប្រាថ្នា សេចក្ដីថា សមាបត្តិលាភីបុគ្គល នឹកក្នុងប្រទេសដែលខ្លួនប្រាថ្នា ក្នុងស្រុកក៏ដោយ ក្នុងព្រៃក៏ដោយ ។

បទថា **យទិច្ឆកំ** ប្រាថ្នាក្នុងកាលណា សេចក្ដីថា នឹកក្នុងវេលាត្រជាក់ក៏ដោយ ក្ដៅក៏ដោយ ។ ម្យ៉ាងវិញទៀត នឹកដល់បឋមឈាន មានបឋវីកសិណជាអារម្មណ៍ក៏ដោយ មានកសិណដ៏សេសជាអារម្មណ៍ក៏ដោយ ។ ដោះស្រាយដូចមុនប្រសើរជាងព្រោះលោកពោលដល់ភាពជាអ្នកជំនាញក្នុងឈាន សូម្បីមានកសិណណាមួយជាអារម្មណ៍ទុកហើយ ។

បទថា **យាវតិច្ឆកំ** ប្រាថ្នាត្រឹមណា គឺ នឹកដល់កាលដែលប្រាថ្នាត្រឹមតែមួយផ្ទាត់ម្រាមដៃ ឬ ៧ ថ្ងៃ ។ បទថា **អាវជ្ជនាយ** ក្នុងការនឹក បានដល់ មនោទ្វារាវជ្ជនៈ ។

បទថា **ទន្ធាយិតត្តំ** ភាពយឺតយូរ គឺ ការមិនប្រព្រឹត្តទៅ

ក្នុងអំណាច ។ ឬភាពខ្ជិលច្រអូស ។

បទថា **សមាបជ្ជតិ** រមែងចូល គឺ រមែងបដិបត្តិ ។ អធិប្បាយថា រមែងតាំងស៊ប់ ។

បទថា **អធិដ្ឋាតិ** រមែងអធិដ្ឋាន គឺ តាំងចិត្តធ្វើឲ្យក្រៃលែងក្នុងខាងក្នុងសមាបត្តិ ។ បទថា **បឋមំ ឈានំ** ក្នុងវុដ្ឋានវសី ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃបញ្ចមីវិភត្តិ ប្រែថា ចេញចាកបឋមឈាន ។

បទថា **បច្ចវេក្ខតិ** រមែងពិចារណា គឺ ឃើញភ្លាម ៗ ដោយការស្ទុះទៅនៃការពិចារណា ។ នេះជាការពណ៌នាបាលីក្នុងបទនេះ ។

តទៅនេះជាការបង្ហាញសេចក្តី កាលព្រះយោគាវចរចេញចាកបឋមឈាន ហើយរឭកដល់វិតក្កៈ ជវនចិត្ត ៤ ឬ ៥ ដួងមានវិតក្កៈជាអារម្មណ៍ រមែងស្ទុះទៅក្នុងលំដាប់នៃអាវជ្ជនចិត្តដែលផ្តាច់ភវង្គប្រព្រឹត្តទៅ ។ បន្ទាប់ពីភវង្គចិត្ត ២ ដួង ស្ទុះទៅអាវជ្ជនចិត្តមានវិចារៈជាអារម្មណ៍ស្ទុះទៅ ដោយន័យដូចពោលហើយ ។ ព្រះយោគាវចរដាក់ចិត្តដោយលំដាប់ក្នុងអង្គឈាន ៥



ដោយប្រការដូច្នេះ ។ គ្រានេះ អាវជ្ជនវសីរបស់ព្រះយោគាវចរនោះ រមែងសម្រេចដោយពិត ។

ចំណែកវសីដែលដល់ទីបំផុតនេះ រមែងបានក្នុងយមកប្បាដិហារិយ៍របស់ព្រះមានព្រះភាគជាម្ចាស់ប៉ុណ្ណោះ ។ ក្រៅអំពីនេះ មិនមានអាវជ្ជនវសីដែលរហ័សជាងនេះ ។ ការប្រមាណក្នុងភវង្គវារៈក្នុងលំដាប់ ៗ មិនមានដល់អ្នកដទៃ ។ ភាពជាអ្នកអាចក្នុងការចូលសមាបត្តិបានរហ័ស ដូចក្នុងការទូន្មាននន្ទោបនន្ទនាគរបស់ព្រះមហាមោគ្គល្លានត្ថេរ ឈ្មោះថា **សមាបជ្ជនវសី** ។ ភាពជាអ្នកអាចដើម្បីតាំងសមាបត្តិ រហូតត្រឹមតែមួយខណៈផ្ទាត់ម្រាមដៃ ឬត្រឹម ១០ ម្រាមដៃ ឈ្មោះថា **អធិដ្ឋានវសី** ។

ម្យ៉ាងទៀត ភាពជាអ្នកអាចចេញរហ័សជាងនោះ ឈ្មោះថា **វុដ្ឋានវសី** ។ ចំណែកបច្ចវេក្ខណវសី លោកពោលទុកហើយក្នុងអាវជ្ជនវសីនោះឯង ។ ព្រោះថា បច្ចវេក្ខណជវន ជាលំដាប់នៃអាវជ្ជនៈក្នុងអាវជ្ជនវសីនោះ ។ បច្ចវេក្ខវសី សម្រេចដោយការសម្រេចនៃអាវជ្ជនវសី ដោយប្រការដូច្នេះ ។ និងវុដ្ឋានវសីជាការសម្រេច ដោយការសម្រេចនៃអធិដ្ឋានវសី ។

សូម្បីដូច្នេះក៏ដោយ ភាពជាអ្នកអាចក្នុងការញ៉ាំងអាវជ្ជនៈ ឲ្យប្រព្រឹត្តទៅដោយន័យដូចពោលហើយ ក្នុងកសិណនោះលឿនរហ័សតាមប្រាថ្នារបស់អ្នកបំណងនឹងចូលឈាន មានកសិណនោះ ៗ ជាអារម្មណ៍ ព្រោះការសម្រេចដោយអំណាចកសិណផ្សេង ៗ របស់អ្នកនិមិត្តជាភេទច្រើនយ៉ាងជាដើម ព្រោះមិនមានបច្ចវេក្ខណៈដែលជាអន្តឈាន ក្នុងពេលសម្តែងបាដិហារិយ៍ ព្រោះលោកពោលទុកហើយថា វសីដែលដល់ទីបំផុតនេះ រមែងបានក្នុងយមកបាដិហារិយ៍របស់ ព្រះមានព្រះភាគជាម្ចាស់ប៉ុណ្ណោះ ឈ្មោះថា អាវជ្ជនវសី ។

ភាពជាអ្នកអាចក្នុងអប្បនា និងភាពជាអ្នកអាចចូលឈាននោះ ក្នុងវីថិនៃអាវជ្ជនៈក្នុងកាលនោះ ឈ្មោះថា សមាបជ្ជនវសី ។ កាលបើពោលយ៉ាងនេះ ជាការត្រឹមត្រូវនឹងមិនខុស ។ ម្យ៉ាងទៀត លំដាប់នៃវសី រមែងគួរតាមលំដាប់នោះឯង ។ ម្យ៉ាងទៀត ក្នុងការពិចារណាអន្តនៃឈាន ព្រោះលោកពោលទុកថា ជវនចិត្ត ៥ ដួង ដល់ទីបំផុតហើយ សូម្បីកាលជវនចិត្ត ៧ ដួង ស្ទុះទៅ ដោយន័យដូចពោលហើយ ក៏រមែងជាបច្ចវេ-



ក្ខណវសីដូចគ្នា ។

បើដូច្នោះលោកពោលថា ពាក្យថា នឹកដល់បឋមជ្ឈាន រមែងមិនត្រឹមត្រូវ ។ លោកពោលឈានប្រព្រឹត្តទៅក្នុងកសិណថា ជាកសិណដែលជាឧបចារៈរបស់ហេតុ យ៉ាងណា ។ លោកពោលកសិណមានឈានជាបច្ច័យ ក៏ដូច្នោះ ថាជាឈានដោយជាឧបចារៈនៃផល ដូចក្នុពាក្យមានជាអាទិ៍ថា **សុខោ ពុទ្ធានមុប្បាទោ**[១] ការកើតឡើងនៃព្រះពុទ្ធជាម្ចាស់ទាំងឡាយ នាំមកនូវសេចក្តីសុខ ។ សូម្បីបើមានការឈានចុះកាន់ឈានទៀត ដូចបុគ្គលដែលភ្ញាក់ពីការដេកលក់ លក់តាម កាលដែលកំណត់ទុក ហើយឈានចុះកាន់ការដេកលក់ម្តងទៀត ឈ្មោះថា អធិដ្ឋានវសី ។ សូម្បីបើមានការ អធិដ្ឋានក្នុងការក្រោកឡើង របស់អ្នកក្រោកឡើងតាមកាលដែលកំណត់ ក៏ឈ្មោះថា **វុដ្ឋានវសី** ។ នេះជាសេចក្តីផ្សេងគ្នារបស់វសីទាំងនោះ ដោយប្រការដូច្នេះ ។

ដើម្បីបញ្ជាក់ដល់និរោធសមាបត្តិ ទើបមានបញ្ហាដូចតទៅ

---

(១) ខុទ្ទកនិកាយ ធម្មបទ

នេះ និរោធសមាបត្តិ យ៉ាងដូចម្ដេច ។ នរណាចូលនិរោធសមាបត្តិនោះ ។ នរណាមិនចូល ។ ចូលក្នុងទីណា ។ ព្រោះហេតុអ្វីទើបចូល ។ យ៉ាងណាទើបជាការចូលនិរោធសមាបត្តិនោះ ។ តាំងនៅយ៉ាងណា ។ ចេញយ៉ាងណា ។ អ្នកចេញមានចិត្តបង្អោនទៅកាន់អ្វី ។ មនុស្សស្លាប់ និងមនុស្សចូលនិរោធសមាបត្តិផ្សេងគ្នាយ៉ាងណា ។ និរោធសមាបត្តិ ជាសង្ខតៈ ឬអសង្ខតៈ ជាលោកិយៈ ឬលោកុត្តរៈ ជានិប្ផន្នៈ ( សម្រេច ) ឬអនិប្ផន្នៈ ( មិនសម្រេច ) ។

ក្នុងបញ្ហាកម្មទាំងនោះ បទថា **កា និរោធសមាបត្តិ** និរោធសមាបត្តិដូចម្ដេច គឺ ចិត្ត ចេតសិកធម៌ទាំងឡាយមិនប្រព្រឹត្តទៅដោយអំណាចនៃអនុបុព្វនិរោធ គឺ និរោធតាមលំដាប់ ។ ឈ្មោះថា និរោធសមាបត្តិ ។

បទថា **កេ តំ សមាបជ្ជន្តិ , កេ ន សមាបជ្ជន្តិ** នរណាចូលនិរោធសមាបត្តិនោះ នរណាមិនចូល គឺ បុថុជ្ជនទាំងអស់ ព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី ព្រះអរហន្តដែលជាសុក្ខវិបស្សកៈ មិនអាចចូលបាន ។ ចំណែកព្រះអនាគាមីដែល



បានសមាបត្តិ ៨ និងព្រះខីណាស្រព ចូលបាន ។

បទថា **កត្ថ សមាបជ្ជន្តិ** ចូលក្នុងទីណា ? គឺ ក្នុងភពដែលមានខន្ធ ៥ ។ ព្រោះហេតុអ្វី ? ព្រោះមានសមាបត្តិតាមលំដាប់ ។ ចំណែកក្នុងភព គឺ ខន្ធ ៤ បឋមជ្ឈានជាដើម មិនមានការកើតបានឡើយ ។ ព្រោះដូច្នោះ ទើបមិនអាចចូលក្នុងភពនោះបាន ។

បទថា **កស្មា សមាបជ្ជន្តិ** ព្រោះហេតុអ្វីទើបចូល ? គឺ ជាអ្នកនឿយណាយក្នុងការប្រព្រឹត្តទៅរបស់សង្ខារ មិនជាប់នៅក្នុងទិដ្ឋធម៌ ទើបចូល ដោយគិតថា យើងដល់និព្វានដែលស្ងប់ហើយ នឹងនៅជាសុខ ។

បទថា **កថញ្ចស្សា សមាបជ្ជនំ ហោតិ** យ៉ាងណាទើបជាការចូលនិរោធសមាបត្តិនោះ ? គឺ កាលបើខ្វល់ខ្វាយ ដោយអំណាចសមថវិបស្សនា ហើយធ្វើកិច្ចជាខាងដើម ញ៉ាំងនេវសញ្ញានាសញ្ញាយតនៈឲ្យរលត់ ជាការចូលនិរោធសមាបត្តិដោយអាការយ៉ាងនេះ ។ ព្រោះអ្នកណាខ្វល់ខ្វាយដោយអំណាចនៃសមថៈប៉ុណ្ណោះ អ្នកនោះសម្រេចនេវសញ្ញានាសញ្ញាយតនសមាបត្តិហើយ

តាំងនៅ ។ ចំណែកអ្នកណាខ្វល់ខ្វាយដោយអំណាចវិបស្សនាប៉ុណ្ណោះ ។ អ្នកនោះ សម្រេចផលសមាបត្តិហើយតាំងនៅ ។ ម្យ៉ាងទៀត អ្នកណាខ្វល់ខ្វាយដោយអំណាចទាំងពីរយ៉ាង រមែងញុំាងនេវសញ្ញានាសញ្ញាយតនៈឲ្យរលត់ ។ អ្នកនោះឈ្មោះថា រមែងចូលដល់និរោធសមាបត្តិ នេះជាសេចក្តីសង្ខេបក្នុងបទនេះ ។

ចំណែកសេចក្តីពិស្តារ គប្បីជ្រាបដូចតទៅនេះ ភិក្ខុក្នុងសាសនានេះ បំណងនឹងចូលនិរោធ ឆាន់អាហារស្រេចហើយ លាងដៃ និងជើង អង្គុយចម្រើនសមាធិលើអាសនៈ ដែលក្រាលទុកយ៉ាងល្អក្នុងទីស្ងាត់ តាំងកាយឲ្យត្រង់តម្រង់សតិទុកចំពោះមុខ ។ ភិក្ខុនោះចូលបឋមជ្ឈាន លុះចេញហើយ ពិចារណាឃើញច្បាស់សង្ខារទាំងឡាយថា មិនទៀង ជាទុក្ខ ជាអនត្តា ក្នុងទីកន្លែងនោះ ។

ក៏វិបស្សនានោះ មាន ៣ យ៉ាង គឺ **សង្ខារបរិគ្គណ្ហណកវិបស្សនា** វិបស្សនាកំណត់សង្ខារ ១ , **ផលសមាបត្តិវិបស្សនា** វិបស្សនាដែលជាផលសមាបត្តិ ១ , **និរោធសមាបត្តិវិបស្សនា** វិបស្សនាដែលជានិរោធសមាបត្តិ ១ ។



ក្នុងវិបស្សនា ៣ យ៉ាងនោះ សង្ខារបរិគ្គណ្ហណកវិបស្សនា ទន់ខ្ចី ឬចាស់ក្លាក៏ដោយ រមែងជាបទដ្ឋាននៃមគ្គនោះឯង ។ ផលសមាបត្តិវិបស្សនាចាស់ក្លា ដូចគ្នានឹងមគ្គភាវនា ទើបគួរ ។ ចំណែកនិរោធសមាបត្តិវិបស្សនា មិនទន់ខ្ចីពេក មិនចាស់ក្លាពេកនោះឯងទើបគួរ ។ ព្រោះដូច្នោះ ភិក្ខុនោះទើបពិចារណាឃើញច្បាស់សង្ខារទាំងនោះ ដោយវិបស្សនាដែលមិនទន់ខ្ចីពេក មិនចាស់ក្លាពេក រួចចូល ទុតិយជ្ឈាន លុះចេញហើយពិចារណាឃើញច្បាស់សង្ខារទាំងឡាយ ក្នុងទុតិយជ្ឈាននោះ ។ បន្ទាប់ពីនោះ ទើបចូលតតិយជ្ឈាន ។ល។ ក៏ចូលវិញ្ញាណញ្ចាយតនៈ លុះចេញហើយ ពិចារណាឃើញច្បាស់នូវសង្ខារទាំងឡាយ ក្នុងវិញ្ញាណញ្ចាយតនៈនោះ ។ ឬន័យម្យ៉ាងទៀត ភិក្ខុនោះចូលអាកិញ្ចញ្ញាយតនៈ លុះចេញហើយ ក៏ធ្វើកិច្ចខាងដើម ៤ យ៉ាង គឺ ៖

**នានាពន្ធអវិកោបន ១**

**សង្ឃបដិមានន ១**

**សត្ថុបកោសន ១**

## អទ្ធានបរិច្ឆេទ ១

ក្នុងកិច្ច ៤ យ៉ាងនោះ បទថា **នានាពន្ធអវិកោបនំ** មិនឲ្យរបស់ប្រើប្រាសផ្សេង ៗ ដែលខូច សេចក្តីថា វត្ថុណាដែលមិនមែនជារបស់ប្រើប្រាស ជាប់ទាក់ទងជាមួយគ្នានឹង ភិក្ខុនេះ មានរបស់ប្រើផ្សេង ៗ ដែលតាំងទុក ដូចជា បាត្រ ចីវរ គ្រែ តាំងទីនៅអាស្រ័យ ឬសូម្បីបរិក្ខារណា ៗ ដទៃ , មិនឲ្យបាត់បង់របស់នោះ ។ មិនឲ្យខូចបង់ទៅដោយ ភ្លើង ទឹក ខ្យល់ ចោរ និងសត្វកណ្តុលជាដើម ដោយប្រការណា គប្បីអធិដ្ឋានដោយប្រការនេះ ។ វិធីអធិដ្ឋានពោលដូច្នេះ ក្នុងរវាង ៧ ថ្ងៃនេះ សូមរបស់នេះ ៗ ចូរកុំត្រូវភ្លើងឆេះ , កុំត្រូវទឹកបន្សាត់នាំទៅ , កុំឲ្យខ្យល់បក់ផាត់ទៅ , កុំត្រូវចោរលួចយក , កុំត្រូវពពួកសត្វកណ្តុរបំផ្លាញជាដើម ។ កាលបើអធិដ្ឋានយ៉ាងនេះរហូត ៧ ថ្ងៃនោះ នឹងមិនមានអន្តរាយណា ៗ ដល់វត្ថុទាំងនោះ ។ តែបើមិនបានអធិដ្ឋាន នឹងវិនាសដោយភ្លើងជាដើម ។ នេះឈ្មោះថា នានាព័ន្ធអវិកោបនៈ ។ តែវត្ថុណាដែលប្រើប្រាសជាប់នឹងខ្លួន ដូចជា សំពត់ស្លៀកសំពត់ដណ្តប់ ទីអង្គុយ ក្នុងវត្ថុនោះមិនមាន



កិច្ចនឹងអធិដ្ឋានផ្សេងទៀតឡើយ ។ សមាបត្តិនោះឯង រមែងរក្សាវត្ថុទាំងនោះឯង ។

បទថា **សង្ឃបដិមាននំ** ការរាប់អានរបស់សង្ឃ បានដល់ការរាប់អាន គឺ ការរង់ចាំមើលរបស់ភិក្ខុសង្ឃ ។ អធិប្បាយថា មិនធ្វើសង្ឃកម្មមុននឹងភិក្ខុនោះមក ។ ម្យ៉ាងទៀត ក្នុងបទនេះ ការរាប់អាន មិនមែនជាបុព្វកិច្ចរបស់ភិក្ខុនេះ ។ តែការនឹកដល់ការរាប់អានជាបុព្វកិច្ច ព្រោះដូច្នោះគួរនឹកដល់យ៉ាងនេះថា ប្រសិនបើក្នុងរវាង ៧ ថ្ងៃ ពេលចូលនិរោធ សង្ឃបំណងនឹងធ្វើកម្មណាមួយ ក្នុងអបលោកនកម្មជាដើម ។ យើងនឹងចេញដោយមិនចាំបាច់ភិក្ខុណាមួយមកហៅ ។ ក៏ភិក្ខុធ្វើយ៉ាងនេះហើយ ទើបចូលសមាបត្តិ រមែងចេញបាន ក្នុងសម័យនោះ ៗ ឯង ។ តែភិក្ខុណាមិនបានធ្វើយ៉ាងនេះ ។ ទាំងសង្ឃក៏ប្រជុំគ្នាហើយ បើមិនឃើញភិក្ខុនោះ ទើបសួរថា ភិក្ខុរូបឯណោះទៅណា បើឆ្លើយថា កំពុងចូលសមាបត្តិ ទើបបញ្ជូនភិក្ខុមួយរូបទៅថា លោកចូរទៅហៅភិក្ខុនោះតាមពាក្យសង្ឃ ។ លំដាប់នោះ ត្រឹមពាក្យដែលភិក្ខុនោះឈរនៅ ក្នុងទីជិតល្មមនឹងបានឮ ពោលថា អាវុសោ

សង្ឃរង់ចាំលោក ប៉ុណ្ណោះ ដូច្នេះ ភិក្ខុនោះក៏ចេញពីនិរោធ ។ ព្រោះថា ឈ្មោះថា **អាណា** គឺ អំណាចរបស់សង្ឃធ្ងន់យ៉ាងនេះ ។ ដូច្នោះ គប្បីចូលនិរោធ ដោយអាការដែលភិក្ខុនឹកដល់ហើយ ចេញចាកនិរោធមុន ។

បទថា **សត្ថុ បក្កោសនំ** ព្រះសាស្ដាត្រាស់ហៅរក សូម្បីក្នុងបទនេះ ការនឹកដល់ ការហៅរករបស់ព្រះសាស្ដា ក៏ជាបុព្វ-កិច្ចរបស់ភិក្ខុនេះ ព្រោះដូច្នោះ គប្បីនឹកដល់បុព្វកិច្ចនោះ យ៉ាងនេះថា ប្រសិនបើយើងចូលនិរោធរហូត ៧ ថ្ងៃ ។ ព្រះសាស្ដាទ្រង់បញ្ញត្តិសិក្ខាបទ ព្រោះរឿងដែលល្មើស ។ ឬទ្រង់សម្ដែងធម៌ ព្រោះហេតុដែលកើតរឿងនោះឯង ។ យើងនឹងចេញ ដោយមិនចាំបាច់ភិក្ខុណាមួយមកហៅយើង ។ ភិក្ខុនោះឯង រមែងចេញក្នុងសម័យនោះឯង ។ មយ៉ាងទៀត ភិក្ខុណាមិនធ្វើយ៉ាងនោះ ។ ទាំងព្រះសាស្ដា កាលបើសង្ឃប្រជុំគ្នា ទ្រង់មិនឃើញភិក្ខុនោះ ត្រាស់សួរថា ភិក្ខុអង្គនោះទៅណា កាលក្រាបទូលថា ចូលនិរោធ ទ្រង់ទើបបញ្ជូនភិក្ខុមួយរូបទៅថា អ្នកចូរទៅហៅភិក្ខុនោះ តាមពាក្យរបស់តថាគត ។ ត្រឹមតែភិក្ខុនោះឈរនៅ



ក្នុងទីជិត ល្មមពោលឮថា ព្រះសាស្ដាត្រាស់ហៅរកលោកម្ចាស់ ដូច្នេះ ប៉ុណ្ណោះ ភិក្ខុនោះក៏បានចេញចាកនិរោធ ។ ព្រោះថា ការត្រាស់ហៅរករបស់ព្រះសាស្ដា គឺ ជារឿងដ៏ធ្ងន់យ៉ាងនេះ ។ ដូច្នោះគប្បីចូលនិរោធ ដោយអាការដែលភិក្ខុនោះនឹកដល់ហើយ ចេញមុននោះឯង ។

បទថា **អទ្ធានបរិច្ឆេទោ** កំណត់កាល គឺ កំណត់កាលរបស់ជីវិត ។ ពិតហើយ ភិក្ខុនេះគួរជាអ្នកឆ្លាតក្នុងការកំណត់កាល ។ គួរនឹកថា អាយុសង្ខាររបស់ខ្លួននឹងប្រព្រឹត្តទៅបានរហូត ៧ ថ្ងៃឬទេ ។ ឬប្រព្រឹត្តទៅមិនបាន ហើយចូលនិរោធ ។ ព្រោះថា បើអាយុសង្ខាររលត់ក្នុងចន្លោះ ៧ ថ្ងៃ ។ ភិក្ខុមិនគប្បីចូលនិរោធ ។ និរោធរបស់ភិក្ខុនោះ មិនអាចហាមសេចក្ដីស្លាប់បាន ។ ភិក្ខុរមែងចេញចាកសមាបត្តិក្នុងចន្លោះបាន ព្រោះនៅក្នុងនិរោធក៏មិនមានសេចក្ដីស្លាប់ ។ ដូច្នោះគួរនឹកដល់កាលនោះ ហើយទើបចូលនិរោធ ។ សូម្បីមិននឹកដល់កាលដ៏សេស ក៏គួរ ។ តែគួរនឹកដល់កាលនេះ តែម្យ៉ាង ។ លោកអធិប្បាយទុកដូច្នេះ ។

ភិក្ខុនោះចូល អាកិញ្ចញ្ញាយតនៈយ៉ាងនេះហើយ លុះចេញហើយ ក៏ធ្វើបុព្វកិច្ចនេះ រមែងចូលដល់នេវសញ្ញានាសញ្ញាយតនៈបាន លុះឈានកន្លងវារៈចិត្តមួយ ឬពីរហើយ ក៏ជាអចិត្តកៈ រមែងពាល់ត្រូវនិរោធបាន ។ សួរថា ក៏ព្រោះហេតុអ្វី ចិត្តខាងលើ គឺលើសចិត្តពីរជួងទើបប្រព្រឹត្តទៅមិនបាន [១] ។ ឆ្លើយថា ព្រោះជាបយោគនៃនិរោធ ។ ពិតណាស់ ការធ្វើសមថៈ និងវិបស្សនាទាំងពីររបស់ភិក្ខុនោះ ឲ្យជាយុគនទ្ធៈ គឺ ធម៌ដែលជាគូនេះ ហើយឡើងកាន់សមាបត្តិ ៨ ជាសេចក្ដីខ្វល់ខ្វាយ របស់និរោធតាមលំដាប់ ។ មិនមែនព្រោះនេវសញ្ញានាសញ្ញាយតនសមាបត្តិ ព្រោះហេតុនោះ ចិត្តទាំងឡាយ ទើបមិនប្រព្រឹត្តទៅខាងលើចិត្តពីរជួង ព្រោះជាបយោគៈនៃនិរោធ ។

បទថា **កថំ ឋានំ** តាំងនៅយ៉ាងណា គឺ តាំងនៅដោយអំណាចកំណត់កាលនៃសមាបត្តិនោះ ដែលចូលដល់ព្រមហើយ

---

( ១ ) ន័យថា ក្នុងខណៈដែលចូលនិរោធសមាបត្តិ ចតុត្ថអរូបជ្ឈានសមាបត្តិកើតឡើង ២ ដង ហើយក៏ដល់និរោធ ។



យ៉ាងនេះ និងដោយមិនមានអាយុក្ខ័យ ការរង់ចាំរបស់សង្ឃ និងការត្រាស់ហៅរករបស់ព្រះសាស្ដាក្នុងចន្លោះនោះ ។

បទថា **កថំ វុដ្ឋានំ** ចេញយ៉ាងណា បានដល់ ចេញ ២ យ៉ាងនេះ គឺ ដោយអនាគាមិផលសមាបត្តិ ១ ដោយអរហត្តផលសមាបត្តិរបស់ព្រះអរហន្ត ១ ។

បទថា **វុដ្ឋិតស្ស កិន្និន្នំ ចិត្តំ ហោតិ** ចិត្តរបស់អ្នកចេញចាកហើយ បង្អោនទៅកាន់អ្វី សេចក្ដីថា បង្អោនទៅកាន់និព្វាន ។ សមដូចព្រះមានព្រះភាគត្រាស់ទុកថា ៖

ម្នាលអាវុសោវិសាខៈ ចិត្តរបស់
ភិក្ខុអ្នកចេញចាកសញ្ញាវេទយិតនិរោធ
សមាបត្តិ បង្អោនទៅកាន់វិវេក ទោរ
ទៅកាន់វិវេក ផ្ទាកទៅកាន់វិវេក ។

បទថា **មតស្ស ច សមាបន្នស្ស ច កោ វិសេសោ** អ្នកស្លាប់ហើយ និងអ្នកចូលនិរោធ ផ្សេងគ្នាដូចម្ដេច លោកពោលសេចក្ដីនេះទុកហើយក្នុងព្រះសូត្រ សមដូចព្រះមានព្រះភាគត្រាស់ទុកថា ៖

ម្នាលអាវុសោ កាយសង្ខាររបស់អ្នកស្លាប់ហើយ ធ្វើមរណកាលហើយ រលត់ស្ងប់ ។ វចីសង្ខារ ចិត្តសង្ខារ រលត់ ស្ងប់ ។ អាយុអស់ទៅ ។ ភ្លើអធាតុស្ងប់ទៅ ។ ឥន្ទ្រិយ៍បែកធ្លាយទៅ ។ សូម្បីកាយសង្ខាររបស់ភិក្ខុអ្នកចូលសញ្ញាវេទយិតនិរោធ ក៏រលត់ ស្ងប់ ។ វចីសង្ខារ ចិត្តសង្ខារ ក៏រលត់ ស្ងប់ ។ អាយុនៅមិនទាន់អស់ ។ ភ្លើងធាតុមិនស្ងប់ ។ ឥន្ទ្រិយ៍មិនបែកធ្លាយ ។

ក្នុងពាក្យសួរមានជាអាទិ៍ថា **និរោធសមាបត្តិ** គឺ **សង្ខតា អសង្ខតា** និរោធសមាបត្តិជាសង្ខតៈ ឬអសង្ខតៈ ? មានអធិប្បាយដូចតទៅនេះ មិនគួរពោលថា ជាសង្ខតៈខ្លះ អសង្ខតៈខ្លះ លោកិយៈខ្លះ លោកុត្តរៈខ្លះ ។ ព្រោះហេតុអ្វី ? ព្រោះមិនមានដោយសភាវៈ ។ ព្រោះភិក្ខុ ឈ្មោះថា ជាអ្នកចូលដល់ព្រមហើយដោយអំណាចនៃការចូលនិរោធ ។ ដូច្នោះ គួរពោលថា ជានិប្ផន្នៈ គឺ សម្រេចហើយ មិនគួរពោលថា ជាអនិប្ផន្នៈ គឺ មិនសម្រេច ។



សមាបត្តិដែលស្ងប់ហើយ ដែលព្រះអរិយសេពហើយនេះឈ្មោះថា និព្វាន ក្នុងទិដ្ឋធម៌ដោយប្រការដូច្នេះ ។

( ចប់ អដ្ឋកថានិរោធសមាបត្តិញ្ញាណនិទ្ទេស )

## អដ្ឋកថា បរិនិព្វានញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងបរិនិព្វានញ្ញាណនិទ្ទេស ដូចតទៅនេះ ។ បទថា **ឥធ** គឺ ក្នុងសាសនានេះ ។ បទថា **សម្បជានោ** អ្នកដឹងខ្លួន សេចក្តីថា អ្នកដឹងខ្លួនដោយ **សម្បជញ្ញ** ៤ ទាំងនេះ គឺ ៈ-

**សាត្ថកសម្បជញ្ញ** សេចក្តីដឹងខ្លួនក្នុងកិច្ចដែលជាប្រយោជន៍ដល់ខ្លួន ១ ។

**សប្បាយសម្បជញ្ញ** សេចក្តីដឹងខ្លួនក្នុងបច្ច័យដែលសប្បាយ ១ ។

**គោចរសម្បជញ្ញ** សេចក្តីដឹងខ្លួនក្នុងធម៌ដែលជាគោចរ ១ ។

**អសម្មោហសម្បជញ្ញ** សេចក្តីដឹងខ្លួនក្នុងការមិនវង្វេង ១ ។

បទថា **បវត្តំ** ការប្រព្រឹត្តទៅ គឺ ការប្រព្រឹត្តទៅនៃបរិយុដ្ឋានកិលេស និងការប្រព្រឹត្តទៅនៃអនុស័យកិលេសតាមសមគួរក្នុងទីទាំងពួង ។

បទថា **បរិយាទិយតិ** ឲ្យអស់ទៅ គឺ ធ្វើឲ្យប្រព្រឹត្តទៅមិនបាន ដោយអំណាចនៃវិក្ខម្ភនប្បហានក្នុងធម៌ទាំងឡាយ ដែលលោកពោលដោយអំណាចនៃឧបចារៈ និងអប្បនា ។ ដោយអំណាចនៃតទង្គប្បហានក្នុងធម៌ទាំងឡាយ ដែលលោកពោលដោយអំណាចនៃវិបស្សនា ។ ដោយអំណាចនៃសមុច្ឆេទប្បហាន ក្នុងធម៌ទាំងឡាយដែលលោកពោលដោយអំណាចនៃមគ្គ ។ ពិតណាស់លោកសង្ខេបឈានសមាបត្តិ មានទុតិយជ្ឈានជាដើម មហាវិបស្សនា និងមគ្គ ទុកដោយមាតិកាបេយ្យាល ។ ព្រោះញាណដែលប្រព្រឹត្តទៅហើយ ដល់អ្នកពិចារណាញាណនោះ ឈ្មោះថា **បរិនិព្វានញ្ញាណ** ។ ដូច្នោះ ទើបលោកពោលទុកថា **វិក្ខម្ភនប្បរិនិព្វានំ** បរិនិព្វានដោយការគ្របសង្កត់ទុក , **តទង្គប្បរិនិព្វានំ** បរិនិព្វានដោយអង្គនៃធម៌នោះ ។ **សមុច្ឆេទប្បរិនិព្វានំ** បរិនិព្វានដោយដាច់ខាត ។ ដោយបទទាំងនេះ លោកទើបពោលដល់



បច្ចវេក្ខណញ្ញាណក្នុងការរំលត់កិលេស ។

ដោយបទមានជាអាទិ៍ថា **អថវា បន** ប្រការមួយទៀត ព្រះសារីបុត្តត្ថេរ សម្តែងដល់បច្ចវេក្ខណញ្ញាណ ក្នុងការរំលត់ខន្ធ ។

បទថា **អនុបាទិសេសាយ និព្វានធាតុយា** ដោយអនុបាទិសេសនិព្វានធាតុ បានដល់ ព្រោះនិព្វានធាតុ មាន ២ យ៉ាង គឺ សឧបាទិសេសនិព្វានធាតុ ១ , អនុបាទិសេសនិព្វានធាតុ ១ ។ ក្នុងនិព្វានធាតុ ២ យ៉ាងនោះ ឈ្មោះថា **ឧបាទិ** ព្រោះអត្ថថា ដែលបុគ្គលដល់នោះ គឺ ប្រកាន់យ៉ាងខ្ជាំងក្ខាថា យើង របស់យើង ។ បទថា ឧបាទិនេះ ជាឈ្មោះ របស់ខន្ធបញ្ចកៈ ។

ឈ្មោះថា **ឧបាទិសេស** ព្រោះអត្ថថា ឧបាទិនោះឯង នៅសេសសល់ ។

ឈ្មោះថា **សឧបាទិសេស** ព្រោះអត្ថថា ប្រព្រឹត្តទៅជាមួយនឹងឧបាទិសេសៈ គឺ ខន្ធ ៥ ដែលសល់ ។

ឈ្មោះថា **អនុបាទិសេស** ព្រោះអត្ថថា មិនមានឧបាទិសេសៈ ក្នុងនិព្វានធាតុនេះ ។

លោកពោលដល់សឧបាទិសេសៈមុន ចំណែកនិព្វានធាតុនេះ ជាអនុបាទិសេសៈ ។ ដោយអនុបាទិសេសនិព្វានធាតុនោះ ។

បទថា **ចក្ខុបវត្តំ** ការប្រព្រឹត្តិទៅនៃភ្នែក គឺ ការប្រាកដកើតឡើងផ្លូវភ្នែក ។

បទថា **បរិយាទិយតិ** បានដល់ រមែងអស់ទៅ គឺ ត្រូវញាំញី ។ ក្នុងបទដ៏សេសមានន័យនេះ ។

( ចប់ អដ្ឋកថាបរិនិព្វានញ្ញាណនិទ្ទេស )



# អដ្ឋកថា សមសីសដ្ឋញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងសមសីសដ្ឋញ្ញាណនិទ្ទេស ដូចតទៅនេះ គប្បីជ្រាបការសង្គ្រោះទាំងអស់ ដោយពួក១០ មានជាអាទិ៍ថា **បញ្ចក្ខន្ធា** ខន្ធទាំងឡាយ ៥ ។ ពិតណាស់ លោកមិនបានចាត់ធម៌ទាំងអស់ទុកមួយ ៗ ផ្នែក ដោយពួក ៨ ដ៏សេសវៀរពួកអាយតនៈ ធាតុ ដោយអំណាចធម៌ពួកមួយ ៗ ។ ក៏ព្រោះលោកុត្តរធម៌ មិនមែនជាធម៌ដែលគួរលះ ដោយការកាត់ផ្តាច់ហេតុដូច្នោះលោកុត្តរធម៌ សូម្បីលោកសង្គ្រោះចូល ដោយស័ព្ទថា **សព្វធម្មា** ក៏មិនគប្បីកាន់យកក្នុងទីនេះ ព្រោះមានពាក្យថា **សមុច្ឆេទ** គួរកាន់យកតេភូមិកធម៌ដែលគួរលះ ដោយកាកាត់ផ្តាច់ហេតុ ។

បទថា **សម្មា សមុច្ឆិន្ទតិ** កាត់ផ្តាច់ដោយល្អ សេចក្តីថា កាលបើរំលត់បរិយុដ្ឋានកិលេស និងអនុស័យកិលេស ដោយអំណាចនៃវិក្ខម្ភនប្បហាន តទង្គប្បហាន និងសមុច្ឆេទប្បហានតាមសមគួរ ឈ្មោះថា កាត់ផ្តាច់ដោយល្អ ។ លោកសម្តែងការ

កាត់ផ្តាច់ដោយប្រពៃ ដោយទេសនាជាបុគ្គលាធិដ្ឋានយ៉ាងនេះ ។

បទថា **និរោធេតិ** ឲ្យរលត់ គឺ ឲ្យរលត់ដោយអនុប្បាទនិរោធ រលត់ដោយមិនមានកើតឡើង ។ បទនេះ លោកពោលដល់អត្ថនៃសមុច្ឆេទ ។

បទថា **ន ឧបដ្ឋាតិ** រមែងមិនប្រាកដ សេចក្តីថា បើរលត់យ៉ាងនេះហើយ ធម៌នោះ ៗ ក៏មិនប្រាកដកើតឡើងទៀត គឺ មិនកើតឡើង ។ បទនេះ លោកពោលដល់អត្ថនៃនិរោធ ។ លោកសម្តែងដល់ការមិនប្រាកដ ដោយអំណាចនៃធម៌ដែលមិនប្រាកដ ។

បទថា **សមំ** សេចក្តីស្ងប់ គឺ ឈ្មោះថា **ស្ងប់** ព្រោះកាមច្ឆន្ទៈជាដើមស្ងប់ ។ ធម៌ ៣៧ គឺ ធម៌ ៧ មាននេក្ខម្មៈជាដើមទាំងនោះ រូបឈាន.អរូបឈាន ៨ , មហាវិបស្សនា ១៨ , អរិយមគ្គ ៤ ។

លោកពោលធម៌ជាប្រធាន គឺ **សីសៈ** ១៣ ប្រការ ដោយអំណាចនៃការសង្គ្រោះធម៌ទាំងអស់ដែលជាសីសៈ តែក្នុងទីនេះធម៌ជាប្រធាន ៨ មានសទ្ធាជាដើមរមែងគួរ ។ ព្រោះធម៌ជាប្រធាន ៥ មានតណ្ហាជាដើម មិនមានដល់ព្រះអរហន្ត ។



បទថា **បលិពោធសីសំ** មានសេចក្តីកង្វល់ជាប្រធាន គឺ មានការហួងហែងជាកង្វល់ ។ អធិប្បាយថា ជាគ្រឿងបិទផ្លូវទៅនិព្វាន ។ បទថា **សីសំ** ជាប្រធាន គឺ ជាធម៌ដ៏ក្រៃលែង ។ បលិពោធនោះឯងជាប្រធាន ឬជាប្រធានក្នុងបលិពោធទាំងពួង មានការប្រកបដោយធម៌នោះជាដើម ព្រោះហេតុនោះ ទើបឈ្មោះថា **បលិពោធសីសំ** ។ ក្នុងបទដ៏សេសក៏មានន័យនេះឯង ។ តែដោយសេចក្តីផ្សេងគ្នាក្នុងបទថា **ពន្ធនំ** ការចង គឺ ចងក្នុងសង្សារដោយអំណាចការក្រអឺតក្រទម ។

បទថា **បរាមាសោ** គឺ សេចក្តីប្រកាន់មាំ ។

បទថា **វិក្ខេបោ** គឺ សេចក្តីរាយមាយ ។

បទថា **កិលេសោ** គឺ សេចក្តីសៅហ្មង ។

បទថា **អធិមោក្ខោ** គឺ បង្អោនចិត្តជឿ ។

បទថា **បគ្គហោ** គឺ សេចក្តីផ្គង គឺ ភាពឧស្សាហ៍ ។

បទថា **ឧបដ្ឋានំ** គឺ ចូលទៅតាំងទុក គឺការផ្ញើដដែល ៗ ។

បទថា **អវិក្ខេបោ** គឺ ភាពមិនរាយមាយ ។

បទថា **ទស្សនំ** ការឃើញ គឺ ចាក់ធ្លុះតាមសេចក្តីពិត ។

បទថា **បវត្តំ** ការប្រព្រឹត្តទៅ គឺ ការប្រព្រឹត្តទៅដោយឧបាទិន្នក្ខន្ធ ។

បទថា **គោចរេ** គឺ អារម្មណ៍ ។

ធម៌មានអត្ថជាប្រធាន ជាប្រមុខ ក្នុងវារៈសូម្បីទាំង ១២ នេះ ។

បទថា **វិមោក្ខោ** គឺ និព្វានដែលជានិស្សរណវិមុត្តិ ក្នុងវិមុត្តិ ៥ គឺ វិក្ខម្ភនវិមុត្តិ ១ , តទង្គវិមុត្តិ ១ , សមុច្ឆេទវិមុត្តិ ១ , បដិប្បស្សទ្ធិវិមុត្តិ ១ , និស្សរណវិមុត្តិ ១ ។

បទថា **សង្ខារសីសំ** មានសង្ខារជាប្រធាន គឺ ជាប្រធាននៃសង្ខារដែលជាសង្ខតៈទាំងពួង ។ អធិប្បាយថា ជាកំពូលបំផុត ដោយបទនេះ លោកពោលដល់អនុប្បាទិសេសបរិនិព្វាន ។ ឬលោកពោលដល់ខន្ធប្បរិនិព្វាន ដោយត្រឹមតែមិនមានសង្ខារ ។

បទថា **សមសីសី** ព្រោះអត្ថថា មានសេចក្តីស្ងប់ មាននេក្ខម្មៈជាដើម និងធម៌ជាប្រធានមានសទ្ធាជាដើម ឬមានសេចក្តីស្ងប់ និងធម៌ជាប្រធានស្មើគ្នា ។

មួយវិញទៀត ការត្រាស់ដឹង និងអនុប្បាទិសេសបរិ-



និព្វាន ព្រោះភេគណាមួយក្តី , ព្រោះឥរិយាបថណាមួយក្តី , ព្រោះជីវិតិន្ទ្រិយដែលស្មើគ្នាក្តី នៃអរិយសច្ច ៤ ទាំង នេះ គឺ ៖

ធម៌ជាប្រធាន ៥ មានតណ្ហាជាដើម
នៃធម៌ជាប្រធាន ១៣ ជាសមុទយសច្ចៈ ។
ធម៌ជាប្រធាន ៥ មានសទ្ធាជាដើម ជាមគ្គ-
សច្ចៈ , ជីវិតិន្ទ្រិយ មានការប្រព្រឹត្តទៅជា
ប្រធាន ជាទុក្ខសច្ចៈ ។ វិមោក្ខមានអារម្មណ៍
ជាប្រធាន និងមានសង្ខារជាប្រធាន ជានិ-
រោធសច្ចៈ ។

រមែងមានដល់អ្នកណា អ្នកនោះលោកពោលថាជា **សម-សីសី** ព្រោះមានសេចក្តីស្ងប់ ដូចបានពោលទុកក្នុងកាលមុន និងមានធម៌ទាំងនេះជាប្រធាន ។

( ចប់ អដ្ឋកថា សមសីសដ្ឋញ្ញាណនិទ្ទេស )

# អដ្ឋកថា សល្លេខដ្ឋញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងសល្លេខដ្ឋញ្ញាណនិទ្ទេស ដូចតទៅនេះ ។ បទថា **រាគោ** បុថុ រាគៈក្រាស់ គឺ រាគៈដទៃផ្សេង មិនលាយឡំដោយលោកុត្តរៈ ។ ក្នុងបទដ៏សេសក៏មានន័យនេះ ។

ឈ្មោះថា **រាគ** ព្រោះអត្ថថា ប្រាថ្នា ។

ឈ្មោះថា **ទោស** ព្រោះអត្ថថា ប្រទូសរ៉ាយ ។

ឈ្មោះថា **មោហ** ព្រោះអត្ថថា វង្វេង ។

ព្រះសារីបុត្រពោលអំពីកិលេសដែលជាប្រធាន ៣ ទាំងនេះ គឺ រាគៈ មានលក្ខណៈប្រាថ្នា ។ ទោសៈ មានលក្ខណៈប្រទូសរ៉ាយ ។ មោហៈ មានលក្ខណៈវង្វេង ហើយឥឡូវនេះ កាលនឹងសម្តែងដោយប្រភេទ ទើបពោលបទមានជាអាទិ៍ថា **កោធោ** ។

ក្នុងបទទាំងនោះ ក្នុងបទថា **កោធោ** មានលក្ខណៈក្រោធនេះ លោកបំណងយកវត្ថុ ៧ យ៉ាង ។

**ឧបនាហ** មានលក្ខណៈចងសេចក្តីក្រោធទុក គឺ សេចក្តីក្រោធនោះឯង ដែលមានសភាពមាំទាំ ។

**មក្ខ** មានលក្ខណៈលុបគុណអ្នកដទៃ គឺ លុបបំបាត់គុណ



អ្នកដទៃ ។

**បលាស** មានលក្ខណៈវាយឫកស្មើ គឺ ឃើញគុណអ្នកដទៃដោយការវាយឫកស្មើ ។

**ឥស្សា** មានលក្ខណៈធ្វើសម្បត្តិអ្នកដទៃឲ្យវិនាសទៅ គឺ ឫស្យា ។

**មច្ឆរិយ** មានលក្ខណៈលាក់បាំងសម្បត្តិរបស់ខ្លួន គឺ សម្បត្តិរបស់យើង ចូរកុំជារបស់អ្នកដទៃ ។

**មាយា** មានលក្ខណៈបិទបាំងអំពើអាក្រក់ដែលខ្លួនធ្វើ គឺ ធ្វើជាមាយាដោយសេចក្តីបិទបាំង ។

**សាឋេយ្យ** មានលក្ខណៈប្រកាសគុណដែលមិនមានក្នុងខ្លួន គឺ ភាពជាអ្នកអួតអាង ។

**ថម្ភ** មានលក្ខណៈធ្វើចិត្តឲ្យប៉ោង គឺ ភាពជាអ្នករឹងត្អឹង ។

**សារម្ភ** មានលក្ខណៈ ប្រណាំងប្រជែង ។

**មានៈ** មានលក្ខណៈប្រកាន់ខ្លួន ។

**អតិមានៈ** មានលក្ខណៈមើលងាយគេ ។

**មទ** មានលក្ខណៈស្រវឹង ។ **បមាទ** មានលក្ខណៈបណ្តោយ

ចិត្តទៅក្នុងកាមគុណ ៥ ។

ព្រះសារីបុត្តត្ថេរ លុះសម្តែងសភាពក្រាស់ ដោយអំណាចកិលេសទុកមួយផ្នែក ៗ ហើយ ដើម្បីនឹងសម្តែងដល់កិលេសដែលពោលទុកហើយ និងកិលេសដទៃដែលមិនទាន់បានពោលទុកដោយសង្គ្រោះចូលជាមួយគ្នាទាំងអស់ ទើបពោលបទមានជាអាទិ៍ថា **សព្វេ កិលេសា** កិលេសទាំងពួង ។

ក្នុងបទទាំងនោះ ឈ្មោះថា **កិលេស** ព្រោះអត្ថថា ញុំាំងសត្វឲ្យសៅហ្មង ឲ្យក្តៅក្រហាយ ឲ្យលំបាកក្នុងភពនេះ និងភពខាងមុខ ។ ទាំងដែលសង្គ្រោះចូលក្នុងអកុសលកម្មបថ ទាំងដែលមិនបានសង្គ្រោះចូល ។ ឈ្មោះថា **ទុច្ចរិត** ព្រោះអត្ថថា ប្រព្រឹត្តអំពើអាក្រក់ ឬប្រព្រឹត្តអាក្រក់ ។

ទុច្ចរិតនោះ មាន ៣ ប្រការគឺ កាយទុច្ចរិត ១ វចី-ទុច្ចរិត ១ មនោទុច្ចរិត ១ ។ ឈ្មោះថា **អភិសង្ខារ** ព្រោះអត្ថថាតាក់តែងវិបាក ។

អភិសង្ខារនោះ ក៏មាន ៣ ប្រការគឺ

**បុញ្ញាភិសង្ខារ** អភិសង្ខារ គឺ បុណ្យ ១



**អបុញ្ញាភិសង្ខារ** អភិសង្ខារ គឺ បាប ១ ។

**អានេញ្ជាភិសង្ខារ** អភិសង្ខារ គឺ ការមិនញាប់ញ័រ ១ ។

ឈ្មោះថា **ភវគាមិនោ** ព្រោះអត្ថថា សត្វទៅកាន់ភពដោយអំណាចវិបាក ។ កម្មដែលជាហេតុឲ្យសត្វទៅកាន់ភព ឈ្មោះថា **ភវគាមិកម្មា** ។ ដោយបទនេះ សូម្បីអភិសង្ខារមានហើយ ក៏ជាការហាមកម្មដែលមិនទាន់បានសោយ ។ នេះជាសេចក្តីផ្សេងគ្នាដោយប្រការដូច្នេះ ។

បទថា **ទុច្ចរិតា** និង **កម្ម** ជាលិង្គវិបល្លាស ។

បទថា **នានត្តេកត្តំ** សភាពផ្សេងៗនិងសភាពតែមួយ ក្នុងឧទ្ទេសមាតិកានេះ គឺ សូម្បីមិនមានស័ព្ទថា **ឯកត្ត** អ្នកប្រាជ្ញនឹងចង្អុលបង្ហាញសូម្បីសភាពតែមួយ ព្រោះការសម្ល឵ឹងដល់គ្នានឹងគ្នានៃសភាពផ្សេងៗ និងសភាពតែមួយ ទើបធ្វើឧទ្ទេសថា **នានត្តេកត្តំ** ។ បើសម្តែងសភាពតែមួយក្នុងការដុសខាត់សភាពផ្សេង ៗ លោកក៏សម្តែងដល់ញាណក្នុងការដុសខាត់បានដោយងាយ ។

បទថា **នានត្តំ** គឺ សភាពផ្សេង ៗ ព្រោះភាពមិនតាំងមាំ និងព្រោះមានភាពញាប់ញ័រ ។

បទថា **ឯកត្តំ** គឺ សភាពតែមួយ ព្រោះការតាំងមាំ និង ព្រោះមានភាពមិនញាប់ញ័រ ។

បទថា **ចរណតេជោ** ចរណតេជៈ ឈ្មោះថា **ចរណ** ព្រោះអត្ថថា ត្រាច់ទៅកាន់ទិសដែលមិនទាន់បានទៅ គឺ ទៅកាន់និព្វានដោយចរណតេជៈនោះ ។ ចរណៈនោះ គឺអ្វី ? គឺ **សីល** ។ ចរណៈនោះឯង ឈ្មោះថា តេជៈ ព្រោះអត្ថថា ដុតវត្ថុដែលជាសត្រូវ ។

បទថា **គុណតេជោ** គុណតេជៈ គឺ សមាធិតេជៈ ដែលតាំងមាំបាន ដោយសីល ។

បទថា **បញ្ញាតេជោ** បញ្ញាតេជៈ គឺ វិបស្សនាតេជៈ ដែលតាំងមាំបានដោយសមាធិ ។

បទថា **បុញ្ញតេជោ** បុញ្ញតេជៈ គឺ អរិយមគ្គកុសលតេជៈ ដែលតាំងមាំបាន ដោយវិបស្សនា ។

បទថា **ធម្មតេជោ** ធម្មតេជៈ គឺ ពុទ្ធវចនតេជៈដែលជាគោលនៃតេជៈទាំង ៤ ។

បទថា **ចរណតេជេន តេជិតត្តា** បានដល់ អ្នកមានចិត្ត



ក្លៀវក្លា រមែងញាំញីតេជៈ គឺ ភាពជាអ្នកទ្រុស្តសីលឲ្យវិនាសទៅ ដោយចរណតេជៈ គឺ សីលតេជៈ ។

បទថា **ទុស្សីល្យតេជំ** បានដល់ តេជៈ គឺ ភាពជាអ្នកទ្រុស្តសីល ។ ឈ្មោះថា **តេជោ** ព្រោះដុតសន្តាននោះ ។

បទថា **បរិយាទិយតិ** គឺ ឲ្យអស់ទៅ ។

បទថា **អគុណតេជំ** ញាំញីតេជៈមិនមែនគុណ បានដល់ តេជៈ គឺ សេចក្តីរាយមាយ ដែលជាបដិបក្ខរបស់សមាធិ ។

បទថា **ទុប្បញ្ញាតេជំ** តេជៈ គឺ ភាពជាអ្នកមានបញ្ញាថោកថយ បានដល់ តេជៈ គឺ មោហៈ ដែលជាបដិបក្ខដល់វិបស្សនាញាណ ។

បទថា **អបុញ្ញតេជំ** តេជៈមិនមែនបុណ្យ បានដល់ តេជៈ គឺ អកុសលកម្ម ដែលជាសំឡាញ់របស់កិលេស ដោយការមិនលះបង់កិលេស ដែលកម្ចាត់មគ្គនោះ ៗ ។ មិនមែនឲ្យតេជៈមិនមែនឲ្យបុណ្យវិនាសទៅតែប៉ុណ្ណោះ ញាំញីកុសលកម្មឲ្យវិនាសទៅផង ព្រោះព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ កម្មមិនខ្មៅ មិនស មានហើយ កម្មដែលជាវិបាករបស់កម្ម មិនខ្មៅ

មិនស រមែងប្រព្រឹត្តទៅដើម្បីការអស់ទៅនៃកម្ម ដូច្នេះ លោកពោលតេជៈដែលមិនមែនបុណ្យប៉ុណ្ណោះ ដោយអំណាចជាបដិបក្ខដល់តេជៈដែលជាបុណ្យ ។

បទថា **អធម្មតេជំ** តេជមិនមែនធម៌ បានដល់ តេជៈដែលជាពាក្យពេជន៍សម្តែងលទ្ធិរបស់ពួកតិរត្ថីយ៍ផ្សេង ៗ ។ កាលលោកពោលអត្ថវិកប្បទីពីរ ក្នុងការពណ៌នាឧទ្ទេសនៃញាណនេះ តេជៈ គឺ ភាពជាអ្នកទ្រុស្តសីលច្រើន មាន ១៩ យ៉ាង មានរាគៈជាដើម ។ ក្នុងបទនេះថា **អភិសង្ខារា ភវគាមិកម្មា** បានដល់ អបុញ្ញាភិសង្ខារ និងអកុសលកម្ម ជាតេជៈ មិនមែនបុណ្យ ។ អានេញ្ជាភិសង្ខារជាកុសលកម្ម ផ្នែកលោកិយៈ ឈ្មោះថា រមែងជាបដិបក្ខដល់តេជៈមិនមែនបុណ្យ ព្រោះញ៉ាំងបុណ្យតេជៈឲ្យវិនាសទៅ ។ សភាពផ្សេង ៗ ១៥ មានកាមច្ឆន្ទៈជាដើម រមែងជាតេជៈមិនមែនគុណ ។ សភាពផ្សេង ៗ ១៨ មាននិច្ចសញ្ញាជាដើម រមែងជាតេជៈនៃភាពជាអ្នកមានបញ្ញាថោកទាប ។ សភាពផ្សេងៗ ៤ ដែលទម្លាយមគ្គ ៤ រមែងជាតេជៈមិនមែនបុណ្យ ។ គប្បីសង្គ្រោះតេជៈមិនមែនធម៌ ដោយសភាពផ្សេង ៗ ដែលទម្លាយ



សោតាបត្តិមគ្គ ។

ព្រះសារីបុត្តត្ថេរ បំណងនឹងសម្តែងធម៌ជាគ្រឿងដុសខាត់ ដោយធម៌មិនមែនជាគ្រឿងដុសខាត់ ដែលជាបដិបក្ខដល់ធម៌ជាគ្រឿងដុសខាត់ទុកក្នុងនិទ្ទេស ទើបសម្តែងធម៌ជាគ្រឿងដុសខាត់ទុកមុនធម៌មិនមែនជាគ្រឿងដុសខាត់ ។ សភាពនៃធម៌ ៣៧ មាននេក្ខម្មៈជាដើម លោកពោលទុកថា ធម៌ជាគ្រឿងដុសខាត់ ព្រោះដុសខាត់ធម៌ជាសត្រូវ ។ ញាណក្នុងធម៌ជាគ្រឿងដុសខាត់ ៣៧ ប្រភេទ មាននេក្ខម្មៈជាដើមនោះ ឈ្មោះថា **សល្លេខដ្ឋញ្ញាណ** ។

( ចប់ អដ្ឋកថាសល្លេខដ្ឋញ្ញាណនិទ្ទេស )

## អដ្ឋកថា វីរិយារម្ភញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ ក្នុងវីរិយារម្ភញ្ញាណនិទ្ទេសដូចតទៅនេះ ។

បទថា **អនុប្បន្នានំ** ដែលនៅមិនទាន់កើត គឺ នៅមិនទាន់កើតក្នុងអត្តភាពមួយ ឬក្នុងអារម្មណ៍មួយ ។ ព្រោះឈ្មោះថា អកុសលដែលមិនកើតក្នុងសង្សារ ដែលមិនដឹងខាងដើម និងខាងចុងរមែងមិនមាន តែកុសលមាន ។

បទថា **បាបកានំ** គឺ លាមក ។

បទថា **អកុសលានំ ធម្មានំ** គឺ ធម៌ដែលមិនល្អ ។

បទថា **អនុប្បាទាយ** ដើម្បីមិនឲ្យកើតឡើង គឺ ដើម្បីភាពដែលមិនឲ្យកើតឡើង ។

បទថា **ឧប្បន្នានំ** គឺ ដែលកើតហើយក្នុងអត្តភាព នេះ ។

បទថា **បហានាយ** គឺ ដើម្បីប្រយោជន៍ដល់ការលះបង់ ។

បទថា **អនុប្បន្នានំ កុសលានំ ធម្មានំ** កុសលធម៌ ដែលមិនទាន់កើត គឺ ធម៌ដែលមានសភាពល្អ ដែលមិនធ្លាប់កើតក្នុងអត្តភាពនេះ ។

បទថា **ឧប្បាទាយ** ដើម្បីប្រយោជន៍ឲ្យកើតឡើង ។



បទថា **ឧប្បន្នានំ** ដែលកើតឡើងហើយ គឺ ដែលកើតហើយក្នុងអត្តភាពនេះ ។

បទថា **ឋិតិយា** គឺ ដើម្បីការតាំងមាំ ។

បទថា **អសម្មោសាយ** ដើម្បីមិនឲ្យវិនាស គឺ ដើម្បីសេចក្តីមិនសូន្យទៅ ។

បទថា **ភិយ្យោភាវាយ** ដើម្បីសេចក្តីចម្រើន គឺ ដើម្បីឲ្យកើតឡើងដ៏ក្រៃលែង ។

បទថា **វេបុល្លាយ** គឺ ដើម្បីភាពធំទូលាយ ។

បទថា **ភាវនាយ** គឺ ដើម្បីសេចក្តីចម្រើន ។

បទថា **បារិបូរិយា** គឺ ដើម្បីភាពពេញលេញ ។

ពេលនេះ ព្រះសារីបុត្តត្ថេរ ដើម្បីសម្តែងដល់កាមច្ឆន្ទៈក្នុងអកុសល និងនេក្ខម្មៈក្នុងកុសលឲ្យប្លែកគ្នា ទើបពោលបទមានជាអាទិ៍ថា **អនុប្បន្នស្ស កាមច្ឆន្ទស្ស** កាមច្ឆន្ទៈ ដែលនៅមិនទាន់កើត ។

ក្នុងបទទាំងនោះ បទថា **កាមច្ឆន្ទោ** បានដល់ កាមរាគៈដែលជាបដិបក្ខដល់សមាធិ ។

បទថា **នេក្ខម្មំ** បានដល់ បឋមជ្ឈានសមាធិ ឬបឋមជ្ឈាន ឬកុសលធម៌ទាំងអស់នោះឯង ជានេក្ខម្មៈ ។

ពេលនេះ ព្រះសារីបុត្តត្ថេរដើម្បីសម្ដែងប្រកបដោយ អំណាចនៃកិលេសទាំងពួង និងអរហត្តមគ្គ ដែលជាបដិបក្ខដល់កិលេសទាំងពួង ទើបពោលបទមានជាអាទិ៍ថា **អនុប្បន្នានំ សព្វកិលេសានំ** ញុំាងកិលេសទាំងពួងដែលមិនទាន់កើតឡើង ។

ក្នុងបទទាំងនោះ បទមានជាអាទិ៍ថា **ឧប្បន្នស្ស អរហត្តមគ្គស្ស ឋិតិយា** ដើម្បីការតាំងមាំនៃអរហត្តមគ្គដែលកើតឡើងហើយ គប្បីជ្រាបការប្រកបបទមានជាអាទិ៍ថា **ឋិតិយា** ដោយអំណាចនៃឋិតិខណៈ និងភង្គខណៈ របស់អរហត្តមគ្គដែលកើតឡើងហើយក្នុងឧប្បាទខណៈ ។ សូម្បីក្នុងអដ្ឋកថានៃវិភង្គ លោកក៏ពោលថា ការប្រព្រឹត្តទៅនៃអរហត្តមគ្គ ឈ្មោះថា **ឋិតិ** គឺការតាំងមាំ ។ តែអាចារ្យពួកខ្លះពោលថា គប្បីឃើញមគ្គដែលជាចំណែកខាងដើមនៃអរហត្តមគ្គ ។

( ចប់ អដ្ឋកថាវីរិយារម្ភញ្ញាណនិទ្ទេស )



# អដ្ឋកថា អត្ថសន្ទស្សនញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ ក្នុងអត្ថសន្ទស្សនញ្ញាណនិទ្ទេស ដូចតទៅនេះ ។ បទជាដើមថា **បញ្ចក្ខន្ធា** មានអត្ថដូចបានពោលហើយ ។

បទថា **បកាសេតិ** រមែងប្រកាស គឺ ធ្វើឲ្យប្រាកដ ។ អធិប្បាយថា ញុំាងការឃើញដោយញាណចក្ខុឲ្យចម្រើនដល់អ្នកស្ដាប់ ។

បទថា **នានាធម្មា** ធម៌ផ្សេង ៗ ទាំងឡាយ លោកពោលដល់ធម៌ទាំងពួង ដែលជាលោកិយៈ និងលោកុត្តរៈ ។ បើសួរថា ព្រោះហេតុអ្វីទើបលោកពោលធម៌ជាលោកិយៈប៉ុណ្ណោះ ក្នុងនិទ្ទេសនៃការប្រកាស ។ ឆ្លើយថា លោកមិនពោលដល់ធម៌ជាលោកុត្តរៈ ព្រោះប្រារព្ធការប្រកាសដោយភាពជារបស់ មិនទៀងជាដើម និងព្រោះធម៌ជាលោកុត្តរៈមិនទាន់ចូលដល់ ការពិចារណា ។ តែលោកពោលដល់ការប្រកាសដោយការប្រកាសប៉ុណ្ណោះ ដោយអាការដែលគួរប្រកាសធម៌ទាំងនោះ ព្រោះលោកសង្គ្រោះធម៌ទាំងនោះដោយការសម្ដែងធម៌ផ្សេង ៗ និងដោយការសម្ដែងឲ្យឃើញច្បាស់

នូវអត្ថ ។

បទថា **បជហន្តោ** ពេលលះ គឺ ឲ្យអ្នកស្តាប់លះ ។

បទថា **សន្ទស្សេតិ** រមែងឃើញច្បាស់ គឺ សម្តែងដល់អ្នកស្តាប់ដោយប្រពៃ ។ តែអាចារ្យពួកខ្លះពោលដោយន័យជាដើមថា ព្រះយោគាវចរ រមែងឃើញច្បាស់នូវអត្ថនៃនេក្ខម្មៈ ព្រោះលះកាមច្ឆន្ទៈបានហើយ ។ គប្បីជ្រាបថា លោកពោលន័យនេះដើម្បីសម្តែងថា ពេលអ្នកត្រងត្រាប់ស្តាប់ធម៌ទាំងនោះឯង ធ្វើការលះបង់ទោស និងបានចំពោះហើយនៅគុណ ទេសនាញាណរមែងដល់លំដាប់កំពូល ។

( ចប់ អដ្ឋកថាអត្ថសន្ទស្សនញាណនិទ្ទេស )



# អដ្ឋកថា ទស្សនវិសុទ្ធិញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងទស្សនវិសុទ្ធិញ្ញាណនិទ្ទេស ដូចតទៅនេះ ។ បទថា **សព្វេ ធម្មា ឯកសង្គហិតា** ធម៌ទាំងពួង លោកសង្គ្រោះជាពួកមួយ បានដល់ ធម៌ដែលជាសង្ខតៈ និងអសង្ខតៈទាំងអស់ លោកសង្គ្រោះ គឺ កំណត់ដោយពួកមួយ ។

បទថា **តថដ្ឋេន** ដោយអត្ថថា ពិត គឺ ដោយសភាវៈពិត ។ អធិប្បាយថា មានដោយអំណាចតាមសភាវៈរបស់ខ្លួន ៗ ។

បទថា **អនត្តដ្ឋេន** ដោយអត្ថថា មិនមែនខ្លួន គឺ ដោយសភាវៈវៀរចាកតួខ្លួនដែល បានដល់ អ្នកធ្វើ និងអ្នកសោយ ។

បទថា **សច្ចដ្ឋេន** ដោយអត្ថថា ទៀង គឺ ដោយសភាវៈដែលមិនខុសអំពីសេចក្តីពិត ។ អធិប្បាយថា ដោយភាពជាសភាវៈរបស់ខ្លួន មិនជាយ៉ាងដទៃ ។

បទថា **បដិវេធដ្ឋេន** ដោយអត្ថថា ចាក់ធ្លុះ គឺ គប្បីចាក់ធ្លុះដោយញាណ ។ ក្នុងបទនេះ គប្បីជ្រាបការចាក់ធ្លុះដោយការមិនវង្វេង និងដោយអារម្មណ៍ដោយញាណដែលជាលោកុត្តរៈ ។

បទថា **អភិជាននដ្ឋេន** ដោយអត្ថថា ដែលគួរដឹងក្រៃលែង

គឺ ដោយសភាវៈដែលគួរដឹងក្រៃលែងនៅធម៌នោះៗ ដោយអារម្មណ៍ ដោយញាណដែលជាលោកិយៈ ដោយការមិនវង្វេង និងដោយអារម្មណ៍ ដោយញាណដែលជាលោកុត្តរៈ ។ ដូចដែលព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ទុកថា **សព្វំ ភិក្ខវេ អភិញ្ញេយ្យំ** ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួង គួរដឹងដ៏ក្រៃលែង ។ បទថា **បរិជាននដ្ឋេន** ដោយអត្ថថា កំណត់ដឹង គឺ ដោយសភាវៈដែលគួរកំណត់ដឹងធម៌ទាំងឡាយដែលដឹងដ៏ក្រៃលែងហើយ ដោយសភាវៈដោយញាណដែលជាលោកិយៈ និងលោកុត្តរៈ តាមន័យដែលពោលហើយនោះឯង ដោយសភាពមិនទៀងជាដើម និងដោយការចេញទៅជាដើម ដូចដែលត្រាស់ទុកថា **សព្វំ ភិក្ខវេ បរិញ្ញេយ្យំ** ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងគួរកំណត់ដឹង ។

បទថា **ធម្មដ្ឋេន** ដោយអត្ថថា ទ្រទ្រង់ គឺ ដោយសភាវៈដែលជាធម៌ មានការទ្រទ្រង់ទុកនៅសភាវៈជាដើម ។

បទថា **ធាតដ្ឋេន** ដោយអត្ថថា ជាធាតុ គឺ ដោយសភាវៈដែលជាធាតុ មានការមិនមានជីវៈជាដើម ។

បទថា **ញាតដ្ឋេន** ដោយអត្ថថា ដឹង គឺ ដោយសភាវៈ



ដែលអាចដឹងដោយញាណ ដែលជាលោកិយៈ និងលោកុត្តរៈ ។

គប្បីជ្រាបថា មានសភាវៈអាចដឹងសូម្បីក្នុងបទនេះ ដូចដែលលោកពោលទុកថា **ទិដ្ឋំ** រូបដែលឃើញ **សុតំ** សំឡេងដែលបានឮ **មុតំ** អារម្មណ៍ ៣ ដែលបានដឹង **វិញ្ញាតំ** ធម៌ដែលដឹងហើយជារូប ដោយអត្ថមានសភាវៈ ដែលអាចឃើញបានជាដើម ដូច្នោះ ។

បទថា **សច្ឆិកិរិយដ្ឋេន** ដោយអត្ថថា ធ្វើឲ្យជាក់ច្បាស់ គឺ ដោយសភាពដែលគួរធ្វើឲ្យប្រចក្សច្បាស់ ដោយអារម្មណ៍ ។

បទថា **ផុស្សនដ្ឋេន** ដោយអត្ថថា ពាល់ត្រូវ គឺ ដោយសភាពដែលគួរពាល់ត្រូវរឿយ ៗ ដោយអារម្មណ៍ នៃសភាវៈដែលធ្វើឲ្យជាក់ច្បាស់ហើយ ។

បទថា **អភិសមយដ្ឋេន** ដោយអត្ថថា ត្រាស់ដឹង គឺ ដោយសភាពដែលគួរត្រាស់ដឹងដោយញាណ ដែលជាលោកិយៈ ។ សូម្បីលោកពោលដល់ញាណនិមួយ ៗ ថា បញ្ញាក្នុងសភាវៈពិត ជាញាណក្នុងវិវដ្ត គឺ និព្វានពិត ។ បញ្ញាដែលគួរដឹងដ៏ក្រៃលែងជាញាណក្នុងសភាវៈដែលគួរដឹង ។ បញ្ញាដែលគួរធ្វើឲ្យជាក់ច្បាស់

ជាញាណក្នុងសភាវៈ ដែលគួរពោលត្រូវ ។ មយ៉ាងទៀត លោកពោលទុកក្នុងអដ្ឋកថា ថា :

***សមវាយេ ខណេ កាលេ    សមូហេ ហេតុទិដ្ឋិសុ***
***បដិលាភេ បហានេ ច    បដិវេធេ ច ទិស្សតិ ។***

ព្រះយោគាវចរ រមែងប្រាកដក្នុងពួក ខណៈ កាល ទីប្រជុំ ហេតុ ទិដ្ឋិ ការបាន ការលះ និងក្នុងការចាក់ធ្លុះ ។

ក្នុងការពណ៌នាគាថា លោកពោលអត្ថរបស់បដិវេធនៃ ***អភិសមយ*** សព្ទ ។ តែក្នុងទីនេះគប្បីជ្រាបដល់សភាវៈផ្សេង ៗ នៃធម៌ទាំងនោះដោយអត្ថតាមដែលពោលហើយ ។ ព្រោះក្នុងអដ្ឋកថានោះឯង លោកពោលដល់ការត្រាស់ដឹងធម៌ដោយអំណាចនៃញាណដែលជាលោកិយៈ ។

បទថា ***កាមច្ឆន្ទោ នានត្តំ*** កាមច្ឆន្ទៈ ជាសភាវៈផ្សេង ៗ សេចក្តីថា កាមច្ឆន្ទៈជាសភាវៈផ្សេង ៗ ព្រោះមានអារម្មណ៍ផ្សេង ៗ ដោយមានការរាយមាយ ។ គប្បីជ្រាបកិលេសទាំងអស់ ដោយប្រការដូច្នេះ ។

បទថា ***នេក្ខម្មំ ឯកត្តំ*** នេក្ខម្មៈមានចំណែកតែមួយ សេចក្តីថា



នេក្ខម្មៈមានសភាពជាចំណែកដូចគ្នា ដោយមានចិត្តជាឯកគ្គតា និងដោយមិនមានសេចក្តីរាយមាយក្នុងអារម្មណ៍ផ្សេង ៗ ។ គប្បីជ្រាបកុសលទាំងពួងដោយប្រការដូច្នេះ ។

ក្នុងទីនេះ គប្បីជ្រាបសេចក្តីផ្សេងគ្នានៃអកុសលទាំងឡាយមានព្យាបាទៈជាដើម ដែលលោកសង្ខេបទុកដោយបេយ្យាល ដោយអត្ថតាមដែលពោលហើយ ។ មយ៉ាងទៀត គប្បីជ្រាបសេចក្តីផ្សេងគ្នានៃធម៌ថ្នាក់ទាប មានវិតក្កវិចារៈជាដើម ដោយសភាពគ្រោតគ្រាតជាង ធម៌ថ្នាក់ខ្ពស់ ៗ ។ ព្រោះការចាក់ធ្លុះសភាវៈផ្សេង ៗ និងសភាវៈដែលដូចគ្នា លោកសង្គ្រោះចូលគ្នាតែមួយ រមែងសម្រេចដោយការចាក់ធ្លុះសច្ចៈ ក្នុងខណៈនៃមគ្គ ដូច្នោះព្រះសារីបុត្តត្ថេរទើបលើកបទថា ***បដិវេធោ*** ឡើង ហើយសម្តែងដល់ការត្រាស់-ដឹងសច្ចៈ ។

បទថា ***បរិញ្ញាបដិវេធំ បដិវិជ្ឈតិ*** ព្រះយោគាវចររមែងចាក់ធ្លុះទុក្ខសច្ចៈ ជាការចាក់ធ្លុះដោយការកំណត់ដឹង គឺត្រាស់ដឹងដោយ ***បរិញ្ញាភិសមយ*** ។ ក្នុងបទដ៏សេសក៏មានន័យនេះ ។ ពិតណាស់ ក្នុងកាលត្រាស់ដឹងសច្ចៈក្នុងខណៈមគ្គ ជា

ចំណែកជាមួយគ្នានៃមគ្គញ្ញាណ រមែងមានកិច្ច ៤ យ៉ាងគឺ **បរិញ្ញា ១ បហាន ១ សច្ឆិកិរិយា ១ ភាវនា ១** ។ ដូចជាទូកធ្វើកិច្ច ៤ យ៉ាង ក្នុងខណៈតែមួយមិនមុនមិនក្រោយ គឺ លះត្រើយអាយ ១ កាត់ក្រសែទឹក ១ នាំទំនិញទៅ ១ ដល់ត្រើយនាយ ១ យ៉ាងណា ។ ព្រះយោគាវចរ រមែងត្រាស់ដឹងសច្ចៈ ៤ ក្នុងខណៈតែមួយ មិនមុនមិនក្រោយ គឺ ត្រាស់ដឹងទុក្ខ ដោយការកំណត់ដឹង ១ ត្រាស់ដឹងសមុទយៈដោយការលះ ១ ត្រាស់ដឹងមគ្គដោយការចម្រើន ១ ត្រាស់ដឹងនិរោធដោយការធ្វើឲ្យជាក់ច្បាស់ ១ ដូច្នោះ ។ លោកអធិប្បាយទុកយ៉ាងណា ។ អធិប្បាយទុកថា ព្រះយោគាវចរធ្វើនិរោធឲ្យជាអារម្មណ៍ រមែងបានសម្រេច រមែងឃើញ រមែងចាក់ធ្លុះសច្ចៈ ៤ ដោយអំណាចកិច្ច ។ ដូចជាទូកលះត្រើយអាយ យ៉ាងណា ។ ព្រះយោគាវចរកំណត់ដឹងទុក្ខដែលជាមគ្គញ្ញាណ ដូច្នោះ ។ ទូកកាត់ក្រសែទឹកយ៉ាងណា ។ ព្រះយោគាវចរលះសមុទយ ដូច្នោះ ។ ទូកនាំទំនិញទៅ យ៉ាងណា ។ ព្រះយោគាវចរចម្រើនមគ្គ ព្រោះជាបច្ច័យ មានការកើតរួមគ្នាជាដើម ដូច្នោះ ។ ទូកដល់ត្រើយនាយ យ៉ាងណា ។ ព្រះយោគា-



វចរធ្វើឲ្យជាក់ច្បាស់និរោធ ដែលជាត្រើយនាយ ដូច្នោះ ។ គប្បីជ្រាបសេចក្ដីឧបមាឧបមេយ្យ ដោយប្រការដូច្នេះ ។

បទថា **ទស្សនំ វិសុជ្ឈតិ** ទស្សន រមែងបរិសុទ្ធ គឺ ញាណទស្សនៈ រមែងដល់ការបរិសុទ្ធដោយការលះកិលេសដែលកម្ចាត់ដោយមគ្គនោះ ៗ ។

បទថា **ទស្សនំ វិសុទ្ធំ** ទស្សនបរិសុទ្ធហើយ គឺ ញាណ-ទស្សនៈដល់ការបរិសុទ្ធហើយ ដោយដល់ការបរិសុទ្ធ នៃកិច្ចរបស់មគ្គញ្ញាណនោះ ៗ ក្នុងខណៈកើតផលនោះ ៗ ។

លោកពោល មគ្គផលញ្ញាណក្នុងទីបំផុត ដោយសម្រេចមគ្គផលញ្ញាណនៃបញ្ញា ចាក់ធ្លុះសភាវៈផ្សេង និងសភាវៈជាមួយគ្នា ដែលលោកសង្គ្រោះធម៌ទាំងពួងជាចំណែកតែមួយ ។

( ចប់ អដ្ឋកថាទស្សនវិសុទ្ធិញ្ញាណនិទ្ទេស )

# អដ្ឋកថា ខន្តិញ្ញាណបរិយោគាហណញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ ក្នុងខន្តិញ្ញាណបរិយោគាហណញ្ញាណនិទ្ទេសដូចតទៅនេះ ។ បទថា **រូបំ អនិច្ចតោ វិទិតំ** រូបប្រាកដដោយភាពជារបស់មិនទៀង គឺ ប្រាកដដោយអនិច្ចានុបស្សនាញាណថា ជារបស់មិនទៀង ។

បទថា **រូបំ ទុក្ខតោ វិទិតំ** រូបប្រាកដដោយភាពជាទុក្ខ គឺ ប្រាកដដោយទុក្ខានុបស្សនាញាណថា ជាទុក្ខ ។

បទថា **រូបំ អនត្តតោ វិទិតំ** រូបប្រាកដដោយភាពជាអនត្តា គឺ ប្រាកដដោយអនត្តានុបស្សនាញាណថា ជាអនត្តា ។

បទថា **យំ យំ វិទិតំ តំ តំ ខមតិ** រូបណា ៗ ដែលប្រាកដ រូបនោះ ៗ រមែងតាំងនៅ គឺ រូបណា ៗ ដែលប្រាកដដោយភាពជារបស់មិនទៀងជាដើម ។ រូបនោះ ៗ រមែងតាំងនៅ គឺ ពេញចិត្តដោយភាពជារបស់មិនទៀងជាដើម ។ លោកធ្វើទុកជាចំណែក ៗ ហើយសរសេរទុកក្នុងគម្ពីរខ្លះថា រូបប្រាកដដោយភាពជារបស់មិនទៀង ។ រូបណា ៗ ប្រាកដហើយ ។



រូបនោះ ៗ រមែងតាំងនៅ ។ គប្បីប្តូរលិង្គ ហើយប្រកបដោយបទជាដើមថា **វេទនា សញ្ញា សង្ខារា អនិច្ចតោ វិទិតា** វេទនា សញ្ញា សង្ខារ ប្រាកដហើយ ដោយភាពជារបស់មិនទៀង ។

បទថា **ផុសតិ** រមែងពាល់ត្រូវ គឺ រមែងពាល់ត្រូវ រមែងផ្សាយទៅដោយការពាល់ត្រូវវិបស្សនាញាណ ។

បទថា **បរិយោគហតិ** រមែងស្ទង់ គឺ ចូលទៅដោយវិបស្សនាញាណ ។ បាឋៈថា **បរិយោគាហតិ** ខ្លះ ។

( ចប់ អដ្ឋកថាខន្តិញ្ញាណបរិយោគាហណញ្ញាណនិទ្ទេស )

# អដ្ឋកថា បទេសវិហារញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទេសវិហារញ្ញាណនិទ្ទេស ដូចតទៅនេះ ។ ព្រះសារីបុត្តត្ថេរ កាលនឹងសម្តែងដល់អាការដែលគួរពិចារណាញាណចំណែកខ្លះ ដែលលើកឡើងទុកក្នុងមាតិកា ទើបសម្តែងបទជាដើមថា **មិច្ឆាទិដ្ឋិបច្ចយាបិ វេទយិតំ** ព្រោះមិច្ឆាទិដ្ឋិជាបច្ច័យ ទើបមានអកុសលវេទនា ។

ក្នុងបទទាំងនោះ បទថា **មិច្ឆាទិដ្ឋិបច្ចយា** ព្រោះមិច្ឆាទិដ្ឋិជាបច្ច័យ សេចក្តីថា វេទនាសម្បយុត្តដោយទិដ្ឋិខ្លះ វេទនាជាកុសល អកុសលខ្លះ វេទនាជាវិបាកខ្លះកើតឡើង ញុាំងទិដ្ឋិឲ្យជាឧបនិស្ស័យ រមែងគួរ ។ ក្នុងវេទនាទាំងនោះ វេទនាដែលសម្បយុត្តដោយមិច្ឆាទិដ្ឋិជាអកុសល ប៉ុណ្ណោះ ។ តែវេទនាជាកុសលខ្លះ អកុសលខ្លះ រមែងកើតឡើងព្រោះអាស្រ័យទិដ្ឋិ ។ ពិតណាស់ ពួកបុគ្គលមិច្ឆាទិដ្ឋិ ឲ្យបាយយាគូ និងភត្តជាដើម ក្នុងថ្ងៃនៃបក្ខ ព្រោះអាស្រ័យទិដ្ឋិ រមែងបដិបត្តិចំពោះមនុស្សខ្វាក់និងមនុស្សមានរោគឃ្លង់ជាដើម រមែងសាងសាលាធទាន ជីកស្រះ



បោក្ខរណីក្នុងផ្លូវបែកជា ៤ ដាំសួនផ្កាឈើ សួនផ្លែឈើ សង់ស្ពានក្នុងទីលំបាកព្រោះទឹក ពង្រាបដីដែលមិនស្មើឲ្យស្មើ វេទនាដែលជាកុសល រមែងកើតដល់ពួកបុគ្គលមិច្ឆាទិដ្ឋិទាំងនោះ ដោយប្រការដូច្នេះ ។ ប៉ុន្តែព្រោះអាស្រ័យមិច្ឆាទិដ្ឋិ រមែងជេរប្រទេចសម្លាប់ និងឃុំឃាំងជាដើមនូវពួកបុគ្គលសម្មាទិដ្ឋិ សម្លាប់សត្វបួងសួងទេវតា ។ វេទនាជាអកុសល រមែងកើតដល់ពួកបុគ្គលមិច្ឆាទិដ្ឋិទាំងនោះ ដោយប្រការដូច្នេះ ។ ចំណែកវេទនាជាវិបាក រមែងមានដល់សត្វទៅក្នុងភពដទៃ ។

មយ៉ាងទៀត មិច្ឆាទិដ្ឋិនោះ រមែងជាបច្ច័យដល់វេទនាដែលកើតរួមគ្នាដោយអំណាចសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។

**មិច្ឆាទិដ្ឋិ** រលត់មួយរំពេចនោះ រមែងជាបច្ច័យដល់វេទនា ដែលសម្បយុត្តដោយមិច្ឆាទិដ្ឋិក្នុងបច្ចុប្បន្ន ដោយអំណាចអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ ឧបនិស្សយប្បច្ច័យ អាសេវនប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ ។

**មិច្ឆាទិដ្ឋិ** រមែងជាបច្ច័យដល់វេទនា សហគតដោយលោភៈ

របស់បុគ្គលត្រេកអរធ្វើមិច្ឆាទិដ្ឋិឲ្យធ្ងន់ ដោយអំណាចអារម្មណា-ធិបតិប្បច្ច័យ និងអារម្មណូបនិស្សយប្បច្ច័យ ។

**មិច្ឆាទិដ្ឋិ** រមែងជាបច្ច័យដល់វេទនាជាកុសល និងអព្យា-កតៈ របស់បុគ្គលអ្នកធ្វើមិច្ឆាទិដ្ឋិឲ្យត្រឹមតែជាអារម្មណ៍ ដោយអកុសលទាំងពួង អ្នកពិចារណាឃើញច្បាស់ដល់មិច្ឆាទិដ្ឋិដោយវេទនាជាអកុសលទាំងពួង ដោយអំណាចអារម្មណប្បច្ច័យ ប៉ុណ្ណោះ ។

**មិច្ឆាទិដ្ឋិ** រមែងជាបច្ច័យដល់វេទនាជាកុសល និងអកុ-សល ដែលកើតឡើងដោយមិច្ឆាទិដ្ឋិជាបច្ច័យ និងដល់វេទនាជាវិបាកក្នុងភពដទៃ ដោយអំណាចឧបនិស្សយប្បច្ច័យ ។

បទថា **មិច្ឆាទិដ្ឋិរូបសមប្បច្ចយា** ព្រោះសេចក្តីស្ងប់នៃមិច្ឆាទិដ្ឋិជាបច្ច័យ សេចក្តីថា **សម្មាទិដ្ឋិ** ឈ្មោះថា ជាសេចក្តីស្ងប់នៃមិច្ឆាទិដ្ឋិ ព្រោះដូច្នោះ គប្បីជ្រាបបទដែលលោកពោលទុកថា ព្រោះសម្មាទិដ្ឋិជាបច្ច័យ រមែងមានកុសលវេទនាថា **មិច្ឆាទិដ្ឋិរូបសមប្បច្ចយា** ។ ចំណែកអាចារ្យពួកខ្លះពោលថា ឈ្មោះថា សេចក្តីស្ងប់នៃមិច្ឆាទិដ្ឋិ រមែងមានក្នុងខណៈនៃវិបស្សនា និងក្នុងខណៈនៃសោតាបត្តិមគ្គ ។



សូម្បីក្នុងបទនេះថា **សម្មាទិដ្ឋិប្បច្ចយាបិ វេទយិតំ** ព្រោះសម្មាទិដ្ឋិជាបច្ច័យ ក៏រមែងមានកុសលវេទនា មានអធិប្បាយដូចតទៅនេះ វេទនាសម្បយុត្តដោយសម្មាទិដ្ឋិខ្លះ វេទនាជាកុសលអកុសលខ្លះ វេទនាជាវិបាកខ្លះកើតឡើង ធ្វើសម្មាទិដ្ឋិឲ្យជាឧបនិស្ស័យ រមែងគួរ ។ ក្នុងវេទនាទាំងនោះ វេទនាសម្បយុត្តដោយសម្មាទិដ្ឋិជាកុសលប៉ុណ្ណោះ ។

ម្យ៉ាងទៀត ពួកសម្មាទិដ្ឋិ អាស្រ័យសម្មាទិដ្ឋិ ធ្វើបុណ្យមានជាអាទិ៍យ៉ាងនេះ គឺ ចាត់ចែងប្រទីប និងផ្កាឈើបូជាព្រះពុទ្ធ ស្ដាប់មហាធម៌ សាងព្រះចេតិយក្នុងទិស ដែលមិនទាន់បានសាង ដោយប្រការដូច្នេះ កុសលវេទនា រមែងកើតដល់សម្មាទិដ្ឋិនៃជនទាំងនោះ ។ សម្មាទិដ្ឋិជនទាំងនោះ អាស្រ័យសម្មាទិដ្ឋិ ក៏តិះ-ដៀលពួកមិច្ឆាទិដ្ឋិ ។ លើកខ្លួនឯង សង្កត់អ្នកដទៃ ដោយប្រការដូច្នេះ ។ អកុសលវេទនារមែង កើតដល់សម្មាទិដ្ឋិជនទាំងនោះ ។ ចំណែកវិបាកវេទនា រមែងមានដល់អ្នកទៅកាន់ភពដទៃ ។

ម្យ៉ាងទៀត សម្មាទិដ្ឋិនោះ រមែងជាបច្ច័យដល់មិច្ឆាទិដ្ឋិ ដែលជាបច្ចុប្បន្ន វេទនាដែលរលត់ទៅជិតក្នុងទីបំផុត ដែលកើត

រួមគ្នាដោយអំណាចបច្ច័យ ដូចពោលមកហើយនោះឯង ។

លោកិយសម្មាទិដ្ឋិ រមែងជាបច្ច័យដល់វេទនាដែលសម្បយុត្ត ដោយការពិចារណា សម្បយុត្តដោយវិបស្សនា និងសម្បយុត្ត ដោយសេចក្តីប្រាថ្នា ដោយអំណាចអារម្មណប្បច្ច័យ ។ លោកិយសម្មាទិដ្ឋិ រមែងជាបច្ច័យដល់មិច្ឆាទិដ្ឋិដោយឧបនិស្សយប្បច្ច័យ ដោយន័យដែលពោលហើយនោះឯង ។ សម្មាទិដ្ឋិដែលជាមគ្គផល រមែងជាបច្ច័យដល់វេទនាដែលសម្បយុត្តដោយការពិចារណា ដោយអំណាចនៃអារម្មណាធិបតិប្បច្ច័យ និងអារម្មណូបនិស្សយប្បច្ច័យ ។

បទថា **សម្មាទិដ្ឋិវូបសមប្បច្ចយាបិ វេទយិតំ** ព្រោះសេចក្តីស្ងប់នៃសម្មាទិដ្ឋិជាបច្ច័យ ក៏រមែងមានអកុសលវេទនា សេចក្តីថា មិច្ឆាទិដ្ឋិ ឈ្មោះថា សេចក្តីស្ងប់នៃសម្មាទិដ្ឋិ ។ ព្រោះដូច្នោះ គប្បីជ្រាបបទដែលលោកពោលថា ព្រោះមិច្ឆាទិដ្ឋិជាបច្ច័យ ក៏រមែងមានអកុសលវេទនានោះឯង ថា **សម្មាទិដ្ឋិវូបសមប្បច្ចយា** ព្រោះសេចក្តីស្ងប់នៃសម្មាទិដ្ឋិជាបច្ច័យ ។ សូម្បីក្នុងបទមានជាអាទិ៍ថា **មិច្ឆាសង្កប្បប្បច្ចយា មិច្ឆាសង្កប្បវូបសមប្ប-**



**ច្ចយា** ព្រោះមិច្ឆាសង្កប្បៈជាបច្ច័យ ព្រោះសេចក្តីស្ងប់នៃមិច្ឆាសង្កប្បៈជាបច្ច័យ ក៏មានន័យនេះដូចគ្នា ។ ពិតណាស់ លោកពោលថា **វូសមបច្ចយា** ព្រោះសេចក្តីស្ងប់ជាបច្ច័យនៃធម៌ណា ៗ លោកបំណងយកវេទនានោះ ៗ ព្រោះមានធម៌ជាបដិបក្ខនៃធម៌នោះ ៗ ជាបច្ច័យ ។

ម្យ៉ាងទៀត គប្បីជ្រាបសេចក្តីក្នុងមិច្ឆាញាណជាដើម ដូចតទៅនេះ ការគិតដើម្បីរកឧបាយក្នុងការធ្វើបាប ឈ្មោះថា **មិច្ឆាញាណ** ។ ម្យ៉ាងវិញទៀត មិច្ឆាញាណ គឺ ញាណក្នុងការពិចារណាខុស ។ ញាណដែលជាកុសល និងអព្យាក្រិតដ៏សេសវៀរវិបស្សនាសម្មាទិដ្ឋិ និងលោកុត្តរសម្មាទិដ្ឋិ ឈ្មោះថា **សម្មាញាណ** ។ ការរួចផុតចាកបាប ឈ្មោះថា មិច្ឆាវិមុត្តិ ។ ម្យ៉ាងទៀត ការផុតដែលមិនពិត ការរួចផុតដែលមិននាំចេញទៅ អ្នកមិនរួចផុតសម្គាល់ថារួចផុត ។ ការបង្អោនទៅក្នុងកល្យាណធម៌ និងផលវិមុត្តិ ឈ្មោះថា **សម្មាវិមុត្តិ** ។ សម្មាទិដ្ឋិជាដើម មានអត្ថដូចបានពោលហើយក្នុងខាងក្រោយ ។

ចំណែកក្នុងបទមានជាអាទិ៍ថា **ឆន្ទបច្ចយាបិ** ព្រោះឆន្ទៈ

ជាបច្ច័យ គប្បីជ្រាបដូចតទៅនេះ សេចក្តីលោភ ឈ្មោះថា ឆន្ទៈ ។ គប្បីជ្រាបថា វេទនាសម្បយុត្តដោយចិត្ត ដែលសហគត ដោយលោភៈ ៨ ព្រោះមានឆន្ទៈជាបច្ច័យ ។ វេទនាក្នុងបឋមជ្ឈាន ឈ្មោះថា មានសេចក្តីស្ងប់នៃឆន្ទៈជាបច្ច័យ ។ វេទនាក្នុងបឋម-ជ្ឈាន ឈ្មោះថា មានវិតក្កៈជាបច្ច័យ ។ វេទនាក្នុងទុតិយជ្ឈាន ឈ្មោះថា មានសេចក្តីស្ងប់នៃវិតក្កៈជាបច្ច័យ ។ វេទនាក្នុងសញ្ញាសមាបត្តិ ៦ ដ៏សេស វៀរបឋមជ្ឈាន ឈ្មោះថា មានសញ្ញាជាបច្ច័យ ។ វេទនាក្នុងនេវសញ្ញានាសញ្ញាយតនៈ ឈ្មោះថា មានសេចក្តីស្ងប់នៃសញ្ញាជាបច្ច័យ ។

ក្នុងបទមានជាអាទិ៍ថា **ឆន្ទោ ច អវូបសន្តោ ហោតិ** ឆន្ទៈជាធម៌មិនស្ងប់ មានសេចក្តីថា ឆន្ទៈ វិតក្កៈ និងសញ្ញា ជាធម៌មិនស្ងប់ ។

បទថា **តប្បច្ចយា** គឺ ការមិនស្ងប់នៃឆន្ទៈ វិតក្កៈ និងសញ្ញាជាបច្ច័យ ឈ្មោះថា **តប្បច្ចយា** មានធម៌នោះជាបច្ច័យ ។ ព្រោះដូច្នោះ ទើបឈ្មោះថា **តប្បច្ចយា** ព្រោះឆន្ទៈ វិតក្កៈ និងសញ្ញានោះ ជាធម៌មិនស្ងប់ជាបច្ច័យ ។ អធិប្បាយថា ព្រោះសេចក្តីមិន



ស្ងប់ឆន្ទៈ វិតក្កៈ និងសញ្ញាជាបច្ច័យ ទើបមានវេទនា ។ វេទនានោះ ជាវេទនាសម្បយុត្តដោយចិត្ត សហគតដោយលោភៈ ៨ ។ ប្រសិនបើ ឆន្ទៈស្ងប់ វិតក្កៈ និងសញ្ញាមិនស្ងប់ ។

បទថា **តប្បច្ចយា** គឺ សេចក្តីស្ងប់នៃឆន្ទៈនោះ មានវិតក្កៈ សញ្ញាដែលមិនស្ងប់ជាបច្ច័យ ឈ្មោះថា **តប្បច្ចយោ** ។ ព្រោះដូច្នោះ ឈ្មោះថា **តប្បច្ចយា** ព្រោះវិតក្កៈ និងសញ្ញានោះជាធម៌មិនស្ងប់ជាបច្ច័យ ។ វេទនានោះ ជាវេទនាក្នុងបឋមជ្ឈាន ។ ប្រសិនបើ ឆន្ទៈ និងវិតក្កៈជាធម៌ស្ងប់ សញ្ញាជាធម៌មិនស្ងប់ ។

បទថា **តប្បច្ចយា** គឺ សេចក្តីស្ងប់នៃឆន្ទៈ និងវិតក្កៈនោះ មានសញ្ញាមិនស្ងប់ជាបច្ច័យ ឈ្មោះថា **តប្បច្ចយោ** ។ ព្រោះដូច្នោះ ឈ្មោះថា **តប្បច្ចយា** ព្រោះសញ្ញាជាធម៌មិនស្ងប់ជាបច្ច័យ ។ វេទនានោះ ជាវេទនាក្នុងទុតិយជ្ឈាន ។ បើថា ឆន្ទៈ វិតក្កៈ និងសញ្ញាជាធម៌ស្ងប់ ។

បទថា **តប្បច្ចយា** គឺ ឆន្ទៈ វិតក្កៈ សញ្ញា ជាធម៌ស្ងប់ជាបច្ច័យ ឈ្មោះថា **តប្បច្ចយោ** ។ ព្រោះដូច្នោះ ឈ្មោះថា **តប្បច្ចយា** ព្រោះឆន្ទៈ វិតក្កៈ និងសញ្ញានោះ ជាធម៌ស្ងប់ជាបច្ច័យ

វេទនានោះ ជាវេទនាក្នុងនេវសញ្ញានាសញ្ញាយតនៈ ។ តែអាចារ្យពួកខ្លះពណ៌នាទុកយ៉ាងនេះថា “ សេចក្តីពេញចិត្តក្នុងធម៌ ជាចំណែកខាងដើម ដោយគិតថា យើងនឹងសម្រេចឲ្យដល់អប្បនា ដូច្នេះ ឈ្មោះថា ឆន្ទៈ សេចក្តីពេញចិត្តរបស់អ្នកបានសម្រេចអប្បនា ជាសេចក្តីស្ងប់ ។ វិតក្កៈ រមែងមានក្នុងបឋមជ្ឈាន វិតក្កៈរបស់អ្នកបានសម្រេចទុតិយជ្ឈាន ក៏ស្ងប់ ។ សញ្ញារមែងមានក្នុងសមាបត្តិ ៧ ។ សញ្ញារបស់អ្នកចូលដល់នេវសញ្ញានា-សញ្ញាយតនៈ និងចូលដល់និរោធ ក៏ស្ងប់ទៅដែរ ” ដូច្នេះ ។ តែក្នុងទីនេះ និរោធសមាបត្តិរមែងមិនប្រកប ។

បទថា **អប្បត្តស្ស បត្តិយា** ដើម្បីសម្រេចអរហត្តផលដែលនៅមិនទាន់បានសម្រេច គឺ ដើម្បីត្រូវការសម្រេចនូវអរ-ហត្តផល ។

បទថា **អត្ថិ អាយវំ** បានដល់ សេចក្តីព្យាយាមមានហើយ បាឋៈថា **អាយាវំ** ខ្លះ ។

បទថា **តស្មិម្បិ ឋានេ អនុប្បត្តេ** បើនៅមិនទាន់បានសម្រេចឋានៈនោះ គឺ កាលបើនៅមិនទាន់បានសម្រេចអរិយមគ្គ



ដែលជាហេតុនៃអរិយផលនោះ ដោយអំណាចនៃការប្រារព្ធសេចក្តីព្យាយាមនោះ ។

បទថា **តប្បច្ចយាបិ វេទយិតំ** គឺ ព្រោះឋានៈនៃព្រះអរហត្តជាបច្ច័យ រមែងមានកុសលវេទនា ដោយបទនេះ លោកកាន់យកលោកុត្តរវេទនាដែលកើតហើយ កើតព្រម ជាមួយមគ្គ ៤ ។ តែអាចារ្យពួកខ្លះពណ៌នាទុកាថា បទថា **អាយវំ** គឺ ការបដិបត្តិ ។ បទថា **តស្មិម្បី ឋានេ អនុប្បត្តេ** កាលបើនៅមិនទាន់បានសម្រេចឋានៈសូម្បីនោះ គឺ បាន សម្រេចភូមិនោះ ដូច្នេះ ។

( ចប់ អដ្ឋកថាបទេសវិហារញ្ញាណនិទ្ទេស )

# អដ្ឋកថា វិវដ្តញ្ញាណឆក្កនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងអដ្ឋកថាវិវដ្តញ្ញាណឆក្កនិទ្ទេស ដូចតទៅនេះ ។ បទថា **នេក្ខម្មាធិបតត្តា បញ្ញា** បញ្ញាមាននេក្ខម្មៈជាអធិបតី គឺ បញ្ញាដែលប្រព្រឹត្តទៅដ៏ក្រៃលែងក្នុងនេក្ខម្មៈ ធ្វើនេក្ខម្មៈឲ្យប្រសើរឡើង ។

បទថា **កាមច្ឆន្ទតោ សញ្ញាយ វិវដ្តតិ** រមែងគេចចេញចាកកាមច្ឆន្ទៈដោយបញ្ញាជាគ្រឿងត្រាស់ដឹង គឺ រមែងគេចចេញវិលត្រឡប់ចាកកាមច្ឆន្ទៈដែលជាហេតុ ជាការណៈ នៃសញ្ញាសម្បយុត្តដោយបញ្ញា ធ្វើនេក្ខម្មៈឲ្យជាធំក្រៃលែង ។ អធិប្បាយថា បែរខ្នងឲ្យកាមច្ឆន្ទៈ ក្នុងបទដ៏សេសក៏មានន័យនេះ ។

បទថា **កាមច្ឆន្ទោ នានត្តំ** កាមច្ឆន្ទៈ មានសេចក្តីផ្សេងៗ គឺ កាមច្ឆន្ទៈមិនមានសភាពតែមួយដូចគ្នា ព្រោះមិនមានការប្រព្រឹត្តស្ងប់ ។

បទថា **នេក្ខម្មំ ឯកត្តំ** នេក្ខម្មៈជាធម៌តែមួយ គឺ នេក្ខម្មៈមានសភាពតែមួយ ព្រោះមានសេចក្តីស្ងប់ ។



បទថា **នេក្ខម្មេកត្តំ ចេតយតោ** កាលបើព្រះយោគាវចរគិតដល់នេក្ខម្មៈជាធម៌តែមួយដូចគ្នា គឺ ញុំាងនេក្ខម្មៈឲ្យប្រព្រឹត្តទៅដោយការឃើញទោសក្នុងកាមច្ឆន្ទៈ ។

បទថា **កាមច្ឆន្ទតោ ចិត្តំ វិវដ្តតិ** ចិត្តរមែងគេចចេញចាកកាមច្ឆន្ទៈ គឺ ចិត្តរមែងគេចចេញចាកកាមច្ឆន្ទៈ ដោយសភាពជាទោស ដែលការឃើញក្នុងខណៈនៃនេក្ខម្មៈ ។ ក្នុងបទដ៏សេសក៏មានន័យនេះ ។

បទថា **កាមច្ឆន្ទំ បជហន្តោ** ព្រះយោគាវចរលះបង់ កាមច្ឆន្ទៈ គឺ លះបង់កាមច្ឆន្ទៈក្នុងខណៈបដិបត្តិនេក្ខម្មៈដោយ វិក្ខម្ភនប្បហានៈ ។

បទថា **នេក្ខម្មវសេន ចិត្តំ អធិដ្ឋាតិ** ព្រះយោគាវចររមែងអធិដ្ឋានចិត្តដោយអំណាចនៃនេក្ខម្មៈ បានដល់ ការតាំងចិត្តសម្បយុត្តដោយនេក្ខម្មៈនោះ ដោយអំណាចនៃនេក្ខម្មៈ ដែលបានហើយ គឺ ធ្វើឲ្យតាំងនៅយ៉ាងប្រសើរ ។ អធិប្បាយថា ឲ្យប្រព្រឹត្តទៅ ។ ក្នុងបទដ៏សេសក៏មាននន័យនេះ ។

បទថា **ចក្ខុ សុញ្ញំ អត្តេន វា** ចក្ខុសូន្យចាកខ្លួន គឺ

ចក្ខុសូន្យទទេចាកតខ្លួន ព្រោះមិនមានខ្លួន ពោលគឺ អ្នកធ្វើ អ្នកសោយ ដែលបុគ្គលពាលកំណត់ទុក ។ ព្រោះចក្ខុ ឈ្មោះថា សូន្យ ដោយចក្ខុមិនមានខ្លួន ។

បទថា **អត្តនិយេន វា** ចាកវត្ថុដែលជាប់នឹងខ្លួន គឺ សូន្យចាករបស់ជារបស់ខ្លួន ព្រោះមិនមានសូម្បីរបស់ខ្លួន ដោយមិនមានខ្លួន ។ លោកពោលការមិនមានខ្លួន និងការមិនមានវត្ថុដែលជាប់នឹងខ្លួន ដើម្បីបដិសេធការប្រកាន់ទាំងពីរយ៉ាង ព្រោះមានការប្រកាន់ដោយអាការទាំងពីររបស់សត្វលោកថា ខ្លួន និងវត្ថុដែលជាប់នឹងខ្លួន ។

បទថា **និច្ចេន វា** ចាកសភាពទៀង គឺ ឈ្មោះថា សូន្យចាកសភាពទៀង ព្រោះមិនមាននរណា ៗ ដែលនឹងកន្លងការបែកធ្លាយ ហើយតាំងនៅបាន ។

បទថា **ធុវេន វា** ចាកការយឺនយូរ គឺ ឈ្មោះថា ចាកការយឺនយូរ ព្រោះមិនមាននរណា ៗ ដែលនឹងតាំងមាំបាន សូម្បីក្នុងខណៈដែលប្រព្រឹត្តទៅ ។

បទថា **សស្សតេន វា** ចាកសភាពទៀងទាត់ គឺ ឈ្មោះថា



សូន្យចាកសភាពទៀងទាត់ ព្រោះមិនមាននរណា ៗ ដែលនឹងតាំងនៅអស់កាលរហូតបាន ។

បទថា **អវិបរិណាមធម្មេន វា** ចាកការមិនប្រែប្រួលជាធម្មតា គឺ ឈ្មោះថា សូន្យចាកការមិនប្រែប្រួលជាធម្មតា ព្រោះមិនមាននរណា ៗ ជាប្រក្រតី មិនប្រែប្រួលដោយហេតុពីរប្រការ គឺ **ជរា** ការចាស់ និង **ភង្គ** ការបែកធ្លាយទៅ ។

ម្យ៉ាងទៀត មានអធិប្បាយថា សូន្យចាកសេចក្តីទៀង ចាកសេចក្តីយឺនយូរ ចាកសេចក្តីទៀងទាត់ និងចាកសេចក្តីមិនប្រែប្រួលជាធម្មតា ។

បទថា **យថាភូតំ ជានតោ បស្សតោ** ព្រះយោគាវចរបានដឹង បានឃើញតាមសេចក្តីពិត គឺ ដឹងតាមសភាវៈដោយអនត្តានុបស្សនាញាណយ៉ាងនេះ និងឃើញ ដូចឃើញដោយភ្នែក ។

បទថា **ចក្ខាភិនិវេសតោ ញាណំ វិវដ្តតិ** ញាណ រមែងគេចចេញចាកការប្រកាន់ក្នុងចក្ខុ គឺ ញាណរមែងគេចចេញចាកការប្រកាន់ដែលឃើញហើយ ដែលប្រព្រឹត្តទៅថា ចក្ខុជាតួខ្លួន ឬជាវត្ថុដែលជាប់នឹងតួខ្លួន ។ ក្នុងបទដ៏សេស ក៏មានន័យនេះ ។

បទថា **នេក្ខម្មេន កាមច្ឆន្ទំ វោស្សជ្ជតិ** ព្រះយោគាវចរលះបង់កាមច្ឆន្ទៈដោយនេក្ខម្មៈ គឺ បុគ្គលអ្នកបាននេក្ខម្មៈ រមែងលះបង់កាមច្ឆន្ទៈដែលជាបដិបក្ខដល់នេក្ខម្មៈនោះ ដោយនេក្ខម្មៈ ។

បទថា **វោស្សគ្គេ បញ្ញា** បញ្ញាក្នុងការរលាស់ចេញ គឺ បញ្ញាសម្បយុត្តដោយនេក្ខម្មៈនោះ ក្នុងនេក្ខម្មៈដែលមានសភាពរលាស់ចេញនៃកាមច្ឆន្ទៈ ។

បទថា **បីឡនដ្ឋា** ការបៀតបៀនជាដើម មានអត្ថដូចបានពោលហើយក្នុងខាងក្រោយ ។

បទថា **បរិជានន្តោ វិវដ្ដតិ** កាលបើកំណត់ដឹង រមែងគេចចេញ ជាទេសនាបុគ្គលាធិដ្ឋាន លោកពោលថា បុគ្គលអ្នកព្រម-ព្រៀងដោយមគ្គ កំណត់ដឹងអត្ថ ៤ យ៉ាងនៃទុក្ខ ដោយអំណាចនៃកិច្ច រមែងគេចចេញ ដោយការចេញចាកទុក្ខ ។ បុគ្គលអ្នកព្រមព្រៀងដោយញាណ រមែងគេចចេញ សូម្បីក្នុងញាណវិវដ្ដៈ ។

បទថា **តថដ្ឋេន បញ្ញា** បញ្ញាក្នុងសេចក្ដីថា ធម៌ពិត គឺ វិវដ្ដនាបញ្ញា បញ្ញា គឺ ការគេចចេញ ក្នុងសេចក្ដីថា ធម៌ពិតរបស់បុគ្គលនោះ ។ ក្នុងបទដ៏សេសក៏មានន័យនេះ ។



ឥឡូវនេះ ព្រះសារីបុត្តត្ថេរ កាលនឹងសម្ដែងវិវដ្ដញ្ញាណ ៦ ដោយផ្សេងគ្នានៃអាការ ដោយអំណាចកិច្ចក្នុងខណៈនៃមគ្គ ទើបតាំងមាតិកាមានជាអាទិ៍ថា **សញ្ញា វិវដ្ដោ** ហើយកាលនឹងចែកមាតិកានោះដោយអត្ថ ទើបពោលបទ មានជាអាទិ៍ថា **សញ្ជានន្តោ វិវដ្ដតិ** ព្រះយោគាវចរ កាលដឹងព្រម រមែងគេចចេញទៅ ។

ក្នុងបទទាំងនោះ បទថា **សញ្ជានន្តោ វិវដ្ដតីតិ សញ្ញា-វិវដ្ដោ** ព្រះយោគាវចរ កាលដឹងព្រម រមែងគេចចេញ ព្រោះហេតុនោះ ទើបជាសញ្ញាវិវដ្ដៈ សេចក្ដីថា ព្រោះព្រះយោគាវចរ កាលដឹងព្រមនេក្ខម្មៈជាដើម ក្នុងចំណែកខាងដើមដោយភាពជាអធិបតី ចំណែកខាងក្រោយ រមែងគេចចេញចាកកាមច្ឆន្ទៈជាដើម ដោយញាណសម្បយុត្តជាមួយនេក្ខម្មៈ ។ ដូច្នោះ ញាណនោះ ទើបឈ្មោះថា សញ្ញាវិវដ្ដៈ ។

បទថា **ចេតយន្តោ វិវដ្ដតីតិ ចេតោវិវដ្ដោ** ព្រះយោ-គាវចរកាលគិត រមែងគេចចេញ ព្រោះហេតុនោះ ទើបឈ្មោះថា ចេតោវិវដ្ដៈ សេចក្ដីថា ព្រោះព្រះយោគាវចរ កាលគិតធម៌តែម្យ៉ាង មាននេក្ខម្មៈជាដើម រមែងគេចចេញចាកកាមច្ឆន្ទៈជាដើម

ដោយញាណ ដែលសម្បយុត្តដោយ នេក្ខម្មៈនោះ ។ ដូច្នោះ ញាណនោះទើបឈ្មោះថា ចេតោវិវដ្តៈ ។

បទថា **វិជានន្តោ វិវដ្ដតីតិ ចិត្តវិវដ្ដោ** ព្រះយោគាវចរ កាលដឹងច្បាស់ រមែងគេចចេញ ព្រោះហេតុនោះទើបឈ្មោះថា ចិត្តវិវដ្តៈ សេចក្តីថា ព្រោះព្រះយោគាវចរ កាលដឹងច្បាស់ដោយ ចិត្តអធិដ្ឋាន ដោយអំណាចនេក្ខម្មៈជាដើម រមែងគេចចេញចាក កាមច្ឆន្ទៈជាដើម ដោយញាណ ដែលសម្បយុត្តជាមួយនេក្ខម្មៈ នោះ ។ ដូច្នោះ ញាណនោះទើបឈ្មោះថា ចិត្តវិវដ្តៈ ។

បទថា **ញាណំ ករោន្តោ វិវដ្ដតីតិ ញាណវិវដ្ដោ** កាលញាណគេចចេញ ព្រោះហេតុនោះ ទើបជាញាណវិវដ្តៈ សេចក្តីថា ព្រោះព្រះយោគាវចរកាលធ្វើអាយតនៈខាងក្នុង ៦ ឲ្យ ដឹងច្បាស់ថាជារបស់សូន្យ ដោយអនត្តានុបស្សនាញាណ រមែង គេចចេញចាកការប្រកាន់មាំ ដោយការឃើញដោយញាណនោះ ឯង ។ ដូច្នោះ ញាណនោះ ទើបឈ្មោះថា ញាណវិវដ្តៈ ។

បទថា **វោសជ្ជន្តោ វិវដ្ដតីតិ វិមោក្ខវិវដ្ដោ** កាល បើរលាស់ចេញ រមែងគេចចេញ ព្រោះហេតុនោះ ទើបឈ្មោះថា



វិមោក្ខវិវដ្តៈ សេចក្តីថា ព្រោះព្រះយោគាវចរ កាលបើរលាស់ ផុតកាមច្ឆន្ទៈជាដើម ដោយនេក្ខម្មៈជាដើម រមែងគេចចេញចាក កាមច្ឆន្ទៈជាដើម ដោយញាណដែលសម្បយុត្តជាមួយនេក្ខម្មៈនោះ ។ ដូច្នោះ ញាណនោះ ទើបឈ្មោះថា វិមោក្ខវិវដ្តៈ ។

បទថា **តថដ្ឋេ វិវដ្ដតីតិ សច្ចវិវដ្ដោ** រមែងគេចចេញ ក្នុងសេចក្តីថា ធម៌ពិត ព្រោះហេតុនោះទើបឈ្មោះថា សច្ចវិវដ្តៈ សេចក្តីថា ព្រោះព្រះយោគាវចរ រមែងគេចចេញចាកទុក្ខក្នុង សេចក្តីថា ធម៌ពិត ៤ យ៉ាង ដោយអំណាចការចេញ ។ ដូច្នោះ មគ្គញាណ ទើបឈ្មោះថា សច្ចវិវដ្តៈ ។ ឬថា មគ្គញាណនោះឯង រមែងគេចចេញចាកទុក្ខ ក្នុងសេចក្តីថា ធម៌ពិត ដោយការចេញ ព្រោះហេតុនោះ ទើបឈ្មោះថា សច្ចវិវដ្តៈ ។

បទមានជាអាទិ៍ថា **យត្ថ សញ្ញាវិវដ្ដោ** ក្នុងខណៈនៃមគ្គ ណាមានសញ្ញាវិវដ្តៈ លោកពោលសំដៅដល់ខណៈនៃសច្ចវិវដ្តៈ ព្រោះលោកពោលទុកហើយក្នុងសច្ចវិវដ្តញាណនិទ្ទេស ។ ព្រោះ ញាណទាំងអស់ រមែងប្រកបនៅក្នុងមគ្គញាណនោះឯង ។ សួរថា យ៉ាងណា ? ឆ្លើយថា ព្រោះអរិយមគ្គមកហើយដោយសរុបក្នុង

ញាណដ៏សេស វៀរញាណក្នុងវិវដ្ដៈ ។ សូម្បីញាណក្នុងញាណ-វិវដ្ដៈ រមែងប្រកបក្នុងខណៈនៃមគ្គ ដោយអំណាចសម្រេចកិច្ចនៃវិបស្សនា ព្រោះវិបស្សនាសម្រេចកិច្ចដោយមគ្គនោះឯង ។ ឬថាការពោលដល់ញាណនោះ ក្នុងមគ្គញ្ញាណថា បទមានជាអាទិ៍ថា ចក្ខុំ សុញ្ញំ ចក្ខុសូន្យទទេ ជាការចាក់ធ្លុះដោយអំណាចនៃកិច្ចដូច្នេះ រមែងគួរ ក្នុងខណៈមគ្គនោះឯង ។

ម្យ៉ាងទៀត ក្នុងបទនេះ មានការប្រកបសេចក្ដីដូចតទៅនេះ គួរធ្វើការប្រកបក្នុងការប្រៀបធៀបទាំងអស់ ដោយន័យមានជាអាទិ៍ថា ក្នុងខណៈនៃមគ្គណា មានសញ្ញាវិវដ្ដៈ ក្នុងខណៈនៃមគ្គនោះ រមែងមានចេតោវិវដ្ដៈ ។ ក្នុងខណៈនៃមគ្គណា មានចេតោ-វិវដ្ដៈ ក្នុងខណៈនៃមគ្គនោះ មានសញ្ញាវិវដ្ដៈ ។ ម្យ៉ាងទៀត សច្ចវិវដ្ដៈមកហើយ ព្រោះអរិយមគ្គ ៤ មកដល់ហើយ ក្នុងសញ្ញាវិវដ្ដៈ ចេតោវិវដ្ដៈ ចិត្តវិវដ្ដៈ និងវិមោក្ខវិវដ្ដៈ ។

ម្យ៉ាងទៀត ញាណវិវដ្ដៈ ជាការសម្រេចដោយអំណាចនៃកិច្ច ដោយសច្ចវិវដ្ដៈនោះឯង ។ កាលពោលបេយ្យាលឲ្យពិស្ដារក្នុងសញ្ញាវិវដ្ដៈ ចេតោវិវដ្ដៈ ចិត្តវិវដ្ដៈ និងវិមោក្ខវិវដ្ដៈ សូម្បី



ញាណក្នុងញាណវិវដ្ដៈ ក៏មកហើយក្នុងញាណទាំងនោះ ព្រោះមានបាឋៈថា បញ្ញាមានអនត្តានុបស្សនាជាអធិបតី រមែងគេចចេញចាកការប្រកាន់មាំដោយសញ្ញា ព្រោះហេតុនោះ បញ្ញាជាអធិបតីទើបឈ្មោះថា សញ្ញាវិវដ្តញ្ញាណ ។ ការប្រកាន់មាំដោយសភាពផ្សេង ៗ អនត្តានុបស្សនាជាធម៌តែមួយ ។ កាលគិតដល់ភាពតែមួយរបស់អនត្តានុបស្សនា ចិត្តរមែងគេចចេញចាកការប្រកាន់មាំ ព្រោះហេតុនោះ បញ្ញាក្នុងសេចក្ដីផ្សេង ៗ ទើបជាចេតោ-វិវដ្តញ្ញាណ កាលលះសេចក្ដីប្រកាន់មាំ ចិត្តរមែងតាំងមាំដោយអំណាចនៃអនត្តានុបស្សនា ព្រោះហេតុនោះ បញ្ញាក្នុងការអធិ-ដ្ឋាន ទើបឈ្មោះថា ចិត្តវិវដ្តញ្ញាណ ។ និងរលាស់ការប្រកាន់មាំដោយអនត្តានុបស្សនា ព្រោះហេតុនោះ បញ្ញាក្នុងការរលាស់ចេញ ទើបឈ្មោះថា វិមោក្ខវិវដ្តញ្ញាណ ។

ម្យ៉ាងទៀត ក្នុងញាណវិវដ្ដៈ រមែងបានសច្ចវិវដ្ដៈផង ព្រោះប្រកបបទមានជាអាទិ៍ថា ចក្ខុសូន្យទទេចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន ដោយអំណាចកិច្ចរបស់អ្នកចេញចាកអនត្តានុបស្សនា ហើយបានអរិយមគ្គ ។ ព្រោះដូច្នោះ ក្នុងវិវដ្ដៈមួយ ៗ រមែងបានវិវដ្ដៈ ៥

ដ៏សេស ។ ព្រោះដូច្នោះ គប្បីជ្រាបថា លោកពោលប្រៀបធៀបទុកមានជាអាទិ៍ថា ក្នុងខណៈនៃមគ្គណាមានសញ្ញាវិវដ្តៈ ។ ក្នុងខណៈនៃមគ្គនោះ រមែងមានចេតោវិវដ្តៈ ដោយប្រការដូច្នេះ ។

( ចប់ អដ្ឋកថាវិវដ្តញ្ញាណឆក្កនិទ្ទេស )



# អដ្ឋកថា ឥទ្ធិវិធញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងឥទ្ធិវិធញ្ញាណនិទ្ទេសដូចតទៅនេះ ។

បទថា **ឥធ ភិក្ខុ** គឺ ភិក្ខុក្នុងសាសនានេះ ។

ក្នុងបទនេះថា **ឆន្ទសមាធិបធានសង្ខារសមន្នាគតំ** ដែលប្រកបដោយសមាធិដ៏ក្រៃលែង ដោយឆន្ទៈ និងសង្ខារ ជាប្រធានមានអធិប្បាយដូចតទៅនេះ ។ សមាធិមានឆន្ទៈជាហេតុ ឬសមាធិដ៏ក្រៃលែងដោយឆន្ទៈ ឈ្មោះថា **ឆន្ទសមាធិ** ។ បទនេះ ជាឈ្មោះរបស់សមាធិដែលបាន ព្រោះធ្វើកត្តុកម្យតាឆន្ទៈ សេចក្តីពេញចិត្តព្រោះប្រាថ្នានឹងធ្វើការងារ ឲ្យជាអធិបតី ។ សង្ខារជាប្រធានឈ្មោះថា **បធានសង្ខារទាំងឡាយ** បទនេះ ជាឈ្មោះរបស់សេចក្តីព្យាយាម គឺ សម្មប្បធាន ដែលឲ្យសម្រេចកិច្ច ៤ យ៉ាង ។ លោកធ្វើជាពហុវចនៈ ដោយអំណាចកិច្ច ៤ យ៉ាងឲ្យសម្រេច ។

បទថា **សមន្នាគតំ** ប្រកបហើយ គឺ ចូលដល់ហើយដោយសមាធិដ៏ក្រៃលែង ដោយឆន្ទៈ និងសង្ខារជាប្រធាន ។

បទថា **ឥទ្ធិបាទំ** ឥទ្ធិបាទ សេចក្ដីថា ពពួកចិត្ត និងចេតសិកដ៏សេសដែលជាបាទ ដោយការអធិដ្ឋាននៃសមាធិដ៏ក្រៃលែងដោយឆន្ទៈ និងសង្ខារជាប្រធាន ដែលសម្បយុត្តដោយចិត្តជាកុសល មានឧបចារឈានជាដើម ដែលបានឈ្មោះថា **ឥទ្ធិ** ព្រោះអត្ថថា សម្រេច ដោយបរិយាយនៃសេចក្ដីសម្រេច ឬដោយបរិយាយនេះថា សត្វទាំងឡាយជាអ្នកសម្រេចហើយ ចម្រើនហើយ ដល់សេចក្ដីប្រសើរវិសេសហើយ រមែងសម្រេចដោយឥទ្ធិនោះ ។ សមដូចលោកអធិប្បាយទុក ក្នុងសុត្តន្តភាជនីយ៍ ក្នុងឥទ្ធិបាទវិភង្គថា បទថា **ឥទ្ធិបាទោ** គឺ វេទនាខន្ធ ។ល។ វិញ្ញាណក្ខន្ធរបស់បុគ្គលនោះ ។ មួយវិញទៀត លោកពោលទុកក្នុងអភិធម្មភាជនីយ៍ថា បទថា **ឥទ្ធិបាទោ** គឺ ផស្សៈ វេទនា ។ល។ បគ្គាហៈ ការផ្គងទុក , អវិក្ខេបៈ សេចក្ដីមិនរាយមាយរបស់អ្នកនោះ ។ ព្រោះដូច្នោះ ក្នុងបទនេះថា **សេសចិត្តចេតសិករាសី** ពពួកនៃចិត្តចេតសិកដ៏សេស គប្បីជ្រាបថា លោកធ្វើឥទ្ធិបាទមួយ ៗ ក្នុងសមាធិដ៏ក្រៃលែងដោយឆន្ទៈ និងសង្ខារជាប្រធាន ហើយធ្វើពាក្យដ៏សេស ដោយបទមួយ ៗ ពីរ ៗ ។



ពិតណាស់ លោកសង្គ្រោះខន្ធ ៤ និងធម៌មានផស្សៈជាដើម ទាំងអស់ចូលជាមួយគ្នាយ៉ាងនេះ ។ ដោយន័យនេះ សូម្បីក្នុងបទដ៏សេស គប្បីជ្រាបសេចក្ដីដូចតទៅនេះ ។ សមាធិដែលបាន ព្រោះធ្វើវីរិយៈ ចិត្តៈ វិមំសាឲ្យជាអធិបតី លោកពោលថា វិមំសាសមាធិ ដូចសមាធិដែលបាន ព្រោះធ្វើឆន្ទៈឲ្យជាអធិបតី លោកពោលថា ឆន្ទសមាធិ ដូច្នោះ ។

ក្នុងឥទ្ធិបាទមួយៗ ធម៌តែមួយ ៗ មានបីៗ[១] គឺ មានឆន្ទៈជាដើម មានវីរិយៈជាដើម មានចិត្តៈជាដើម មានវិមំសាជាដើម លោកពោលថា ឥទ្ធិខ្លះ ឥទ្ធិបាទខ្លះ ដោយប្រការដូច្នេះ ។ ចំណែកខន្ធ ៤ យ៉ាង សម្បយុត្តគ្នា ដ៏សេសជាឥទ្ធិបាទតែម្យ៉ាង ។

ម្យ៉ាងទៀត គប្បីជ្រាបថា ព្រោះធម៌មួយ ៗ មានបី ៗ ទាំងនេះ រមែងសម្រេចព្រមគ្នាជាមួយខន្ធ ៤ ដែលសម្បយុត្តគ្នា ។ វៀរខន្ធ ៤ ទាំងនោះចេញ រមែងមិនសម្រេច ។ ដូច្នោះ ដោយ

---

១-មានឆន្ទៈជាដើម បានដល់ ធម៌ ៣ គឺ វីរិយៈ ចិត្តៈ វិមំសា កើតរួមជាមួយឆន្ទៈដែលជាប្រធាន ហៅថា ឆន្ទសមាធិ ។

ដោយបរិយាយនោះ សូម្បីខន្ធ ៤ ទាំងអស់ ក៏ឈ្មោះថា **ឥទ្ធិ** ព្រោះអត្ថថា ឲ្យសម្រេច ។ ឈ្មោះថា **បាទ** ព្រោះអត្ថថា ជាទីតាំង ។

ចំណែកក្នុងបទនេះថា **វីរិយសមាធិបធានសង្ខារសមន្នាគតំ** ប្រកបដោយសមាធិដ៏ក្រៃលែងដោយវីរិយៈ និងសង្ខារជាប្រធាន មានសេចក្ដីដូចតទៅនេះ ។ វីរិយៈ និងសង្ខារជាប្រធានតែមួយដូចគ្នា ។ បើសួរថា ព្រោះហេតុអ្វី លោកទើបពោលទុកជាពីរយ៉ាង ។ ឆ្លើយថា ក្នុងទីនេះលោកបំណងយកវីរិយៈមុនដោយការសម្ដែងវីរិយៈជាអធិបតី ដើម្បីសម្ដែងវីរិយៈនោះឯងឲ្យសម្រេចកិច្ច ៤ យ៉ាង លោកទើបពោលសង្ខារជាប្រធាន ។

ម្យ៉ាងទៀត ក្នុងបទនេះ ព្រោះលោកពោលទុកពីរយ៉ាងនោះឯង ទើបលោកពោលធម៌មួយ ៗ ទៅជាបី ៗ ។ ចំណែកអាចារ្យពួកខ្លះពោលថា ឈ្មោះថា **ឥទ្ធិ** នៅមិនទាន់សម្រេច ។ ឈ្មោះថា **ឥទ្ធិបាទ** សម្រេចហើយ ព្រោះលោកពោលទុកក្នុងវិភង្គថា សេចក្ដីសម្រេច សេចក្ដីសម្រេចដោយល្អ ការប្រាថ្នា ការប្រាថ្នាដោយល្អនូវធម៌នោះ ៗ ឈ្មោះថា **ឥទ្ធិ** ។ តែក្នុងទីនេះ



លោកសម្រេចថា ឥទ្ធិក្ដី ឥទ្ធិបាទក្ដី សម្រេចហើយ កម្ចាត់នូវតម្រេកបានហើយ ដោយបទមានជាអាទិ៍ថា **ឥទ្ធិ សមិទ្ធិ** គប្បីជ្រាបថា លោកពោលដល់ធម៌ដោយអាការ គឺ សេចក្ដីសម្រេច ។

បទថា **ភាវេតិ** រមែងចម្រើន គឺ រមែងសេព ។ សូម្បីក្នុងបទនេះ ការចម្រើនឥទ្ធិបាទជាលោកិយៈ ដូចក្នុងសុត្តន្តភាជនីយ៍ ព្រោះដូច្នោះ ព្រះយោគាវចរអ្នកបំណងនឹងញុំាងឥទ្ធិបាទឲ្យបរិបូរណ៍មុនចម្រើនឥទ្ធិបាទ ដែលជាលោកិយៈ ជាអ្នកចូលសមាបត្តិ ៨ រហូតដល់ភាពជំនាញក្នុងកសិណ ៨ មានបឋវីកសិណជាដើម

**ហ្វឹកហាត់ចិត្តដោយអាការ ១៤ ទាំងនេះ គឺ ៖**

ដោយអនុលោមកសិណ ១ , ដោយបដិលោមកសិណ ១ , ដោយអនុលោមបដិលោមកសិណ ១ , ដោយអនុលោមឈាន ១ , ដោយបដិលោមឈាន ១ , ដោយអនុលោមបដិលោមឈាន ១ , ដោយឈានទៅកាន់ឈាន ១ , ដោយឈានកន្លងកសិណ ១ , ដោយឈានកន្លងឈាន និងកសិណ ១ , ដោយស្ទុះទៅកាន់អង្គ ១ , ដោយស្ទុះទៅកាន់អារម្មណ៍ ១ , ដោយស្ទុះទៅកាន់អង្គ និងអារម្មណ៍ ១ , ដោយកំណត់អង្គ ១ , ដោយកំណត់

អារម្មណ៍ ១ ហើយចូលឈានរឿយៗ ដោយអំណាចឆន្ទៈ វីរិយៈ ចិត្តៈ វីមំសាជាប្រធាន ។ អាចារ្យពួកខ្លះប្រាថ្នា សូម្បីការកំណត់អង្គ និងអារម្មណ៍ ។ អ្នកដល់ព្រមដោយហេតុខាងដើម សន្សំភាពជំនាញក្នុងហេតុត្រឹមតែឈាន ៤ ពួក ក្នុងកសិណទាំងឡាយ រមែងសមគួរ ព្រោះហេតុនោះ ព្រះយោគាវចរចម្រើនឥទ្ធិបាទសមាធិនោះ ៗ រមែងអធិដ្ឋានវីរិយៈ ៤ ប្រការមានជាអាទិ៍ថា ដើម្បីមិនឲ្យកើតអកុសលធម៌ដ៏លាមកដែលនៅមិនទាន់កើតឲ្យកើតឡើង លុះដឹងសេចក្ដីវិនាស និងសេចក្ដីចម្រើនរបស់សមាធិនោះហើយ រមែងអធិដ្ឋានវីរិយៈទុករឿយ ៗ ។ ព្រះយោគាវចរនោះ អប់រំចិត្តក្នុងឥទ្ធិបាទ ៤ យ៉ាងនេះហើយ រមែងញ៉ាំងឥទ្ធិវិធឲ្យសម្រេចបាន ។

បទថា **សោ** ក្នុងបទមានជាអាទិ៍ថា **សោ ឥមេសុ ចតូសុ ឥទ្ធិបាទេសុ** គឺ ភិក្ខុអ្នកចម្រើនឥទ្ធិបាទ ៤ នោះ ។

បទថា **ចតូសុ ឥទ្ធិបាទេសុ ចិត្តំ បរិភាវេតិ** ភិក្ខុរមែងអប់រំចិត្តក្នុងឥទ្ធិបាទ ៤ គឺ ភិក្ខុធ្វើឥទ្ធិបាទមួយ ៗ ក្នុងឆន្ទៈទាំងឡាយរឿយ ៗ ហើយ ឈ្មោះថា អប់រំចិត្តក្នុងឥទ្ធិបាទ



ទាំងនោះដោយការចូលឈាន ។ អធិប្បាយថា ឲ្យកាន់យកអាការអប់រំឆន្ទៈជាដើម ។

បទថា **បរិទមេតិ** រមែងគ្របសង្កត់ចិត្ត គឺ ធ្វើចិត្តឲ្យអស់ការប្រកាន់ខ្លួន ។ បទមុនពោលដល់នៃរបស់បទក្រោយ ។ ព្រោះចិត្តដែលអប់រំហើយ រមែងជាចិត្តដែលគ្របសង្កត់បាន ។

បទថា **មុទុំ ករោតិ** ធ្វើឲ្យជាចិត្តទន់ គឺ ធ្វើចិត្តដែលគ្របសង្កត់ទុកបានហើយនោះឯង ឲ្យដល់ភាពជំនាញ ។ ព្រោះចិត្តឲ្យប្រព្រឹត្តទៅក្នុងអំណាច លោកពោលថា **មុទុ** ទន់ ។

បទថា **កម្មនិយំ** គួរដល់ការងារ គឺ ធ្វើឲ្យសមគួរដល់ការងារ ។ ព្រោះចិត្តទន់រមែងគួរដល់ការងារ ដូចមាសដែលបានដេញល្អហើយ ។ តែក្នុងទីនេះ បានដល់ ចិត្តគួរដល់ការងារ គឺ សម្ដែងឫទ្ធិបាន ។

បទថា **សោ** គឺ ភិក្ខុអ្នកមានចិត្តអប់រំហើយ ។ លោកពោលបទមានជាអាទិ៍ថា **កាយម្បិ ចិត្តេ សមោទហតិ** រមែងតាំងកាយទុកក្នុងចិត្តខ្លះ ដើម្បីសម្ដែងវិធីយោគៈ ដើម្បីសម្រេចនៃការត្រាច់ទៅរបស់ចិត្តតាមសប្បាយ ក្នុងវេលាធ្វើឥទ្ធិ ។

ក្នុងបទទាំងនោះ បទថា **កាយម្បិ ចិត្តេ សមោទហតិ** រមែងតាំងកាយទុកក្នុងចិត្តខ្លះ សេចក្តីថា រមែងតាំង គឺ ឲ្យចូលទៅលើកករជកាយទុកក្នុងចិត្ត មានឈានជាបាទខ្លះ ។ អធិប្បាយថា ធ្វើកាយឲ្យប្រព្រឹត្តទៅតាមចិត្ត ។ ការធ្វើយ៉ាងនេះ រមែងមាន ដើម្បីឧបការៈដល់ការទៅដោយកាយដែលមិនប្រាកដ ។

បទថា **ចិត្តម្បិ កាយេ សមោទហតិ** រមែងតាំងចិត្តទុកក្នុងកាយខ្លះ សេចក្តីថា រមែងតាំង គឺ លើកចិត្តមានឈានជាបាទក្នុងករជកាយរបស់ខ្លួន អធិប្បាយថា ធ្វើចិត្តឲ្យប្រព្រឹត្តទៅតាមកាយខ្លះ ។ ការធ្វើយ៉ាងនេះ រមែងមានដើម្បីឧបការៈដល់ការទៅដោយកាយដែលប្រាកដ ។ បាឋៈថា **សមាទហតិ** ខ្លះ ។ សេចក្តីថា ឲ្យតាំងទុក ។

បទថា **កាយវសេន ចិត្តំ បរិណាមេតិ** រមែងបង្អោនចិត្តទៅដោយអំណាចនៃកាយខ្លះ សេចក្តីថា កាន់យកចិត្តមានឈានជាបាទលើកឡើងក្នុងករជកាយ ។ ធ្វើឲ្យប្រព្រឹត្តទៅតាមកាយ ។ បទនេះជាវេវចនៈរបស់ការតាំងចិត្តទុកក្នុងកាយ ។

បទថា **ចិត្តវសេន កាយំ បរិណាមេតិ** រមែងបង្អោនកាយ



ទៅដោយអំណាចរបស់ចិត្តខ្លះ សេចក្តីថា កាន់យកករជកាយហើយ លើកទុកក្នុងចិត្តដែលមានឈានជាបាទ ធ្វើឲ្យប្រព្រឹត្តទៅតាមចិត្ត ។ បទនេះជាវេវចនៈរបស់ការតាំងកាយទុកក្នុងចិត្ត ។

បទថា **អធិដ្ឋាតិ** រមែងអធិដ្ឋាន គឺ អធិដ្ឋានថា សូមឲ្យជាយ៉ាងនេះចុះ ។ លោកពោលដល់ការបង្អោនទៅ ដើម្បីអធិប្បាយអត្ថនៃសេចក្តីតាំងទុក ។ លោកពោលដល់អធិដ្ឋាន ដើម្បីអធិប្បាយអត្ថនៃការបង្អោនទៅ ។ ព្រោះបទថា **សមោទហតិ** ជាបទតាំង ។ បទថា **បរិណាមេតិ អធិដ្ឋាតិ** ជាបទអធិប្បាយរបស់បទថា **សមោទហតិ** នោះ ។ ដូច្នោះ ដោយអំណាចនៃបទទាំងពីរនោះ លោកទើបពោលថា **បរិណាមេត្វា** បង្អោនទៅហើយ **អធិដ្ឋហិត្វា** អធិដ្ឋានហើយ ។ មិនពោលថា **សមោទហិត្វា** តាំងទុកហើយ ។

បទថា **សុខសញ្ញញ្ច លហុសញ្ញញ្ច កាយេ ឱក្កមិត្វា វិហរតិ** រមែងបញ្ចូលសុខសញ្ញា និងលហុសញ្ញាក្នុងកាយ សេចក្តីថា រមែងបញ្ចូលសុខសញ្ញាដែលកើតរួមជាមួយចតុត្ថជ្ឈាន និងលហុសញ្ញា ឲ្យចូលទៅក្នុងករជកាយ សូម្បីករជកាយ

របស់ភិក្ខុនោះអ្នកមានកាយធ្លាក់ចុះក្នុងសញ្ញានោះ ក៏ជាករជកាយស្រាលដូចប៉ុយគ ។

បទថា **សោ** គឺ ភិក្ខុអ្នកធ្វើយោគវិធីនោះ ។

បទថា **តថា ភាវិតេន ចិត្តេន** មានចិត្តដែលអប់រំហើយជាតតិយាវិភត្តិចុះក្នុងលក្ខណៈនៃឥត្ថម្ភូតៈ មាន ឬចុះក្នុងអត្ថនៃហេតុ ព្រោះសេចក្ដីថា មានចិត្តដែលអប់រំហើយ គឺ ជាហេតុ ។

បទថា **បរិសុទ្ធេន** បរិសុទ្ធិ៍ គឺ ឈ្មោះថា សេចក្ដីបរិសុទ្ធិ៍នៃសតិក្នុងឧបេក្ខា ។ ឈ្មោះថា ផូរផង់ ព្រោះបរិសុទ្ធិ៍នោះឯង ។ អធិប្បាយថា ចិត្តត្រចះត្រចង់ ស្រស់ថ្លា ។

បទថា **ឥទ្ធិវិធញ្ញាណាយ** ដើម្បីឥទ្ធិវិធញ្ញាណ គឺ ក្នុងចំណែកនៃឥទ្ធិ ។ ឬដើម្បីត្រូវការញាណក្នុងការកំណត់ឥទ្ធិ ។

បទថា **ចិត្តំ អភិនីហរតិ** រមែងបង្អោនចិត្តទៅ គឺ ភិក្ខុនោះ កាលបើចិត្តមានអភិញ្ញាជាបាទកើតហើយ ដោយអំណាចប្រការដូចពោលហើយ រមែងបង្អោនបរិកម្មចិត្តទៅ ដើម្បីសម្រេចឥទ្ធិវិធញ្ញាណ ។ នាំចេញចាកអារម្មណ៍កសិណ ហើយឆ្ពោះមុខទៅកាន់ឥទ្ធិវិធ ។



បទថា **អភិនិន្នាមេតិ** រមែងបង្អោនទៅ គឺ ធ្វើការបង្អោនទៅកាន់ឥទ្ធិដែលគួរសម្រេចឲ្យទៅកាន់ឥទ្ធិ ។

បទថា **សោ** គឺ ភិក្ខុអ្នកធ្វើចិត្តឲ្យមានអភិនិហារយ៉ាងនេះ ។

បទថា **អនេកវិហិតំ** ច្រើនយ៉ាង គឺ ច្រើនយ៉ាងមានប្រការផ្សេងៗ ។

បទថា **ឥទ្ធិវិធំ** សម្ដែងឫទ្ធិបាន គឺ ចំណែកនៃឫទ្ធិ ឬកំណត់ឫទ្ធិ ។

បទថា **បច្ចនុភោតិ** គឺ រមែងសោយផល ។ អធិប្បាយថា រមែងធ្វើសម្ផ័ស្សឲ្យជាក់ច្បាស់ គឺ សម្រេច ។ ពេលនេះ ព្រះសារីបុត្តត្ថេរកាលនឹងសម្ដែងភាពដែលភិក្ខុនោះ សម្ដែងឫទ្ធិបានច្រើនយ៉ាង ទើបពោលបទមានជាអាទិ៍ថា **ឯកោបិ ហុត្វា** ។

ក្នុងបទទាំងនោះ បទថា **ឯកោបិ ហុត្វា** គឺ សូម្បីបុគ្គលតែម្នាក់ សេចក្ដីថា តាមប្រក្រតីមុនសម្ដែងឫទ្ធិជាបុគ្គលម្នាក់ ។

បទថា **ពហុធា ហោតិ** ជាបុគ្គលច្រើននាក់ គឺ បំណងនឹងដើរចង្ក្រមក្នុងសំណាក់របស់ភិក្ខុច្រើនក្ដី បំណងនឹងស្វាធ្យាយ

ក្តី បំណងនឹងសួរបញ្ហាក្តី ជារយក៏បាន ជាពាន់ក៏បាន ។ សួរថា ធ្វើយ៉ាងនោះបានដោយហេតុដូចម្តេច ? ឆ្លើយថា ប្រសិនបើ ភិក្ខុនោះញុំាងធម៌ដែលជាបទមូល របស់បាទនៃភូមិរបស់ឫទ្ធិឲ្យ ពេញលេញ ហើយចូលឈានជាបាទនៃអភិញ្ញា លុះចេញហើយ ប្រាថ្នាជារយ ក៏បរិកម្មថា សូមឲ្យខ្លួនយើងមានចំនួនជារយនាក់ ៗ ហើយចូលឈានដែលជាបាទ លុះចេញអំពីឈាននោះហើយ ក៏ អធិដ្ឋាន ព្រមជាមួយនឹងការអធិដ្ឋាននោះឯង ក៏សម្រេចជារយនាក់ បាន ។ សូម្បីក្នុងពាន់នាក់ជាដើម ក៏មានន័យនេះដូចគ្នា ។ ប្រសិនបើមិនប្រាថ្នាយ៉ាងនោះ គប្បីធ្វើបរិកម្មទៀត ហើយចូល ជាលើកទីពីរ លុះចេញវិញហើយទើបអធិដ្ឋាន ។

ក្នុងអដ្ឋកថាសំយុត្ត លោកពោលថា គួរចូល ១ ដង ឬ ២ ដង ក្នុងការចូលនោះ ចិត្តមានឈានជាបាទ មាននិមិត្តជា អារម្មណ៍ ។ ចិត្តបរិកម្មមានចំនួនរយ ឬចំនួនពាន់ជាអារម្មណ៍ ។ ចិត្តទាំងនោះឯង ដោយអំណាចវណ្ណៈ មិនមែនដោយអំណាចនៃ បញ្ញត្តិ ។ សូម្បីចិត្តអធិដ្ឋានមានចំនួនរយ ឬចំនួនពាន់ជាអារម្មណ៍ ដូចគ្នា ។ ចិត្តនោះមានអារម្មណ៍តែមួយប៉ុណ្ណោះ ជារូបាវចរចតុ-



ត្ថជ្ឈាន រមែងកើតឡើងក្នុងលំដាប់គោត្រភូ ដូចអប្បនាចិត្តពេល ដំបូង ។

ក្នុងបទថា **ពហុធា ហោតិ** នោះ អ្នកដែលនិមិត្តបានច្រើន ដូចគ្នានឹងអ្នកមានឫទ្ធិ ព្រោះនិមិត្តមិនកំណត់ទុក ។ រមែងធ្វើ វត្ថុដែលអ្នកមានឫទ្ធិធ្វើបានក្នុងការឈរ ការអង្គុយជាដើម ឬក្នុង ការនិយាយ ការនៅស្ងៀមជាដើម ។ ប្រសិនបើប្រាថ្នានឹងធ្វើ រូបនិមិត្តប្រភេទផ្សេង ៗ ធ្វើពួកខ្លះជាបឋមវ័យ ។ ពួកខ្លះជា មជ្ឈិមវ័យ ។ ពួកខ្លះជាបច្ឆិមវ័យ ។ ពួកខ្លះមានសក់វែង ពាក់កណ្តាលកោរសក់ មានសក់ផ្កាថ្កូវ មានចីវរពណ៌ក្រហម ពាក់កណ្តាល ពណ៌សពាក់កណ្តាល សូត្របទភាណ សម្តែង ធម្មកថា សូត្រសរភញ្ញ សួរបញ្ហា ឆ្លើយបញ្ហា ហាលចីវរ ជ្រលក់ចីវរ ដេរ និងបោកចីវរជាដើម ក៏ដូចគ្នា ឬបំណងនឹង ធ្វើនានប្បការយ៉ាងដទៃ ។ លុះចេញចាកឈានដែលជាបាទហើយ ធ្វើបរិកម្មដោយន័យមានជាអាទិ៍ថា ភិក្ខុប្រមាណប៉ុណ្ណេះ ចូរជា បឋមវ័យ ហើយចូលសមាបត្តិទៀត លុះចេញហើយគប្បីអធិដ្ឋាន ព្រមជាមួយចិត្តអធិដ្ឋាន ភិក្ខុរមែងប្រព្រឹត្តទៅតាមដែលខ្លួនអធិដ្ឋាន

ដោយ ប្រការដូច្នេះ ។

ក្នុងបទមានជាអាទិ៍ថា **ពហុធាបិ ហុត្វា ឯកោ ហោតិ** បុគ្គលច្រើននាក់មកតែម្នាក់ក៏បាន ក៏មានន័យនេះ ។ តែមានសេចក្ដីផ្សេងគ្នាដូចតទៅនេះ ពិតហើយ ភិក្ខុនេះ លុះនិមិត្តរូបដ៏ច្រើនយ៉ាងនេះហើយ ក៏គិតទៀតថា យើងនឹងដើរចង្ក្រមតែម្នាក់ឯងប៉ុណ្ណោះ ។ យើងនឹងធ្វើការស្វាធ្យាយ ។ យើងនឹងសួរបញ្ហាដូច្នេះក្ដី គិតថា វិហារនេះមានភិក្ខុតិច ។ បើមានភិក្ខុខ្លះនិមន្តមក ។ ភិក្ខុប្រមាណប៉ុណ្ណោះនឹងគង់នៅទីណា ។ នឹងដឹងដល់យើងថា នេះជាអានុភាពរបស់ព្រះថេរៈ ពិតប្រាកដក្ដី ទើបប្រាថ្នាថា សូមឲ្យយើងមកជាមនុស្សម្នាក់ ព្រោះជាអ្នកប្រាថ្នាតិច ចូលឈានជាបាទ លុះចេញចាកឈាន ទើបធ្វើបរិកម្មថា សូមឲ្យយើងជាមនុស្សតែម្នាក់ ហើយចូលឈានម្ដងទៀត ពេលចេញចាកឈានគប្បីអធិដ្ឋានថា សូមឲ្យយើងជាមនុស្សតែម្នាក់ចុះ ។ ភិក្ខុនោះក៏នឹងមកតែម្នាក់ ព្រមជាមួយនឹងចិត្តដែលអធិ-ដ្ឋាននោះឯង ។ បើមិនធ្វើយ៉ាងនេះ រមែងមានតែខ្លួនឯងម្នាក់ប៉ុណ្ណោះ ដោយអំណាចតាមការដែលកំណត់ទុក ។



បទថា **អាវិភាវំ** គឺ ធ្វើឲ្យប្រាកដ ។

បទថា **តិរោភាវំ** ធ្វើឲ្យកំបាំងក៏បាន ។ គប្បីភ្ជាប់បទមុនថា **អាវិភាវំ បច្ចនុភោតិ ។ តិរោភាវំ បច្ចនុភោតិ** សម្ដែងឲ្យប្រាកដក៏បាន ។ សម្ដែងឲ្យបាត់ទៅក៏បាន ។ ក្នុងបទនេះអ្នកមានឫទ្ធិបំណងនឹងធ្វើឲ្យប្រាកដ ។ រមែងធ្វើទីងងឹតឲ្យភ្លឺក៏បាន ។ ឬធ្វើទីកំបាំងឲ្យឃើញក៏បាន ។ ឬធ្វើទីមិនមែនជាគន្លងនៃភ្នែក ឲ្យមកជាគន្លងនៃភ្នែក ។ សួរថា យ៉ាងដូចម្ដេច ? ឆ្លើយថា ដូចជាភិក្ខុនេះសូម្បីនៅក្នុងទីកំបាំង ឬសូម្បីនៅក្នុងទីឆ្ងាយ ក៏ប្រាកដបាន ។ បំណងសម្ដែងខ្លួន ឬអ្នកដទៃឲ្យប្រាកដក៏ដូច្នោះ លុះចេញចាកឈាន ជាបាទហើយក៏នឹកថា សូមទីកំបាំងនេះកុំឲ្យកំបាំងឡើយ ។ ឬសូមទីដែលមិនមែនជាគន្លងនៃភ្នែក ចូរជាគន្លងនៃភ្នែកចុះ ហើយបរិកម្មអធិដ្ឋាន ដោយន័យដូចពោលហើយនោះឯង ។ ព្រមជាមួយនឹងការអធិដ្ឋាន រមែងប្រព្រឹត្តទៅតាមការអធិដ្ឋាននោះ ។ អ្នកដទៃសូម្បីឈរនៅក្នុងទីឆ្ងាយក៏ឃើញបាន ។ ប្រាថ្នាចង់ឃើញសូម្បីខ្លួនឯងក៏ឃើញបាន ។ ប្រាថ្នានឹងធ្វើឲ្យបាត់ទៅ រមែងធ្វើទីភ្លឺឲ្យងងឹតបាន ឬធ្វើទីកំបាំងមិនឲ្យកំបាំងបាន ។

ឬធ្វើទីដែលជាគន្លងនៃភ្នែក មិនឲ្យជាគន្លងនៃភ្នែកបាន ។ សួរថា យ៉ាងណា ? ឆ្លើយថា ដូចជាសូម្បីនៅក្នុងទីកំបាំង ឬសូម្បីឈរនៅក្នុងទីឆ្ងាយដែលមិនប្រាកដ យ៉ាងណា ។ ភិក្ខុបំណងនឹងសម្តែងខ្លួន ឬអ្នកដទៃក៏ដូច្នោះ លុះចេញចាកឈានជាបាទហើយនឹកគិតថា សូមទីមិនកំបាំងនេះចូរកំបាំងចុះ ។ ឬសូមទីដែលជាគន្លងចក្ខុនេះ ចូរមិនមែនគន្លងចក្ខុ ហើយធ្វើបរិកម្មអធិដ្ឋានដោយន័យដូចពោលហើយនោះឯង ។ ព្រមនឹងការអធិដ្ឋានរមែងប្រព្រឹត្តទៅ តាមការអធិដ្ឋាននោះ ។ អ្នកដទៃសូម្បីឈរនៅទីជិត ក៏មិនប្រាកដ ។ សូម្បីបំណងនឹងមិនឲ្យឃើញខ្លួនឯងក៏មិនឃើញ ។ ម្យ៉ាងទៀត បាដិហារ្យ៍ដែលប្រាកដសូម្បីទាំងអស់ ឈ្មោះថា ធ្វើឲ្យប្រាកដ ។ បាដិហារ្យ៍ដែលមិនប្រាកដឈ្មោះថា ធ្វើឲ្យបាត់ទៅ ។

ក្នុងបាដិហារ្យ៍ធ្វើឲ្យប្រាកដនោះ ឫទ្ធិក្តី អ្នកមានឫទ្ធិក្តីរមែងប្រាកដ ។ គប្បីសម្តែងបាដិហារ្យ៍ដែលប្រាកដនោះ ដោយយមកបាដិហារ្យ៍ ។ ក្នុងបាដិហារ្យ៍ដែលមិនប្រាកដ ឫទ្ធិប៉ុណ្ណោះរមែងប្រាកដ អ្នកមានឫទ្ធិមិនប្រាកដ ។ គប្បីសម្តែង



បាដិហារ្យ៍ដែលមិនប្រាកដនោះ ដោយយមកសូត្រ និងដោយព្រហ្មនិមន្តនិកសូត្រ ។

បទថា **តិរោកុឌ្ឌំ** ខាងក្រៅជញ្ជាំង គឺ ជញ្ជាំងដទៃ ។ អធិប្បាយថា ចំណែកដទៃ ។ ចំណែកខាងក្រៅកំផែង ខាងក្រៅភ្នំ ក៏មានន័យនេះ ។ បទថា **កុឌ្ឌោ** គឺ ជញ្ជាំងក្រុង ។

បទថា **បាការោ** គឺ កំផែងជុំវិញក្រុង វិហារ និងផ្ទះជាដើម ។ បទថា **បព្វតោ** គឺ ភ្នំដី ឬភ្នំថ្ម ។ **អសជ្ជមានោ** គឺ មិនជាប់ ។ បទថា **សេយ្យថាបិ អាកាសេ** គឺ ដូចទៅក្នុងទីទទេ ។

ម្យ៉ាងទៀត អ្នកបំណងនឹងទៅយ៉ាងនេះ គប្បីចូលអាកាសកសិណ លុះចេញហើយនឹកគិតដល់ជញ្ជាំងក្តី កំផែងក្តី ភ្នំក្តី ហើយធ្វើបរិកម្មអធិដ្ឋានថា សូមឲ្យជារបស់ទទេចុះ ។ រមែងជាទីទទេបាន ។ អ្នកបំណងនឹងចុះទៅកាន់ទីទាបក្តី បំណងឡើងទៅកាន់ខាងលើក្តី រមែងបានតាមប្រាថ្នា ។ អ្នកបំណងនឹងទំលុះទៅ ក៏រមែងទៅជាចន្លោះបាន ។

ភិក្ខុនោះទៅបានដោយមិនទើសទាក់ក្នុងទីនោះ ។ ម្យ៉ាងទៀតហើយទៅ ។ ការចូលឈានហើយ អធិដ្ឋានម្តងទៀតមិនខុសឬ

មិនខុស ។ ព្រោះការចូលឈាន ហើយអធិដ្ឋានម្តងទៀត រមែងដូចជាការកាន់យកនិស្ស័យ ក្នុងសំណាក់របស់ព្រះឧបជ្ឈាយ៍ ។ ព្រោះភិក្ខុនេះអធិដ្ឋានថា សូមជាទីវាលទទេចុះ ដូច្នេះរមែងជាទីវាលទទេទាន់ពេល ។ ប្រការដូចជាភ្នំក្តី ដើមឈើក្តី កើតឡើងតាមរដូវកាលក្នុងរវាងភិក្ខុនោះ ដោយកម្លាំងអធិដ្ឋានមកពីមុន មិនមែនជាឋានៈ ។ តែការនិម្មិតលើកដំបូង រមែងជាកម្លាំងក្នុងការដែលអ្នកមានឫទ្ធិដទៃនិម្មិតហើយ ។ អ្នកមានឫទ្ធិក្រៅអំពីនេះ គួរទៅពីខាងលើ ឬពីខាងក្រោមភិក្ខុនោះ ។

ក្នុងបទនេះថា **បឋវិយាបិ ឧម្មុជ្ជនិម្មុជ្ជំ** ផុសឡើង មុជចុះក្នុងផែនដីក៏បាន មានសេចក្តីដូចតទៅនេះ ។

បទថា **ឧម្មុជ្ជំ** ផុសឡើង បានដល់ ងើបឡើង ។

បទថា **និម្មុជ្ជំ** មុជចុះ បានដល់ លិចចុះ ។

ការផុសឡើង និងមុជចុះ ឈ្មោះថា **ឧម្មុជ្ជនិម្មុជ្ជំ** ។

មយ៉ាងទៀត ភិក្ខុបំណងនឹងធ្វើយ៉ាងនេះ ចូលអាបោកសិណ លុះចេញហើយកំណត់ថា សូមផែនដីក្នុងទីប្រមាណប៉ុណ្ណោះ ចូរជាទឹកចុះ ហើយបរិកម្ម គប្បីអធិដ្ឋានដោយន័យដូចពោលហើយ



នោះឯង ។ ផែនដីរមែងទៅជាទឹកទាន់ពេល តាមដែលកំណត់ទុកព្រមជាមួយការអធិដ្ឋាននោះ ។

ភិក្ខុនោះ រមែងផុសឡើង មុជចុះក្នុងផែនដីនោះ ដូចនៅក្នុងទឹក ។ មិនមែនត្រឹមតែការផុសឡើង មុជចុះតែម្យ៉ាងប៉ុណ្ណោះទេ នៅធ្វើវត្ថុដទៃតាមប្រាថ្នាក៏បាន ដូចជាការងូត ការផឹក ការលុបលាងមុខ និងការលាងរបស់ប្រើប្រាស ។ មយ៉ាងទៀត មិនមែនធ្វើតែទឹកតែម្យ៉ាងប៉ុណ្ណោះទេ នៅទឹកដល់វត្ថុដែលប្រាថ្នាជាដើមថា ទឹកដោះថ្លា ប្រេង ទឹកឃ្មុំ និងទឹកអំពៅថា សូមវត្ថុនេះ ៗ ចូរជាវត្ថុប្រមាណប៉ុណ្ណោះចុះ ដូច្នេះហើយ ក៏បរិកម្មអធិដ្ឋាន រមែងប្រព្រឹត្តទៅតាមការអធិដ្ឋាននោះបាន ។ កាលលើកឡើងដាក់ភាជនៈ ទឹកដោះថ្លាក៏ជាទឹកដោះថ្លា ។ ប្រេងជាដើមក៏ជាប្រេង ទឹកក៏ជាទឹក ។ ភិក្ខុនោះបំណងនឹងឲ្យទទឹកក្នុងទឹកនោះ ក៏ទទឹក ។ បំណងនឹងមិនឲ្យទទឹក ក៏មិនទទឹក ។

មយ៉ាងទៀត ផែនដីនោះ រមែងជាទឹកចំពោះតែភិក្ខុនោះប៉ុណ្ណោះ ។ ជាផែនដីដល់ជនដ៏សេស ។ លើផែនដីនោះ មនុស្សក៏គង់ដើរទៅមកបាន ។ យានទាំងឡាយក៏ប្រព្រឹត្តទៅបាន ។

សូម្បីកសិកម្មជាដើម ក៏ធ្វើបានដូចគ្នា ។ ប្រសិនបើភិក្ខុនេះបំណងថា ផែនដីនេះចូរទៅជាទឹកដល់ជនទាំងនោះចុះ ។ ក៏រមែងទៅជាទឹកតែម្តង ។ គ្រាកន្លងកាលដែលកំណត់ទុក ទីដែលកំណត់ទុកដ៏សេស វៀរទឹកក្នុងថ្នាំង និងក្នុងស្រះជាដើម តាមប្រក្រតី ក៏រមែងជាផែនដីវិញ ។

ក្នុងបទនេះថា **ឧទកេបិ អភិជ្ជមានេ គច្ឆតិ** ដើរទៅលើទឹកមិនលិចចុះបាន មានអធិប្បាយដូចតទៅនេះ ។ លោកពោលដល់ទឹកដែលជាន់លើហើយលិចថា **ភិជ្ជមានំ** គឺ ទឹកបែក ។ ទឹកផុយគ្នានឹងបែក ។ ភិក្ខុបំណងទៅយ៉ាងនេះ ចូលបឋវីកសិណ លុះចេញហើយកំណត់ថា សូមទឹកនេះចូរ ក្លាយទៅជាផែនដីក្នុងទីប្រមាណប៉ុណ្ណោះចុះ ហើយធ្វើបរិកម្ម គប្បីអធិដ្ឋានដោយន័យដូចពោលហើយនោះឯង ។ ទឹក រមែងក្លាយជាផែនដីក្នុងទីតាមដែលកំណត់ ព្រមជាមួយការអធិដ្ឋាន ។

ភិក្ខុនោះ ដើរលើទឹកនោះដូចដើរលើផែនដី ។ មិនមែនដើរទៅតែម្យ៉ាងនោះទេ ។ អាចឲ្យសម្រេចឥរិយាបថតាមប្រាថ្នាបាន ។ មិនមែនធ្វើឲ្យទៅជាផែនដីតែម្យ៉ាងប៉ុណ្ណោះ ។ នៅទឹក



អធិដ្ឋានវត្ថុតាមប្រាថ្នាជាដើមថា កែវមណី មាស ក្អំ និងដើមឈើ ដោយន័យដូចពោលហើយ បានទៀតផង ។ រមែងប្រព្រឹត្តទៅតាមការអធិដ្ឋាននោះឯង ។ ទឹក នោះរមែងក្លាយជាផែនដីដល់ភិក្ខុនោះប៉ុណ្ណោះ ។ រមែងជាទឹកដល់ជនដ៏សេស ។ ត្រី និងអណ្តើក និងក្អែកទឹកជាដើម រមែងត្រាច់ទៅតាមសេចក្តីពេញចិត្ត ។ ប្រសិនបើភិក្ខុនេះប្រាថ្នានឹងធ្វើផែនដីនោះដល់មនុស្សទាំងឡាយ ក៏រមែងធ្វើបាន ។ តែរមែងជាទឹកព្រោះកន្លងកាលដែលបានកំណត់ទុក ។

បទថា **អាកាសេបិ បល្លង្កេន ចង្កមតិ** ហោះទៅឰដ៏អាកាសក៏បាន គឺ ទៅឯអាកាសទាំងភ្នែន ដោយជុំវិញឰដ៏អាកាសក៏បាន ។

បទថា **បក្ខី សកុណោ** គឺ បក្សីមានស្លាប មិនមែនបក្សីដែលមានស្លាបមិនបរិបូរណ៌ ឬបក្សីបាក់ស្លាប ។ ព្រោះថាបក្សីនោះ មិនអាចហើរទៅកាន់ឰដ៏អាកាសបាន ។ ភិក្ខុអ្នកបំណងនឹងទៅកាន់ឰដ៏អាកាសយ៉ាងនេះ ចូលបឋវីកសិណ លុះចេញហើយ ។ ប្រសិនបើប្រាថ្នានឹងអង្គុយហើយទៅ ។ គួរកំណត់

ខ្នាតបល្ល័ង្ក ធ្វើបរិកម្មហើយអធិដ្ឋាន ដោយន័យដូចពោលហើយ ។

បើបំណងនឹងដេកហើយទៅ ។ គួរកំណត់ខ្នាតគ្រែ ។ បើបំណងនឹងដើរ ។ គួរកំណត់រយៈផ្លូវ ។ លុះកំណត់ទីតាមសមគួរយ៉ាងនេះ ដោយប្រការដូច្នេះ គប្បីអធិដ្ឋានថា សូមអាកាសចូរក្លាយជាផែនដី ដោយន័យដូចពោលហើយនោះឯង ។ អាកាសក៏នឹងក្លាយជាផែនដី ព្រមជាមួយការ អធិដ្ឋាននោះឯង ។

ម្យ៉ាងទៀត ភិក្ខុបំណងនឹងទៅកាន់ទួដ៏អាកាស គប្បីបានទិព្វចក្ខុផង ។ ព្រោះហេតុអ្វី ? ព្រោះក្នុងចន្លោះនោះ រមែងមានភ្នំ និងដើមឈើជាដើម ដែលកើតតាមរដូវកាល ។ ឬនាគ និងគ្រុឌជាដើម ហួងហែង សាងទុក ។ ដើម្បីបានឃើញវត្ថុទាំងនោះ ។ ក៏កាលឃើញវត្ថុទាំងនោះហើយ គួរធ្វើយ៉ាងណា ? គប្បីចូលឈានជាបាទ លុះចេញហើយធ្វើ បរិកម្មថា សូមវត្ថុទាំងនោះ ចូរជាអាកាសចុះ ហើយអធិដ្ឋាន ។

ម្យ៉ាងទៀត សូម្បីនឹងចុះក្នុងទីទទេ ក៏គួរមានទិព្វចក្ខុ ។ ព្រោះប្រសិនបើភិក្ខុនេះចុះផ្លូតទឹក ឬទីទ្វារផ្ទះដែលមិនមែនទទេ ។ នឹងប្រាកដដល់មហាជន ។ ព្រោះដូច្នោះ សម្លឹងមើលដោយ



ទិព្វចក្ខុ ហើយវៀរទីមិនទទេនោះ ចុះក្នុងទីទទេ ដោយប្រការដូច្នេះ ។

ក្នុងបទនេះថា **ឥមេបិ ចន្ទិមសុរិយេ ឯវំមហិទ្ធិកេ ឯវំមហានុភាវេ** ស្ទាបអង្អែលចាប់ពាល់ព្រះចន្ទ ព្រះអាទិត្យ សូម្បីទាំងនេះ ដែលមានឫទ្ធិច្រើន មានអានុភាពច្រើនដោយ ដៃក៏បាន គប្បីជ្រាបសេចក្ដីដូចតទៅនេះ ។ គប្បីជ្រាបការមានឫទ្ធិច្រើនរបស់ព្រះចន្ទព្រះអាទិត្យ ដោយការគោចរហួតបួនម៉ឺនពីរពាន់យោជន៍ ( ៤២.០០០ យោជន៍ ) ។ ការមានអានុភាពច្រើនដោយការបញ្ចេញពន្លឺក្នុងខណៈតែមួយ ៣ ទ្វីប ។ ឬមានឫទ្ធិច្រើនដោយការគោចរទៅខាងលើ និងបញ្ចេញពន្លឺដោយអាការយ៉ាងនេះ ។ មានអានុភាពច្រើន ដោយការមានឫទ្ធិច្រើននោះ ៗ ឯង ។

បទថា **បរាមសតិ** គឺ ស្ទាប ឬចាប់ពាល់ក្នុងចំណែកមួយ ។

បទថា **បរិមជ្ជតិ** គឺ ស្ទាបដូចស្ទាបផ្ទៃកញ្ចក់ដោយជុំវិញ ។

ម្យ៉ាងទៀត ឫទ្ធិរបស់ភិក្ខុនោះ រមែងសម្រេចដោយអំណាចនៃឈាន មានអភិញ្ញាជាបាទ ។ ក្នុងឫទ្ធិនេះ មិននិយម

កសិណសមាបត្តិ ។ ប្រសិនបើថាភិក្ខុនេះប្រាថ្នានឹងទៅស្ទាប ។ ក៏ទៅស្ទាបបាន ។ បើប្រាថ្នាអង្គុយ ឬដេកស្ទាបអង្រែលព្រះចន្ទព្រះអាទិត្យនេះ ។ ក៏អធិដ្ឋានថា សូមព្រះចន្ទ ព្រះអាទិត្យ ចូរមកកាន់ទីបាតដៃយើងចុះ ។ ដោយកម្លាំងអធិដ្ឋាន ភិក្ខុនឹងស្ទាបអង្រែលព្រះចន្ទព្រះអាទិត្យ ឲ្យមកប្រាកដដល់អន្ទាក់ដៃ ( បាតដៃ ) ដូចផ្លែត្នោតធ្លាក់អំពីដើមដូច្នោះ ។ ឬលូកដៃទៅស្ទាបអង្រែលបាន ។

ម្យ៉ាងទៀត កាលបើភិក្ខុឈោងដៃទៅឧបាទិន្នកៈ ឬថាអនុបាទិន្នកៈឈោងទៅ ។ អនុបាទិន្នកៈឈោងទៅ ព្រោះអាស្រ័យ ឧបាទិន្នកៈ ។ ភិក្ខុធ្វើយ៉ាងនេះ មិនមែនស្ទាបអង្រែលព្រះចន្ទ ព្រះអាទិត្យបានតែម្យ៉ាងនោះទេ ។ បើប្រាថ្នាធ្វើឲ្យជាប្រដាប់ជូតជើង ក៏តាំងទុកត្រង់ជើងបាន ។ ធ្វើតាំងអង្គុយក៏បាន ។ ធ្វើគ្រែដេកក៏បាន ។ ធ្វើខ្នើយកើយក៏បាន ។ សូម្បីធ្វើយ៉ាងដទៃទៀតក៏ដូចគ្នា ។ សូម្បីភិក្ខុមួយសែនអង្គ ធ្វើយ៉ាងនេះ ឫទ្ធិរបស់ភិក្ខុទាំងនោះ រមែងសម្រេចយ៉ាងនោះ ដល់អង្គនិមួយ ៗ ប៉ុណ្ណោះ ។ ការគោចរធ្វើពន្លឺរបស់ព្រះចន្ទ ព្រះ



អាទិត្យ រមែងមានជាប្រក្រតី ។ ដូចមណ្ឌលព្រះចន្ទ រមែងប្រាកដដល់ថាសទាំងអស់ ដែលពេញដោយទឹកទាំង ១ ពាន់ថាស ។ ការគោចរ និងការបញ្ចេញពន្លឺរបស់ព្រះចន្ទ ក៏មានជាប្រក្រតីយ៉ាងណា ។ បាដិហារយ៍នេះក៏មានឧបមាដូច្នោះ ។

បទថា **យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ** ប្រើអំណាចផ្លូវកាយទៅរហូតព្រហ្មលោកក៏បាន សេចក្តីថា ធ្វើព្រហ្មលោកឲ្យជាទីកំណត់ ហើយញុំាងអភិញ្ញាច្រើនយ៉ាង ក្នុងវវាងនៃការប្រើអំណាច គឺ ភាពជាឥស្សរៈផ្លូវកាយរបស់ខ្លួន ។ ចំណែកសេចក្តីពិស្តារក្នុងនិទ្ទេសនេះ នឹងមានច្បាស់ក្នុងឥទ្ធិកថា ដោយប្រការដូច្នេះ ។

( ចប់ អដ្ឋកថាឥទ្ធិវិធញ្ញាណនិទ្ទេស )

# អដ្ឋកថា សោតធាតុវិសុទ្ធិញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ ក្នុងសោតធាតុវិសុទ្ធិញ្ញាណនិទ្ទេស ដូចតទៅនេះ ។ លោកពោលបទមានជាអាទិ៍ថា **ទូរេបិ សទ្ទានំ** ឮសំឡេងទាំងឡាយសូម្បីក្នុងទីឆ្ងាយ ដើម្បីចង្អុលបង្ហាញដល់ឧបាយរបស់ភិក្ខុដែលជាអាទិកម្មិកៈ ( អ្នកធ្វើកម្មជាលើកដំបូង បំណងនឹងញុំាងទិព្វសោតឲ្យកើត ) ។

ក្នុងបទទាំងនោះបទថា **ទូរេបិ សទ្ទានំ សទ្ទនិមិត្តំ** សំឡេងជានិមិត្តនៃសំឡេងទាំងឡាយ សូម្បីក្នុងទីឆ្ងាយ គឺ សំឡេងក្នុងរវាងនៃសំឡេងទាំងឡាយក្នុងទីឆ្ងាយ ។ ពិតណាស់ សំឡេងនោះឯង ជាសទ្ទនិមិត្តដោយអំណាចធ្វើជានិមិត្ត ។ សូម្បីកាលលោកពោលថា **ទូរេ** ក៏បានដល់ ក្នុងទីដែលជាគន្លងនៃសំឡេងតាមប្រក្រតីនោះឯង ។

បទថា **ឱឡារិកានំ** គឺ សំឡេងគ្រោតគ្រាត ។ បទថា **សុខុមានំ** គឺ សំឡេងល្អិត ។

បទថា **សណ្ហសណ្ហានំ** គឺ សំឡេងល្អិតដ៏ក្រៃលែង ។



ដោយបទនេះ គឺ លោកពោលដល់សំឡេងដែលល្អិតក្រៃលែង ។ ភិក្ខុដែលជាអាទិកម្មិកបំណងនឹងញុំាងញាណនេះឲ្យកើត ចូលឈានដែលមានអភិញ្ញាជាបាទ លុះចេញហើយ មានចិត្តជាបរិកម្មសមាធិមុនដំបូងគប្បីនឹកដល់សំឡេងគ្រោតគ្រាត មានសំឡេងសីហៈជាដើម ក្នុងទីឆ្ងាយជាគន្លងនៃត្រចៀកតាមប្រក្រតី ។ គប្បីនឹកដល់សំឡេងដែលល្អិតដ៏ក្រៃលែងតាមលំដាប់ តាំងពីសំឡេងគ្រោតគ្រាតទាំងពួង យ៉ាងនេះ គឺ សំឡេងរគាំងក្នុងវត្ត សំឡេងស្គរ សំឡេងស័ង្ខ សំឡេងស្វាធ្យាយរបស់សាមណេរ និងសំឡេងភិក្ខុកំលោះដែលស្វាធ្យាយ ដោយកំលាំងទាំងអស់ សំឡេងមានជាអាទិ៍ថា អ្វីលោកម្ចាស់ ។ អ្វីអាវុសោ ។ របស់ភិក្ខុដែលពោលកថាតាមប្រក្រតី សំឡេងបក្សី សំឡេងខ្យល់ សម្រិបជើង សំឡេងទឹកពុះ សំឡេងស្លឹកត្នោតឆាប់ព្រោះកំដៅថ្ងៃ សំឡេងស្រមោចខ្មៅ ស្រមោចក្រហមវារជាដើម ។

ម្យ៉ាងទៀត ភិក្ខុធ្វើយ៉ាងនេះហើយ គប្បីមនសិការដល់សទ្ទនិមិត្តក្នុងទិសទាំង១០ មានទិសខាងកើតជាដើមដោយលំដាប់ ។ តាមន័យដូចបានពោលហើយ ។ ភិក្ខុដែលមនសិការ គប្បី

មនសិការដោយចិត្តប្រព្រឹត្តទៅក្នុងមនោទ្វារ ដោយការផ្ទៀងត្រចៀកតាមប្រក្រតី ក្នុងសំឡេងដែលត្រចៀកបានឮតាមប្រក្រតី ។ សំឡេងទាំងនោះរមែង ប្រាកដដល់ភិក្ខុដែលមានចិត្តជាប្រក្រតី ។ តែប្រាកដយ៉ាង ក្រៃលែងដល់ភិក្ខុអ្នកមានចិត្តបរិកម្មសមាធិ ។ កាលភិក្ខុ មនសិការសទ្ទនិមិត្តយ៉ាងនេះហើយ មនោទ្វារាវជ្ជនៈរមែងកើត ព្រោះធ្វើអារម្មណ៍ណាមួយក្នុងសំឡេងទាំងនោះថា ពេលនេះទិព្វសោតធាតុនឹងកើត ។ កាលមនោទ្វារាវជ្ជនៈនោះរលត់ ជវនចិត្ត ៤ ឬ ៥ ខណៈ រមែងស្ទុះទៅ ។ កាមាវចរចិត្តដែលឈ្មោះថា បរិកម្ម ឧបចារ អនុលោម គោត្រភូ ៣ ឬ ៤ ខណៈ រមែងស្ទុះទៅ ។ អប្បនាចិត្តទី ៤ ឬទី ៥ ដែលប្រព្រឹត្តទៅក្នុងចតុត្ថជ្ឈាន ជារូបាវចររមែងស្ទុះទៅ ។

ញាណដែលកើតឡើងជាមួយអប្បនាចិត្តនោះ ឈ្មោះថា ទិព្វសោតធាតុញ្ញាណ ។ ភិក្ខុធ្វើញាណនោះ ឲ្យមានកំលាំងកំណត់ត្រឹមតែមួយអង្គុលីថា **ក្នុងចន្លោះនេះ យើងនឹងស្តាប់សំឡេង** ហើយគប្បីចម្រើន ។ ប៉ុន្តែគប្បីចម្រើនដរាបដល់ចក្រវាឡ ដោយផ្តើមជាដំបូង ២ អង្គុលី ៤ អង្គុលី ៨ អង្គុលី



មួយធ្នាប់ មួយហត្ថ ចំណែកខាងក្រោយ ខាងមុខ បរិវេណប្រាសាទ សង្ឃារាម គោចរគាម និងជនបទ ។ ឬកំណត់ហើយគប្បីចម្រើនឲ្យក្រៃលែងជាងនោះ ។ ភិក្ខុនោះសម្រេចអភិញ្ញាយ៉ាងនេះ សូម្បីមិនចូលឈានជាបាទទៀត រមែងបានឮសំឡេងដែលទៅក្នុងចំណែកខាង ក្នុងឱកាសដែលពាល់ត្រូវដោយអារម្មណ៍ នៃឈានជាបាទ ដោយអភិញ្ញាញាណ ។ កាលបានឮយ៉ាងនេះ ប្រសិនបើមានកោលាហល ដូចជាសំឡេងស័ង្ខ ស្គរ និងបណ្ឌោះជាដើម រហូតដល់ព្រហ្មលោក ។ ព្រោះជាអ្នកប្រាថ្នាដើម្បីកំណត់ចំពោះតែម្យ៉ាង រមែងអាចកំណត់ថា នេះសំឡេងស័ង្ខ ។ នេះសំឡេងស្គរ ។ កាលបានឮសំឡេងមានប្រយោជន៍ ដោយអភិញ្ញាញាណ ភិក្ខុរមែងដឹងអត្ថដោយកាមាវចរចិត្តជាខាងក្រោយ ។ ទិព្វសោត រមែងកើតដល់ភិក្ខុដែលមានត្រចៀកជាប្រក្រតី ។ មិនបានកើត ដល់ភិក្ខុដែលថ្លង់ ។ អាចារ្យពួកមួយពោលថា កាលខាងក្រោយ ត្រចៀកជាប្រក្រតីវិនាសទៅ ទិព្វសោតក៏មិនវិនាសដែរ ។

ក្នុងបទនេះថា *សោ ទិព្វាយ សោតធាតុយា* សោតធាតុ

ដែលជាទិព្វ មានសេចក្តីដូចតទៅនេះ ។ ឈ្មោះថា ទិព្វ ព្រោះដូចគ្នានឹងទិព្វ ។ បសាទសោតធាតុជាទិព្វ អាចទទួលអារម្មណ៍សូម្បីក្នុងទីឆ្ងាយ ព្រោះផុតចាកឧបកិលេស មិនជាប់ទៅដោយប្រម៉ាត់ ស្លេស្ម៍ និងឈាមជាដើម ព្រោះទេវតាទាំងឡាយកើតដោយកម្មដែលសុចរិត ។ ញាណសោតធាតុក៏ដូចគ្នា កើតដោយកំលាំងនៃការចម្រើនសេចក្តីព្យាយាមរបស់ភិក្ខុនេះ ព្រោះហេតុនោះ ទើបឈ្មោះថា ទិព្វ ព្រោះដូចគ្នានឹងទិព្វ ។

ម្យ៉ាងវិញទៀត ឈ្មោះថា ទិព្វ ព្រោះបានដោយអំណាចនៃទិព្វវិហារធម៌ ។ និងព្រោះអត្តថា មិនមានជីវៈ ។ ម្យ៉ាងទៀត ជាសោតធាតុដោយធ្វើកិច្ចរបស់សោតធាតុ ព្រោះដូច្នោះ ទើបឈ្មោះថា សោតធាតុ ។ ដោយសោតធាតុដែលជាទិព្វនោះ ។

បទថា **វិសុទ្ធាយ** គឺ បរិសុទ្ធិ៍មិនមានឧបកិលេស ។

បទថា **អតិក្កន្តមានុសិកាយ** ដោយទិព្វសោតធាតុដ៏បរិសុទ្ធិ៍កន្លងសោតរបស់មនុស្ស គឺ ដោយទិព្វសោតដែលកន្លងឧបចាររបស់មនុស្ស ឈានកន្លងមំសសោតធាតុរបស់មនុស្ស ដោយការស្តាប់សំឡេង ។



បទថា **ឧភោ សទ្ទេ សុណាតិ** គឺ ឮសំឡេងទាំងពីរយ៉ាង ។ សំឡេងពីរយ៉ាង គឺអ្វី ? គឺ ទាំងសំឡេងជាទិព្វ និងសំឡេងមនុស្ស ។ លោកអធិប្បាយថា សំឡេងរបស់ទេវតា និងរបស់មនុស្ស ។ ដោយបទនេះ គប្បីជ្រាបការកាន់យកទីកន្លែងរស់នៅ ។

បទថា **យេ ទូរេ សន្តិកេ ច** ទាំងក្នុងទីឆ្ងាយ និងក្នុងទីជិត លោកអធិប្បាយថា រមែងបានឮសំឡេងក្នុងទីឆ្ងាយ សូម្បីក្នុងចក្រវាឡដទៃ និងក្នុងទីជិតដោយទីបំផុត សូម្បីសំឡេងសត្វដែលអាស្រ័យនៅក្នុងកាយរបស់ខ្លួន ។ ដោយបទនេះ គប្បីជ្រាបការកាន់យកមិនមានទីអាស្រ័យនៅ ដោយប្រការដូច្នេះ ។

( ចប់ អដ្ឋកថាសោតធាតុវិសុទ្ធិញ្ញាណនិទ្ទេស )

# អដ្ឋកថា ចេតោបរិយញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងចេតោបរិយញ្ញាណនិទ្ទេស មានដូចតទៅនេះ បទថា **សោ ឯវំ បជានាតិ** ភិក្ខុនោះរមែងដឹងយ៉ាងនេះ សេចក្ដីថា ឥឡូវនេះ ព្រះសារីបុត្តត្ថេរនឹងលើកវិធីដែលគប្បីពោលឡើងសម្ដែង ។

បទមានជាអាទិ៍ថា **ឥទំ រូបំ សោមនស្សិន្ទ្រិយសមុដ្ឋិតំ** រូបនេះកើតឡើងដោយសោមនស្សិន្ទ្រិយ ជាវិធីដែលភិក្ខុអ្នកសម្លឹង ជាអាទិកម្មិកគួរបដិបត្តិយ៉ាងណា ? ចំណែកភិក្ខុអ្នកសម្លឹងបំណងនឹងញុំាងញាណនោះឲ្យកើតឡើង គួរឲ្យទិព្វចក្ខុ-ញ្ញាណកើតឡើងមុន ។ ព្រោះចេតោបរិយញ្ញាណនោះ រមែងសម្រេចដោយអំណាចនៃទិព្វចក្ខុ ។ ញាណនុ៎ះ ជាបរិកម្មរបស់ទិព្វចក្ខុនោះ ។ ព្រោះដូច្នោះ ភិក្ខុនោះចម្រើនអាលោកកសិណ ឃើញពណ៌របស់លោហិតដែល ប្រព្រឹត្តទៅ ព្រោះអាស្រ័យហទយរូបរបស់អ្នកដទៃដោយទិព្វចក្ខុ ទើបគួរស្វែងរកចិត្ត ។ ព្រោះលោហិតនោះ បើកុសលសោមនស្សប្រព្រឹត្តទៅ រមែងមាន



ពណ៌ក្រហមដូចពណ៌ផ្លែជ្រៃទុំ ។ បើជាអកុសលសោមនស្សប្រព្រឹត្តទៅ លោហិតនោះរមែងមានពណ៌ល្អក់ ។ បើជាទោម-នស្សប្រព្រឹត្តទៅ រមែងមានពណ៌ខ្មៅល្អក់ដូចពណ៌ផ្លែព្រីងទុំ ។ បើកុសលឧបេក្ខាប្រព្រឹត្តទៅ រមែងមានពណ៌ថ្លាដូចប្រេងល្ង ។ បើអកុសលឧបេក្ខាប្រព្រឹត្តទៅ លោហិតនោះរមែងល្អក់ ។ ព្រោះដូច្នោះ ភិក្ខុនោះឃើញពណ៌លោហិតក្នុងហទយរបស់បុគ្គលដទៃថា រូបនេះកើតដោយសោមនស្សិន្ទ្រិយ ។ រូបនេះកើតឡើងដោយទោមនស្សិន្ទ្រិយ រូបនេះកើតឡើងដោយឧបេក្ខិន្ទ្រិយ ដូច្នេះហើយស្វែងរកចិត្ត គប្បីធ្វើចេតោបរិយញ្ញាណឲ្យមានកម្លាំង ។ ព្រោះកាលចេតោបរិយញ្ញាណនោះ មានកម្លាំងយ៉ាងនេះ ភិក្ខុរមែងដឹងចិត្តដែលមានប្រភេទជាកាមាវចរជាដើម សូម្បីទាំងអស់ដោយលំដាប់ ឈានកន្លងពីចិត្ត ឆ្ពោះទៅកាន់ចិត្ត វៀរការឃើញរូប ( ពណ៌ ) របស់ហទយ ។ សូម្បីក្នុងអដ្ឋកថា លោកក៏ពោលថា ៖

សួរថា អ្នកបំណងនឹងដឹងចិត្តរបស់អ្នកដទៃ
ក្នុងអរូបភព រមែងឃើញហទយរូបរបស់
នរណា ? រមែងសម្លឹងមើលវិការនៃឥន្ទ្រិយ

របស់នរណា ? ឆ្លើយថា មិនសម្លឹងមើល
របស់នរណា ៗ នេះជាវិស័យរបស់អ្នក
មានឫទ្ធិ គឺ ភិក្ខុរឭកដល់ចិត្តក្នុងទីណាៗ
រមែងដឹងចិត្ត ១៦ ប្រភេទ ។ នេះជា
កថាដោយអំណាចនៃការមិនធ្វើសេចក្ដី
ប្រកាន់មាំ ។

បទថា **បរសត្តានំ** នៃសត្វដទៃ គឺ សត្វដទៃដែលវៀរខ្លួនឯង ។

បទថា **បរបុគ្គលានំ** នៃបុគ្គលដទៃ សូម្បីបទនេះ ក៏មានន័យដូចគ្នានឹងបទថា **បរសត្តានំ** នេះ តែលោកពោលសេចក្ដីផ្សេងគ្នាឲ្យពីរោះដោយការទេសនា និងដោយព្យញ្ជនៈ ដោយអំណាចវេនេយ្យសត្វ ។

បទថា **ចេតសា ចេតោ បរិច្ច បជានាតិ** កំណត់ដឹងចិត្តដោយចិត្ត គឺ កំណត់ដឹងចិត្តរបស់សត្វទាំងនោះ ដោយចិត្តរបស់ខ្លួនដោយប្រការផ្សេង ៗ ដោយអំណាចចិត្តមានរាគៈជាដើម ។ **វា** ស័ព្ទ ក្នុងបទមានជាអាទិ៍ថា **សរាគំ វា** ជាសមុច្ចយត្ថៈ



គឺ អត្ថថា រួបរួម ។

ក្នុងបទនោះ ចិត្តសហគតដោយលោភៈ ៨ យ៉ាង ឈ្មោះថា ចិត្តមានរាគៈ ។ កុសលចិត្ត និងអព្យាកតចិត្ត ប្រព្រឹត្តទៅក្នុងភូមិ ៤ ដ៏សេស ឈ្មោះថា ចិត្តប្រាសចាករាគៈ ។

ចំណែកចិត្ត ៤ ដួងទាំងនេះ គឺ ចិត្តដែលសហគតៈដោយទោមនស្ស ២ ដួង ចិត្តដែលសហគតដោយវិចិកិច្ឆា និងឧទ្ធច្ចៈ ២ ដួង មិនសង្គ្រោះចូលក្នុងទុកៈនេះ ។ តែព្រះថេរៈពួកខ្លះសង្គ្រោះចិត្តសូម្បីទាំងនេះ ដោយបទថា **វីតរាគ** ប្រាសចាករាគៈ ។

ចំណែកចិត្តសហគតដោយទោមនស្ស ២ យ៉ាង ឈ្មោះថា ចិត្តមានទោសៈ ។ កុសលចិត្ត និងអព្យាកតចិត្តប្រព្រឹត្តទៅក្នុងភូមិ ៤ សូម្បីទាំងអស់ ឈ្មោះថា ចិត្តប្រាសចាកទោសៈ ។ អកុសលចិត្ត ១០ ដ៏សេស មិនសង្គ្រោះចូលក្នុងទុកៈនេះ ។ តែព្រះថេរៈពួកខ្លះសង្គ្រោះអកុសលចិត្ត សូម្បីទាំងនោះ ដោយបទថា **វីតទោសំ** ប្រាសចាកទោស ។

តែក្នុងបទនេះថា **សមោហំ វីតមោហំ** ចិត្តមានមោហៈ ចិត្តប្រាសចាកមោហៈ ពីរបទនេះ សហគតៈដោយវិចិកិច្ឆា និង

ឧទ្ធច្ចៈ ដោយអំណាចជាឯកហេតុកៈរបស់មោហៈ ឈ្មោះថា ចិត្តមានមោហៈ ។ អកុសលចិត្តសូម្បីទាំង ១២ យ៉ាង គប្បីជ្រាបថា ឈ្មោះថា ចិត្តមានមោហៈ ព្រោះមោហៈកើតក្នុងអកុសលទាំងអស់ ។ កុសល និងអព្យាក្រិតដ៏សេស ជាចិត្តប្រាសចាកមោហៈ ។

ចំណែកចិត្តដែលទាក់ទងនឹងថីនមិទ្ធៈ ជាចិត្តខ្ជិល ប្រអូស ចិត្តដែលទាក់ទងដោយឧទ្ធច្ចៈ ជាចិត្តរាយមាយ ។

រូបាវចរចិត្ត និងអរូបាវចរចិត្ត ជាមហគ្គតចិត្ត ។ ចិត្តប្រព្រឹត្តទៅក្នុងភូមិ ៣ សូម្បីទាំងអស់ ជាចិត្ត មានចិត្តដទៃក្រៃលែងជាង ។ លោកុត្តរចិត្ត ជាចិត្តមិនមានចិត្តដទៃក្រៃលែងជាង ។

ចិត្តដែលជាឧបចារៈ និងចិត្តដែលជាអប្បនា ជាចិត្តមានសមាធិ ។ ចិត្តដែលមិនដល់ទាំងពីរយ៉ាង ជាចិត្តមិនមានសមាធិ ។

ចិត្តដែលដល់តទង្គវិមុត្តិ វិក្ខម្ភនវិមុត្តិ សមុច្ឆេទវិមុត្តិ បដិបស្សទ្ធិវិមុត្តិ និងនិស្សរណវិមុត្តិ ជាចិត្តរួចផុតហើយ ។ ចិត្តដែលមិនដល់វិមុត្តិទាំង ៥ នេះ គប្បីជ្រាបថា ជាចិត្តនៅមិនទាន់រួចផុត ។



ភិក្ខុដែលបានចេតោបរិយញ្ញាណ រមែងដឹងចិត្តសូម្បីមានប្រភេទ ១៦ យ៉ាង ។

បុថុជ្ជនទាំងឡាយ រមែងមិនដឹងមគ្គចិត្ត និងផលចិត្តរបស់ព្រះអរិយៈទាំងឡាយ ។ សូម្បីព្រះអរិយៈថ្នាក់ទាប ៗ ក៏មិនដឹងមគ្គចិត្ត និងផលចិត្តរបស់ព្រះអរិយៈថ្នាក់ខ្ពស់ ៗ តែព្រះអរិយៈថ្នាក់ខ្ពស់ៗ រមែងដឹងចិត្តរបស់ព្រះអរិយៈថ្នាក់ទាប ៗ ដោយប្រការដូច្នេះ ។

( ចប់ អដ្ឋកថាចេតោបរិយញ្ញាណនិទ្ទេស )

# អដ្ឋកថា បុព្វេនិវាសានុស្សតិញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ ក្នុងបុព្វេនិវាសានុស្សតិញ្ញាណដូចតទៅនេះ ។ បទមានជាអាទិ៍ថា **ឯវំ បជានាតិ** ភិក្ខុដឹងច្បាស់យ៉ាងនេះ ព្រះសារីបុត្តត្ថេរពោលដើម្បីសម្តែងវិធីឲ្យកើតឥទ្ធិបាទនោះ ដល់នរណាដើម្បីញុំាងបុព្វេនិវាសានុស្សតិញ្ញាណឲ្យកើតដល់ចិត្តដែលអប់រំហើយក្នុងឥទ្ធិបាទ ៤ ។

ពិតណាស់ ភិក្ខុកាលឃើញបដិច្ចសមុប្បាទ ដោយលំដាប់ហើយ រមែងឃើញសង្ខេបនៃផលដែលកើតឡើង ពោលគឺ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ និងវេទនា ។

រមែងឃើញសង្ខេបនៃហេតុ ពោលគឺ កម្ម កិលេស ក្នុងភពមុន ដែលជាបច្ច័យនៃសង្ខេបរបស់ផលនោះ ។

រមែងឃើញសង្ខេបនៃផលក្នុងភពមុន ដែលជាបច្ច័យនៃសង្ខេបរបស់ហេតុនោះ ។

រមែងឃើញសង្ខេបនៃហេតុក្នុងភពទី ៣ ដែលជាបច្ច័យនៃសង្ខេបរបស់ផលនោះ ។



រមែងឃើញចំណែកខាងដើមរបស់ជាតិ ដោយការឃើញបដិច្ចសមុប្បាទយ៉ាងនេះ ។ ការមនសិការបដិច្ចសមុប្បាទ មានឧបការៈច្រើនដល់បុព្វេនិវាសានុស្សតិញ្ញាណ ដោយប្រការដូច្នេះ ។

ក្នុងបទទាំងនោះ បទនេះថា **ឥមស្មឹ សតិ ឥទំ ហោតិ , ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ** កាលវត្ថុនេះមាន វត្ថុនេះរមែងមាន ព្រោះវត្ថុនេះកើតឡើង វត្ថុនេះទើបកើតឡើង ជាពាក្យលើកឡើងបរិយាយសេចក្តីបដិច្ចសមុប្បាទ ។ ប្រសិនបើសួរថា បើសម្រេចសេចក្តីដោយពាក្យណាមួយនៃបទទាំងនោះ ព្រោះហេតុអ្វីទើបពោលជាពីរយ៉ាង ។ ឆ្លើយថា ព្រោះមានសេចក្តីផ្សេងគ្នាដោយអត្ថ ។

បទថា **ឥមស្មឹ សតិ** បើវត្ថុនេះមាន គឺ បើបច្ច័យនេះមាន ។ បទនេះពោលទូទៅដល់បច្ច័យទាំងអស់ ។

បទនេះថា **ឥទំ ហោតិ** វត្ថុនេះរមែងមាន គឺ វត្ថុនេះរមែងកើតឡើងព្រោះបច្ច័យ ។ បទនេះពោលទូទៅដល់វត្ថុដែលកើតឡើង ព្រោះបច្ច័យទាំងអស់ ។ ដោយពាក្យទាំងអស់នេះ អហេតុកវាទ គឺ លោកបដិសេធហើយ ព្រោះធម៌ទាំងឡាយណា

កើតព្រោះបច្ច័យ មិនកើតព្រោះមិនមានបច្ច័យ ធម៌ទាំងឡាយនោះ មិនឈ្មោះថា អហេតុកៈ ។

បទថា **ឥមស្សុប្បាទា** ព្រោះវត្ថុនេះកើតឡើង គឺ ព្រោះហេតុបច្ច័យនេះកើតឡើង ។ បទនេះជាពាក្យពោលសម្តែងសេចក្តីផ្សេងគ្នានៃការកើតឡើងរបស់បច្ច័យទាំងអស់ ។

បទនេះថា **ឥទំ ឧប្បជ្ជតិ** វត្ថុនេះរមែងកើតឡើង គឺ វត្ថុនេះមានបច្ច័យកើតឡើង ទើបកើត ។ បទនេះពោលសម្តែងដល់បច្ច័យទាំងអស់កើតឡើង ទើបកើតឡើងតអំពីនោះទៅ ។ ដោយពាក្យទាំងអស់នេះ សស្សតវាទ និងអហេតុកវាទ គឺ លោកបដិសេធហើយ ព្រោះធម៌ទាំងឡាយណាមានការកើតឡើង ធម៌ទាំងឡាយនោះមិនទៀង ព្រោះដូច្នោះ លោកទើបអធិប្បាយទុកថា កាលបើធម៌ទាំងឡាយមានហេតុ មានហើយ ធម៌ទាំងឡាយនោះ មានការមិនទៀង ជាហេតុ មិនមែនមានបុរសជាប្រក្រតីជាដើម ដែលសម្មតិថា ទៀងក្នុងលោកជាហេតុ ។

បទថា **យទិទំ** ជាពាក្យចង្អុលបង្ហាញអត្ថដែលគួរប្រាប់ ។

ក្នុងបទនេះថា **អវិជ្ជាបច្ចយា សង្ខារា** ព្រោះអវិជ្ជាជាបច្ច័យ



ទើបមានសង្ខារ មានអធិប្បាយដូចតទៅនេះ ផលកើតឡើងព្រោះអាស្រ័យវត្ថុណា វត្ថុនោះក៏ជាបច្ច័យ ។

បទថា **បដិច្ច** អាស្រ័យ គឺ មិនប្រាសទៅ ។ អធិប្បាយថា ព្រមព្រៀង ។

បទថា **ឯតិ** គឺ រមែងកើតឡើង និងរមែងប្រព្រឹត្តទៅ ។ ម្យ៉ាងទៀត មានអត្ថថា ជាឧបការៈ ជាបច្ច័យ ។ អវិជ្ជានោះជាបច្ច័យផង ព្រោះហេតុនោះឈ្មោះថា អវិជ្ជាជាបច្ច័យ ។ ព្រោះដូច្នោះ គប្បីប្រកបសេចក្តីថា **អវិជ្ជាបច្ចយា សង្ខារា សម្ភវន្តិ** ព្រោះអវិជ្ជាជាបច្ច័យ ទើបមានសង្ខារ ។ គប្បីធ្វើការប្រកប **សម្ភវន្តិ** សព្ទ័ សូម្បីដោយបទដ៏សេស ។

ម្យ៉ាងទៀត ក្នុងបទថា សោកៈ ជាដើម មានសេចក្តីដូចតទៅនេះ ។ ការក្រៀមក្រំចិត្ត ឈ្មោះថា **សោក** ។ ការថ្ងូញថ្ងែរ ឈ្មោះថា **បរិទេវ** ។ វត្ថុដែលអស់ទៅបានលំបាក ឈ្មោះថា **ទុក្ខ** ឬវត្ថុគួរខ្ជាច ២ យ៉ាង គឺ ដោយអំណាចនៃការកើត និងការតាំងនៅ ឈ្មោះថា **ទុក្ខ** ។ ការទាស់ចិត្ត ឈ្មោះថា **ទោមនស្ស** ។ ការចង្អៀតចង្អល់ចិត្តយ៉ាងក្រៃលែង ឈ្មោះថា **ឧបាយាស** ។

ក្នុងបទនេះថា **សម្ភវន្តិ** រមែងមាន គឺ រមែងកើត ។

បទថា **ឯវំ** ជាបទសម្តែងន័យ ដែលសម្តែងហើយ ។ ដោយបទនោះ ព្រះសារីបុត្តសម្តែងថា ដោយហេតុមិនមានអវិជ្ជាជាដើម មិនមែនដោយលទ្ធិទាំងឡាយមានព្រះជាអ្នកសាងឡើងជាដើម ។

បទថា **ឯតស្ស** គឺ តាមដែលបានពោលហើយ ។

បទថា **កេវលស្ស** ទាំងអស់ គឺ មិនមានសល់ ឬដោយអស់ជើង ។

បទថា **ទុក្ខក្ខន្ធស្ស** គឺ កងទុក្ខ ។ មិនមែនជាសត្វ មិនមែនសុខ និងស្អាតជាដើម ។

បទថា **សមុទយោ** គឺ កើត ។ បទថា **ហោតិ** គឺមាន ។

ក្នុងបទទាំងឡាយនោះ អវិជ្ជាដូចម្តេច ? គឺ ការមិនដឹងទុក្ខ មិនដឹងទុក្ខសមុទ័យ មិនដឹងទុក្ខនិរោធ មិនដឹងទុក្ខនិរោធគាមិនីបដិបទា មិនដឹងទីបំផុតខាងដើម មិនដឹងទីបំផុតខាងចុង មិនដឹងទីបំផុតខាងដើម និងខាងចុងមិនដឹងក្នុងធម៌ដែលអាស្រ័យគ្នាកើតឡើង គឺ **ឥទប្បច្ចយតា** ( វត្ថុនេះជាបច្ច័យដល់វត្ថុនេះ ) ។

សង្ខារដូចម្តេច ? គឺ បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អានេញ្ជាភិសង្ខារ , កាយសង្ខារ វចីសង្ខារ ចិត្តសង្ខារ , កាមាវចរកុសលចេតនា ៨ រូបាវចរកុសលចេតនា ៥ ឈ្មោះថា បុញ្ញាភិសង្ខារ , អកុសលចេតនា ១២ ឈ្មោះថា អបុញ្ញាភិសង្ខារ , អរូបាវចរកុសលចេតនា ៤ ឈ្មោះថា អានេញ្ជាភិសង្ខារ ។ កាយសញ្ចេតនា ឈ្មោះថា កាយសង្ខារ ។ វចីសញ្ចេតនា ឈ្មោះថា វចីសង្ខារ ។ មនោសញ្ចេតនា ឈ្មោះថា ចិត្តសង្ខារ ។

ក្នុងប្រការនោះ គប្បីមានពាក្យសួរថា នឹងគប្បីដឹងប្រការនោះបានដូចម្តេចថា សង្ខារទាំងនេះរមែងមាន ព្រោះអវិជ្ជាជាបច្ច័យ ។ ដឹងបាន ព្រោះមានអវិជ្ជា ។ ពិតណាស់ ការមិនដឹងពោលគឺ អវិជ្ជាក្នុងទុក្ខជាដើម ដែលភិក្ខុណាលះបង់មិនបាន ភិក្ខុនោះប្រកាន់សង្ខារទុក្ខ ដោយសម្គាល់ថា ជាសុខ ដោយមិនដឹងក្នុងទុក្ខ និងក្នុងទីបំផុតខាងដើមជាដើមអំពីមុន ហើយប្រារព្ធសង្ខារ ៣ យ៉ាង ដែលជាហេតុនៃទុក្ខនោះ ។ ភិក្ខុសម្គាល់ហេតុនៃសុខ ប្រារព្ធសង្ខារទាំងឡាយដែលជាបរិក្ខាររបស់តណ្ហាដែលជាហេតុនៃទុក្ខ ដោយមិនដឹងក្នុងសមុទ័យ ។

ម្យ៉ាងទៀត ភិក្ខុដែលមានការសម្គាល់ក្នុងការរលត់ទុក្ខដែលជាគតិវិសេស សូម្បីមិនមែនជាការរលត់ទុក្ខដោយមិនដឹងក្នុងនិរោធ និងមគ្គ និងជាអ្នកមានការសម្គាល់ក្នុងនិរោធ និងមគ្គក្នុងយ័ញ្ញ និងតបៈដើម្បីសេចក្តីមិនស្លាប់ជាដើម សូម្បីមិនមែនជាមគ្គនៃនិរោធ ប្រាថ្នាការរំលត់ទុក្ខ រមែងប្រារព្ធសង្ខារទាំងឡាយសូម្បី ៣ យ៉ាង ដោយមានយ័ញ្ញ និងតបៈដើម្បីសេចក្តីមិនស្លាប់ជាដើម ជាប្រធាន ។

ម្យ៉ាងវិញទៀត ភិក្ខុនោះមិនដឹងទុក្ខ ពោលគឺ ផលបុណ្យសូម្បីលាយឡំដោយទោសដ៏ច្រើន មានជាតិ ជរា រោគ មរណៈជាដើម ដោយពិសេសព្រោះមិនដឹងការមិនលះបង់ក្នុងសច្ចៈ ៤ ដោយអវិជ្ជានោះ ដោយសភាពជាទុក្ខ រមែងប្រារព្ធបុញ្ញាភិសង្ខារ មានកាយសង្ខារ វចីសង្ខារ និងចិត្តសង្ខារ ដើម្បីកំណត់ដឹងនូវទុក្ខនោះ ដូចអ្នកប្រាថ្នានាងទេពអប្សរ ប្រារព្ធការកើតជាទេវតា ដូច្នោះ ។ សូម្បីមិនឃើញទុក្ខ គឺ សេចក្តីប្រែប្រួល និងវត្ថុដែលមានសេចក្តីរីករាយតិច ដែលកើតអំពីសេចក្តីដុតរោលដ៏ធំក្នុងទីបំផុតនៃផលបុណ្យនោះ សូម្បីសម្មតិថាជាសេចក្តីសុខ រមែង



ប្រារព្ធបុញ្ញាភិសង្ខារ មានប្រការដូចពោលហើយ ដែលមានទុក្ខនោះជាបច្ច័យ ដូចសត្វមមាចហើរចូលក្នុងអណ្តាតភ្លើង ដូច្នោះ ។ និងដូចបុគ្គលប្រាថ្នាតំណក់ទឹកឃ្មុំ ប្រារព្ធលិទ្ធទឹកឃ្មុំដែលជាប់នឹងមុខសស្ត្រាដ៏មុត ដូច្នោះ ។ មិនឃើញទោសក្នុងទុក្ខព្រមទាំងវិបាក មានការសេពកាមជាដើម ប្រារព្ធអបុញ្ញាភិសង្ខារសូម្បីប្រព្រឹត្តទៅក្នុងទ្វារទាំង ៣ ដោយការសម្គាល់ថាជាសុខ និងព្រោះត្រូវកិលេសគ្របសង្កត់ ដូចទារកប្រារព្ធការលេងលាមក ដូច្នោះ ។ និងដូចបុគ្គលប្រាថ្នាស្លាប់ ប្រារព្ធការបរិភោគថ្នាំពុល ដូច្នោះ ។ មិនដឹងសង្ខារថាជាទុក្ខ ព្រោះការប្រែប្រួលក្នុងវិបាកដែលមិនមានរូប ប្រារព្ធអានេញ្ជាភិសង្ខារ ដែលជាចិត្តសង្ខារដោយការឃើញខុស ថាទៀងជាដើម ដូចបុគ្គលវង្វេងទិស ប្រារព្ធការដើរផ្លូវដោយបែរមុខទៅនគរបិសាច ដូច្នោះ ។ ព្រោះការកើតនៃសង្ខារដោយមានអវិជ្ជា មិនមែនព្រោះមិនមាននោះទេ ។ ដូច្នោះ គប្បីដឹងបទនេះថា **ឥមេ សង្ខារា អវិជ្ជាបច្ចយា ហោន្តិ** សង្ខារទាំងឡាយនេះមាន ព្រោះអវិជ្ជាជាបច្ច័យ ដោយប្រការដូច្នេះ ។

ក្នុងបទនេះ ព្រះសារីបុត្តត្ថេរពោលទុកថា យើងនឹងកាន់

យកបទនេះមុនថា **អវិជ្ជា សង្ខារានំ បច្ចយោ** អវិជ្ជាជាបច្ច័យនៃសង្ខារទាំងឡាយ ។ ក៏អវិជ្ជានេះតែម្យ៉ាងប៉ុណ្ណោះឬ ជាបច្ច័យនៃសង្ខារ ឬថាសូម្បីមានធម៌ដទៃទៀតជាបច្ច័យ ។ នឹងពោលថា ក្នុងបទនេះ អវិជ្ជាតែម្យ៉ាងប៉ុណ្ណោះជាបច្ច័យ វាទៈដែលជាហេតុតែម្យ៉ាង រមែងមានឬ ។ បើដូច្នោះ សូម្បីយ៉ាងដទៃក៏រមែងមាន ។ ការចង្អុលបង្ហាញហេតុតែមួយថា ព្រោះអវិជ្ជាជាបច្ច័យ ទើបមានសង្ខារដូច្នេះ នឹងកើតឡើងមិនបាន ។ មិនកើតព្រោះហេតុអ្វី ? ព្រោះ

**ឯកំ ន ឯកតោ ឥធ  នានេកមនេកតោបិ នោ ឯកំ**
**ផលមត្ថិ អត្ថិ បន  ឯកហេតុផលទីបនេ អត្ថោ ។**

ក្នុងលោកនេះ ផលតែម្យ៉ាង រមែង
មានព្រោះហេតុតែម្យ៉ាងក៏ទេ ផលច្រើន
យ៉ាង រមែងមានព្រោះហេតុតែម្យ៉ាងក៏ទេ
ផលតែម្យ៉ាង រមែងមានហេតុច្រើនក៏ទេ
តែប្រយោជន៍ក្នុងការសម្តែងហេតុ និង
ផល តែម្យ៉ាងមានហើយ ។



ពិតណាស់ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់សម្តែងហេតុនិងផលតែម្យ៉ាងប៉ុណ្ណោះ ដោយសមគួរដល់ទេសនា និងដល់វេនេយ្យសត្វ ព្រោះជាប្រធានក្នុងទីគ្រប់កន្លែង ព្រោះប្រាកដក្នុងទីគ្រប់កន្លែង ។ ព្រោះទូទៅក្នុងទីគ្រប់កន្លែង ។ ដូច្នោះ គប្បីជ្រាបថា អវិជ្ជាក្នុងទីនេះ សូម្បីជាហេតុនៃសង្ខារទាំងឡាយដែលមានវត្ថុជាអារម្មណ៍ និងធម៌កើតរួមគ្នាជាដើមពួកដទៃទៀត លោកក៏សម្តែងដោយភាពជាហេតុនៃសង្ខារទាំងឡាយ ព្រោះជាប្រធានក្នុងបទថា អវិជ្ជាជាហេតុ នៃហេតុរបស់សង្ខារ មានតណ្ហាជាដើមសូម្បីដទៃទៀត ព្រោះបាលីថា **អស្សាទានុបស្សិនោ តណ្ហា បវឌ្ឍតិ** តណ្ហារមែងចម្រើនដល់អ្នកឃើញសេចក្តីរីករាយ និងថា **អវិជ្ជា សមុទយា អាសវសមុទយោ** ព្រោះអវិជ្ជាជាសមុទ័យ អាសវៈទើបកើត ។ ព្រោះប្រាកដក្នុងបាលីថា **អវិទ្វា ភិក្ខវេ អវិជ្ជាគតោ បុញ្ញាភិសង្ខារម្បិ អភិសង្ខរោតិ** ម្នាលភិក្ខុទាំងឡាយ អ្នកមិនដឹង លុះក្នុងអំណាចអវិជ្ជា រមែងតាក់តែង សូម្បីបុញ្ញាភិសង្ខារ នេះក៏ឈ្មោះថា អភិសង្ខារ ។ ម្យ៉ាងទៀត គប្បីជ្រាបប្រយោជន៍ក្នុងការសម្តែងហេតុផលតែមួយ ៗ ក្នុងទីទាំងពួង

ដោយការពារការសម្តែងហេតុផលតែមួយ ៗ នោះ នោះឯង ។

ក្នុងបទនេះ ព្រះសារីបុត្តត្ថេរពោលថា បើដូច្នោះ សភាពនៃអវិជ្ជា មានទោសជាផល មិនគួរប្រាថ្នាជាបច្ច័យនៃបុញ្ញាភិ-សង្ខារ និងអានេញ្ជាភិសង្ខារ នឹងត្រឹមត្រូវយ៉ាងណា ។ ព្រោះអំពៅមិនកើតពីពូជស្តៅបាន ។ នឹងពោលត្រឹមត្រូវបានយ៉ាងណា ? ព្រោះក្នុងលោក

វិរុទ្ធ ចាវិរុទ្ធា ច សទិសាសទិសោ តថា
ធម្មានំ បច្ចយោ សិទ្ធា វិបាកា ឯវ តេ ច ន ។

ធម៌ទាំងឡាយដែលសម្រេចជាបច្ច័យហើយ
ខុសឋានៈគ្នាក៏មាន ដូចគ្នាក៏មាន ម្យ៉ាងទៀត មាន
ដូចគ្នា និងមិនដូចគ្នាក៏មាន ធម៌ទាំងនោះមិនមែន
វិបាកតែម្យ៉ាងក៏ទេដែរ ។

ដោយប្រការដូច្នេះ គប្បីជ្រាបថា អវិជ្ជានេះទើបមានផលមិនគួរប្រាថ្នាដោយពិត ដោយអំណាចវិបាក ។ អវិជ្ជាសូម្បីមានទោសដោយអំណាចសភាវៈ ក៏នៅតែជាបច្ច័យ ដោយអំណាចជាបច្ច័យនៃសេចក្តីខុស និងមិនខុស ដោយឋានៈ កិច្ច និងសភាវៈ



តាមសមគួរដល់បុញ្ញាភិសង្ខារជាដើម ទាំងឡាយនោះទាំងអស់ និងដោយអំណាចជាបច្ច័យដូចគ្នា និងមិនដូចគ្នា ។

ម្យ៉ាងវិញទៀត

បុគ្គលណាវង្វេងក្នុងសង្សារដែលមានចុតិ
និងឧប្បត្តិ ក្នុងលក្ខណៈនៃសង្ខារទាំងឡាយ និង
ក្នុងធម៌ដែលអាស្រ័យគ្នាកើតឡើង ។

បុគ្គលនោះរមែងតាក់តែងសង្ខារ ៣ យ៉ាង
ទាំងនោះ ព្រោះអវិជ្ជានេះជាបច្ច័យនៃសង្ខារ ៣
យ៉ាងនោះ ។

ដូចបុគ្គលខ្វាក់ភ្នែកពីកំណើត មិនមានអ្នក
នាំផ្លូវ គ្រាខ្លះក៏ទៅត្រូវផ្លូវ គ្រាខ្លះក៏ទៅខុសផ្លូវ
យ៉ាងណា ។

បុគ្គលពាល កាលត្រាច់ទៅក្នុងសង្សារមិន
មានអ្នកណែនាំ ក៏ដូច្នោះ ។ គ្រាខ្លះក៏ធ្វើបុណ្យ
គ្រាខ្លះក៏ធ្វើបាប ។

កាលបើបុគ្គលនោះដឹងធម៌ហើយ ត្រាស់

ដឹងអរិយសច្ច កាលនោះនឹងត្រាច់ទៅយ៉ាងស្ងប់
ព្រោះអវិជ្ជាស្ងប់ ។

បទថា **សង្ខារប្បច្ចយា វិញ្ញាណំ** ព្រោះសង្ខារជា បច្ច័យ ទើបមានវិញ្ញាណ សេចក្តីថា កងវិញ្ញាណមាន ៦ គឺ ចក្ខុវិញ្ញាណ ១ សោតវិញ្ញាណ ១ ឃានវិញ្ញាណ ១ ជិវ្ហាវិញ្ញាណ ១ កាយវិញ្ញាណ ១ មនោវិញ្ញាណ ១ ។

ក្នុងវិញ្ញាណទាំងនោះ ចក្ខុវិញ្ញាណមាន ២ យ៉ាង គឺ កុសលវិបាក ១ អកុសលវិបាក ១ ។ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ ក៏ដូចគ្នា ។ មនោវិញ្ញាណមាន ២២ គឺ វិបាកមនោធាតុ ២ អហេតុកមនោវិញ្ញាណធាតុ ៣ ។ សហេតុកវិបាកចិត្ត ៨ ។ រូបាវចរវិបាកចិត្ត ៥ ។ អរូបាវចរវិបាកចិត្ត ៤ ។ វិញ្ញាណទាំងអស់ ជាលោកិយវិបាកវិញ្ញាណ ៣២ ដោយប្រការដូច្នេះ ។

ក្នុងប្រការនោះ គប្បីមានពាក្យសួរថា គប្បីដឹងបានយ៉ាងណាថា វិញ្ញាណមានប្រការដូចពោលមកនេះ មានព្រោះសង្ខារជាបច្ច័យ ។ ព្រោះមិនមានវិបាក ក្នុងកាលមិនបានសន្សំកម្មទុក ។



ពិតណាស់ វិបាកនេះរមែងមិនកើត ព្រោះមិនមានកម្មដែលសន្សំទុក ។ នឹងថា គប្បីកើត ។ វិបាកទាំងអស់របស់កម្មទាំងពួងគប្បីកើត ។ តែវិបាកទាំងពួងមិនកើត ព្រោះដូច្នោះ គប្បីដឹងប្រការនេះថា ព្រោះសង្ខារជាបច្ច័យ វិញ្ញាណទើបមាន ។

ពិតហើយ វិញ្ញាណនេះទាំងអស់ រមែងប្រព្រឹត្តទៅ ២ ចំណែក ដោយអំណាចបដិសន្ធិដែលប្រព្រឹត្តទៅ ។ ក្នុងវិញ្ញាណនោះ វិញ្ញាណ ១៣ ទាំងនេះ គឺ វិញ្ញាណ ៥ យ៉ាងក្នុងមួយ ៗ មាន ២ , មនោធាតុ ២ , អហេតុកមនោវិញ្ញាណធាតុ សហគតដោយសោមនស្ស ១ ។ រមែងប្រព្រឹត្តទៅក្នុងបញ្ចវោការភព ។ វិញ្ញាណ ១៩ ដ៏សេស រមែងប្រព្រឹត្តទៅក្នុងបវត្តិកាលខ្លះ ក្នុងបដិសន្ធិកាលខ្លះ តាមសមគួរក្នុងភព ៣ ។

**លទ្ធប្បច្ចយមិតិ ធម្ម មត្តមេតំ ភវន្តរមេតិ**
**នាស្ស តតោ សង្កន្តិ ន តតោ ហេតុំ វិនា ហោតិ ។**

វិញ្ញាណនេះ ជាធម៌ដែលបានបច្ច័យហើយ
រមែងចូលដល់ភពដទៃដោយប្រការដូច្នេះ
ការឃ្លាតទៅពីភព រមែងមិនមានដល់

វិញ្ញាណនោះ វិញ្ញាណវៀរហេតុអំពីភព
នោះ ក៏មិនមាន ។

លោកអធិប្បាយថា វិញ្ញាណនេះកើតឡើងអាស្រ័យរូបធម៌និងនាមធម៌ជាបច្ច័យដែលបានហើយ រមែងចូលដល់ភពដទៃ មិនមែនសត្វ មិនមែនជីវៈ ដោយប្រការដូច្នេះ ម្យ៉ាងទៀត ការឃ្លាតចាកភពក្នុងអតីតមកក្នុងភពនេះរបស់វិញ្ញាណនោះ ក៏មិនមានការប្រាកដរបស់វិញ្ញាណក្នុងលោកនេះ វៀរហេតុអំពីភពអតីតក៏មានមិនបាន ។ ម្យ៉ាងទៀត ក្នុងបទនេះលោកពោលថា ការចុតិ ដោយការឃ្លាតទៅមានមុន ។ ការបដិសន្ធិដោយការបន្តរវាងភពជាដើម មានក្នុងខាងក្រោយ ។

ក្នុងបទនេះ ព្រះសារីបុត្តត្ថេរៈពោលទុកថា កាលបើមានការមិនឃ្លាតទៅប្រាកដយ៉ាងនេះ នឹងគប្បីមានផលរបស់វត្ថុដទៃដោយសភាពដទៃ ។ ព្រោះខន្ធក្នុងអត្តភាពមនុស្ស រលត់ទៅព្រោះកម្ម ដែលជាបច្ច័យរបស់ផលមិនស្ទុះទៅក្នុងវិញ្ញាណនោះ មិនមែនឬ ។ ម្យ៉ាងទៀត កាលមិនមានអ្នកសេព ផលនឹងគប្បីមានដល់បុគ្គលណា ។ ព្រោះដូច្នោះ វិធីនេះទើបមិនល្អ ។



លោកពោលទុកក្នុងបទនេះថា

**សន្តានេ យំ ផលំ ឯតំ នាញ្ញស្ស ន ច អញ្ញតោ**
**ពីជានំ អភិសង្ខារោ ឯតស្សត្ថស្ស សាធកោ ។**

ផលណាក្នុងសន្តាន ផលនេះមិនមែនរបស់កម្មដទៃ និងមិនមានពីកម្មដទៃ ការតាក់តែងពូជទាំងឡាយជាការពិចារណាខ្លឹមសារនេះ ។

**ផលស្សុប្បត្តិយា ឯវ សិទ្ធា ភុញ្ជកសម្មុតិ**
**ផលុប្បាទេន រុក្ខស្ស យថា ផលតិសម្មុតិ ។**

សម្មុតិថា បុគ្គលអ្នកសោយសម្រេច ព្រោះការកើតឡើងនៃផល ក៏ដូចជាសម្មុតិថា ដើមឈើផលិតផល ព្រោះការកើតឡើងនៃផល ។

សូម្បីអ្នកណាគប្បីពោលថា បើដូច្នេះ សង្ខារទាំងនេះមានហើយក៏ដោយ មិនមានក៏ដោយ គប្បីជាបច្ច័យដល់ផល ។ និងពោលថា មាននៅក្នុងខណៈប្រព្រឹត្តទៅនោះឯង ក៏គប្បីជាវិបាកនៃសង្ខារទាំងនោះ ។ កាលបើមិនមានហើយ សង្ខារទាំងឡាយគប្បីនាំមកនូវផលជានិច្ច ទាំងមុន និងក្រោយពីការប្រព្រឹត្ត

ទៅ ។ បញ្ហាកម្មនោះ គប្បីឆ្លើយតប អ្នកសួរនោះយ៉ាងនេះថា

**កដត្តា បច្ចយា ឯតេ ន ច និច្ចផលាវហា**
**បាដិភោគាទិកំ តត្ថ វេទិតព្វំ និទស្សនំ ។**

សង្ខារទាំងនេះជាបច្ច័យ ព្រោះការធ្វើ មិនមែន
នាំមកនូវផលជានិច្ចឡើយ ក្នុងរឿងនោះ គប្បី
ជ្រាបរឿងអ្នកវេញខ្សែ ជាតួយ៉ាង ។

បទថា **វិញ្ញាណប្បច្ចយា នាមរូបំ** ព្រោះវិញ្ញាណជាបច្ច័យ ទើបមាននាមរូប សេចក្តីថា វេទនា សញ្ញា សង្ខារ ជានាម ។ មហាភូតរូប ៤ និងរូបអាស្រ័យមហាភូតរូប ៤ ជារូប ។ ធម៌ ២៣ ទាំងនេះបាន រូប ២០ គឺ វត្ថុទសកៈ កាយទសកៈ ក្នុងខណៈបដិសន្ធិរបស់សត្វដែលកើតក្នុងគភ៌ អ្នកមិនមានភាវៈ និងអ្នកកើតក្នុងស៊ុត និងអរូបក្ខន្ធ ៣ [១] គប្បីជ្រាបថា ព្រោះវិញ្ញាណជាបច្ច័យ ទើបមាននាមរូប ។ បន្ថែមភាវទសកៈនៃសត្វដែលមានភាវរូប ទើបជាធម៌ ៣៣ ។

---

១ អរូបក្ខន្ធ ៣ បានដល់ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ ។



ធម៌ ៤២ ទាំងនេះ គឺ រូប ៣៩ គឺ ចក្ខុទសកៈ សោតទសកៈ វត្ថុទសកៈ និងជីវិតិន្ទ្រិយនវកៈ ក្នុងខណៈនៃបដិសន្ធិរបស់ព្រហ្មកាយិកា គឺ ទេពដែលរាប់បញ្ចូលក្នុងពពួកព្រហ្មជាដើម ក្នុងបណ្តាសត្វដែលជាឱបបាតិកៈទាំងឡាយ និងអរូបក្ខន្ធ ៣ ។ គប្បីជ្រាបថា ព្រោះវិញ្ញាណជាបច្ច័យ ទើបមាននាមរូប ។

មយ៉ាងទៀត ក្នុងកាមភព ធម៌ ៧៣ ទាំងនេះ គឺ រូប ៧០ បានដល់ ចក្ខុទសកៈ សោតទសកៈ ឃានទសកៈ ជិវ្ហាទសកៈ កាយទសកៈ វត្ថុទសកៈ ភាវទសកៈ ក្នុងខណៈបដិសន្ធិរបស់ឱបបាតិកៈក្តី សំសេទជៈក្តី ដែលមានអាយតនៈបរិបូរណ៍តាមសភាវៈ ។ និងអរូបក្ខន្ធ ៣ ។ ឈ្មោះថា ព្រោះវិញ្ញាណជាបច្ច័យ ទើបមាននាមរូប ។ នេះជាសេចក្តីដ៏កំពូល ។ តែដោយសេចក្តីសង្ខេប គប្បីជ្រាបការកំណត់នាមរូប ព្រោះវិញ្ញាណជាបច្ច័យក្នុងបដិសន្ធិ ព្រោះបន្ថយចុះមក ដោយអំណាចនៃភាពមិនប្រក្រតីរបស់ទសកៈនោះៗ នៃនាមរូបនោះៗ ។ អរូបក្ខន្ធ ៣ របស់ធម៌មិនមានរូប ។ ជីវិតិន្ទ្រិយនវកៈនោះឯង ជារូបរបស់ធម៌មិនមានសញ្ញា ។ ក្នុងបដិសន្ធិក៏មានន័យនេះ ។

ក្នុងបទនោះ គប្បីមានពាក្យសួរថា ប្រការនោះនឹងគប្បីដឹងបានយ៉ាងណា ? បដិសន្ធិនាមរូប មានវិញ្ញាជាបច្ច័យឬ ។ ឆ្លើយថា ដឹងបានដោយសូត្រ និងយុកតិ ( ការពេញចិត្តក្នុងហេតុផល ) ។ ព្រោះក្នុងសូត្រ សភាពវេទនាជាដើម មានវិញ្ញាណជាបច្ច័យ ជាទីពឹងអាស្រ័យគ្នាដោយចំណែកច្រើន តាមន័យមានជាអាទិ៍ថា ធម៌ទាំងឡាយប្រព្រឹត្តទៅតាមចិត្ត តែដោយយុកតិថា

**ចិត្តជេន ហិ រូបេន ឥធ ទិដ្ឋេន សិជ្ឈតិ**
**អទិដ្ឋស្សាបិ រូបស្ស វិញ្ញាណំ បច្ចយោ ឥតិ ។**

សេចក្តីពិត វិញ្ញាណរមែងសម្រេចដោយរូប
ដែលកើតពីចិត្តឃើញហើយ ក្នុងទីនេះវិញ្ញាណ
ជាបច្ច័យដល់រូប សូម្បីមិនបានឃើញ ។

បទថា **នាមរូបប្បច្ចយា សឡាយតនំ** ព្រោះនាមរូបជាបច្ច័យ ទើបមានសឡាយតនៈ នាមដូចបានពោលហើយ ។ តែរូបក្នុងទីនេះ ដោយនិយមមាន ១១ យ៉ាង គឺ មហាភូតរូប ៤ វត្ថុ ៦ ជីវិតិន្ទ្រិយ ១ ។ អាយតនៈ ៦ គឺ ចក្ខាយតនៈ ១ សោតាយតនៈ ១ ឃានាយតនៈ ១ ជិវ្ហាយតនៈ ១ កាយាយតនៈ



១ មនាយតនៈ ១ ។

ក្នុងបទនោះ គប្បីមានពាក្យសួរថា ប្រការនោះនឹងគប្បីដឹងបានយ៉ាងណាថា នាមរូបជាបច្ច័យដល់សឡាយតនៈ ។ ឆ្លើយថាដឹងបានព្រោះការកើតនាមរូប ។ ពិតណាស់ អាយតនៈនោះៗរមែងមានក្នុងការកើតនៃនាម និងរូបនោះ ៗ ។ មិនមែនមានក្នុងទីដទៃ ។

បទថា **សឡាយតនប្បច្ចយា ផស្សោ** ព្រោះមានសឡាយតនៈជាបច្ច័យ ទើបមានផស្សៈ សេចក្តីថា ៖

ផស្សៈយ៉ាងសង្ខេបមាន ៦ យ៉ាង មានចក្ខុសម្ផ័ស្សជាដើម ។ ដោយពិស្តារមាន ៣២ យ៉ាង ដូចវិញ្ញាណ ។

បទថា **ផស្សប្បច្ចយា វេទនា** ព្រោះមានផស្សៈជាបច្ច័យ ទើបមានវេទនា សេចក្តីថា :

លោកពោលវេទនា មានចក្ខុសម្ផ័ស្សជាវេទនាជាដើម ដោយទ្វារ វេទនាទាំងនោះដោយប្រភេទមាន ៦ តែក្នុងទីនេះ វេទនាមាន ៣២ ។

បទថា **វេទនាបច្ចយា តណ្ហា** ព្រោះវេទនាជាបច្ច័យ ទើប

មានតណ្ហា សេចក្តីថា ៖

ក្នុងទីនេះ លោកសម្តែងតណ្ហា ៦ យ៉ាង ដោយប្រភេទមានរូបតណ្ហាជាដើម តណ្ហាមួយ ៗ មាន ៣ យ៉ាង ដោយអាការដែលប្រព្រឹត្តទៅក្នុងវេទនានោះ ។

អ្នកមានទុក្ខ រមែងប្រាថ្នាសេចក្តីសុខ អ្នកមានសេចក្តីសុខ រមែងប្រាថ្នាឲ្យមានសេចក្តីសុខក្រៃលែងឡើង តែឧបេក្ខាជាសុខតែម្យ៉ាង ព្រោះស្ងប់ ។

ព្រោះដូច្នោះ វេទនា ៣ យ៉ាង ជាបច្ច័យដល់តណ្ហា ព្រះមានព្រះភាគជាម្ចាស់ ដែលស្វែងរកគុណដ៏ធំ ទើបត្រាស់ថា ព្រោះមានវេទនាជាបច្ច័យ ទើបមានតណ្ហា ។

បទថា **តណ្ហាបច្ចយា ឧបាទានំ** ព្រោះមានតណ្ហាជាបច្ច័យ ទើបមានឧបាទាន សេចក្តីថា ឧបាទាន ៤ គឺ កាមុបាទាន ១ ទិដ្ឋុបាទាន ១ សីលព្វតុបាទាន ១ អត្តវាទុបាទាន ១ ។

បទថា **ឧបាទានប្បច្ចយា ភវោ** ព្រោះមានឧបាទានជាបច្ច័យ ទើបមានភព ។ ក្នុងទីនេះលោកបំណងយកកម្មភព ។ តែលោកពោលឧបបត្តិភពដោយបំណងដល់ស័ព្ទ ។



បទថា **ភវប្បច្ចយា ជាតិ** ព្រោះមានភពជាបច្ច័យ ទើបមានជាតិ គឺ សេចក្តីប្រាកដនៃបដិសន្ធិខន្ធ ព្រោះមានកម្មភពជាបច្ច័យ ។

ក្នុងបទនោះ ប្រសិនបើមានពាក្យសួរថា ប្រការនោះនឹងគប្បីដឹងបានយ៉ាងណាថា ភពជាបច្ច័យដល់ជាតិ ។ ឆ្លើយថា ដឹងបាន ព្រោះសម្តែងដល់ការផ្សេងគ្នា មានថោកទាប និងប្រណីតជាដើម សូម្បីក្នុងការស្មើគ្នាដោយបច្ច័យខាងក្រៅ លោកក៏សម្តែងសេចក្តីផ្សេងគ្នា មានថោកទាប និងប្រណីតជាដើម របស់សត្វទាំងឡាយតាំងពី ១០០ គូ សូម្បីក្នុងការស្មើគ្នានៃបច្ច័យខាងក្រៅមានបិតាមាតា ឈាមស និងអាហារជាដើម ។ សេចក្តីផ្សេងគ្នានោះ មិនមែនជាអហេតុកៈ ព្រោះមិនមានក្នុងកាលទាំងពួង និងដល់សត្វទាំងពួង ។ មិនមែនហេតុដទៃក្រៅអំពីកម្មភព ព្រោះមិនមានហេតុដទៃ ក្នុងសន្តានរបស់សត្វដែលកើតក្នុងកម្មភពនោះ ព្រោះហេតុនោះ ទើបឈ្មោះថា មានកម្មភពជាហេតុ ។ ពិតហើយ កម្មជាហេតុនៃសេចក្តីប្លែកគ្នា មានសភាពថោកទាប និងប្រណីតជាដើម របស់សត្វទាំងឡាយ ។

ដោយហេតុនោះ ព្រះដ៏មានព្រះភាគទើបត្រាស់ថា **កម្មំ សត្តេ វិភជតិ យទិទំ ហីនប្បណីតតាយ**[១] កម្មរមែងចែកសត្វទាំងឡាយ គឺ ឲ្យមានសភាពថោកទាប និងប្រណីត ។

ក្នុងបទមានជាអាទិ៍ថា **ជាតិប្បច្ចយា ជរាមរណំ** ព្រោះមានជាតិជាបច្ច័យ ទើបមានជរា និងមរណៈ មានអធិប្បាយដូចតទៅនេះ គប្បីជ្រាបថា ព្រោះបើមិនមាន ជាតិ ជរាមរណៈ ឬថាធម៌មានសោកៈជាដើម ក៏មិនមាន ។ តែកាលបើមានជាតិ ជរាមរណៈ និងធម៌ទាំងឡាយមានសោកៈជាដើម ដែលទាក់ទងជាមួយជរា មរណៈ របស់បុគ្គលពាល ដែលត្រូវទុក្ខធម៌នោះ ៗ ពាល់ត្រូវហើយ ក៏មាន ។ ដូច្នោះ ជាតិនេះ ទើបជាបច្ច័យនៃជរាមរណៈ និងដល់សោកៈជាដើម ។

ក្នុងបទមានជាអាទិ៍ថា **សោ តថា ភាវិតេន ចិត្តេន** ភិក្ខុនោះមានចិត្តអប់រំហើយយ៉ាងនោះ គប្បីជ្រាបការអធិប្បាយដូចតទៅនេះ បទថា **បុព្វេនិវាសានុស្សតិញ្ញាណាយ** លោកអធិ-

---

១ មជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ



ប្បាយថា ដើម្បីសម្រេចញាណនោះ គឺ ដល់ ៗ បទថា **អនេកវិហិតំ** គឺ ច្រើនយ៉ាង ៗ ច្រើនប្រការ ៗ ឬប្រព្រឹត្តទៅហើយពណ៌នាហើយ ដោយប្រការមិនតិច ។

បទថា **បុព្វេនិវាសំ** ជាតិមុន គឺ សន្តានដែលនៅក្នុងជាតិនោះ ៗ ធ្លើកពក្នុងអតីត ដែលជិតជាទីបំផុតឲ្យជាខាងដើម ។

បទថា **អនុស្សរតិ** រមែងរឭកតាមរឿយ ៗ ដោយអំណាចលំដាប់ខន្ធ ឬដោយអំណាចចុតិបដិសន្ធិ ។ ពិតហើយ ជនទាំង ៦ គឺ តិរ្ថិយ៍ ១ , សាវកធម្មតា ១ , មហាសាវក ១ , អគ្គសាវក ១ , ព្រះបច្ចេកពុទ្ធ ១ , ព្រះសម្ពុទ្ធជាម្ចាស់ ១ រមែងរឭកដល់ជាតិមុនបាន ។

ក្នុងជនទាំងនោះ **តិរ្ថិយ៍ទាំងឡាយ** រមែងរឭកបាន ៤០ កប្ប ។ មិនច្រើនជាងនោះ ។ ព្រោះហេតុអ្វី ព្រោះតិរ្ថិយ៍មានបញ្ញាទន់ខ្សោយ ។ ពិតណាស់ បញ្ញារបស់តិរ្ថិយ៍ទាំងនោះទន់ខ្សោយព្រោះមិនមានការកំណត់នាមរូប ។

**សាវកធម្មតា** រមែងរឭកបាន ១០០ កប្បខ្លះ ១.០០០ កប្បខ្លះ ព្រោះមានបញ្ញាចាស់ក្លា ។ **មហាសាវក** ៨០ រូប រឭក

បាន ១ សែនកប្ប ។ **អគ្គសាវក** ទាំងពីរ រឭកបាន ១ អសង្ខេយ្យ និង ១ សែនកប្ប ។ **ព្រះបច្ចេកពុទ្ធ** រឭកបាន ២ អសង្ខេយ្យ និង ១ សែនកប្ប ។ ព្រោះអភិនិហាររបស់ព្រះបច្ចេកពុទ្ធទាំងនោះ មានប្រមាណត្រឹមនេះ ។ តែ **ព្រះសម្ពុទ្ធជាម្ចាស់ទាំងឡាយ** រឭកបានមិនមានកំណត់ ។

ម្យ៉ាងទៀត **តិរ្ថីយ៍ទាំងឡាយ** រឭកបានតាមលំដាប់ខន្ធប៉ុណ្ណោះ ផុតអំពីលំដាប់នោះទៅ មិនអាចរឭកដល់ចុតិ និងបដិសន្ធិបានឡើយ ។ តិរ្ថីយ៍ទាំងនោះ រឭកបានមិនផុតអំពីលំដាប់ខន្ធ ដូចមនុស្សខ្វាក់ភ្នែកពីកំណើត មិនបោះបង់ឈើច្រត់ហើយដើរទៅដូច្នោះ ។

**សាវកធម្មតា** រឭកបានសូម្បីតាមលំដាប់ខន្ធ រមែងឈានទៅដល់ចុតិបដិសន្ធិ ។ **មហាសាវក ៨០ រូប** ក៏យ៉ាងនោះ ។ ចំណែក **អគ្គសាវកទាំងពីរ** មិនមានកិច្ចត្រូវរឭកតាមលំដាប់ខន្ធ គឺ ឃើញចុតិរបស់អត្តភាពមួយហើយ រមែងឃើញបដិសន្ធិផង រមែងឈានទៅដល់ចុតិ និងបដិសន្ធិយ៉ាងនេះ គឺ គ្រាឃើញចុតិរបស់អ្នកដទៃទៀត ក៏រមែងឃើញបដិសន្ធិផង ។ **ព្រះបច្ចេកពុទ្ធ**



ក៏ដូចគ្នា ។ ចំណែក **ព្រះពុទ្ធជាម្ចាស់ទាំងឡាយ** មិនមានកិច្ចត្រូវរឭកតាមលំដាប់ខន្ធ មិនមានកិច្ចត្រូវរឭកទៅដល់ចុតិបដិសន្ធិ ព្រោះថា ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ទ្រង់ប្រាថ្នាឋានៈណា ៗ ខាងក្រោម គឺ កាលកន្លងក្តី ខាងលើ គឺ អនាគតក្តី ក្នុងកោដិកប្ប ច្រើនឋានៈនោះ ៗ រមែងប្រាកដបាន ។ ព្រោះដូច្នោះ ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ទ្រង់បំព្រួញកោដិកប្បដ៏ច្រើន ហើយប្រាថ្នាឋានៈណា ៗ ទ្រង់ឈានចូលទៅក្នុងឋានៈនោះ ៗ ដោយអំណាចនៃការឈានទៅរបស់ព្រះពុទ្ធជាម្ចាស់ ដូចជាសីហៈ ។ ញាណរបស់ព្រះពុទ្ធជាម្ចាស់ទាំងនោះ ប្រព្រឹត្តទៅហើយយ៉ាងនេះ មិនទើសទាក់ក្នុងជាតិ ក្នុងចន្លោះ ៗ រមែងកាន់យកឋានៈដែលទ្រង់ប្រាថ្នា ។

ក៏បណ្តាជនទាំង ៦ នេះ រឭកដល់ជាតិមុនហើយ ការឃើញជាតិមុនរបស់ពួកតិរ្ថីយ៍ រមែងប្រាកដដូចជាពន្លឺសត្វអំពិលអំពែក ។ របស់សាវកធម្មតា ដូចជាពន្លឺប្រទីប ។ របស់មហាសាវក ដូចជាពន្លឺគប់ភ្លើង ។ របស់ព្រះអគ្គសាវក ដូចជារស្មីផ្កាយព្រឹក ។ របស់ព្រះបច្ចេកពុទ្ធ ដូចជារស្មីព្រះច័ន្ទ ។ របស់ព្រះពុទ្ធជាម្ចាស់

រមែងប្រាកដដូចជាមណ្ឌលព្រះអាទិត្យក្នុងសរទកាល ប្រដាប់ដោយរស្មីមួយពាន់ដួង ។

ការរឭកដល់ជាតិមុនរបស់តិរ្ថីយ៍ ដូចមនុស្សខ្វាក់ភ្នែកដើរទៅដោយឈើច្រត់ ។ របស់សាវកធម្មតា ដូចដើរលើស្ពានដោយមានឈើច្រត់ ។ របស់ព្រះមហាសាវក ដូចដើរលើស្ពានដោយស្មងជើង ។ របស់ព្រះអគ្គសាវក ដូចដើរលើស្ពានរទេះ ។ របស់ព្រះបច្ចេកពុទ្ធ ដូចដើរតាមផ្លូវដោយកម្លាំងស្មងជើង ។ របស់ព្រះពុទ្ធជាម្ចាស់ ដូចដើរតាមផ្លូវរទេះធំ ។ ក៏ក្នុងអធិការនេះ លោកបំណងយក ការរឭកដល់ជាតិមុនរបស់ព្រះសាវកទាំងឡាយ ។

ព្រោះដូច្នោះ ភិក្ខុដែលជាអាទិកម្មិកៈ បំណងរឭកដល់យ៉ាងនេះ ត្រឡប់ពីបិណ្ឌបាត្រ ឆាន់អាហារហើយ ទៅក្នុងទីស្ងាត់ ចូលឈាន ៤ តាមលំដាប់ លុះចេញចាកចតុត្ថជ្ឈានដែលជាបាទនៃអភិញ្ញា ពិចារណាបដិច្ចសមុប្បាទ ដោយន័យដូចពោលហើយ គប្បីអន្ទ្រុយពិចារណាខាងក្រោយភិក្ខុទាំងអស់ ។ បន្ទាប់ពីនោះ គប្បីនឹកដល់កិច្ចដែលធ្វើអស់យប់ និងថ្ងៃតាម



លំដាប់ដោយគ្រប់សព្វយ៉ាងនេះ គឺ ក្រាលអាសនៈ ចូលទៅកាន់សេនាសនៈ ទុកដាក់បាត្រចីវរ វេលាឆាន់ វេលាមកពីស្រុក វេលាត្រាច់ទៅបិណ្ឌបាត្រក្នុងស្រុក វេលាចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត្រ វេលាចេញពីវត្ត វេលាសំពះព្រះចេតិយ និងដើមពោធិ វេលាលាងបាត្រ វេលាទទួលបាត្រ ធ្វើកិច្ចចាប់ផ្តើមតាំងអំពីទទួលបាត្រ រហូតដល់លាងបាត្រ ធ្វើកិច្ចក្នុងវេលាថ្ងៃជិតរះ ធ្វើកិច្ចក្នុងមជ្ឈិមយាម ក្នុងបឋមយាម ។ កិច្ចប្រមាណប៉ុណ្ណេះ រមែងប្រាកដដល់សូម្បីដល់ចិត្តប្រក្រតី ។

ចំណែកចិត្តក្នុងបរិកម្មសមាធិ រមែងប្រាកដក្រៃលែងឡើងទៅ ប្រសិនបើមិនមានអ្វី ៗ ប្រាកដក្នុងចិត្តនេះ គួរចូលឈានជាបាទទៀត លុះចេញហើយ ទើបគួររឭកដល់ ដោយហេតុនេះចិត្តប្រាកដដូចជាប្រទីបដែលមានពន្លឺស្វាងស្វៃ ។ គួររឭកដល់កិច្ចដែលធ្វើក្នុងថ្ងៃទី ២ ខ្លះ ក្នុងថ្ងៃទី ៣ ខ្លះ ទី ៤ ទី ៥ ខ្លះ ក្នុង ១០ ថ្ងៃខ្លះ ក្នុងកន្លះខែខ្លះ ក្នុងមួយខែខ្លះ ក្នុងមួយឆ្នាំខ្លះ តាមលំដាប់ដោយសព្វគ្រប់ យ៉ាងនេះឯង ។ ដោយឧបាយនេះការរឭកដល់រហូតបដិសន្ធិរបស់ខ្លួនក្នុងភពនេះ គឺ ១០ ឆ្នាំ ២០

ឆ្នាំ គប្បីវព្រកដល់នាមរូបដែលប្រព្រឹត្តទៅក្នុងខណៈចុតិក្នុងភពមុន ។

ពិតណាស់ ភិក្ខុដែលឆ្លាត លុះបានឃើញបដិសន្ធិក្នុងវារៈទីមួយហើយ ក៏ល្មមនឹងធ្វើនាមរូបឲ្យជាអារម្មណ៍ ។ ព្រោះនាមរូបក្នុងភពមុនរលត់មិនមានសល់ ។ ក្នុងភពនេះ នាមរូបដទៃកើត ។ ដូច្នោះ ឋានៈនោះទើបដូចជាផ្លូវបិទដ៏ងងឹតដែលបុគ្គលមានបញ្ញាទន់ខ្សោយ ឃើញបានលំបាក ។ សូម្បីដោយហេតុនោះ ក៏មិនគួរលះបង់ធុរៈថា យើងមិនអាចនឹងសម្រេចការឃើញបដិសន្ធិ ហើយធ្វើនាមរូបឲ្យជាអារម្មណ៍ក្នុងខណៈចុតិបាន ។ គប្បីចូលឈានដែលជាបាទ នោះឯងរឿយ ៗ លុះចេញចាកឈាននោះហើយ គប្បីវព្រកដល់ឋានៈនោះ ៗ ។

ព្រោះបើភិក្ខុធ្វើយ៉ាងនេះហើយ លុះចេញចាកឈានដែលជាបាទ មិនវព្រកដល់ឋានៈដែលវព្រកដល់ក្នុងកាលមុន វព្រកដល់បដិសន្ធិប៉ុណ្ណោះ បានឃើញបដិសន្ធិដោយមិនយឺតយូរ ដើម្បីធ្វើនាមរូបក្នុងខណៈចុតិឲ្យជាអារម្មណ៍ ។ ដូចជាបុរសអ្នកមានកម្លាំងកាប់ដើមឈើធំ ដើម្បីប្រយោជន៍ដល់ជហ្វាផ្ទះកំពូល សូម្បី



មិនអាចកាប់ដើមឈើធំដោយពូថៅមុតដែលរិល ដោយត្រឹមតែកាត់មែក និងស្លឹកប៉ុណ្ណោះ ក៏កុំដាក់ធុរៈ គួរទៅកាន់រោងជាងដែក ប្រុងពូថៅឲ្យមុតវិញ ហើយត្រឡប់មកកាប់ជាថ្មី ។ បើពូថៅមិនមុតទៀត ក៏គួរឲ្យជាងដែកប្រុកបន្តទៀត ហើយបន្តការកាប់ ។ បុរសនោះ កាលព្យាយាមកាប់យ៉ាងនេះ ក្នុងកាលមិនយូរ ដើមឈើធំនោះនឹងដាច់បាន ព្រោះកាលបើកាត់បានហើយក៏មិនមានដើមឈើគួរកាត់ទៀត និងព្រោះដើមឈើដែលកាត់មិនមាន ដូច្នោះ ។ ញាណដែលប្រព្រឹត្តទៅ ព្រោះធ្វើនាមរូបឲ្យជាអារម្មណ៍ តាំងពីការអង្គុយចុះរហូតដល់បដិសន្ធិ មិនឈ្មោះថា បុព្វេនិវាសញ្ញាណ តែញាណនោះឈ្មោះថា **បរិកម្មសមាធិ-ញ្ញាណ** ។ អាចារ្យពួកមួយពោលថា ញាណនេះជាអតីតង្ស-ញ្ញាណខ្លះ ។ ពាក្យនោះសំដៅដល់រូបាវចរ ព្រោះអតីតង្សញ្ញាណជារូបាវចរ មិនត្រូវ ។ ក៏ក្នុងកាលណា មនោទ្វារាវជ្ជនៈឈានកន្លងបដិសន្ធិរបស់ភិក្ខុនោះហើយ ធ្វើនាមរូបដែលប្រព្រឹត្តទៅហើយក្នុងខណៈចុតិឲ្យជាអារម្មណ៍កើតឡើង អប្បនាចិត្តរមែងកើតឡើង ដោយន័យដូចពោលហើយក្នុងពេលមុន ។ ក្នុងកាល

នោះ ញាណដែលសម្បយុត្តដោយចិត្តនោះ របស់ភិក្ខុនោះ ឈ្មោះថា **បុព្វេនិវាសានុស្សតិញ្ញាណ** ។ ភិក្ខុរមែងរឭកដល់ជាតិមុនដោយសតិ ដែលសម្បយុត្តដោយញាណនោះ ។

ក្នុងបទទាំងនោះ បទថា **សេយ្យថីទំ** ជានិបាត ក្នុងអត្ថសម្ដែងដល់ប្រភេទដែលប្រារព្ធហើយ ។ ព្រះសារីបុត្តត្ថេរកាលសម្ដែងប្រភេទ នៃប្រភេទរបស់បុព្វេនិវាសនោះ ទើបពោលបទមានជាអាទិ៍ថា **ឯកម្បិ ជាតឹ** មួយជាតិខ្លះ គឺ ខន្ធសន្តានដែលជាប់ក្នុងភពមួយ មានបដិសន្ធិជាមូល មានចុតិជាបរិយោសាន ។

ក្នុងបទមានជាអាទិ៍ថា **ទ្វេបិ ជាតិយោ** ពីរជាតិខ្លះ ក៏មានន័យដូចពោលហើយ ។

ក្នុងបទមានជាអាទិ៍ថា **អនេកេបិ សំវដ្ដកប្បេ** រហូតសំវដ្ដកប្បដ៏ច្រើន មានអធិប្បាយដូចតទៅនេះ ។ **កប្បវិនាស** ឈ្មោះថា **សំវដ្ដកប្ប** ព្រោះក្នុងគ្រានោះ សត្វទាំងពួងប្រជុំគ្នាក្នុងព្រហ្មលោក ។ **កប្បចម្រើន** ឈ្មោះថា **វិវដ្ដកប្ប** ព្រោះក្នុងគ្រានោះ សត្វទាំងឡាយចេញចាកព្រហ្មលោក គឺ លោកកាន់យកការតាំងនៅក្នុងសំវដ្ដកប្ប ដោយសំវដ្ដកប្ប និងការតាំងនៅ



ក្នុងវិវដ្ដៈ ដោយវិវដ្ដៈក្នុងព្រហ្មលោកនោះ ព្រោះមានព្រហ្មលោកនោះជាមូល ។ ពិតណាស់ បើដូច្នេះ លោករមែងកំណត់អសង្ខេយ្យ ៤ ដូចព្រះមានព្រះភាគត្រាស់ទុកថា :

ម្នាលភិក្ខុទាំងឡាយ កប្បមួយមាន
៤ អសង្ខេយ្យ , ៤ អសង្ខេយ្យដូចម្ដេច ?
ម្នាលភិក្ខុទាំងឡាយ ក្នុងកាលណាកប្បវិនាស ។
រហូតកាលនោះ មិនងាយនឹងរាប់ ។ ម្នាល
ភិក្ខុទាំងឡាយ ក្នុងកាលណា សំវដ្ដកប្ប
តាំងនៅ ។ល។ ម្នាលភិក្ខុទាំងឡាយ ក្នុង
កាលណា កប្បចម្រើន ។ល។ ម្នាលភិក្ខុ
ទាំងឡាយ ក្នុងកាលណាវិវដ្ដកប្បតាំងនៅ ។
រហូតកាលនោះ មិនងាយមានអ្នករាប់បាន[1] ។

ក្នុងកប្បទាំងនោះ **សំវដ្ដកប្ប** មាន ៣ គឺ តេជោសំវដ្ដៈ ១ , អាបោសំវដ្ដៈ ១ , វាយោសំវដ្ដៈ ១ ។ **សំវដ្ដសីមា**

---

១ អង្គុត្តរនិកាយ តិកនិបាត

ខេត្តរបស់សំវដ្តៈ មាន ៣ គឺ អាភស្សរា ១ , សុភកិណ្ហា ១ , វេហប្ផលា ១ ។ កាលណាកប្បវិនាសព្រោះភ្លើង ត្រូវភ្លើងឆេះដល់ចំណែកខាងក្រោមនៃអាភស្សរា ។ កាលណាកប្បវិនាសព្រោះទឹក ត្រូវទឹកជន់លិចរហូតដល់ខាងក្រោមនៃសុភកិណ្ហា ។ កាលណាកប្បវិនាសព្រោះខ្យល់ ត្រូវខ្យល់បក់ផាត់ រហូតដល់ខាងក្រោមនៃវេហប្ផលា ។ ក៏ដោយចំណែកដ៏ធំក្នុងកាលនោះ ពុទ្ធ-ខេត្តមួយ ក៏រមែងវិនាសផងដែរ ។

**ពុទ្ធខេត្ត មាន ៣ គឺ**

ជាតិខេត្ត ១

អាណាខេត្ត ១

វិស័យខេត្ត ១

ក្នុងខេត្ត ៣ ទាំងនោះ ខេត្តដែលកម្រើកញ័រក្នុងការកាន់បដិសន្ធិជាដើម របស់ព្រះតថាគត មានមួយម៉ឺនចក្រវាឡជាទីបំផុត ឈ្មោះថា **ជាតិខេត្ត** ។

អានុភាពរបស់ព្រះបរិត្តទាំងនេះ គឺ **រតនបរិត្ត ខន្ធបរិត្ត ធជគ្គបរិត្ត អាដានាដិយបរិត្ត មោរបរិត្ត** រមែងប្រព្រឹត្តទៅ



ក្នុងខេត្តដែលមាន មួយសែនកោដិចក្រវាឡជាទីបំផុត ឈ្មោះថា **អាណាខេត្ត** ។

ខេត្តដែលព្រះមានព្រះភាគត្រាស់ថា **យាវតា វា បន អាកង្ខេយ្យ** [១] ឬថា ព្រះតថាគតគប្បីប្រាថ្នាដោយប្រមាណត្រឹមណា ដែលរកប្រមាណទីបំផុតមិនបាន ឈ្មោះថា **វិសយខេត្ត** ។ ព្រះតថាគត រមែងទ្រង់ជ្រាបខេត្តដែលទ្រង់ប្រាថ្នា ។ ក្នុងពុទ្ធខេត្ត ៣ យ៉ាង ទាំងនេះ អាណាខេត្តមួយរមែងវិនាសទៅ ។ បើអាណាខេត្តនោះវិនាសទៅ ជាតិខេត្តក៏វិនាសផងដែរ ។ បើខេត្តនោះវិនាស រមែងវិនាសទៅជាមួយគ្នា ។ កាលតាំងនៅ រមែងតាំងនៅជាមួយគ្នា ។

សេចក្តីវិនាស និងការតាំងនៅរបស់ខេត្តនោះ គប្បីជ្រាបយ៉ាងនេះ សម័យណាកប្បវិនាសព្រោះភ្លើង ។ មហាមេឃដែលញុំាងកប្បឲ្យវិនាស ផ្តើមឡើង ញុំាងភ្លៀងមួយមេធំឲ្យធ្លាក់ចុះក្នុងមួយសែនកោដិចក្រវាឡ ។ មនុស្សទាំងឡាយនាំគ្នាត្រេកអរនាំពូជទាំងពួងចេញពីជង្រុក ។ ក៏កាលស្រូវដុះឡើងល្មមគោទំពារស៊ីបាន មហាមេឃក៏ប្រែជាក្តៅ ភ្លៀងសូម្បីមួយតំណក់ក៏

មិនធ្លាក់ចុះ ។ កាលនោះ គឺ មានន័យថា ខ្វះទឹកភ្លៀង ។ សត្វដែលអាស្រ័យភ្លៀងចិញ្ចឹមជីវិត រមែងកើតក្នុងព្រហ្មលោកតាមលំដាប់ ។ និងទេវតាដែលអាស្រ័យផលបុណ្យចិញ្ចឹមជីវិត ក៏ទៅកើតក្នុងព្រហ្មលោកដែរ ។ កាលបើមេឃរាំងយូរយ៉ាងនេះ ទឹកក្នុងសមុទ្រនោះ ៗ ក៏ហួតហែងទៅ ។ សូម្បីត្រី និងអណ្ដើក ក៏ស្លាប់ទៅតាមលំដាប់ ហើយកើតក្នុងព្រហ្មលោក ។ សូម្បីសត្វនរក ក៏ទៅកើតផងដែរ ។

ក្នុងសេចក្ដីនេះ អាចារ្យពួកមួយពោលថា សត្វនរករមែងវិនាសទៅក្នុងការប្រាកដឡើងនៃព្រះអាទិត្យដួងទី ៧ ។ បុគ្គលមិនវៀចាកឈាន រមែងកើតក្នុងព្រហ្មលោក ។ ពួកខ្លះត្រូវទុព្ភិកភ័យបៀតបៀន ។ ពួកខ្លះមិនគួរដើម្បីបាននូវឈាន ។ សត្វទាំងនោះ កើតក្នុងព្រហ្មលោកបានយ៉ាងណា ?

ឆ្លើយថា ដោយអំណាចឈានដែលបានក្នុងទេវលោក ។

ពិតណាស់ ក្នុងកាលនោះ ដោយកន្លងទៅមួយសែនឆ្នាំ កប្បនឹងវិនាស ។ ដូច្នោះ កាមាវចរទេពទាំងឡាយ ឈ្មោះថាលោកព្យូហ ជាសត្វលោក ទម្លាក់សីរសៈ សក់សំពីងសំពោង



ស្រែកយំ យកដៃជូតទឹកភ្នែក ដណ្ដប់សំពត់ក្រហម មានភេទខុសអំពីរូបយ៉ាងច្រើន ត្រាច់ទៅក្នុងផ្លូវរបស់មនុស្ស នាំគ្នាពោលប្រាប់យ៉ាងនេះថា

អ្នកនិរទុក្ខទាំងឡាយ កន្លងទៅមួយសែន
ឆ្នាំ កប្បនឹងវិនាស ។ លោកនេះនឹងវិនាស ។
សូម្បីមហាសមុទ្រក៏នឹងហួតហែង ។ និងមហា
ប្រថពី ភ្នំព្រះសិនេរុនឹងរលំរលាយវិនាសទៅ ។
លោកនឹងវិនាសរហូតដល់ព្រហ្មលោក ។ អ្នក
និរទុក្ខទាំងឡាយ ពួកលោកចូរចម្រើនមេត្តា
ករុណា មុទិតា ឧបេក្ខានឹងគ្នាចុះ ។ ចូរទំនុក
បម្រុងមាតាបិតា ចូរជាអ្នកគោរពដល់អ្នកជា
រាមច្បងក្នុងត្រកូល ដូច្នេះ ។

ពួកមនុស្ស និងភូម្មទេវតាដោយច្រើន លុះស្ដាប់ពាក្យរបស់កាមាវចរទេពទាំងនោះ ក៏នាំគ្នាសង្វេគ មានចិត្តបង្អោនរកគ្នានឹងគ្នា ធ្វើបុណ្យ មានមេត្តាជាដើម ហើយបានទៅកើតក្នុងទេវលោក ។ ក្នុងទេវលោកនោះ ពួកទេពបរិភោគអាហារទិព្វ

ធ្វើបរិកម្មក្នុងវាយោកសិណ ហើយបានឈាន ។ ចំណែកមនុស្ស ពួកដទៃទៅកើតក្នុងទេវលោក ដោយអបរាបរិយវេទនិយកម្ម (កម្មឲ្យផលក្នុងភពត ៗ ទៅ ។ សត្វឈ្មោះថា ត្រាច់ទៅក្នុងសង្សារ វៀរអបរាបរិយវេទនិយកម្មមិនមាន ។ សូម្បីសត្វទាំងនោះ ក៏រមែងបានឈានយ៉ាងនោះ ក្នុងភពនោះ ។ សត្វទាំងពួងរមែងកើតក្នុងព្រហ្មលោក ដោយអំណាចដែលបានឈានហើយក្នុងទេវលោក យ៉ាងនេះ ដោយប្រការដូច្នេះ ។

ដោយកាលដ៏យូរទៅ ក្នុងការកំណត់ឆ្នាំ ព្រះអាទិត្យដួងទីពីររមែងប្រាកដ ។ កាលបើព្រះអាទិត្យនោះប្រាកដ ការកំណត់យប់ថ្ងៃមិនប្រាកដ ។ ព្រះអាទិត្យមួយដួងរះឡើង ។ មួយដួងលិច ។ លោកមិនដាច់សភាពក្តៅ ពីដួងព្រះអាទិត្យឡើយ ។ ក្នុងព្រះអាទិត្យដែលញ៉ាំងកប្បវិនាស មិនមានសុរិយទេវបុត្ត ។ ដូចក្នុងព្រះអាទិត្យប្រក្រតីទេ បើព្រះអាទិត្យប្រក្រតីនៅប្រព្រឹត្តទៅវលាហកខ្លះ អណ្តាតភ្លើងខ្លះ រមែងទៅក្នុងអាកាស ។ កាលបើព្រះអាទិត្យញ៉ាំងកប្បឲ្យវិនាសកំពុងប្រព្រឹត្តទៅ ពួដ៏អាកាសប្រាសចាកផ្សែង និងវលាហក ដូចផ្ទៃកញ្ចក់មិនមានបាទ ដូច្នោះ ។



ទឹកក្នុងជងអូរជាដើមស្ងួតហែង វៀរមហានទីទាំង ៥ តអំពីនោះកន្លងកាលដ៏យូរ ព្រះអាទិត្យដួងទី ៣ កើតឡើង ។ ព្រោះព្រះអាទិត្យដួងទី ៣ នោះប្រាកដ សូម្បីមហានទីក៏ហួតហែង ។ កាលតអំពីនោះដ៏យូរ ព្រះអាទិត្យដួងទី ៤ ប្រាកដ ។ ព្រោះព្រះអាទិត្យដួងទី ៤ ប្រាកដ មហាស្រះ ៧ ទាំងនេះ គឺ សីហបាតនៈ ១ ហង្សបាតនៈ ១ កណ្ណបុណ្ណហៈ ១ រថការទហៈ ១ អនោត្តទហៈ ១ ឆទ្ទន្តទហៈ ១ កុណាលវាហៈ ១ រីងស្ងួត ព្រោះជាកន្លែងកើតមហានទីក្នុងព្រៃហិមពាន្ត ។ តអំពីនោះ ដោយកាលកន្លងយូរទៅ ព្រះអាទិត្យដួងទី ៥ ប្រាកដ ។ ព្រោះព្រះអាទិត្យដួងទី ៥ នោះប្រាកដ ទឹកសូម្បីត្រឹមតែសើមម្រាមដៃ ក៏មិនមាននៅក្នុងមហាសមុទ្រដោយលំដាប់ ។ តពីនោះ ដោយកាលកន្លងយូរទៅ ព្រះអាទិត្យដួងទី ៦ ប្រាកដ ។ ព្រោះព្រះអាទិត្យដួងទី ៦ នោះប្រាកដ ចក្រវាឡទាំងអស់ មានផ្សែងហុយឡើង ពោរពេញទៅដោយផ្សែង ។ សូម្បីមួយសែនកោដិចក្រវាឡ ក៏ដូចជាចក្រវាឡនោះ ។ តពីនោះ អស់កាលដ៏យូរ ព្រះអាទិត្យដួងទី ៧ ប្រាកដ ។ ព្រោះព្រះអាទិត្យដួងទី ៧ ប្រាកដ ចក្រវាឡ

ទាំងអស់ព្រមដោយសែនកោដិ ចក្រវាឡក៏មានអណ្តាតភ្លើងភ្លឺរន្ទាលដូចគ្នា ។ សូម្បីកំពូលភ្នំសិនេរុ កំពស់ប្រមាណ ១០០ យោជន៍ ក៏ត្រូវវិនាសទៅក្នុងអាកាសនោះឯង ។ អណ្តាតភ្លើងនោះ ធាបឆេះរហូតដល់សួគ៌ជាន់ចាតុម្មហារាជកា ។ អណ្តាតភ្លើងឆេះផុតកនកវិមាន រតនវិមាន និងមណីវិមាន រហូតដល់តាវតឹង្សពិភព ។ ដោយឧបាយនេះឯង អណ្តាតភ្លើងបន្តឆេះរហូតដល់បឋមឈានភូមិ ។ ឆេះព្រហ្មលោកទាំង ៣ រហូតដល់អាភស្សរព្រហ្ម ។ អណ្តាតភ្លើងនោះឆេះមិនរលត់ ដរាបសូម្បីសង្ខារត្រឹមតែមួយអណូ ក៏មិនមានសល់ ។ តែព្រោះអស់សង្ខារទាំងពួង សូម្បីផេះក៏មិនមានសល់ ទើបអណ្តាតភ្លើងរលត់ ដូចភ្លើងឆេះខ្លាញ់ និងប្រេង ដូច្នោះ ។ អាកាសផ្នែកខាងលើ និងខាងក្រោម ងងឹតសូន្យដូចគ្នា ។

តមក អស់កាលដ៏យូរ មហាមេឃតាំងឡើង ញុាំងភ្លៀងគ្រាប់ល្អិត ៗ ឲ្យធ្លាក់ចុះជាលើកដំបូង ។ មហាមេឃញុាំងភ្លៀងដែលមានគ្រាប់ប្រមាណប៉ុនទងឈូក ឈើប្រត់ អង្រែ និងដើមត្នោតជាដើម ឲ្យធ្លាក់ចុះមកតាមលំដាប់ ធ្វើទីដែលត្រូវភ្លើងឆេះ



ទាំងអស់ឲ្យពេញ ។ ខ្យល់តាំងឡើង បក់កួរទឹកនោះទាំងខាងក្រោម និងខាងទទឹង ឲ្យទៅជាដុំ ជាផ្លូវដោយជុំវិញ ប្រៀបដូចតំណក់ទឹកលើស្លឹកឈូក ។

ប្រសិនបើសួរថា ធ្វើអន្លង់ទឹកធំដល់ម្លោះ ឲ្យជាដុំបាន យ៉ាងណា ?

ឆ្លើយថា ព្រោះបើកជាចន្លោះទុក ។ ឲ្យមានជាចន្លោះក្នុងទីនោះ ៗ ដល់អន្លង់ទឹកនោះ ។ ទឹកនោះ ត្រូវខ្យល់បក់ប្រមូលធ្វើឲ្យទៅជាដុំអស់ទៅ ក៏ហូរចុះទៅខាងក្រោមតាមលំដាប់ ។ កាលទឹកហូរចុះទៅ ៗ ព្រហ្មលោករមែងប្រាកដ ក្នុងទីរបស់ព្រហ្មលោក ។ ក៏ឯទេវលោករមែងប្រាកដក្នុងទីកន្លែងនៃកាមាវចរទេវលោកចំណែកខាងលើ ។ កាលទឹកហូរចុះដល់ផែនដីដូចមុន ខ្យល់ដ៏មានកម្លាំងកើតឡើង ។ ខ្យល់ដ៏មានកម្លាំងនោះការពារធ្វើឲ្យទឹកមិនហូរចេញ ដូចទឹកនៅក្នុងធម្មក្រកដែលរក្សាទុកល្អហើយ ។ កាលទឹកផ្អែមហួតទៅ ញុាំងក្រាមដី ( រសដី ) ឲ្យតាំងឡើងមកខាងលើ ។ ក្រាមដីនោះ មានពណ៌ មានក្លិន និងរស ដូចគេក្រាលទុកខាងលើបាយបាយាស ដែលមិនមានទឹក ។

ក្នុងកាលនោះ សត្វទាំងឡាយដែលកើតមុនក្នុងអាភស្សរព្រហ្ម-លោក ឃ្លាតចាកទីនោះ ព្រោះអស់អាយុក្ខ័ ព្រោះអស់បុណ្យក្ខ័ រមែងមកកើតនៅទីនេះ ។ សត្វទាំងនោះមានរស្មីដោយខ្លួនឯង ហោះទៅកាន់ឰដ៏អាកាសបាន ។ សត្វទាំងនោះ លុះអស់ផែនដីដែលមានរសនោះ តាមន័យដូចពោលហើយក្នុងអគ្គញ្ញសូត្រ [១] ត្រូវតណ្ហាគ្របសង្កត់ ព្យាយាមបរិភោគវត្ថុដែលធ្វើឲ្យកើតសេចក្ដីលោភ ។

គ្រានោះ រស្មីរបស់សត្វទាំងនោះក៏វិនាសទៅ ។ សភាពងងឹតកើតឡើង ។ សត្វទាំងនោះមានសេចក្ដីភ័យខ្លាច ព្រោះភាពងងឹត ។ តអំពីនោះ សុរិយមណ្ឌលទំហំ ៥០ យោជន៍ ប្រាកដឡើង ញុំាងសេចក្ដីភ័យខ្លាចរបស់សត្វទាំងនោះឲ្យវិនាសទៅ ឲ្យកើតសេចក្ដីក្លាហាន ។ សត្វទាំងនោះ លុះបានឃើញសុរិយមណ្ឌលនោះ សត្វខ្លះរីករាយថា យើងបានពន្លឺហើយ ទើបតាំងឈ្មោះសុរិយមណ្ឌលថា **សុរិយ** ព្រោះតាំងឡើងឲ្យពួកយើង

១ ទីឃនិកាយ បាលី



វិនាសសេចក្ដីភ័យខ្លាច ហើយកើតសេចក្ដីក្លាហានឡើង ព្រោះដូច្នោះ សូមចូរជាសុរិយៈចុះ ។

កាលបើព្រះសុរិយៈ ធ្វើពន្លឺស្វាងស្វែអស់ថ្ងៃហើយរលត់ទៅ សត្វទាំងឡាយមានសេចក្ដីភ័យខ្លាចម្ដងទៀតថា ពន្លឺដែលយើងបានវិនាសទៀតហើយ ។ សត្វទាំងនោះទើបគិតយ៉ាងនេះថា នឹងជាការល្អប្រសិនបើពួកយើងបានពន្លឺដទៃ ។ ច័ន្ទមណ្ឌលប្រមាណ ៤៩ យោជន៍ ប្រាកដឡើង ដូចដឹងចិត្តរបស់សត្វទាំងនោះ ។ សត្វទាំងនោះ លុះឃើញច័ន្ទមណ្ឌលនោះ ក៏នាំគ្នាត្រេកអររីករាយក្រៃលែង ទើបតាំងឈ្មោះច័ន្ទមណ្ឌលនោះថា **ចន្ទ** ព្រោះតាំងឡើងប្រៀបដូចបានដឹងនូវបំណងរបស់ពួកយើង ព្រោះដូច្នោះ សូមចូរជាច័ន្ទចុះ ។

កាលព្រះច័ន្ទ ព្រះអាទិត្យប្រាកដយ៉ាងនេះ នក្ខត្តឫក្សទាំងឡាយក៏ប្រាកដជារូបផ្កាយ ។ ចាប់តាំងអំពីនោះមក យប់ថ្ងៃ និងកន្លះខែ មួយខែ រដូវ ឆ្នាំ ក៏ប្រាកដតាមលំដាប់ ។ ក្នុងថ្ងៃប្រាកដព្រះច័ន្ទ ព្រះអាទិត្យនោះឯង ភ្នំសិនេរុ ចក្រវាឡ ព្រៃហិមពាន្ត និងភ្នំក៏ប្រាកដ ។ ទាំងអស់នោះ ប្រាកដក្នុងថ្ងៃ

ពេញ ខែ ៤ មិនមុនមិនក្រោយ ។ ប្រាកដយ៉ាងណា ? ដូចជាស្រងែផើម ? កាលដាំបាយដោយកូរតែម្តងប៉ុណ្ណោះ ។ កន្លែងខ្លះ ក៏ប៉ោងឡើងស្រដៀងដូចស្តូប ។ កន្លែងខ្លះផតចុះ ដូចជារណ្តៅ ។ កន្លែងខ្លះក៏រាបស្មើ យ៉ាងណា ។ ក្នុងទីដែលទួល ៗ ស្រដៀងស្តូប ក៏ទៅជាភ្នំ ។ ក្នុងទីជារណ្តៅ ក៏ជាមហាសមុទ្រ ។ ក្នុងទីដែលស្មើ ៗ ក៏ទៅជាកោះ ។

លុះកាលបើសត្វទាំងនោះ បរិភោគរសដី ពួកខ្លះក៏សម្បុរស្អាត ពួកខ្លះក៏មានសម្បុរមិនស្អាត តាមលំដាប់ ។ ក្នុងពីរពួកនោះ ពួកដែលមានសម្បុរស្អាតក៏មើលងាយដល់ពួកដែលមានសម្បុរមិនស្អាត ព្រោះការមើលងាយរបស់សត្វទាំងនោះជាបច្ច័យ រសផែនដីក៏វិនាស ។ ប្រាកដជាក្រមរផែនដី ។

លុះក្រមរផែនដី របស់សត្វទាំងឡាយនោះ វិនាសទៅ ដោយន័យនោះ **បទាលតា** វល្លិ៍ម្យ៉ាង មានរសផ្អែមក៏ប្រាកដឡើង សូម្បីបទាលតានោះក៏វិនាសទៅ ដោយន័យនោះ ក៏ប្រាកដជាស្រូវសាលិ មិនមានពូជ មិនមានកន្ទក់ មិនមានសំបក បរិ-សុទ្ធិ៍ មានក្លិនក្រអូប មានផ្លែអំពីស្រូវសារ ។ តអំពីនោះភាជនៈ



រមែង កើតឡើងដល់សត្វទាំងនោះ ។ សត្វទាំងនោះ ដាក់ស្រូវសាលិលើភាជនៈ ហើយតាំងទុកលើផែនថ្ម ។ អណ្តាតភ្លើងកើតឡើងឯង ដុតចំអិនស្រូវសាលិនោះ ស្រូវដែលឆ្អិននោះ ប្រៀបដូចជាផ្កាម្លិះក្រពំ ។ មិនចាំបាច់ធ្វើសម្ល ឬបន្លែជាមួយបាយសាលីនោះ ។ ប្រាថ្នាបរិភោគរសណា ៗ ក៏មានរសនោះ ៗ ឲ្យបរិភោគ ។ កាលសត្វទាំងនោះ បរិភោគអាហារគ្រោតគ្រាតតាំងអំពីនោះមក មូត្រ និងករីសៈក៏កើតឡើង ។

លុះសត្វទាំងនោះ ត្រូវការឲ្យមូត្រ និងករីសៈចេញ ក៏បែកចេញជាមុខដំបៅ ។ សភាពជាបុរស ក៏ប្រាកដដល់បុរស ។ សភាពជាស្ត្រី ក៏ប្រាកដដល់ស្ត្រី ។ ក្នុងគ្រានោះឯង ស្ត្រីក៏សម្លឹងមើលបុរស និងបុរសក៏សម្លឹងមើលស្ត្រី មិនមានវេលា ។ ព្រោះសត្វទាំងនោះសម្លឹងមើលគ្នាគ្មានពេលវេលាជាបច្ច័យ ទើបកើតសេចក្តីក្រហល់ក្រហាយព្រោះកាម ។ តអំពីនោះ ក៏សេពមេថុននឹងគ្នា ។ សត្វទាំងនោះ ត្រូវវិញ្ញូជនតិះដៀលធ្វើឲ្យលំបាក ព្រោះការសេពអសទ្ធម្ម ទើបសាងសង់ផ្ទះដើម្បីបិទបាំងអសទ្ធម្មនោះ ។ សត្វទាំងនោះ កាលគ្រប់គ្រងផ្ទះ ក៏ប្រព្រឹត្តទៅតាម

ទិដ្ឋានុគតិរបស់បុគ្គលមិនខ្ជិលច្រអូសណាមួយតាមលំដាប់ ហើយធ្វើការសន្សំទុក ។

ចាប់តាំងអំពីនោះ កន្ទក់ខ្លះ សំបកខ្លះ ក៏កើតមានដល់ស្រូវសារ ។ សូម្បីទីច្រូតកាត់ហើយ ក៏មិនដុះវិញ ។ សត្វទាំងនោះប្រជុំគ្នាសម្រេចចិត្តថា អ្នកដ៏ចម្រើនទាំងឡាយ ធម៌លាមកប្រាកដហើយក្នុងសត្វទាំងឡាយ ព្រោះពួកយើង កាលអំពីមុនសម្រេចអ្វីស្រេចតែចិត្ត ដូច្នេះ ។ គប្បីឲ្យពិស្តារដោយន័យដូចពោលហើយក្នុងអគ្គញ្ញសូត្រ ។ តាំងតែអំពីនោះមក សត្វទាំងឡាយ ក៏បានតែងតាំងរបៀបបដិបត្តិទុកឡើង ដូចតទៅនេះ ។

ប្រសិនបើអ្នកណាមួយ កាន់យកចំណែកអ្នកដទៃដែលគេមិនបានឲ្យ ។ ពោលថាតីរដង ក្នុងលើកទីបី ត្រូវប្រហារដោយដៃ ដុំដី និងដំបង ។ សត្វទាំងនោះ កាលបើកើតមានការលួចទ្រព្យ និយាយតិះដៀល និយាយកុហក ក៏ដាក់ទណ្ឌកម្មរាងកាយឡើង ទើបប្រជុំគ្នាគិតថា ព្រោះហេតុអ្វីពួកយើងគប្បីលើកសរសើរសត្វមួយនេះ យើងនឹងបន្ថែមចំណែកនៃស្រូវសាលិឲ្យដល់អ្នកដែលគប្បីគ្របសង្កត់ អ្នកដែលគួរគ្របសង្កត់ គប្បីតិះ-



ដៀលអ្នកដែលគួរតិះដៀល គប្បីបណ្តេញចេញដល់អ្នកដែលគួរបណ្តេញចេញ ដោយត្រឹមត្រូវរបស់ពួកយើង ។

ក៏កាលសត្វទាំងឡាយ ធ្វើសេចក្តីព្រមព្រៀងគ្នាយ៉ាងនេះហើយក្នុងកប្បនេះ ព្រះមានព្រះភាគ កាលនៅជាព្រះពោធិសត្វមានរូបរាងដ៏ស្អាត គួរក្រឡេកមើល មានសក្តិ៍ធំ សត្វទាំងនោះក្នុងសម័យនោះ សម្បូរណ៍ដោយបញ្ញា មានកម្លាំង អាចធ្វើការគ្របសង្កត់ និងលើកសរសើរបាន ។ សត្វទាំងនោះ ទើបនាំគ្នាចូលទៅរកព្រះពោធិសត្វនោះ លើកសរសើរ អង្វរក ។ ព្រះពោធិសត្វនោះ ប្រាកដដោយនាម ៣ គឺ ឈ្មោះថា **មហាសម្មតិ** ព្រោះមហាជនសន្មត់ ១ ។ ឈ្មោះថា **ខត្តិយ** ព្រោះជាអធិបតីនៃខេត្តទាំងឡាយ ១ ។ ឈ្មោះថា **រាជា** ព្រោះឲ្យសត្វទាំងឡាយដទៃត្រេកអរដោយធម៌ស្មើ ១ ។ ព្រះពោធិសត្វជាបុរសដំបូងក្នុងឋានៈជាអច្ឆរិយបុរសក្នុងលោក ។ កាលធ្វើព្រះពោធិសត្វឲ្យជាអាទិ៍បុរស តាំងនៅក្នុងខត្តិយមណ្ឌលហើយ វណ្ណៈទាំងឡាយមានវណ្ណៈព្រាហ្មណ៍ជាដើម ក៏តាំងឡើងតាមលំដាប់ ។

ការឆេះដោយភ្លើង តាំងពីមហាមេឃញុំាងកប្បឲ្យវិនាស

អសង្ខេយ្យមួយនេះ លោកហៅថា **សំវដ្ដ** ។

មហាមេឃដ៏ធំ ញុំាងសែនកោដិចក្រវាឡឲ្យពេញប្រៀប តាំងពីការវិនាស ព្រោះឆេះដោយភ្លើង អសង្ខេយ្យទីពីរនេះ លោកហៅថា **សំវដ្ដដ្ឋាយី** ។

ការប្រាកដនៃព្រះច័ន្ទ ព្រះអាទិត្យ តាំងពីមហាមេឃសម្បូរណ៍ អសង្ខេយ្យទីបីនេះ លោកហៅថា **វិវដ្ដ** ។

មហាមេឃញុំាងកប្បឲ្យវិនាសទៀត តាំងពីសេចក្ដីប្រាកដនៃព្រះច័ន្ទ ព្រះអាទិត្យ អសង្ខេយ្យទីបួននេះ លោកហៅថា **វិវដ្ដដ្ឋាយី** ។

អសង្ខេយ្យ ៤ ទាំងនេះ ជាមហាកប្បមួយ ។ គប្បីជ្រាបសេចក្ដីវិនាសដោយភ្លើង និងការតាំងនៅ ដោយប្រការដូច្នេះ ។

ក៏សម័យណា កប្បវិនាសទៅដោយទឹក មហាមេឃញុំាងកប្បឲ្យវិនាស តាំងអំពីផ្ដើមឡើង គប្បីធ្វើឲ្យពិស្ដារដោយន័យដូចពោលហើយ ក្នុងខាងក្រោយនោះឯង ។ តែសេចក្ដីប្លែកគ្នាមានដូចតទៅនេះ ។ មហាមេឃមានទឹកក្រុត ញុំាងកប្បឲ្យវិនាស តាំងឡើងក្នុងទីនេះ ។ ដូចជាព្រះអាទិត្យដួងទីពីរតាំងឡើងក្នុង



អាកាសនោះ ដូច្នោះ ។

មហាមេឃនោះ កាលបើញុំាងភ្លៀងដែលមានគ្រាប់ល្អិតឲ្យធ្លាក់ចុះ រមែងធ្លាក់ចុះពេញសែនកោដិចក្រវាឡ ដោយតំណក់គ្រាប់ភ្លៀងធំ ៗ តាមលំដាប់ផែនដី និងភ្នំជាដើម ត្រូវទឹកក្រុតពាល់ត្រូវហើយ រមែងរលាយ ត្រូវទឹកក្រុតបន្សាត់នាំទៅដោយជុំវិញ ទឹកជន់ឡើងតាំងពីផែនដីរហូតដល់ទុតិយជ្ឈានភូមិ ទឹកនោះ ញុំាងព្រហ្មលោកសូម្បីទាំង ៣ ឲ្យរលាយទៅក្នុងទីនោះរហូតដល់សុភកណ្ហាទើបឈប់ ។ ទឹកនោះនៅមិនទាន់ស្ងប់ ដរាបណាសង្ខារសូម្បីប៉ុនអណូនៅមាន ។

ក៏ឯទឹកនោះ គ្របសង្កត់សង្ខារទាំងពួងដែលទៅតាមទឹកនោះហើយ ក៏ស្ងប់រំងាប់ភ្លាម អាកាសខាងលើងងឹតសូន្យសុងតែម្យ៉ាង មួយអន្លើដោយអាកាសខាងក្រោម ។ បទទាំងពួងស្រដៀងនឹងការបានពោលហើយ តែក្នុងទីនេះលោកធ្វើ ( ការសាង ) អាភស្សរព្រហ្មលោកទាំងអស់ ឲ្យប្រាកដជាខាងដើម ។ សត្វទាំងឡាយឃ្លាតចាកសុភកិណ្ហាហើយ រមែងកើតក្នុងអាកស្សរព្រហ្មជាដើម ។ ការវិនាសដោយទឹកក្រុត ដែលញុំាងកប្ប

ឲ្យវិនាស តាំងអំពីមហាមេឃញ៉ាំងកប្បឲ្យវិនាស នេះជាអសង្ខេយ្យមួយ មហាមេឃសម្បូរណ៍ តាំងពីការវិនាសដោយទឹក នេះជាអសង្ខេយ្យ ទីពីរ ។ល។ អសង្ខេយ្យ ៤ ទាំងនេះ ជាមហាកប្បមួយ ។ គប្បីជ្រាបសេចក្ដីវិនាសដោយទឹក និងការតាំងនៅដោយ ប្រការដូច្នេះ ។

មួយវិញទៀត សម័យណាកប្បវិនាសដោយខ្យល់នោះ ។ មហាមេឃញ៉ាំងកប្បឲ្យវិនាសទៅ តាំងអំពីការផ្ដើមឡើងហើយគប្បីធ្វើឲ្យពិស្ដារ តាមន័យដូចពោលហើយអំពីមុននោះឯង ។

តែសេចក្ដីផ្សេងគ្នាមានដូចតទៅនេះ ។ ខ្យល់តាំងឡើងដើម្បីញ៉ាំងកប្បឲ្យវិនាសក្នុងលោកនេះ ដូចព្រះអាទិត្យដួងទីពីរក្នុងអាកាសនោះ ដូច្នោះ ។ ខ្យល់នោះ ញ៉ាំងធុលីគ្រោតគ្រាតឲ្យតាំងឡើងមុន ។ តពីនោះញ៉ាំងធុលីល្អិត ខ្សាច់ល្អិត ខ្សាច់គ្រោតគ្រាត ដុំគ្រួស និងថ្មជាដើម ឲ្យតាំងឡើងលើផែនដីប្រមាណប៉ុនផ្ទះកំពូល និងទីដើមឈើធំ ៗ ដែលតាំងឡើងក្នុងទីមិនស្មើ ។ ធុលីទាំងនោះ មិនធ្លាក់ចាកផែនដី ព្រោះលិចចុះនៅក្នុងផ្ទៃមេឃ ។ ធុលីទាំងនោះហ្មត់ល្អិតទៅក្នុងទីនោះ រហូត



ដល់មិនមាន ។

គ្រានោះឯង ខ្យល់តាំងឡើងពីទីខាងក្រោមផែនដីដ៏ធំនេះតាមលំដាប់ ហើយបក់ត្រឡប់ផែនដី ធ្វើស្រទាប់ផែនដីឲ្យមកខាងលើ ហើយបន្សាត់ទៅក្នុងអាកាស ។ ផ្ទៃផែនដីមានប្រមាណ ១០០ យោជន៍ជាប្រមាណ បែកចេញទៅ មានប្រមាណ ២ យោជន៍ ៣ យោជន៍ ៤ យោជន៍ ៥ យោជន៍ ត្រូវកម្លាំងខ្យល់បក់ផាត់ទៅ ធ្វើឲ្យហ្មត់ល្អិតក្នុងអាកាសនោះឯង រហូតដល់មិនមានសល់ ។ ខ្យល់លើកភ្នំចក្រវាឡខ្លះ ភ្នំសិនេរុខ្លះឡើងហើយបន្សាត់ទៅក្នុងអាកាស ។ ផ្ទៃផែនដីទាំងនោះបះខ្ទប់គ្នានឹងគ្នា ហើយបែកទៅជាផង់ធុលីល្អិត ៗ វិនាសទៅ ។ ដោយឧបាយនេះឯង ខ្យល់ញ៉ាំងភុម្មដ្ឋកវិមាន និងអាកាសដ្ឋកវិមានឲ្យវិនាស ញ៉ាំងកាមាវចរទេវលោក ៦ ឲ្យវិនាស ហើយញ៉ាំងចក្រវាឡសែនកោដិ ឲ្យវិនាស ។

ចក្រវាឡប៉ះខ្ទប់នឹងចក្រវាឡ ។ ថ្មនៅខាងកើតប៉ះខ្ទប់នឹងថ្មខាងកើត ។ សិនេរុប៉ះខ្ទប់នឹងសិនេរុ ហើយក្លាយជាផង់ធុលីវិនាសទៅ ។ ខ្យល់បក់ផាត់តាំងពីផែនដីរហូតដល់តតិយ-

ជ្ឈានភូមិ ។ ខ្យល់ញុំាងព្រហ្មលោក ៣ ឲ្យវិនាស រហូតដល់វេហប្ផលាទើបឈប់ ។ លុះញុំាងសង្ខារទាំងពួង ឲ្យវិនាសទៅយ៉ាងនេះ សូម្បីខ្លួនឯងក៏វិនាសទៅផង ។ អាកាសចំណែកខាងលើ និងអាកាសចំណែកខាងក្រោមងងឹតសូន្យសុងដូចគ្នាទាំងអស់ ប្រហាក់ប្រហែលដូចដែលបាន ពោលហើយនោះឯង ។ តែក្នុងទីនេះលោកធ្វើ គឺ សាង សុភកិណ្ហព្រហ្មលោកជាខាងដើមឲ្យប្រាកដ ។

ក៏សត្វទាំងឡាយឃ្លាតចាកពីវេហប្ផលាហើយ រមែងកើតក្នុងសុភកិណ្ហព្រហ្មលោកជាដើម ។ ការវិនាសដោយខ្យល់ញុំាងកប្បឲ្យវិនាស តាំងអំពីមហាមេឃញុំាងកប្បឲ្យវិនាស នេះជាអសង្ខេយ្យមួយ ។ មហាមេឃសម្បូរណ៍ តាំងពីការវិនាសដោយខ្យល់ នេះជាអសង្ខេយ្យទី ២ ។ល។ អសង្ខេយ្យ ៤ ទាំងនេះ ជាមហាកប្បមួយ ។ គប្បីជ្រាបការវិនាសដោយខ្យល់ និងការតាំងនៅ ដោយប្រការដូច្នេះ ។

ព្រោះហេតុអ្វី លោកទើបវិនាសទៅយ៉ាងនេះ ។ ព្រោះអកុសលមូលជាហេតុ ។ ព្រោះកាលបើអកុសលមូលចម្រើន



ហើយ លោកទើបវិនាសទៅយ៉ាងនេះ ។ មួយវិញទៀត លោកនោះឯង កាលបើរាគៈចម្រើនជាលំដាប់ រមែងវិនាសទៅដោយភ្លើង ។ ប្រសិនបើទោសៈចម្រើនឡើង លោករមែងវិនាសទៅដោយទឹក ។

តែអាចារ្យពួកខ្លះពោលថា បើទោសៈចម្រើន លោកវិនាសទៅដោយភ្លើង ។ បើរាគៈចម្រើន ក៏វិនាសទៅដោយទឹក ។ ប្រសិនបើមោហៈចម្រើន នឹងវិនាសទៅដោយខ្យល់ ។ កាលបើវិនាសយ៉ាងនេះ រមែងវិនាសទៅដោយភ្លើង ៧ ដង ជាលំដាប់ ។ លើកទី ៨ វិនាសទៅដោយទឹក ។ ព្រោះហេតុនោះ ប្រសិនបើវិនាសទៅ ៨ ៗ ដង យ៉ាងនេះ ការវិនាសទៅដោយទឹក ៧ ដងវិនាសទៅដោយភ្លើង ៧ ដងទៀត ។ ដោយហេតុប្រមាណប៉ុណ្ណោះ ៦៣ កប្ប ជាការកន្លងទៅហើយ ។ ក្នុងចន្លោះនេះខ្យល់បានឱកាសហាមវារៈ ដែលវិនាសទៅដោយទឹក សូម្បីដល់ព្រមហើយ កម្ចាត់សុភកិណ្ហាព្រហ្មលោក ដែលមានអាយុ ៦៤ កប្ប បរិបូរណ៍ ញុំាងលោកឲ្យវិនាស ។

ភិក្ខុដែលរឭកដល់កប្ប សូម្បីរឭកដល់ជាតិមុន រមែងរឭក

ដល់សំវដ្ដកប្ប វិវដ្ដកប្ប សំវដ្ដវិវដ្ដកប្ប មិនតិចជាងកប្ប ទាំងនោះ ។

បទថា **សំវដ្ដកប្បេ វិវដ្ដកប្បេ** លោកពោលកំណត់ពាក់កណ្ដាលរបស់កប្បមួយ ។

បទថា **សំវដ្ដវិវដ្ដកប្បេ** លោកពោលកំណត់យកកប្ប ទាំងអស់ ។ ប្រសិនបើសួរថា រឭកដល់ដូចម្ដេច ? ឆ្លើយថា រឭកដល់ ដោយន័យមានជាអាទិ៍ថា **អមុត្រាសឹ** ក្នុងជាតិឯនោះ យើងបានកើតហើយ ។

ក្នុងបទទាំងនោះ បទថា **អមុត្រាសឹ** គឺ យើងបានកើតហើយក្នុងសំវដ្ដកប្បឯណោះ សេចក្ដីថា យើងបានកើតហើយ ក្នុងភព ក្នុងកំណើត ក្នុងគតិ ក្នុងវិញ្ញាណឋិតិ ក្នុងសត្តាវាស ឬក្នុងសត្តនិកាយ ។

បទថា **ឯវំនាមោ** មានឈ្មោះយ៉ាងនេះ គឺ តិស្ស ឬ បុស្ស ។ បទថា **ឯវំគោត្តោ** មានគោត្តយ៉ាងនេះ គឺ កច្ចានគោត្ត ឬកស្សបគោត្ត ។ បទនេះ លោកពោលដោយអំណាចការរឭកដល់ឈ្មោះ និងគោត្ររបស់ខ្លួន ក្នុងអតីតភពរបស់ភិក្ខុនោះ ។



ប្រសិនបើ ក្នុងកាលនោះ ភិក្ខុនោះ បំណងនឹងរឭកដល់-វណ្ណសម្បត្តិ ភាពប្រណីត និងសៅហ្មង ភាពជាអ្នកច្រើនដោយសុខ និងទុក្ខ ឬការមានអាយុតិច អាយុវែងរបស់ខ្លួន ។ ក៏រឭកបាន ។ ដោយហេតុនោះ ព្រះសារីបុត្តត្ថេរ ទើបពោលថា **ឯវំវណ្ណោ ។បេ។ ឯវមាយុបរិយន្តោ** ។

ក្នុងបទទាំងនោះ បទថា **ឯវំវណ្ណោ** មានពណ៌សម្បុរយ៉ាងនេះ គឺ សម្បុរស ឬសម្បុរខ្មៅ ។

បទថា **ឯវមាហារោ** មានអាហារយ៉ាងនេះ គឺ មានស្រូវសាលី បាយ សាច់ ជាអាហារ ឬមានផ្លែឈើទុំ ជាអាហារ ។

បទថា **ឯវំសុខទុក្ខប្បដិសំវេទី** បានសោយសុខ សោយទុក្ខយ៉ាងនេះ គឺ សោយសុខ និងទុក្ខ ដែលប្រព្រឹត្តទៅផ្លូវកាយ ផ្លូវចិត្ត ឬមានប្រភេទជាដើមថា មានអាមិស ឬមិនមានអាមិស ។

បទថា **ឯវមាយុបរិយន្តោ** មានអាយុកំណត់ត្រឹមប៉ុណ្ណេះ គឺ មានអាយុកំណត់ ១០០ ឆ្នាំ ឬ ៨ កោដិ ៤ សែនកប្ប ។

បទថា **សោ តតោ ចុតោ អមុត្រ ឧទបាទឹ** លុះចុតិអំពីភពនោះហើយ បានមកកើតក្នុងភពនេះ គឺ លុះយើងចុតិចាក

ភព កំណើត គតិ វិញ្ញាណឋិតិ សត្តាវាស ឬសត្តនិកាយនោះហើយ បានមកកើតក្នុងភព កំណើត គតិ វិញ្ញាណឋិតិ សត្តាវាស ឬសត្តនិកាយឯណោះ ។

បទថា **តត្រាបាសឹ** បានមានហើយក្នុងភពនោះ គឺ បានកើតទៀតហើយក្នុងភព កំណើត គតិ វិញ្ញាណឋិតិ សត្តាវាស ឬសត្តនិកាយសូម្បីនោះ ។ បទមានជាអាទិ៍ថា **ឯវំនាមោ** មានន័យដូចបានពោលហើយ ។

ម្យ៉ាងមួយទៀត ព្រោះបទថា **អមុត្រាសឹ** នេះ ជាការរឭកដល់របស់អ្នកប្រាថ្នាទៅតាមលំដាប់ ។

បទថា **សោ តតោ ចុតោ** ជាការពិចារណារបស់អ្នកត្រឡប់ ។ ដូច្នោះ បទថា **ឥធូប្បន្នោ** គប្បីជ្រាបថា លោកពោលបទនេះថា **អមុត្រឧទបាទឹ** សំដៅដល់ទីកើតរបស់ភិក្ខុនោះ ក្នុងលំដាប់នៃការកើតក្នុងលោកនេះ ។

បទមានជាអាទិ៍ថា **តត្រាបាសឹ** លោកពោលដើម្បីសម្ដែងការរឭកដល់ឈ្មោះ និងគោត្រជាដើម ក្នុងទីកើតក្នុងលំដាប់នៃការកើតនេះក្នុងភពនោះ របស់ភិក្ខុនោះ ។



បទថា **សោ តតោ ចុតោ ឥធូប្បន្នោ** លុះចុតិចាកភពនោះហើយ មកកើតក្នុងភពនេះ សេចក្ដីថា លុះយើងចុតិចាកទីដែលកើតក្នុងលំដាប់នោះហើយ ក៏មកកើតក្នុងត្រកូលក្សត្រិយ៍ ឬក្នុងត្រកូលព្រាហ្មណ៍ឯណោះ ក្នុងភពនេះ ។

បទថា **ឥតិ** គឺ ដោយប្រការដូច្នេះ ។

បទថា **សាការំ សឧទ្ទេសំ** ព្រមទាំងអាការ ព្រមទាំងឧទ្ទេស គឺ ព្រមទាំងឧទ្ទេស ដោយឈ្មោះ និងគោត្រ ។ ព្រមទាំងអាការ គឺ ពណ៌សម្បុរជាដើម ។ ព្រោះលោកសម្ដែងដល់សត្វ ដោយឈ្មោះ និងគោត្រថា **តិស្ស ផុស្ស កស្សប្បគោត្រ** ។ ប្រាកដដោយសេចក្ដីផ្សេងគ្នា ដោយពណ៌សម្បុរជាដើមថា សខ្មៅ ។ ព្រោះដូច្នោះ ឈ្មោះ និងគោត្រ ជាឧទ្ទេស ។ ក្រៅអំពីនោះ ជាអាការ ដោយប្រការដូច្នេះ ។

( ចប់ អដ្ឋកថាបុព្វេនិវាសានុស្សតិញ្ញាណនិទ្ទេស )

## អដ្ឋកថា ទិព្វចក្ខុញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងទិព្វចក្ខុញ្ញាណនិទ្ទេស ដូចតទៅនេះ ។

បទថា **អាលោកសញ្ញំ មនសិ ករោតិ** មនសិការអាលោកសញ្ញា គឺ មនសិការពន្លឺព្រះអាទិត្យ ព្រះច័ន្ទ និងកែវមណី ទាំងពេលថ្ងៃ ពេលយប់ថា **អាលោកោ** ពន្លឺ ។ ម្យ៉ាងទៀត កាលបើមនសិការយ៉ាងនេះ លោកពោលថា មនសិការអាលោកសញ្ញា ព្រោះញុំាងសញ្ញាឲ្យប្រព្រឹត្តទៅក្នុងចិត្តថា **អាលោកោ** ។

បទថា **ទិវាសញ្ញំ អធិដ្ឋាតិ** តាំងសញ្ញាថា ជាពេលថ្ងៃ គឺ មនសិការអាលោកសញ្ញាយ៉ាងនេះហើយ តាំងសញ្ញា ថាជាពេលថ្ងៃ ។

បទថា **យថា ទិវា តថា រត្តឹ** ពេលថ្ងៃយ៉ាងណា ពេលយប់ក៏ដូច្នោះ គឺ មនសិការសូម្បីពេលយប់ ដូចជាឃើញពន្លឺក្នុងពេលថ្ងៃ ដូច្នោះ ។

បទថា **យថា រត្តឹ តថា ទិវា** ពេលយប់យ៉ាងណា ពេលថ្ងៃក៏ដូច្នោះ គឺ មនសិការពេលថ្ងៃ ដូចឃើញពន្លឺក្នុងពេលយប់ដូច្នោះ ។



បទថា **ឥតិ វិវដេន ចេតសា** មានចិត្តបើកហើយ គឺ មានចិត្តមិនបានបិទបាំងយ៉ាងនេះ ។

បទថា **អបរិយោនទ្ធេន** មិនមានអ្វីរុំព័ទ្ធ គឺ មិនរុំព័ទ្ធដោយជុំវិញ ។

បទថា **សប្បភាសំ ចិត្តំ ភាវេតិ** គឺ ចម្រើនចិត្តឲ្យមានពន្លឺ ដោយបទនេះ លោកពោលដល់ចិត្តមានពន្លឺដោយការបរិកម្មជាអារម្មណ៍របស់ទិព្វចក្ខុ ។ ឬលោកពោលសំដៅដល់ចតុត្ថជ្ឈាន មានអាលោកកសិណជាអារម្មណ៍ ។ បើភិក្ខុនោះចម្រើនយ៉ាងនេះ ចិត្តមានពន្លឺប្រាសចាកសេចក្ដីងងឹតដែលបិទបាំង ។ កុលបុត្រដែលជាអាទិកម្មិកៈ ប្រាថ្នាដើម្បីញុំាងទិព្វចក្ខុឲ្យកើត ធ្វើអភិញ្ញាមានឈានជាបាទ មានកសិណជាអារម្មណ៍ ដោយទំនងដូចគ្នានឹងព្រះបាលីនោះឯង ឲ្យជាការគួរដល់អភិនិហារ ដោយអាការទាំងពួង ។ ហើយគប្បីធ្វើកសិណយ៉ាងណាមួយ ក្នុងកសិណ ៣ យ៉ាងទាំងនេះ គឺ តេជោកសិណ ១ ឱទាតកសិណ ១ អាលោកកសិណ ១ ឲ្យជិតទុក ។ គប្បីធ្វើឧបចារឈាន ឲ្យជាអារម្មណ៍ ហើយឲ្យកំណត់ចម្រើនទុក ។

អធិប្បាយថា មិនគួរឲ្យអប្បនាកើតក្នុងឧបចារឈាននោះ ។ ព្រោះប្រសិនបើថា ឲ្យអប្បនាកើត រមែងជានិស្ស័យនៃឈានជាបាទ មិនមែនជានិស្ស័យនៃបរិកម្ម ។

ក្នុងកសិណ ៣ យ៉ាងទាំងនេះ អាលោកកសិណនោះប្រសើរជាង ។ លោកពោលកសិណ ២ យ៉ាងក្រៅអំពីនោះ ដោយអនុលោមអាលោកកសិណនោះឯង ។ ព្រោះដូច្នោះ គួរធ្វើអាលោកកសិណឲ្យជាអារម្មណ៍ណាមួយ នៃកសិណក្រៅពីនោះ ហើយញ៉ាំងឈាន ៤ ឲ្យកើត តាំងនៅក្នុងឧបចារភូមិទៀត ទើបចម្រើនកសិណ ។ គប្បីឃើញរូបខាងក្នុងរបស់ទីដែលត្រូវចម្រើនហើយ ។ កាលភិក្ខុនោះឃើញរូប មិនធ្វើការផ្សាយទៅនៃពន្លឺដោយចិត្តបរិកម្ម ឲ្យទូលំទូលាយនោះ វារៈនៃបរិកម្មរមែងកន្លងហួសទៅ ។ ឯពន្លឺនោះ ក៏វិនាសទៅដែរ ។ បើពន្លឺវិនាសហើយ សូម្បីរូបក៏មិនប្រាកដ ។

កាលបើដូច្នោះ ភិក្ខុនោះគួរចូលឈានជាបាទរឿយ ៗ លុះចេញចាកឈាននោះ គប្បីផ្សាយពន្លឺទៅតាមលំដាប់យ៉ាងនេះ ពន្លឺរមែងមានកម្លាំងច្រើន ដោយប្រការដូច្នេះ ។ ពន្លឺនឹងតាំង



នៅក្នុងឋានៈដែលកំណត់ទុកថា ពន្លឺចូរមានក្នុងទីនេះ ដូច្នេះ ។ ការឃើញរូប រមែងមានដល់ភិក្ខុដែលអង្គុយមើលសូម្បីអស់នូវថ្ងៃ ។ កាលណារូបនេះ គឺ រូបដែលមិនទៅកាន់គន្លងនៃចក្ខុ រូបនៅក្នុងផ្ទៃ រូបអាស្រ័យហទយវត្ថុ រូបអាស្រ័យនៅក្រោមផែនដី រូបនៅខាងក្រៅជញ្ជាំងភ្នំ និងកំពែង រូបដែលនៅក្នុងចក្រវាឡដទៃ រមែងមកកាន់គន្លងនៃញាណចក្ខុរបស់ភិក្ខុនោះ ដូចឃើញរូបដោយមំសចក្ខុ ។ កាលនោះ ទិព្វចក្ខុរមែងកើតឡើង ។ ទិព្វចក្ខុនោះ អាចឃើញរូបក្នុងទីនេះបាន ។ មិនមែនចិត្តដែលជាចំណែកខាងដើម ។

ក្នុងបទមានអធិប្បាយដូចតទៅនេះ លំដាប់ការកើតរបស់ទិព្វចក្ខុ ធ្វើរូបមានប្រការដូចពោលហើយឲ្យជាអារម្មណ៍ កើតក្នុងមនោទ្វារាវជ្ជនៈ កាលមនោទ្វារាវជ្ជនៈរលត់ ធ្វើរូបនោះឯងឲ្យជាអារម្មណ៍ គប្បីជ្រាបតាមន័យដូចពោលហើយថា ជវនចិត្ត ៤ ឬ ៥ ខណៈ រមែងកើតឡើង ។

មយ៉ាងទៀត ញាណនេះលោកពោលថា **ចុតូបបាតញ្ញាណ** របស់សត្វទាំងឡាយខ្លះ ទិព្វចក្ខុញ្ញាណខ្លះ ។ ញាណនោះមាន

អន្តរាយដល់បុថុជ្ជន ។ ព្រោះបុថុជ្ជននោះ អធិដ្ឋានថា ពន្លឺចូរមានគ្រប់ទីកន្លែង ។ ញាណនោះ ៗ ក៏ទម្លុះទៅក្នុងផែនដី ក្នុំសមុទ្រ ពន្លឺក៏កើតមានដូចគ្នា ។ បើដូច្នោះ ភិក្ខុនោះឃើញរូបមានយក្ស រាក្ស័កជាដើម ដែលគួរខ្លាចក្នុងទីនោះ ក៏កើតសេចក្តីភ័យខ្លាចឡើង ។ ព្រោះដូច្នោះ មិនគួរប្រមាទក្នុងការឃើញរូបឡើយ ។

បទថា **សត្តានំ ចុតូបបាតញ្ញាយ** គឺ ដើម្បីញាណក្នុងចុតិ និងឧប្បត្តិរបស់សត្វទាំងឡាយ សេចក្តីថា ដើម្បីញាណដែលដឹងចុតិ និងឧប្បត្តិរបស់សត្វទាំងឡាយ ។ អធិប្បាយថា ដើម្បីទិព្វចក្ខុញ្ញាណ ។

បទថា **ទិព្វេន ចក្ខុនា** នេះ មានសេចក្តីដូចពោលហើយ ។

បទថា **វិសុទ្ធេន** បរិសុទ្ធិ៍ ឈ្មោះថា បរិសុទ្ធិ៍ ព្រោះហេតុឃើញបរិសុទ្ធិ៍ ដោយការឃើញចុតិ និងឧប្បត្តិ ។ ពិតណាស់ អ្នកណាឃើញត្រឹមតែចុតិប៉ុណ្ណោះ មិនឃើញឧប្បត្តិ អ្នកនោះរមែងប្រកាន់ដោយឧច្ឆេទទិដ្ឋិ អ្នកណាឃើញឧប្បត្តិ ប៉ុណ្ណោះមិនឃើញចុតិ អ្នកនោះរមែងប្រកាន់ដោយទិដ្ឋិ គឺ ការប្រាកដនៃសត្វ



ថ្មី ។

ចំណែកអ្នកណាឃើញទាំងពីរយ៉ាងនោះ ។ អ្នកនោះរមែងលះបង់ទិដ្ឋិ សូម្បីទាំងពីរបាន ។ ព្រោះដូច្នោះ ការឃើញរបស់អ្នកនោះ ឈ្មោះថា ជាហេតុនៃការឃើញបរិសុទ្ធិ៍ ។ ពុទ្ធបុត្តទាំងឡាយ រមែងឃើញទាំងពីរយ៉ាងនោះ ។ ដោយហេតុនេះលោកទើបពោលថា ឈ្មោះថា **វិសុទ្ធំ** ព្រោះហេតុនៃការឃើញបរិសុទ្ធិ៍ដោយការឃើញចុតិ និងឧប្បត្តិ ។ ឈ្មោះថា **អតិក្កន្ត-មានុសកំ** ។ ព្រោះឃើញរូបកន្លងឧបចារៈរបស់មនុស្ស ។ ឈ្មោះថា **អតិក្កន្តមានុសកំ** ព្រោះកន្លងមំសចក្ខុរបស់មនុស្ស ដោយចក្ខុជាទិព្វ បរិសុទ្ធិ៍កន្លងចក្ខុរបស់មនុស្ស ។

បទថា **សត្តេ បស្សតិ** ឃើញសត្វទាំងឡាយ គឺ សម្លឹងមើលសត្វទាំងឡាយ ដូចមើលដោយមំសចក្ខុរបស់មនុស្ស ។

ក្នុងបទនេះថា **ចវមានេ ឧបបជ្ជមានេ** មានអធិប្បាយ ថា មិនអាចឃើញដោយទិព្វចក្ខុក្នុងខណៈចុតិ ឬក្នុងខណៈឧប្បត្តិ ។ ម្យ៉ាងទៀត សត្វពួកឯណាជិតចុតិ នឹងឃ្លាតចាកក្នុងពេលនេះ ដូច្នោះ សត្វពួកនោះ ឈ្មោះថា កំពុងចុតិ ។ ចំណែកសត្វពួក

ណាបដិសន្ធិហើយ ឬកើតហើយនេះ សត្វពួកនោះ លោកបំណង ថាកំពុងឧប្បត្តិ ។ លោកសម្តែងថា រមែងឃើញសត្វពួកនោះ គឺ ឃើញកំពុងចុតិ និងកំពុងឧប្បត្តិ ។

បទថា **ហីនេ** ថោកទាប គឺ គួរខ្ពើម គួរនឿយណាយ គួរតិះដៀល គួរមើលងាយ ដោយអំណាចនៃជាតិ ត្រកូល និង ភោគៈជាដើម ដែលថោកទាប ព្រោះប្រកបដោយផលរបស់ មោហៈ ។

បទថា **បណីតេ** ប្រណីត គឺ ផ្ទុយគ្នានឹងថោកទាប ព្រោះ ប្រកបដោយផលរបស់អមោហៈ ។

បទថា **សុវណ្ណេ** មានពណ៌សម្បុរល្អ គឺ មានពណ៌សម្បុរ គួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត ព្រោះប្រកបដោយផល របស់អទោសៈ ។

បទថា **ទុព្វណ្ណេ** មានពណ៌សម្បុរអាក្រក់ គឺ មានពណ៌ សម្បុរមិនគួរប្រាថ្នា មិនគួរស្រឡាញ់ មិនគួរពេញចិត្ត ព្រោះ ប្រកបដោយផលរបស់ទោសៈ ។ អធិប្បាយថា មិនស្អាត មាន រូបខុសប្រក្រតី ។



បទថា **សុគតេ** បានល្អ គឺ ទៅដោយល្អ ឬមាំមួន មាន ទ្រព្យច្រើន ព្រោះប្រកបដោយផលរបស់អលោភៈ ។

បទថា **ទុគ្គតេ** លំបាក គឺ ដល់នូវសេចក្តីលំបាក ឬលំបាក រហូតមានបាយទឹកតិច ព្រោះប្រកបដោយផលនៃលោភៈ ។

បទថា **យថាកម្មូបគេ** ប្រព្រឹត្តទៅតាមកម្ម គឺ ប្រព្រឹត្តទៅ តាមកម្មដែលសន្សំទុក ។ លោកពោលដល់កិច្ចរបស់ទិព្វចក្ខុ ដោយមានជាអាទិ៍ថា **ចវមានេ** បទមុន ។ តែដោយបទនេះ លោក ពោលដល់មុខនាទីរបស់យថាកម្មូបគញ្ញាណ ញាណកំណត់ដឹងថា សត្វប្រព្រឹត្តទៅតាមកម្ម ។

មួយវិញទៀត លំដាប់នៃការកើតរបស់ឈាននោះ មានដូច្នេះ ភិក្ខុក្នុងសាសនានេះ ចម្រើនអាលោកកសិណ បំណងទៅកាន់ នរកខាងក្រោម រមែងឃើញសត្វនរកទាំងឡាយ សោយទុក្ខ យ៉ាងក្រៃលែង ។ ការឃើញនោះឯង ជាកិច្ចរបស់ទិព្វចក្ខុ ។ ភិក្ខុនោះ មនសិការយ៉ាងនេះថា សត្វទាំងនេះធ្វើកម្មអ្វីទុកហ្ន៎ ទើបត្រូវសោយទុក្ខនោះ ។ គ្រានោះឯង ញាណមានកម្មនោះ ៗ ជាអារម្មណ៍ កើតដល់ភិក្ខុនោះថា ព្រោះធ្វើកម្មនេះ ។

ម្យ៉ាងទៀត ភិក្ខុចម្រើនអាលោកកសិណ បំណងទៅកាន់ទេវលោកខាងលើ ឃើញសត្វទាំងឡាយសោយមហាសម្បត្តិក្នុងសួនននន្ទវ័ន មិស្សកវ័ន និងបារុសកវ័នជាដើម ។ ការឃើញនោះក៏ជាកិច្ចរបស់ទិព្វចក្ខុនោះឯង ។ ភិក្ខុនោះ មនសិការយ៉ាងនេះថា សត្វទាំងនេះធ្វើកម្មអ្វីទុកហ្ន៎ ទើបត្រូវសោយសម្បត្តិនេះ គ្រានោះឯង ញាណមានកម្មនោះជាអារម្មណ៍ កើតដល់ភិក្ខុនោះថា ព្រោះធ្វើកម្មនេះនេះ ឈ្មោះថា យថាកម្មូបគញ្ញាណ ។ ការបរិកម្មផ្សេងអំពីនេះ មិនមានដល់ភិក្ខុនេះ ។ សូម្បីអនាគតំសញ្ញាណ ក៏ដូចញាណនេះ ។ ពិតណាស់ ញាណទាំងនេះ មានទិព្វចក្ខុញ្ញាណជាបាទ រមែងសម្រេចព្រមជាមួយទិព្វចក្ខុនោះឯង ។

បទថា **ឥមេ** ក្នុងបទមានជាអាទិ៍ថា **ឥមេ វត ភោតោ** ជាបទអធិប្បាយសេចក្តីរបស់អ្នកឃើញដោយទិព្វចក្ខុ ។

បទថា **វត** ជានិបាតចុះក្នុងអត្ថនៃការរលឹកដល់ ។

បទថា **ភោន្តោ** គឺ អ្នកដ៏ចម្រើនទាំងឡាយ ។ ឈ្មោះថា ទុច្ចរិត ព្រោះប្រព្រឹត្តសេចក្តីអាក្រក់ ។ ឬប្រព្រឹត្តអាក្រក់ ព្រោះស្អុយដោយកិលេស ។ ឈ្មោះថា កាយទុច្ចរិត ព្រោះប្រព្រឹត្តអាក្រក់ផ្លូវកាយ ។ ឬការប្រព្រឹត្តអាក្រក់កើតឡើងតាមផ្លូវកាយ ។ សូម្បីក្នុងបទក្រៅពីនោះ ក៏មានន័យនេះដូចគ្នា ។



បទថា **សមន្នាគតា** ប្រកបហើយ គឺ មានការព្រមព្រៀងហើយ ។

បទថា **អរិយានំ ឧបវាទកា** តិះដៀលព្រះអរិយៈ គឺ ជាអ្នកប្រាថ្នាសេចក្តីវិនាសដល់ព្រះអរិយៈ ដល់ព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធជាម្ចាស់ និងព្រះសាវកដោយទីបំផុត សូម្បីដល់គ្រហស្ថដែលជាសោតាបន្ន តិះដៀលដោយអន្តិមវត្ថុ ឬដោយការកម្ចាត់គុណ ។ អធិប្បាយថា ជេរតិះដៀល ។ ពោលថាសមណធម៌មិនមានដល់លោកទាំងនេះ លោកទាំងនេះមិនមែនជាសមណៈ គប្បីជ្រាបថា ឈ្មោះថា តិះដៀលដោយអន្តិមវត្ថុ ។ ពោលពាក្យមានជាអាទិ៍ថា ឈាន វិមោក្ខ មគ្គ ឬផល មិនមានដល់លោកទាំងនេះ គប្បីជ្រាបថា ឈ្មោះថា តិះដៀលដោយការកម្ចាត់គុណ ។ ប៉ុន្តែអ្នកនោះដឹង ឬមិនដឹងគប្បីតិះដៀល ។ សូម្បីទាំងពីរយ៉ាង ឈ្មោះថា ជាការតិះដៀលព្រះអរិយជាម្ចាស់ ។ កម្មធ្ងន់ ហាមសួគ៌ និងហាមមគ្គ ដូចនឹងអនន្តរិយកម្ម

តែជាសតេកិច្ឆា គឺ ល្មមកែខែបាន ។ ព្រោះដូច្នោះ អ្នកណាតិះដៀលព្រះអរិយជាម្ចាស់ ប្រសិនបើព្រះអរិយៈជាបុគ្គលធំជាងខ្លួន គប្បីទៅរកព្រះអរិយៈនោះ អង្គុយច្រហោងសូមខមាទោសថា ខ្ញុំម្ចាស់បានពោលពាក្យនេះ ៗ នឹងលោក សូមលោកមេត្តាអត់ទោសឲ្យដល់ខ្ញុំម្ចាស់ផងចុះ ។

ប្រសិនបើព្រះអរិយៈទាបជាង គួរអង្គុយច្រហោង ផ្គងអញ្ជលី សូមឲ្យអត់ទោសថា លោកម្ចាស់សូមស្តាប់ពាក្យរបស់ខ្ញុំ ខ្ញុំបានពោលពាក្យនេះ ៗ នឹងលោក សូមលោកមេត្តាអត់ទោសដល់ខ្ញុំផងចុះ ។

បើព្រះអរិយៈចៀសចេញទៅកាន់ទិស ។ គួរទៅដោយខ្លួនឯង ឬបញ្ជូនសទ្ធិវិហារិកជាដើម ទៅសូមឲ្យលោកអត់ទោសឲ្យ ។

បើមិនអាចទៅបាន ឬមិនអាចបញ្ជូនទៅបាន គួរទៅរកភិក្ខុទាំងឡាយដែលនៅក្នុងវិហារនោះ ។

បើភិក្ខុទាំងឡាយទាបជាង គួរអង្គុយច្រហោង ។ ប្រសិនបើខ្ពស់ជាង គប្បីបដិបត្តិដោយន័យដូចពោលហើយ ក្នុងព្រះអរិយៈ



លោកជាអ្នកធំនោះឯង ហើយពោលថា សូមលោកម្ចាស់ទទួលពាក្យរបស់ខ្ញុំដែលបានពោលពាក្យនេះ ៗ នឹងលោកម្ចាស់ឈ្មោះឯណោះ ។ សូមលោកម្ចាស់ឯណោះ មេត្តាអត់ទោសឲ្យដល់ខ្ញុំម្ចាស់ផងចុះ ។ សូម្បីបើមិនសូមខមាទោសចំពោះមុខ ក៏គប្បីធ្វើយ៉ាងនោះឯង ។

បើភិក្ខុត្រាច់ទៅតែ ១ រូប ទីនោះមិនមែនជាទីនៅ របស់ភិក្ខុនោះ ។ ទីទៅក៏មិនប្រាកដ ។ គួរទៅរកភិក្ខុអ្នក ឆ្លាតមួយរូប ហើយពោលថា សូមលោកម្ចាស់ទទួលពាក្យខ្ញុំដែលបានពោលពាក្យនេះ ៗ នឹងលោកម្ចាស់ឈ្មោះឯណោះ ។ កាលបើខ្ញុំរលឹកដល់ពាក្យនោះ ក៏មានសេចក្តីក្តៅក្រហាយចិត្ត ខ្ញុំនឹងធ្វើយ៉ាងណាល្អ ។ ភិក្ខុអង្គនោះនឹងពោលថា កុំគិតច្រើនពេកលោកម្ចាស់ ។ ព្រះថេរៈអត់ទោសឲ្យលោកហើយ ចូរស្ងប់ចិត្តចុះ ។

សូម្បីដោយហេតុនោះ ក៏គប្បីផ្គងអញ្ជលីទៅកាន់ទិសដែលព្រះអរិយជាម្ចាស់ត្រាច់ទៅ ហើយពោលថា សូមមេត្តាប្រោសអត់ទោសដល់ខ្ញុំផងចុះ ។ ប្រសិនបើព្រះអរិយៈនោះ បរិនិព្វានហើយ ។ គប្បីទៅកាន់គ្រែដែលបរិនិព្វាន ហើយទៅកាន់ប៉ាឆា

សូមលោកឲ្យអត់ទោសឲ្យ ។ បើធ្វើយ៉ាងនេះ មិនហាមសួគ៌ , មិនហាមមគ្គ ។ ប្រព្រឹត្តទៅតាមប្រក្រតី ។

បទថា **មិច្ឆាទិដ្ឋិកា** បានដល់ មានការឃើញវិបរិត ។

បទថា **មិច្ឆាទិដ្ឋិកម្មសមាទានា** ប្រកាន់ការធ្វើដោយអំណាចមិច្ឆាទិដ្ឋិ គឺ អ្នកដែលដឹកនាំអ្នកដទៃក្នុងកាយកម្មជាដើម មានមិច្ឆាទិដ្ឋិជាមូល ឈ្មោះថា ជាការប្រកាន់កម្ម មានច្រើនយ៉ាង ដោយអំណាចនៃមិច្ឆាទិដ្ឋិ ។

មួយវិញទៀត ការពោលបទទាំងពីរនេះ ក្នុងការតិះដៀលព្រះអរិយៈ ដោយស័ព្ទថា **វចីទុច្ចរិត** និងក្នុងមិច្ឆាទិដ្ឋិ សូម្បីលោកសង្គ្រោះដោយស័ព្ទថា **មនោទុច្ចរិត** ដើម្បីសម្តែងដល់ការមានទោសច្រើន ។ ពិតណាស់ ការតិះដៀលព្រះអរិយជាម្ចាស់មានទោសច្រើន ព្រោះដូចគ្នានឹងអនន្តរិយកម្ម ។ សូម្បីព្រះមានព្រះភាគ ក៏បានត្រាស់ទុកថា :

ម្នាលសារីបុត្ត ប្រៀបដូចភិក្ខុដល់ព្រម
ដោយសីល សមាធិ បញ្ញា គប្បីញ៉ាំងអរហត្ត-
ផលឲ្យសម្រេចក្នុងបច្ចុប្បន្នតែម្យ៉ាង យ៉ាងណា



ម្នាលសារីបុត្ត តថាគតពោលការឧបមេយ្យនេះ
ក៏ដូច្នោះ ។ អ្នកនោះមិនលះវាចាចេញ មិនលះ
ការគិតនោះចេញ មិនលះបង់ទិដ្ឋិនោះចេញ ក៏
ទៀងពិតនឹងទៅកាន់នរក[១] ។

ម្យ៉ាងទៀត ទោសដទៃ មានទោសច្រើនជាងមិច្ឆាទិដ្ឋិមិនមាន ។ សមដូចព្រះមានព្រះភាគទ្រង់ត្រាស់ទុកថា :

ម្នាលភិក្ខុទាំងឡាយ តថាគតមិន
ឃើញធម៌ដទៃត្រឹមតែមួយ ដែលមានទោស
ច្រើនដូចមិច្ឆាទិដ្ឋិនេះឡើយ ។ ម្នាលភិក្ខុ
ទាំងឡាយ ទោសទាំងឡាយ មិច្ឆាទិដ្ឋិមាន
ទោសដ៏ក្រៃលែង[២] ។

បទថា **កាយស្ស ភេទា** ព្រោះកាយបែកធ្លាយ គឺ ព្រោះលះបង់ខន្ធដែលមានចិត្តគ្រប់គ្រង ។

---

១ មជ្ឈិមនិកាយ មូលបណ្ណាសកៈ , ២ អង្គុត្តរនិកាយ ឯកនិបាត

បទថា **បរម្មរណា** កាលស្លាប់ទៅ គឺ ក្នុងការកាន់យកខន្ធដែលកើតឡើងក្នុងលំដាប់នោះ ។

ម្យ៉ាងវិញទៀត បទថា **កាយស្ស ភេទា** គឺ ព្រោះដាច់ជីវិតិន្ទ្រិយ ។

បទថា **បរម្មរណា** គឺ មុនចុតិចិត្ត ។

បទទាំងឡាយមានជាអាទិ៍យ៉ាងនេះថា **អបាយំ** ជាវេវចនៈរបស់នរក ។ ឈ្មោះថា **និរិយ** ព្រោះប្រាសចាកសេចក្ដីចម្រើនដែលសន្មត់ថា ជាបុណ្យដែលជាហេតុនៃសួគ៌ និងនិព្វាន ។ ឈ្មោះថា **អបាយ** ព្រោះមិនមានសេចក្ដីសុខ ឬសេចក្ដីចម្រើន ។ ឈ្មោះថា **ទុគ្គតិ** ព្រោះជាផ្លូវ ជាទីអាស្រ័យរបស់ទុក្ខ ។

ម្យ៉ាងវិញទៀត គតិកើតដោយកម្មអាក្រក់ ព្រោះមានទោសច្រើន ឈ្មោះថា **ទុគ្គតិ** ។ ឈ្មោះថា **វិនិបាត** ព្រោះជាទីធ្លាក់ទៅកាន់ការអស់អំណាចរបស់បុគ្គលធ្វើអាក្រក់ ។

ម្យ៉ាងវិញទៀត ឈ្មោះថា **វិនិបាត** ព្រោះជាទីធ្លាក់ទៅកាន់កន្លែងវិនាស គឺ អវយវៈតូចធំបែកធ្លាយវិនាសទៅ ។

ឈ្មោះថា **និរយ** ព្រោះមិនមានសេចក្ដីចម្រើន ដែលបាន



ដឹងត ៗ មកថាជាការបន្ធិតបន្ធំ ។

ម្យ៉ាងវិញទៀត លោកសម្ដែងដល់កំណើតតិរច្ឆាន ដោយ **អបាយ** ស័ព្ទ ។ កំណើតតិរច្ឆាន ឈ្មោះថា **អបាយ** ព្រោះប្រាសចាកសុគតិ ។ ទុគ្គតិ មិនមែនអបាយ ព្រោះនាគរាជជាដើមដែលមានសក្ដិ៍ធំក៏កើត ។ លោកសម្ដែង បិត្តិវិស័យ គឺ ទីនៅរបស់ប្រេត ដោយ **ទុគ្គតិ** ស័ព្ទ ។

ពិតហើយ បិត្តិវិស័យ មានទាំងអបាយ និងទុគ្គតិ ព្រោះប្រាសចាកសុគតិ និងព្រោះជាផ្លូវទៅនៃទុក្ខ ។ ចំណែកវិនិបាត មិនមែនបិត្តិវិស័យ ព្រោះមិនធ្លាក់ទៅ ដូចជាអសុរ ។ លោកសម្ដែងអសុរកាយដោយ **វិនិបាត** ស័ព្ទ ។ ព្រោះអសុរកាយនោះមានទាំងអបាយ និងទុគ្គតិ ដោយអត្ថដូចពោលហើយ ។ លោកហៅថា **វិនិបាត** ព្រោះរាងកាយទាំងអស់ធ្លាក់ទៅ ។ លោកសម្ដែងដល់នរកប៉ុណ្ណោះ មានច្រើនប្រការ មានអវេចីជាដើម ដោយ **និរយ** ស័ព្ទ ។

បទថា **ឧបបន្នា** គឺ ចូលដល់ហើយ បានដល់ កើតហើយ ។ គប្បីជ្រាបធម៌ចំណែកខាងស ដោយផ្ទុយគ្នានឹងការដែលពោល

ហើយ ។

តទៅនេះជាសេចក្តីវិសេស ។ លោកសង្គ្រោះគតិរបស់មនុស្សដោយ **សុគតិ** ។ សង្គ្រោះគតិរបស់ទេវតាដោយ **សគ្គ** ស័ព្ទ ។

ក្នុងបទថា **សុគតឹ សគ្គំ លោកំ** នោះ មានសេចក្តីដូចតទៅនេះ ឈ្មោះថា **សុគតិ** ព្រោះទៅដោយល្អ ។ ឈ្មោះថា **សគ្គ** ព្រោះល្អប្រសើរដោយវិស័យ មានរូបជាដើម ។ សូម្បីទាំងអស់នោះឈ្មោះថា **លោក** ព្រោះអត្ថថា បែកធ្លាយ ។ នេះជាការអធិប្បាយពាក្យ ។ បទទាំងអស់ មានជាអាទិ៍ថា **ទិព្វេន ចក្ខុនា** ដោយទិព្វចក្ខុ ជាពាក្យសរុបដោយប្រការដូច្នេះ ។ សេចក្តីសង្ខេបក្នុងបទនេះ មានយ៉ាងនេះថា **ទិព្វេន ចក្ខុនា បស្សតិ** រមែងឃើញដោយចក្ខុទិព្វ ។

( ចប់អដ្ឋកថាទិព្វចក្ខុញ្ញាណនិទ្ទេស )



ក្នុងញាណ ៥ ទាំងនេះ **ឥទ្ធិវិធញ្ញាណ** រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ៧ ដោយអំណាចនៃបរិត្តារម្មណ៍ ១ , មហគ្គតារម្មណ៍ ១ , អតីតារម្មណ៍ ១ , អនាគតារម្មណ៍ ១ , បច្ចុប្បន្នារម្មណ៍ ១ , អជ្ឈត្តារម្មណ៍ ១ , ពហិទ្ធារម្មណ៍ ១ ។

**សោតធាតុវិសុទ្ធិញ្ញាណ** រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ៤ ដោយអំណាចនៃបរិត្តារម្មណ៍ ១ , បច្ចុប្បន្នារម្មណ៍ ១ , អជ្ឈត្តារម្មណ៍ ១ , ពហិទ្ធារម្មណ៍ ១ ។

**ចេតោបរិញ្ញាណ** រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ៨ ដោយអំណាចនៃបរិត្តារម្មណ៍ ១ , មហគ្គតារម្មណ៍ ១ , អប្បមាណារម្មណ៍ ១ , មគ្គារម្មណ៍ ១ , អតីតារម្មណ៍ ១ , អនាគតារម្មណ៍ ១ , បច្ចុប្បន្នារម្មណ៍ ១ , ពហិទ្ធារម្មណ៍ ១ ។

**បុព្វេនិវាសានុស្សតិញ្ញាណ** រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ៨ ដោយអំណាចនៃបរិត្តារម្មណ៍ ១ , មហគ្គតារម្មណ៍ ១ , អប្បមាណារម្មណ៍ ១ , មគ្គារម្មណ៍ ១ , អតីតារម្មណ៍ ១ , អជ្ឈត្តារម្មណ៍ ១ , ពហិទ្ធារម្មណ៍ ១ , នវត្តព្វារម្មណ៍ ១ ។

**ទិព្វចក្ខុញ្ញាណ** រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ៤ ដោយ

អំណាចនៃបរិត្តារម្មណ៍ ១ , បច្ចុប្បន្នារម្មណ៍ ១ , អជ្ឈត្តារម្មណ៍ ១ , ពហិទ្ធារម្មណ៍ ១ ។

**យថាកម្មូបគញ្ញាណ** រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ៥ ដោយអំណាចនៃបរិត្តារម្មណ៍ ១ , មហគ្គតារម្មណ៍ ១ , អតីតារម្មណ៍ ១ , អជ្ឈត្តារម្មណ៍ ១ , ពហិទ្ធារម្មណ៍ ១ ។

**អនាគតំសញ្ញាណ** រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ៨ ដោយអំណាចនៃបរិត្តារម្មណ៍ ១ , មហគ្គត្តារម្មណ៍ ១ , អប្បមាណារម្មណ៍ ១ , មគ្គារម្មណ៍ ១ , អនាគតារម្មណ៍ ១ , អជ្ឈត្តារម្មណ៍ ១ , ពហិទ្ធារម្មណ៍ ១ , នវត្តព្វារម្មណ៍ ១ ។

( ចប់ បញ្ចញាណបកិណ្ណកៈ )



# អដ្ឋកថា អាសវក្ខយញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ ក្នុងអាសវក្ខយញ្ញាណនិទ្ទេសដូចតទៅនេះ ។ បទមានជាដើមថា **អនញ្ញាតញ្ញស្សាមីតិន្ទ្រិយំ** មានអត្ថដូចបានពោលហើយ ។

បទថា **កតិ ឋានានិ គច្ឆតិ** រមែងដល់ឋានៈប៉ុន្មាន ជាពាក្យសួរ ដើម្បីកំណត់ឋានៈដែលកើតនៃឥន្ទ្រិយមួយ ៗ ។

បទថា **ឯកំ ឋានំ គច្ឆតិ** រមែងដល់ឋានៈ ១ លោកអធិប្បាយថា រមែងកើតក្នុងឋានៈ ១ ។ ឋានៈឱកាសដែលកើតលោកពោលថា **ឋានៈ** ព្រោះមានទីតាំង ។

បទថា **ឆ ឋានានិ** ឋានៈ៦ គឺ ក្នុងខណៈមគ្គ និងផល ៦ ។ ក្នុងឥន្ទ្រិយ ៣ មានអនញ្ញាតញ្ញស្សាមីតិន្ទ្រិយជាដើមនៃឥន្ទ្រិយទាំងឡាយដើម្បីសម្តែងថា ឥន្ទ្រិយមួយ ៗ ជាឥន្ទ្រិយដ៏ក្រៃលែង ។ លោកទើបពោលបទមានជាដើមថា **សទ្ធិន្ទ្រិយំ អធិមោក្ខបរិវារំ ហោតិ** មានសទ្ធិន្ទ្រិយ ដែលមានការបង្អោនចិត្តជឿជាបរិវារ ។ លោកពោលអធិមោក្ខជាដើម ដោយអំណាចកិច្ចនៃសទ្ធិន្ទ្រិយជា

ដើម ក្នុងបទមានជាអាទិ៍ថា **សទ្ធិន្ទ្រិយស្ស អធិមោក្ខដ្ឋោ** មាន អត្ថថា បង្អោនចិត្តជឿនៃសទ្ធិន្ទ្រិយ យ៉ាងណា , សូម្បីក្នុងទីនេះ ក៏ដូច្នោះ លោកពោលថា បទថា **អធិមោក្ខបរិវារំ ហោតិ** ជាបរិវារនៃការបង្អោនចិត្តជឿ គឺ សទ្ធិន្ទ្រិយជាបរិវារដោយកិច្ចនៃការបង្អោនចិត្តជឿ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះ ។

បទថា **បរិវារំ** ជាលិង្គវិបល្លាស ។

បទថា **បញ្ញិន្ទ្រិយំ** បញ្ញិន្ទ្រិយ លោកពោលអនញ្ញាតញ្ញស្សាមីតិន្ទ្រិយនោះឯង ធ្វើសេចក្តីផ្សេងគ្នាដើម្បីសម្តែងសភាពដឹង ។ សូម្បីក្នុងអភិធម៌ លោកក៏ចែកបញ្ញាមួយទុក ៨ ចំណែក ក្នុងខណៈមគ្គ និងក្នុងខណៈផល ដើម្បីសម្តែងសេចក្តីពិស្តារនៃកិច្ចរបស់បញ្ញា ។

បទថា **អភិសន្ទនបរិវារំ** មានសេចក្តីត្រេកអរជាបរិវារ គឺ សោមនស្សិន្ទ្រិយជាបរិវារនៃចិត្ត និងចេតសិក ដោយកិច្ច គឺការពេញចិត្ត ដូចទឹកជាបរិវារនៃម្ស៉ៅម៉ត់ជម្រះខ្លួនក្នុងវេលាមុជទឹក ។ បទនេះ លោកពោលដោយអំណាចមគ្គសម្បយុត្តដោយសោមនស្ស ។ គប្បីឃើញ ឧបេក្ខិន្ទ្រិយក្នុងឋានៈនៃសោមន-



ស្សិន្ទ្រិយក្នុងមគ្គសម្បយុត្តដោយឧបេក្ខា ។

ម្យ៉ាងទៀត គប្បីកាន់យកឧបេក្ខិន្ទ្រិយនោះថា មានការមិនផ្តើមឡើងជាបរិវារនៃសម្បយុត្តធម៌ទាំងឡាយ ។

បទថា **បវត្តសន្តតាធិបតេយ្យបរិវារំ** ជីវិតិន្ទ្រិយមានសភាពជាអធិបតីក្នុងការជាប់បន្ត ដែលកំពុងប្រព្រឹត្តទៅជាបរិវារ គឺ ការជាប់បន្ត ដែលកំពុងប្រព្រឹត្តទៅ ឈ្មោះថា **បវត្តសន្តតិ** ។ អធិប្បាយថា សន្តានដែលកំពុងប្រព្រឹត្តទៅ ។ ភាពជាអធិបតី ឈ្មោះថា **អធិតេយ្យ** ភាព ជាអធិបតីនៃការជាប់បន្តដែលកំពុងប្រព្រឹត្តទៅ ឈ្មោះថា **បវត្តសន្តតាធិបតេយ្យ** ។

ជីវិតិន្ទ្រិយ ជាបរិវារនៃអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ព្រោះជាបច្ច័យនៃការប្រព្រឹត្តទៅខាងលើនៃជីវិតិន្ទ្រិយ ដែលកំពុងប្រព្រឹត្តទៅ និងព្រោះភាពជាអធិបតីនៃការជាប់បន្ត ដែលប្រព្រឹត្តទៅដោយអំណាចនៃខាងដើម និងខាងចុង ។

បទមានជាដើមថា **សោតាបត្តិមគ្គក្ខណេ ជាតា ធម្មា** ធម៌ទាំងឡាយកើតក្នុងខណៈនៃសោតាបត្តិផល លោកពោលដើម្បីសម្តែងដល់គុណនៃធម៌សម្បយុត្តដោយមគ្គទាំងពួង ។

ក្នុងបទទាំងនោះ បទថា **មគ្គក្ខណេ ជាតា** ធម៌ទាំងឡាយកើតក្នុងខណៈនៃមគ្គ គឺ ធម៌ដែលតាំងនៅក្នុងមគ្គទាំងនោះ ។ មិនមែនធម៌ដទៃ ។ ព្រោះរូបសូម្បីតាំងនៅក្នុងខណៈមគ្គ ក៏មិនបានឈ្មោះថា កុសលជាដើម ។ ដូច្នោះកាលនាំរូបនោះចេញទៅ ទើបពោលថា **ឋបេត្វា ចិត្តសមុដ្ឋានំ រូបំ** ក្រៅអំពីរូបមានចិត្តជាសមុដ្ឋាន ។ ព្រោះថា ធម៌ទាំងឡាយទាំងពួងនោះ ជាកុសលដោយអត្ថថា មានការទម្លាយវត្តគួរខ្ពើមជាដើម ។ ធម៌ទាំងនោះធ្វើនិព្វានឲ្យជាអារម្មណ៍ហើយ ប្រព្រឹត្តទៅហើយ ។ ឈ្មោះថា **អនាសវា** ព្រោះមិនមានអាសវៈ ។

ធម៌ទាំងឡាយកាត់មូលនៃវដ្តៈ ធ្វើនិព្វានឲ្យជាអារម្មណ៍ ឈ្មោះថា **និយ្យានិកា** ព្រោះនាំចេញចាកវដ្តៈ ។

ធម៌ដែលពោល គឺ កុសល អកុសល ឈ្មោះថា **អបចយ-គាមិនោ** ព្រោះធ្វើនិព្វាន ពោលគឺ ការមិនសន្សំ ព្រោះការប្រាសចាកទៅ ឲ្យជាអារម្មណ៍ហើយប្រព្រឹត្តទៅ រមែងដល់ការមិនសន្សំ ។

ឈ្មោះថា **អបចយគាមិនោ** ព្រោះមិនសន្សំ គឺ កម្ចាត់វត្ត



ដែលប្រព្រឹត្តទៅខ្វះ ។

ឈ្មោះថា **និព្វានារម្មណា** ព្រោះមាននិព្វានជាអារម្មណ៍ ។

បទថាមានជាអាទិ៍ថា **ឥមានិ អដ្ឋិន្ទ្រិយានិ** មានឥន្ទ្រិយ ៨ លោកពោលដើម្បីសម្តែងភាពជាបរិវារ ដូចបានពោលហើយក្នុងកាលមុន ភាពជាធម៌មានអាទិ៍ សហគតដោយឥន្ទ្រិយនោះ និងអាការដូចបានពោលហើយក្នុងខាងដើម ។

ក្នុងបទទាំងនោះ បទថា **អដ្ឋិន្ទ្រិយានិ** គឺ ឥន្ទ្រិយ ៨ ព្រមដោយបញ្ញិន្ទ្រិយ មានន័យដូចពោលហើយក្នុងកាលមុន ។

បទថា **សហជាតបរិវារា** មានសហជាតជាបរិវារ គឺ ឥន្ទ្រិយ ៧ ក្រៅពីនោះ ព្រមដោយឥន្ទ្រិយមួយ ៗ ក្នុងឥន្ទ្រិយ ៨ ជាសហជាត ទើបឈ្មោះថា មានសហជាតនៃឥន្ទ្រិយនោះជាបរិវារ ។ម្យ៉ាងទៀត ធម៌ដទៃ ៗ ជា **អញ្ញមញ្ញបរិវារា** គឺ មានធម៌ដទៃ ៗ ជាបរិវារ ដោយប្រការដូច្នេះ ។ ធម៌ទាំងឡាយមានធម៌ដែលអាស្រ័យគ្នាជាបរិវារ មានធម៌ដែលប្រកបគ្នាជាបរិវារនៃគ្នា និងគ្នាយ៉ាងនោះដូចគ្នា ។

បទថា **សហគតា** គឺ ដល់ភាវៈមានកើតរួមគ្នាជាមួយនឹង

អនញ្ញាតញ្ញស្សាមីតិន្ទ្រិយនោះ ។

បទថា **សហជាតា** គឺ កើតព្រមគ្នាជាមួយអនញ្ញាតញ្ញស្សាមីតិន្ទ្រិយនោះ ។

បទថា **សំសដ្ឋា** គឺ ទាក់ទងគ្នាជាមួយអនញ្ញាតញ្ញស្សាមីតិន្ទ្រិយនោះ ។

បទថា **សម្បយុត្តា** គឺ ប្រកបដោយមានការកើតរួមគ្នា ស្មើគ្នាជាមួយអនញ្ញាតញ្ញស្សាមីតិន្ទ្រិយនោះ ។

បទថា **តេ** បានដល់ ធម៌ គឺ ឥន្ទ្រិយ ៨ ទាំងនោះឯង ។

បទថា **តស្ស** បានដល់ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ ។

បទថា **អាការា** គឺ ចំណែកដែលជាបរិវារ ។

បទថា **ផលក្ខណេ ជាតា ធម្មា សព្វេ អព្យាកតា ហោន្តិ** ធម៌ទាំងឡាយដែលកើតក្នុងខណៈនៃផលទាំងអស់ជាអព្យាកតៈ ។ គឺ លោកពោលព្រមជាមួយរូបដែលមានចិត្តជាសមុដ្ឋាន ព្រោះសូម្បីរូបក៏ជាអព្យាកត ។ លោកមិនពោលថា ជាកុសល ជានិយ្យានិកៈ និងជាអបចយគាមី ក្នុងខណៈនៃផល ព្រោះមគ្គជាកុសល ជានិយ្យានិកៈ និងជាអបចយគាមី ។ បទមានជាអាទិ៍ថា **ឥតិ**



ជាបទសរុប មាន ប្រការដូចពោលហើយ ។

ក្នុងបទទាំងនោះ បទថា **អដ្ឋដ្ឋកានិ** ឥន្ទ្រិយ ៨ ពួក គឺ ពួក ៨ នៃឥន្ទ្រិយមួយ ៗ ៨ ដោយអំណាចពួក ៨ ពួកមួយ ៗ ក្នុងមគ្គ និងផល ៨ ។

បទថា **ចតុសដ្ឋី ហោន្តិ** គឺ រួមជាអាការ ៦៤ ។

បទមានជាអាទិ៍ថា **អាសវា** មានសេចក្ដីដូចពោលហើយក្នុងខាងក្រោយនោះឯង ។

ក្នុងទីនេះគប្បីជ្រាបថា លោកមិនបានពោលដល់អាសវៈដែលលះដោយអរហត្តមគ្គប៉ុណ្ណោះទេ លោកពោលដល់ការលះដោយមគ្គ ៣ ពួកដ៏សេស ដោយត្រឹមតែជាពាក្យពោលធម្មតាដល់ការអស់អាសវៈ ។ ព្រោះលោកពោលដល់អរហត្តមគ្គញ្ញាណថា **ខយេ ញាណំ** ញាណក្នុងការអស់ទៅ ព្រោះអស់អាសវៈមិនមានអាសវៈអ្វី ៗ សល់ឡើយ ។ ដូច្នោះ លោកទើបពោលថា ព្រះអរហន្ត ខីណាស្រព ដោយប្រការដូច្នេះ ។

( ចប់ អដ្ឋកថាអាសវក្ខយញ្ញាណនិទ្ទេស )

## អដ្ឋកថា សច្ចញ្ញាណចតុក្កទ្វយនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ ក្នុងសច្ចញ្ញាណចតុក្កទ្វយនិទ្ទេសដូចតទៅនេះ ។ បទមានជាដើមថា **ទុក្ខស្ស បីឡនដ្ឋោ** សភាពបៀតបៀននៃទុក្ខ មានអត្ថដូចបានពោលទុកហើយ ។ បទមានជាអាទិ៍ថា **មគ្គសមង្គិស្ស ញាណំ ទុក្ខេបេតំ ញាណំ** ញាណនៃលោកអ្នកមានសេចក្តីព្រមព្រៀងដោយមគ្គ នេះជាទុក្ខញាណ លោកពោលដោយអំណាចការត្រាស់ដឹងតែម្យ៉ាង ដូចក្នុងពួក ៤ តាមលំដាប់ ។ ពិតណាស់ សច្ចញាណមាន ២ យ៉ាង គឺ លោកិយៈ ១ លោកុត្តរៈ ១ ។ លោកិយៈមាន ២ គឺ អនុពោធិញ្ញាណ ១ បច្ចវេក្ខណញ្ញាណ ១ ។

អនុពោធិញ្ញាណ រមែងប្រព្រឹត្តទៅក្នុងនិរោធ និងមគ្គ ដោយអំណាចការបានស្តាប់មកជាដើម នៃអាទិកម្មិកភិក្ខុ ។ រមែងប្រព្រឹត្តទៅក្នុងទុក្ខ និងសមុទយៈ ដោយអំណាចធ្វើឲ្យជាអារម្មណ៍ ។

បច្ចវេក្ខណញ្ញាណ រមែងប្រព្រឹត្តទៅក្នុងសច្ចៈ ៤ របស់



ភិក្ខុអ្នកចាក់ធ្លុះសច្ចៈហើយ ដោយអំណាចធ្វើឲ្យជាអារម្មណ៍ ។ បដិវេធញ្ញាណដែលជាលោកុត្តរៈធ្វើឲ្យជាអារម្មណ៍ រមែងចាក់ធ្លុះសច្ចៈ ៤ ដោយកិច្ច ។ ដូចព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកថា

> ម្នាលភិក្ខុទាំងឡាយ បុគ្គលណាឃើញទុក្ខ ។ បុគ្គលនោះ រមែងឃើញសូម្បីទុក្ខសមុទយ ។ រមែងឃើញសូម្បីទុក្ខនិរោធ ។ រមែងឃើញសូម្បីទុក្ខនិរោធគាមិនីបដិបទា ដូច្នេះ ។

គប្បីពោលដល់ទុក្ខទាំងអស់ ។ សូម្បីក្នុងនិទ្ទេសនេះ លោកក៏ពោលដល់ទុក្ខនេះឯង ដោយវារៈនេះ ។ ម្យ៉ាងទៀត សូម្បីលោកុត្តរៈនោះ លោកពោលដើម្បីសម្តែងថា លោកុត្តរៈរមែងបាននូវឈ្មោះទាំងឡាយមានជាអាទិ៍ថា **ទុក្ខេ ញាណំ** ការដឹងទុក្ខ ។ តែក្នុងទីនេះ លោកបំណងយកលោកិយញ្ញាណប៉ុណ្ណោះ ។ ព្រោះដូច្នោះ ព្រះសារីបុត្តត្ថេរទើបពោលថា **តត្ថ កតមំ ទុក្ខេ ញាណំ** ក្នុងញាណទាំងនោះ ទុក្ខញ្ញាាណតើដូចម្តេច ? ។

ក្នុងបទទាំងនោះ បទថា **ទុក្ខំ អារព្ភ** ប្រារព្ធទុក្ខ គឺ ការកំណត់ទុក្ខសច្ច , គឺធ្វើឲ្យជាអារម្មណ៍ ។

ក្នុងបទមានជាអាទិ៍ថា **បញ្ញា** គប្បីជ្រាបអធិប្បាយដូចតទៅនេះ , ឈ្មោះថា **បញ្ញា** ព្រោះអត្ថថា ឲ្យដឹង ពោលគឺធ្វើអត្ថនោះ ៗ ឲ្យប្រាកដ ។ ម្យ៉ាងវិញទៀត ឈ្មោះ **បញ្ញា** ព្រោះដឹងធម៌ទាំងឡាយដោយប្រការនោះ ៗ មានការមិនទៀងជាដើម ។ បទនេះ ជាសភាវបទរបស់បញ្ញានោះ ។ អាការដឹងច្បាស់ ឈ្មោះ **បជាននា** ។ ឈ្មោះថា **វិចយ** ព្រោះជ្រើសរើសដល់ការមិនទៀងជាដើម ។ បទថា **បវិចយ** ការស្រាវជ្រាវផ្តើមបទឧបសគ្គចុះទៅ បានដល់ ការជ្រើសរើសដោយទូទៅ ។ ឈ្មោះថា **ធម្មវិចយ** ព្រោះការយកចិត្តទុកដាក់ចតុសច្ចធម៌ ។ ឈ្មោះថា **សល្លក្ខណា** ការកំណត់ល្អ ដោយអំណាចការកំណត់ការមិនទៀងជាដើមដោយប្រពៃ ។ លោកពោលថា សល្លក្ខណៈនោះឯង គឺ **ឧបលក្ខណា** ការចូលទៅកំណត់ ។ **បច្ចុបលក្ខណា** ការចូលទៅកំណត់ចំពោះ ដោយផ្សេងគ្នាត្រង់ឧបសគ្គ ។ អធិប្បាយថា ការកំណត់យ៉ាងខ្ពស់ ឈ្មោះថា ការចូលទៅកំណត់អាស្រ័យធម៌ មានការមិនទៀងជាដើមទាំងនោះ ៗ ។ ភាពជាបណ្ឌិត ឈ្មោះថា **បណ្ឌិច្ចំ** ។ ភាពជាអ្នកឆ្លាត ឈ្មោះថា



**កោសល្លំ** ។ ភាពជាអ្នកម៉ត់ចត់ ឈ្មោះថា **នេបុញ្ញំ** ។ ឈ្មោះថា **វេភព្យា** គឺ ការជាក់ច្បាស់ ដោយអំណាចញ៉ាំងការមិនទៀងជាដើមឲ្យជាក់ច្បាស់ ។ ឈ្មោះថា **ចិន្តា** ការគិត ដោយអំណាចគិតដល់ការមិនទៀងជាដើម ។ ម្យ៉ាងទៀត ឈ្មោះថា **ចិន្តា** ព្រោះញ៉ាំងបុគ្គលដែលកើតការគិតឲ្យគិតដល់ការមិនទៀងជាដើម ។ ឈ្មោះថា **ឧបបរិក្ខា** ព្រោះពិចារណាដល់ការមិនទៀងជាដើម ។

បទថា **ភូរិ** គឺ ផែនដី , ឈ្មោះថា **ភូរិ** ព្រោះមានបញ្ញាដូចផែនដី ដោយអត្ថថា ម៉ត់ចត់ហើយដោយ អត្ថថា ធំទូលាយ ។ ម្យ៉ាងវិញទៀត បញ្ញានោះឯង លោកពោលថា **ភូរិ** ព្រោះអត្ថថា ត្រេកអរក្នុងអត្ថដែលពិត ។

ឈ្មោះថា **មេធា** ព្រោះអត្ថថា សម្លាប់ គឺ ទំលាយកិលេសដូចផ្លេកបន្ទោរ ទម្លាយវត្ថុដែលបង្ករដោយសិលា ដូច្នោះ ។

ម្យ៉ាងវិញទៀត ឈ្មោះ **មេធា** ព្រោះអត្ថថា កាន់យកនឹងទ្រទ្រង់ទុកបានរហ័ស ។

ឈ្មោះថា **បរិណាយិកា** ព្រោះអត្ថថា រមែងនាំញាណដែល

កើតនៅក្នុងសម្បយុត្តធម៌ និងបដិវេធធម៌ ដែលកំណត់តាមសេចក្តីពិត ក្នុងការបដិបត្តិដើម្បីប្រយោជន៍ដល់ខ្លួន ។

ឈ្មោះថា **វិបស្សនា** ព្រោះអត្ថថា ឃើញធម៌ច្រើនយ៉ាងដោយអំណាចការមិនទៀងជាដើម ។

ឈ្មោះថា **សម្បជាន** ព្រោះដឹងការមិនទៀងជាដើម ដោយប្រពៃ ។ ភាពនៃការដឹងព្រមនោះ ឈ្មោះថា **សម្បជញ្ញ** ។

ឈ្មោះថា **បតោទោ** បញ្ញាដូចជាជន្លួញ ព្រោះចាក់ដោតចិត្តកោងដែលស្ទុះទៅក្រៅផ្លូវ ដើម្បីឲ្យចូលផ្លូវ ដូចជន្លួញចាក់សេះដែលរត់ទៅក្រៅផ្លូវ ដើម្បីឲ្យឡើងថ្នល់ ដូច្នោះ ។

ឈ្មោះថា **ឥន្ទ្រិយ** គឺ ភាពជាធំ ព្រោះអត្ថថា ធ្វើភាពជាធំក្នុងលក្ខណៈឃើញ ។ ភាពជាធំ គឺ **បញ្ញា** ឈ្មោះថា **បញ្ញិន្ទ្រិយ** ។ លោកអធិប្បាយទុកយ៉ាងណា ។ លោកមិនពោលបទនេះថា ឥន្ទ្រិយជាបញ្ញា ឈ្មោះថា បញ្ញិន្ទ្រិយ ដូចបទមានជាអាទិ៍ថា **បុរិសស្ស ឥន្ទ្រិយំ បុរិសិន្ទ្រិយំ** ឥន្ទ្រិយរបស់បុរស ឈ្មោះថា បុរិសិន្ទ្រិយ ។ កាលដូច្នោះ លោកទើបពោលថា ឥន្ទ្រិយ គឺ បញ្ញានោះឯង ឈ្មោះថា **បញ្ញិន្ទ្រិយ** គឺ បញ្ញាជាធំ ។



ឈ្មោះថា **បញ្ញាពល** គឺ បញ្ញាជាកម្លាំង ព្រោះមិនញាប់ញ័រទៅដោយអវិជ្ជា ។

បញ្ញាដូចជាសស្ត្រា ព្រោះអត្ថថា កាត់កិលេស ទើបឈ្មោះថា **បញ្ញាដូចសស្ត្រា** ។

បញ្ញាដូចជាប្រាសាទ ព្រោះអត្ថថា ឡើងទៅខ្ពស់ ទើបឈ្មោះថា **បញ្ញាដូចប្រាសាទ** ។

បញ្ញាដូចជាពន្លឺ ព្រោះអត្ថថា ធ្វើឲ្យភ្លឺស្វាង ទើបឈ្មោះថា **បញ្ញាដូចពន្លឺ** ។

បញ្ញាជារស្មី ព្រោះអត្ថថា ធ្វើឲ្យភ្លឺ ទើបឈ្មោះថា **បញ្ញាជារស្មី** ។

បញ្ញារុងរឿង ព្រោះអត្ថថា ធ្វើឲ្យភ្លឺច្បាស់ ទើបឈ្មោះថា **បញ្ញារុងរឿង** ។

ពិតណាស់ លោកធាតុមួយម៉ឺន មានពន្លឺតែមួយ មានការភ្លឺស្វាងតែមួយ មានការរុងរឿងតែមួយ រមែងប្រាកដដល់អ្នកមានបញ្ញា អ្នកអង្គុយដោយបល្ល័ង្កតែមួយ ដោយហេតុនោះលោកទើបពោលបទ **បញ្ញា បជ្ជោតោ** នោះ ។

ម្យ៉ាងទៀត ក្នុង ៣ បទនេះ សូម្បីដោយបទមួយក៏សម្រេចសេចក្តីដូចគ្នា ដូចដែលព្រះមានព្រះភាគជាម្ចាស់ ទ្រង់សម្តែងព្រះសូត្រដោយអធ្យាស្រ័យនៃសត្វទាំងឡាយថា

**ម្នាលភិក្ខុទាំងឡាយ ពន្លឺមាន ៤ យ៉ាងគឺ ពន្លឺរបស់ព្រះច័ន្ទ ១ ពន្លឺរបស់ព្រះអាទិត្យ ១ ពន្លឺរបស់ភ្លើង ១ ពន្លឺរបស់បញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ពន្លឺ ៤ យ៉ាង ទាំងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ពន្លឺ ៤ ទាំងនេះ ពន្លឺនៃបញ្ញាប្រសើរជាងពន្លឺពួកដទៃ ។**

សូម្បីក្នុងនិទ្ទេសនេះ ព្រះថេរៈក៏សម្តែងដោយអនុរូបដល់ព្រះសូត្រនោះ ។ ព្រោះលោកចែកសេចក្តីដែលមានដោយអាការមិនតិច ។ ទាំងអ្នកដទៃរមែងដឹងដោយប្រការដទៃ ។

បញ្ញាដូចរតនៈ ព្រោះអត្ថថា ធ្វើសេចក្តីត្រេកអរ ឲ្យមានការត្រេកអរ ញុំាងការត្រេកអរឲ្យកើត ធ្វើឲ្យវិចិត្ររកបានលំបាកថ្លឹងមិនបាន ជារបស់ប្រើប្រាស់របស់សត្វយ៉ាងស្អាត ទើបឈ្មោះថា **បញ្ញារតនំ** បញ្ញាដូចរតនៈ ។

ឈ្មោះថា **អមោហោ** គឺ ការមិនវង្វេង ព្រោះសត្វទាំងឡាយ មិនឈ្ងក់វង្វេងទៅដោយហេតុនោះ ។ ឬមិនវង្វេងទៅក្នុងអារម្មណ៍ដោយខ្លួនឯង ។ បទថា **ធម្មវិចយ** មានអត្ថដូចពោលហើយ , ក៏ព្រោះហេតុណាលោកទើបពោលទៀត ។ ដើម្បីសម្តែងសេចក្តីដែលអមោហៈជាបដិបក្ខចំពោះមោហៈ ។ ដោយហេតុនោះលោកទើបសំដែងបទនេះទុកថា អមោហៈនោះ មិនមែនសត្រូវ ត្រឹមតែមោហៈម្យ៉ាងទេ ប៉ុន្តែជាបដិបក្ខចំពោះមោហៈក្នុងនិទ្ទេសនេះ លោកបំណងយកអមោហៈ ពោលគឺ ការពិចារណាធម៌ ។

បទថា **សម្មាទិដ្ឋិ** បានដល់ កុសលទិដ្ឋិដែលនាំសត្វចេញទៅបានយ៉ាងពិតប្រាកដ ។ លោកពោលពាក្យសួរទុក ដោយសង្ខេបថា ក្នុងញាណទាំងនោះ ទុក្ខសមុទយញាណ ទុក្ខនិរោធញាណ ទុក្ខនិរោធគាមិនីបដិបទាញាណ តើដូចម្តេច ដោយប្រការដូច្នេះ ។

( ចប់ អដ្ឋកថាសច្ចញ្ញាណចតុក្កទ្វយនិទ្ទេស )

# អដ្ឋកថា សុទ្ធិកបដិសម្ភិទាញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ ក្នុងសុទ្ធិកបដិសម្ភិទាញាណនិទ្ទេស ដូចតទៅនេះ ។ ព្រះសារីបុត្តត្ថេរមិនបានសម្តែងដល់ប្រភេទនៃញាណទាំងនេះ ដូចខាងក្រោយ ព្រោះញាណទាំងនេះមិនមានសេចក្តីផ្សេងគ្នា ទើបពោលបទមានជាអាទិ៍ថា **អត្ថេសុ ញាណំ អត្ថប្បដិសម្ភិទា** ញាណក្នុងអត្ថ ឈ្មោះថា អត្ថប្បដិសម្ភិទា សូម្បីក្នុងសេចក្តីមិនមានការផ្សេងគ្នានៃបញ្ញា លោកទើបពោលថា **អត្ថនានត្តេ បញ្ញា អត្ថប្បដិសម្ភិទេ ញាណំ** បញ្ញាក្នុងសេចក្តីផ្សេងគ្នានៃអត្ថ ជាអត្ថប្បដិសម្ភិទាញាណ ព្រោះមានសេចក្តីផ្សេងគ្នាដោយអំណាចត្រឹមតែការចាក់ធ្លុះចតុសច្ចធម៌ ។

ក្នុងបទទាំងនោះ បទថា **នានត្តេ** ក្នុងសេចក្តីផ្សេងគ្នា គឺ ក្នុងភាវៈមិនតិចនៃអត្ថជាដើម ។

បទថា **វវត្ថានេ** ក្នុងការកំណត់ គឺ ក្នុងការសម្រេចអត្ថជាដើម ។

បទថា **សល្លក្ខណេ** ក្នុងការសម្គាល់ គឺ ក្នុងការឃើញ



អត្ថជាដើម ដោយប្រពៃ ។

ក្នុងបទថា **ឧបលក្ខណេ** ក្នុងការចូលទៅសម្គាល់ គឺ ក្នុងការឃើញអត្ថជាដើម ច្រើនឡើង ។

បទថា **បភេទេ** ក្នុងប្រភេទ គឺ ក្នុងសេចក្តីផ្សេងគ្នានៃអត្ថជាដើម ។

បទថា **បភាវនេ** ក្នុងការប្រាកដ គឺ ក្នុងការកើតនៃអត្ថជាដើម ដោយធ្វើឲ្យប្រាកដ ។

បទថា **ជោតនេ** ក្នុងភាពភ្លឺស្វាង គឺ ក្នុងការសំដែងអត្ថជាដើម ។

បទថា **វិរោចនេ** ក្នុងសេចក្តីរុងរឿង គឺ ក្នុងការសម្តែងអត្ថជាដើម ច្រើនយ៉ាង ។

បទថា **បកាសនេ** ក្នុងការប្រកាស គឺ ក្នុងការប្រកាសអត្ថជាដើម ។

លោកពោល ធ្វើបទថា **នានត្តេ** ឲ្យជាមូលបទដោយអំណាចទូទៅនៃបទទាំងអស់ ។ លោកពោលបទថា **វវត្ថានេ** ដោយអំណាចនៃព្រះសោតាបន្ន ។ ពោលបទថា **សល្លក្ខណេ**

**ឧបលក្ខណេ** ដោយអំណាចនៃព្រះសកទាគាមី ។ ពោលបទថា **បភេទេ បកាវនេ** ដោយអំណាចនៃព្រះអនាគាមី ។ ពោលបទថា **ជោតនេ វិរោចនេ បកាសនេ** ដោយអំណាចនៃព្រះអរហន្ត គប្បីធ្វើការប្រកបក្នុងបទទាំងនេះ ដោយប្រការដូច្នេះ ។

( ចប់ អដ្ឋកថាសុទ្ធិកបដិសម្ភិទាញាណនិទ្ទេស )



# អដ្ឋកថា ឥន្ទ្រិយបរោបរិយត្តញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ ក្នុងឥន្ទ្រិយោបរិយត្តញ្ញាណនិទ្ទេសដូចតទៅនេះ ។ បទថា **តថាគតស្ស** សូម្បីមិនមានដោយសរុបក្នុងឧទ្ទេស លោកក៏ពោលថា **តថាគតស្ស** ព្រោះលោកពោលទុកថា ញាណ ៦ មិនទូទៅដល់សាវកទាំងឡាយ ព្រោះដូច្នោះ ទើបកាន់យកក្នុងនិទ្ទេសនៃពាក្យថា **តថាគត** ដែលសម្រេចហើយដោយអត្ថក្នុងឧទ្ទេស ។

បទថា **សត្តេ បស្សតិ** ឃើញសត្វទាំងឡាយ គឺ ឈ្មោះថាសត្វ ព្រោះជាប់ គឺ ព្រោះត្រូវបណ្តោយតាមដោយឆន្ទរាគៈក្នុងរូបជាដើម ។ ព្រះតថាគតទ្រង់ឃើញ ទ្រង់ត្រួតមើលសត្វទាំងនោះដោយចក្ខុដែលជា **ឥន្ទ្រិយបរោបរិយត្តញ្ញាណ** ញាណកំណត់ដឹងការទន់ខ្សោយ និងចាស់ក្លានៃឥន្ទ្រិយរបស់សត្វទាំងឡាយ ។

បទថា **អប្បរជក្ខេ** អ្នកមានកិលេស គឺ ធូលីតិចក្នុងបញ្ញាចក្ខុនេះ មានវិគ្រោះថា ឈ្មោះថា **អប្បរជក្ខា** ព្រោះអត្ថថា សត្វមានធូលី មានរាគៈជាដើមតិចក្នុងចក្ខុ គឺ បញ្ញា ។

ឬថា ព្រោះអត្ថថា សត្វមានធូលី គឺ រាគៈជាដើម តិច ។ ដែលសត្វទាំងនោះមានកិលេស គឺ ធូលីតិច ក្នុងបញ្ញាចក្ខុ ។

បទថា **មហារជក្ខេ** អ្នកមានកិលេស គឺ ធូលីច្រើន ក្នុងបញ្ញាចក្ខុ មានវិគ្រោះថា ឈ្មោះថា **មហារជក្ខេ** ព្រោះអត្ថថា សត្វមានធូលី មានរាគៈជាដើមច្រើនក្នុងចក្ខុ គឺ បញ្ញា ។ ឬថា សត្វមានធូលី មានរាគៈជាដើមច្រើន ។

បទថា **តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ** មានឥន្ទ្រិយចាស់ក្លា មានឥន្ទ្រិយទន់ខ្សោយ ។ មានវិគ្រោះថា ឈ្មោះថា **តិក្ខិន្ទ្រិយា** គឺ មានឥន្ទ្រិយចាស់ក្លា ព្រោះអត្ថថា សត្វមានឥន្ទ្រិយ មានសទ្ធាជាដើមចាស់ក្លា ។ ឈ្មោះថា **មុទិន្ទ្រិយា** មានឥន្ទ្រិយទន់ខ្សោយ ព្រោះអត្ថថា សត្វមានឥន្ទ្រិយ មានសទ្ធាជាដើមទន់ខ្សោយ ។

បទថា **ស្វាការេ ទ្វាការេ** មានអាការល្អ មានអាការអាក្រក់ សេចក្តីថា ឈ្មោះថា **ស្វាការា** គឺ មានអាការល្អ ព្រោះអត្ថថា សត្វមានអាការ គឺ មានចំណែក មានសទ្ធាជាដើមល្អ ។ ឈ្មោះថា **ទ្វាការា** គឺ មានអាការអាក្រក់ ព្រោះអត្ថថា សត្វមានអាការ គឺ មានចំណែកមិនមានសទ្ធាជាដើម គួរខ្ពើម គួរតិះ-



ដៀល ។

បទថា **សុវិញ្ញាបយេ ទុវិញ្ញាបយេ** គប្បីឲ្យដឹងច្បាស់បានដោយងាយ គប្បីឲ្យដឹងច្បាស់បានដោយក្រ គឺ សត្វពួកណាកំណត់ហេតុដែលពោល ជាអ្នកអាចត្រាស់ដឹង បានដោយងាយ សត្វទាំងនោះ ឈ្មោះថា **សុវិញ្ញាបយា** ។ ផ្ទុយគ្នានឹងការត្រាស់ដឹងបានដោយងាយនោះ ឈ្មោះថា **ទុវិញ្ញាបយា** ។

បទថា **អប្បេកច្ចេ បរលោកវជ្ជភយទស្សាវិនោ** ពួកខ្លះមានប្រក្រតីឃើញបរលោក និងទោសដោយសភាពជាភ័យ គឺ ឈ្មោះថា **បរលោកវជ្ជភយទស្សាវិនោ** គឺ មានប្រក្រតីឃើញបរលោក និងទោសដោយសភាពជាភ័យ ព្រោះអត្ថថា មានប្រក្រតីឃើញភ័យដទៃក្នុងលោក មានខន្ធលោកជាដើម និងទោសមានរាគៈជាដើម ព្រោះពួកខ្លះកាលឃើញបរលោកនឹងទោស មានរាគៈជាដើម ដោយសភាពជាភ័យ ក្នុងនិទ្ទេសនៃបទនេះ លោកទើបមិនពោលដល់បរលោកប៉ុណ្ណោះ ។ គប្បីកាន់យកសេចក្តីយ៉ាងនេះថា សត្វពួកនោះ មានប្រក្រតីឃើញភ័យក្នុងបរលោក និងក្នុងទោសមានរាគៈជាដើម ។

បទថា **អបេ្បកច្ចេ ន បរលោកវជ្ជភយទស្សាវិនោ** ពួកខ្លះមិនបានឃើញបរលោក និងទោសដោយសភាពជាភ័យនេះ មានសេចក្ដីផ្ទុយគ្នានឹងបទដែលពោលហើយនោះ ។ មួ្យ៉ាងវិញទៀត បទថា **លោកោ** ព្រោះអត្ថថាបែកធ្លាយ ។ បទថា **វជ្ជំ** គឺ ទោស ព្រោះអត្ថថា គួរតិះដៀល ។ ដោយបទប្រមាណប៉ុណ្ណេះ ដែលលោកបង្ហាញបទឧទ្ទេសហើយ ។

ព្រះសារីបុត្តត្ថេរ កាលនឹងធ្វើបដិនិទ្ទេស គឺ ការបង្ហាញសារឡើងវិញនូវនិទ្ទេសទៀត ទើបពោលពាក្យមានជាដើមថា **អប្បរជក្ខេ មហារជក្ខេ** សត្វមានកិលេស ធូលីតិច ក្នុងបញ្ញាចក្ខុ សត្វមានកិលេស ធូលីច្រើនក្នុងបញ្ញាចក្ខុ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សទ្ធោ** បុគ្គលមានសទ្ធា ព្រោះបុគ្គលមានសទ្ធា ពោលគឺ ការឈានចុះក្នុងព្រះរតនត្រ័យ ។ បុគ្គលដល់ព្រមដោយសទ្ធានោះ ឈ្មោះថា **អប្បរជក្ខោ** គឺ មានធូលីតិចក្នុងបញ្ញាចក្ខុ ព្រោះធូលី គឺ ការមិនមានសទ្ធា និងធូលី គឺ អកុសលដ៏សេស ដែលជាឫសគល់នៃការមិនមានសទ្ធា ។ ឈ្មោះថា **អស្សទ្ធោ** គឺ អ្នកមិនមានសទ្ធា ព្រោះមិនមានសទ្ធា



បុគ្គលនោះ ឈ្មោះថា **មហារជក្ខោ** គឺ មានធូលីច្រើនក្នុងបញ្ញាចក្ខុ ព្រោះធូលីមានប្រការដូចពោលហើយយ៉ាងច្រើន ។

ឈ្មោះថា **អារទ្ធវីរិយោ** អ្នកប្រារព្ធសេចក្ដីព្យាយាម ព្រោះមានចិត្តប្រារព្ធសេចក្ដីព្យាយាម , បុគ្គលអ្នកប្រារព្ធសេចក្ដីព្យាយាមនោះ ឈ្មោះថា **អប្បរជក្ខោ** ព្រោះធូលី គឺ ការខ្ជិលច្រអូស និងធូលី គឺ អកុសលដ៏សេសដែលជាឫសគល់នៃសេចក្ដីខ្ជិលច្រអូស ។

ឈ្មោះថា **កុសីទោ** ជាអ្នកខ្ជិលច្រអូស ព្រោះអត្ថថា លិចចុះដោយអាការគួរខ្ពើម ព្រោះមានការព្យាយាមលាមក ។ **កុសីទោ** នោះឯង គឺ **កុសីតោ** ។ បុគ្គលអ្នកខ្ជិលច្រអូសនោះ ឈ្មោះថា **មហារជក្ខោ** ព្រោះមានធូលីដែលលិចចុះ មានប្រការដូចពោលហើយ ។

ឈ្មោះថា **ឧបដ្ឋិតស្សតិ** អ្នកមានសតិតាំងមាំ ព្រោះមានសតិចូលទៅតាំងអារម្មណ៍ទុកមាំ ។ បុគ្គលនោះ ឈ្មោះថា **អប្បរជក្ខោ** ព្រោះធូលី គឺ ការវង្វេង និងធូលី គឺ អកុសលដ៏សេសដែលជាឫសគល់នៃការវង្វេង ។

ឈ្មោះថា **មុដ្ឋស្សតិ** គឺអ្នកមិនមានស្មារតី ព្រោះមានសតិភ្លេចភ្លាំង ។ បុគ្គលនោះ ឈ្មោះថា **មហារជក្ខោ** ព្រោះធូលីមានប្រការដូចពោលហើយ ។

ឈ្មោះថា **សមាហិតោ** គឺ បុគ្គលអ្នកមានចិត្តតម្កល់មាំ ព្រោះតាំងទុកស្មើ ឬថា ដោយប្រពៃក្នុងអារម្មណ៍ ដោយអប្បនាសមាធិ ឬដោយឧបចារសមាធិ ។ ម្យ៉ាងទៀត ឈ្មោះថា **សមាហិតោ** ព្រោះអត្ថថា មានចិត្តតាំងមាំ ។ បុគ្គលនោះ ឈ្មោះថា **អប្បរជក្ខោ** ព្រោះធូលី គឺ ការរាយមាយនិងធូលី គឺ អកុសលដ៏សេសដែលជាឫសគល់នៃសេចក្តីរាយមាយ ។

បុគ្គលមានចិត្តមិនតាំងមាំ ឈ្មោះថា **អសមាហិតោ** បុគ្គលនោះ ឈ្មោះថា **មហារជក្ខោ** ព្រោះមានធូលី មានប្រការដូចពោលហើយ ។

ឈ្មោះថា **បញ្ញវា** គឺ បុគ្គលមានបញ្ញា ព្រោះមានបញ្ញាឃើញការកើត និងការរលត់ ។ បុគ្គលអ្នកមានបញ្ញានោះ ឈ្មោះថា **អប្បរជក្ខោ** ព្រោះធូលី គឺ មោហៈ និងធូលី គឺ អកុសលដ៏សេសដែលជាឫសនៃមោហៈតិច ។



ឈ្មោះថា **ទុប្បញ្ញោ** គឺ បុគ្គលអ្នកមានបញ្ញាអាប់ ព្រោះមានឥតបញ្ញា ព្រោះវង្វេងដោយមោហៈ បុគ្គលនោះឈ្មោះថា **មហារជក្ខោ** ព្រោះមានធូលី មានប្រការដូចពោលហើយដោយច្រើន ។

បទថា **សទ្ធោ បុគ្គលោ តិក្ខិន្ទ្រិយោ** បុគ្គលអ្នកមានសទ្ធាជាអ្នកមានឥន្ទ្រិយចាស់ក្លា គឺ មានសទ្ធា ដោយសទ្ធាមានកម្លាំងដែលកើតច្រើន ។ មានឥន្ទ្រិយចាស់ក្លាដោយសទ្ធិន្ទ្រិយនោះឯង ។

បទថា **អស្សទ្ធោ បុគ្គលោ មុទិន្ទ្រិយោ** បុគ្គលអ្នកមិនមានសទ្ធា ជាអ្នកមានឥន្ទ្រិយទន់ខ្សោយ គឺ មិនមានសទ្ធា ដោយការមិនជឿកើតឡើង ។ ជាបុគ្គលមានឥន្ទ្រិយទន់ខ្សោយ ដោយសទ្ធិន្ទ្រិយមានកំលាំងតិច ដែលកើតឡើងក្នុងចន្លោះ ៗ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះ ។

បទថា **សទ្ធោ បុគ្គលោ ស្វាការោ** បុគ្គលអ្នកមានសទ្ធាជាអ្នកមានអាការល្អ គឺ អាការស្អាតដោយសទ្ធានោះឯង ។ បទថា **អស្សទ្ធោ បុគ្គលោ ទ្វាការោ** បុគ្គលអ្នកមិនមានសទ្ធា ជាអ្នកមានភាពអាក្រក់ គឺ មានអាការមិនល្អ ដោយភាពជាអ្នកមិន

ជឿនោះឯង សូម្បីពាក្យដ៏សេស ក៏មាន ន័យនេះ ។

បទថា **សុវិញ្ញាបយា** គឺ គប្បីឲ្យដឹងបានងាយ ។ បទថា **ទុវិញ្ញាបយា** គឺ គប្បីឲ្យដឹងបានលំបាក ។

ក្នុងបទថា **បរលោកវជ្ជភយទស្សាវី** នេះ បគ្បីជ្រាបសេចក្តីដូចតទៅនេះ ។

ព្រោះសទ្ធាជាដើម របស់អ្នកដល់ព្រមដោយបញ្ញា ជាសេចក្តីបរិសុទ្ធដោយល្អ ។ ដូច្នោះ ព្រោះជាអ្នកដល់ព្រមដោយសទ្ធាដែលបរិសុទ្ធដោយល្អជាដើម ព្រោះជាអ្នកប្រកបដោយសទ្ធានោះទើបជាអ្នកមានប្រក្រតីឃើញបរលោក និងទោសដោយភាពជាភ័យ ។ ឬសូម្បីអ្នកដល់ព្រមដោយសទ្ធាបរិសុទ្ធដ៏ស្អាតជាដើមក៏ជាអ្នកមានប្រក្រតីឃើញបរលោក និងទោសដោយភាពជាភ័យដោយបញ្ញាដែលមានសទ្ធានោះ ជាបច្ច័យ ។ ព្រោះដូច្នោះឯងលោកទើបពោលធម៌ ៤ យ៉ាង មានសទ្ធាជាដើមថា **បរលោក-វជ្ជភយទស្សាវី** ជាអ្នកមានប្រក្រតីឃើញបរលោក និងទោសដោយភាពជាភ័យ ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ ដើម្បីនឹងសម្តែងបរលោក និង



ទោស ដូចពោលហើយ ក្នុងបទនេះថា **បរលោកវជ្ជភយទស្សាវី** ទើបពោលពាក្យមានជាអាទិ៍ថា **លោកោ** ដូច្នេះ ក្នុងបទទាំងនោះខន្ធទាំងឡាយនោះឯង ឈ្មោះថា ខន្ធលោក ព្រោះអត្ថថា មានការបែកធ្លាយទៅ ។ សូម្បីក្នុងពីរបទដ៏សេសក៏មានន័យដូចគ្នា ។

បទថា **វិបត្តិភវលោកោ** លោក គឺ ភពវិបត្តិ បានដល់អបាយលោក ។ ព្រោះអបាយលោកនោះ ជាលោកអាក្រក់លាមក ព្រោះមានផលមិនគួរប្រាថ្នា ទើបឈ្មោះថា **វិបត្តិ** ។ ឈ្មោះថា ភព ព្រោះកើត ។ ភព គឺ ការវិបត្តិនោះឯងឈ្មោះថា ភពវិបត្តិ ។ លោក គឺ ភពវិបត្តិនោះឯង ឈ្មោះថា **លោក គឺ ភពវិបត្តិ** ។

បទថា **វិបត្តិសម្ភវលោកោ** លោក គឺ សម្ភវវិបត្តិ បានដល់ កម្មដែលចូលដល់អបាយ ឈ្មោះថា **សម្ភវ** ព្រោះជាដែនកើតនៃផលកម្ម ។ ដែនកើតនៃវិបត្តិ ឈ្មោះថា **សម្ភវវិបត្តិ** ។ លោកមានដែនកើតវិបត្តិនោះឯង ឈ្មោះថា លោក គឺ សម្ភវ-វិបត្តិ ។

បទថា **សម្បត្តិភវលោកោ** លោក គឺ ភពសម្បត្តិ បានដល់

សុគតិលោក ។ ព្រោះសុគតិលោកនោះ ជាលោកល្អ ព្រោះមានផលជាទីប្រាថ្នា ទើបឈ្មោះថា **សម្បត្តិ** ។ ឈ្មោះថា **ភព** ព្រោះកើត ។ ភពដែលជាសម្បត្តិនោះឯង ឈ្មោះថា **ភពសម្បត្តិ** ។ លោក គឺ ដែនកើតនៃសម្បត្តិនោះឯង ឈ្មោះថាលោក គឺ **ភពសម្បត្តិ** ។

បទថា **សម្បត្តិសម្ភវលោកោ** លោក គឺ ភពសម្បត្តិ បានដល់ កម្មដែលចូលដល់សុគតិ ។ ឈ្មោះថា **សម្ភ** ព្រោះជាដែនកើតនៃផលកម្ម ។ ដែនកើតនៃសម្បត្តិ ឈ្មោះថា **សម្ភវសម្បត្តិ** ។ លោក គឺ ដែនកើតនៃសម្បត្តិនោះឯង ឈ្មោះថាលោក គឺ **សម្ភវសម្បត្តិ** ។

បទមានជាអាទិ៍ថា **ឯកោ លោកោ** លោក ១ មានអត្ថដូចបានពោលមកហើយក្នុងខាងក្រោយនោះឯង ។

បទថា **វជ្ជំ** ទោស លោកធ្វើជា នបុំសកលិង្គ ព្រោះមិនបានសម្តែងផង បទថា **អសុកោ** ។

បទថា **កិលេសា** គឺ កិលេសមានរាគៈជាដើម ។

បទថា **ទុច្ចរិតា** គឺ ទុច្ចរិតមានបាណាតិបាតជាដើម ។



បទថា **អភិសង្ខារា** គឺ សង្ខារ មានបុញ្ញាភិសង្ខារជាដើម ។

បទថា **ភវគាមិកម្មា** កម្មដែលជាហេតុឲ្យសត្វទៅកាន់ភព ឈ្មោះថា **ភវគាមិនោ** ព្រោះសត្វទាំងឡាយទៅកាន់ភព ដោយអំណាចការឲ្យវិបាករបស់ខ្លួន ។ លោកពោលកម្ម ដែលឲ្យកើតវិបាកសូម្បីក្នុងអភិសង្ខារទាំងឡាយ ។ បទថា **ឥតិ** ជាបទសម្តែងប្រការដូចពោលហើយ ។ បទថា **ឥមស្មិញ្ច លោកេ ឥមស្មិញ្ច វជ្ជេ** ក្នុងលោកនេះ និងក្នុងទោសនេះ គឺ ក្នុងលោក និងក្នុងទោស ដូចពោលហើយ ។

បទថា **តិព្វា ភយសញ្ញា** ការសម្គាល់ថា ជាភ័យដ៏ខ្លាំងក្លា គឺ ការសម្គាល់ថា ជាភ័យមានកម្លាំង តែលោកពោលអត្ថនៃ **ពល** ស័ព្ទថា **តិព្វា** ។ លោកពោលអត្ថនៃ **ភយ** ស័ព្ទថា **ភយសញ្ញា** ព្រោះថា លោក និងទោសទាំងពីរ ឈ្មោះថា **ភ័យ** ព្រោះជាវត្ថុនៃភយ និងព្រោះជាភ័យខ្លួនឯង ។ ការសម្គាល់ថាភ័យ ក៏ឈ្មោះថា **ភយសញ្ញា** ។

បទថា **បច្ចុបដ្ឋិតា ហោតិ** ប្រាកដហើយ គឺ ប្រាកដ ព្រោះអាស្រ័យភ័យនោះ ៗ បទថា **សេយ្យថាបិ ឧក្ខិតាសិតេ វធកេ**

ដូចការសម្គាល់ក្នុងសត្រូវដែលងាដាវ គឺ ការសម្គាល់ថាជាភ័យខ្លាំងក្លាប្រាកដក្នុងលោក និងក្នុងទោស ដូចការសម្គាល់ថាជាភ័យប្រាកដដូចសត្រូវដែលងាដាវដើម្បីប្រហារ ដូច្នោះ ។

បទថា **ឥមេហិ បញ្ញាសាយ អាការេហិ** ដោយអាការ ៥០ នេះ គឺ ដោយអាការ ៥០ ដោយអំណាចនៃអាការមួយ ៗ មាន ៥ ក្នុងបញ្ចកៈ ១០ មានអប្បរជក្ខបញ្ចកៈជាដើមមួយយ៉ាង ៗ ។

បទថា **ឥមានិ បញ្ចិន្ទ្រិយានិ** បានដល់ឥន្ទ្រិយ ៥ មានសទ្ធិន្ទ្រិយជាដើម ។

បទថា **ជានាតិ** គឺ ព្រះតថាគតរមែងទ្រង់ដឹងដោយបញ្ញា ។ បទថា **បស្សតិ** គឺ ទ្រង់ធ្វើដូចឃើញដោយទិព្វចក្ខុ ។ បទថា **អញ្ញាតិ** ទ្រង់ជ្រាបច្បាស់ គឺ ទ្រង់ជ្រាប ដោយមារយាទនៃអាការទាំងពួង ។ បទថា **បដិវិជ្ឈតិ** ទ្រង់ចាក់ធ្លុះ គឺ ទ្រង់ទម្លាយដោយបញ្ញា ដោយអំណាចការឃើញទាំងអស់ មិនមានសល់ជាឯកទ្ទេស ។

( ចប់អដ្ឋកថា ឥន្ទ្រិយបរោបរិយត្តញ្ញាណនិទ្ទេស )



## អដ្ឋកថា យមកប្បាដិហីរញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ ក្នុងយមកប្បាដិហីរយញ្ញាណនិទ្ទេស ដូចតទៅនេះ ។ បទថា **អសាធារណំ សាវកេហិ** យមកប្បាដិហារិយ៍មិនទូទៅដល់សាវកទាំងឡាយ សេចក្ដីថា ក្នុងសាធារណញ្ញាណនិទ្ទេស ដ៏សេសលោកមិនបានពោលទុក ព្រោះមិនមានឱកាសដោយពាក្យដទៃ តែក្នុងនិទ្ទេសនេះ គប្បីជ្រាបថាលោកពោលទុក ព្រោះមិនមានពាក្យដទៃ ។

បទថា **ឧបរិមកាយតោ** ចេញអំពីព្រះកាយខាងលើ គឺ ចេញពីព្រះសរីរៈខាងលើនៃព្រះនាគី ។

បទថា **អគ្គិក្ខន្ធោ បវត្តតិ** គំនរភ្លើងចេញ គឺ កាលចូលឈានជាបាទ មានតេជោកសិណជាអារម្មណ៍ គ្រាចេញហើយនឹកថា សូមអណ្ដាតភ្លើងចូរចេញពីកាយខាងលើ ហើយធ្វើបរិកម្មអធិដ្ឋានថា សូមអណ្ដាតភ្លើងចូរចេញពីកាយខាងលើ ដោយអភិញ្ញាញាណ អណ្ដាតភ្លើងនឹងចេញពីកាយខាងលើព្រមទាំងការអធិដ្ឋាន ។ ក្នុងនិទ្ទេសនេះ អណ្ដាតភ្លើងនោះ លោកហៅថា **ខន្ធ**

ព្រោះអត្ថថា ជាគំនរ ។

បទថា **ហេដ្ឋិមកាយតោ** ចេញពីព្រះកាយខាងក្រោម គឺ ចេញពីព្រះសរីរៈខាងក្រោមចេញអំពីព្រះនាភី ។

បទថា **ឧទកធារា បវត្តតិ** ធ្នារទឹកចេញ គឺ កាលចូលឈានជាបាទ មានអាបោកសិណជាអារម្មណ៍ ត្រាចេញហើយនឹកថា សូមធ្នារទឹកចេញពីព្រះកាយខាងក្រោម ហើយធ្វើបរិកម្មអធិដ្ឋានថា សូមធ្នារទឹកចូរចេញពីកាយខាងក្រោម ដោយអភិញ្ញាណ ធ្នារទឹកនឹងចេញពីកាយខាងក្រោម ព្រមនឹងអធិដ្ឋាន ។ សូម្បីក្នុងបទទាំងពីរ លោកពោលថា ចេញដោយមិនដាច់ក្រសែ ។ ភវង្គចិត្ត ២ ដួង រមែង ប្រព្រឹត្តទៅក្នុងរវាងអធិដ្ឋាន និងការនឹក ព្រោះដូច្នោះឯង ធ្នារទឹក និងធ្នារភ្លើង ទើបចេញជាគូរមិនប្រាកដ ។ ក៏ការកំណត់ភវង្គចិត្ត មិនមានដល់សាវកដទៃ ។

បទថា **បុរត្ថិមកាយតោ** ចេញពីព្រះកាយខាងមុខ គឺ ចេញពីខាងមុខ ។ **បច្ឆិមកាយតោ** ចេញពីព្រះកាយខាងក្រោយ គឺ ចេញពីខាងក្រោយ ។

បទមានជាអាទិ៍ថា **ទក្ខិណអក្ខិតោ វាមអក្ខិតោ** ចេញពី



ព្រះនេត្រខាងស្តាំ ចេញពីព្រះនេត្រខាងឆ្វេង ជាបាឋៈសមាស មិនមែនបាឋៈដទៃ ។ បាឋៈថា **ទក្ខិណនាសិកាសោតតោ វាម-នាសិកាសោតតោ** ចេញពីរន្ធព្រះ នាសិកខាងស្តាំ ចេញពីរន្ធព្រះនាសិកខាងឆ្វេង ដូច្នេះ ជាបាឋៈល្អ ។ អាចារ្យទាំងឡាយពោលជារស្សៈខ្ញុះ ។

ក្នុងបទថា **អង្សកូដតោ** ចេញពីចង្កួយព្រះអង្សានេះ មានសេចក្តីដូច្នេះ ។ ឈ្មោះថា កូដ ចង្កួយ ព្រោះអត្ថថា ខ្ពស់ឡើងដូចកំពូល ។ ចង្កួយ គឺ អង្សានោះឯង ឈ្មោះថា **អង្សកូដ** ។

បទថា **អង្គុលង្គុលេហិ** គឺ ចេញពីព្រះអង្គុលីមួយៗ ។

បទថា **អង្គុលន្តរិកាហិ** គឺចេញពីចន្លោះនៃអង្គុលី ។

បទថា **ឯកេកលោមតោ អគ្គិក្ខន្ធោ បវត្តតិ** , **ឯកេក-លោមតោ ឧទកធារា បវត្តតិ** គំនរភ្លើងចេញពីព្រះលោមាមួយសរសៃ ៗ ។ ធ្នារទឹកចេញពីព្រះលោមាមួយ ៗ សរសៃ ។ លោកអធិប្បាយថា គំនរភ្លើង ធ្នារទឹក ចេញជាគូ ៗ ពីព្រះលោមាមួយសរសៃ ៗ ព្រោះកាន់យកព្រះលោមា ទាំងអស់ផងដោយពាក្យដដែល ៗ ។ ក្នុងបទសូម្បីទាំងពីរ ។

សូម្បីក្នុងបទថា **លោមកូបតោ លោមកូបតោ អគ្គិក្ខន្ធោ បវត្តតិ , លោមកូបតោ លោមកូបតោ ឧទកធារា បវត្តតិ** គំនរភ្លើងចេញពីរណ្ដៅព្រះលោមាមួយសរសៃ ៗ ។ ផ្កាទឹកចេញពីរណ្ដៅព្រះលោមាមួយសរសៃ ៗ ក៏មានដូចគ្នា ។ ក្នុងគម្ពីរទាំងឡាយ លោកសរសេរទុកថា គំនរភ្លើង ចេញពីរណ្ដៅព្រះលោមាមួយសរសៃៗ ។ ផ្កាទឹកចេញពីរណ្ដៅព្រះលោមាមួយសរសៃៗ។ គំនរភ្លើងចេញពីរណ្ដៅ ព្រះលោមាមួយសរសៃ ៗ ។ ផ្កាទឹកចេញអំពីរណ្ដៅព្រះលោមាមួសរសៃ ៗ បទសូម្បីទាំងនោះ ក៏ត្រឹមត្រូវ ។ ប៉ុន្តែបាឋៈមុនល្អជាង ព្រោះសម្ដែងសេចក្ដីល្អិតយ៉ាងក្រៃលែងនៃ បាដិហារិយ៍ ។

បទថា **ឆន្នំ វណ្ណានំ** ព្រះរស្មីផ្សាយចេញពីព្រះវរកាយដោយអំណាចនៃវណ្ណៈ ៦ ។ សម្ព័ន្ធគ្នាដូចម្ដេច ?

លោកពោលដល់សរីរពព្យត ដោយបទមិនតិចមានជាអាទិ៍ថា **ឧបរិមកាយតោ** ។ ដោយហេតុនោះ ការសម្ព័ន្ធដោយសរីរពព្យតរមែងប្រព្រឹត្តទៅបាន ។ ដូច្នោះលោក ទើបពោលថា រស្មីទាំងឡាយនៃវណ្ណៈ ៦ ដែលជាសរីរពព្យត រមែងផ្សាយចេញជាគូ ៗ



ដោយការសម្ព័ន្ធពាក្យពេចន៍ និងដោយអធិការនៃយមកប្បាដិ-ហារិយ៍ ។ មយ៉ាងទៀត ដោយការសម្ព័ន្ធនៃឆដ្ឋីវិភត្តិ គប្បីប្រាថ្នាបាឋៈដ៏សេសថា **រស្មិយោ** ភាពប្រាកដ ។ ( គឺឲ្យបន្ថែមបទថា **ឆន្នំ វណ្ណានំ រស្មិយោ** ) ។

បទថា **នីលានំ** ពណ៌ខៀវ គឺ មានពណ៌ដូចផ្កា ត្រកៀត ។

បទថា **បីតកានំ** ពណ៌លឿង គឺ មានពណ៌ដូចផ្កាកណ្ណិកា ។

បទថា **លោហិតកានំ** ពណ៌ក្រហម គឺ មានពណ៌ដូចប្រភេទសត្វល្អិតស៊ីឈើតូចៗ ។

បទថា **ឱទាតានំ** ពណ៌ស គឺ មានពណ៌ដូចផ្កាយព្រឹក ។

បទថា **មញ្ជិដ្ឋានំ** ពណ៌ហង្សបាទ គឺ មានពណ៌ក្រហមទន់ ។

បទថា **បភស្សរានំ** ពណ៌ផ្លេក គឺ មានពណ៌ផ្លេក តាមប្រក្រតី ។ ពណ៌ផ្លេកសូម្បីមិនមានផ្សេងគ្នា ។ កាលពោលដល់វណ្ណៈ ៥ រស្មីណា ៗ រុងរឿង រស្មីមាននោះ ៗ ជាពណ៌ផ្លេក ។

ពិតយ៉ាងនោះ កាលព្រះតថាគតទ្រង់ធ្វើយមកប្បាដិហារិយ៍ **រស្មីមានពណ៌ខៀវ** រមែងផ្សាយចេញពីកន្លែងពណ៌ខៀវនៃព្រះកេសា

ព្រះមស្សុ និងព្រះនេត្រ ដោយកម្លាំងនៃយមកប្បបាដិហីរញ្ញាណនោះឯង , ដោយអំណាចរស្មីមានពណ៌ខៀវផ្ទៃមេឃ រមែងខ្វាយទៅ ដូចជាផង់ផ្កាអញ្ជ័ន ដូចដេរដាសទៅដោយត្របកផ្កាត្រកៀត និងដូចផ្កាឧបលខៀវ ដូចបណ្ដូលត្នោតកែវមណីសំយុងចុះមក និងដូចផ្ទាំងសម្ពត់ពណ៌ផ្ទៃមេឃក្រម៉ៅ ដែលគេលាតសន្ធឹងទុក ។

**រស្មីមានពណ៌លឿង** រមែងផ្សាយចេញពីព្រះឆវី និងចេញពីកន្លែងពណ៌លឿងនៃព្រះនេត្រ , ដោយអំណាចនៃ រស្មីមានពណ៌លឿង ទិសាភាគរមែងរុងរោចន៍ ប្រាកដដូចជាទឹកមាស ដូចលាតត្រដាងនូវផ្ទាំងសម្ពត់មាស និងដូចដេរដាសទៅដោយផង់ស្មៅម្យ៉ាង និងផ្កាកណ្ណិកា ។

**រស្មីមានពណ៌ក្រហម** រមែងផ្សាយចេញពីព្រះមំស និងព្រះលោហិត និងចេញពីទីពណ៌ក្រហមនៃព្រះនេត្រ , ដោយអំណាចនៃរស្មីពណ៌ក្រហម ទិសាភាគរមែងរុងរោចន៍ ដូចជ្រលក់ដោយផង់ក្រហម ដូចចេញនូវទឹកពណ៌នៃជ័រម្យ៉ាងដែលទុំឆ្អិន ដូចរុំដោយសំពត់កម្ពលពណ៌ក្រហម និងពោរពេញទៅដោយផ្កាឈើពណ៌ក្រហម គឺ ផ្កាជ័យព្រឹក្ស ផ្ការលួស និងផ្កាចំប៉ា ។



**រស្មីពណ៌ស** រមែងផ្សាយចេញពីព្រះអដ្ឋិ ព្រះទន្ត និងចេញពីទីពណ៌សនៃព្រះនេត្រ , ដោយអំណាចនៃរស្មីមានពណ៌ស ទិសាភាគរមែងរុងរោចន៍ដូចជាផ្សាយទៅ ដោយធ្នារទឹកដោះដែលហូរចេញពីផ្ទាំងប្រាក់ ដូចក្រាលពិតានដោយផែនប្រាក់ ដូចបណ្ដូលត្នោតប្រាក់សំយុងចុះ និងដូចដេរដាសដោយផ្កាឈើមានផ្កាម្លិះវល្លិ៍ ផ្កាឈូកស ផ្កាឈើជ័រ ផ្កាម្លិះលា និងផ្កាម្លិះរួត ។

**រស្មីពណ៌ហង្សបាទ** រមែងចេញចាកត្រង់ពណ៌ក្រហមទន់មានបាតព្រះហត្ថ និងបាតព្រះបាទជាដើម , ដោយអំណាចនៃរស្មីមានពណ៌ហង្សបាទ ទិសាភាគ រមែងរុងរោចន៍ដូចរង្វង់សំណាញ់កែវប្រវាឡ និងដូចដេរដាសដោយមេព្រាម៉ត់សម្រាប់លាប ពណ៌ក្រហម និងផ្កាផ្គាំ។

**រស្មីមានពណ៌ផ្លេក** រមែងផ្សាយចេញចាកត្រង់ពណ៌ផ្លេកមានព្រះឧណ្ណាលោម ព្រះទាឋៈ និងព្រះនខាជាដើម , ដោយអំណាចនៃរស្មីមានពណ៌ផ្លេក ទិសាភាគ រមែងរុងរោចន៍ដូចដេរ-ដាសដោយពពួកផ្កាយព្រឹក និងដេរដាសដោយរស្មីផ្លេកបន្ទោរជាដើម ។

ដោយបទមានជាអាទិ៍ថា **ភគវា ចង្កមតិ** ព្រះមានព្រះភាគជាម្ចាស់ស្តេចចង្ក្រម លោកពោលដើម្បីសម្តែងថា ព្រះឥរិយាបថផ្សេង ៗ នៃព្រះមានព្រះភាគជាម្ចាស់ និងព្រះពុទ្ធនិម្មិតទាំងឡាយ រមែងមាន ដោយយមកប្បាដិហិរញ្ញាណប៉ុណ្ណោះ ។ ព្រោះព្រះឥរិយាបថនៃព្រះពុទ្ធនិម្មិតទាំងនោះ រមែងប្រព្រឹត្តទៅជាគូ ។ ប្រសិនបើសួរថា ព្រះពុទ្ធនិមិត្តមានច្រើន ព្រោះហេតុអ្វី ទើបធ្វើជាឯកវចនៈថា **និម្មិតោ** ជាដើមបរិយាយ ។ ឆ្លើយថា ដើម្បីសម្តែងឥរិយាបថផ្សេង ៗ នៃព្រះពុទ្ធនិម្មិតមួយអង្គ ៗ ក្នុងបណ្តាព្រះពុទ្ធនិម្មិតទាំងឡាយ ។

កាលពោលជាពហុវចនៈ ព្រះពុទ្ធនិម្មិត សូម្បីទាំងអស់ក៏ដូចជាមានឥរិយាបថផ្សេង ៗ គ្នាក្នុងគ្រាតែមួយ ។ ប៉ុន្តែកាលពោលជាឯកវចនៈ ក្នុងបណ្តាព្រះពុទ្ធនិម្មិតមួយអង្គ ៗ រមែងប្រាកដថា មានព្រះឥរិយាបថផ្សេង ៗ ។ ព្រោះដូច្នោះ លោកទើបសំដែងជាឯកវចនៈ ។ សូម្បីព្រះចូឡបន្ថកត្ថេរ ក៏និម្មិតភិក្ខុមានឥរិយាបថផ្សេង ៗ ។ ទាំងពាន់រូប , ការវៀរព្រះចូឡ-បន្ថកត្ថេរចេញហើយ និម្មិតរូបផ្សេង ៗ របស់សាវកពួកដទៃមាន



ឥរិយាបថផ្សេង ៗ ដោយការនឹកគិតមួយគ្រា រមែងមិនសម្រេច ។ ព្រោះព្រះពុទ្ធនិម្មិតទាំងឡាយ រមែងមានឫទ្ធិដូចគ្នា ព្រោះមិនបានកំណត់ទុក ។ ព្រះពុទ្ធនិម្មិតទាំងឡាយ រមែងធ្វើវត្ថុដែលអ្នកមានឫទ្ធិ ធ្វើបានក្នុងការឈរ ការអង្គុយជាដើមក្តី ក្នុងការនិយាយ ការស្ងៀមជាដើមក្តី ។ ការធ្វើមិនដូចគ្នា និងធ្វើកិរិយាផ្សេង ៗ គ្នា រមែងសម្រេចដោយការនឹកគិតផ្សេង ៗ គ្នា ហើយអធិដ្ឋានថា ព្រះពុទ្ធនិម្មិត ប្រមាណប៉ុណ្ណេះ ចូរជាដូច្នេះ ។ ព្រះពុទ្ធនិម្មិតប្រមាណប៉ុណ្ណេះ ចូរធ្វើវត្ថុនេះ ។ ចំណែកការនិម្មិតច្រើនយ៉ាង រមែងសម្រេចដល់ព្រះតថាគត ដោយការនឹកអធិដ្ឋានមួយដងប៉ុណ្ណោះ ។ គប្បីជ្រាបក្នុងការនិម្មិតគំនរភ្លើង និងផ្ការទឹក ហើយក្នុងការនិម្មិតវណ្ណៈផ្សេង ៗ ដោយប្រការដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ភគវា ចង្កមតិ** គឺ ព្រះមានព្រះភាគជាម្ចាស់ ស្តេចចង្ក្រមក្នុងអាកាស ឬលើផែនដី ។ បទថា **និមិត្តោ** បានដល់ រូបព្រះពុទ្ធជាម្ចាស់និម្មិតដោយឫទ្ធិ ។ សូម្បីបទថា **តិដ្ឋតិ វា** ព្រះពុទ្ធនិម្មិតប្រថាប់ឈរជាអាទិ៍ បានដល់ ប្រថាប់ឈរក្នុងអាកាស ឬលើផែនដី ។ បទថា **កប្បេតិ** រមែង

សម្រេច គឺ ការធ្វើ ។

សូម្បីក្នុងបទមានជាអាទិ៍ថា **ភគវា តិដ្ឋតិ** ព្រះមានព្រះភាគជាម្ចាស់ប្រថាប់ឈរ ក៏មានន័យនេះដូចគ្នា ។

( ចប់ អដ្ឋកថាយមកប្បាដិហីរញ្ញាណនិទ្ទេស )



# អដ្ឋកថា អាសយានុសយញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ ក្នុងអាសយានុសយញ្ញាណនិទ្ទេស ដូចតទៅនេះ ។ បទមានជាអាទិ៍ថា **ឥធ តថាគតោ** ជានិទ្ទេស ដែលលោកតាំងទុក ៥ ចំណែក ។

ក្នុងបទទាំងនោះ បទថា **អាសយានុសយា** ឆន្ទៈដែលមកដេក និងកិលេសដែលដេកត្រាំ មានអត្ថដូចពោលទុកហើយ ។

បទថា **ចរិតំ** ចរិត គឺ កុសលកម្ម និងអកុសលកម្ម ដែលធ្វើទុក ហើយក្នុងជាតិមុន ៗ ។

បទថា **អធិមុត្តឹ** បានដល់ ការបណ្ដោយចិត្តទៅក្នុងកុសល ឬអកុសលក្នុងជាតិនេះ ។

បទថា **ភព្វាភព្វេ** បានដល់ ភព្វសត្វ និងអភព្វសត្វ ។ ឈ្មោះថា **ភព្វ** ព្រោះអត្ថថា រមែងសមភព គឺ រមែងកើតក្នុងអរិយជាតិ ជាពាក្យពោលដល់បច្ចុប្បន្នកាល ។ ម្យ៉ាងវិញទៀត ឈ្មោះថា **ភព្វ** ព្រោះនឹងកើត គឺ នឹងកើត ពោលដល់អនាគតកាល ។ អធិប្បាយថា ជាភាជនៈ

ទទួល ។ កព្វបុគ្គលទាំងនោះ ដល់ព្រមដោយឧបនិស្ស័យសមគួរដល់ការបាក់ធ្លុះអរិយមគ្គ ។ អកព្វបុគ្គលផ្ទុយគ្នា និងកព្វបុគ្គលដូចពោលហើយ ។

បទមានជាអាទិ៍ថា **កតមោ ច សត្តានំ អាសយោ** ក៏ធ្នូះជាទីមកដេកនៃសត្វទាំងឡាយ តើដូចម្តេច ? ជាបដិនិទ្ទេស គឺជាការសម្តែងសារឡើងវិញបទនិទ្ទេស ។

ក្នុងបទទាំងនោះ បទថា **សស្សតោ** គឺ ទៀង ។

បទថា **លោកោ** គឺ អត្តា ។ សត្វទាំងឡាយ រមែងសម្គាល់ថា សរីរៈប៉ុណ្ណោះសូន្យទៅក្នុងលោកនេះ ចំណែកអត្តានោះឯងមាននៅក្នុងលោកនេះ និងលោកដទៃ ។ សត្វទាំងឡាយធ្វើការសម្គាល់ថា ខ្លួននោះឯង រមែងមើលខ្លួន ទើបសម្គាល់ថា ខ្លួនជាលោក គឺ អត្តា ។បទថា **អសស្សតោ** គឺ មិនទៀង ។ សត្វទាំងឡាយសម្គាល់ថា អត្តា រមែងសូន្យទៅព្រមជាមួយសរីរៈនោះឯង ។ បទថា **អន្តវា** លោកមានទីបំផុត គឺ សត្វទាំងឡាយញ៉ាំងឈានឲ្យកើតក្នុងកសិណតិចតួច ហើយសម្គាល់ថាចិត្តមានកសិណតិចតួចនោះជាអារម្មណ៍ ជាអត្តាមានទីបំផុត ។ បទថា



**អនន្តវា** លោកមិនមានទីបំផុត គឺ សត្វទាំងឡាយញ៉ាំងឈានក្នុងកសិណមិនមានប្រមាណឲ្យកើតហើយ សម្គាល់ថា ចិត្តមានកសិណមិនមានប្រមាណនោះ ជាអត្តា មិនមានទីបំផុត ។ បទថា **តំ ជីវំ តំ សរីរំ** គឺ ជីវៈ ក៏ចំណែកនោះ សរីរៈក៏ចំណែកនោះបានដល់ ជីវៈ និងសរីរៈក៏ចំណែកនោះ នោះឯង ។ បទថា **ជីវោ** គឺ អត្តា ជានបុំសកលិង្គ ព្រោះលិង្គវិបលាស ។ បទថា **សរីរៈ** បានដល់ ខន្ធបញ្ចកៈ ព្រោះមានសភាពជាគំនរ ។ បទថា **អញ្ញំ ជីវំ អញ្ញំ សរីរំ** ជីវជាដទៃ សរីរៈក៏ជាដទៃ គឺ ជីវៈក៏មួយម្យ៉ាងខន្ធបញ្ចកក៏មួយម្យ៉ាង ។

បទថា **ហោតិ តថាគតោ បរម្មរណា** សត្វខាងមុខពីស្លាប់ទៅរមែងកើតទៀត គឺ ខន្ធសូន្យទៅក្នុងលោកនេះប៉ុណ្ណោះ សត្វខាងមុខអំពីស្លាប់ទៅនៅមាន មិនសូន្យ ។ ក្នុងបទថា **តថាគតោ** នេះ អាចារ្យពួកខ្លះពោលថា ជាឈ្មោះរបស់សត្វ ។ តែពួកខ្លះពោលថា បទថា **តថាគតោ** គឺព្រះអរហន្ត ។ សត្វទាំងឡាយពួកនេះ ឃើញទោសក្នុងចំណែកថា មិនមាន ទើបកាន់យកយ៉ាងនេះ ។

បទថា **ន ហោតិ តថាគតោ បរម្មរណា** សត្វខាងមុខពីស្លាប់ទៅរមែងកើតទៀត ក៏មិនមែន គឺ សូម្បីខន្ធសូន្យទៅក្នុងលោកនេះប៉ុណ្ណោះ សត្វខាងមុខពីស្លាប់ទៅ ក៏មិនមែនមិនវិនាសទៅ មិនដាច់សូន្យ សត្វទាំងឡាយពួកនេះ ឃើញទោសក្នុងចំណែកដែលមាន ទើបកាន់យកយ៉ាងនេះ ។

បទថា **ហោតិ ច ន ច ហោតិ** សត្វស្លាប់ទៅ ហើយកើតទៀតក៏មាន មិនកើតទៀតក៏មាន គឺ សត្វទាំងនេះឃើញទោសក្នុងការកំណត់យកតែចំណែកមួយ ៗ ហើយកាន់យកចំណែកទាំងពីរ ។

បទថា **នេវ ហោតិ ន ន ហោតិ** ស្លាប់ទៅហើយ កើតទៀត ក៏មិនមែនមិនកើតទៀតក៏មិនមែន គឺ សត្វទាំងនេះឃើញដល់ទោសទាំងពីរ ក្នុងការកំណត់ចំណែកទាំងពីរ ទើបកាន់យកចំណែកបដិសេធទាំងអស់ថា កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ។

តទៅនេះជាន័យរបស់អដ្ឋកថាក្នុងនិទ្ទេសនេះ លោកពោលដល់ប្រភេទនៃទិដ្ឋិដោយអាការ ១០ មានជាអាទិ៍ថា **សស្សតោ**



**លោកោតិ វា** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **សស្សតោ លោកោ** លោកទៀង គឺ ជាទិដ្ឋិដែលប្រព្រឹត្តទៅដោយអាការប្រកាន់មាំរបស់ អ្នកដែលប្រកាន់ថា ខន្ធបញ្ចកៈជាលោក ហើយប្រកាន់មាំថា លោកនេះទៀងជានិច្ច ប្រព្រឹត្តទៅរហូត ។

បទថា **អសស្សតោ** លោកមិនទៀង គឺ ជាទិដ្ឋិដែលប្រព្រឹត្តទៅដោយអាការប្រកាន់ថា សូន្យ របស់អ្នកប្រកាន់មាំដល់លោកថាសូន្យ ។

បទថា **អន្តវា** លោកមានទីបំផុត គឺ ទិដ្ឋិប្រព្រឹត្តទៅដោយអាការនៃការប្រកាន់ថា លោកមានទីបំផុតរបស់អ្នកប្រកាន់រូបធម៌ និងអរូបធម៌ ក្នុងខាងក្នុងសមាបត្តិរបស់អ្នកមានកសិណតិចតួចប្រមាណប៉ុនចង្អេរ ឬប្រមាណប៉ុនកែវថា លោកនោះឯងមានទីបំផុតដោយការកំណត់កសិណ ។

ទិដ្ឋិនោះ ជាសស្សតទិដ្ឋិខ្លះ ឧច្ឆេទទិដ្ឋិខ្លះ ។ ទិដ្ឋិដែលប្រព្រឹត្តទៅដោយអាការប្រកាន់ថា លោកមិនមានទីបំផុតរបស់អ្នកប្រកាន់រូបធម៌ និងអរូបធម៌ដែលប្រព្រឹត្តទៅខាងក្នុងសមាបត្តិ

របស់អ្នកចូលកសិណនោះ អ្នកបានកសិណបរិបូណ៌ថា លោកមិនមានទីបំផុតដោយកំណត់កសិណ ។ ទិដ្ឋិនោះ ជាសស្សតទិដ្ឋិខ្លះ ជាឧច្ឆេទទិដ្ឋិខ្លះ ។

បទថា **តំ ជីវំ តំ សរីរំ** ជីវៈក៏ចំណែកនោះ សរីរៈក៏ចំណែកនោះ គឺ ទិដ្ឋិដែលជាអាការប្រកាន់ការសូន្យថា កាលសរីរៈសូន្យសូម្បីជីវៈក៏សូន្យ ព្រោះប្រកាន់ថា ជីវៈរបស់សរីរៈនោះឯង មានការបែកធ្លាយទៅជាធម្មតា ។ ក្នុងបទទីពីរ ទិដ្ឋិប្រព្រឹត្តទៅដោយអាការប្រកាន់ការទៀងថា សូម្បីកាលសរីរៈសូន្យជីវៈក៏មិនសូន្យ ព្រោះប្រកាន់ថា ជីវៈដទៃពីសរីរៈ ។

ក្នុងបទនេះមានជាអាទិ៍ថា **ហោតិ តថាគតោ** មានសេចក្តីដូចតទៅនេះ ។

បុគ្គលប្រកាន់ថា សត្វស្លាប់ទៅហើយរមែងកើតទៀត ជាសស្សតទិដ្ឋិទី ១ ។

បុគ្គលប្រកាន់ថា មិនកើតទៀតជាឧច្ឆេទទិដ្ឋិទី ២ ។

បុគ្គលប្រកាន់ថា កើតទៀតក៏មាន មិនកើតទៀតក៏មាន ជាឯកច្ចសស្សតទិដ្ឋិទី ៣ ។



បុគ្គលប្រកាន់ថា កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ជាអមរាវិក្ខេបទិដ្ឋិទី ៤ ។

ស័ព្ទថា **ឥតិ** ជាស័ព្ទសម្តែងទិដ្ឋិនិស្ស័យដូចពោលហើយ ។

បទថា **ភវទិដ្ឋិសន្និស្សិតា វា សត្តា ហោន្តិ វិភវទិដ្ឋិសន្និស្សិតា វា** សត្វទាំងឡាយជាអ្នកអាស្រ័យទិដ្ឋិក្នុងភពក៏មាន អាស្រ័យទិដ្ឋិក្នុងការប្រាសចាកភពក៏មាន ។ សេចក្តីថា សភាពទៀងលោកពោលថា **ភព** ទិដ្ឋិកើតដោយអំណាចការទៀង ឈ្មោះថា **ភវទិដ្ឋិ** ។ អធិប្បាយថា បទថា **ភវោ** គឺ ទិដ្ឋិ ។ ការសូន្យលោកពោលថា **វិភវ** ។ ទិដ្ឋិកើតដោយអំណាចការសូន្យ ឈ្មោះថា **វិភវទិដ្ឋិ** ។ អធិប្បាយថា បទថា **វិភវោ** គឺ ទិដ្ឋិ ១០ ដូចពោលហើយ រមែងមាន ២ យ៉ាង គឺ ភវទិដ្ឋិ ១ វិភវទិដ្ឋិ ១ ។ ក្នុងទិដ្ឋិ ២ ទាំងនោះ សត្វទាំងឡាយអាស្រ័យទិដ្ឋិមួយ ៗ មិនឃើញហើយ ទើបជាប់ ។

**វា** ស័ព្ទក្នុងបទនេះថា **ឯតេ វា បន ឧភោ អន្តេ អនុបគម្ម** បុគ្គលមិនជាប់នៅទីបំផុតទាំងពីរនេះ ជាសមុច្ចយត្ថៈ គឺ មានអត្ថថា ប្រមូលមក ដូចក្នុងបទមានជាអាទិ៍ថា **អគ្គិតោ វា**

**ឧទកតោ វា មិថុភេទា វា** ពីភ្លើងក្តី ពីទឹកក្តី ពីការទំលាយមេត្រីក្តី ។ អធិប្បាយថា មិនដាច់នៅ គឺ មិនដាច់ទាំងពីរចំណែកដោយអំណាចសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ដូចពោលហើយនោះទើបលះ ។ **វា** សព្ទក្នុងបទថា **អនុលោមិកា វា ខន្តិ** ជាវិកប្បត្ថៈមានអត្ថថា កំណត់ ។

បទថា **ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ** ក្នុងធម៌ទាំងឡាយដែលមានវត្ថុនេះជាបច្ច័យ និងអាស្រ័យគ្នាកើតឡើង សេចក្តីថា បច្ច័យនៃជរា និងមរណៈជាដើម ឈ្មោះថា **ឥទប្បច្ចយ** ។ ឥទប្បច្ចយៈនោះឯង ឈ្មោះថា **ឥទប្បច្ចយតា** ។ ឬការប្រជុំឥទប្បច្ចយៈទាំងឡាយ ឈ្មោះថា **ឥទប្បច្ចយតា** ។ ម្យ៉ាងទៀត គប្បីស្វែងរកលក្ខណៈក្នុងបទ នេះដោយសព្ទសាស្ត្រ ។ ធម៌ទាំងឡាយកើតរួមគ្នាហើយ ដោយប្រពៃ ព្រោះអាស្រ័យបច្ច័យនោះ ៗ ឈ្មោះថា **បដិច្ចសមុប្បន្ន** ។ ក្នុងធម៌ទាំងឡាយ ព្រោះមានវត្ថុនេះ ជាបច្ច័យនោះឯងអាស្រ័យគ្នាកើតឡើងទាំងនោះ ។

បទថា **អនុលោមិកា** គឺ ឈ្មោះថា **អនុលោម** ព្រោះជាធម៌ សមគួរដល់លោកុត្តរធម៌ទាំងឡាយ ។



បទថា **ខន្តិ** គឺ ញាណ ។ ញាណ ឈ្មោះថា **ខន្តិ** ព្រោះការអត់ធន់ ។

បទថា **បដិលទ្ធា ហោតិ** រមែងដឹងបាន គឺ ដែលសត្វទាំងឡាយ បានចាក់ធ្លុះហើយ ។ ការចូលទៅអាស្រ័យត្រង់ខន្តិជាឥទប្បច្ច័យ ជារបស់សូន្យ រមែងមានដោយការឃើញយ៉ាងក្រៃលែងនៃផល ដោយការឃើញយ៉ាងក្រៃលែងនៃបច្ច័យ ព្រោះបច្ចយុប្បន្នធម៌ទាំងឡាយប្រព្រឹត្តទៅតាម ព្រោះក្នុងការព្រមព្រៀងនៃបច្ច័យ ។ ការចូលទៅអាស្រ័យ ដែលខន្តិជារបស់ទៀងក្នុងធម៌ដែលអាស្រ័យគ្នាកើតឡើង រមែងមានដោយការឃើញការកើតឡើងនៃបច្ចយុប្បន្នធម៌ទាំងឡាយថ្មី ៗ ព្រោះក្នុងការព្រមព្រៀងនៃបច្ច័យ ការឃើញប្រពៃ ដែលប្រព្រឹត្តទៅហើយថា មិនសូន្យ មិនទៀង ដោយការឃើញធម៌ដែលអាស្រ័យគ្នាកើតឡើង គឺ បដិច្ចសមុប្បាទ មិនចូលទៅជិតទីបំផុតទាំងពីរយ៉ាងនេះ គប្បីជ្រាបថា អនុលោមិកខន្តិ គឺ ខន្តិដែលសមគួរ ដោយប្រការដូច្នេះ ជាចំណែកលោកពោលដល់សម្មាទិដ្ឋិដែលជាបដិបក្ខចំពោះទិដ្ឋិទាំងពីរនោះ ។

បទថា **យថាភូតំ វា ញាណំ** យថាភូតញាណ គឺ ញាណដែលនាំទៅតាមសេចក្ដីពិត គឺ តាមសភាពដែលពិត ។ សូម្បីញាណដែលប្រព្រឹត្តទៅក្នុងបទនោះ លោកក៏ពោលថា **យថាភូតញ្ញាណ** ដោយវោហារដែលជាវិស័យ ។ ក្នុងនិទ្ទេសនេះ លោកបំណងយកវិបស្សនាញាណ ដែលមានសង្ខារុបេក្ខាញាណជាទីបំផុត ។ តែខាងក្រោយលោកពោលកយតូបដ្ឋានញាណថា យថាភូតញ្ញាណទស្សនៈ ។ ឬគួរសម្ព័ន្ធថា យថាភូតញ្ញាណ ជាចំណែកដែលសត្វទាំងឡាយបានហើយ ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ គ្រាសំដែងសន្តាននៃសត្វដែលជាមិច្ឆាទិដ្ឋិ ដោយបទមានជាអាទិ៍ថា **សស្សតោ លោកោ** ដែលសម្មាទិដ្ឋិអប់រំ ដោយបទមានជាអាទិ៍ថា **ឯតេ វា បន** ទីបំផុតទាំងពីរយ៉ាងនេះ ហើយសម្ដែងសន្តាននៃសត្វចំណែកអកុសលដ៏សេស និងកុសលដ៏សេសអប់រំហើយ ដោយបទមានជាអាទិ៍ថា **កាមំ សេវន្តញ្ញេវ** បុគ្គលអ្នកសេពកាម ។ ក្នុងបទនោះគប្បីប្រកបថា ព្រះតថាគតទ្រង់ជ្រាបបុគ្គលអ្នកសេពកាម ។

បទថា **សេវន្តញ្ញេវ** គឺ អ្នកសេពដោយការប្រព្រឹត្តរឿយ ៗ ។



ឈ្មោះថា **កាមគរុកោ** ព្រោះមានកិលេសកាមធ្ងន់ ដោយសេពមកក្នុងកាលមុន ។

ឈ្មោះថា **កាមាសយោ** ព្រោះមានកាមក្នុងសន្តានជាទីអាស្រ័យ ។

ឈ្មោះថា **កាមាធិមុត្តោ** ព្រោះបង្អោន គឺ ជាប់ក្នុងកាមដោយអំណាចសន្តាននោះឯង ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះដូចគ្នា ។

ពាក្យថា **នេក្ខម្ម** ជាដើម មានអត្ថដូចពោលហើយ ។ គប្បីជ្រាបថា អកុសលដ៏សេស លោកកាន់យកដោយកិលេស ៣ យ៉ាង មានកាមជាដើម ។ កុសលដ៏សេស លោកកាន់យកដោយគុណធម៌ ៣ យ៉ាងមាននេក្ខម្មៈជាដើម ។ ព្រះសារីបុត្តត្ថេរ សម្ដែងសន្តានដែលលោកពោល ៣ យ៉ាងថា នេះជាកិលេសដែលដេកត្រាំក្នុងសត្វទាំងឡាយ ។

ចំណែកក្នុងនិទ្ទេសនេះ មានន័យរបស់អដ្ឋកថាដូចតទៅនេះ ។ បទថា **ឥតិ ភវទិដ្ឋិសន្និស្សិតា វា** សត្វទាំងឡាយអាស្រ័យទិដ្ឋិក្នុងភព ដោយអាការយ៉ាងនេះ គឺ អាស្រ័យសស្សត-

ទិដ្ឋិយ៉ាងនេះ ។ ពិតណាស់ ក្នុងទីនេះលោកពោលសស្សតទិដ្ឋិថាជា **ភវទិដ្ឋិ** ។ ហើយពោលឧច្ឆេទទិដ្ឋិថាជា **វិភវទិដ្ឋិ** ។ ព្រោះសត្វអ្នកមានទិដ្ឋិទាំងឡាយទាំងនេះ អាស្រ័យទិដ្ឋិ ២ យ៉ាងទាំងនេះឯង ព្រោះលោកសង្គ្រោះទិដ្ឋិទាំងអស់ចូលផង សស្សតទិដ្ឋិនិងឧច្ឆេទទិដ្ឋិ ។ សូម្បីមាតិកានេះព្រះមានព្រះភាគក៏ត្រាស់ថា ៖

**ម្នាលកច្ចាន: ដោយច្រើនសត្វលោកអាស្រ័យទិដ្ឋិ ២ យ៉ាងនេះ គឺ ការមាន ១ ការមិនមាន ១ ។**

ក្នុងពីរបទនេះ បទថា **អត្ថិតា** ការមាន បានដល់ សស្សតទិដ្ឋិ ។ បទថា **នត្ថិតា** ការមិនមាន បានដល់ ឧច្ឆេទទិដ្ឋិ ។ នេះជាធម្ម:ដែលមកដេកត្រាំក្នុងសត្វទាំងឡាយជាបុថុជ្ជនអាស្រ័យវដ្ដ: ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ កាលសម្ដែងកិលេស ដែលដេកត្រាំក្នុងសត្វអ្នកបរិសុទ្ធិ អ្នកអាស្រ័យវដ្ដ: ទើបពោលបទមានជាអាទិ៍ថា **ឯតេ វា បន ឧភោ អន្តេ អនុបគម្ម** មិនចូលទៅជិតទីបំផុត ២ យ៉ាងទាំងនេះ ។ ក្នុងបទទាំងនោះ បទថា **ឯតេ វា បន** ក៏គឺ **ឯតេ** នោះឯង ។ បទថា **ឧភោ អន្តេ** គឺទីបំផុតពីរយ៉ាង បានដល់ សស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ។ បទថា **អនុបកម្ម** គឺមិនទាក់ទង ។ បទថា **ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ** គឺ ព្រោះវត្ថុនេះជាបច្ច័យ និងក្នុងធម៌ទាំងឡាយដែលអាស្រ័យគ្នាកើតឡើង ។ បទថា **អនុលោមិកា ខន្តិ** អនុលោមិកខន្តិ គឺ វិបស្សនាញាណ ។ បទថា **យថាភូតំ ញាណំ** គឺ មគ្គញ្ញាណ ។ នេះលោកអធិប្បាយទុកថា វិបស្សនាណាដែលបានកើតហើយ ព្រោះមិនជាប់នៅចំណែកទីបំផុតទាំងពីរ គឺ សស្សតិទិដ្ឋិនិងឧច្ឆេទទិដ្ឋិ ក្នុងបដិច្ចសមុប្បាទ និងធម៌ ដែលអាស្រ័យគ្នាកើតឡើង ។ ហើយមគ្គញ្ញាណណា ដែលបានហើយក្រៃលែងជាង ថាវិបស្សនានោះ ។ នេះជាធម្ម:ជាទីមកដេករបស់សត្វទាំងឡាយ ។ នេះជាទីមកដេក គឺ មគ្គញ្ញាណនេះជាទីនៅរបស់សត្វទាំងឡាយ សូម្បីទាំងអស់ដែលអាស្រ័យវដ្ដ: និងអាស្រ័យវិវដ្ដ: ។ នេះជាអដ្ឋកថា ដែលពួកអាចារ្យឃើញដូចគ្នាដែរ ។



ចំណែកអាចារ្យវិតណ្ឌវាទីសំដែងថា ឈ្មោះថា មគ្គ គឺ ទម្លាយទីនៅ ។ លោកនៅនិយាយថា មគ្គជាទីនៅ ។ គួរសួរ

អាចារ្យនោះថា លោកជាអ្នកពោលថា មគ្គជាទីនៅនៃព្រះអរិយជាម្ចាស់ ឬមិនមែន ។ ប្រសិនអាចារ្យនោះ ឆ្លើយថា យើងមិនមែនជាអ្នកពោល ។ គួរប្រាប់ថា លោកមិនដឹង ព្រោះលោកមិនបានពោល ។ ប្រសិនឆ្លើយថា យើងជាអ្នកពោល ។ គួរប្រាប់ថា នាំព្រះសូត្រមកមើលចុះ ។ ប្រសិននាំមកបាន ក៏ជាការល្អ ។ ប្រសិននាំមកមិនបាន គួរនាំមកខ្លួនឯងថា **ទសយិមេ ភិក្ខវេ អរិយវាសា , យេ អរិយា អាវសឹសុ វា អាវសន្តិ វា អាវសិស្សន្តិ វា** ម្នាលភិក្ខុទាំងឡាយ ព្រះអរិយទាំងឡាយពួកណា នៅហើយ កំពុងនៅ ឬនឹងនៅ ។ អរិយវាសៈទាំងនេះមាន ១០ យ៉ាង ដូច្នេះ ។ ពិតណាស់ ព្រះសារីបុត្តត្ថេរសម្តែងសូត្រជាទីនៅនៃមគ្គ ។ ព្រោះដូច្នោះ នោះជាការពោលត្រឹមត្រូវហើយ ។ ម្យ៉ាងទៀត ព្រះមានព្រះភាគជាម្ចាស់ទ្រង់ជ្រាបអាសយៈនេះ របស់សត្វទាំងឡាយ ទាំងទ្រង់ជ្រាបសូម្បីក្នុងខណៈប្រព្រឹត្តទៅមិនបាននៃទិដ្ឋិទាំងនេះ និងវិបស្សនាញាណ មគ្គញាណទៀតផង ។ ព្រោះដូច្នោះឯង លោកទើបពោលបទមានជាអាទិ៍ថា **កាមំ សេវន្តំ យេវ ជានាតិ** ព្រះតថាគតរមែងទ្រង់ជ្រាបបុគ្គល



អ្នកសេពកាម ។

គប្បីជ្រាបអធិប្បាយ ក្នុងអនុសយនិទ្ទេសដូចតទៅនេះ ។ បទថា **អនុសយា** ឈ្មោះថាអនុស័យ ព្រោះអត្ថថាយ៉ាងណា ? ព្រោះអត្ថថា ការដេកត្រាំ ។ អ្វីហ្ន៎ ឈ្មោះថា ដេកត្រាំ ? កិលេសដែលនៅមិនបានលះ ។ ពិតណាស់ កិលេសទាំងនេះរមែងដេកត្រាំក្នុងសន្តានរបស់សត្វនោះ ៗ ព្រោះអត្ថថា នៅមិនទាន់បានលះ ។ ព្រោះដូច្នោះ លោកទើបពោលថា **អនុសយ** ។

បទថា **អនុសេន្តិ** រមែងដេកត្រាំ គឺ បានហេតុដែលសមគួរហើយទើបកើត ។ កាលជាដូច្នេះគប្បីមានពាក្យនិយាយថា ការពោលថា អាការដែលនៅមិនបានលះ ឈ្មោះថា ជាសភាពនៃអនុស័យ ហើយអនុស័យនោះ រមែងកើតឡើងដូច្នេះមិនត្រូវ ។ ព្រោះអនុស័យកើតឡើងមិនបាន ។ ពាក្យឆ្លើយមានដូច្នេះ

**អនុស័យមិនមែន អាការដែលនៅមិនបានលះ**
**តែលោកពោលដល់កិលេស ដែលមានកំលាំង**
**ព្រោះអត្ថថា នៅមិនទាន់បានលះថាជាអនុស័យ ។**

អនុស័យនោះ សម្បយុត្តដោយចិត្ត មានអារម្មណ៍មានហេតុ

ព្រោះអត្ថថា ប្រព្រឹត្តទៅជាមួយបច្ច័យជាអកុសលតែម្យ៉ាង ជាអតីតខ្លះ ជាអនាគតខ្លះ ជាបច្ចុប្បន្នខ្លះ ព្រោះដូច្នោះ ការពោលថា អនុស័យកើតឡើងទើបត្រូវ ។ ការកំណត់នេះលោកពោលទុកក្នុងអភិសមយកថា ដោយតាំងពាក្យសួរមុនថា **បច្ចុប្បន្នេ កិលេសេ បជហតិ** បុគ្គល រមែងលះកិលេសទាំងឡាយដែលជាបច្ចុប្បន្នបាន ឬពោលវិសជ្ជនាថា **ថាមគតោ អនុសយំ បជហតិ** អ្នកមានកិលេស មានកម្លាំងក៏លះអនុស័យបាន ព្រោះសភាពនៃអនុស័យ ជាកិលេស មាននូវក្នុងបច្ចុប្បន្ន ។

ក្នុងបទភាជនីយ៍នៃមោហៈក្នុងអភិធម្មសង្គណី លោកពោលសភាពនៃមោហៈកើតជាមួយអកុសលចិត្តថា អនុស័យ គឺ អវិជ្ជា , បរិយុដ្ឋាន គឺ អវិជ្ជា , មូល គឺ អវិជ្ជា , អកុសលមូល គឺ អវិជ្ជា ក្នុងសម័យនោះយ៉ាងណា នេះឈ្មោះថាមោហៈមានក្នុងសម័យនោះ ។ ក្នុងកថាវត្ថុ លោកពោលទុកថា អនុស័យ ជាអព្យាកតៈ ជាអហេតុកៈ មិនប្រកបដោយចិត្ត វាទៈទាំងអស់ត្រូវបដិសេធ ។ ក្នុងឧប្បជ្ជនវារៈ វារៈណាមួយនៃ ៧ វារៈ ក្នុងអនុសយយមកៈ លោកពោលបទមានជាអាទិ៍ថា



**កាមរាគានុស័យកើតឡើងដល់អ្នកណា ។ បដិ-**
**ឃានុស័យ រមែងកើតឡើងដល់អ្នកនោះ ។**

ព្រោះដូច្នោះ គប្បីជ្រាបថា បទថា **អនុសេន្តិ** ដែលលោកពោលថា អនុស័យមានហេតុ ដែលសមគួរហើយរមែងកើតបាន ដូច្នេះទើបត្រឹមត្រូវ ដោយការកំណត់បែបផែននេះ សូម្បីពាក្យដែលលោកពោលថា **ចិត្តសម្បយុត្តា សារម្មណា** អនុស័យនោះ សម្បយុត្តដោយចិត្តមានអារម្មណ៍ ដូច្នេះទើបជាការពោលល្អហើយ ។ ព្រោះអនុស័យនេះ ជាអកុសលធម៌ សម្បយុត្តដោយចិត្ត សម្រេចហើយ ដូច្នោះ ក្នុងទីនេះគួរយល់ព្រមបាន ។

ក្នុងបទមានជាអាទិ៍ថា **កាមរាគានុសយោ** មានសេចក្ដីដូចតទៅនេះ ឈ្មោះថា **កាមរាគានុស័យ** ព្រោះកាមរាគៈនោះជាអនុស័យ ដោយសភាពដែលលះមិនបាន ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ ម្យ៉ាងទៀត **កាមរាគានុស័យ** ក្នុងទីនេះជាលោភៈ កើតឡើងដោយអំណាចអារម្មណ៍ក្នុងកាមាវចរធម៌ដ៏សេស ដោយការកើតរួមគ្នាក្នុងចិត្ត សហគតៈដោយលោភៈ និងដោយអារម្មណ៍ដែលគួរពេញចិត្ត ។

ម្យ៉ាងទៀត **បដិឃានុស័យ** ជាទោសៈ កើតឡើងដោយអំណាចនៃធម៌ដែលកើតរួមគ្នាក្នុងចិត្ត ដែលសហគតៈដោយទោមនស្ស ដោយអំណាចអារម្មណ៍ និងដោយអំណាចនៃអារម្មណ៍ក្នុងធម៌ជាកាមាវចរៈដ៏សេស ដែលមិនគួរប្រាថ្នា ។

**មានានុស័យ** ជាមានះកើតឡើង ដោយអំណាចកើតរួមគ្នាក្នុងចិត្ត សហគតៈដោយលោភៈ ដែលប្រាសចាកទិដ្ឋិ ដោយអំណាចអារម្មណ៍ និងដោយអំណាចអារម្មណ៍ក្នុងធម៌ជាកាមាវចរដ៏សេស និងក្នុងធម៌ជារូបាវចរៈ អរូបាវចរៈ ដែលវៀរទុក្ខវេទនា ។

**ទិដ្ឋានុស័យ** កើតក្នុងចិត្ត សម្បយុត្តដោយទិដ្ឋិ ៤ ។

**វិចិកិច្ឆានុស័យ** កើតក្នុងចិត្ត សហគតៈដោយវិចិកិច្ឆា ។

**អវិជ្ជានុស័យ** កើតដោយអំណាចនៃសហជាតធម៌ក្នុងអកុសលចិត្ត ១២ ដោយអំណាចអារម្មណ៍ , ទិដ្ឋិ វិចិកិច្ឆា មោហៈ សូម្បី ៣ យ៉ាង កើតឡើងដោយអំណាចអារម្មណ៍ ក្នុងតេភូមិកធម៌ដ៏សេសនោះឯង ។

**ភវរាគានុស័យ** សូម្បីកើតក្នុងចិត្តប្រាសចាកទិដ្ឋិ ៤ លោក



ក៏មិនពោលដោយអំណាចសហជាត គឺ ការកើតរួមគ្នា ។ ប៉ុន្តែលោកពោលដល់លោភៈកើតក្នុងរូបាវចរធម៌ និងអរូបាវចរធម៌ដោយអារម្មណ៍ប៉ុណ្ណោះ ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ កាលនឹងសម្តែងដល់ឋានៈនៃកិលេសដែលដេកត្រាំរបស់អនុស័យ ដូចដែលពោលមកហើយ ទើបពោលបទមានជាអាទិ៍ថា **យំ លោកេ** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **យំលោកេ បិយរូបំ** អារម្មណ៍ដែលគួរប្រាថ្នាក្នុងលោក គឺ អារម្មណ៍ដែលមានសភាពគួរប្រាថ្នាពីកំណើត ដែលគួរប្រាថ្នាក្នុងលោកនេះ ។

បទថា **សាតរូបំ** អារម្មណ៍ដែលគួរត្រេកអរ គឺ អារម្មណ៍ដែលគួរត្រេកអរពីកំណើត ដែលមានការសរសើរជាបទដ្ឋាន ។

បទថា **ឯត្ថ សត្តានំ កាមរាគានុសយោ អនុសេតិ** កាមរាគានុស័យនៃសត្វទាំងឡាយ រមែងដេកត្រាំក្នុងអារម្មណ៍នេះ គឺ កាមរាគានុស័យ មានសភាពនៅមិនទាន់បានលះរបស់សត្វទាំងឡាយ រមែងដេកត្រាំក្នុងអារម្មណ៍ដែលគួរប្រាថ្នានេះ ។ ម្យ៉ាងទៀត ធម៌ គឺ កាមាវចរៈ លោកបំណងយកក្នុងទីនេះថា **បិយរូបំ**

**សាតរូបំ** ។

ដូចជា បុគ្គលស្ងួតទឹក ទាំងខាងក្រោមខាងលើ និងដោយជុំវិញ ក៏ជាទឹកទាំងអស់ យ៉ាងណា ។ ឈ្មោះថា រាគៈកើតក្នុងឥដ្ឋារម្មណ៍ ក៏ដូច្នោះ ជាការប្រព្រឹត្ត ជាការសន្សំរបស់សត្វទាំងឡាយ ។ ការកើតបដិឃៈក្នុងអនិដ្ឋារម្មណ៍ ក៏ដូចគ្នា ។

ឬថា **ឥតិ ឥមេសុ ទ្វីសុ ធម្មេសុ** ក្នុងធម៌ពីរយ៉ាងទាំងនេះ ក៏យ៉ាងនេះ គឺ ក្នុងធម៌ជាឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ពីរយ៉ាងនោះ ក៏យ៉ាងនេះ ។

បទថា **អវិជ្ជា អនុបតិតា** អវិជ្ជាធ្លាក់ទៅតាម គឺ អវិជ្ជាសម្បយុត្តដោយដោយកាមរាគៈ និងបដិឃៈធ្លាក់ទៅតាម គឺ ទៅតាមដោយអំណាចធ្វើឲ្យជាអារម្មណ៍ ។ បាឋៈ លោកកាត់បទជា **អវិជ្ជា អនុបតិតា អនុគតា** ក៏មាន ។

បទថា **តទេកដ្ឋោ** តាំងនៅរួមគ្នាជាមួយនឹងអវិជ្ជា នោះ គឺ តាំងនៅដោយការនៅជាមួយអវិជ្ជានោះ ដោយតាំងនៅជាមួយគ្នា ព្រោះកើតរួមគ្នា ។

បទថា **មានោ ច ទិដ្ឋិ ច វិចិកិច្ឆា ច** បានដល់ មានះ ៩



ទិដ្ឋិ ៦២ វិចិកិច្ឆា ៨ ។ យោជនាកែថា មានះ ទិដ្ឋិ វិចិកិច្ឆា តាំងនៅរួមជាមួយអវិជ្ជានោះ ។

បទថា **ទដ្ឋព្វា** គប្បីឃើញ គឺ គប្បីមើល គប្បីតាមចូលទៅ ។ ធ្វើទាំងបីរួមគ្នា ឲ្យទៅជាពហុវចនៈ ។ម្យ៉ាងទៀត ភវរាគានុស័យក្នុងនិទ្ទេសនេះ គប្បីជ្រាបថា លោកសង្គ្រោះដោយកាមរាគានុស័យ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងចរិតនិទ្ទេសដូចតទៅនេះ ។ ចេតនា ១៣ ជាបុញ្ញាភិសង្ខារ ។ ចេតនា ១២ ជាអបុញ្ញាភិសង្ខារ ។ ចេតនា ៤ ជាអនេញ្ជាភិសង្ខារ ។

ក្នុងបទទាំងនោះ កាមាវចរៈជាបរិត្តភូមិ ។ ក្រៅពីនោះជាមហាភូមិ ។

ម្យ៉ាងទៀត គប្បីជ្រាបថា ក្នុងអភិសង្ខារ ៣ ទាំងនេះ អភិសង្ខារណា មានវិបាកតិច ជាបរិត្តភូមិ ។ មានវិបាកច្រើនជាមហាភូមិ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងអធិមុត្តិនិទ្ទេសដូចតទៅនេះ ។

បទថា **សន្តិ** បានដល់ មាន ។

បទថា **ហីនាធិមុត្តិកា** មានអាធិមុត្តិអន់ថយ គឺ មានអធ្យាស្រ័យលាមក ។

បទថា **បណីតាធិមុត្តិកា** មានអធិមុត្តិប្រណិត គឺ មានអធ្យាស្រ័យល្អ ។

បទថា **សេវន្តិ** រមែងសេព គឺ អាស្រ័យ ទាក់ទង ។

បទថា **ភជន្តិ** រមែងគប់ គឺ ចូលទៅអង្គុយជិត ។

បទថា **បាយិរុបាសតិ** ចូលទៅរក គឺ ទៅចូលរករឿយ ៗ ។

ប្រសិនបើពោលថា អាចារ្យ និងឧបជ្ឈាយ៍ ជាអ្នកមិនមានសីល ។ អន្តេវាសិក និងសទ្ធិវិហារិក ជាអ្នកមានសីល គេនឹងមិនចូលទៅអង្គុយជិត សូម្បីអាចារ្យ និងឧបជ្ឈាយ៍របស់ខ្លួន ។ នឹងចូលទៅរកភិក្ខុអ្នកសមគួរដូចជាខ្លួនប៉ុណ្ណោះ ។

ប្រសិនបើថា អាចារ្យ និងឧបជ្ឈាយ៍ ជាភិក្ខុសមគួរ គឺ មានសីល ភិក្ខុក្រៅអំពីនោះមិនសមគួរ ។ ភិក្ខុទាំងនោះ ក៏នឹងមិនចូលទៅរកអាចារ្យ និងឧបជ្ឈាយ៍ នឹងចូលទៅរកភិក្ខុអ្នកមានអធិមុត្តិអាក្រក់ដូចនឹងខ្លួន ។

មួយ៉ាងទៀត ការចូលទៅរកយ៉ាងនេះ មិនមែនមានតែក្នុង



ឥឡូវនេះប៉ុណ្ណោះ ។ ព្រះសារីបុត្តត្ថេរសម្ដែងថា សូម្បីក្នុងអតីត និងអនាគតក៏មាន ទើបពោលបទមានជាអាទិ៍ថា **អតីតម្បិ អទ្ធានំ** កាលដ៏យូរយោ សូម្បីកន្លងទៅហើយ ។

ក្នុងបទទាំងនោះ បទថា **អតីតម្បិ អទ្ធានំ** គឺ ក្នុងអតីតកាល , បទដ៏សេសមានអត្ថងាយទាំងអស់ ។ សួរថា អ្នកទ្រុស្តសីល សេពអ្នកទ្រុស្តសីល ។ អ្នកមានសីលសេពអ្នកមានសីល ។ អ្នកមានបញ្ញាទន់ខ្សោយ សេពអ្នកមានបញ្ញាទន់ខ្សោយ អ្នកមានបញ្ញា សេពអ្នកមានបញ្ញា ។ អ្នកណាកំណត់ទុក , ឆ្លើយថា ធាតុនៃអធ្យាស្រ័យកំណត់ទុក ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងភព្វាភព្វនិទ្ទេសដូចតទៅនេះ ។ ព្រះសារីបុត្តត្ថេរ ដើម្បីសម្ដែងរបស់ដែលគួរលះបង់មុន ហើយសម្ដែងរបស់ដែលគួរកាន់យកក្នុងពេលក្រោយ ទើបសម្ដែងអភព្វសត្វមុន ក្រៅលំដាប់នៃឧទ្ទេស ។ តែក្នុងឧទ្ទេស លោកប្រកប **ភព្វ** ស័ព្ទ មុនដោយអំណាចលក្ខណៈនិបាត ខាងដើមនៃបទដែលគួរកាន់យក និងមានអក្ខរៈទន់ក្នុងទ្វន្ទ្វសមាស ។

បទថា **កម្មាវរណេន** ដោយធម៌ជាគ្រឿងបិទបាំង គឺ កម្ម

បានដល់ អនន្តរិយកម្ម ៥ យ៉ាង ។

ឈ្មោះថា **សមន្នាគតា** ប្រកបហើយ គឺ មានការព្រមព្រៀងហើយ ។

បទថា **កិលេសាវរណេន** ដោយធម៌ដែលជាគ្រឿងបិទបាំង គឺ កិលេស បានដល់ និយតមិច្ឆាទិដ្ឋិ ។ ទាំងពីរបទនេះ ឈ្មោះថា **អាវរណៈ** ព្រោះបិទបាំងស្ថានសួគ៌ និង មគ្គ ។ សូម្បីកម្ម មានការប្រទូសរ៉ាយភិក្ខុនីជាដើម លោកក៏សង្គ្រោះដោយធម៌ជាគ្រឿងបិទបាំង គឺ កម្មនោះឯង ។

បទថា **វិបាកាវរណេន** ដោយធម៌ជាគ្រឿងរាំង គឺ វិបាក បានដល់ អហេតុកបដិសន្ធិ , ព្រោះការចាក់ធ្លុះអរិយមគ្គ រមែងមិនមាន សូម្បីដល់ទុហេតុកៈ ។ ដូច្នោះ គប្បីជ្រាបថា សូម្បីបដិសន្ធិជាទុហេតុកៈ ក៏ជាធម៌រាំង គឺ វិបាកនោះឯង ។

បទថា **អស្សទ្ធា** ជាអ្នកមិនមានសទ្ធា គឺ មិនមានសទ្ធាក្នុងព្រះពុទ្ធជាដើម ។

បទថា **អច្ឆន្ទិកា** មិនមានឆន្ទៈ គឺ មិនមានឆន្ទៈក្នុងកុសល គឺ ភាពជាអ្នកប្រាថ្នាដើម្បីនឹងធ្វើ ។ ពួកមនុស្សដែនឧត្តរកុរុចូលទៅកាន់ឋានៈមិនមានការពេញចិត្ត ។



បទថា **ទុប្បញ្ញា** ឥតបញ្ញា គឺ វិនាសចាកអំពីភវង្គប្បញ្ញា ។ ម្យ៉ាងទៀត សូម្បីកាលភវង្គប្បញ្ញាបរិបូរ ភវង្គរបស់អ្នកណា មិនមែនជាបាទរបស់លោកុត្តរៈ សូម្បីអ្នកនោះ ក៏មានឈ្មោះថាជាអ្នកឥតបញ្ញានោះឯង ។

បទថា **អភព្វា និយាមំ ឱក្កមិតុំ កុសលេសុ ធម្មេសុ សម្មត្តំ** មិនអាចឈានចុះកាន់សម្មត្តនិយាម ក្នុងកុសលធម៌ទាំងឡាយ គឺ មិនឈានចូលដល់អរិយមគ្គ ពោលគឺ សម្មត្តនិយាមក្នុងកុសលធម៌ទាំងឡាយ ។ ព្រោះអរិយមគ្គ ជាសភាវៈដោយប្រពៃ ទើបឈ្មោះថា **សម្មត្ត** ។ អរិយមគ្គនោះឯង ជាសម្មត្តៈក្នុងការឲ្យផលក្នុងលំដាប់ ។ ឬថា អ្នកមិនមានសទ្ធា មិនមានឆន្ទៈ មិនមានបញ្ញា មិនអាចឈានចុះ គឺ ចូលទៅកាន់សម្មត្តនិយាមនោះ ព្រោះខ្លួនឯងជាអ្នកល្ងង់ខ្លៅ ។

បទមានជាអាទិ៍ថា **ន កម្មាវរណេន** គប្បីជ្រាបដោយផ្ទុយនឹងបទដូចពោលហើយនុ៎ះឯង ។

( ចប់អដ្ឋកថា អាសយានុសយញ្ញាណនិទ្ទេស )

## អដ្ឋកថា មហាករុណាញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ ក្នុងមហាករុណាញាណនិទ្ទេសដូចតទៅនេះ ។ បទថា **ពហុកេហិ អាការេហិ** ដោយអាការច្រើនយ៉ាង គឺ ដោយប្រការ ៨៩ យ៉ាង ដែលនឹងពោលក្នុងពេលនេះ ។

បទថា **បស្សន្តានំ** ទ្រង់ពិចារណាឃើញហើយ គឺ ទ្រង់ពិចារណាហើយដោយញាណចក្ខុ និងពុទ្ធចក្ខុ ។

បទថា **ឱក្កមតិ** ទ្រង់ផ្សាយ គឺ ទ្រង់ញុំាងចុះស៊ប់ ទ្រង់ចូលទៅ ។

បទថា **អាទិត្តោ** គឺ ដែលភ្លើងឆេះជាប់ជានិច្ច ដោយសភាពក្តៅក្រហល់ក្រហាយ ចាកការបៀតបៀនដោយទុក្ខលក្ខណៈ ។ គប្បីជ្រាបថា លោកពោលថា **អាទិត្តោ** ដោយអំណាចទុក្ខលក្ខណៈនៃសង្ខតធម៌ទាំងពួង ព្រោះព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកថា **យទនិច្ចំ តំ ទុក្ខំ** វត្ថុណាមិនទៀង វត្ថុនោះជាទុក្ខ និងដោយអំណាចទុក្ខលក្ខណៈលើកដំបូង ព្រោះត្រូវទុក្ខបៀតបៀន និងព្រោះព្រះមហាករុណាជាឫសគល់ ។ នឹងពោលសភាពក្តៅដោយរាគៈជាដើម ខាងមុខ ។



ម្យ៉ាងមួយទៀត បទថា **អាទិត្តោ** គឺ ក្តៅដោយរាគៈជាដើមនោះឯង ។ ចំណែកខាងមុខ គប្បីជ្រាបថា លោកពោលទៀតដោយអំណាចការសម្លឹងដល់អត្ថថា មិនមានអ្វី ៗ ដទៃរលត់សេចក្តីក្តៅ គឺ រាគៈនោះបាន ។

បទថា **លោកសន្និវាសោ** លោកសន្និវាស បានដល់បញ្ចក្ខន្ធ ឈ្មោះថា **លោក** ដោយអត្ថថា បែកធ្លាយ ។ ឈ្មោះថា **សន្និវាស** ព្រោះជាទីអាស្រ័យរបស់សត្វទាំងឡាយ ដោយអំណាចតណ្ហា និងទិដ្ឋិ ។ ទីអាស្រ័យ គឺ លោកនោះឯង ឈ្មោះថា **លោកសន្និវាស** ។ សូម្បីពពួកសត្វ ក៏ឈ្មោះថា **លោកសន្និវាស** ព្រោះជាទីអាស្រ័យរបស់សត្វលោក ដែលតែងហៅថា **សត្វ** ព្រោះអាស្រ័យខន្ធសន្តានដែលជាទុក្ខ ។ សូម្បីលោកសន្និវាសនោះ ក៏ប្រព្រឹត្តទៅជាមួយខន្ធដូចគ្នា ។

បទថា **ឧយ្យុត្តោ** លោកសន្និវាសខ្វល់ខ្វាយជានិច្ច គឺ ធ្វើសេចក្តីព្យាយាម ធ្វើសេចក្តីឧស្សាហៈ ព្រោះខ្វល់ខ្វាយជានិច្ចក្នុងកិច្ចច្រើនយ៉ាង ។ អធិប្បាយថា មានសេចក្តីខ្វល់ខ្វាយ ក្នុងសព្វកិច្ចទាំងឡាយ ។ ឬប្រកបដោយ សេចក្តីព្យាយាម គឺ ខ្វល់-

ខ្វាយ ។

បទថា **បយាតោ** លោកសន្និវាសមានដំណើរទៅជានិច្ច គឺ ដំណើរទៅស្លាប់ ដោយដល់ការមិនតាំងមាំ ដូចទន្លេដែលកើតអំពីភ្នំ ។

បទថា **កុម្មគ្គំ បដិបន្នោ** លោកសន្និវាសដំណើរទៅកាន់ផ្លូវខុស គឺ ដំណើរខុសដ៏យ៉ាងអាក្រក់ ។ ចំណែកខាងមុខលោកពោលផ្សេងគ្នាដោយបទផ្សេង ៗ ថា **វិបថបក្ខន្តោ** ស្ទុះទៅកាន់ផ្លូវខុស ។

បទថា **ឧបនីយតិ** លោកដែលជរានាំចូលទៅ គឺ ដែលជរានាំចូលទៅរកមរណៈ ។ ព្រោះលោកពោលជរាថា **អាយុនោ សំហានិ**[១] សេចក្ដីវិនាសនៃអាយុ ។

បទថា **អទ្ធុវោ** មិនបានយឺនយូរ គឺ មិនតាំងមាំ មិននៅយ៉ាងនោះរហូតកាល ព្រោះមិនយឺនយូរ ដូច្នោះ បទថា **អទ្ធុវោ** នេះ ពោលដល់ហេតុរបស់បទមុនថា **ឧបនីយតិ** ដែលជរានាំទៅ ។

---

១ សំយុត្តនិកាយ និទានវគ្គ



ដោយបទនេះ លោកពោលដល់ជរាទុក្ខ ព្រមនឹងហេតុ ។ វិញ្ញូ-ជនទាំងឡាយ លុះឃើញជរាទុក្ខនោះហើយ សូម្បីមិនមានការវិនាសព្រោះជរា ក៏ចេញបួស ។

បទថា **អត្តាណោ** លោក មិនមានទីជ្រកពួន គឺ មិនមានអំណាចដែលនឹងជ្រកពួន គឺ រក្សាទុកបាន អធិប្បាយថា មិនមានគ្រឿងការពារ ។

បទថា **អនភិស្សរោ** មិនជាឥស្សរៈ គឺ មិនមានអំណាចតាមការប្រាថ្នា ព្រោះខ្វះអ្នកជំនួយ អធិប្បាយថា មិនមានមិត្តសំឡាញ់ ព្រោះមិនជាធំដូច្នោះ បទថា **អនភិស្សរោ** នេះជាពាក្យពោលដល់ហេតុរបស់បទមុនថា **អត្តាណោ** ។ ដោយបទនេះ លោកពោលដល់ទុក្ខកើតព្រោះ សេចក្ដីព្រាត់ប្រាសចាករបស់ជាទីស្រឡាញ់ព្រមនឹងហេតុ ។

វិញ្ញូជនទាំងឡាយ លុះឃើញទុក្ខកើតចាកសេចក្ដីព្រាត់-ប្រាសចាករបស់ដែលជាទីស្រឡាញ់នោះ សូម្បីមិនទាន់មានការវិនាសចាកញាតិ ក៏ចេញបួស ។

បទថា **អស្សកោ** មិនមានអ្វីជារបស់ខ្លួន គឺ មិនមានវត្ថុ

ជារបស់ខ្លួន ។

បទថា **សព្វំ បហាយ គមនីយំ** ត្រូវលះបង់វត្ថុទាំងពួងហើយទៅ គឺ សត្វលោកចាំបាច់ត្រូវលះបង់វត្ថុទាំងឡាយ ដែលកំណត់ថា ជាវត្ថុរបស់ខ្លួនហើយទៅ ។ ព្រោះចាំបាច់ត្រូវលះបង់វត្ថុទាំងពួងហើយទៅ ។ ដូច្នោះបទនេះ ជាបទពោលដល់ហេតុរបស់បទមុនថា **អស្សកោ** ។ ដោយបទនេះ លោកពោលដល់មរណទុក្ខ ព្រមជាមួយហេតុ ។ វិញ្ញូជនទាំងឡាយ លុះឃើញមរណទុក្ខនោះហើយ សូម្បីមិនទាន់មានការវិនាសចាកភោគៈក៏ចេញបួស ។ ក្នុងទីដទៃលោកពោលថា **កម្មស្សកាមាណវ សត្តា**[១] ម្នាលមាណព សត្វទាំងឡាយមានកម្មជារបស់ខ្លួន ។ ចំណែកក្នុងទីនេះ និងក្នុងរដ្ឋបាលសូត្រ លោកពោលថា **អស្សកោ លោកោ**[១] លោកមិនមែនជារបស់ខ្លួន ។ ប្រសិនបើសួរថា បទនោះ ត្រឹមត្រូវដូចម្តេច ? ឆ្លើយថា លោកពោលថា **អស្សកោ** មិនមែនជារបស់ខ្លួន សំដៅដល់លះបង់ហើយទៅ ។ ចំណែកកម្ម

១ មជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ



មិនលះបង់ ។ ព្រោះដូច្នោះ ទើបលោកពោលថា **កម្មស្សកា** សត្វមានកម្មជារបស់ខ្លួន ។ ម្យ៉ាងវិញទៀត ក្នុងរដ្ឋបាលសូត្រនោះឯង លោកពោលបទនេះទុកយ៉ាងនេះថា **ត្វំ បន យថាកម្មំ គមិស្សសិ**[២] សត្វលោកទៅតាមកម្ម ។

បទថា **ឩនោ** លោកខ្វះ គឺ មិនពេញ ។

បទថា **អតិត្តោ** លោកមិនចេះឆ្អែត គឺ មិនពេញចិត្តដោយការប្រាថ្នាក្រៃលែងឡើង ។ បទនេះ ជាបទពោលដល់ហេតុនៃសេចក្តីខ្វះខាត ។

បទថា **តណ្ហាទាសោ** ជាទាសនៃតណ្ហា គឺ ជាទាសៈនៃតណ្ហា ព្រោះប្រព្រឹត្តទៅក្នុងអំណាចតណ្ហា ។ បទនេះជាពាក្យពោលដល់ហេតុនៃការមិនឆ្អែត ។ ដោយបទនេះ លោកពោលដល់ព្យាធិទុក្ខ ព្រមជាមួយនឹងហេតុ ដោយអាងដល់រោគ គឺ សេចក្តីលំបាក ។ វិញ្ញូជនទាំងឡាយ លុះឃើញព្យាធិទុក្ខនោះហើយ សូម្បីមិនទាន់មានសេចក្តីវិនាសចាកព្យាធិ ក៏ចេញបួស ។

២ មជ្ឈិមនិកាយ មូលបណ្ណាសកៈ

បទថា **អតាយនោ** លោកសន្និវាសមិនមានទីបិទបាំង គឺ មិនមានការការពារ ព្រោះមិនមានទីបិទបាំង សូម្បីចាកមូលជាដើម ឬមិនរួចផុតអំពីភ័យ ។

បទថា **អលេណោ** លោកសន្និវាសមិនមានទីពួន គឺ មិនមានទីកំបាំង គឺ អាស្រ័យនៅបាន និងមិនធ្វើកិច្ច គឺ ទីជ្រកពួន សូម្បីទីកន្លែងរបស់អ្នកដែលជិតស្និទ ។

បទថា **អសរណោ** លោកសន្និវាស មិនមានទីពឹង គឺ មិននាំភ័យរបស់អ្នកដែលអាស្រ័យនៅចេញទៅបាន មិនធ្វើឲ្យអស់ភ័យ ។

បទថា **អសរណីភូតោ** លោកសន្និវាស មិនមានទីពឹងរបស់នរណា អធិប្បាយថា ឈ្មោះថា **អសរណោ** ព្រោះមិនមានការកើតក្នុងប្រទេសរបស់ខ្លួន ឈ្មោះថា **អសរណីភូតោ** ព្រោះមិនមានទីពឹងបានអស់កាលដែលកើតនោះឯង ។

បទថា **ឧទ្ធតោ** លោករាយមាយ គឺ លោកមានការព្រមជាមួយនឹងអកុសល ព្រោះកើតសេចក្តីរាយមាយក្នុងអកុសលទាំងពួង និងព្រោះច្រើនទៅដោយអកុសលកើតក្នុងសន្តានសត្វ



ឈ្មោះថា រាយមាយ ដោយឧទ្ធច្ចៈនោះ ។

បទថា **អវូបសន្តោ** លោកមិនស្ងប់ គឺ មិនស្ងប់ ព្រោះប្រកបដោយឧទ្ធច្ចៈ ដែលមានលក្ខណៈមិនស្ងប់ ប្រៀបដូចម្រឹគក្រវីស្នែង ។ បទថា **លោកោ** មកហើយ ក្នុងឋានៈ ៤ មានជាអាទិ៍ថា **ឧបនិយតិ លោកោ** និងក្នុងឋានៈ ៥ ថា **ឧទ្ធតោ លោកោ** , មានមកហើយក្នុងបទដ៏សេសថា **លោកសន្និវាសោ** ។ សូម្បីក្នុងបទទាំងពីរនោះ ក៏ជាលោកតែម្យ៉ាងដូចគ្នា ។

បទថា **សសល្លោ** លោកសន្និវាស ជាកូនសរ គឺ ប្រព្រឹត្តទៅជាមួយនឹងកូនសរ មានរាគៈជាដើម ដែលឈ្មោះថា **កូនសរ** ព្រោះឲ្យកើតសេចក្តីបៀតបៀន ព្រោះទម្លុះចូលទៅក្នុងខាងក្នុង និងព្រោះនាំចេញបានលំបាក ។

បទថា **វិទ្ធោ** ត្រូវកូនសរមុតហើយ គឺ ម្រឹគជាដើម គ្រាខ្លះត្រូវអ្នកដទៃចាក់ , តែលោក គឺ ពពួកសត្វនេះ ខ្លួនឯងប៉ុណ្ណោះត្រូវមុតគ្រប់វេលា ។

បទថា **បុថុសល្លេហិ** កូនសរចំនួនច្រើន គឺ ត្រូវកូនសរ ៧ ដែលលោកពោលទុកថា កូនសរ ៧ គឺ សរ គឺ រាគៈ ១ ,

សរ គឺ ទោសៈ ១ , សរ គឺ មោហៈ ១ , សរ គឺ មានះ ១ , សរ គឺ ទិដ្ឋិ ១ , សរ គឺ កិលេស ១ , សរ គឺ ទុច្ចរិត ១ ។

បទថា **តស្ស** គឺ របស់លោកសន្និវាសនោះ ។

បទថា **សល្លានំ ឧទ្ធតា** អ្នកនឹងដកកូនសរទាំងឡាយ គឺ បុគ្គលដែលនឹងដកកូនសរទាំងនោះចាកសន្ដានសត្វ ។

បទថា **អញ្ញត្រ មយា** គឺ វៀរតថាគត ។ សាវកទាំងឡាយណា របស់ព្រះមានព្រះភាគជាម្ចាស់ ដកកូនសរបាន , ព្រោះសាវកទាំងនោះ ដកបានតាមពាក្យទូន្មានរបស់ព្រះមានព្រះភាគនោះឯង ទើបឈ្មោះថា ព្រះមានព្រះភាគប៉ុណ្ណោះ ដកបាន ។

បទថា **អវិជ្ជន្ធការាវរណោ** លោកសន្និវាស មានការងងឹតឈឹង គឺ អវិជ្ជាបិទបាំងទុក ឈ្មោះថា **សេចក្ដីងងឹតឈឹង** គឺ **អវិជ្ជា** ព្រោះអវិជ្ជានោះឯងធ្វើ ដូចសេចក្ដីងងឹតដែលបិទ-បាំងការឃើញសភាវធម៌ ។ អវិជ្ជានោះឯង ឈ្មោះថា ការងងឹត គឺ អវិជ្ជា បិទបាំងទុក ព្រោះមានគ្រឿងបិទបាំង ដោយហាមការឈានចុះកាន់សភាវធម៌ ។

បទថា **កិលេសបញ្ជរបក្ខិត្តោ** ត្រូវធ្លាក់ចូលទៅក្នុងទ្រុង



កិលេស គឺ ឈ្មោះថា **ទ្រុងកិលេស** ព្រោះកិលេសនោះឯងជាទ្រុង ដោយហាមការចូលដល់កុសល , ត្រូវដាក់ គឺ ឲ្យធ្លាក់ទៅក្នុងទ្រុងកិលេស ដែលមានអវិជ្ជាជាដែនកើត ។

បទថា **អាលោកំ ទស្សេតា** នឹងសម្ដែងជាពន្លឺ គឺ មានប្រក្រតីឃើញពន្លឺ គឺ បញ្ញា ឈ្មោះថា នឹងសម្ដែងការឃើញពន្លឺដោយបញ្ញា ។

បទថា **អវិជ្ជាគតោ** លោកសន្និវាស ធ្លាក់នៅក្នុងអំណាចអវិជ្ជា គឺ ចូលទៅកាន់អវិជ្ជា , មិនមែនត្រឹមតែបិទបាំងដោយអវិជ្ជាតែម្យ៉ាង , ការពិតចូលទៅចំណែកក្នុងបក្ខពួករបស់អវិជ្ជា ដូចចូលទៅក្នុងទីគ្មានសណ្ដាប់ធ្នាប់ ។ ព្រោះហេតុនោះ ទើបប្លែកអំពីបទមុន ។

បទថា **អណ្ឌភូតោ** គឺ កើតក្នុងពង ដូចសេចក្ដីថា សត្វពួកខ្លះកើតក្នុងពង លោកហៅថា **អណ្ឌភូតា** យ៉ាងណា ។ លោកនេះ លោកហៅថា **អណ្ឌភូតោ** ព្រោះកើតក្នុងពង និងស្រោមរបស់អវិជ្ជា ។

បទថា **បរិយោនទ្ធោ** ដែលអវិជ្ជាហ៊ុំព័ទ្ធទុក គឺ ត្រូវហ៊ុំព័ទ្ធ

ចងទុកដោយពង និងស្រោម គឺ អវិជ្ជាដោយជុំវិញ ។

បទថា **តន្តាកុលជាតោ** គឺ ស្មុគ្រស្មាញដូចសរសៃអំបោះ សេចក្តីថា សរសៃអំបោះរបស់ជាងតម្បាញ រក្សាទុកមិនល្អត្រូវកណ្តុរកាត់ រមែងជំពាក់ក្នុងទីនោះ ៗ ជាការលំបាកនឹងវាយតម្លៃឲ្យសម ឬសមតាមតម្លៃថា នេះមានតម្លៃប៉ុណ្ណេះ មានតម្លៃប៉ុណ្ណេះ យ៉ាងណា ។ សត្វទាំងឡាយក៏ដូច្នោះ ជាអ្នកក្វាត់ក្វាំងស្មុគ្រស្មាញ ខ្វល់ខ្វាយក្នុងបច្ចយាការ រមែងមិនអាចធ្វើបច្ចយាការឲ្យត្រង់បាន ។ ជាងតម្បាញដែលតាំងនៅក្នុងភាពជំនាញចំពោះខ្លួន ក៏អាចធ្វើសរសៃអំបោះឲ្យត្រង់បាន ។ ប៉ុន្តែសត្វដទៃ វៀរព្រះពោធិសត្វ ឈ្មោះថា អាចនឹងធ្វើបច្ចយាការឲ្យត្រង់បាន ដោយធម្មតារបស់ខ្លួនរមែងមិនមាន ។ ម្យ៉ាងទៀត ដូចជាសរសៃអំបោះដែលជំពាក់ ជាងតម្បាញយកទៅជ្រលក់ទឹកបាយហើយ ក៏នឹងជាប់គ្នាវិញបាន និងព័ន្ធគ្នាជាល្បាយ យ៉ាងណា ។ លោកនេះក៏ដូច្នោះ លុះឃ្លាតចាកក្នុងបច្ច័យទាំងឡាយ មិនអាចធ្វើបច្ច័យទាំងឡាយឲ្យត្រង់បាន រមែងកើតគំនិតដែលលាយដោយអំណាចទិដ្ឋិ ៦២ ។ សត្វពួកខ្លះទាំងឡាយណាអាស្រ័យដោយទិដ្ឋិ



ទាំងឡាយ សត្វទាំងនោះមិនអាចធ្វើបច្ច័យឲ្យត្រង់បាន ។

បទថា **គុលាគុណ្ឋិកជាតោ** សម្ព័ន្ធគ្នាជាក្រុមជាកង គឺ ដូចជាក្រុម ។ ដោយជ្រលក់ទឹកបាយរបស់ជាងតម្បាញ លោកពោលថាជាដុំ ។ អាចារ្យពួកមួយពោលថា សំបុកសត្វ ឈ្មោះថា **គុលា** ភាពស្មុគ្រស្មាញលំបាកសូម្បីទាំង ពីរនោះលំបាកធ្វើការវាយតម្លៃឲ្យស្មើគ្នាបាន ។

បទថា **មុញ្ជបព្វជភូតោ** ជំពាក់ជំពិនដូចស្មៅយាផ្លង និងស្មៅជំណោកទន្សាយ គឺ ដូចជាស្មៅយាផ្លង និងស្មៅជំណោកទន្សាយ កើតមានដូចជាស្មៅយាផ្លង និងស្មៅជំណោកទន្សាយ ។ ជំស្មៅទាំងនោះធ្វើខ្សែ ក្នុងវេលាខ្សែដាច់ កាន់យកខ្សែដែលធ្លាក់ទៅក្នុងទីណាមួយហើយ លំបាកនឹងវាយតម្លៃស្មៅទាំងនោះឲ្យមានតម្លៃ ឬមានតម្លៃសមគួរថា នេះមានតម្លៃប៉ុណ្ណេះ មានតម្លៃប៉ុណ្ណេះ ។ ជាងអ្នកតាំងនៅក្នុងភាពជំនាញចំពោះខ្លួន ក៏គប្បីអាចធ្វើឲ្យស្មៅនោះត្រង់បាន ។ ប៉ុន្តែសត្វដទៃ វៀរព្រះពោធិសត្វ ឈ្មោះថា អាចនឹងធ្វើបច្ចយាការឲ្យត្រង់បានតាមធម្មតារបស់ខ្លួន រមែងមិនមាន យ៉ាងណា ។ លោកនេះ ក៏ដូច្នោះ

មិនអាចនឹងធ្វើបច្ចយាការឲ្យត្រង់បាន កើតជាគ្រឿងដោតក្រង ដោយអំណាចទិដ្ឋិ ៦២ រមែងមិនផុតចាកអបាយ ទុគតិ វិនិបាត សង្សារទៅបាន ។

ក្នុងបទទាំងនោះ បទថា **អបាយោ** បានដល់ នរក កំណើតតិរច្ឆាន បេត្តិវិស័យ អសុរកាយ ។ ទាំងអស់នោះ លោកហៅថា **អបាយ** ព្រោះមិនមានសេចក្តីចម្រើន គឺ សេចក្តីដឹង ។

មយ៉ាងទៀត ឈ្មោះថា **ទុគតិ** ព្រោះជាផ្លូវទៅកាន់សេចក្តីទុក្ខ ។

ឈ្មោះថា **វិនិបាត** ព្រោះសេចក្តីសុខធ្លាក់ទៅចាកកាយ ។ ចំណែកសង្សារក្រៅអំពីនេះ លោកពោលថា

**ខន្ធានញ្ច បដិបាដិ ធាតុអាយតនាន ច**
**អព្វោច្ឆិន្នំ វត្តមានំ សំសារោ បវុច្ចតិ ។**

លំដាប់នៃ ខន្ធ ធាតុ អាយតនៈ មិនទាន់ដាច់ខ្សែ
នៅប្រព្រឹត្តទៅ លោកហៅថា សង្សារ ដូច្នេះ ។

មិនកន្លងសង្សារនោះសូម្បីទាំងអស់ទៅបាន ។ តាមពិតកាលនៅមានចុតិ និងបដិសន្ធិរឿយ ៗ យ៉ាងនេះ គឺ ចាកចុតិ



កាន់យកបដិសន្ធិ ចាកបដិសន្ធិកាន់យកចុតិ រមែងវិលវល់ក្នុងភព ៣ ក្នុងកំណើត ៤ ក្នុងគតិ ៥ ក្នុងវិញ្ញាណដ្ឋិតិ ៧ ក្នុងសត្តាវាស ៩ ដូចទូកត្រូវខ្យល់ផាត់ទៅក្នុងមហាសមុទ្រ និងដូចគោដែលត្រូវទឹមដោយយន្ត ដូច្នោះ ។

បទថា **អវិជ្ជាវិសទោសសល្លិត្តា** លោកសន្និវាស ត្រូវអវិជ្ជា មានទោសជាពិសដោតជាប់ហើយ ឈ្មោះថា **អវិជ្ជាមានទោស** ព្រោះអវិជ្ជានោះឯងជាទោស ព្រោះញុំាងជីវិតដែលជាកុសលឲ្យវិនាសទៅ ដោយការកើតនៃអកុសល ។ ពិស គឺ អវិជ្ជានោះឯង ។ ឈ្មោះថា **អវិជ្ជា មានទោសជាពិស** ព្រោះប្រទូសរ៉ាយសន្តាន ។ ឈ្មោះថា **អវិជ្ជាមានទោសជាពិសដោតជាប់ហើយ** ព្រោះជាប់នៅដោយអនុស័យ បរិយុដ្ឋានកិលេស និងទុច្ចរិតនោះយ៉ាងខ្លាំងក្លា ។

បទថា **កិលេសកលលីភូតោ** មានកិលេសជាទោសឈ្មោះថា **កិលេសកលលំ** ព្រោះកិលេស មានអវិជ្ជាជាដើមជាមូល ជាកលលៈ គឺ ល្បប់ ព្រោះអត្ថថា លិច ។ ឈ្មោះថា **កិលេសកលលី** ព្រោះមានកិលេសនោះដូចជាភក់ល្បប់ ។ បទថា **រាគ-**

**ទោសមោហជដាជដិតោ** លោកសន្និវាស ជាព្រៃក្រាស់ដោយរាគៈ ទោសៈ មោហៈ គឺ រាគៈ ទោសៈ មោហៈ ដែលជាលោកៈបដិយៈ និងអវិជ្ជា ឈ្មោះ ជដា ព្រោះកើតរឿយ ៗ ទាំងខាងក្រោមខាងលើ ក្នុងអារម្មណ៍ មានរូបជាដើម ដូចព្រៃក្រាស់ពោលគឺ សំណាញ់មែកឫស្សីជាដើម ដោយការចាក់ស្រេះគ្នា ។ ព្រៃក្រាស់ដោយការជុះ គឺ រាគៈ ទោសៈ និងមោហៈនោះ ។ អធិប្បាយថា លោកនេះជាព្រៃក្រាស់ គឺ ចងជាប់ជាតក្រង ដោយការជុះនោះ ដូចជាឫស្សីជាដើម ជុះដោយការជុះរបស់ឫស្សីជាដើម ។

បទថា **ជដំ វិជដេតា** ឆ្ការព្រៃក្រាស់ គឺ ជម្រះ កាត់ទម្លាយ ព្រៃក្រាស់នេះ ឆ្ការលោកដែលជាត្រៃធាតុហើយ តាំងនៅយ៉ាងនេះបាន ។

បទថា **តណ្ហាសង្ឃាដប្បដិមុក្កោ** លោកសន្និវាស ត្រូវកងតណ្ហាប្រមូលទុក ឈ្មោះថា **កងតណ្ហា** ព្រោះតណ្ហានោះឯងមិនទាន់ដាច់ខ្សែ នៅប្រព្រឹត្តទៅ ឈ្មោះថា **កង** ព្រោះនៅតទៅ ។ ឈ្មោះថា **កងតណ្ហាប្រមូលទុក** ព្រោះប្រមូលទុកខាងក្នុងកងតណ្ហានោះ ។



បទថា **តណ្ហាជាលេន ឱត្ថដោ** លោកសន្និវាសត្រូវសំណាញ់តណ្ហាគ្របទុក ឈ្មោះថា **សំណាញ់តណ្ហា** ព្រោះតណ្ហានោះឯងជាសំណាញ់ ដោយជាតក្រងទុកតាមន័យដូចពោលហើយអំពីមុន ។ លោកសន្និវាសត្រូវសំណាញ់ គឺ តណ្ហាគ្រប បិទបាំងទុកដោយជុំវិញ ។

បទថា **តណ្ហាសោតេន វុយ្ហតិ** លោកសន្និវាសត្រូវក្រសែតណ្ហាផាត់នាំទៅ ឈ្មោះថា **ក្រសែតណ្ហា** ព្រោះតណ្ហានោះឯងជាក្រសែ ដោយនាំទៅក្នុងសង្សារ ។ លោកសន្និវាសត្រូវក្រសែតណ្ហានោះផាត់នាំទៅ គឺ បន្សាត់ទៅ ។

បទថា **តណ្ហាសញ្ញោជនេន សញ្ញុត្តោ** លោកសន្និវាសត្រូវតណ្ហាជាគ្រឿងទាក់ ចងទុក ឈ្មោះថា **តណ្ហាជាគ្រឿងទាក់** ព្រោះតណ្ហានោះឯងជាគ្រឿងទាក់ ព្រោះចង គឺ ចងសត្វលោកទុកក្នុងវដ្តៈ ។ លោកសន្និវាសត្រូវតណ្ហា ជាគ្រឿងទាក់នោះទាក់ទុក គឺ ចងទុក ។

បទថា **តណ្ហានុសយេន អនុសដោ** លោកសន្និវាសផ្សាយ

ទៅ ព្រោះតណ្ហានុស័យ ឈ្មោះថា **តណ្ហានុស័យ** ព្រោះតណ្ហានោះឯងជាអនុស័យ ដោយដេកត្រាំនៅក្នុងសន្តាន ។ លោកសន្និវាសផ្សាយទៅ តាមទៅ ទៅយ៉ាងខ្លាំងក្លា ដោយតណ្ហានុស័យ ។

បទថា **តណ្ហាសន្តាបេន សន្តប្បតិ** លោកសន្និវាសក្តៅក្រហាយ ដោយសេចក្តីក្តៅក្រហាយព្រោះតណ្ហា ឈ្មោះថា **ក្តៅក្រហាយ** ព្រោះតណ្ហានោះឯង ញុាំងលោកឲ្យក្តៅក្រហាយក្នុងកាលប្រព្រឹត្តទៅ និងក្នុងកាលនៃផល ។ លោកសន្និវាសក្តៅក្រហាយ ដោយសេចក្តីក្តៅក្រហាយ ព្រោះតណ្ហានោះ ។

បទថា **តណ្ហាបរិឡាហេន បរិឌយ្ហតិ** លោកសន្និវាសក្រហល់ក្រហាយ ដោយសេចក្តីក្រហល់ក្រហាយព្រោះតណ្ហា ឈ្មោះថា **ក្រហល់ក្រហាយព្រោះតណ្ហា** ព្រោះតណ្ហានោះឯង មានកម្លាំងក្រហល់ក្រហាយច្រើន ដោយសេចក្តីក្រហល់ក្រហាយក្នុងកាលប្រព្រឹត្តទៅ និងក្នុងកាលនៃផលដោយជុំវិញ ។ លោកសន្និវាសក្រហល់ក្រហាយ ដោយសេចក្តីក្រហល់ក្រហាយ ព្រោះតណ្ហានោះដោយជុំវិញ ។



គប្បីប្រកបបទមាន **ទិដ្ឋិសង្ឃាដាទយោ** កងទិដ្ឋិទុកដោយបទតណ្ហានោះឯង ។

បទថា **អនុគតោ** លោកសន្និវាសទៅតាមជាតិ គឺ ចូលទៅ ។

បទថា **អនុសដោ** លោកសន្និវាសជ្រមុជជ្រមុលទៅ ព្រោះជរា គឺ ស្គុះទៅ ។

បទថា **អភិភូតោ** លោកសន្និវាសត្រូវព្យាធិគ្របសង្កត់ គឺ បៀតបៀន ។

បទថា **អភិហតោ** លោកសន្និវាសត្រូវមរណៈបង្ខិល គឺ ត្រូវកម្ចាត់ ត្រូវទម្លាយយ៉ាងខ្លាំងចំពោះមុខ ។

បទថា **ទុក្ខេ បតិដ្ឋិតោ** លោកសន្និវាសតាំងនៅក្នុងកងទុក្ខ គឺ តាំងនៅអាស្រ័យខន្ធបញ្ចកដែលជាទុក្ខ ដោយយល់ខុសថាជាសុខ ។

បទថា **តណ្ហាយ ឧឌ្ឌិតោ** លោកសន្និវាសត្រូវតណ្ហាចងទុក គឺ ត្រូវតណ្ហាបុករុក ។ សេចក្តីថា ចក្ខុត្រូវចងទុកដោយខ្សែ គឺ តណ្ហា ហើយទុកនឹងបង្គោល គឺ រូប ។ ត្រចៀកជាដើម ត្រូវ

ចងទុកដោយខ្សែ គឺ តណ្ហា ត្រូវចងទុកនឹងបង្គោល គឺ សំឡេង ជាដើម ។ សូម្បីលោក មានការព្រមព្រៀងដោយតណ្ហានោះ ក៏ឈ្មោះថា ត្រូវចងទុកនោះឯង ។

បទថា **ជរាបាការបរិក្ខិត្តោ** លោកសន្និវាសត្រូវកំផែង គឺ ជរាហ៊ុំទុក គឺ ត្រូវជរាដែលជាកំផែងហ៊ុំទុក គេចចេញមិនបាន ។

បទថា **មច្ចុបាសេន បរិក្ខិត្តោ** លោកសន្និវាសត្រូវអន្ទាក់មច្ចុទាក់ទុក ឈ្មោះថា ត្រូវមរណៈដែលជាអន្ទាក់ ព្រោះដោះបានលំបាក ទាក់ទុក ។

បទថា **មហាពន្ធនពន្ធោ** លោកសន្និវាសត្រូវចងទុកដោយគ្រឿងចងដ៏ច្រើន គឺ ត្រូវចងដោយគ្រឿងចងដ៏ធំ ព្រោះជាប់ស្អិត និងព្រោះផ្តាច់បានលំបាក ។

បទថា **រាគពន្ធនេន** ដោយគ្រឿងចង គឺ រាគៈ ឈ្មោះថា **រាគពន្ធនំ** ព្រោះរាគៈនោះឯង ចងទុកមិនឲ្យរបូតចាកសង្សារបាន ។ ដោយគ្រឿងចង គឺ រាគៈនោះ ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះដូចគ្នា ។

បទថា **កិលេសពន្ធនេន** គឺ ដោយគ្រឿងចង គឺ កិលេស



ដ៏សេស ដូចដែលបានពោលហើយ ។

បទថា **ទុច្ចរិតពន្ធនេន** គឺ ដោយគ្រឿងចង គឺ ទុច្ចរិត ៣ យ៉ាង ។ ចំណែកសុចរិតជាហេតុនៃការរួចផុតពីគ្រឿងចង និងជាគ្រឿងរួចផុតចាកគ្រឿងចង មានហើយ ។ ព្រោះដូច្នោះ មិនគួរកាន់យកសុចរិតនោះ ។

បទថា **ពន្ធនំ មោចេតា** ដោះគ្រឿងចងឲ្យ គឺ ដោះគ្រឿងចងឲ្យដល់លោកសន្និវាសនោះ ។ បាឋៈថា **ពន្ធនា មោចេតា** ខ្លះ ។ សេចក្តីថា ដោះលោកសន្និវាសនោះ ចាកគ្រឿងចង ។

បទថា **មហាសម្ពាធបដិបន្នោ** លោកសន្និវាសជាផ្លូវដើរចង្អៀតក្រៃលែង គឺ ដើរទៅកាន់ទីស្អុក គឺ រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ កិលេស និងទុច្ចរិត ដែលបានដល់ទីចង្អៀតដ៏ក្រៃលែង ព្រោះបៀតបៀនការដើរផ្លូវរបស់កុសល ។

បទថា **ឱកាសំ ទស្សេតា** បង្ហាញផ្លូវភ្លឺឲ្យ គឺ ឲ្យឃើញច្បាស់ គឺ សមាធិ និងបញ្ញាដែលជាលោកិយៈ និងលោកុត្តរៈ ។

បទថា **មហាបលិពោធេន បលិពុទ្ធោ** លោកសន្និវាសត្រូវសេចក្តីកង្វល់ដ៏ច្រើនចងទុក គឺ ត្រូវគ្រឿងការពារធំបិទបាំង

ទុក ។ ឬឈាបទុកដោយគ្រឿងឈាបធំ ។

ម្យ៉ាងទៀត បទថា **បលិពោធោ** គឺ សេចក្ដីកង្វល់ ៧ យ៉ាង មានរាគៈជាដើម ។ អាចារ្យខ្លះលោកពោលថា សេចក្ដីកង្វល់ គឺ តណ្ហា និងទិដ្ឋិ ។ បទថា **បលិពោធំ ឆេទេតា** គឺ កាត់សេចក្ដីកង្វល់នោះ ។ បទថា **មហាបបាតេ** ក្នុងអន្លង់ធំ បានដល់ ក្នុងអន្លង់ គឺ គតិ ៥ ។ ឬក្នុង អន្លង់ គឺ ជាតិ ជរា និងមរណៈ ។ ទាំងអស់នោះឈ្មោះថា **បបាត** ព្រោះឡើងបានលំបាក ។ បទថា **បបតា ឧទ្ធតា** គឺ ឡើងផុតអំពីអន្លង់នោះ ។

បទថា **មហាកន្តារប្បដិបន្នោ** លោកសន្និវាសដើរទៅកាន់ផ្លូវលំបាកខ្លាំង គឺ ដើរផ្លូវកន្តារ ព្រោះជាតិ ជរា ព្យាធិ មរណៈ សោកៈ បរិទេវៈ ទុក្ខ ទោមនស្ស និងឧបាយាសៈ ។ ទាំងអស់នោះឈ្មោះថា **កន្តារ** ព្រោះឲ្យកន្លងបាន ដោយលំបាក ។ បាឋៈថា **កន្តារា តរេតា** ខ្លះ ។

បទថា **មហាសំសារប្បដិបន្នោ** លោកសន្និវាសដើរទៅក្នុងមហាសង្សារ គឺ ដើរទៅកាន់ខន្ធសន្តានដែលមិនទាន់ដាច់ ។ បទថា **សំសារា មោចេតា** គឺ ជួយឲ្យរួចផុតចាកសង្សារវដ្ដ ។



បាឋៈថា **សំសារំ មោចេតា** ខ្លះ ។ បទថា **មហាវិទុគ្គេ** ក្នុងល្បាប់ធំ បានដល់ ក្នុងល្បាប់ គឺ សង្សារវដ្ដ ។ សង្សារវដ្ដនោះឯង ឈ្មោះថា **ល្បាប់** ព្រោះចេញទៅបានលំបាក ។ បទថា **សម្បរិវត្តតិ** បម្រះនទៀល គឺ ត្រឡប់ទៅមកយ៉ាងលំបាក ។ បទថា **មហាបលិបេ** ក្នុង ភក់ល្បាប់ គឺ កាមធំ ។ **កាម** ឈ្មោះថា ភក់ល្បាប់ ព្រោះធ្វើឲ្យលិច ។ បទថា **បលិបន្នោ** គឺ ជាប់ ។ បាឋៈថា **មហាបលិបបលិបន្នោ** ខ្លះ គឺ ជាប់ក្នុងភក់ល្បាប់ធំ បទថា **អព្ភាហតោ** គ្របសង្កត់ គឺ ត្រូវអន្តរាយទាំងពួងគ្របសង្កត់ ។ បទថា **រាគគ្គិនា** គឺ រាគៈជាដើម ឈ្មោះថា **អគ្គិ** ព្រោះអត្ថថា ដុតបំផ្លាញ ។ ដោយភ្លើង គឺ រាគៈជាដើមនោះ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

បទថា **ឧន្នីតកោ** លោកសន្និវាសទុរនទុរា គឺ ត្រូវចាប់នាំទៅ ។ អធិប្បាយថា ត្រូវជាតិចាប់ហើយនាំទៅ ដើម្បីអន្តរាយ មានជរាជាដើម ។ គប្បីឃើញថា **ក** អក្សរ ក្នុងបទនេះ ជាការបន្ថែមសេចក្ដី ។ បទថា **ហញ្ញតិ និច្ចមត្តាណោ** ក្ដៅក្រហាយជានិច្ច មិនមានអ្វីទីពឹង គឺ មិនមានអ្នកទីពឹង ត្រូវបៀត-

បៀនជានិច្ច ។ បទថា **បត្តទណ្ឌា** ត្រូវទទួលអាជ្ញា គឺ បានទទួលអាជ្ញាពីព្រះរាជាជាដើម ។ បទថា **តក្ការោ** ត្រូវធ្វើតាមអាជ្ញា គឺ ចោរ ។ បទថា **វជ្ឈពន្ធនពន្ធា** គឺ លោកសន្និវាសត្រូវចងដោយគ្រឿងចង គឺ ទោសមានរាគៈជាដើម ។ បទថា **អាឃាតនបច្ចុបដ្ឋិតោ** ប្រាកដហើយត្រង់ផ្លូវត្រឡែងកែង គឺ ចូលទៅប្រាកដត្រង់ទីចង គឺ មរណៈ ។ បទថា **កោចិ ពន្ធនំ មោចេតា** នរណានឹងជួយឲ្យរួចផុតបាន ។ បាឋៈថា នរណានឹងជួយឲ្យផុតចាកគ្រឿងចងបានក៏មាន ។ បទថា **អនាថោ** លោកសន្និវាសមិនមានទីពឹង ឈ្មោះថា **អនាថោ** ព្រោះមិនមានទីពឹង គឺ ឥស្សរៈ ។ ឬទីពឹងដែលជាឥស្សរៈដោយខ្លួនឯងមិនមាន ។ បទថា **បរមការុញ្ញប្បត្តោ** គួរបានទទួលសេចក្ដីអាណិតយ៉ាងក្រៃលែង គឺ ដល់ភាពគួរករុណាក្រៃពេក ព្រោះមិនត្រឹមល្មមក្នុងការបៀតបៀនជាដើម ។ បទថា **តាយេតា** នឹងជាអ្នកជួយស្រោចស្រង់ គឺ ឃុំគ្រង ។ បាឋៈថា **តាយិតា** ល្អជាង ។

បទថា **ទុក្ខាភិតុន្នោ** លោកសន្និវាសត្រូវទុក្ខចាក់ដោត គឺ ត្រូវទុក្ខដ៏ច្រើន មានជាតិទុក្ខជាដើមចាក់ដោត បៀតបៀនញាប់ញ័រក្រៃលែង ។ បទថា **ចិររត្តបិឡិតោ** ត្រូវទុក្ខបៀតបៀនមកដ៏យូរ គឺ ត្រូវទុក្ខបៀតបៀន ចាក់ដោតមកអស់កាលយូរ ។



បទថា **គធិតោ** លោកសន្និវាសជាប់ជំពាក់ គឺ ស្រេកឃ្លានដោយការជាប់ចិត្ត ឬចងដោយគ្រឿងចង គឺ អភិជ្ឈាកាយគន្ថៈ ។ បទថា **និច្ចំ បិបាសិតោ** ស្រេកឃ្លានជានិច្ច គឺ ប្រាថ្នាស្រេកឃ្លាន ដើម្បីនឹងផឹក ដើម្បីនឹងបរិភោគ សេចក្ដីស្រេកឃ្លាននោះឯង គឺ តណ្ហា ។ សេចក្ដីស្រេកឃ្លាន មិនមានចន្លោះ ឈ្មោះថា សេចក្ដីស្រេកឃ្លាន គឺ តណ្ហា ។

បទថា **អន្ធោ** លោកសន្និវាសខ្វាក់ ឈ្មោះថា ខ្វាក់ ព្រោះមិនមានបញ្ញា ដែលឈ្មោះថា ចក្ខុ ព្រោះអត្ថថា ឃើញ ។ បញ្ញានោះឯង រមែងឃើញសភាវធម៌ ។ បទថា **អចក្ខុកោ** មិនមានចក្ខុ ភាពជាអ្នកខ្វាក់នោះ មិនមានក្នុងខាងក្រោយ ។ ភាពជាអ្នកខ្វាក់នោះឯង គឺ ជាអ្នកមានភ្នែកដូចមិនមានភ្នែករមែងមានតាមប្រក្រតីនោះឯង ។

បទថា **ហតនេត្តោ** លោកសន្និវាសមានភ្នែកវិនាស ឈ្មោះថាមានភ្នែកវិនាស ព្រោះមិនមានបញ្ញា ដែលហៅថា **នេត្រ** ព្រោះ

មានសភាពនាំទៅ ។ លោកហៅថា **នេត្រ** ព្រោះនាំអត្តភាពឲ្យឃើញទីស្មើ និងទីមិនស្មើ ។ នាំទៅកាន់ផ្លូវល្អ និងមិនល្អដោយបញ្ញា ។ ព្រះសារីបុត្តត្ថេរ កាលនឹងសម្តែងដល់ការមិនមាននេត្ររបស់អ្នកនោះ ព្រោះភ្នែកវិនាស ទើបពោល **អបរិណាយកោ** មិនមានអ្នកនាំ ។ អធិប្បាយថា មានភ្នែកដូចជាមិនមាន ។ លោកអធិប្បាយថា មិនមានអ្នកដទៃនាំទៅបាន ។

បទថា **វិបថបក្ខន្ទោ** លោកសន្និវាសស្ទុះទៅកាន់ផ្លូវខុស ឈ្មោះថា **ផ្លូវខុស** ព្រោះផ្លូវខុស ឬផ្លូវមិនរាប ។ ឈ្មោះថា **ស្ទុះទៅកាន់ផ្លូវខុស** ព្រោះស្ទុះទៅ គឺ ចូលទៅ ដើរទៅខុសផ្លូវ ។ អធិប្បាយថា ដើរទៅកាន់មិច្ឆាទិដ្ឋិ គឺ ផ្លូវខុស ។

បទថា **អញ្ចសាបរទ្ធោ** វង្វេងផ្លូវហើយ គឺ វង្វេងផ្ងាតក្នុងផ្លូវ គឺ ផ្លូវត្រង់ ដែលបានដល់មជ្ឈិមាបដិបទា ។

បទថា **អរិយបថំ អានេតា** មកកាន់ផ្លូវអរិយៈ គឺ នាំចូលទៅឲ្យដល់អដ្ឋង្គិកមគ្គ ដែលជាអរិយៈ ។

បទថា **មហោឃបក្ខន្ទោ** លោកសន្និវាសស្ទុះទៅកាន់អន្លង់មោហៈ ឈ្មោះថា **ឱឃា** ព្រោះញ៉ាំងសត្វដែលមានកិលេសឲ្យ



លិចចុះក្នុងវដ្តៈ ។ ឈ្មោះថា **មហោឃា** ព្រោះឱឃៈធំជាងឱឃៈប្រក្រតី ។ ឱឃៈទាំងនោះមាន ៤ យ៉ាងគឺ កាមោឃៈ ១ ភវោឃៈ ១ ទិដ្ឋោឃៈ ១ អវិជ្ជោឃៈ ១ ។ ឈ្មោះថា **មហោឃបក្ខន្ទោ** ព្រោះស្ទុះចូលទៅកាន់ឱឃៈទាំងនោះ ។ ឬថាស្ទុះទៅកាន់ឱឃៈធំ គឺ សង្សារវដ្ត ។

ឥឡូវនេះ គប្បីជ្រាបន័យដែលប្លែកពីន័យទីមួយ ។ ក្នុងបទទាំងនោះ បទថា **ទ្វីហិ ទិដ្ឋិគតេហិ** ត្រូវទិដ្ឋិ ២ គឺ ត្រូវសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិរួបរិត ។

**ទិដ្ឋិគត** ក្នុងបទនោះ គឺ ទិដ្ឋិនោះឯង ដូចបទមានជាអាទិ៍ថា **គូថគតំ មុត្តគតំ** [1] មូត្រលាមក ។ ម្យ៉ាងវិញទៀត ឈ្មោះថា **ទិដ្ឋិគតំ** ព្រោះទៅជាមួយទិដ្ឋិ ព្រោះមិនមានវត្ថុដែលគួរទៅ ។ ការឃើញនេះ ប្រព្រឹត្តទៅក្នុងទិដ្ឋិទាំងឡាយ ឈ្មោះថា **ទិដ្ឋិគតំ** ព្រោះទិដ្ឋិ ៦២ ធ្លាក់ចុះក្នុងខាងក្នុងខ្លះ ។ ពិតហើយទិដ្ឋិ ៦២ និងទិដ្ឋិ ៦៣ ក៏ជាទិដ្ឋិ ២ យ៉ាងនោះឯង គឺ សស្ស-

---

១ អង្គុត្តរនិកាយ នវកនិបាត

តទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ។ ព្រោះដូច្នោះ កាលធ្វើទិដ្ឋិទាំងអស់ ដោយសង្ខេបទុកខាងក្នុង លោកទើបពោល **ទ្វីហិ ទិដ្ឋិគតេហិ** ។

បទថា **បរិយុដ្ឋិតោ** ត្រូវទិដ្ឋិ ២ យ៉ាងរួបរិត គឺ ដល់នូវការរុំព័ទ្ធ ដល់សេចក្ដីប្រាកដ ។ អធិប្បាយថា ដល់ការប្រកាន់អាចារៈដែលជាកុសល ដោយមិនឲ្យកើតឡើង ។ សមដូចព្រះមានព្រះភាគ ត្រាស់ទុកមានជាអាទិ៍ថា

> **ម្នាលភិក្ខុទាំងឡាយ ទេវតានិងមនុស្ស**
> **ពួកខ្លះ ត្រូវទិដ្ឋិ ២ រួបរិត រមែងជាប់**
> **នៅ ពួកខ្លះរមែងស្ទុះទៅ អ្នកមានចក្ខុ**
> **រមែងឃើញ**[1] ។

បទថា **តីហិ ទុច្ចរិតេហិ** គឺ ដោយកាយទុច្ចរិត ៣ វចីទុច្ចរិត ៤ និងមនោទុច្ចរិត ៣ ។

បទថា **វិប្បដិបន្នោ** លោកសន្និវាសបដិបត្តិខុស បានដល់បដិបត្តិខុស គឺ បដិបត្តិគួរខ្ពើម ឈ្មោះថា មិច្ឆាបដិបត្តិ ។

---

១ ខុទ្ទកនិកាយ ឥតិវុត្តក



បទថា **យោគេហិ យុត្តោ** លោកសន្និវាស ប្រកបដោយកិលេសគ្រឿងប្រកប ឈ្មោះថា **យោគ** ព្រោះអត្ថថា ប្រកបទុកក្នុងវដ្ដៈ ។ ឬឈ្មោះថា យោគៈ ដោយអត្ថដូច្នេះគឺ ប្រកបពោរពេញទៅដោយយោគៈទាំងនោះ ។

បទថា **ចតុយោគយោជិតោ** លោកសន្និវាសត្រូវកិលេសជាគ្រឿងប្រកប ៤ យ៉ាង ប្រកបទុក គឺ ប្រកបទុកក្នុងវដ្ដៈដោយយោគៈ ៤ ទាំងនេះគឺ កាមយោគៈ ១ ភវយោគៈ ១ ទិដ្ឋិយោគៈ ១ អវិជ្ជាយោគៈ ១ ។ ដូចគោត្រូវចងទុកនឹងរទេះ ។ រាគៈប្រកបដោយកាមគុណ ៥ ឈ្មោះថា **កាមរាគ** ។ ឆន្ទរាគៈក្នុងរូបភព និងអរូបភព ការប្រាថ្នាក្នុងឈាន , រាគៈសហគតដោយសស្សតទិដ្ឋិ សេចក្ដីប្រាថ្នាដោយអំណាចភព ឈ្មោះថា **ភវរាគ** ។ ទិដ្ឋិ ៦២ ឈ្មោះថា **ទិដ្ឋិយោគ** ។ ការមិនដឹងក្នុងឋានៈ ៨ យ៉ាង ឈ្មោះថា **អវិជ្ជាយោគ** ។ ឱឃៈ ៤ ទាំងនោះ មានកម្លាំងខ្លាំងក្លា , យោគៈ ៤ មានកម្លាំងទន់ខ្សោយ ។

បទថា **ចតូហិ គន្ថេហិ** កិលេសជាគ្រឿងដោតក្រង ៤ យ៉ាង ឈ្មោះថា **គន្ថ** ព្រោះក្រង គឺ ចងអ្នកមានកិលេសទុក

ក្នុងវដ្ដៈ ដោយចុតិ និងបដិសន្ធិ ។ គន្ថៈមាន ៤ យ៉ាង គឺ អភិជ្ឈាកាយគន្ថៈ ១ ព្យាបាទកាយគន្ថៈ ១ សីលព្វតបរាមាស-កាយគន្ថៈ ១ ឥទំសច្ចាភិនិវេសកាយគន្ថៈ គឺ ការប្រកាន់វត្ថុនេះថា ជាសច្ចៈ ១ ។

ឈ្មោះថា **អភិជ្ឈា** ព្រោះអត្ថថា ជាហេតុសម្លឹងរំពៃ ។ ឬសម្លឹងរំពៃដោយខ្លួនឯង ។ ឬមានត្រឹមតែការសម្លឹងប៉ុណ្ណោះ ។ បានដល់ លោភៈនោះឯង ។ ឈ្មោះថា **កាយគន្ថ** ព្រោះអត្ថថា ក្រងនាមកាយ គឺ ចងទុកក្នុងវដ្ដៈ ដោយចុតិ និងបដិសន្ធិ ។

ឈ្មោះថា **ព្យាបាទ** ព្រោះអត្ថថា ជាហេតុបៀតបៀន គុំគួនឲ្យដល់សេចក្ដីវិនាស ។ ឬញុំាងសេចក្ដីសុខដែលជាប្រយោជន៍ដល់ការប្រព្រឹត្តវិន័យ និងរូបសម្បត្តិជាដើមឲ្យដល់សេចក្ដីវិនាស ។

ការប្រកាន់មាំជឿថា សេចក្ដីបរិសុទ្ធមានដោយសីលវត្តឬសីល និងវត្តរបស់សមណព្រាហ្មណ៍ខាងក្រៅ មានដោយប្រការដូច្នេះ ឈ្មោះថា **សីលព្វតបរាមាស** ។

ឈ្មោះថា **ឥទំសច្ចាភិនិវេស** ព្រោះអត្ថថា បដិសេធសព្វញ្ញុតញ្ញាណ... សព្វញ្ញូ



អាទិ៍ថា លោកទៀង នេះប៉ុណ្ណោះពិត យ៉ាងដទៃជាមោឃៈ ។ អធិប្បាយថា ដោតក្រង គឺ ចងទុកដោយគន្ថៈ ៤ ទាំងនោះ ។

បទថា **ចតូហិ ឧបាទានេហិ** ដោយឧបាទាន ៤ ឈ្មោះថា **ឧបាទាន** ព្រោះប្រកាន់យ៉ាងខ្លាំង គឺ ចាប់យក ។ ឧបាទានទាំងនោះ មាន ៤ យ៉ាង គឺ កាមុបាទាន ១ ទិដ្ឋុបាទាន ១ សីលព្វតុបាទាន ១ អត្តវាទុបាទាន ១ ។ ឈ្មោះថា **កាមុបាទាន** ព្រោះប្រកាន់មាំក្នុងកាម គឺ វត្ថុ ។ម្យ៉ាងទៀត ឈ្មោះថា **កាមុបាទាន** ព្រោះកាមនោះជាឧបាទាន ។ ឈ្មោះថា **ទិដ្ឋុបាទាន** ព្រោះទិដ្ឋិនោះជាឧបាទាន ។ ឈ្មោះថា **ទិដ្ឋុបាទាន** ព្រោះប្រកាន់មាំដោយទិដ្ឋិ ។ ឧត្តរទិដ្ឋិ (ទិដ្ឋិខាងក្រោយ) ប្រកាន់មាំបុរិមទិដ្ឋិ ( ទិដ្ឋិមានក្នុងខាងកាលមុន ) ក្នុងបទមានជាអាទិ៍ថា **សស្សតោ អត្តា ច លោកោ**[1] អត្តា និងលោកទៀង ។ ឈ្មោះថា **សីសព្វតុបាទាន** ព្រោះការប្រកាន់សីល និងវត្ត ។ ម្យ៉ាងទៀត ឈ្មោះថា **សីលព្វតុបាទាន** ព្រោះសីល និងវត្តនោះជា

---

១ ខុទ្ទកនិកាយ ខុទ្ទកបាឋៈ

ឧបាទាន ។ សីលរបស់គោ និងវត្តរបស់គោជាដើម ជាឧបាទាន ព្រោះប្រកាន់ថា សេចក្តីបរិសុទ្ធរមែងមានយ៉ាងនេះ ។ ឈ្មោះថា **វាទ** ព្រោះជាហេតុពោល ។ ឈ្មោះថា **ឧបាទាន** ព្រោះជាហេតុប្រកាន់មាំ ។ ពោលអ្វី ? ប្រកាន់មាំអ្វី ? ពោលអត្តា ។ ការប្រកាន់មាំវាទៈរបស់ខ្លួន ។ ឈ្មោះថា **អត្តវាទុបាទាន** ។ ឬឈ្មោះថា **អត្តវាទុបាទាន** ព្រោះជាហេតុប្រកាន់មាំថា ខ្លួនមានត្រឹមតែវាទៈថា ខ្លួនប៉ុណ្ណោះ ។ ទិដ្ឋិសូម្បីទាំងអស់ វៀរទិដ្ឋិ ២ យ៉ាងទាំងនេះ ឈ្មោះថា **ទិដ្ឋុបាទាន** ។ ដោយឧបាទាន ៤ ទាំងនោះ ។

បទថា **ឧបាទីយតិ** ប្រកាន់មាំ គឺ កាន់យក ។ បាឋៈថា **ឧបាទិយតិ** ក៏មាន ។ សេចក្តីថា សត្វលោករមែងកាន់យកអារម្មណ៍នោះ ៗ ដោយឧបាទាន ។

បទថា **បញ្ចគតិសមារុឡ្ហា** លោកសន្និវាសឡើងកាន់គតិ ៥ ឈ្មោះថា **គតិ** ព្រោះទៅ គឺ ចូលទៅជិត ដោយហេតុធ្វើល្អ និងធ្វើអាក្រក់ គឺ ខន្ធទាំងឡាយ ព្រមដោយការប្រាកដ ។ លោកសន្និវាសឡើងកាន់គតិ ៥ ទាំងនេះ គឺ នរក ១ កំណើត-



តិរច្ឆាន ១ បេតវិស័យ ១ មនុស្ស ១ ទេវតា ១ ដ៏មានកម្លាំងដោយការឈានចុះ ។

បទថា **បញ្ចហិកាមគុណេហិ** ដោយកាមគុណ ៥ ដោយចំណែកនៃវត្ថុកាម ៥ គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ។

បទថា **រជ្ជតិ** រមែងត្រេកអរ គឺ អាស្រ័យអយោនិសោមនសិការ រមែងត្រេកអរដោយកាមគុណទាំងនោះ ព្រោះធ្វើឲ្យរាគៈកើតឡើង ។ អធិប្បាយថា ធ្វើសេចក្តីពេញចិត្តត្រេកអរ ។

បទថា **បញ្ចហិ នីវរណេហិ** ត្រូវនីវរណៈ ៥ បិទទុក ឈ្មោះថា **នីវរណ** ព្រោះរមែងរារាំង គឺ គ្របសង្កត់ចិត្ត ។ ត្រូវនីវរណៈ ៥ គឺ កាមច្ឆន្ទៈ ១ ព្យាបាទ ១ ថីនមិទ្ធៈ ១ ឧទ្ធច្ចកុក្កុច្ចៈ ១ វិចិកិច្ឆា ១ ចាប់ទុក ។

បទថា **ឱត្ថតោ** គឺ បិទបាំងទុកចំណែកខាងលើ ។

បទថា **ឆហិ វិវាទមូលេហិ** គឺ ដោយមូលហេតុវិវាទ ៦ យ៉ាង ។ ដូចព្រះមានព្រះភាគត្រាស់ទុកថា

ម្នាលភិក្ខុទាំងឡាយ មូលហេតុ នៃវិវាទទាំងនេះ មាន ៦

យ៉ាង ៗ ៦ យ៉ាង ដូចម្តេច ? ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកក្រោធ ចងសេចក្តីក្រោធទុក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជាអ្នកក្រោធ ចងសេចក្តីក្រោធទុក។ ភិក្ខុនោះ មិនគោរព មិនកោតក្រែង ក្នុងព្រះសាស្តា ។ មិនធ្វើឲ្យបរិបូរណ៍ សូម្បីក្នុងព្រះធម៌ សូម្បីក្នុងព្រះសង្ឃ សូម្បីក្នុងសិក្ខា ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាមិនកោតក្រែងក្នុងព្រះសាស្តា មិនធ្វើឲ្យបរិបូរណ៍ក្នុងព្រះធម៌ ក្នុងព្រះសង្ឃ ក្នុងសិក្ខា ។ ភិក្ខុនោះ រមែងញ៉ាំងវិវាទឲ្យកើតឡើង ក្នុងសង្ឃ ។ វិវាទរមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍



ដល់ជនដ៏ច្រើន ដើម្បីភាពមិនជាសុខដល់ជនដ៏ច្រើន ដើម្បីសេចក្តីវិនាសដល់ជនដ៏ច្រើន ដើម្បីភាពមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខដល់ទេវតា និងមនុស្សទាំងឡាយ ។

ម្នាលភិក្ខុទាំងឡាយ ប្រសិនបើពួកអ្នកពិចារណាឃើញវិវាទ នោះឯងជាមូលហេតុនៃវិវាទ ខាងក្នុងក្តី ខាងក្រៅក្តី ម្នាលភិក្ខុទាំងឡាយ ក្នុងប្រការនោះ ពួកអ្នកគប្បីព្យាយាមដើម្បីលះមូលហេតុនៃវិវាទដ៏លាមកនោះចេញ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើពួកអ្នកមិនពិចារណាឃើញវិវាទ នេះឯងជាមូល-ហេតុនៃវិវាទ ខាងក្នុងក្តី ខាងក្រៅក្តី ។

ម្នាលភិក្ខុទាំងឡាយ ក្នុងប្រការនោះ ពួកអ្នកគប្បីបដិបត្តិ ដើម្បីការមិនកើត

ផលនៃមូលហេតុនៃវិវាទដ៏លាមកនោះ តទៅបាន ។ ការលះមូលហេតុនៃវិវាទដ៏លាមកនេះ រមែងមានដោយប្រការដូច្នេះ ។ ការមិនកើតផលនៃមូលហេតុនៃវិវាទដ៏លាមកនេះ រមែងមានដោយប្រការដូច្នេះ ។

ម្នាលភិក្ខុទាំងឡាយ ប្រការដទៃនៅមានទៀត ភិក្ខុជាអ្នកមានការលុបគុណ វាយឫកស្មើ ។ ជាអ្នកមានសេចក្តីប្រណែនកំណាញ់ ។ ជាអ្នកអួតអាង មាក់ងាយគេ ។ ជាអ្នកមានការប្រាថ្នាលាមក ច្រើនទៅដោយមិច្ឆាទិដ្ឋិ ។ ជាអ្នកមានទិដ្ឋិជារបស់ខ្លួន ច្រើនទៅដោយការប្រកាន់មាំ ការប្រកាន់នោះ លះបានដោយក្រ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា



មានការប្រកាន់មាំទិដ្ឋិរបស់ខ្លួន ជាអ្នកមានការប្រកាន់មាំ មានការលះបានលំបាក ។ ភិក្ខុនោះមិនគោរពក្នុងសូម្បីក្នុងព្រះសាស្តា ។ល។ មិនកើតផលតទៅ[1] ។

ក្នុងបទទាំងនោះ បទថា **កោធនោ** ច្រើនទៅដោយសេចក្តីក្រោធ គឺ ប្រកបដោយសេចក្តីទាស់ចិត្ត ដែលមានអាការខឹងក្រោធជាលក្ខណៈ ។

បទថា **ឧបនាហី** ចងសេចក្តីក្រោធទុក គឺ ប្រកបដោយឧបនាហៈ ដែលមានលក្ខណៈមិនវៀរចាកពៀរ ។

បទថា **អហិតាយ ទុក្ខាយ ទេវមនុស្សានំ** ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខដល់ទេវតា និងមនុស្សទាំងឡាយ ។ វិវាទរបស់ភិក្ខុ ២ រូប រមែងប្រព្រឹត្តទៅដើម្បីភាពមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខដល់ទេវតា និងមនុស្សទាំងឡាយ

---

១ អង្គុត្តរនិកាយ ឆក្កនិបាត

យ៉ាងណា ។ កាលបើភិក្ខុ ២ រូប វិវាទគ្នា ដូចក្នុងកោសម្ពកខន្ធកៈ[1] អន្តេវាសិករបស់ភិក្ខុ ២ រូបនោះក្នុងវត្តនោះ ក៏វិវាទគ្នា ។ ភិក្ខុសង្ឃ ភិក្ខុនីសង្ឃ អ្នកទទួលឱវាទរបស់ភិក្ខុ ២ រូបនោះ ក៏វិវាទគ្នា ។ តពីនោះ ឧបដ្ឋាករបស់ភិក្ខុ ២ រូបនោះ ក៏វិវាទគ្នា ។ តមកទេវតា អ្នករក្សាមនុស្សទាំងឡាយ ក៏បែកចេញជាពួក ។ ទេវតារក្សាធម្មវាទី ក៏ជាពួកធម្មវាទី ។ ដែលរក្សាអធម្មវាទី ក៏ជាពួកអធម្មវាទី ។ បន្ទាប់មក ភុម្មដ្ឋទេវតាដែលជាមិត្តរបស់អារក្ខទេវតា ក៏បែកគ្នា ។ ទេវតា និងមនុស្សទាំងឡាយ វៀរព្រះអរិយសាវក បែកជា ២ ចំណែក ដោយត ៗ គ្នាយ៉ាងនេះ រហូតដល់ព្រហ្មលោក ។ អធម្មវាទី ច្រើនជាងធម្មវាទី ។ តអំពីនោះមក វត្ថុដែលពួកដ៏ច្រើនប្រកាន់ ទើបជាសច្ចៈ ព្រោះហេតុនោះ ពួកដែលច្រើនជាងទើបនាំគ្នាលះបង់ធម៌ ប្រកាន់យកអធម៌ ។ ពួកអធម៌ទាំងនោះ ប្រកាន់អធម៌ជាគោល រមែងកើតក្នុងអបាយ ។ ការវិវាទរបស់ភិក្ខុ ២ រូប យ៉ាងនេះ រមែងប្រព្រឹត្ត

[1] វិន័យ មហាខន្ធកៈ



ទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខដល់ទេវតា និងមនុស្សទាំងឡាយ ។

បទថា **អជ្ឈត្តំ វា** ខាងក្នុងក្តី គឺ ក្នុងបរិស័ទរបស់ពួកលោក ។ បទថា **ពហិទ្ធា វា** ចំណែកខាងក្រៅក្តី គឺ បរិស័ទរបស់ពួកដទៃ ។ បទថា **មក្ខី** គឺ ប្រកបដោយការលុបគុណ ដែលមានលក្ខណៈលុបបំបាត់គុណលោក ។ បទថា **បលាសី** គឺ ប្រកបដោយការវាយឫកស្មើ ដែលមានលក្ខណៈរឹងត្អឹង ។ បទថា **ឥស្សុកី** គឺ ប្រកបដោយសេចក្តីច្រណែន មានលក្ខណៈ គឺ សេចក្តីឫស្យា មានសក្ការៈរបស់អ្នកដទៃជាដើម ។ បទថា **មច្ឆរី** គឺ ប្រកបដោយមច្ឆរិយៈ ៥ មានអាវាសមច្ឆរិយៈជាដើម ។ បទថា **សឋោ** អួតអាង គឺ ពេញទៅដោយការឡេកឡើយ ។ បទថា **មាយាវី** មាយា គឺ បិទបាំងអំពើអាក្រក់ដែលខ្លួនបានធ្វើ ។ បទថា **បាបិច្ឆោ** មានការប្រាថ្នាលាមក គឺ ជាអ្នកទ្រុស្តសីល ប្រាថ្នាការលើកសរសើរក៏មិនមាន ។ បទថា **មិច្ឆាទិដ្ឋិ** បានដល់ នត្ថិកវាទី ( មានវាទៈថាមិនមាន ) អហេតុកវាទី ( មានវាទៈថាមិនមានហេតុ ) អកិរិយវាទី ( មានវាទៈថាមិនមានការធ្វើ ) ។

បទថា **សន្ទិដ្ឋិបរាមាសី** គឺ ស្ទាបអង្អែលទិដ្ឋិរបស់ខ្លួនឯងប៉ុណ្ណោះ ។

បទថា **អាធានគ្គាហី** គឺ ប្រកាន់មាំ ។

បទថា **ទុប្បដិនិស្សគ្គី** គឺ មិនអាចលះបង់វត្ថុដែលខ្លួនប្រកាន់បាន ។ ចំណែកក្នុងខុទ្ទកវិភង្គ លោកពោលដល់ធម៌មួយ ៗ ដោយអំណាចជាប្រធានថា មូលហេតុនៃវិវាទ ៦ ដូចម្តេច ? គឺ កោធៈ ១ មក្ខៈ ១ ឥស្សា ១ សាថេយ្យៈ ១ បាបិច្ឆា ១ សន្ទិដ្ឋិបរាមាសី ១ ( ការប្រកាន់ទិដ្ឋិរបស់ខ្លួន ) ១ ។ នេះគឺមូលហេតុនៃវិវាទ ៦ យ៉ាង[1] ។

បទថា **ឆហិ តណ្ហាកាយេហិ** ដោយកងតណ្ហា ៦ គឺ ដោយតណ្ហា ៦ ដូចបានពោលហើយ គឺ រូបតណ្ហា ១ សទ្ទ-តណ្ហា ១ គន្ធតណ្ហា ១ រសតណ្ហា ១ ផោដ្ឋព្វតណ្ហា ១ ធម្មតណ្ហា ១ ក្នុងតណ្ហាទាំងនោះ ព្រោះតណ្ហាមួយ ៗ រមែងមានដ៏ច្រើន ព្រោះកើតរឿយៗ ក្នុងអារម្មណ៍សូម្បីមួយៗ ព្រោះ

---

១ អភិធម្ម វិភង្គ



មានអារម្មណ៍ច្រើន ។ ដូច្នោះលោកទើបពោលថា **តណ្ហាកាយា** កងតណ្ហា ព្រោះប្រកប **កាយ** ស័ព្ទ ដោយអត្ថថា ពួក ។ សូម្បីកាលពោលថា **តណ្ហាកាយា** ក៏គឺ តណ្ហានោះឯង ។

បទថា **រជ្ជតិ** រមែងប្រាថ្នា គឺ ពេញចិត្តរីករាយក្នុងអារម្មណ៍ដោយខ្លួនឯង ។

បទថា **ឆហិ ទិដ្ឋិគតេហិ** ដោយទិដ្ឋិ ៦ លោកពោលទុកហើយក្នុងសព្វាសវសូត្រ ។ ក្នុងសូត្រនោះ ព្រះមានព្រះភាគត្រាស់ទុកថា

> កាលបើភិក្ខុមនសិការដោយមិនប្រពៃ
> យ៉ាងនេះ ទិដ្ឋិ ៦ យ៉ាង ណាមួយ រមែងកើត
> ឡើង ។ គឺ ទិដ្ឋិដោយសេចក្តីពិត ដោយ
> សេចក្តីតាំងមាំ រមែងកើតដល់ភិក្ខុនោះថា
> **អត្ថិ មេ អត្តា** អត្តារបស់យើងមាន ។
> ទិដ្ឋិដោយសេចក្តីពិត ដោយការប្រកាន់
> ជឿបាន រមែងកើតដល់ភិក្ខុនោះថា **នត្ថិ**
> **មេ អត្តា** អត្តារបស់យើងមិនមាន ។

ទិដ្ឋ ។ល។ រមែងកើតឡើងដល់ភិក្ខុនោះ ថា **អត្តានាវ អត្តានំ សញ្ជានាមិ** យើងដឹងច្បាស់អត្តាដោយខ្លួនឯង ។ឬទិដ្ឋិ ។ល។ រមែងកើតដល់ភិក្ខុនោះថា **អនត្តនាវ អត្តានំ សញ្ជានាមិ** យើងដឹងច្បាស់អត្តាដោយអនត្តា ។ ម្យ៉ាងវិញទៀត ទិដ្ឋិរមែងមានដល់ភិក្ខុនោះ យ៉ាងនេះថា អត្តារបស់យើងនេះ ជាអត្តាដែលអ្នកពោល អ្នកដឹង រមែងសោយវិបាករបស់កម្មទាំងឡាយទាំងល្អ និងអាក្រក់ក្នុងអារម្មណ៍នោះ ៗ ក៏អត្តារបស់យើងនេះ ពិតប្រាកដ យឺនយូរទៀង មិនមានការប្រែប្រួលជាធម្មតា នឹងតាំងនៅជារបស់ទៀងជានិច្ចយ៉ាងនោះឯង[១] ។

ក្នុងបទទាំងនោះ បទថា **អត្ថិ មេ អត្តា** គឺ សស្សតទិដ្ឋិ

១ មជ្ឈិមនិកាយ មូលបណ្ណាសកៈ



រមែងកាន់យកថា ខ្លួនមានហើយក្នុងកាលទាំងពួង ។

បទថា **សច្ចតោ ថេតតោ** គឺ ដោយសេចក្តីពិត និងដោយសេចក្តីតាំងមាំ ។ លោកអធិប្បាយថា ដោយការតាំងមាំយ៉ាងល្អថា **ឥទំ សច្ចំ** នេះទៀង ។

បទថា **នត្ថិ មេ អត្តា** គឺ ឈ្មោះថា ឧច្ឆេទទិដ្ឋិ ព្រោះប្រកាន់ការមិនមានមិនកើតក្នុងអត្តានោះ ៗ របស់សត្វដែលមានហើយ ។ ម្យ៉ាងវិញទៀត ឈ្មោះថា សស្សតទិដ្ឋិ ព្រោះប្រកាន់ថាសូម្បីទិដ្ឋិមុន ៗ ក៏មានក្នុងកាល ៣ , ឧច្ឆេទទិដ្ឋិ ព្រោះប្រកាន់ថា បច្ចុប្បន្នប៉ុណ្ណោះមាន , ឧច្ឆេទទិដ្ឋិ ព្រោះប្រកាន់ថា សូម្បីទិដ្ឋិក្រោយក្នុងអតីត និងអនាគតក៏មិនមាន ដូចទិដ្ឋិរបស់ម្ចាស់លទ្ធិដែលប្រកាន់ថា " ផេះ ធ្យូង ជាគ្រឿងបូជា " សស្សតទិដ្ឋិ ព្រោះប្រកាន់ថា ក្នុងអតីតប៉ុណ្ណោះមិនមាន ដូចរបស់អ្នកមានការឃើញកើតឡើងដោយមិនមានហេតុផល ។

បទថា **អត្តនាវ អត្តានំ សញ្ជានាតិ** គឺ មានទិដ្ឋិថា យើងរមែងដឹងច្បាស់អត្តានេះ ដោយខ្លួននេះ ព្រោះប្រកាន់ថា អត្តាក្នុងខន្ធដោយប្រកតី គឺ សញ្ញាខន្ធ ហើយដឹងច្បាស់ខន្ធ

ដ៏សេសដោយសញ្ញាខន្ធ ។

បទថា **អត្តនាវ អនត្តានំ** មានទិដ្ឋិយ៉ាងនេះ ព្រោះប្រកាន់សញ្ញាខន្ធនោះឯង ថាជាអត្តា ។ ប្រកាន់ខន្ធដ៏សេស ៤ យ៉ាងថាជាអនត្តា ហើយដឹងច្បាស់ខន្ធទាំងនោះ ដោយសញ្ញាខន្ធ ។

បទថា **អនត្តាវ អត្តានំ** គឺ មានទិដ្ឋិយ៉ាងនេះ ព្រោះប្រកាន់សញ្ញាខន្ធថា ជាអនត្តា ។ ប្រកាន់ខន្ធ ៤ ពួកនេះ ថាជាអត្តា ហើយដឹងច្បាស់ខន្ធទាំងនោះ ដោយសញ្ញាខន្ធ ។

ទិដ្ឋិសូម្បីទាំងអស់ ក៏ជាសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិនោះឯង ។

ចំណែកបទមានជាអាទិ៍ថា **វទោ វេទេយ្យោ** ជាអាការរបស់ការប្រកាន់មាំក្នុងសស្សតទិដ្ឋិនោះឯង ក្នុងបទទាំងនោះ ឈ្មោះថា **វទោ** ព្រោះអត្ថថា ពោល ។ លោកអធិប្បាយថា អ្នកធ្វើវចីកម្ម ឈ្មោះថា **វេទេយ្យោ** ព្រោះអត្ថថា ដឹង ។ លោកអធិប្បាយថា ដឹង និងសោយ ដឹងអ្វី ? ដឹងវិបាករបស់កម្មល្អ និងកម្មអាក្រក់ ក្នុងអារម្មណ៍នោះ ៗ ។

បទថា **តត្រ តត្រ** គឺ ក្នុងយោនិ គតិ ឋិតិ និវាស និង



និកាយនោះ ៗ ឬក្នុងអារម្មណ៍ ។ បទថា **និច្ចោ** គឺ មិនមានការកើតរលត់ ។ បទថា **ធុវោ** គឺ តាំងមាំជាសារៈ ។

បទថា **សស្សតោ** គឺ ប្រព្រឹត្តទៅអស់កាលទាំងពួង ។ បទថា **អវិបរិណាមធម្មោ** គឺ មិនលះបង់ការៈដើមរបស់ខ្លួន មិនដល់សភាពមានប្រការផ្សេង ៗ ដូចសត្វបង្កួយ ។

បទ **សស្សតិសមំ** លោកពោល **សស្សតិយោ** ដោយវោហារថា ព្រះច័ន្ទ ព្រះអាទិត្យ សមុទ្រ ផែនដីធំ ភ្នំ ពន្ទឹ ។ ស្មើដោយសភាពទៀង ឈ្មោះថា **សស្សតិសមំ** ។

ទិដ្ឋិមានយ៉ាងនេះ ព្រោះប្រកាន់ថា នឹងតាំងនៅដរាបមានសភាពទៀងនឹងនៅប្រាកដ ។ តែក្នុងខុទ្ទកវត្ថុវិភង្គ លោកពោលដល់ទិដ្ឋិ ៦ ប្លែកចេញទៅយ៉ាងនេះថា អត្តាសោយវិបាករបស់កម្មល្អ និងកម្មអាក្រក់អស់កាលដ៏យូរ ក្នុងអារម្មណ៍នោះ ៗ ។ អត្តានោះ មិនកើតមិនមាន ។ អត្តានោះមិនកើត នឹងមិនមាន ។ អត្តាជារបស់ពិតប្រាកដ យឺនយូរ ទៀង មានការមិនប្រែប្រួលទៅជាធម្មតា ។ ឬថា ទិដ្ឋិរមែងកើតដោយសេចក្តីពិត ដោយសេចក្តីតាំងមាំដល់ភិក្ខុនោះ ដោយប្រការដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **ន សោ ជាតោ នាហោសិ** គឺ អត្តានោះឈ្មោះថា មិនកើត ព្រោះមិនកើតជាធម្មតា ។ អធិប្បាយថា មាននៅគ្រប់កាល ដោយហេតុនោះ អត្តាមិនមានក្នុងអតីត ។ នឹងមិនមានក្នុងអនាគត ។ ព្រោះអត្តាណាកើតហើយ ។ អត្តានោះមានហើយ ។ និងអត្តាណានឹងកើត អត្តានោះក៏នឹងមាន លោកពោលទុកដូច្នេះ ។

ម្យ៉ាងវិញទៀត បទថា **ន សោ ជាតោ នាហោសិ** គឺ អត្តានោះមិនកើត មិនមានហើយសូម្បីក្នុងអតីត ព្រោះកើតគ្រប់កាល ។ សូម្បីក្នុងអនាគតមិនកើត នឹងមិនមាន ។ អនុស័យទាំងឡាយមានអត្ថដូចបានពោលហើយ ។

បទថា **សត្តហិ សញ្ញោជនេហិ** ត្រូវសំយោជនៈ ៧ ចងទុក លោកពោលទុកហើយក្នុងសត្តកនិបាត ។ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា

ម្នាលភិក្ខុទាំងឡាយ សំយោជន៍ ៧
ទាំងនេះ ។ សំយោជន៍ ៧ ដូចម្តេច ?
អនុនយសំយោជន៍ ១ បដិឃសំយោជន៍ ១



ទិដ្ឋិសំយោជន៍ ១ វិចិកិច្ឆាសំយោជន៍ ១
មានះសំយោជន៍ ១ ភវរាគសំយោជន៍ ១
អវិជ្ជាសំយោជន៍ ១ ។ ម្នាលភិក្ខុទាំងឡាយ
សំយោជន៍ ៧ ទាំងនេះឯង[១] ។

ក្នុងបទទាំងនោះ បទថា **អនុនយសញ្ញោជនំ** បានដល់កាមរាគសំយោជន៍ ។ សំយោជន៍ទាំងនេះទាំងអស់ ហៅថា **សញ្ញោជន** ព្រោះជាកិលេសគ្រឿងចង ។

បទថា **សត្តហិ មានេហិ** លោកសន្និវាសប៉ោងឡើងព្រោះមានះ ៧ លោកពោលទុកហើយក្នុងខុទ្ទកវត្ថុវិភង្គ ។ ពិតណាស់ក្នុងវិភង្គនោះ ព្រះមានព្រះភាគត្រាស់ទុកថា

**មានះ អតិមានះ មានាតិមានះ ឱមានះ**
**អធិមានះ អស្មិមានះ មិច្ឆាមានះ ។**

ក្នុងបទទាំងនោះ បទថា **មានោ** ការប្រកាន់ខ្លួន គឺ ស្មាបអង្អែលបុគ្គល ដោយអំណាចនៃបុគ្គលអ្នកប្រសើរជាង ជាដើម

---

១ អង្គុត.សត្តក

និងក្រអឺតក្រទម ឆ្មើងកន្ទ្រើងក្នុងវត្ថុ មានជាតិជាដើម ។

បទថា **អតិមានោ** មើលងាយលោក គឺ ក្រអឺតក្រទម ដោយន័យថា មិនមាននរណាដូចយើងដោយជាតិជាដើម ។

បទថា **មានាតិមានោ** មើលងាយដោយការទម្រើសខ្លួន គឺ កើតការប្រកាន់ខ្លួនថា អ្នកនេះកាលមុនដូចនឹងយើង តែពេលនេះ យើងប្រសើរជាង អ្នកនេះថោកទាបជាងយើង ។

បទថា **ឱមានោ** ប្រកាន់ខ្លួនថា អន់ជាងគេ គឺ ប្រកាន់ខ្លួនថាទាបជាងដោយជាតិជាដើម គឺ ប្រកាន់ខ្លួនថា យើង ជាមនុស្សថោកទាបនោះឯង ។

បទថា **អធិមានោ** ប្រកាន់ខ្លួនខ្លាំង គឺ មានះថា យើងដឹងច្បាស់សច្ចធម៌ ៤ ដែលមិនមានអ្នកដឹងឡើយ ។ អធិមានះនេះ កើតដល់បថុជ្ជនអ្នកមានសីលបរិសុទ្ធ មិនប្រមាទក្នុងកម្មដ្ឋាន កំណត់នាមរូប ឆ្លងសេចក្តីសង្ស័យដោយកំណត់បច្ច័យ លើកឡើងកាន់ព្រះត្រៃលក្ខណ៍ ពិចារណាសង្ខារ ប្រារព្ធវិបស្សនា , មិនកើតដល់អ្នកដទៃ ។

បទថា **អស្មិមានោ** ប្រកាន់យើង គឺ មានះថា យើងមាន



នៅក្នុងខន្ធ មានរូបជាដើម ។ លោកអធិប្បាយថា មានមានះ កើតឡើងដោយបទមានជាអាទិ៍ថា **អហំ រូបំ** រូប ជាយើង យើង គឺ រូប ។

បទថា **មិច្ឆាមានោ** មានះខុស គឺ មានះកើតឡើង ដោយបទមានជាអាទិ៍ថា **បាបកេន កម្មាយតនា** កម្មាយតនៈ កើតដោយសភាពលាមក ។

បទថា **លោកធម្មា** មានអត្ថបានពោលហើយ ។ បទថា **សម្បរិវត្តតិ** វិលហើយ គឺ វិលវល់ទៅដោយលោកធម៌ ដែលជាហេតុ ដោយសេចក្តីរីករាយក្នុងលោកធម៌ ៤ ។ មានលាភជាដើម ដោយការមិនរីករាយក្នុងលោកធម៌ ៤ មានការវិនាសលាភជាដើម ។ អធិប្បាយថា លះភាវៈប្រក្រតី ។ សូម្បី **មិច្ឆត្តា** ក៏មានអត្ថដូចពោលហើយ ។ បទថា **និយ្យាតោ** សំយុងចុះហើយ គឺ ស្ទុះទៅ អធិប្បាយថា គ្របសង្កត់ហើយ ។

បទថា **អដ្ឋហិ បុរិសទោសេហិ** ព្រោះបុរសទោស ៨ ក្នុងអដ្ឋកនិបាត លោកពោលព្រមដោយឧបមា ។ ក្នុងខុទ្ទកវត្ថុ-វិភង្គ លោកពោលវៀរឧបមា ។ សមពិតដូចលោកពោលទុកថា

បុរសទោស ៨ ដូចម្តេច ? ភិក្ខុទាំងឡាយ ក្នុងសាសនានេះ ចោទភិក្ខុដោយអាបត្តិ , ភិក្ខុនោះ ត្រូវភិក្ខុទាំងឡាយចោទដោយអាបត្តិរមែងកែខ្លួន ដោយការមិនមានសតិថា ខ្ញុំនឹកមិនបាន ខ្ញុំនឹកមិនបាន ។ នេះជាបុរសទោសប្រការទី ១ ។

ប្រការតទៅ ភិក្ខុទាំងឡាយចោទភិក្ខុដោយអាបត្តិ ភិក្ខុនោះ ត្រូវភិក្ខុទាំងឡាយចោទដោយអាបត្តិ រមែងដាក់កំហុសចោទក៍ថា មិនមានប្រយោជន៍អ្វីដែលនឹងនិយាយជាមួយលោកដែលល្ងង់ មិនឆ្លាត , សូម្បីលោកក៏សមគួរដែលនឹងនិយាយជាមួយខ្ញុំឬ ? នេះជាបុរសទោសប្រការទី ២ ។

ប្រការតទៅ ភិក្ខុទាំងឡាយចោទភិក្ខុដោយអាបត្តិ ។ ភិក្ខុនោះ ត្រូវភិក្ខុទាំងឡាយចោទដោយអាបត្តិ ក៏ប្រាប់អាបត្តិចោទក៍ថា



សូម្បីលោកក៏ត្រូវអាបត្តិប្រការនេះ លោកចូរធ្វើយប់មុន ។ នេះជាបុរសទោសប្រការទី ៣ ។

ប្រការតទៅ ភិក្ខុ ។ល។ និយាយត្រឡប់បញ្ច្រាស់ និយាយរឿងផ្សេង ធ្វើសេចក្តីក្រោធ ទោសៈ និងការមិនពេញចិត្តឲ្យប្រាកដ ។ នេះជាបុរសទោសទី ៤ ។

ប្រការតទៅ ភិក្ខុ ។ល។ និយាយលើកដៃក្នុងកណ្តាលសង្ឃ ។ នេះជាបុរសទោសប្រការទី ៥ ។

ប្រការតទៅ ភិក្ខុ ។ល។ មិនជឿសង្ឃ មិនជឿចោទក៍ ដើរគេចចេញទៅ ។ នេះជាបុរសទោសទី ៦ ។

ប្រការតទៅ ភិក្ខុ ។ល។ គិតថា យើងមិនបានត្រូវអាបត្តិ , យើងបានត្រូវអាបត្តិ ហើយនៅស្ងៀម ធ្វើឲ្យសង្ឃ

លំបាក ។ នេះជាបុរសទោសប្រការទី ៧ ។

ប្រការតទៅ ភិក្ខុ ។ល។ ពោលយ៉ាងនេះថា ពុទ្ធោអើយ ពួកលោកនឹងមកជ្រួលច្របល់អ្វីចំពោះខ្ញុំ ។ ពេលនេះខ្ញុំនឹងប្រាប់លាសិក្ខា លាសឹកហើយ ។ ភិក្ខុនោះក៏សឹក ហើយពោលយ៉ាងនេះថា ពេលនេះពួកលោកចូរសប្បាយចិត្តចុះ ។ នេះជាបុរសទោសប្រការទី ៨ ។

ក្នុងបទទាំងនោះ បទថា **បុរិសទោសា** គឺ ទោសរបស់បុរស ឈ្មោះថា ទោស ព្រោះប្រទូសរ៉ាយសន្តានបុរស ។ បទថា **ន សរាមិ** គឺ ភិក្ខុនោះកែខ្លួន ដោះសារ ដោយមិនមានសតិថា ខ្ញុំចាំមិនបាន មិនបានយកចិត្តទុកដាក់ដល់កម្មដែលខ្ញុំធ្វើហើយនោះទេ ។

បទថា **ចោទកំយេវ បដិប្ផរតិ** គឺ ដាក់កំហុសចោទក៍ ។ តាំងនៅដោយសភាពក្មេចឆ្មើយតប ។ បទថា **កិន្នុ ខោ តុយ្ហំ** គឺ លោកសម្តែងថា ប្រយោជន៍អ្វីដែលនឹងត្រូវនិយាយជាមួយលោក



ដែលល្ងង់មិនឆ្លាត , លោកមិនដឹងវត្ថុ , មិនដឹងអាបត្តិ , មិនដឹងការចោទ ។ បន្តុះបង្អាប់ថា សូម្បីលោកក៏មិនដឹងអ្វី ៗ ក៏ប្រាថ្នានឹងនិយាយ ។

បទថា **បច្ចារោបេតិ** លើកទោសឡើង គឺ ពោលបទមានជាអាទិ៍ថា សូម្បីលោកនេះឯង ឈ្មោះថាលើកទោសឡើង គឺ ប្រាប់អាបត្តិ ។ បទថា **បដិករោហិ** ធ្វើយប់ លោកសម្តែងទុកថា លោកចូរសម្តែងទេសនាគាមិនី គឺ ការសម្តែងអាបត្តិ លោកចូរចេញចាកវុដ្ឋានគាមិនី គឺ ចេញចាកអាបត្តិ ។ តអំពីនោះលោកតាំងនៅក្នុងសេចក្តីបរិសុទ្ធិហើយ ទើបចោទអ្នកដ៏ទៃ ។

បទថា **អញ្ញេនញ្ញំ បដិចរតិ** និយាយត្រឡប់ត្រឡិន គឺ បិទបាំងហេតុដទៃដោយហេតុដទៃ ឬបិទបាំងពាក្យនិយាយដោយពាក្យដទៃ ។ ចោទក៍ពោលថា លោកត្រូវអាបត្តិហើយ ។ ភិក្ខុនោះពោលថា នរណាត្រូវអាបត្តិ ត្រូវអាបត្តិអ្វី ត្រូវអាបត្តិក្នុងប្រការណា ត្រូវអាបត្តិយ៉ាងណា ។ លោកពោលអ្វី កាលបើចោទក៍ពោលថា អាបត្តិអ្វី លោកក៏ឃើញហើយ ។ ភិក្ខុនោះពោលថា យើងមិនបានឮ ហើយផ្ទៀងត្រចៀកស្តាប់ទៅ ។

បទថា **ពហិទ្ធា កថំ អបនាមេតិ** និយាយក្រៅរឿង គឺ កាលបើចោទក៏សួរថា លោកត្រូវអាបត្តិប្រការនេះឬ ។ ភិក្ខុពោលថា ខ្ញុំនឹងទៅក្រុងបាដលីបុត្ត ។ កាលបើចោទក៏និយាយដដែល ៗ ថា ខ្ញុំមិនបានសួរដល់ការទៅក្រុងបាដលីបុត្តរបស់លោកទេ ។ ខ្ញុំសួរអាបត្តិ ។ ភិក្ខុនោះពោលថា បន្ទាប់ពីនោះខ្ញុំនឹងទៅព្រះរាជមន្ទីរ ។ កាលបើចោទក៏ ពោលថា លោកម្ចាស់នឹងទៅព្រះរាជមន្ទីរ ឬទៅផ្ទះព្រាហ្មណ៍ក៏ដោយ ។ លោកម្ចាស់ត្រូវអាបត្តិហើយ ។ ភិក្ខុនោះពោលពាក្យមានជាអាទិ៍ថា ខ្ញុំនឹងបានសាច់ជ្រូកក្នុងទីនោះ គឺ និយាយក្រៅរឿងទៅវិញ ។

បទថា **កោបំ** គឺ សេចក្តីក្រោធ ។ បទថា **ទោសំ** គឺ ការប្រទូសរ៉ាយ ។ បទទាំងពីរនេះ ជាឈ្មោះរបស់សេចក្តីក្រោធនោះឯង ។

បទថា **អប្បច្ចយំ** គឺ អាការមិនពេញចិត្ត ។ បទនេះជាឈ្មោះរបស់ទោមនស្ស ។

បទថា **បាតុករោតិ** គឺ សម្តែងប្រកាស ។ បទថា **ពាហាវិក្ខេបកំ ភណតិ** គឺ គ្រវីដៃទៅមកហើយនិយាយពាក្យមិនមាន



អៀនខ្មាស់ ។ បទថា **អនាទិយិត្វា** សេចក្តីថា មិនប្រកាន់ជឿរដោយសេចក្តីគោរព មើលងាយ មិនចូលចិត្ត ។

បទថា **វិហេសេតិ** គឺ ឲ្យលំបាក រំខាន ។ បទថា **អតិពាឡ្ហំ** គឺ ធ្ងន់ខ្លាំង លើសខ្នាត ។

បទថា **មយិ ព្យាវដា** គឺ ដល់សេចក្តីខ្វល់ខ្វាយក្នុងយើង ។ បទថា **ហីនាយាវត្តិត្វា** គឺ វិលមកដើម្បីភាពជាបុគ្គលថោកទាប គឺ ជាគ្រហស្ថ ។

បទថា **អត្តមនា ហោថ** គឺ ពួកលោកចូរសប្បាយចិត្តចុះ ភិក្ខុនោះពោលដោយបំណងថា លោកចូរបានវត្ថុដែលខ្ញុំគួរបានចុះ ។ ខ្ញុំធ្វើសេចក្តីសុខឲ្យដល់ពួកលោកហើយ ។ បទថា **ទុស្សតិ** គឺ ប្រទូសរ៉ាយ ។

បទថា **នវហិ អាឃាតវត្ថូហិ** ដោយអាឃាតវត្ថុ ៩ លោកពោលដោយអំណាចការកើតក្នុងសត្វទាំងឡាយ ។ សមដូចព្រះមានព្រះភាគត្រាស់ទុកថា :

ម្នាលភិក្ខុទាំងឡាយ អាឃាតវត្ថុ វត្ថុ

ជាហេតុអាឃាតគ្នា ៩ យ៉ាងទាំងនេះ ។

អាឃាតវត្ថុ ៩ យ៉ាងដូចម្ដេច ?

-ភិក្ខុចងអាឃាតថា គេបានប្រព្រឹត្តសេចក្ដីវិនាសដល់យើង ១ ។

-គេរមែងប្រព្រឹត្តសេចក្ដីវិនាសដល់យើង ១ ។

-គេនឹងប្រព្រឹត្តសេចក្ដីវិនាសដល់យើង ១ ។

-គេបានប្រព្រឹត្តសេចក្ដីវិនាស ដល់អ្នកដែលជាទីស្រឡាញ់ជាទីពេញចិត្តរបស់យើង ១ ។

-គេរមែងប្រព្រឹត្តសេចក្ដីវិនាស ដល់អ្នកដែលជាទីស្រឡាញ់ជាទីពេញចិត្តរបស់យើង ១ ។

-គេនឹងប្រព្រឹត្តសេចក្ដីវិនាស ដល់អ្នកដែលជាទីស្រឡាញ់ជាទីពេញចិត្តរបស់យើង ១ ។

-គេបានប្រព្រឹត្តប្រយោជន៍ ដល់អ្នកដែលមិនជាទីស្រឡាញ់មិនជាទីពេញចិត្តរបស់យើង ១ ។

-គេរមែងប្រព្រឹត្តប្រយោជន៍ ដល់អ្នកដែលមិនជាទីស្រឡាញ់មិនជាទីពេញចិត្តរបស់យើង ១ ។

-គេនឹងប្រព្រឹត្តប្រយោជន៍ ដល់អ្នកដែលមិនជាទីស្រឡាញ់



មិនជាទីពេញចិត្តរបស់យើង ១ ។

ម្នាលភិក្ខុទាំងឡាយ អាឃាតវត្ថុ ៩ យ៉ាងទាំងនេះឯង ។

ក្នុងបទទាំងនោះ បទថា **អាឃាតវត្ថូនិ** គឺ ហេតុនៃសេចក្ដីអាឃាត ។

មយ៉ាងទៀត ក្នុងបទថា **អាឃាតំ** នេះ បានដល់ សេចក្ដីក្រោធ ។ សេចក្ដីក្រោធនោះឯង លោកហៅថា អាឃាតវត្ថុ ព្រោះជាវត្ថុនៃសេចក្ដីក្រោធខ្លាំងឡើង ៗ ។ បទថា **អាឃាតំ ពន្ធតិ** គឺ ចង ធ្វើឲ្យសេចក្ដីក្រោធកើត ។

អាឃាតវត្ថុ ៩ សូម្បីដទៃដែលលោកពោលទុកក្នុងនិទ្ទេសថា ៖

គេមិនបានប្រព្រឹត្តប្រយោជន៍ដល់យើង ១ គេរមែងមិនប្រព្រឹត្ត ១ គេនឹងមិនប្រព្រឹត្ត ១ ។ គេមិនបានប្រព្រឹត្តប្រយោជន៍ដល់អ្នកជាទីស្រឡាញ់ ជាទីពេញចិត្តរបស់យើង ១ គេរមែងមិនប្រព្រឹត្ត ១ ។ គេនឹងមិនប្រព្រឹត្ត ១ ។ គេមិនបានប្រព្រឹត្តសេចក្ដីវិនាសដល់អ្នកមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់យើង ១ គេរមែងមិនប្រព្រឹត្ត ១ គេនឹង មិនប្រព្រឹត្ត ១ ដូច្នេះ លោកសង្គ្រោះ

ចូលអាឃាតវត្ថុ ៩ យ៉ាង ដូចគ្នា ។

បទថា **អាឃាតិតោ** ប្រទូសរ៉ាយ គឺ បៀតបៀនគ្នា ។

បទថា **នវវិធមានេហិ** ព្រោះមានះ ៩ យ៉ាង ។ មានះ ៩ យ៉ាងដូចម្តេច ? មានះ ៩ យ៉ាង គឺ មានះថា ជាអ្នកប្រសើរជាងគេ ប្រកាន់ខ្លួនថា ប្រសើរជាងគេ ១ ស្មើគេ ១ ថោកទាបជាងគេ ១ , ជាអ្នកស្មើគេ ប្រកាន់ខ្លួនថា ប្រសើរជាងគេ ១ ស្មើគេ ១ ថោកទាបជាងគេ ១ , ជាអ្នកថោកទាបជាងគេ ប្រកាន់ខ្លួនថា ប្រសើរជាងគេ ១ ស្មើគេ ១ ថោកទាបជាងគេ ១ ។ មានះ ៩[1] យ៉ាង ទាំងនេះ ។

គប្បីជ្រាបសេចក្តីក្នុងបទនេះដូចតទៅនេះ ។ បទថា **សេយ្យស្ស សេយ្យោហមស្មីតិ មានោ** មានះថា ជាអ្នកប្រសើរជាងគេ , ប្រកាន់ថា ប្រសើរជាងគេ រមែងកើតដល់ព្រះរាជា និងបព្វជិតទាំងឡាយ ។ ព្រោះព្រះរាជារមែងទ្រង់ធ្វើមានះនេះថា នរណាដូចយើងដោយដែន ទ្រព្យ ឬពាហនៈ ។

១ អភិធម្ម វិភង្គ



សូម្បីបព្វជិតក៏ធ្វើមានះថា នរណាដូចយើង ដោយសីល និងធុតង្គ ។

បទថា **សេយ្យស្ស សទិសោហមស្មីតិ មានោបិ** សូម្បីមានះថា ជាអ្នកប្រសើរជាងគេ ប្រកាន់ថាស្មើគេ ក៏រមែងកើតដល់ព្រះរាជា និងបព្វជិតទាំងនោះដូចគ្នា ព្រោះព្រះរាជារមែងទ្រង់ធ្វើមានះនេះថា អ្វីរបស់យើងធ្វើឲ្យផ្សេងគ្នានឹងព្រះរាជាដទៃដោយដែន ទ្រព្យ ឬពាហនៈ ។ សូម្បីបព្វជិតក៏ធ្វើមានះនេះថា អ្វីរបស់យើងធ្វើឲ្យផ្សេងគ្នានឹងភិក្ខុដទៃដោយសីល និងធុតង្គជាដើម ។

បទថា **សេយ្យស្ស ហីនោហមស្មីតិ មានោបិ** សូម្បីមានះថា ជាអ្នកប្រសើរជាងគេ ប្រកាន់ថា ថោកទាបជាងគេ ក៏រមែងកើតដល់ព្រះរាជា និងបព្វជិតទាំងឡាយនោះ ដូចគ្នា ។ ព្រោះដែន ទ្រព្យ ឬពាហនៈជាដើមរបស់ព្រះរាជាណាដែលមិនទាន់សម្បូរ ។ ព្រះរាជានោះ រមែងទ្រង់ធ្វើមានះនេះថា ត្រឹមតែសេចក្តីសុខរបស់ពាក្យនិយាយថា ព្រះរាជារបស់យើងប៉ុណ្ណោះ ។ យើងនឹងជាព្រះរាជាបានយ៉ាងណា ។ សូម្បីបព្វជិតមានលាភសក្ការៈ

តិច រមែងធ្វើមានះនេះថា ត្រឹមតែនិយាយគ្នាប៉ុណ្ណោះថា យើងជាធម្មកថិក ជាពហុស្សូត ជាមហាថេរៈ ។ យើងជាធម្មកថិកបានដូចម្តេច ជាពហុស្សូត ជាមហាថេរៈបានដូចម្តេច ។ លាភសក្ការៈមិនមានដល់យើង ។

បទមានជាអាទិ៍ថា **សទិសស្ស សេយ្យោហមស្មីតិ មានោ** មានះថា ជាអ្នកស្មើគេប្រកាន់ថា ប្រសើរជាងគេ រមែងកើតដល់ពួកអាមាត្យជាដើម ។ ព្រោះអាមាត្យក្តី ខ្ញុំរាជការក្តី រមែងធ្វើមានះថា នរណាជារាជបុរសដទៃដូចជា យើងដោយភោគៈ យាន និងពាហនៈជាដើម ។ អ្វីរបស់យើងធ្វើឲ្យផ្សេងគ្នានឹងអ្នកដទៃ ។ ឬថា ឈ្មោះថា អាមាត្យប៉ុណ្ណោះរបស់យើង ។ សូម្បីត្រឹមតែរបស់ស៊ី និងគ្រឿងស្លៀកដណ្តប់របស់យើងក៏មិនមាន ។ យើងជាអាមាត្យបានយ៉ាងណា ។

បទមានជាអាទិ៍ថា **ហីនស្ស សេយ្យោហមស្មីតិ មានោ** មានះថា ជាអ្នកថោកទាបជាងគេ ប្រកាន់ថា ប្រសើរជាងគេ រមែងកើតដល់ពួកទាសៈជាដើម ។ ព្រោះទាសៈ រមែងធ្វើមានះនេះថា នរណាជាទាសៈដទៃដូចជាយើង ដោយចំណែកមាតា ឬបិតា ។



អ្នកដទៃមិនអាចមានជីវិតរស់នៅបាន កើតជាទាសៈព្រោះហេតុផ្ទៃ ។ តែយើងជាអ្នកប្រសើរជាង ព្រោះមកដោយខ្សែស្រឡាយ ។ អ្វីរបស់យើង ធ្វើឲ្យផ្សេងគ្នាជាមួយទាសៈនោះ ដោយភាពជាទាសៈពិតទាំងពីរចំណែក ព្រោះមកដោយខ្សែស្រឡាយ ឬយើងដល់ភាពជាទាសៈព្រោះផ្ទៃ ។ តែឋានៈជាទាសៈរបស់យើងក្នុងទីបំផុត មាតាបិតាមិនមាន ។ យើងនឹងជាទាសៈបានដូចម្តេច ។ សូម្បីអ្នកក្រលំបាក និងមនុស្សចណ្ឌាលជាដើម ក៏ធ្វើមានះនោះដូចទាសៈ ដូច្នោះ ។

ម្យ៉ាងទៀត ក្នុងបទនេះ មានះដែលកើតឡើងថា ជាអ្នកប្រសើរជាងគេ ប្រកាន់ថា ប្រសើរជាងគេ ជាមានះពិតប្រាកដ ។ ពីរពួកដទៃពីនេះ ជាមានះមិនពិតប្រាកដ ។ ម្យ៉ាងទៀត មានះដែលកើតឡើងថា ជាអ្នកស្មើគេ ប្រកាន់ថា ស្មើគេ ជាអ្នកថោក-ទាបជាងគេ ប្រកាន់ថា ថោកទាបជាងគេ ជាមានះពិតប្រាកដ ។ ពីរពួកនេះ ជាមានះមិនពិតប្រាកដ ។ ការកម្ចាត់កិលេសដោយអរហត្តមគ្គ ជាមានះពិតប្រាកដ ។ ការកម្ចាត់កិលេសដោយសោតបត្តិមគ្គ ជាមានះមិនពិតប្រាកដ ។

បទថា **តណ្ហាមូលកា** មានតណ្ហាជាមូល បានពោលទុកហើយ ។

បទថា **វដ្ឋតិ** ត្រេកអរហើយ អធិប្បាយថា មិនមែនត្រេកអរដោយភាគៈតែម្យ៉ាងប៉ុណ្ណោះ ។ ដែលពិត ការត្រេកអរប្រកបដោយអកុសលធម៌ទាំងអស់ មានតណ្ហាជាមូល ព្រោះកើតសូម្បីការស្វែងរកជាដើម មានតណ្ហាជាមូល ។

បទថា **ទសហិ កិលេសវត្ថូហិ** លោកសន្និវាសសៅហ្មង ព្រោះកិលេសវត្ថុ ១០ ប្រការ កិលេសវត្ថុ ១០ ដូចម្ដេច ? កិលេសវត្ថុ ១០ ទាំងនេះ គឺ លោភៈ ១ ទោសៈ ១ មោហៈ ១ មានៈ ១ ទិដ្ឋិ ១ វិចិកិច្ឆា ១ ថីនៈ ១ ឧទ្ធច្ចៈ ១ អហិរិកៈ ១ អនោតប្បៈ ១ ។

គប្បីជ្រាបក្នុងបទទាំងនោះដូចតទៅនេះ កិលេសវត្ថុ គឺ កិលេសនោះឯង ដែលឈ្មោះថា **វត្ថុ** ព្រោះកិលេសជាទីនៅរបស់សត្វដែលមិនមែនជាខីណាស្រព ព្រោះតាំងនៅក្នុងលោភៈជាដើម ។

ឈ្មោះថា **កិលេសវត្ថុ** ព្រោះកិលេសទាំងនោះ ជាទីនៅរបស់សត្វទាំងឡាយ ។ ម្យ៉ាងទៀត ព្រោះកិលេសទាំងឡាយ



សូម្បីកើតដោយភាពជាអនន្តរប្បច្ច័យ ជាដើម ក៏ឈ្មោះថារមែងនៅដូចគ្នា ។ ដូច្នោះទើបឈ្មោះ ថាកិលេសវត្ថុ ព្រោះជាទីនៅរបស់កិលេសទាំងឡាយ ។

ឈ្មោះថា **លោភ** ព្រោះជាហេតុបាន ។ ឬរមែងបានដោយខ្លួនឯង ។ ឬត្រឹមតែបានប៉ុណ្ណោះ ។ ឈ្មោះថា **ទោសៈ** ព្រោះជាហេតុប្រទូសរ៉ាយ ។ ឬប្រទូសរ៉ាយដោយខ្លួនឯង ។ ឬត្រឹមតែប្រទូសរ៉ាយប៉ុណ្ណោះ ។ ឈ្មោះថា **មោហ** ព្រោះជាហេតុវង្វេង ។ ឬវង្វេងដោយខ្លួនឯង ។ ឬត្រឹមតែសេចក្ដីវង្វេងប៉ុណ្ណោះ ។ ឈ្មោះថា **មានៈ** ព្រោះប្រកាន់ ។ បទមាន **ទិដ្ឋិ** ជាដើម មានអត្ថដូចពោលហើយ ។ ឈ្មោះថា **អហិរិក** ព្រោះមិនខ្មាស់ ។ ភាពជាអ្នកមិនខ្មាស់នោះ ។ ឈ្មោះថា **អហិរិក** ។ ឈ្មោះថា **អនោតប្ប** ព្រោះមិនខ្លាចក្រែង ។ ភាពជាអ្នកមិនខ្លាចក្រែងនោះ ឈ្មោះថា **អនោតប្ប** ។ ក្នុងពីរបទនោះ អហិរិកៈ មានលក្ខណៈមិនខ្មាស់ដោយកាយទុច្ចរិតជាដើម ។ អនោតប្បៈ មានលក្ខណៈមិនត្រេកអរដោយកាយទុច្ចរិតជាដើម ។ បទថា **កិលិស្សតិ** រមែងសៅហ្មង គឺ ដុតបំផ្លាញ បៀតបៀន ។

បទថា **ទសហិ អាឃាតវត្ថូហិ** លោកសន្និវាស ប្រទូស-រ៉ាយគ្នា ព្រោះអាឃាតវត្ថុ ១០[១] ។ អាឃាតវត្ថុ ៩ ពោលទុកហើយក្នុងខាងមុន ដោយអាឃាតវត្ថុ ១០ លោកពោលបន្ថែមថា អាឃាតរមែងកើតក្នុងឋានៈមិនសមគួរ ។ ព្រោះភាពអាឃាតរមែងកើតក្នុងឋានៈដែលមិនសមគួរ មានដង្គត់ និងបន្ទាជាដើម មិនចាត់ចូលជាមួយបទមានជាអាទិ៍ថា **អនត្ថំ មេ អចរិ** គេបានប្រព្រឹត្តសេចក្ដីវិនាសដល់យើងហើយ ។

បទថា **ទសហិ អកុសលកម្មបថេហិ** លោកសន្និវាសប្រកប ដោយអកុសលកម្មបថ ១០ អកុសលកម្មបថ ១០ ដូចម្ដេច ? អកុសលកម្មបថ ១០ ទាំងនេះ គឺ បាណាតិបាត ១ អទិន្នាទាន ១ កាមេសុមិច្ឆាចារ ១ មុសាវាទ ១ បិសុណាវាចា ១ ផរុស-វាចា ១ សម្ផប្បលាបៈ ១ អភិជ្ឈា ១ ព្យាបាទ ១ មិច្ឆាទិដ្ឋិ ១ ។

ក្នុងបទនោះមានសេចក្ដីដូច្នេះ ឈ្មោះថា **អកុសលកម្មបថ** ព្រោះអកុសលកម្មទាំងនោះ ជាផ្លូវនៃទុគ្គតិ ។

---

[១] អភិធម្ម វិភង្គ



បទថា **សមន្នាគតោ** គឺ មានការព្រមព្រៀង ។

បទថា **ទសហិ សញ្ញោជនេហិ** លោកសន្និវាសត្រូវសំយោជន៍ ១០ ចងទុក ។ សំយោជន៍ ១០ ដូចម្ដេច ? សំយោជន៍ ១០[១] ទាំងនេះ គឺ កាមរាគៈ ១ បដិឃៈ ១ មានៈ ១ ទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាសៈ ១ ភវរាគៈ ១ ឥស្សា ១ មច្ឆរិយៈ ១ អវិជ្ជា ១ ។

បទថា **មិច្ឆត្តា** លោកសន្និវាសទាញចុះ ព្រោះមិច្ឆត្តៈបានពោលទុកហើយ ។

បទថា **ទសវត្ថុកាយ មិច្ឆាទិដ្ឋិយា** លោកសន្និវាសប្រកប ដោយមិច្ឆាទិដ្ឋិ មានវត្ថុ ១០ ។ មិច្ឆាទិដ្ឋិ មានវត្ថុ ១០ ដូចម្ដេច ? មិច្ឆាទិដ្ឋិមានវត្ថុ ១០ គឺ ទានដែលឲ្យ ហើយមិនមានផល ១ ការបួងសួងមិនមានផល ១ ការ បូជាមិនមានផល ១ វិបាកដែលជាផលរបស់កម្មដែលធ្វើល្អធ្វើអាក្រក់មិនមាន ១ លោកនេះមិនមាន ១ លោកខាងមុខមិនមាន ១ មាតាមិនមាន ១ បិតា

---

[១] អភិធម្ម វិភង្គ

មិនមាន ១ ឱបបាតិកសត្វមិនមាន ១ សមណព្រាហ្មណ៍អ្នកប្រព្រឹត្តល្អ បដិបត្តិល្អ ធ្វើឲ្យច្បាស់លោកនេះ លោកខាងមុខដោយអភិញ្ញា ហើយដឹងដោយខ្លួនឯង មិនមានក្នុងលោក ១ ។

ក្នុងបទទាំងនោះ បទថា **ទសវត្ថុកា** ឈ្មោះថា **វត្ថុ** ១០ ព្រោះមានវត្ថុ ១០ ។

បទថា **នត្ថិ ទិន្នំ** គឺ ដឹងថា ឈ្មោះថា ទានដែលឲ្យហើយរមែងមានផល , អាចឲ្យអ្វី ៗ ដល់នរណា ៗ បាន ។ តែបុគ្គលមិច្ឆាទិដ្ឋិប្រកាន់ថា វិបាកដែលជាផលរបស់ទាន ដែលឲ្យហើយមិនមាន ។

បទថា **នត្ថិ យិដ្ឋំ** គឺ **មហាយាគោ** [១] ការបួងសួងធំលោកហៅថា **យិដ្ឋំ** , ដឹងថា ការបួងសួងនោះអាចឲ្យផលបាន ។ តែបុគ្គលមិច្ឆាទិដ្ឋិ ប្រកាន់ថា វិបាកដែលជាផលរបស់ការបួងសួងនោះមិនមាន ។

១ មហាយាគោ ៥ គឺ អស្សមេធោ បុរិសមេធោ និរគ្គោ សម្មាបាសោ វាជបេយ្យោ ។



បទថា **ហុតំ** គឺ ការធ្វើមង្គល ដោយការបូជាទទួល , ដឹងថា ការធ្វើនោះឲ្យផល ។ តែបុគ្គលមិច្ឆាទិដ្ឋិ ប្រកាន់ថា ផលដែលជាវិបាករបស់ការបូជានោះមិនមាន ។

ក្នុងបទថា **សុកដទុក្កដានំ** នេះ បានដល់ កុសលកម្ម ១០ ឈ្មោះថា កម្មល្អ , អកុសលកម្មបថ ១០ ឈ្មោះថា កម្មអាក្រក់ ។ ដឹងសេចក្តីដែលកម្មទាំងនោះមានផល ។ តែបុគ្គលជាមិច្ឆាទិដ្ឋិប្រកាន់ថា វិបាកដែលជាផលមិនមាន ។

បទថា **នត្ថិ អយំ លោកោ** គឺ បុគ្គលមិច្ឆាទិដ្ឋិ ប្រកាន់ថា អ្នកតាំងនៅក្នុងលោកដទៃមិនមានក្នុងលោកនេះ ។

បទថា **នត្ថិ បរោ លោកោ** ប្រកាន់ថា អ្នកតាំងនៅក្នុងលោកនេះមិនមានក្នុងលោកដទៃ ។

បទថា **នត្ថិ មាតា នត្ថិ បិតា** គឺ ដឹងថាមាតាបិតាមានគុណ តែបុគ្គលមិច្ឆាទិដ្ឋិ ប្រកាន់ថា វិបាកណា ៗ ដែលជាផលដោយបច្ច័យ ដែលធ្វើដល់មាតាបិតាទាំងនោះ មិនមាន ។

បទថា **នត្ថិ សត្តា ឱបបាតិកា** គឺ ប្រកាន់ថា សត្វ ( ឱបបាតិកៈ ) ចុតិ និងកើតមិនមាន ។

បទថា **សម្មគ្គតា សម្មាបដិបន្នា** គឺ ប្រកាន់ថា សមណព្រាហ្មណ៍អ្នកតាំងនៅក្នុងធម៌បដិបត្តិ បដិបទាដែលសមគួរ មិនមានក្នុងលោក ។

បទថា **យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញាយ សច្ឆិកត្វា បវេទេន្តិ** គឺ ប្រកាន់ថា ព្រះពុទ្ធជាម្ចាស់ ដែលជាសព្វញ្ញូ អាចដឹងលោកនេះ និងលោកខាងមុខ ដោយព្រះញាណដ៏ប្រសើរដោយព្រះអង្គឯង ហើយទ្រង់ប្រកាស មិនមាន ។

បទថា **អន្តគ្គាហិកាយ ទិដ្ឋិយា** លោកសន្និវាស ប្រកបដោយអន្តគាហិកទិដ្ឋិ គឺ ទិដ្ឋិប្រកាន់យកទីបំផុត ។ ឈ្មោះថា **អន្តគាហិក** ព្រោះប្រកាន់យកចំណែកបំផុតមួយៗ មានជាអាទិ៍ថា លោកទៀង ។ ម្យ៉ាងវិញទៀត ការកាន់យកទីបំផុត ឈ្មោះថា **អន្តគាហ** ។ ឈ្មោះថា **អន្តគាហិក** ព្រោះទិដ្ឋិមានការប្រកាន់យកទីបំផុត ។ ដោយការប្រកាន់យកទីបំផុតនោះ ។ អន្តគាហិកទិដ្ឋិនោះ លោកពោលទុកហើយ ។

បទថា **អដ្ឋសតតណ្ហាបបញ្ចសតេហិ** លោកសន្និវាសត្រូវឃឹតយូរ ព្រោះតណ្ហាជាគ្រឿងធ្វើឲ្យឃឹតយូរ ១០៨ ។ ឈ្មោះថា



**អដ្ឋសតំ** ។ ឈ្មោះថា **បបញ្ចា** ព្រោះឲ្យឃឹតយូរ ក្នុងសង្សារវដ្ត គឺ ឲ្យស្ថិតនៅយូរ ។ តណ្ហានោះឯងជាគ្រឿងឲ្យឃឹតយូរ ទើបឈ្មោះថា **តណ្ហាបបញ្ចា** ។ តណ្ហាគ្រឿងឲ្យឃឹតយូរមួយរយ លោកធ្វើឲ្យជាពហុវចនៈ ព្រោះតណ្ហាមានច្រើនដោយប្រភេទនៃអារម្មណ៍ និងដោយការកើតរឿយ ៗ ទើបឈ្មោះថា **តណ្ហាបបញ្ចសតំ** ។ ដោយហេតុនោះ បើគួរនឹងពោលថា **តណ្ហាបបញ្ចសតេន** ដោយការឃ្លៀងឃ្លាតរបស់វចនៈ ទើបលោកធ្វើនិទ្ទេសជាពហុវចនៈថា **តណ្ហាបបញ្ចសតេហិ** ។ គប្បីឃើញអត្ថនៃបទថា **តណ្ហាបបញ្ចសតេន** ដោយតណ្ហាជាគ្រឿងធ្វើឲ្យឃឹតយូរមួយរយ គឺ **អដ្ឋសតំ** ១០៨ ។ គប្បីជ្រាបថា លោកកាន់យក ១០០ ប៉ុណ្ណោះ ព្រោះធ្វើ ៨ ជាអព្វោហារិកៈ គឺ មានដូចមិនមាន ។ បទថា **តណ្ហាវិចរិតានិ** មកក្នុងខុទ្ទកវត្ថុវិភង្គ ។ ដូចព្រះមានព្រះភាគត្រាស់ទុកថា ៖

តណ្ហាវិចរិត ខាងក្នុង ១៨ ខាងក្រៅ ១៨ រួម<br>
ជាតណ្ហាវិចរិត ៣៦ ។ អតីត ៣៦ អនាគត ៣៦<br>
បច្ចុប្បន្ន ៣៦ រួមជាតណ្ហាវិចរិត ១០៨ ។

ម្យ៉ាងទៀត ក្នុងខុទ្ទកវត្ថុវិភង្គនេះ លោកពោល តណ្ហាជាគ្រឿងធ្វើឲ្យយឺតយូរថា តណ្ហាវិចរិត ។ អធិប្បាយថា ការប្រព្រឹត្តទៅនៃតណ្ហា ព្រោះប្រព្រឹត្តនៅក្នុងតណ្ហា ។

បទថា **អជ្ឈត្តិកស្ស ឧបាទាយ** គឺ សំដៅដល់ ខន្ធបញ្ចកខាងក្នុង ។ បទនេះជាឆដ្ឋីវិភត្តិចុះក្នុងអត្ថនៃទុតិយាវិភត្តិ ។ ចំណែកសេចក្ដីពិស្ដាររបស់បទនេះ គប្បីជ្រាបដោយន័យដូចពោលហើយក្នុងនិទ្ទេសនៃខុទ្ទកវត្ថុវិភង្គនោះ ។ តែក្នុងនិទ្ទេសនេះគប្បីជ្រាបន័យយ៉ាងដទៃ ។ តណ្ហា ៣ គឺ កាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ មានរូបជាអារម្មណ៍តែម្យ៉ាង ។ ម្យ៉ាងទៀត តណ្ហា ១៨ ក្នុងអារម្មណ៍ ៦ មានសំឡេងជាដើមជាអារម្មណ៍ ។ តណ្ហាមានអារម្មណ៍ខាងក្នុង ១៨ ខាងក្រៅ ១៨ រួមជាតណ្ហា ៣៦ ។ តណ្ហាទាំងនោះ មានអារម្មណ៍ក្នុងអតីត ៣៦ អារម្មណ៍ក្នុងអនាគត ៣៦ អារម្មណ៍ក្នុងបច្ចុប្បន្ន ៣៦ រួមជាតណ្ហាវិចរិត ១០៨ ។

បទថា **បបញ្ចិតោ** គឺ ត្រូវយឺតយូរ ស្ថិតនៅយូរក្នុងអារម្មណ៍ ឬក្នុងសង្សារវដ្ដ ។

បទថា **ទ្វាសដ្ឋិយា ទិដ្ឋិគតេហិ** លោកសន្និវាស ត្រូវទិដ្ឋិ



៦២ រុំព័ទ្ធ ព្រះមានព្រះភាគត្រាស់ទិដ្ឋិ ៦២ ទុកក្នុងវេយ្យាករណភាសិតក្នុងព្រហ្មជាលសូត្រ ដូចម្ដេច ? ទិដ្ឋិ ៦២[1] ដែលព្រះមានព្រះភាគត្រាស់ទុក ក្នុងវេយ្យាករណភាសិត ក្នុងព្រហ្មជាលសូត្រមានដូច្នេះ គឺ សស្សតវាទ វាទៈថា ទៀង ៤ , ឯកច្ចសស្សតវាទ វាទៈថាទៀង ៤ , អន្តានន្តិកវាទ វាទៈថាមានទីបំផុតនិងមិនមានទីបំផុត ៤ , អមរាវិក្ខេបិកវាទ វាទៈបដិសេធដោយអស់ជើង ៤ , អធិច្ចសមុប្បន្និកវាទ វាទៈថាប្រកាន់ជឿមិនបាន ២ , សញ្ញីវាទ វាទមានសញ្ញា ១៦ , អសញ្ញីវាទ វាទៈថាមិនមានសញ្ញា ៨ , នេវសញ្ញីនាសញ្ញីវាទ វាទៈថាមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ៨ , ឧច្ឆេទវាទ វាទៈថា សូន្យ ៧ , ទិដ្ឋធម្មនិព្វានវាទ វាទៈថានិព្វានមានក្នុងបច្ចុប្បន្ន ៥ ។ ចំណែកសេចក្ដីពិស្ដារក្នុងនិទ្ទេសនេះ គប្បីជ្រាបន័យដូចពោលហើយក្នុងព្រហ្មជាលសូត្រនោះឯង ។

បទថា **អហញ្ចម្ហិ តិណ្ណោ** យើងជាអ្នកឆ្លងបានហើយ ។

---

១ អភិធម្ម វិភង្គ

គឺ យើងជាអ្នកឆ្លងឱឃៈ ៤ ឬសមុទ្រ គឺ សង្សារវដ្តបានហើយ ។ បទថា **មុត្តោ** យើងជាអ្នករួចផុតហើយ គឺ រួចផុតចាកគ្រឿងចង មានរាគៈជាដើម ។ បទថា **ទន្តោ** យើងទូន្មានបានហើយ គឺ អស់ការប្រកាន់ លែងរើបម្រះហើយ ។ បទថា **សន្តោ** យើងជាអ្នកស្ងប់ហើយ គឺ មានសេចក្តីត្រជាក់ ។ បទថា **អស្សត្ថោ** យើងជាអ្នកធូរស្រាល គឺ បានភាពរួចផុតដោយឃើញនិព្វាន ។

បទថា **បរិនិព្វុតោ** យើងជាអ្នករលត់ដោយជុំវិញហើយ គឺ រលត់ជុំវិញដោយការរលត់កិលេស ។ បទថា **បហោមិ** គឺ យើងជាអ្នកអាច ។ បទថា **ខោ** ជានិបាតចុះ ក្នុងអត្ថនៃឯកំសៈ គឺ ចំណែកមួយ ។

**បរេ ច** ស័ព្ទក្នុងបទនេះថា **បរេ ច បរិនិព្វាបេតុំ** ដើម្បីឲ្យអ្នកដទៃរលត់ដោយជុំវិញផង គប្បីប្រកបសូម្បីដោយបទមានជាអាទិ៍ថា **បរេ ច តារេតុំ** ដើម្បីឲ្យអ្នកដទៃឆ្លងផុតទៅផង ។

( ចប់ អដ្ឋកថាមហាករុណាញាណនិទ្ទេស )



# អដ្ឋកថា សព្វញ្ញុតញ្ញាណនិទ្ទេស

ព្រះសារីបុត្តត្ថេរសួរថា ព្រះសព្វញ្ញុតញ្ញាណរបស់ព្រះតថាគត តើដូចម្តេច ? ហើយសម្តែង **អនាវរណញ្ញាណ** ញាណមិនមានអ្វីជាគ្រឿងរាំង ដូចសព្វញ្ញុតញ្ញាណនោះឯង ព្រោះមានគតិស្មើគ្នានឹងអនាវរណញាណនោះ ។

ពិតណាស់ អនាវរណញ្ញាណមិនមានសេចក្តីផ្សេងពីធម្មតា ។ ព្រោះញាណនេះ ជាញាណដូចគ្នាប៉ុណ្ណោះ លោកទើបពោលជា ២ យ៉ាង ដូចប្រភេទនៃអាការសទ្ធិន្ទ្រិយ និងសទ្ធាពលៈជាដើម ។ ព្រះសព្វញ្ញុតញ្ញាណនោះឯង លោកពោលថា **អនាវរណ** ព្រោះមិនមានគ្រឿងរាំង ព្រោះមិនមានធម៌អ្វី ៗ ឬបុគ្គលមិនអាចនឹងធ្វើការរាំងបាន ព្រោះធម៌ទាំងពួងជាប់ទាក់ទងដោយការនឹកគិត ។ ប៉ុន្តែបុគ្គលដទៃសូម្បីនឹកគិតក៏ដឹងមិនបាន ។ ចំណែកអាចារ្យពួកខ្លះ ពោលថា ឈ្មោះថា **សព្វញ្ញុតញ្ញាណ** ព្រោះប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំងពួង ដូចមនោវិញ្ញាណ ។ សព្វញ្ញុតញ្ញាណនោះឯង ជាអនាវរណញ្ញាណ ព្រោះមិនមានអ្វីរាំងក្នុង

អារម្មណ៍ទាំងឡាយ ដូចវជិរាវុធរបស់ព្រះឥន្ទ្រ ។ ព្រះសព្វញ្ញុតញ្ញាណ បដិសេធភាពជាសព្វញ្ញូតាមលំដាប់ ។ អនាវរណញ្ញាណ បដិសេធភាពជាសព្វញ្ញូតែម្យ៉ាង ។ ព្រះមានព្រះភាគជាម្ចាស់ ដែលបណ្ឌិតពោលថា ព្រះសព្វញ្ញូ ព្រោះការបានព្រះសព្វញ្ញុតញ្ញាណ មិនមែនការបានសព្វញ្ញូតាមលំដាប់ ។ បណ្ឌិតពោលថា ព្រះសព្វញ្ញូ ព្រោះការបានអនាវរណញ្ញាណ មិនមែនការបានសព្វញ្ញូម្តងម្កាល ។

បទថា **សព្វំ** ក្នុងបទនេះថា **សព្វំ សង្ខតមសង្ខតំ អនវសេសំ ជានាតិ** ព្រះមានព្រះភាគជាម្ចាស់ទ្រង់ដឹងសង្ខតធម៌ និងអសង្ខតធម៌ទាំងពួងមិនមានសល់ ជាបទកាន់យកសេចក្តីមិនមានសល់របស់ធម៌ទាំងពួងដោយជាតិ ។

បទថា **អនវសេសំ** មិនមានចំណែកសល់ ជាបទកាន់យកសេចក្តីមិនមានចំណែកសល់នៃធម៌មួយ ៗ ដោយអំណាចអាការទាំងពួង ។

បទថា **សង្ខតមសង្ខតំ** ជាបទសម្តែងប្រភេទ ២ យ៉ាង ។ ព្រោះសង្ខតៈជាប្រភេទមួយ ។ អសង្ខតៈជាប្រភេទមួយ ។ ខន្ធ-



បញ្ចកៈជាសង្ខតៈ ព្រោះអាស្រ័យបច្ច័យតាក់តែង ។ និព្វានជាអសង្ខតៈ ព្រោះមិនមានបច្ច័យតាក់តែងយ៉ាងនោះ ។ រមែងដឹងសង្ខតៈមិនមានចំណែកសល់ ដោយអាការមានការមិនទៀង ជាទុក្ខ ជាអនត្តាជាដើម ។ រមែងដឹងអសង្ខតៈមិនមានចំណែកសល់ ដោយអាការមានសុញ្ញតនិមិត្ត និងអប្បណិហិតនិមិត្តជាដើម ។

ឈ្មោះថា **អនវសេសំ** ព្រោះមិនមានសង្ខតៈ និងអសង្ខតៈដ៏សេស ។ បញ្ញត្តិ សូម្បីច្រើនប្រភេទ រមែងចូលជាមួយចំណែកអសង្ខតៈ ព្រោះបច្ច័យមិនបានតាំងតែង ។ ពិតណាស់ ព្រះសព្វញ្ញុតញ្ញាណ រមែងដឹងបញ្ញត្តិសូម្បីទាំងពួងដោយប្រការមិនតិច ។

ម្យ៉ាងទៀត បទថា **សព្វំ** ជាបទកាន់យកធម៌ទាំងអស់ ។ បទថា **អនវសេសំ** ជាបទកាន់យក មិនមានការអាស្រ័យ ។

បទថា **តត្ថ អាវរណំ នត្ថិ** មិនមានគ្រឿងរាំងក្នុងញាណនុ៎ះ សេចក្តីថា គ្រឿងរាំងព្រះសព្វញ្ញុតញ្ញាណមិនមាន ព្រោះមិនមានគ្រឿងរាំងក្នុងសង្ខតៈ និងអសង្ខតៈដែលមិនមានចំណែកសល់នោះ ។ ព្រោះដូច្នោះ ព្រះសព្វញ្ញុតញ្ញាណនោះឯង

ទើបឈ្មោះថា **អនាវរណញ្ញាណ** ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរ ដើម្បីនឹងសម្ដែងដោយប្រភេទនៃអារម្មណ៍ច្រើនយ៉ាង ទើបពោលបទមានជាដើមថា **អតីតំ** ធម៌ចំណែកអតីត ។

ក្នុងបទទាំងនោះបទថា **អតីតំ អនាគតំ បច្ចុប្បន្នំ** លោកសំដែងដោយប្រភេទនៃកាល ។

បទមានជាដើមថា **ចក្ខុញ្ចេវ រូបា ច** លោកសំដែងដោយប្រភេទនៃអារម្មណ៍ និងវត្ថុ ។

បទថា **ឯវំ តំ សព្វំ** ដឹងធម៌ទាំងអស់នោះយ៉ាងនេះ ជាបទកាន់យកដោយមិនមានចំណែកសល់របស់ចក្ខុ និងរូបទាំងនោះ ។ ក្នុងបទដ៏សេសក៏យ៉ាងនេះ ។

បទថា **យាវតា** រហូតទាំងអស់ ជាបទកាន់យកដោយមិនមានចំណែកសល់ ។

បទមានជាដើមថា **អនិច្ចដ្ឋំ** គឺ មានសភាពមិនទៀង លោកសម្ដែងដោយប្រភេទនៃសាមញ្ញលក្ខណៈ ។

បទថា **អនិច្ចដ្ឋំ** គឺ មានការមិនទៀង ។ ក្នុងបទនោះ ក៏



មានន័យនេះ ។

បទមានជាអាទិ៍ថា **រូបស្ស** លោកសម្ដែងដោយប្រភេទនៃខន្ធ ។

បទថា **ចក្ខុស្ស ។ បេ ។ ជរាមរណស្ស** គប្បីប្រកបដោយន័យរបស់ **បេយ្យាល** ដែលពោលទុកហើយក្នុងខាងក្រោយ ។

ក្នុងបទមានជាអាទិ៍ថា **អភិញ្ញាយ** ដោយអភិញ្ញា បានដល់ញាណ ដូចបានពោលហើយក្នុងខាងក្រោយនោះឯង ។

បទថា **អភិញ្ញដ្ឋំ** សភាពដែលគួរដឹងច្បាស់ ។ ក្នុងបទនោះ ក៏មានន័យនេះ ។

បទមានជាអាទិ៍ថា **ខន្ធានំ ខន្ធដ្ឋំ** ដឹងសភាវៈដែលជាខ្លួនឯងនៃខន្ធ គប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងខាងក្រោយនោះឯង ។

បទមានជាអាទិ៍ថា **កុសលេ ធម្មេ** កុសលធម៌ទាំងឡាយគឺ ជាប្រភេទដោយអំណាចនៃ **កុសលត្តិក** ពួក ៣ នៃកុសល ។

បទមានជាអាទិ៍ថា **កាមាវចរេ ធម្មេ** កាមាវចរធម៌ជាប្រភេទដោយអំណាចនៃធម៌ប្រព្រឹត្តទៅក្នុងភូមិ ៤ ។ សូម្បីក្នុងបាឋៈជាពហុវចនៈថា **សព្វេ ជានាតិ** រមែងដឹងធម៌ទាំងឡាយ

ទាំងពួងជាបាឋៈល្អ ។ ប៉ុន្តែព្រោះធ្លាក់ទៅក្នុងក្រសែនៃឯកវចនៈក្នុងគម្ពីរ លោកទើបសរសេរដោយឯកវចនៈ ។

បទមានជាអាទិ៍ថា **ទុក្ខស្ស** ជាប្រភេទនៃអារម្មណ៍ពុទ្ធ-ញ្ញាណ ១៤ យ៉ាង ។

បទមានជាអាទិ៍ថា **ឥន្ទ្រិយបរោបរិយត្តេ ញាណំ** ឥន្ទ្រិយ-បរោបរិយត្តញ្ញាណ ប្រសិនបើសួរថា ព្រោះហេតុអ្វី លោកទើបពោលឈាន ៤ មិនពោលព្រះសព្វញ្ញុតញ្ញាណ ។ ឆ្លើយថា ព្រោះឈាន ៤ ដែលលោកពោលជាសព្វញ្ញុតញ្ញាណដោយប្រភេទនៃអារម្មណ៍ ក៏មិនគួរពោលដល់ញាណនោះ ។ មួយ៉ាងទៀត ព្រះសព្វញ្ញុតញ្ញាណ រមែងជាវិស័យនៃព្រះសព្វញ្ញុតញ្ញាណនោះឯង ។

ព្រះសារីបុត្តត្ថេរ កាលនឹងសម្តែងភូមិនៃព្រះសព្វញ្ញុត-ញ្ញាណ ដោយន័យដូចពោលហើយក្នុងកាលកាលាមសូត្រជាដើម ទើបពោលបទមានជាអាទិ៍ថា **យាវតា សទេវកស្ស លោកស្ស** នៃលោកព្រមទាំងទេវលោករហូតទាំងអស់ ។

ក្នុងបទទាំងនោះ គប្បីជ្រាបសេចក្តីដូចតទៅនេះ លោកព្រម



ទាំងទេវតា ឈ្មោះថា **សទេវកស្ស** ។ ព្រមទាំងមារ ឈ្មោះថា **សមារកស្ស** ។ ព្រមទាំងព្រហ្ម ឈ្មោះថា **សព្រហ្មកស្ស** ។ ព្រមទាំងសមណព្រាហ្មណ៍ ឈ្មោះថា **សស្សមណព្រាហ្មណិយា** ។ ពួកសត្វព្រមទាំង ទេវតា និងមនុស្ស ឈ្មោះថា **សទេវមនុ-ស្សាយ** ។

បទថា **បជា** នេះជាពាក្យពោលដោយបរិយាយរបស់សត្វលោក ព្រោះជាអ្នកកើតហើយ ។

ក្នុងបទទាំងនោះគប្បីជ្រាប ការកាន់យកកាមវចរទេព ៥ ដោយពាក្យថា ព្រមទាំងទេវលោក ។ កាន់យកកាមាវចរទេពទី ៦ ដោយពាក្យ ព្រមទាំងមារលោក ។ កាន់យកពួកព្រហ្មមានព្រហ្មកាយិកាជាដើម ដោយពាក្យថា ព្រមទាំងព្រហ្មលោក ។ កាន់យកសមណព្រាហ្មណ៍ដែលជាសត្រូវរបស់សាសនា ហើយកាន់យកសមណព្រាហ្មណ៍អ្នកស្ងប់ អ្នកបន្សាត់បាបហើយ ដោយពាក្យថា ព្រមទាំងសមណព្រាហ្មណ៍ ។ កាន់យកសត្វលោកដោយពាក្យថា **បជា** ។ កាន់យកសម្មតិទេព និងមនុស្សដ៏សេសដោយពាក្យថា ព្រមទាំងទេវតា និងមនុស្ស ។

ក្នុងនិទ្ទេសនេះ គប្បីជ្រាបថា លោកកាន់យកឱកាសលោក ដោយ ៣ បទ ។ សត្វលោក ដោយអំណាចពួកសត្វ ដោយ ២ បទ ។ គប្បីជ្រាបន័យដទៃតទៅ , កាន់យកអរូបាវចរលោក ដោយ **សទេវក** ស័ព្ទ ។ កាន់យកឆកាមាវចរទេវលោក ដោយ **សមារក** ស័ព្ទ ។ កាន់យករូបាវចរព្រហ្មលោក ដោយ **សព្រហ្មក** ស័ព្ទ ។ កាន់យកមនុស្សលោក ឬសត្វលោកដ៏សេស ព្រមដោយបរិស័ទ ៤ ឬសម្មតិទេព ដោយ **សស្សមណព្រាហ្មណ** ស័ព្ទជាដើម ។

ម្យ៉ាងទៀត ក្នុងនិទ្ទេសនេះ លោកញ៉ាំងការកើត គឺ ការដឹងមានអារម្មណ៍ដែលបានឃើញនៃសត្វលោកទាំងអស់ ឲ្យសម្រេចដោយកំណត់យ៉ាងឧក្រិដ្ឋ ដោយពាក្យថា **សទេវក** ។ ប៉ុន្តែព្រះសារីបុត្តត្ថេរ កាលនឹងកម្ចាត់សេចក្តីសង្ស័យរបស់ជនទាំងឡាយ ដែលមានបញ្ញាថា មារ មានអានុភាពច្រើន ជាធំក្នុងឆកាមាវចរទេព ជាអ្នកមានអំណាច ។ រមែងដឹងអារម្មណ៍ដែលឃើញហើយជាដើមរបស់មារនោះ ឬទើបពោលថា **សមារកស្ស** ព្រមទាំងមារលោក ។ ព្រះសារីបុត្តត្ថេរ កាលនឹងកម្ចាត់សេចក្តីសង្ស័យ



របស់ពួកជនទាំងឡាយ ដែលនឹងគប្បី មានសេចក្តីសង្ស័យថា ព្រហ្មមានអានុភាពច្រើន រមែងផ្សាយពន្លឺក្នុងមួយពាន់ចក្រវាឡ ដោយ ១ អង្គុលី ។ រមែងផ្សាយពន្លឺក្នុងម៉ឺនចក្រវាឡដោយ ២ អង្គុលី ។ល។ ១០ អង្គុលី នឹងរមែងសោយសុខក្នុងឈានសមាបត្តិយ៉ាងកំពូល ។ រមែងដឹងអារម្មណ៍ដែលបានឃើញជាដើម របស់ព្រហ្មនោះឬ ទើបពោលថា **សព្រហ្មកស្ស** ព្រមទាំងព្រហ្មលោក ។

ប៉ុន្តែព្រះសារីបុត្តត្ថេរ កាលនឹងកម្ចាត់សេចក្តីសង្ស័យរបស់ជនទាំងឡាយ ដែលនឹងគប្បីមានបញ្ញាថា សមណព្រាហ្មណ៍ទាំងនោះឬ ទើបពោលថា **សស្សមណព្រាហ្មណិយា** បជាយ ពួកសត្វព្រមដោយសមណព្រាហ្មណ៍ ព្រះសារីបុត្តត្ថេរលុះប្រកាសការកើត គឺ ការដឹងអារម្មណ៍ដែលឃើញហើយជាដើម យ៉ាងឧក្រិដ្ឋយ៉ាងនេះហើយ ទើបប្រកាសការកើត គឺ ការដឹងអារម្មណ៍ដែលឃើញហើយជាដើមរបស់សត្វដ៏សេស ដោយកំណត់យ៉ាងឧក្រិដ្ឋ អាស្រ័យសម្មតិទេព និងមនុស្សដ៏សេស ។ នេះជាលំដាប់អនុសន្ធិក្នុងនិទ្ទេសនេះ ។

ចំណែកព្រះបុរាណាចារ្យពោលថា បទថា **សទេវកស្ស** គឺលោកដ៏សេសព្រមដោយទេវលោក ។ បទថា **សមារកស្ស** គឺលោកដ៏សេសព្រមដោយមារលោក ។ បទថា **សព្រហ្មកស្ស** គឺលោកដ៏សេសព្រមដោយព្រហ្មលោក ។

ដើម្បីបន្ថែមសត្វទាំងឡាយ ដែលកើតក្នុងភព ៣ សូម្បីទាំងអស់យ៉ាងនេះចូលក្នុង ៣ បទ ដោយអាការ ៣ ហើយកាន់យកដោយអាការ ២ ទៀត ព្រះសារីបុត្តត្ថេរទើបពោលថា **សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ** នៃពួកសត្វព្រមទាំងសមណព្រាហ្មណ៍ទេវតា និងមនុស្ស ។ ដែលលោកកាន់យកត្រៃធាតុនោះឯង ដោយអាការនោះ ៗ ដោយបទ ៥ បទ ដោយប្រការដូច្នេះ ។

បទថា **ទិដ្ឋំ** អារម្មណ៍ដែលឃើញហើយ បានដល់ រូបាយតនៈ ។

បទថា **សុតំ** អារម្មណ៍ដែលបានស្តាប់ហើយ បានដល់សទ្ទាយតនៈ ។

បទថា **មុតំ** អារម្មណ៍ដែលបានជ្រាបហើយ បានដល់



គន្ធាយតនៈ រសាយតនៈ ផោដ្ឋាយតនៈ ព្រោះដល់ហើយ ទើបកាន់យកបាន ។

បទថា **វិញ្ញាតំ** អារម្មណ៍ដែលបានដឹងហើយ បានដល់ធម្មារម្មណ៍ មានសុខទុក្ខជាដើម ។

បទថា **បត្តំ** អារម្មណ៍ដែលបានដឹងហើយ បានដល់អារម្មណ៍ដែលដឹងហើយ ព្រោះស្វែងរកក្តី មិនស្វែងរកក្តី ។

បទថា **បរិយេសិតំ** អារម្មណ៍ដែលស្វែងរកហើយ បានដល់ អារម្មណ៍ដែលស្វែងរកហើយបានក្តី មិនបានក្តី ។

បទថា **អនុវិចរិតំ មនសា** គឺអារម្មណ៍ដែលស្វែងរកដោយចិត្ត ។ ព្រះសារីបុត្តត្ថេរសម្តែងបទនេះ ដោយបទនេះថា **សព្វំ ជានាតិ** ដឹងអារម្មណ៍ទាំងពួង ។

រូបារម្មណ៍ណាមានជាអាទិ៍ថា **នីលំ បីលំ** ខៀវ លឿងមកកាន់គន្លងក្នុងចក្ខុទ្វាររបស់លោក ព្រមទាំងទេវលោកនេះ ក្នុងលោកធាតុដែលរកប្រមាណមិនបាន ព្រះសព្វញ្ញុតញ្ញាណរបស់ព្រះតថាគត រមែងដឹងរូបារម្មណ៍ទាំងពួងនោះថា សត្វនេះឃើញរូបារម្មណ៍ឈ្មោះនេះ ក្នុងខណៈនេះ ហើយជាអ្នកមានចិត្តល្អ

ចិត្តអាក្រក់ ឬជាកណ្តាល កើតហើយ ដូច្នេះ ។

សទ្ទារម្មណ៍មានជាអាទិ៍ថា **ភេរិសទ្ទោ មុទិង្គសទ្ទោ** សំឡេងស្គរ សំឡេងសម្ភោរ មកកាន់គន្លងក្នុងសោតទ្វារ , គន្ធារម្មណ៍មានជាអាទិ៍ថា **មូលគន្ធោ តចគន្ធោ** ក្លិនឫស ក្លិនសំបក មកកាន់គន្លងឃានទ្វារ , រសារម្មណ៍មានជាអាទិ៍ថា **មូលរសោ ខន្ធរសោ** រសឫស រសដើម មកកាន់គន្លងក្នុងជិវ្ហាទ្វារ , ផោដ្ឋារម្មណ៍មាន ៣ ប្រភេទ គឺ បឋវីធាតុ តេជោធាតុ វាយោធាតុ មានជាអាទិ៍ថា **កក្ខឡំ មុទុកំ** រឹង ទន់ មកកាន់គន្លងក្នុងកាយទ្វាររបស់លោក ព្រមទាំងទេវលោកនេះ ក្នុងលោកធាតុរកប្រមាណមិនបាន ។ ព្រះសព្វញ្ញុតញ្ញាណរបស់ព្រះតថាគត ក៏រមែងដឹងអារម្មណ៍ទាំងអស់នោះថា សត្វនេះពាល់ត្រូវផោដ្ឋព្វារម្មណ៍ឈ្មោះនេះ ក្នុងខណៈនេះហើយ ការរីករាយ ការទាស់ចិត្ត ឬជាកណ្តាល ដូច្នេះដូចគ្នា ។

ម្យ៉ាងទៀត ធម្មារម្មណ៍ណាមានប្រភេទជាសុខ និងជាទុក្ខជាដើម មកកាន់គន្លងក្នុងមនោទ្វាររបស់លោក ព្រមទាំងទេវលោកនេះ ក្នុងលោកធាតុរកប្រមាណមិនបាន ។ ព្រះសព្វញ្ញុត-



ញ្ញាណរបស់ព្រះតថាគត រមែងដឹងធម្មារម្មណ៍ទាំងអស់នោះថា សត្វនេះដឹងធម្មារម្មណ៍ឈ្មោះនេះ ក្នុងខណៈនេះ ហើយមានការរីករាយ ការទាស់ចិត្ត ឬជាកណ្តាល ដូច្នេះ ។

ម្យ៉ាងទៀត មហាជននេះសូម្បីស្វែងរកហើយមិនបានចាក់ធ្លុះក៏មាន សូម្បីស្វែងរកហើយចាក់ធ្លុះក៏មាន ។ សូម្បីមិនស្វែងរកហើយ មិនចាក់ធ្លុះក៏មាន សូម្បីមិនស្វែងរក ហើយចាក់ធ្លុះក៏មាន ឈ្មោះថា ការមិនចាក់ធ្លុះទាំងអស់ មិនមានដោយសព្វញ្ញុតញ្ញាណដល់ព្រះតថាគត ។

ព្រះសារីបុត្តត្ថេរ ពោលគាថាមានជាអាទិ៍ថា **ន តស្ស** ដើម្បីឲ្យភាពជាព្រះសព្វញ្ញុតញ្ញាណ សម្រេចដោយបរិយាយដទៃទៀត ។

ក្នុងបទទាំងនោះ បទថា **ន តស្ស អទិដ្ឋមិធត្ថិ កិញ្ចិ** បទធម៌ណា ៗ ដែលព្រះតថាគតនោះទ្រង់មិនឃើញ ហើយមិនមានក្នុងលោកនេះ សេចក្តីថា បទធម៌ណា ៗ សូម្បីត្រឹមតែបន្តិចបន្តួច ដែលព្រះតថាគតនោះ ទ្រង់មិនបានឃើញហើយដោយបញ្ញាចក្ខុមិនមានក្នុងលោក ដែលជាត្រៃធាតុ ឬក្នុងបច្ចុប្បន្ន-

កាលនេះ ។

បទថា **អត្ថិ** នេះជាបទអាខ្យាត ប្រព្រឹត្តទៅក្នុងបច្ចុប្បន្នកាល ។ ដោយបទនេះ ព្រះសារីបុត្តត្ថេរសំដែងសេចក្ដីដែលព្រះតថាគត ទ្រង់ដឹងធម៌ទាំងពួងក្នុងបច្ចុប្បន្នកាលម្យ៉ាងទៀត ក្នុងបទនេះ លោកប្រើ **ធ** អក្សរ ដើម្បីងាយស្រួលក្នុងការប្រព័ន្ធគាថា ។

បទថា **អថោ** ក្នុងបទនេះថា **អថោ អវិញ្ញាតំ** ជានិបាតប្រាប់សេចក្ដីផ្សេង ៗ ។

បទថា **អវិញ្ញាតំ** គឺធម៌ណា ៗ ដែលព្រះតថាគតទ្រង់មិនដឹងហើយក្នុងអតីតកាល ។ ចុះបាឋៈថា **នាហោសិ** ទៅ ។ ក្នុងការកាន់យក **អត្ថិ** សព្ទ ជាអព្យយសព្ទ សូម្បីចុះបាឋៈទៅក៏ប្រើបាន ។ ដោយបទនេះ ព្រះសារីបុត្តត្ថេរសម្ដែងសេចក្ដីដែលព្រះតថាគតទ្រង់ដឹងធម៌ទាំងពួង ដែលជាអតីតកាល ។

បទថា **អជានិតព្វំ** ធម៌ដែលមិនគួរដឹង គឺ ធម៌ដែលមិនគួរដឹង ដែលជាអនាគតកាលនឹងមិនមាន ឬមិនមាន ។ ដោយបទនេះ ព្រះសារីបុត្តត្ថេរសម្ដែង សេចក្ដីដែលព្រះតថាគតទ្រង់



ដឹងធម៌ទាំងពួង ដែលជាអនាគតកាល ។ **អ** អក្សរ ក្នុងបទនេះ ត្រឹមតែជាកិរិយាវិសេសនរបស់ **ជានន** គឺ ការដឹង ។

គប្បីជ្រាបសេចក្ដីក្នុងបទនេះថា **សព្វំ អភិញ្ញាសិ យទត្ថិ នេយ្យំ** ព្រះតថាគតទ្រង់ជ្រាបដ៏ក្រៃលែងនូវធម៌ ជាគ្រឿងនាំទៅទាំងពួង ដូចតទៅនេះ ។ ព្រះតថាគតទ្រង់ជ្រាបដ៏ក្រៃលែង គឺ ទ្រង់ដឹង ទ្រង់ចាក់ធ្លុះធម៌ទាំងពួងជាគ្រឿងនាំទៅ គឺ ការដឹងក្នុងកាលទាំង ៣ ឬផុតចាកកាល ដោយព្រះសព្វញ្ញុតញ្ញាណដ៏ក្រៃលែង ។

ការកាន់យក ៣ កាល និងផុតចាកកាល ដោយ **អត្ថិ** សព្ទ ក្នុងបទនេះ ។ គប្បីជ្រាបថា **អត្ថិ** ជាអព្យយសព្ទ ។

បទថា **តថាគតោ តេន សមន្តចក្ខុ** ដោយហេតុនោះ ព្រះតថាគត ទើបជាព្រះសមន្តចក្ខុ សេចក្ដីថា ឈ្មោះថា **សមន្តចក្ខុ** ព្រោះមានញាណចក្ខុប្រព្រឹត្តទៅហើយដោយជុំវិញ គឺ ដោយប្រការទាំងពួង ព្រោះមិនមានគ្រឿងបិទបាំងដោយ កាល និងដោយឱកាស ។ ដោយហេតុ តាមដែលពោលហើយនោះ ព្រះតថាគតទើបជាព្រះសមន្តចក្ខុ ។ លោកអធិប្បាយថា ជា

ព្រះសព្វញ្ញូ ។ ដោយបុគ្គលាធិដ្ឋាន ទេសនានៃគាថានេះ ទើបសម្រេចជាព្រះសព្វញ្ញុតញ្ញាណ ។

ព្រះសារីបុត្តត្ថេរ បំណាងនឹងសម្ដែងព្រះសព្វញ្ញុតញ្ញាណ ដោយវិស័យនៃព្រះពុទ្ធញ្ញាណ ទើបពោលបទមានជាអាទិ៍ថា **សមន្តចក្ខូតិ កេនដ្ឋេន សមន្តចក្ខុ** បទថា **សមន្តចក្ខុ** សេចក្ដីថា ឈ្មោះថា **សមន្តចក្ខុ** ព្រោះអត្ថថាដូចម្ដេច ? សេចក្ដីនៃគាថា ក្នុងបទនោះថា ឈ្មោះថា **សមន្តចក្ខុ** ក្នុងបទដែលលោកពោលថា **សមន្តចក្ខុ** ព្រោះអត្ថថាដូចម្ដេច ? ព្រះសារីបុត្តត្ថេរ ពោលអត្ថនៃបទនោះ ដោយបទមានជាអាទិ៍ថា **យាវតា ទុក្ខស្ស ទុក្ខដ្ឋោ** ឈ្មោះថា សព្វញ្ញុតញ្ញាណ ព្រោះអត្ថថា មានសភាពអត់ទ្រាំបានលំបាកនៃទុក្ខ ។ ពិតណាស់ សមន្តចក្ខុ គឺ ព្រះសព្វញ្ញុតញ្ញាណ ។ សមដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ព្រះសព្វញ្ញុតញ្ញាណ ហៅថា សមន្តចក្ខុ ។ កាលពោលដល់អត្ថនៃព្រះសព្វញ្ញុតញ្ញាណនោះ ជាការពោលដល់អត្ថនៃសមន្តចក្ខុនោះឯង ។ ញាណរបស់ព្រះពុទ្ធជាម្ចាស់នោះឯង ឈ្មោះថា ពុទ្ធញ្ញាណ ។



សូម្បីបទមានជាអាទិ៍ថា **ទុក្ខេ ញាណំ** ញាណក្នុងទុក្ខក៏រមែងប្រព្រឹត្តទៅចំពោះព្រះមានព្រះភាគ ដោយអាការទាំងពួង , ប្រព្រឹត្តទៅដល់សាវកត្រឹមតែឯកទេសប៉ុណ្ណោះ ។ មយ៉ាងទៀត បទថា **សាវកសាធារណានិ** ទូទៅដល់ព្រះសាវក លោកពោលសំដៅដល់ការមានសូម្បីដោយឯកទេស គឺ ចំណែកខ្លះ ។

បទថា **សព្វោ ញាតោ** គឺ ព្រះមានព្រះភាគទ្រង់ជ្រាបទាំងអស់ដោយព្រះញាណ ។ ព្រះសារីបុត្តត្ថេរធ្វើឲ្យច្បាស់ដោយបដិសេធអត្ថដែលលោកពោលថា **អញ្ញាតោ ទុក្ខដ្ឋោ នត្ថិ** សភាពនៃទុក្ខ ដែលព្រះមានព្រះភាគជាម្ចាស់ទ្រង់មិនបានជ្រាប មិនមាន ។

បទថា **សព្វោ ទិដ្ឋោ** ទ្រង់ឃើញទាំងអស់ហើយ គឺ មិនមែនត្រឹមតែទ្រង់ដឹងម្យ៉ាងប៉ុណ្ណោះ ។ ដែលពិតទ្រង់ធ្វើដូចដឹងដោយចក្ខុទៀតផង ។

បទថា **សព្វោ វិទិតោ** ទ្រង់ដឹងច្បាស់ទាំងអស់ គឺ មិនមែនទ្រង់ឃើញត្រឹមតែម្យ៉ាងប៉ុណ្ណោះ ។ ដែលពិតទ្រង់ធ្វើឲ្យប្រាកដទៀតផង ។

បទថា **សព្វោ សច្ឆិកតោ** ទ្រង់ធ្វើឲ្យជាក់ច្បាស់ទាំងអស់

ហើយ គឺ មិនមែនត្រឹមតែទ្រង់ដឹងច្បាស់ប៉ុណ្ណោះ ។ ដែលពិត ទ្រង់ធ្វើឲ្យប្រចក្ស ដោយការបានព្រះញាណក្នុង ញាណនោះទៀត ផង ។

បទថា **សព្វា ផស្សិតោ** ទ្រង់ពាល់ត្រូវហើយ ទាំងអស់ គឺ ទ្រង់មិនបានធ្វើឲ្យច្បាស់តែម្យ៉ាងប៉ុណ្ណោះ ។ សេចក្តី ពិត ទ្រង់ពាល់ត្រូវ ដោយអំណាចទ្រង់ប្រព្រឹត្តដោយប្រពៃរឿយ ៗ ។

ម្យ៉ាងទៀត បទថា **ញាតោ** គឺ ទ្រង់ដឹងដល់ លក្ខណៈ របស់សភាវៈ ។

បទថា **ទិដ្ឋា** ទ្រង់ឃើញដល់សាមញ្ញលក្ខណៈ ។ បទថា **វិទិតោ** ទ្រង់ដឹងច្បាស់ដល់រស ។ បទថា **សច្ឆិកតោ** ទ្រង់ធ្វើឲ្យជាក់ច្បាស់ដល់អាការប្រាកដ ។ បទថា **ផស្សិតោ** ទ្រង់ពាល់ត្រូវ ដល់ហេតុជិត ។

ម្យ៉ាងវិញទៀត បទថា **ញាតោ** ទ្រង់ដឹង ដោយការកើត ឡើងនៃញាណ ។

បទថា **ទិដ្ឋា** ទ្រង់ឃើញ ដោយការកើតឡើងនៃចក្ខុ ។

បទថា **វិទិតោ** ទ្រង់ដឹងច្បាស់ ដោយការកើតឡើងនៃ បញ្ញា ។



បទថា **សច្ឆិកតោ** ទ្រង់ធ្វើឲ្យជាក់ច្បាស់ ដោយការកើត ឡើងនៃវិជ្ជា ។

បទថា **ផស្សិតោ** ទ្រង់ពាល់ត្រូវ ដោយការកើតឡើងនៃ ពន្លឺ ។

គប្បីជ្រាបសេចក្តីពិស្តារ ដោយន័យមានជាអាទិ៍ថា សភាព ដែលទ្រាំបានលំបាកនៃទុក្ខ ។ ទ្រង់ឃើញទាំងអស់ , សភាព ដែលអត់ធន់បានលំបាក ទ្រង់មិនបានឃើញមិនមាន និងដោយ ន័យមានជាអាទិ៍ថា ដែលត្រាច់ស្វែងរកដោយចិត្ត នៃលោកព្រម ទាំងទេវលោក ។ល។ ទ្រង់ជ្រាបទាំងអស់ហើយ ដែលមិនជ្រាប មិនមាន ។ លោកពោលគាថាទៀត ដោយសរុបគាថា ដែល ពោលទុកគ្រាដំបូង កាលសរុបគាថានោះហើយ ក៏ជាការសរុប ញាណផង ។

ចប់ អដ្ឋកថាសព្វញ្ញុតញ្ញាណនិទ្ទេស

អដ្ឋកថា ញាណកថា

អដ្ឋកថាបដិសម្ភិទាមគ្គ ឈ្មោះថាសទ្ធម្មបកាសិនី

# ប្រជុំកខធម៌

## ក្នុងគម្ពីរអដ្ឋកថាបដិសម្ភិទាមគ្គ


| ឈ្មោះធម៌ | ពួក | ទំព័រ |
|---|---|---|
| កាម | ២ | ១៨៩ |
| និព្វានធាតុ | ២ | ២៦៦ |
| សច្ចញ្ញាណ មាន | ២ | ៤៣៥ |
| សំវដ្តកប្ប មាន | ៣ | ៣៨៥ |
| ពុទ្ធខេត្ត | ៣ | ៣៨៥ |
| នាមព្រះពោធិសត្វ | ៣ | ៣៩៨ |
| ឧបាទាន | ៤ | ៥២២ |
| បដិបទា | ៤ | ១៩៨ |
| អារម្មណ៍ ( ឈាន ) | ៤ | ១៩៩ |
| សង្គហវត្ថុ | ៤ | ២០០ |
| អរិយវង្ស | ៤ | ២០០ |
| ចក្រ | ៤ | ២០១ |
| ធម្មបទ | ៤ | ២០៣ |
| នាម | ៤ | ២២០ |
| អប្បនាសមាធិពួក | ៤ | ២៣៤ |
| អ្នកចូលនិរោធ ធ្វើកិច្ច | ៤ | ២៥៦ |
| សម្បជញ្ញៈ | ៤ | ២៦៤ |
| មគ្គញ្ញាណធ្វើកិច្ច | ៤ | ២៩១ |
| អសង្ខេយ្យ | ៤ | ៣៨៤ |





| ឈ្មោះធម៌ | ពួក | ទំព័រ |
|---|---|---|
| សោធាតុវិសុទ្ធិញ្ញាណប្រព្រឹត្តទៅក្នុងអារ. | ៤ | ៤២៦ |
| ទិព្វចក្ខុញ្ញាណប្រព្រឹត្តទៅក្នុងអារម្មណ៍ | ៤ | ៤២៦ |
| ពន្លឺ | ៤ | ៤៤១ |
| វិមុត្តិ | ៥ | ២៧១ |
| យថាកម្មូបគញ្ញាណរពរពឹត្តទៅក្នុងអារ. | ៥ | ៤២៦ |
| ពួកតណ្ហា | ៦ | ៥៣១ |
| ទិដ្ឋិ | ៦ | ៥៣២ |
| ឥទ្ធិវិធញ្ញាណប្រព្រឹត្តទៅក្នុងអារម្មណ៍ | ៧ | ៤២៦ |
| កូនសរ | ៧ | ៥០០ |
| សំយោជនៈ | ៧ | ៥៣៧ |
| មានះ | ៧ | ៥៣៨ |
| ភង្គានុបស្សនាញាណមានអានិសង្ស | ៨ | ៩៦ |
| ចេតោបរិយញ្ញាណប្រព្រឹត្តទៅក្នុង | ៨ | ៤២៦ |
| បុព្វេនិវាសនានុស្សតិញ្ញាណប្រព្រឹត្តទៅ | ៨ | ៤២៦ |
| បុរសទោស | ៨ | ៥៤០ |
| អាឃាតវត្ថុ | ៩ | ៥៤៦ |
| អាឃាតវត្ថុ (ន័យម្យ៉ាងទៀត) | ៩ | ៥៤៨ |
| អសុភៈ | ១០ | ២០៤ |
| កិលេស | ១០ | ៤៤១ |
| មិច្ឆាទិដ្ឋិ | ១០ | ៥៥៦ |
| កាមាវចរ | ១១ | ១៩០ |
| បច្ចយាការ | ១២ | ៣៣ |

| ឈ្មោះធម៌ | ពួក | ទំព័រ |
|---|---|---|
| ឱទ្បារិករូប | ១២ | ៥០ |
| ហ្វឹកហាត់ចិត្តដោយអាការ | ១៤ | ៣២០ |
| រូបព្រហ្ម | ១៦ | ១៤ |
| អហេតុកចិត្ត | ១៨ | ១៧៨ |
| សមាធិ | ២៥ | ២២ |
| ទិដ្ឋិ | ៦២ | ៥៦២ |
| តណ្ហា | ១០៨ | ៥៦០ |



## នាមសប្បុរស បូជាធម្មទាន

| | |
|---|---|
| ឧបាសិកា ពូ ហ៊ាង ............................................ | 80 $ U.S.A |
| ឧបាសក ជា ស៊ីបាន ........................................... | 50 $ U.S.A |
| ឧបាសក ហាម សារ៉េន ប្រធានអាស្រមទួលត្នោតជុំ .. | 50 $ U.S.A |
| ឧបាសិកា ម៉ម សុខហេង .................................... | 30 $ U.S.A |
| ឧបាសិកា ថាប់ លឿម .................................. | 20 $ U.S.A |
| ឧបាសក ថន វាសនា ប្រធានកម្មវិធីកល្យាណមិត្ត .... | ៣០០.០០០ ៛ |
| ឧបាសក សោម រតនៈ និងភរិយា ព្រមទាំងបុត្ត ....... | ១០០.០០០ ៛ |
| លោក ហម ស៊ុនទ្បេង និងភរិយា ព្រមទាំងបុត្ត ....... | ៥០.០០០ ៛ |
| ឧបាសិកា ប៊ុត សុម៉ាលី និងបុត្រី........................... | ១០ ដុល្លា |
| ឧបាសិកា ថាប់ ទ្បឹង ........................................ | ៥ ដុល្លា |
| ឧបាសិកា យស់ សម្បត្តិ ................................... | ៥ ដុល្លា |
| ឧបាសក គុយ សុធន់ ឧបាសិកា ខាត់ កាន និងបុត្រ . | ៣០.០០០ ៛ |
| ឧបាសិកា ម៉ែន ថាប់ ...................................... | ២០.០០០ ៛ |
| ឧបាសិកា ប៊ុត សេដាដួង ................................ | ១៥.០០០ ៛ |
| ឧបាសិកា យិន យឹម ....................................... | ១៥.០០០ ៛ |
| ឧបាសិកា ........................................ | ១០.០០០ ៛ |
| ឧបាសិកា គង់ សាន់........................................ | ១០.០០០ ៛ |
| ឧបាសិកា គុយ សេងណា ............................... | ១០.០០០ ៛ |
| កញ្ញា ហ៊្គិច ហៀក ....................................... | ១០.០០០ ៛ |
| ឧបាសក តាំង ផល ភរិយានិងបុត្រ .................. | ១០.០០០ ៛ |
| លោកយាយ ឈួម .......................... | ៦.០០០ ៛ |
| ឧបាសិកា គួច សាវ៉ុន .......................... | ៥.០០០ ៛ |
| ឧបាសិកា រ៉ុន សោភ័ណ .......................... | ៥.០០០ ៛ |
| ឧបាសិកា យិន យឺន .......................... | ៥.០០០ ៛ |

| | | |
|---|---|---|
| ឧបាសិកា គី ពេញ | .................. | ៥.000 ៛ |
| ឧបាសិកា ភួង លីណា | .................. | ៥.000 ៛ |
| លោកយាយ យុន | .................. | ៥.000 ៛ |
| លោកយាយ វ៉ាន | .................. | ៥.000 ៛ |
| លោកយាយ ស៊ុំ ហេង | .................. | ៥.000 ៛ |
| ភិក្ខុ សួ ឈិន | ................................ | ៥.000 ៛ |
| ឧបាសិកា ខុន | ................................ | ៥.000 ៛ |
| ឧបាសិកា ឡៃ | ................................ | ៥.000 ៛ |
| ឧបាសិកា សត់ | ................................ | ៥.000 ៛ |
| ឧបាសិកា សោម យ៉ាន | ........................ | ៥.000 ៛ |
| លោកយាយ យូន | .............................. | ៣.000 ៛ |
| លោកយាយ ទុំ | ................................ | ២.000 ៛ |

## ភិក្ខុចិត្តរក្ខិត្តោ សំ សម្បត្តិ និងពុទ្ធបរិស័ទនៅប្រទេសអូស្ត្រាលី

| | |
|---|---|
| លោក រស់ ធារុន កូនស្រី ជេស មិន ..................... | 100 $ AUS |
| ឧបាសិកា ស សាន ......................................... | 100 $ AUS |
| ឧបាសិកា តាំង ពូជី ឧបាសិកា សៀក លី .............. | 100 $ AUS |
| ឧបាសក បុត ឡៅគីមងួន , ឧបាសិកា ដួង លី ........ | 100 $ AUS |
| ឧបាសក ឱ មុយ ឧបាសិកា តែ ចាន់ណារ៉ា ហៅ ឌឹង.. | 100 $ AUS |
| ឧបាសិកា ទៀន ស៊ីហ៊ុន .................................. | 100 $ AUS |
| ឧបាសក ទា អែតិច ឧបាសិកា ឡៅសែងម .......... | 100 $ AUS |
| ឧបាសក ភិន ហាច ឧបាសិកា ពេជ្រ សឿម .......... | 100 $ AUS |
| ឧបាសិកា  គិមស៊ីន ឧបាសិកា សំ ថានី ................. | 100 $ AUS |
| ឧបាសិកា ស៊ឹម គីមហេង .................................. | 0 $ AUS |
| ឧបាសិកា ស៊ូ ឃឹម ស៊ូ សៀងតិច ......................... | 50 $ AUS |



| | |
|---|---|
| ឧបាសក ថាំ ហ៊ូ ............................................. | 50 $ AUS |
| ឧបាសក យ៉ង សិន ឧបាសិកា នន់ ហេង ............... | 50 $ AUS |
| ឧបាសិកា សេង សៀងឈុន និងបុត្ត .................... | 50 $ AUS |
| ឧបាសិកា វ៉ាន់ យ៉ាណូរី និងបុត្ត ........................... | 50 $ AUS |
| ឧបាសិកាប៉ាង សុម ......................................... | 50 $ AUS |
| ឧបាសក ស៊ុន សាន ឧបាសិកា សម្បត្តិ គង់ .......... | 50 $ AUS |
| ឧបាសិកា ស៊ឹម គីមហេង និងកូនចៅ ................. | 50 $ AUS |
| យ៉ុង គិមសាន យ៉ុង ម៉ាលី ............................... | 50 $ AUS |
| ឧបាសិកា ចំរើន រ៉ាក់ជិត ................................ | 50 $ AUS |
| ឧបាសិកា ផន ដារ៉ា លោកស្រី គ្រី ប្រសើរ លោកស្រី លី ធីមដៃ និងកូនស្រី . ............................................................... | 50 $ AUS |
| ឧបាសក គង់ ហ៊ល ឧបាសិកា គង់ ជា ................. | 50 $ AUS |
| លោក ស្រ៊ុន ហេង លោក តឹក ចាន់ដារ៉ា លោកស្រី រូថា សេង | 40 $ AUS |
| ឧបាសិកា ផោក វណ្ណា ................................... | 40 $ AUS |
| ឧបាសក ហៀក ម៉េងហួរ ឧបាសិកា ផ្លោក ម៉ុង .... | 40 $ AUS |
| ឧបាសក ណាំង លាងហុង ឧបាសិកា អង្គជុំ សុវណ្ណារ៉េត | 30 $ AUS |
| ឧបាសក សុខ យូ ឧបាសិកា សុខ ណារី ............... | 30 $ AUS |
| ឧបាសិកា លីវ ទូច ........................................ | 30 $ AUS |
| លោកយាយ ញឹប ......................................... | 30 $ AUS |
| ចឿក ផន .................................................... | 30 $ AUS |
| តែ យក់ហ៊ុន ............................................... | 30 $ AUS |
| ឧបាសិកា ជួន រ៉េន ......................................... | 30 $ AUS |
| ឧបាសក តូ សារ៉ឿន ឧបាសក មាន សុវត្ថិ ............. | 30 $ AUS |
| ឧបាសក រស់ សារ៉េន ឧបាសិកា គង់ សារឿន ........ | 30 $ AUS |
| ឧបាសក ឡុង ហួន និងគ្រួសារ .......................... | 30 $ AUS |

| | |
|---|---|
| ឧបាសិកា វ៉ាន់ យ៉ាណូរ៉េត និងបុត្ត ...................... | 30 $ AUS |
| ឧបាសក ធម្មសារី សេក ឈុន ........................... | 20 $ AUS |
| ឧបាសក ពុធ ប៉េងណេង ឧបាសិកា ហ៊ុន ស៊ីវអៀង និងកូនចៅ | 20 $ AUS |
| ឧបាសិកា លឹម យ៉ាណូវ៉ាន់ និងបុត្ត ...................... | 20 $ AUS |
| ឧបាសក នួន សុឆេង ....................................... | 20 $ AUS |
| ឧបាសក ហួត វ៉ា ហែម ឃឿន ........................... | 20 $ AUS |
| ឧបាសក សំហៃឡេង ឧបាសិកា ស៊ុត ផល្លីន ............ | 20 $ AUS |
| ឧបាសិកា នួន គុង ............................................ | 20 $ AUS |
| ឧបាសិកា ដា្ង ចេង ............................................ | 20 $ AUS |
| ឧបាសិកាយ៉ា យ៉ុម និងស្វាមី ............................... | 20 $ AUS |
| ឧបាសិកា សាត់ ឡាយ ....................................... | 20 $ AUS |
| ឧបាសិកា ម៉េង សំបូរ ....................................... | 20 $ AUS |
| ឧបាសិកា សៅ សុឃឿន .................................... | 20 $ AUS |
| ឧបាសិកា ស៊ីង គិមព្រូ , ទូច ស៊ីថា និងបុត្ត ............ | 20 $ AUS |
| ឧបាសិកា កាំង ជូ ........................................... | 20 $ AUS |
| ឧបាសិកា ហឿ  សិទ្ធ , គិត យ៉ុាំ ........................ | 20 $ AUS |
| ឧបាសិកា ជីវ អេង ......................................... | 20 $ AUS |
| ឧបាសិកា មុយ ហួរម៉ា ..................................... | 20 $ AUS |
| ឧបាសិកា មាឃ សូផាន .................................... | 20 $ AUS |
| ឧបាសិកា លឹម យូឃាង និងគ្រួសារ .................... | 20 $ AUS |
| ឧបាសក សុខ ជួន ឧបាសិកា មាស ឃឿន ............ | 20 $ AUS |
| ឧបាសិកា ឡាយ លាង ..................................... | 20 $ AUS |
| ឧបាសិកា អៀ ភិចណៃ .................................... | 20 $ AUS |
| ឧបាសក RAKHA LEAS ............................... | 10 $ AUS |
| ប៉ាន់ យ៉ា , វិលាម ភិត , វី ជាឡេង .................... | 10 $ AUS |



| | |
|---|---|
| គុយ ថ ........................................................ | 10 $ AUS |
| សៅ លីម ...................................................... | 10 $ AUS |
| ឧបាសិកា អឹប គីមឡាយ ................................ | 10 $ AUS |
| ឧបាសក ទូត ភាង ឧបាសិកា ចៅ ចន្ថា ............... | 5 $ AUS |
| ចៅ សារិ ...................................................... | 5 $ AUS |

**ពុទ្ធបរិស័ទអូស្ត្រាលី តាមរយៈ ព្រះអគ្គទិន្ននោ ភិក្ខុ នៅ បូ៉រ៉ា**

| | |
|---|---|
| លោក ជុង ឡេង និងអ្នកស្រី ......................... | 100 $ AUS |
| ឧបាសក សេង លី ឧបាសិកា ចាន់ ផល្លា ............ | 100 $ AUS |
| ឧបាសក នូ សុវ៉ារុំធ និងភរិយា ........................ | 50 $ AUS |
| ឧបាសក រិន គ្រេត និងភរិយា ........................ | 50 $ AUS |
| ឧបាសក លឹម ហុងលី ឧបាសិកា តេង គី ........... | 50 $ AUS |
| ឧបាសក ង៉ូវ ឈីវ ឧបាសិកា ហេង ពាស៊ីម និងបុត្ត ៤ នាក់ | 50 $ AUS |
| ឧបាសក ទូត សឿប ឧបាសិកា សល់ កែវ............ | 50 $ AUS |
| ឧបាសក សឹម តាជួន .................................... | 20 $ AUS |
| ឧបាសក ជួន យ៉ារ៉ែន ឧបាសិកា អ៊ុន ផល្លី ............ | 20 $ AUS |
| ឧបាសក ភុន ញ៉ាន ....................................... | 20 $ AUS |
| លោក SO KON និងអ្នកស្រី HUn ................ | 20 $ AUS |
| ឧបាសក ហ៊ាង ម៉ុន ..................................... | 20 $ AUS |
| លោក RRUN SRANN និងអ្នកស្រី RANY KAO | 20 $ AUS |
| លោក PHEAP KAO ................................ | 10 $ AUS |
| លោក SOU SOPHON ............................ | 10 $ AUS |
| លោក THEAR ROS ................................ | 10 $ AUS |
| ឧបាសក ប៉ុន ដេត ឧបាសិកា ម៉ាច និងបុត្ត ........ | 10 $ AUS |
| លោក SOKEN និងអ្នកស្រី SEYLA ........... | 10 $ AUS |

| | |
|---|---|
| ឧបាសក ផៃ មន្ទីកៅ ................................ | 10 $ AUS |
| ឧបាសក ពៅ វ៉ាន់ទីន ................................ | 10 $ AUS |
| លោក Chouy Sannykao ......................... | 10 $ AUS |
| ឧបាសក ស៊ុន គិមឆេង ................................ | 10 $ AUS |
| លោក KIM YEE ..................................... | 5 $ AUS |
| ឧបាសក ឆាយ ឈួយលិម ហៅ មិត ឆិម .......... | 5 $ AUS |

**ពុទ្ធបរិស័ទវត្តត្រៃរតនារាម សហរដ្ឋអាមេរិក**
**តាមរយៈ ព្រះភិក្ខុ ធម្មត្ថេរោ សៅ ឃួន**
**ព្រះភិក្ខុធម្មប្បញ្ញោ វ៉ាន វឿន**

| | |
|---|---|
| ព្រះភិក្ខុ ធម្មត្ថេរោ សៅ ឃួន ............................ | 300 $ U.S.A |
| ព្រះភិក្ខុ កិត្តិកធម្មោ ប៊ូ សាំយ៉ុន .......................... | 50 $ U.S.A |
| ឧបាសិកា ទូន សឿយ ....................................... | 50 $ U.S.A |
| ឧបាសិកា ឈួន ផៃ .......................................... | 30 $ U.S.A |
| ឧបាសិកា ប្រាក់ យឿត ..................................... | 30 $ U.S.A |
| ឧបាសិកា អុក ណៃ .......................................... | 30 $ U.S.A |
| ឧបាសក អួន មិត្ត ឧបាសិកា នាក់ ប្រិម ................. | 25 $ U.S.A |
| ឧបាសិកា ចាប ឡាន ........................................ | 25 $ U.S.A |
| ឧបាសក សាន សុទ្ធ ឧបាសិកា យស់ សារី ................ | 20 $ U.S.A |
| លោកអាចារ្យ កង កាក់ ឧបាសិកា ទឹម សារី ............ | 20 $ U.S.A |
| ឧបាសិកា សរ គឹម ............................................ | 20 $ U.S.A |
| ឧបាសក លឹម សេងហ៊ួ ........................................ | 20 $ U.S.A |
| ឧបាសិកា កែវ ស៊ីណាត ...................................... | 20 $ U.S.A |
| ឧបាសក គាំ សាមុត ......................................... | 20 $ U.S.A |
| វ៉ា ស៊ីម៉ន ...................................................... | 20 $ U.S.A |



| | |
|---|---|
| អេម អែម និង អែល អ៊ុន ................................ | 20 $ U.S.A |
| ឧបាសក ឃុន ខេន .......................................... | 20 $ U.S.A |
| ឧបាសក ម៉ៅ សារី ឧបាសិកា ឯក ផេន និងបុត្ត ...... | 20 $ U.S.A |
| ឧបាសិកា អ៊ុំ សឿន ឧបាសិកា សែម អ៊ុំ ............... | 20 $ U.S.A |
| ផូ លាង និង សុខ ខេន .................................... | 20 $ U.S.A |
| នាង ឡាយ សុវណ្ណ ......................................... | 20 $ U.S.A |
| ឃុត នីកង ................................................... | 20 $ U.S.A |
| ទឹម សុជាតិ .................................................. | 20 $ U.S.A |
| ឧបាសិកា ជួប ប៉ាក់ ......................................... | 15 $ U.S.A |
| ជាស់ ស៊ីន ................................................... | 10 $ U.S.A |
| អ៊ីស ស៊ីន ................................................... | 10 $ U.S.A |
| សារុន ម៉ន .................................................... | 10 $ U.S.A |
| មឿង ម៉ៅ ..................................................... | 10 $ U.S.A |
| មាន ណាត .................................................... | 10 $ U.S.A |
| គិម លាងជា ................................................. | 10 $ U.S.A |
| វី យ៉ាត ...................................................... | 10 $ U.S.A |
| ឧបាសិកា ចិន ឈួន .......................................... | 10 $ U.S.A |
| គង់ថៃ ប៊ុនរឿង ............................................. | 10 $ U.S.A |
| ឧបាសិកា ឡឹក រេត ......................................... | 10 $ U.S.A |
| ព្រហ្ម សារិន ................................................ | 10 $ U.S.A |
| ព្រហ្ម វ៉ារុំធ ................................................ | 10 $ U.S.A |
| វ៉ារិត អួន .................................................. | 10 $ U.S.A |
| ឌីកូឡូ ជីរ៉ូខាយ ........................................... | 10 $ U.S.A |
| អាន ណាង ................................................. | 10 $ U.S.A |
| សយស ាម៉ុន និងបុត្ត ..................................... | 10 $ U.S.A |

| | |
|---|---|
| ចិន្តា អឿរ និង ចក់ ណាហួត ............................. | 10 $ U.S.A |
| សែង ឈឹម និង ហួត ចាន់ទួន ............................ | 10 $ U.S.A |
| ហួត ចាន់ណាត និង ឈឿង សុភាព .................... | 10 $ U.S.A |
| វ៉ែន ឡៃ ........................................................ | 10 $ U.S.A |
| ទឹម ស៊ីនួន ..................................................... | 10 $ U.S.A |
| ឈី ជិម ..................................................... | 10 $ U.S.A |
| ឡេង ដា ...................................................... | 10 $ U.S.A |
| ឱ ណាញ៉ឹប ...................................................... | 10 $ U.S.A |
| ញ៉ឹប ហុង ..................................................... | 10 $ U.S.A |
| នី សាញ៉ឹប .................................................... | 10 $ U.S.A |
| ឧបាសិកា ញ៉ឹប ទាង ......................................... | 10 $ U.S.A |
| ឧបាសិកា អ៊ឹម លឹម ........................................ | 10 $ U.S.A |
| ឧបាសិកា ខាត់ សំអឿន ..................................... | 10 $ U.S.A |
| ម៉ៅ ចំបើង .................................................... | 10 $ U.S.A |
| ម៉ៅ វ៉ាត .................................................... | 10 $ U.S.A |
| ម៉ៅ កំសត់ ................................................... | 10 $ U.S.A |
| ម៉ៅ កំសាន្ត ................................................... | 10 $ U.S.A |
| ម៉ៅ សុខា ................................................... | 10 $ U.S.A |
| ម៉ៅ គឹមសុង .................................................. | 10 $ U.S.A |
| លោកយាយ ភួង សឿន ..................................... | 5 $ U.S.A |
| សែម ម៉ីញ៉ឹប ............................................. | 5 $ U.S.A |
| ឧបាសិកា មឿង ញ៉ិល ........................................ | 5 $ U.S.A |
| គឹម ស៊ា ............................................. | 5 $ U.S.A |